



# សេចក្តីក្លាហានគ្មានព្រំដែន

## អ្នកការពារសិទ្ធិមនុស្សដែលកំពុងផ្លាស់ប្តូរពិភពលោករបស់យើង








ស្រង់ពីសៀវភៅនិពន្ធដោយ លោកស្រី ឃែរី ខិណ្ណិឌី។ រូបភាពថតដោយ លោក អេតឌី អាដាំស៍ ។ មានការសម្តែង សេចក្តីក្លាហានគ្មានព្រំដែន៖ សម្លេងចេញពីទីងងឹត និពន្ធដោយ លោក អារៀល ដ័ហ្វមែន។ សហការណ៍រវាង មជ្ឈមណ្ឌល រ៉ូបឺត អ៊ែហ្វ ខិណ្ណិឌី ដើម្បីយុត្តិធម៌ និង សិទ្ធិមនុស្ស ជាមួយដៃគូនៅកម្ពុជា ស៊ីវីកហ្គ័ស៖ មជ្ឈមណ្ឌលអប់រំដើម្បីពលរដ្ឋខ្មែរ។

ROBERT F. KENNEDY
CENTER FOR JUSTICE & HUMAN RIGHTS

CIVICUS

“អ្វីៗដែលយើងបិទភ្នែកធ្វើមិនឃើញ, អ្វីៗដែលយើងរត់គេចចេញចោល, អ្វីៗដែលយើងបដិសេធបន្ទុះបង្អាប់ ឬ ស្អប់ ធ្វើឲ្យយើងចាញ់នៅពេលចុងបញ្ចប់។ អ្វីដែលមើលទៅស្មោគគ្រោគ, ឈឺចាប់, ទុច្ចរិត អាចក្លាយជាប្រភពនៃសោភ័ណភាព, ការរីករាយ និង ភាពរឹងប៉ឹង ប្រសិនបើបើកចិត្តឲ្យទូលាយ”។ លោកស្រី រីហ្គូបឺតា ម៉ែនជូ RIGOBERTA MENCHU. “អាវុធដែលមានកម្លាំងបំផុត នៅក្នុងដៃរបស់អ្នកជិះជាន់ គឺជា ចិត្តគំនិតរបស់អ្នកដែលគេជិះជាន់”។ លោក ស្ទីវ ប៊ីកូ STEVE BIKO. “សន្តិភាព, នៅក្នុងន័យថាភាពគ្មានសង្គ្រាម, គឺ មានតម្លៃតិចតួច ចំពោះមនុស្សណា ដែលនឹងជិតស្លាប់ ដោយសារ ភាពអត់ឃ្លានឬភាពត្រជាក់ខ្លាំង។ សន្តិភាពបែបនេះ នឹងមិនដកចេញនូវ ភាពឈឺចុកចាប់ដោយសារទារុណកម្ម ដែលបានដាក់ទោសទៅលើអ្នកជាប់ទោសមនសិការម្នាក់។ សន្តិភាពដែលមានភាពយូរអង្វែង មាននៅទីកន្លែងណា ដែលត្រូវបានគេគោរពសិទ្ធិមនុស្ស, មាននៅទីកន្លែងណា ដែលមនុស្សមានអាហារបរិភោគគ្រប់គ្រាន់, និង មាននៅទីកន្លែងណា ដែលបុគ្គលម្នាក់ៗនិងប្រជាជាតិ មានសេរីភាពពេញលេញ”។ ព្រះតេជគុណ ដាឡៃ ឡាម៉ា DALAI LAMA. “ប្រសិនបើ អ្នកមានភាពអព្យាក្រឹត នៅក្នុងស្ថានភាពអយុត្តិធម៌, ជាក់ស្តែង អ្នកបានជ្រើសរើសយកភាគីនៃអ្នកជិះជាន់។ ប្រសិនបើ ដំរីយកជើងជាន់លើកន្ទុយកណ្តុរ ហើយអ្នកនិយាយថា អ្នកមានអព្យាក្រឹត, កណ្តុរនឹងមិនអបអរសាទរចំពោះភាពអព្យាក្រឹតរបស់អ្នកទេ”។ លោក ដែសមិន ធូធូ DESMOND TUTU. “ខ្ញុំគិតក្នុងខ្លួនខ្ញុំថា តើខ្ញុំកំពុងធ្វើអ្វី?’ ខ្ញុំមិនទទួលនូវអ្វីៗ សម្រាប់ខ្លួនខ្ញុំទេ ហើយខ្ញុំទំនងជាមិនអាចធ្វើអ្វីៗ ដើម្បីបន្ធូរបន្ថយការឈឺចាប់បានទេ...។ ស្របពេលជាមួយគ្នានោះដែរ ប្រសិនបើ ខ្ញុំបែរខ្នង ហើយដើរចេញពីបញ្ហា វានឹងមិនមាននរណាម្នាក់ ជួយដោះស្រាយបញ្ហា”។ លោក កា ហ្សា វ៉ា KA HSAW WA. “វាកើតមកពីសកម្មភាពផ្សេងៗ ដែលរាប់មិនបាន នៃសេចក្តីក្លាហាន និង សេចក្តីជឿជាក់ ដែលប្រវត្តិសាស្ត្ររបស់មនុស្ស ត្រូវបានផ្លាស់ប្តូររូបរាង។ រាល់ពេលដែលមនុស្សម្នាក់ ប្រកាន់ឧត្តមគតិខ្ជាប់ខ្ជួន, ឬ ធ្វើឲ្យជីវភាពរបស់អ្នកដទៃមានភាពប្រសើរឡើង, ឬ ប្រឈមមុខនឹងអំពើអយុត្តិធម៌, ពេលនោះ គាត់បង្កើតរលកមួយ នៃក្តីសង្ឃឹម។ ហើយរលកនីមួយៗ ឆ្លងកាត់គ្នាទៅវិញទៅមក ពីមណ្ឌលថាមពលនិងសេចក្តីក្លាហាន ផ្សេងៗរាប់លានកន្លែង, រលកទាំងអស់នោះ បង្កើតចរន្តទឹកមួយ ដែលអាចធ្វើឲ្យរលំជញ្ជាំងមហារឹងមាំ នៃភាពសង្កត់សង្កិន និង ភាពជំទាស់”។ លោក រ៉ូប៊ឺត អ៊ែហ្វ ខិណ្ណិឌី ROBERT F. KENNEDY.

# សេចក្ដីក្លាហាន
# គ្មានព្រំដែន

អ្នកការពារសិទ្ធិមនុស្សដែលកំពុងផ្លាស់ប្ដូរពិភពលោករបស់យើង

CIVICUS

THE CHARITABLE FOUNDATION

ROBERT F. KENNEDY
CENTER FOR JUSTICE & HUMAN RIGHTS

# មាតិកា


គម្រោង *សេចក្តីក្លាហានគ្មានព្រំដែន* ៦

លោកស្រី ឃែរី ខិណ្ណិឌី (Kerry Kennedy) ៧

មជ្ឈមណ្ឌល រ៉ូបឺត អេហ្វ ខិណ្ណិឌី និង ស៊ីវីកហ្គសកម្ពុជា ៩

អ្នកនាង សេង ធារី (Theary C. SENG) ១០

អំពីកម្មវិធីសិក្សានេះ ១៣

ព័ត៌មានសម្រាប់គ្រូបង្រៀន ១៣

កាលប្រវត្តិវិជ្ជានៃសិទ្ធិមនុស្ស ១៨

តើសិទ្ធិមនុស្សគឺជាអ្វី? ១៩

សកបរិវត្តន៍សង្ខេប នៃ *សេចក្តីប្រកាសជាសកល ស្តីពីសិទ្ធិមនុស្ស* ២០

*សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស* សកបរិវត្តន៍សាមញ្ញ (Simplified Version) ២១

ប្រវត្តិសង្ខេបនៃសិទ្ធិមនុស្ស ២៥

ក្លាយជាអ្នកការពារ ៣០

អ៊ីលី វីសែល Elie Wiesel, ប្រទេសរ៉ូម៉ានី អំពើប្រល័យពូជសាសន៍ ៣៤

ម៉ារីណា ពីសក្លាកូវ៉ា Marina Pisklakova, ប្រទេសរុស្ស៊ី អំពើហិង្សាក្នុងគ្រួសារ ៤៤

ជូលីអាណា ដកបាតហ្ស៊ី Juliana Dogbadzi, ប្រទេសហ្គាណា ភាពជាទាសករ / ការជួញដូរមនុស្ស ៥៣

វ៉ាក្លាវ ហាវែល Vaclav Havel, ប្រទេសឆែកសាធារណៈ សេរីភាពក្នុងការបញ្ចេញមតិ ៦១

ម៉ូហាមែត យូណេស Muhammad Yunus, ប្រទេសបង់ក្លាដែស សិទ្ធិឥណទាន / ការប្រឆាំងនឹងភាពក្រីក្រ ៦៨

ដេសមុន ធូធូ Desmond Tutu, ប្រទេសអាហ្វ្រិកខាងត្បូង ការបង្រួបបង្រួម ៧៨

កា ហ្សា វ៉ា Ka Hsaw Wa, ប្រទេសភូមា ការទទួលខុសត្រូវសង្គមនៃក្រុមហ៊ុន ៨៧

កៃឡាស់ សាទីអាទី Kailash Satyarthi, ប្រទេសឥណ្ឌា កម្លាំងពលកម្មកុមារ ៩៥

អំពីរឿងសម្តែង សេចក្តីក្លាហានគ្មានព្រំដែន៖ *សម្លេងចេញពីទីងងឹត* ១០៣

សម្រង់ពីលិខិតុបករណ៍អន្តរជាតិសិទ្ធិមនុស្ស ១៣៣

សទ្ទានុក្រមពាក្យ / វាក្យស័ព្ទ (Glossary of Terms) ១៣៨

សេចក្តីថ្លែងអំណរគុណ ១៤២

ប្រតិកិរិយា / ទម្រង់ព័ត៌មានត្រលប់ (Feedback) ១៤៦

# គម្រោង សេចក្តីក្លាហានគ្មានព្រំដែន (Speak Truth To Power)

សេចក្តីក្លាហានគ្មានព្រំដែន ដែលជាគម្រោងរៀបចំដោយ មជ្ឈមណ្ឌល រ៉ូប៊ឺត អ៊ែហ្វ ខិណ្ណិឌី ដើម្បីយុត្តិធម៌ និង សិទ្ធិមនុស្ស *(Robert F. Kennedy Center for Justice and Human Rights)* ជាគំនិតផ្តួចផ្តើមសាកលដ៏ច្រើនផ្នែក ដែលភ្ជាប់ទៅនឹងបទពិសោធន៍របស់ បណ្តាអ្នកការពារសិទ្ធិមនុស្ស ដ៏ក្លាហានមួយចំនួននៅជុំវិញពិភពលោក ដើម្បីអប់រំសិស្សនិស្សិត និង អ្នកដទៃទៀត អំពីសិទ្ធិមនុស្ស, ព្រមទាំងជម្រុញដល់ពួកគាត់ឲ្យចាត់ធ្វើសកម្មភាព។ ប្រធានបទ មានតាំងពីករណី ទាសភាព និង ការតស៊ូការពារបរិស្ថាន រហូតទៅដល់ សិទ្ធិស្វ័យសម្រេចផ្ទាល់ខ្លួនចំពោះរឿងសាសនា (religious self-determination) និង សិទ្ធិនយោបាយសព្វបែបយ៉ាង។

គម្រោង សេចក្តីក្លាហានគ្មានព្រំដែន បានផ្តើមឡើងពីសៀវភៅមួយក្បាល និពន្ធដោយ លោកស្រី ឃែរី ខិណ្ណិឌី (Kerry Kennedy) (ដែលត្រូវបានបកប្រែជា ៦ភាសារួចហើយ, ហើយនឹងមានបន្តបកប្រែទៅជាច្រើន ភាសាថែមទៀត), ក្រោយមកគម្រោងនេះត្រូវបានប្រែសម្រួលទៅជា ផលិតកម្មសម្តែង នាដកម្មមួយដោយ លោក អារៀល ដ័ហ្វមែន (Ariel Dorfman)។ រូបថតរបស់ អ្នកការពារសិទ្ធិមនុស្ស ដែលថតដោយ អ្នកថតរូប ដ៏ឆ្នើមម្នាក់ ដែលបានទទួលរង្វាន់ ភូលីតហ្សឺ (Pulitzer Prize) ឈ្មោះលោក អេតឌី អាដាំស៍ (Eddie Adams) ដែលមានបង្ហាញក្នុងសៀវភៅនេះ ត្រូវបានតាំងជាពិព័រណ៍រូបថត នៅជាង២០ទីក្រុងរបស់សហរដ្ឋអាមេរិក ក្រោយពីការចាប់ផ្តើមតាំងជាពិព័រណ៍ផ្លូវការ នៅវិចិត្រសាលខកកូរ៉ាន (Corcoran Gallery of Art) ក្នុងក្រុង វ៉ាស៊ីនតោនឌីស៊ី (Washington, D.C.) រួចមក។ បច្ចុប្បន្ននេះ រូបថតទាំងនោះ ត្រូវបានគេតាំងពិព័រណ៍ នៅលើទ្វីបទាំងបួន នៃសកលលោក។

គម្រោង សេចក្តីក្លាហានគ្មានព្រំដែន ត្រូវបានចែកជូនដល់សិស្សនិស្សិត នៅទ្វីបអាមេរិក, អឺរ៉ុប និង អាហ្វ្រិក ជាច្រើនសែននាក់។ កម្មវិធីសិក្សាអប់រំនេះ បានទទួលការចាប់អារម្មណ៍ខ្លាំងឡើងៗ នៅលើផ្ទៃអន្តរជាតិ ហើយក៏បានបើកឱកាសឲ្យមានការចាប់ដៃគូថ្មីៗទៀត ជាមួយអ្នកផ្តល់ជំនួយ, រដ្ឋាភិបាលផ្សេងៗ និង សហជីពគ្រូបង្រៀន នៅសហរដ្ឋអាមេរិកជាដើម។ ប្រទេសគំរូមួយ ដែលបានផ្តួចផ្តើមការអប់រំនេះ គឺប្រទេសអ៊ីតាលី ដែលផ្តល់ការបង្រៀន១២សប្តាហ៍ ដល់សិស្សនិស្សិត ២៥០,០០០នាក់។ កម្មវិធីអប់រំសិទ្ធិមនុស្សនេះ ក៏បានបង្រៀននៅ ប្រទេសអាហ្វ្រិកខាងត្បូង និង រូម៉ានី ដែរ។

ផលិតកម្មសម្តែងនាដកម្ម សេចក្តីក្លាហានគ្មានព្រំដែន៖ សម្លេងចេញពីទីងងឹត (Speak Truth To Power: Voices from Beyond the Dark) ត្រូវបានគេសម្តែងមុនដំបូងបង្អស់នៅ មជ្ឈមណ្ឌលខិណ្ណិឌី (The John F. Kennedy Center for thePerforming Arts) ក្នុងអំឡុងឆ្នាំ២០០០, ដោយទទួលបានការថ្លែងណែនាំបង្ហាញដោយ លោកប្រធានាធិបតី ប៊ីល គ្លីនតុន (President Bill Clinton) នៃសហរដ្ឋអាមេរិក និង សម្តែងដោយ បណ្តាតារាហូលីវូដមួយចំនួនដូចជា អ្នកស្រី ស៊ីហ្គ័នី វីវើ (Sigourney Weaver), លោក ចន ម៉ាលកូវីច (John Malkovich), លោក ខេវិន ខ្លាយន៍ (Kevin Kline), លោក ជៀនខាលូ អ៊ែសប៉ូស៊ីតូ (Giancarlo Esposito), លោកស្រី ជូលា លូវីស៍-ឌ្រែយហ្វ៊ូស (Julia Louis-Dreyfuss), លោកស្រី រីតា ម៉ូ រេណូ (Rita Moreno), លោក ហិកត័រ អេលីហ្សនដូ (Hector Elizondo), លោក អាឡេច បលដ៍វីន (Alec Baldwin) និង លោក អ៊ែលហ្វ វូឌ័ត (Alfre Woodard) ព្រមទាំងតន្ត្រីករ ហ្យូ ម៉ាសេឃែឡា (Hugh Masekela) និង ជែកសិន ប្រោន (Jackson Browne)។ ការសម្តែងនេះ ត្រូវបានគេបញ្ចាំងមួយម៉ោង លើបណ្តាញទូរទស្សន៍ ភីប៊ីអេស (PBS) ក្រោមកម្មវិធីឈ្មោះថា ឈុតសម្តែងដ៏អស្ចារ្យ (Great Performances Series)។ រឿងនេះ ក៏ត្រូវបានគេយកមកសម្តែងដោយ តារាល្បីៗជាច្រើន នៅទីក្រុង ហ្សឺណែវ (Geneva), ម៉ាឌ្រីដ (Madrid), បាស៊ីឡូន (Barcelona), ហែលស៊ីនគី (Helsinki), រ៉ូម (Rome), មីឡង់ (Milan), សេអ៊ូល (Seoul), ហ្វ្ល័រ៉ង់ (Florence), ម៉ានទួរ (Mantua), ចូហាណេសប៊ឺក (Johannesburg), ខេបថោន (Cape Town), ស៊ីដនី (Sydney) និង ភ្នំពេញជាដើម។ ឆាកសម្តែងដ៏ល្អបំផុត បានប្រព្រឹត្តនៅទីក្រុង ដូហា (Doha) ប្រទេស កាតា (Qatar) ដោយមានការផ្សាយបន្តផ្ទាល់ តាមបណ្តាញទូរទស្សន៍ អ៊ែលចាស៊ីរ៉ា (Al Jazeera) ផង ព្រមទាំងមានការចូលរួមអានដោយ តារាសម្តែង និង តារាចម្រៀងល្បីៗឈ្មោះចំនួន១០នាក់ ពីទ្វីបអារ៉ាប់។ រឿងនេះក៏ត្រូវបានសម្តែងដោយ សិស្សសាលា, និស្សិតសាកលវិទ្យាល័យ, វីរជន ក្នុងប្រទេសនានា ព្រមទាំងអ្នកទោសទៀតផង (នៅឯរោងមហោស្រពដ៏ធំមួយ នាទីក្រុង ប៊ូយការេស (Bucharest) បន្ទាប់ពីមានការលំហាត់នៅក្នុងមន្ទីរឃុំឃាំងរួចរាល់មក)។ ទៅអនាគតការសម្តែង ក៏នឹងមានការរៀបចំនៅទីក្រុង ប៉ារីស (Paris), អ៊ីស្តង់ប៊ូល (Istanbul), ហុងកុង (Hong Kong), ប្រទេសហ្សីមបាវេ (Zimbabwe) និង ប្រទេសម៉ិចស៊ីកូ (Mexico) ព្រមទាំងប្រទេសធំៗ នៅអាមេរិកឡាទីន មួយចំនួនដែរ។

គម្រោង សេចក្តីក្លាហានគ្មានព្រំដែន លើកទឹកចិត្តឲ្យ រដ្ឋាភិបាល, អង្គការក្រៅរដ្ឋាភិបាល, មូលនិធិធំៗ និង បុគ្គលទាំងឡាយ ឲ្យជួយគាំទ្រសិទ្ធិមនុស្ស ហើយគម្រោងនេះ ក៏នាំមកនូវការចាប់អារម្មណ៍ដ៏ចាំបាច់បំផុត ទៅលើការ រំលោភសិទ្ធិមនុស្ស ដែលកំពុងបន្តរីករាលដាល។ សមិទ្ធិផលដ៏យូរលង់របស់គម្រោងនេះ គឺ ការបង្ហាញ អំពីសមត្ថភាពរបស់បុគ្គលនីមួយៗ ក្នុងការផ្តើមឲ្យមានការផ្លាស់ប្តូរ។

គម្រោង សេចក្តីក្លាហានគ្មានព្រំដែន នៅកម្ពុជាបាន សម្ពោធឡើងនៅ ខែកុម្ភៈ ឆ្នាំ២០១១ ជាមួយដៃគូ ស៊ីវីកហ្គ័ស៖ មជ្ឈមណ្ឌលអប់រំដើម្បីពលរដ្ឋខ្មែរ (CIVICUS: Center for Cambodian Civic Education) ដោយមានវត្តមានរបស់ លោកស្រី ឃែរី ខិណ្ណិឌី (Kerry Kennedy) ដែលជាកូនស្រីរបស់ លោក រ៉ូប៊ឺត អ៊ែហ្វ ខិណ្ណិឌី និង ជាប្រធាន មជ្ឈមណ្ឌល រ៉ូប៊ឺត អ៊ែហ្វ ខិណ្ណិឌី ដើម្បីយុត្តិធម៌ និង សិទ្ធិមនុស្ស (Robert F. Kenney Center for Justice and Human Rights) ទៀតផង។

# លោកស្រី ឃែរី ខិណ្ណិឌី (Kerry Kennedy)

ជាម្តាយ របស់នាង ខារ៉ា, ម៉ារីយ៉ា និង មីខេឡា លោកស្រី ឃែរី ខិណ្ណិឌី (Kerry Kennedy) ជាអ្នកនិពន្ធ សៀវភៅលក់ដាច់ជាងគេរបស់សារព័ត៌មានញូវយ៉កថៃមស៍ (New York Times Bestseller) ដែលមានចំណងជើងថា ក្លាយជាអ្នកកាន់សាសនាកាតូលិកឥឡូវនេះ៖ ជនជាតិអាមេរិកជាន់ខ្ពស់និយាយពីការផ្លាស់ប្តូរក្នុងព្រះវិហារ និង ការស្វះស្វែងរកអត្ថន័យ។ លោកស្រី ខិណ្ណិឌី ផ្តើមធ្វើការផ្នែកសិទ្ធិមនុស្ស ក្នុងឆ្នាំ១៩៨១ នៅពេលគាត់បានស៊ើបអង្កេត ការរំលោភបំពាន បង្កដោយមន្ត្រីអន្តោប្រវេសន៍សហរដ្ឋអាមេរិក មកលើជនភៀសខ្លួនពីប្រទេស អែល សាល់វ៉ាឌ័រ (El Salvador)។ ចាប់ពីពេលនោះមក គាត់បានបូជាជីវិតរបស់គាត់ក្នុងការស្វែងរកយុត្តិធម៌, ការលើកកម្ពស់ និង ការការពារសិទ្ធិមនុស្ស ជាមូលដ្ឋាន និង ការថែរក្សានីតិរដ្ឋ។ លោកស្រីបានបង្កើត មជ្ឈមណ្ឌលអនុស្សាវរីយ៍ រ៉ូប៊ឺត អេហ្វ ខិណ្ណិឌី ដើម្បីសិទ្ធិមនុស្ស (RFK Memorial Center) ក្នុងឆ្នាំ១៩៨៨។ លោកស្រី បានដឹកនាំប្រតិភូសិទ្ធិមនុស្សជាង៤០នាក់ ទៅកាន់ប្រទេសនានាក្នុងពិភពលោក។ លោកស្រី ខិណ្ណិឌី ជាប្រធានក្រុមប្រឹក្សាអ្នកដឹកនាំ អង្គការលើកលែងទោសអន្តរជាតិសហរដ្ឋអាមេរិក (Amnesty International US) និង ជាប្រធាន មជ្ឈមណ្ឌលរ៉ូប៊ឺត អេហ្វ ខិណ្ណិឌី ដើម្បីយុត្តិធម៌និងសិទ្ធិមនុស្ស, គាត់ជាអ្នកនិពន្ធសៀវភៅ សេចក្តីក្លាហានគ្មានព្រំដែន៖ អ្នកការពារសិទ្ធិមនុស្ស ដែលកំពុងផ្លាស់ប្តូរពិភពលោកយើង (Speak Truth To Power: Human Rights Defenders Who Are Changing the World)។



Kerry Kennedy, ©1998 Jane Silk

ក្នុងពិភពលោកមួយដែលមនុស្សទាំងឡាយបាននិយាយដូចគ្នា ទាំងភាពសោកស្តាយ និងក្រៀមក្រំថា លែងមានវីរជនទៀតហើយ នោះយើងតែងសង្កេតឃើញជាញឹកញយថា ភាពចំអកឡកឡឺយ និង ភាពអស់សង្ឃឹម ត្រូវគេមើលឃើញថា ជាភស្តុតាងនៃការបាត់បង់នូវភាពក្លាហានផ្នែកសីលធម៌ផ្លូវចិត្ត។ ការយល់ឃើញបែបនោះ គឺជាការយល់ខុស។ មនុស្សដែលមានភាពក្លាហាន និង ទឹកចិត្តដ៏អស្ចារ្យ មានការប្តេជ្ញាក្នុងការសម្រេចឲ្យបាននូវគោលបំណងដ៏ថ្លៃថ្នូរ រួមជាមួយនឹងប្រវត្តិយ៉ាងវែងក្នុងការលះបង់ផ្ទាល់ខ្លួននោះ កំពុងដើរជាមួយពួកយើងនៅគ្រប់ប្រទេសក្នុងពិភពលោក ។

សម្រាប់វីរជនជាច្រើនក្នុងចំណោមវីរជនទាំងអស់នេះ ការយល់ដឹង អំពីការរំលោភសិទ្ធិមនុស្សកើតចេញមកយ៉ាងស៊ីជម្រៅ ពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់ពួកគេ មានជាអាទិ៍៖ ការគម្រាមសម្លាប់, ការដាក់ពន្ធនាគារ, ហើយក្នុងករណីមួយចំនួន, ការរងការឈឺចាប់ដល់រាងកាយទៀតផង។ ក៏ប៉ុន្តែ រឿងរ៉ាវរបស់ពួកគេទាំងនេះ មិនមែនជាការចងក្រងបង្កើនចំនួនជនរងគ្រោះទេ។ ផ្ទុយទៅវិញ អ្វីដែលធ្វើឲ្យពួកគេមាន លក្ខណៈពិសេសប្លែកពីអ្នកដទៃ គឺសេចក្តីក្លាហានគួបផ្សំនឹងការបញ្ជាក់អះអាងពីលទ្ធភាព និង ការផ្លាស់ប្តូរ ដែលពួកគេមានរៀងៗខ្លួន និង មានរួមគ្នា។ ពួកគេម្នាក់ៗនិយាយ ជាមួយខ្ញុំដោយវោហារកោសល្យដ៏គួរស្ញប់ស្ញែង អំពីការប្តេជ្ញាចិត្តរបស់ពួកគេសម្រាប់ បុព្វហេតុ និង មូលហេតុដែលពួកគេសុខចិត្តលះបង់អាយុជីវិតខ្លួន ដូចជា ចាប់រាប់ពីសេរីភាពបញ្ចេញមតិ ដល់នីតិរដ្ឋ, ពីការការពារបរិស្ថាន ដល់ការលុបបំបាត់ការងារធ្ងន់ធ្ងរដើម្បីសងបំណុល, ពីការទទួលបានប្រាក់ទុន ដល់មានសិទ្ធិទទួលបានដំណើរត្រឹមត្រូវតាមផ្លូវច្បាប់, ពីសិទ្ធិស្ត្រី ដល់សេរីភាពសាសនា ។ ដូចគ្នាទៅនឹង លោក ម៉ានដេឡា, លោក គន្ធី, និង លោកស្រី ម៉ាថាយ៍ នៅក្នុងបណ្តាប្រទេសពួកគេអញ្ចឹង អ្នកដឹកនាំនេះ មានលក្ខណៈរួមមួយ គឺប្រវត្តិនៃសមិទ្ធិផលដែលមានកម្លាំងបណ្តាលចិត្ត និង សមត្ថភាពយ៉ាងជ្រាលជ្រៅក្នុងការជម្រុញឲ្យមានការផ្លាស់ប្តូរ។

សម្លេងរបស់អ្នកការពារសិទ្ធិ បានចោទជាសំណួរសំខាន់សាមញ្ញៗមួយចំនួនដូចជា៖ ហេតុអ្វីបានជាបុគ្គលដែលប្រឈមនឹងការជាប់ពន្ធនាគារ, អំពើទារុណកម្ម និង សេចក្តីស្លាប់ នៅតែបន្តកិច្ចការរបស់ខ្លួនទៀត ក្នុងខណៈពេលដែលលទ្ធភាពនៃជោគជ័យនៅឆ្ងាយក្រៃលែង ហើយផលវិបាក ដែលអាចធ្លាក់មកលើខ្លួនមានសភាពយ៉ាងធ្ងន់ធ្ងរពន់ពេកនោះ? ហេតុអ្វីក៏ពួកគេចូលរួម? អ្វីទៅ ដែលជួយជម្រុញឲ្យពួកគេនៅតែបន្តទៅមុខ? តើថាមពល និង

កម្លាំងបណ្តាលចិត្តរបស់ពួកគេ មានប្រភពចេញមកពីណា? តើពួកគេជំនះភាពភ័យខ្លាច យ៉ាងដូចម្តេច? តើគេរស់រវើងជោគជ័យដោយវិធីណា? ក្នុងចំណោមចម្លើយទៅនឹងសំណួរទាំងនោះ យើងសង្កេតឃើញមាន ការរៀបរាប់អំពី សមានចិត្ត សណ្តោសប្រណី និង ការផ្តល់ថាមពល នៃអំណាចនាំការដោះស្រាយនិងការតាំងចិត្តនៅចំពោះមុខនៃអំពើអយុត្តិធម៌។ សំណួរសំខាន់សាមញ្ញៗទាំងឡាយនេះ នាំឲ្យខ្ញុំចាប់អារម្មណ៍ផ្ទាល់ខ្លួន យ៉ាងពិសេស។

ភាគច្រើននៃសម្លេងទាំងនោះ គឺជាការអំពាវនាវឲ្យធ្វើសកម្មភាព ដែលមានភាពចាំបាច់ខ្លាំងណាស់ ពីព្រោះការរំលោភសិទ្ធិមនុស្សរមែងកើតឡើងនៅពេលយប់, នៅទីដាច់ស្រយាល និង ទីងងឹត។ ចំពោះអ្នកដែលរងគ្រោះ, ភាពឯកោ ជាសត្រូវដ៏អាក្រក់បំផុតរបស់ពួកគេ ហើយការលាតត្រដាងអំពីអំពើព្រៃផ្សៃទាំងនោះ ជាសេចក្តីសង្ឃឹមតែមួយគត់របស់ពួកគេ។ យើងផ្លូវនាំយកការលាតត្រដាងជាអន្តរជាតិ ចំពោះការរំលោភបំពានទាំងនោះ ហើយយើងត្រូវពង្រីកសហគមន៍របស់អ្នកដែលបានដឹង និង យកចិត្តទុកដាក់ចំពោះបុគ្គល ដែលត្រូវបានបង្ហាញទាំងនេះ។ គ្រាន់តែការធ្វើបៀបនេះម៉្យាង វាក៏អាចនឹងបញ្ឈប់ការបាត់ខ្លួនរបស់មនុស្សម្នាក់, អាចលុបចោលការធ្វើទារុណកម្មម្តង, ឬក៏អាចនឹងសង្គ្រោះជីវិតមនុស្សម្នាក់ផងក៏ថាបាន។ កាលណាសម្លេងកាន់តែកើនឡើងក្នុងការប្រឆាំងនោះលទ្ធភាពនៃការផ្លាស់ប្តូរក៏កាន់តែច្រើន ។

ខ្ញុំធំដឹងក្តីឡើងជាអ្នកកាន់ប្រពៃណីសាសនាគ្រិស្ត-ជ្វីហ្វ (Judeo-Christian) ហើយយើងគួររូបព្រះរបស់យើង នៅលើពិដាន ហើយតម្កល់បដិមាព្រះអង្គក្នុងកញ្ចក់តាំងតាមព្រះវិហារ។ ព្រះទាំងឡាយ នោះជាតួអង្គអច្ឆរិយៈ មិនអាចរិះគន់ ឬ ប៉ះពាល់បាន ដូច្នេះ យើងក៏មិនចាំបាច់មានបន្ទុកក្នុង ការប្រឈមមុខប្រជែងដែរ។ ប៉ុន្តែនៅលើផែនដីនេះ មនុស្សបែបនោះ និង អ្នកការពារ សិទ្ធិមនុស្សរាប់មិនអស់ កំពុងរស់នៅ កំពុងដកដង្ហើម ក្នុងចំណោមពួកយើង។ ការប្តេជ្ញាចិត្ត, ភាពក្លាហាន និង ការតាំងចិត្តរបស់ពួកគេ នៅចំពោះមុខគ្រោះថ្នាក់ដ៏ធំធេង បានជម្រុញឲ្យ យើងលើកភ្លើងគប់ឡើង ដើម្បីទាមទារឲ្យមានសង្គមមួយមានលក្ខណៈសមរម្យជាងនេះ។ បច្ចុប្បន្ននេះ យើងសំណាងណាស់ ដោយមានវត្តមានរបស់វីរជនទាំងឡាយនេះ ជាអំណោយទានពីព្រះជាម្ចាស់។ ពួកគាត់ជាគ្រូបង្រៀនដែលបង្ហាញដល់ពួកយើងថា មិន ត្រឹមតែធ្វើដូចជាលោកសង្ឃទេ តែត្រូវធ្វើ ខ្លួនឲ្យក្លាយជាមនុស្សពេញលក្ខណៈវិញ។

ជាក់ស្តែងគម្រោងនេះ ជាដៃគូរវាង មជ្ឈមណ្ឌល រ៉ូប៊ើត អ៊ែហ្វ ខិណ្ណិឌី ដើម្បីយុត្តិធម៌ និង សិទ្ធិមនុស្ស (Robert F. Kenney Center for Justice and Human Rights) និង ស៊ីវីកហ៊្គស៖ មជ្ឈមណ្ឌលអប់រំដើម្បីពលរដ្ឋខ្មែរ (CIVICUS: Center for Cambodian Civic Education), ដែលបានរៀបចំដោយ អ្នកដែលបានគិតគូរខ្ពស់ អំពីការអប់រំនៅក្នុងសង្គមខ្មែរ។ យើងសូមថ្លែងអំណរគុណដ៏ខ្ពង់ខ្ពស់បំផុតដល់អ្នកទាំងនោះ។

សូមប្រកបដោយសុខសន្តិភាព
ឃែរី ខិណ្ណិឌី
ប្រធាន, មជ្ឈមណ្ឌល រ៉ូប៊ើត អ៊ែហ្វ ខិណ្ណិឌី ដើម្បីយុត្តិធម៌ និង សិទ្ធិមនុស្ស

## អំពី មជ្ឈមណ្ឌល រ៉ូបឺត អ៊ែហ្វ ខិណ្ណិឌី ដើម្បីយុត្តិធម៌ និង សិទ្ធិមនុស្ស

មជ្ឈមណ្ឌល រ៉ូបឺត អ៊ែហ្វ ខិណ្ណិឌី ដើម្បីយុត្តិធម៌ និង សិទ្ធិមនុស្ស (Robert F. Kennedy Center for Justice and Human Rights) ត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៦៨ ដោយគ្រួសារ និង មិត្តភក្តិ របស់ លោក រ៉ូបឺត ខិណ្ណិឌី ដើម្បីជាការចងចាំដ៏រស់រវើក ក្នុងការបន្តចក្ខុវិស័យ របស់គាត់ ដើម្បីទទួលបានពិភពលោកមួយ ដែលពោរពេញដោយយុត្តិធម៌ និង សន្តិភាព។ បច្ចុប្បន្ន មជ្ឈមណ្ឌលនេះ មានកម្មវិធីធំៗចំនួន៣។ រង្វាន់សៀវភៅ និង សារព័ត៌មាន មជ្ឈមណ្ឌល រ៉ូបឺត អ៊ែហ្វ ខិណ្ណិឌី ដើម្បីយុត្តិធម៌ និង សិទ្ធិមនុស្ស ដែលគេស្គាល់ថា ជារង្វាន់ "ភូលីតហ្សរបស់ជនក្រីក្រ" បានបើកកកាយអំពីបញ្ហាអយុត្តិធម៌ នៅក្នុងសហរដ្ឋអាមេរិក និង ជុំវិញពិភពលោក។ មជ្ឈមណ្ឌលនេះ ផ្តល់ រង្វាន់សិទ្ធិមនុស្ស រ៉ូបឺត អ៊ែហ្វ ខិណ្ណិឌី ដល់ជើងឯកលើវិស័យយុត្តិធម៌ ចំពោះការបង្កើតឲ្យមានដំណាក់កាលសំខាន់ៗ ក្នុងការផ្លាស់ប្តូរសង្គម។ បន្ទាប់ពីនោះ យើងធ្វើជាដៃគូជាមួយអ្នកទទួលបានរង្វាន់ជាច្រើននាក់ សម្រាប់រយៈពេល៥ឆ្នាំ ហើយជួយពួកគេឲ្យសម្រេចបានគោលបំណងផ្នែកយុត្តិធម៌សង្គមរបស់ពួកគេ។ តាមរយៈគម្រោង *សេចក្តីក្លាហានគ្មានព្រំដែន (Speak Truth To Power)*, យើងនិយាយរឿងរ៉ាវរបស់អ្នកការពារសិទ្ធិ និង ផ្តល់ជូនសិស្សនិស្សិត ព្រមទាំងសាធារណជនទូទៅ នូវឧបករណ៍ សម្រាប់ធ្វើសកម្មភាពក្នុងការបង្កើតឲ្យមានការផ្លាស់ប្តូរក្នុងថ្នាក់រៀន, សហគមន៍ ប្រទេសជាតិ និង ពិភពលោក ទៅលើប្រធានបទ អំពីពលកម្មកុមារ, ការជួញដូរ, សិទ្ធិស្ត្រី, ការការពារបរិស្ថាន និង សិទ្ធិដទៃទៀត។ សម្រាប់ព័ត៌មានបន្ថែម អំពីគម្រោង *សេចក្តីក្លាហានគ្មានព្រំដែន (Speak Truth To Power)* សូមទាក់ទង លោកនាយក ចន ហែហ្វឺនិន (John Heffernan) តាមរយៈ អ៊ីម៉ែល jheffernan@rfkcenter.org ឬ អាចផ្តល់ជំនួយបាន តាមគេហទំព័រ www.rfkcenter.org។

## អំពី ស៊ីវីកហ្គ័ស៖ មជ្ឈមណ្ឌលអប់រំដើម្បីពលរដ្ឋខ្មែរ

ស៊ីវីកហ្គ័ស៖ មជ្ឈមណ្ឌលអប់រំដើម្បីពលរដ្ឋខ្មែរ ( ឬ ស៊ីវីកហ្គ័សកម្ពុជា ) (CIVICUS: Center for Cambodian Civic Education) គឺជាអង្គការក្រៅរដ្ឋាភិបាល, មិនរកប្រាក់កម្រៃ, ផ្តល់ការអប់រំ, មិនប្រកាន់បក្សពួក, ដែលបានចុះបញ្ជីនៅក្នុងក្រសួងមហាផ្ទៃនៃព្រះរាជាណាចក្រកម្ពុជា។ ស៊ីវីកហ្គ័សកម្ពុជា តាំងចិត្តក្នុងការលើកកម្ពស់ ឲ្យពលរដ្ឋ មានការទទួលខុសត្រូវនិងមានចំណេះដឹង,មានការតាំងចិត្តគោរពតាមគោលការណ៍លទ្ធិប្រជាធិបតេយ្យ និង មានការចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តលទ្ធិប្រជាធិបតេយ្យ និង ការបង្រួបបង្រួម ក្នុងប្រទេសកម្ពុជា និង ក្នុងពិភពលោក។ បច្ចុប្បន្ននេះ ប្រទេសកម្ពុជា មានតែសង្គមនៃ "អ្នករួចរស់រានមានជីវិត" (survivor) តែមិនមែនជាសង្គមនៃ "អ្នកតំណាង" (representative) ឬ "ពលរដ្ឋ" (citizen) នោះទេ។ ប្រជាជនកម្ពុជា ដែលជា អ្នករួចរស់រានមានជីវិត គឺជា "អ្នករួចរស់រានមានជីវិត-អ្នកគ្រប់គ្រងដោយអំណាច" (survivor-authoritarian) ប្រសិនបើនៅក្នុងតួនាទី ជាអ្នកមានអំណាច, ឬ ប្រជាជនកម្ពុជា គ្រាន់តែជា "អ្នករួចរស់រានមានជីវិត-អ្នកត្រូវគេគ្រប់គ្រង" (survivor-subject) ប្រសិនបើជាជនធម្មតា។ គោលដៅចំបងរបស់ ស៊ីវីកហ្គ័សកម្ពុជា គឺដើម្បី ជួយពលរដ្ឋកម្ពុជា អភិវឌ្ឍន៍ ( ១ ) ការយល់ដឹងបន្ថែមអំពីស្ថាប័នប្រជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញរបស់ប្រទេសកម្ពុជា និង គោលការណ៍គ្រឹះ និង គុណតម្លៃជាមូលដ្ឋានដែលបានបង្កើតឡើង, ( ២ ) ការសន្ទនាជាទម្លាប់សម្រាប់ទំនាក់ទំនង, ការកសាងសន្តិភាព និង ការបង្រួបបង្រួម, ( ៣ ) ជំនាញចាំបាច់ ក្នុងការចូលរួមជាពលរដ្ឋ មានការទទួលខុសត្រូវ និង មានប្រសិទ្ធភាព, និង ( ៤ ) ការប្តេជ្ញាចិត្ត និង ភាពងាយស្រួល ក្នុងការប្រើប្រាស់នីតិវិធីប្រជាធិបតេយ្យ សម្រាប់ការធ្វើការសម្រេចចិត្ត និង ការគ្រប់គ្រងជម្លោះ។ ក្នុងការធ្វើឲ្យប្រជាជនមានការចូលរួម ស៊ីវីកហ្គ័សកម្ពុជា ផ្តោតសំខាន់ទៅលើ ( ១ ) សិស្សនិស្សិត ពីថ្នាក់បឋមសិក្សាដល់សាកលវិទ្យាល័យ និង ជនកើតក្នុងជំនាន់ក្រោយរបបខ្មែរក្រហម, ( ២ ) ការចូលរួមរបស់មនុស្សស្រី ( ទាំងក្មេងស្រី និង ស្ត្រីទូទៅ ), និង ( ៣ ) អ្នកតំណាងដែលបានជាប់ឆ្នោត។ សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់គេហទំព័រ www.civicus-cam.org ឬ សរសេរអ៊ីម៉ែលទៅកាន់ info@civicus-cam.org។

# អ្នកនាង សេង ធារី (Theary C. SENG)



សេង ធារី (Photo: Roland Neveu, ខែធ្នូ ឆ្នាំ២០០៩)

អ្នកនាង សេង ធារី គឺជាប្រធានស្ថាបនិក អង្គការ ស៊ីវិកហ្គ័ស៖ មជ្ឈមណ្ឌលអប់រំដើម្បីពលរដ្ឋខ្មែរ។ ពី ខែមីនា ឆ្នាំ២០០៦ រហូតដល់ ខែកក្កដា ឆ្នាំ២០០៩, អ្នកនាង ធារី បានដឹកនាំ អង្គការ មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម។

អ្នកនាង ធារី កើតនៅដើមឆ្នាំ១៩៧១ នៅទីក្រុងភ្នំពេញ។ ក្រោមរបបខ្មែរក្រហម, នាង រស់នៅក្នុង ខេត្តស្វាយរៀង ដែលជាកន្លែងរងនូវ ការសម្លាប់យ៉ាងខ្លាំងក្លា ហើយជាកន្លែងដែល នាងបានជាប់គុកអស់ រយៈពេល ៥-៦ ខែ។ ខ្មែរក្រហមបានសម្លាប់ ឪពុក ម្តាយ របស់នាង។ នាង និង ក្រុមគ្រួសារដែលនៅរស់រានមានជីវិត បានធ្វើដំណើរឆ្លងកាត់ព្រំដែន ប្រទេសថៃ ក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៩, ហើយមួយឆ្នាំក្រោយមក បានភៀសខ្លួនទៅកាន់សហរដ្ឋអាមេរិក។

ចាប់ពីឆ្នាំ១៩៩៥ សេង ធារី បានត្រលប់មកប្រទេស កំណើតវិញ ហើយស្ម័គ្រចិត្តជាមួយ អង្គការសិទ្ធិមនុស្ស និង សហជីពពលកម្មមួយចំនួន។ ខែមករា ឆ្នាំ២០០៤ នាងបានផ្លាស់មករស់នៅជាអចិន្ត្រៃយ៍នៅកម្ពុជា។ ដោយចេតនា លំនៅដ្ឋានរបស់នាង គឺប្រទេសកម្ពុជា។

សេង ធារី បានទទួលសញ្ញាប័ត្រផ្នែកនយោបាយអន្តរជាតិ ពី សាកលវិទ្យាល័យ ចច ថោន (Georgetown University's School of Foreign Service) នៅទីក្រុងវ៉ាស៊ីនតោន ឌីស៊ី, និង សញ្ញាប័ត្របណ្ឌិតច្បាប់ (Juris Doctor) ពីសាលាច្បាប់ នៃសាកលវិទ្យាល័យម៉ីឈីហ្គែន (University of Michigan Law School), ហើយ នាង ប្រហែលជាជនជាតិខ្មែរលើកដំបូងដែលបានប្រលងជាប់សមាគមច្បាប់ញូយ៉ក (New York Bar)។

សេង ធារី បាននិពន្ធ សៀវភៅមួយក្បាល ជាភាសាអង់គ្លេស បោះពុម្ព នៅទីក្រុងឡុងដ៍ (London) ក្នុងឆ្នាំ២០០៥ ដែលមានចំណងជើងថា *កូនស្រីនៃវាលពិឃាត*, ហើយនឹងមានការបោះពុម្ព នៅទីក្រុងញូយ៉ក ដើមឆ្នាំ២០១២, និង ការបកប្រែជាភាសាខ្មែរ នៅឆ្នាំ២០១២ ផងដែរ។ នាង ជាដើមបណ្តឹងរដ្ឋប្បវេណីដំបូងគេបង្អស់ ប្រឆាំងនឹងមេដឹកនាំខ្មែរក្រហមជាន់ខ្ពស់ នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ECCC)។

សហការី លោកគ្រូ អ្នកគ្រូ និង អ្នកអប់រំការសិក្សាទាំងអស់ ជាទីគោរព (ដែលជាវីរជន និង វីរនារី ដ៏ពិត ប្រាកដ តែ មិនត្រូវបានគេកត់សម្គាល់ច្បាស់លាស់)៖

នេះគឺជាសៀវភៅរបស់លោកអ្នក! យើងខ្ញុំបានរៀបចំបង្កើតសៀវភៅនេះឡើង ដោយសំដៅទៅលើ រូបលោកអ្នកដែលជាអ្នកអប់រំ ក្នុងការសិក្សា។ យើងខ្ញុំក៏បានយល់ដឹងដែរ អំពីបញ្ហាមួយចំនួន ដែលលោកអ្នកកំពុងប្រឈមមុខ នៅក្នុងប្រទេសកម្ពុជា នាសម័យបច្ចុប្បន្ន, ហើយយើងក៏សូមចូលរួមចំណែក ក្នុងបញ្ហាទាំងអស់នេះដែរ។ ជាមួយគ្នានេះដែរ យើងក៏សូមប្រសិទ្ធិពរ ជូនអស់លោកអ្នក សូមប្រកបទៅដោយអនុភាពដ៏មោះមុតជានិច្ច។

យើងមានទំនុកចិត្តយ៉ាងមុតមាំ អំពីសារៈសំខាន់ នៃ កម្មវិធីសិក្សានេះ ពីព្រោះយើងជឿជាក់យ៉ាងជ្រាលជ្រៅ ទៅលើគុណធម៌របស់សេចក្តីក្លាហាន។ ដូច្នេះ យើងជឿជាក់ថា កម្មវិធីសិក្សានេះ គឺជាគុណធម៌ដែលនឹងត្រូវបានយកទៅអនុវត្តន៍ ដោយមនុស្សជាច្រើន, ជាពិសេស អំពីមជ្ឈដ្ឋានយុវវ័យ។

សេចក្តីក្លាហាន ត្រូវបានកំណត់អត្ថន័យថា "ជាកម្លាំងប្រាជ្ញា និង សីលធម៌ ដើម្បីការពារ និង ទប់ទល់ជាមួយគ្រោះថ្នាក់ ឬ ក៏ភាពភ័យខ្លាច និង ភាពលំបាកលំបិន" ដែលជាសភាពការណ៍មួយ ដែលពួកយើងទាំងអស់គ្នា (ទោះជាជនជាតិខ្មែរ—ទោះជា អ្នកប្រកបការងារក្នុងជួរ អង្គការក្រៅរដ្ឋាភិបាល (NGOs), ឬ នៅក្នុងជួរ រដ្ឋាភិបាល និង គណៈបក្សជំទាស់ជាដើម, ទោះអ្នកជំនួញ និង ពាណិជ្ជករ នៅតាមបណ្តាខេត្តនានា ដូចជា មណ្ឌលគីរី, កំពត ។ល។ ទោះជានៅទីកន្លែងណាក៏ដោយ, ទោះជាមានជំនឿសាសនាអ្វីក៏ដោយ, ទោះជាមានឫក្រ ឬ ក៏ជាជនបរទេស ដូចជាជនជាតិ បារាំង, អាហ្វ្រិក, ចិន ។ល។ ទោះជាមកពីប្រភពណាក៏ដោយ) អាច នឹងមានជំនឿទៅលើវាបាន។

ដូចជា ការតាំងចិត្តធ្វើអ្វីៗទាំងឡាយ, សេចក្តីក្លាហាន អាចនៅគង់វង់ក្នុងខ្លួនយើងបាន លុះត្រាតែ យើងអនុវត្ត វាជាប្រចាំ។ ដូចជា កំណត់សម្គាល់ នៅក្នុងក្រមសីលធម៌នីកូម៉ាគី (Nicomachean Ethics) របស់ទស្សនវិទូជាតិក្រិក លោក អារីស្តូត (Aristotle) កាលពី ពីរពាន់បួនរយឆ្នាំមុនកន្លងទៅ ដែលបានចែងថា យើងអាចបណ្តុះភាពក្លាហានបាន ដោយអនុវត្តន៍សកម្មភាពណា ដែលត្រូវការបញ្ចេញសេចក្តីក្លាហាន។ ឧទាហរណ៍ ដូចជាថា "បើយើងមានទម្លាប់ស្អប់អ្វីមួយ ដែលជាបញ្ហាអាក្រក់ ហើយយើងបានក្រោកឈរឡើង ប្រឈមតតាំងជាមួយវា នោះយើងនឹងមាន សេចក្តីក្លាហាន, ហើយលុះត្រាតែយើង

តាំងចិត្តដូច្នេះ ទើបយើងអាចតទល់នឹងបញ្ហានោះបាន"។ ម្យ៉ាងវិញទៀត ប្រសិនបើយើង បានជួបប្រទះឧបសគ្គណាមួយ ដោយចៃដន្យ, យើង ត្រូវរំឭកខ្លួនយើងថា ឧបសគ្គនោះ ជាការអន្ទង សេចក្តីក្លាហាន របស់យើង មកវិញ។ ការភ័យខ្លាច គឺជា ការបំបាក់ស្មារតី របស់មនុស្សទាំងឡាយ, ផ្ទុយទៅវិញ សេចក្តីក្លាហាន ជួយធ្វើឲ្យមនុស្សទាំងឡាយ ព្រមទាំងសង្គម មានលំនឹងរឹងមាំពិតប្រាកដ។

យើងរាល់គ្នា ទោះរស់នៅទីកន្លែងណាក៏ដោយ នៅលើពិភពលោកនេះ នៅក្នុងកាលៈទេសៈ ប្រវត្តិសាស្ត្រណាក៏ដោយ គឺយើងជឿជាក់ អំពីសារៈសំខាន់ និង ការអនុវត្ត នៃ គុណធម៌ របស់ សេចក្តីក្លាហាន ជានិច្ច។ ហេតុដូច្នេះហើយ បានជាយើង មានការស្ងើចសរសើរយ៉ាងជ្រាលជ្រៅ ចំពោះលោកអ្នកដែលឈរនៅជួរខាងមុខក្នុងការជួយបណ្តុះគុណធម៌ នេះ តាមរយៈកម្មវិធីសិក្សានេះ ទៅដល់ កូនចៅរបស់យើង។

យើង ប្រាកដជាចង់ឃើញកម្មវិធីសិក្សានេះ ត្រូវបានដាក់បញ្ចូល ក្នុងផ្នែកមួយ នៃកម្មវិធីសិក្សាផ្លូវការ របស់ការអប់រំ, ដូច្នេះ យើងនឹង ចូលរួម ព្រមទាំងបន្ត កិច្ចសហប្រតិបត្តិការ ជាមួយមន្ត្រីរដ្ឋាភិបាល ដើម្បី បំពេញគោលបំណងនេះ ឲ្យសម្រេចបាន។ មុននឹងអាចសម្រេចគោលបំណងនេះបាន យើងទាំងអស់គ្នា ត្រូវយល់ដឹងអំពីខ្លឹមសាររបស់វា, ដូច្នេះ យើងត្រូវការចំណាយពេលវេលា ដើម្បី យល់ដឹង។

យើង យល់ឃើញថា យើងមានដំណើរដើមទងសមរម្យ, ឧទាហរណ៍ យើងមានសេចក្តីសោមនស្ស ពីការចូលរួម របស់ ឯកឧត្តម ឱម យិនទៀង ក្នុងការទទួលស្គាល់ពីសារៈសំខាន់របស់គម្រោង *សេចក្តីក្លាហានគ្មានព្រំដែន* (ដូចជា ការសម្តែងឡើង ជាមួយ លោកស្រី ឃែរី ខិណ្ណិឌី នៅក្នុងពេលជប់លៀងភោជនាហារមួយ ដែល ឯកឧត្តម បានរៀបចំធ្វើឡើង នៅខែកុម្ភៈ ឆ្នាំ២០១១)។ ចំពោះគម្រោងនេះ យើងនៅតែបន្តពឹងផ្អែកទៅលើ គណៈកម្មការសិទ្ធិមនុស្សកម្ពុជារបស់ ឯកឧត្តម ឱម យិនទៀង ដែលជាយន្តការមួយ ដើម្បីចែកចាយចំណេះទាំងនេះ។ យើងមានជំនឿទៅលើសកលភាព នៃគុណធម៌នេះ, យើងក៏មានជំនឿទៅលើ សេចក្តីក្លាហាន របស់រដ្ឋាភិបាល ក្នុងការទទួលយកកម្មវិធីសិក្សានេះ,ហើយយើងនឹងធ្វើអ្វីៗទាំងអស់ដើម្បីរួមសហការណ៍ជាមួយ ដៃគូពាក់ព័ន្ធទាំងឡាយណា ដែលមានជំនឿទៅលើ ការអប់រំដូចគ្នា។

ខ្ញុំចង់រៀបរាប់បន្តិច អំពី សាវតា និង ដំណើរការ នៃ ការបង្កើតកម្មវិធីសិក្សា សេចក្តីក្លាហាន នេះឡើង។

ជាដំបូង យើងមានកម្មវិធីសិក្សាព្រាង ជាភាសាអង់គ្លេស ដែលត្រូវបានរៀបចំធ្វើឡើង ផ្អែកទៅលើការពិភាក្សា រវាង ស៊ីកហ្គ័ស៖ មជ្ឈមណ្ឌលអប់រំដើម្បីពលរដ្ឋខ្មែរ ដែលមានទីតាំងការិយាល័យ នៅរាជធានីភ្នំពេញ ប្រទេសកម្ពុជា និង មជ្ឈមណ្ឌល រ៉ូបឺត អ៊ែហ្វ ខិណ្ណិឌី ដើម្បីយុត្តិធម៌ និង សិទ្ធិមនុស្ស (Robert F. Kennedy Center for Justice and Human Rights) ស្ថិតនៅទីក្រុង វ៉ាស៊ីនតោន ឌីស៊ី (Washington, D.C.) ដែលជាគំនិត និង មតិយោបល់ របស់ លោកស្រី ឃែរី ខិណ្ណិឌី ក្រោយពីការធ្វើទស្សនកិច្ច របស់ លោកស្រី នៅកម្ពុជា កាលពី ខែកុម្ភៈ ឆ្នាំ២០១១។

ក្នុងចំណោមអ្នកការពារ ៥១រូប ដែលបានចែងក្នុងសៀវភៅរបស់ លោកស្រី ឃែរី ខិណ្ណិឌី ដែលមានចំណងជើងថា *សេចក្តីក្លាហានគ្មានព្រំដែន* នេះ, យើងបានសម្រេចចិត្តផ្តោតអារម្មណ៍ ទៅលើតែ បុគ្គល ៨រូប ប៉ុណ្ណោះ ដែលបានបំពេញការងារ សមស្របទៅលើ ស្ថានភាពបច្ចុប្បន្ន នៅប្រទេសកម្ពុជា, ដូចជា លោក អ៊ីលី វីសែល (របបពេជ្ឈឃាដ), លោកស្រី ម៉ារីណា ពីសក្លាកូវ៉ា (អំពើហិង្សាក្នុងគ្រួសារ), លោកស្រី ជូលាអាណា ដកបាដហ្ស៊ី (ទាសភាព/ការជួញដូរ), លោក វ៉ាក្លាវ ហាវែល (សេរីភាពក្នុងការបញ្ចេញមតិ), លោក ម៉ូហាមែត យូណែស (សិទ្ធិក្នុងការទទួលប្រាក់កម្ចី),លោកដែសមិន ធូធូ (ការផ្សះផ្សាទំនាស់), លោក កា ហ្សា វ៉ា (ការទទួលខុសត្រូវកិច្ចការសង្គមពីសហគ្រាស) និង លោក កៃឡាស៍ សាទីអាទី (ពលកម្មកុមារ)។

បន្ទាប់មកទៀត យើងបានយកសេចក្តីព្រាងកម្មវិធីសិក្សាជាភាសាអង់គ្លេសនេះ មកបកប្រែជាភាសាខ្មែរ ដែលបានឆ្លងកាត់ជាច្រើនដំណាក់កាល។ យើងបានចំណាយអស់ កម្លាំងកាយជាច្រើន នៅក្នុងដំណើរការនេះ, ព្រោះយើងយល់ថា នៅទីបំផុត មានតែឯកសារភាសាខ្មែរទេ ដែលអាចត្រូវគេយកមក អាន និង យល់បាន។ អ្នកដែលចូលរួមក្នុងការបកប្រែ ពី ភាសាអង់គ្លេស ទៅ ជាភាសាខ្មែរ អាចយល់ដឹងពីដំណើរនេះបាន ព្រោះការបកប្រែនេះ ត្រូវការធានា នូវគុណភាព នៃខ្លឹមសារ រក្សាស្មារតី និង អត្ថន័យខ្លឹមសារ របស់ឯកសារដើមជាភាសាអង់គ្លេស ព្រមទាំងជួបប្រទះការពិបាក ជាមួយនឹងបញ្ហាបច្ចេកទេស ក្នុងការវាយអក្សរខ្មែរ និង ការរៀបចំរចនាសម្ព័ន្ធ។ល។ យើងបានស្វែងរក អ្នកបកប្រែល្អៗ នៅក្នុងប្រទេសកម្ពុជា ដើម្បី បកប្រែសំណៅដើមរបស់យើង។ ឆ្លោះទៅកាន់ ការបកប្រែ សំណៅកណ្តាល និង សំណៅបង្ហើយ, ខ្ញុំបានពិនិត្យពិច័យយ៉ាងល្អិតល្អន់ ទៅលើបន្ទាត់អក្សរមួយជួរៗ របស់ឯកសារភាសាខ្មែរនេះ, ហើយ ខ្ញុំបានផ្ទៀងផ្ទាត់ជាមួយនឹងអត្ថបទជាភាសាអង់គ្លេស ដើម្បី ប្រៀបធៀបបញ្ចូលខ្លឹមសារ ឲ្យងាយស្រួលយល់។ នៅក្នុងដំណាក់កាលនេះ ខ្ញុំក៏មានជំនួយការរបស់ខ្ញុំ គឺ នាង អៀម ស៊ីវនីន ដែលបានជួយវាយបញ្ចូល ពាក្យដែលត្រូវផ្លាស់ប្តូរ និង ជួយសម្របសម្រួលការពន្យល់ ដូចជា ការលើកឡើងជា សំណួរសុំាដដែលៗរបស់ខ្ញុំ ដូចជា៖ តើ ក្មេង អាយុ១៣ឆ្នាំ អាចអានយល់ ឬ ទេ? តើ មាន ពាក្យសាមញ្ញណា អាចយកមកជំនួសបានដែរ ឬ ទេ? ចូរនាង ប្រាប់ខ្ញុំថា តើ នាង គិតថា ពាក្យ ឬ ប្រយោគនេះ មានន័យថា យ៉ាងដូចម្តេចដែរ?

ខណៈពេលដែលវាមានសារៈសំខាន់ ក្នុងការរក្សាទុកនូវស្មារតីរបស់ខ្លឹមសារ, យើងក៏មានការព្រួយបារម្ភដែរ អំពី ការបកប្រែជាភាសាខ្មែរ ដែល តម្រូវឲ្យមានការអានបានយ៉ាងរលូន និង អាចយល់បាន ចំពោះប្រជាជនដ៏ច្រើន, ជាពិសេស យើងបានផ្តោតអារម្មណ៍ ទៅលើ ភាពច្បាស់លាស់ និង ការប្រើប្រាស់ពាក្យពេចន៍សាមញ្ញធម្មតា (ភាសាប្រើប្រាស់ប្រចាំថ្ងៃ) ដើម្បីងាយស្រួលអាចយល់បាន។ យើងចង់បាន ពាក្យពេចន៍សាមញ្ញធម្មតា ជាជាង ពាក្យបច្ចេកទេស, ប្រសិនបើអាចជៀសវាងមិនប្រើបាន។ នេះ គឺជា ការពិបាកមួយ សម្រាប់ខ្ញុំ និង នាង ស៊ីវនីន, ហើយ ជាក់ស្តែង នៅពេលខ្លះ យើងត្រូវការប្រើរយៈពេលជិតកន្លះម៉ោង សម្រាប់ត្រួតពិនិត្យមើល ឃ្លា ឬ ប្រយោគមួយ តែប៉ុណ្ណោះ។ ម្យ៉ាងវិញទៀត យើងក៏បានប្រើវចនានុក្រម សម្រាប់ជំនួយកិច្ចការយើង, ជាពិសេស

វចនានុក្រម ដ៏មានតម្លៃ របស់សម្តេចព្រះសង្ឃរាជ ជួន ណាត។

នៅក្នុងអំឡុងពេលដំណើរការនេះ យើងក៏បានសហការណ៍ជាមួយ លោកគ្រូ និង អ្នកគ្រូមួយចំនួន ដែលនឹងត្រូវបង្រៀនអំពីកម្មវិធីសិក្សានេះ នាពេលអនាគត។ យើងបានជួបពួកគាត់ជាលក្ខណៈសិក្ខាសាលា ដើម្បី ផ្តល់ការប្រឹក្សាចំនួនបីដង, ដែលមានគ្នាប្រហែលជាសែសិបនាក់, រួមមាន សាស្រ្តាចារ្យអប់រំជាន់ខ្ពស់ ដែលមកពីខេត្តចំនួនបួន ស្ថិតនៅទិសពាយព្យ ដូចជា ខេត្តសៀមរាប, បាត់ដំបង, បន្ទាយមានជ័យ, កំពង់ធំ, ក៏ដូចជា លោកគ្រូ និង អ្នកគ្រូ មួយចំនួនផ្សេងទៀត នៅ រាជធានីភ្នំពេញ និង ខេត្តកណ្តាល។ ពួកគាត់ទាំងនេះ បានជួយយើងយ៉ាងច្រើន ក្នុងការ ផ្តល់ជាមតិយោបល់ និង ការកែតម្រូវ ជាពិសេសលទ្ធភាព ក្នុងការជួយ អាន និង ការត្រួតពិនិត្យមើលការប្រើប្រាស់ និង អក្ខរាវិរុទ្ធជាទូទៅ។ ចំពោះចំណុចនេះ យើងបានបញ្ចូលយោបល់ជាច្រើន របស់ពួកគាត់ តាមការគួរ។ ( សូមអរគុណច្រើន, លោកគ្រូ និង អ្នកគ្រូ! )

ជាចុងបញ្ចប់ យើងបានធ្វើ ការតាក់តែងគ្រោងឯកសារនេះ ជាមួយ នឹង នាង សុង ៉ាន្នី ក្នុងការដាក់បញ្ចូលអ្វីៗទាំងអស់ចូលគ្នា, រួមមានទាំង ដំបូន្មាន និង មតិយោបល់ ដែលយើងបានទទួលមកពីការប្រឹក្សា ( សិក្ខា សាលា និង ការត្រួតពិនិត្យមើលសំណៅសាឡើងវិញ )។

ខ្ញុំស្នើសុំ ឆន្ទៈដ៏ប្រពៃរបស់លោកអ្នក ក្នុងការអធ្យាស្រ័យ និង អត់ធ្មត់ ចំពោះកំហុស ( ឧ.ការប្រកបអក្ខរាវិរុទ្ធ ) ដែលលោកអ្នកអាចអានឃើញ និង ការលម្អៀង (ឧ. ការប្រើសញ្ញាកៀស) ដែលលោកអ្នកខ្លះមិន អាចយល់ស្របជាមួយ។ យើងសូមទទួលខុសត្រូវទាំងស្រុង ទៅលើ ខ្លឹមសាររបស់ កម្មវិធីសិក្សានេះ, ប៉ុន្តែ យើងក៏ស្នើសុំ ឲ្យមានការជួយគាំទ្រ ពីលោកអ្នក ក្នុងការផ្តល់យោបល់ សម្រាប់ការបោះពុម្ពកម្មវិធីសិក្សា នេះ នាពេលអនាគត។

ខ្ញុំសូមបួងសួង ឲ្យលោកអ្នកយល់ឃើញថា កម្មវិធីសិក្សាសេចក្តី ក្លាហាននេះ គឺជាការជួយបំផុសគំនិត មិនត្រឹមតែ សម្រាប់សិស្សានុសិស្ស របស់លោកអ្នកតែប៉ុណ្ណោះទេ, ក៏ប៉ុន្តែ សម្រាប់ខ្លួន របស់លោកអ្នកផ្ទាល់ ផងដែរ។ សូមឲ្យមាន សន្តិភាព និង សេចក្តីក្លាហាន បដិសន្ធិនៅជាមួយ លោកអ្នកជានិច្ច។

សេង ធារី
ប្រធានស្ថាបនិក ស៊ីវីកហ្គ័ស៖ មជ្ឈមណ្ឌលអប់រំដើម្បីពលរដ្ឋខ្មែរ
ភ្នំពេញ, ខែកញ្ញា ឆ្នាំ២០១១



លោកគ្រូ អ្នកគ្រូ និង ព្រះសង្ឃ មកពីខេត្ត សៀមរាប, បាត់ដំបង, កំពង់ធំ, ព្រះវិហារ និង បន្ទាយមានជ័យ ក្នុងសិក្ខាសាលាពិគ្រោះយោបល់ (វត្តដំណាក់, ខែសីហា ឆ្នាំ២០១១)

# អំពីកម្មវិធីសិក្សានេះ

កម្មវិធីសិក្សានេះ បង្ហាញនូវបញ្ហាសិទ្ធិមនុស្សទូទៅ តាមរយៈរឿងរ៉ាវមនុស្ស ដែលគួរឲ្យកត់សម្គាល់មួយចំនួន ដែលធ្វើការនៅក្នុងវិស័យនេះ, និង ជម្រុញឲ្យសិស្សនិស្សិតចូលរួមផ្ទាល់ក្នុងការការពារសិទ្ធិមនុស្ស។

សិទ្ធិមនុស្ស សំដៅដល់សិទ្ធិពីកំណើត ដែលបានផ្តល់ដល់មនុស្សគ្រប់រូប ដែលបានកំណត់ដោយច្បាប់អន្តរជាតិ។ វាមានសារៈសំខាន់ដែលសិស្សនិស្សិតមានទស្សនៈច្បាស់លាស់មួយ អំពីអ្វីជាការរំលោភសិទ្ធិមនុស្ស ស្ថិតក្រោមវិធាននៃច្បាប់។

កម្មវិធីសិក្សានេះ ផ្តល់នូវទិដ្ឋភាពទូទៅមួយ នៃសិទ្ធិមនុស្ស និង បញ្ហាយុត្តិធម៌សង្គមនៅលើពិភពលោក។ ការប្រើប្រាស់សម្ភារៈសម្រាប់សកម្មភាព (Toolkit for Action), សិស្សនិស្សិត និង សាធារណជន នឹងមានធនធានដើម្បីដោះស្រាយបញ្ហានៅ កម្រិតមូលដ្ឋាន, កម្រិតជាតិ និង កម្រិតពិភពលោក។

# ព័ត៌មានសម្រាប់គ្រូបង្រៀន

## សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស

*មាត្រា ២៦៖* ការអប់រំត្រូវសំដៅទៅរកការរីកលូតលាស់ពេញលេញនៃបុគ្គលិកលក្ខណៈរបស់មនុស្ស និង ពង្រឹងការគោរពសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន។ ការអប់រំនេះត្រូវលើកកម្ពស់ការយល់ដឹង ការអត់ឱនអធ្យាស្រ័យគ្នា និង មិត្តភាពរវាងប្រជាជាតិនិងក្រុមពូជសាសន៍ ឬក្រុមសាសនាទាំងអស់ ព្រមទាំងការអភិវឌ្ឍសកម្មភាពរបស់សហប្រជាជាតិក្នុងការថែរក្សាសន្តិភាព។

ការបង្រៀនសិទ្ធិមនុស្ស គឺជាផ្នែកចាំបាច់ និង ជាមូលដ្ឋានគ្រឹះមួយ នៃការរៀនសូត្រសម្រាប់មនុស្សគ្រប់រូប។ ការអប់រំសិទ្ធិមនុស្ស គឺជាការហ្វឹកហ្វឺនចម្រុះ និង ស្របតាមគំនិតនិងគោលការណ៍នៃតម្រូវការក្នុងការអប់រំរបស់រាជរដ្ឋាភិបាលកម្ពុជា។ នៅក្នុងធនធាននេះ គ្រូបង្រៀននឹងទទួលបានមេរៀនដែលទាក់ទងទៅនឹងការសិក្សាសង្គម និង សិល្បៈភាសា។ ក្រៅពីនេះទៀត សមាសធាតុដូចជា កាលានុវត្ត (កាលប្បវត្តិ), និទានកថា នៃអ្នកការពារ និង ការសម្តែងអាចត្រូវបានដាក់បញ្ចូលទៅក្នុងសិល្បៈ, ភូមិសាស្ត្រ និង ស្ថិតិដែលមានគតិបណ្ឌិត, ជាឧទាហរណ៍។

ខណៈដែលគោលបំណងរៀនសូត្រ គឺច្បាស់លាស់ វាមានសារៈសំខាន់ក្នុងការទទួលស្គាល់ថា គម្រោង *សេចក្តីក្លាហានគ្មានព្រំដែន* និង ការអប់រំសិទ្ធិមនុស្ស សង្កត់ធ្ងន់លើ គរុកោសល្យ ដែលជម្រុញការលើកទឹកចិត្តទាំងទ្រឹស្តី និង ការអនុវត្ត។ មេរៀននានាត្រូវបានព្រាងឡើងដើម្បីផ្តល់ឱកាសសម្រាប់សិស្សនិស្សិតស្នើនូវទស្សនៈ និង ធ្វើការវិនិច្ឆ័យផ្ទាល់ខ្លួន អំពីពិភពជុំវិញខ្លួនរបស់ពួកគេ។ ការផ្តោតលើការអនុវត្ត ត្រូវបានដោះស្រាយដែលមានទំនាក់ទំនងនឹងការចាត់វិធានការ និង ការដាក់ឲ្យក្លាយជាអ្នកការពារផងដែរ។

## ក្របខ័ណ្ឌអប់រំសិទ្ធិមនុស្ស

ការអប់រំសិទ្ធិមនុស្ស មានជោគជ័យបំផុត ប្រសិនបើចំណុចខាងក្រោមនៃប្រព័ន្ធអប់រំកំពុងដំណើរការ។

## បរិស្ថាននៃការរៀនសូត្រ

ការអប់រំសិទ្ធិមនុស្ស ព្យាយាមយ៉ាងខ្លាំងចំពោះបរិស្ថាន ដែលសិទ្ធិមនុស្សត្រូវបានអនុវត្តន៍ និង ស្ថិតនៅក្នុងជីវិតប្រចាំថ្ងៃនៃសហគមន៍សាលារៀនទាំងមូល។ លើសពីនេះទៀត ការរៀនសូត្រផ្នែកវិភាគ (cognitive learning), ការអប់រំសិទ្ធិមនុស្ស រួមបញ្ចូលនូវ ការអភិវឌ្ឍផ្នែកសង្គម និង ចិត្តសាស្ត្រ សម្រាប់សិស្សនិស្សិតនិងគ្រូបង្រៀន។

## ការបង្រៀន និង ការរៀនសូត្រ

ការអប់រំសិទ្ធិមនុស្ស ត្រូវការយុទ្ធវិធីដ៏ហ្មត់ចត់មួយ ក្នុងការបង្រៀន និង ការរៀនសូត្រ ដែលឆ្លុះបញ្ចាំងនូវតម្លៃនៃសិទ្ធិមនុស្ស។ គោលបំណង និង មាតិកានៃកម្មវិធីសិក្សា គឺផ្អែកលើសិទ្ធិមនុស្ស វិធីសាស្ត្រ គឺតាម

បែបប្រជាធិបតេយ្យនិងមានការចូលរួម, ហើយសម្ភារៈ និង សៀវភៅសិក្សាទាំងអស់មានភាពស៊ីគ្នាជាមួយតម្លៃនៃសិទ្ធិមនុស្ស។

### ការអភិវឌ្ឍការអប់រំ និង ជំនាញវិជ្ជាជីវៈ (មុន និង ក្នុងការអប់រំ/បណ្តុះបណ្តាល)

ការអភិវឌ្ឍការអប់រំ និង ជំនាញវិជ្ជាជីវៈ ត្រូវពង្រឹងចំណេះដឹង ការប្តេជ្ញាចិត្ត និងទឹកចិត្តរបស់អ្នកអប់រំ អំពីសិទ្ធិមនុស្ស។

### គោលនយោបាយអប់រំ

ការជម្រុញផ្នែកច្បាប់ ដែលដាក់បញ្ចូលសិទ្ធិមនុស្សនៅក្នុងផែនការសកម្មភាព, កម្មវិធីសិក្សា, មុន និង ក្នុងការអប់រំ ការបណ្តុះបណ្តាល ការប៉ាន់ប្រមាណ និង ការទទួលខុសត្រូវ នឹងផ្តល់មូលដ្ឋាននយោបាយ សម្រាប់ប្រព័ន្ធអប់រំផ្អែកលើសិទ្ធិមនុស្ស។

## ក្របខ័ណ្ឌអភិវឌ្ឍន៍

ការអប់រំសិទ្ធិមនុស្ស ស្វែងរកការពង្រឹងឲ្យមានភាពប្រសើរឡើង ការយល់ដឹង, ឥរិយាបថ, និង អាកប្បកិរិយារបស់សិស្សនិស្សិតចំពោះសិទ្ធិមនុស្ស។

## ទិដ្ឋភាពទូទៅ

### ការលើកកម្ពស់ចំណេះដឹង

- សិក្សាលើការអភិវឌ្ឍការការពារសិទ្ធិមនុស្ស ចេញពីទស្សនៈតាមបែបប្រវត្តិសាស្ត្រ ក៏ដូចជា សេចក្តីប្រកាស, អនុសញ្ញា, និង សន្ធិសញ្ញានានា ក្នុងពេលបច្ចុប្បន្ន ហើយសិក្សាលើការបន្តនៃចំណេះដឹង លើផ្នែកសិទ្ធិមនុស្ស ការប្រឈមនានាក្នុងការប្រើប្រាស់ដ៏ពេញលេញ នូវសិទ្ធិមនុស្ស និង កត្តាដែលរួមចំណែក ដល់ការរំលោភសិទ្ធិមនុស្ស។
- សញ្ជឹងគិតលើសេចក្តីក្លាហាន
- អភិវឌ្ឍន៍ការយល់ដឹងដោយការវិភាគល្អិតល្អន់ អំពីស្ថានភាពជីវិតពិត, ការសាកសួរ អំពីរនាំងនិងរចនាសម្ព័ន្ធ ដែលរារាំងការប្រើប្រាស់សិទ្ធិ និង សេរីភាពពេញលេញ។

### ការផ្លាស់ប្តូរឥរិយាបថ

- សញ្ជឹងគិតអំពីតម្លៃ ដូចជា យុត្តិធម៌ សមភាព និង ភាពត្រឹមត្រូវ
- ជម្រុញឲ្យមានការយល់ដឹងប្រសើរឡើងរវាងក្រុមផ្សេងៗគ្នា។
- ទទួលស្គាល់ការតស៊ូរបស់មនុស្សផ្សេង ជាមនុស្សដូចយើង ដែលកំពុងស្វែងរកការឆ្លើយតប ចំពោះតម្រូវការជាមូលដ្ឋាន និង ការឆ្លើយតបចំពោះការរំលោភសិទ្ធិមនុស្ស។
- សញ្ជឹងគិត អំពីសេចក្តីក្លាហាន

### ការផ្លាស់ប្តូរអាកប្បកិរិយា

លើកទឹកចិត្តមនុស្សឲ្យដាក់បញ្ចូល គោលការណ៍សិទ្ធិមនុស្ស ទៅក្នុងជីវិតរស់នៅរបស់បុគ្គលម្នាក់ៗ និង ស្ថាប័នសង្គមនានា។

- ជម្រុញ និង សម្រួលមនុស្សឲ្យទាមទារ, គាំទ្រ និង ការពារ សិទ្ធិមនុស្ស ជាឧបករណ៍មួយ សម្រាប់ការផ្លាស់ប្តូរសង្គមប្រកបដោយនិរន្តរភាព។

## ការបញ្ចូលសិទ្ធិមនុស្សទៅក្នុងកម្មវិធី និង វិធីសាស្ត្រ

គម្រោង *សេចក្តីក្លាហានគ្មានព្រំដែន* នេះ ជម្រុញឲ្យមានការរៀនសូត្រ អំពីសិទ្ធិមនុស្សតាមរយៈនិទានកថារបស់បុគ្គល, តាមរយៈការប្រើពាក្យនិយាយ, តាមរយៈរូបភាព, និង តាមរយៈមេរៀននិងសកម្មភាពនានា។ ផ្នែកនេះនឹងផ្តល់ឧទាហរណ៍នានា អំពីថា តើអ្នកអប់រំអាចបញ្ចូល គម្រោង *សេចក្តីក្លាហានគ្មានព្រំដែន* នេះ ដោយរបៀបណាទៅក្នុងការបង្រៀនរបស់ពួកគេ ដែលជាការបន្ថែមលើមេរៀនដែលបានផ្តល់។ លើសពីនេះទៀត ផ្នែកនេះនឹងបង្ហាញ អំពីវិសាលភាព នៃវិធីសាស្ត្រ ដែលគ្រូបង្រៀនអាចប្រើប្រាស់ឯករាជ្យភាព ពីផែនការមេរៀន ដែលបានដាក់បញ្ចូល។

## សកម្មភាព និង មេរៀនគំរូនានា

ការណែនាំការអប់រំ គម្រោង *សេចក្តីក្លាហានគ្មានព្រំដែន* (ស.គ.ព.) ដាក់បញ្ចូលមេរៀន, សកម្មភាព និង សំណួរពិភាក្សានានាសម្រាប់អ្នកការពារនីមួយៗ។ ដើម្បីរៀបចំមេរៀនផ្ទាល់របស់អ្នក ត្រូវពិចារណាដូចខាងក្រោម៖ តើបញ្ហា ឬ ទស្សនៈស្របគ្នាជាមួយបទដ្ឋាន នៃការរៀនសូត្រដោយរបៀបណា? តើសិស្សនិស្សិតរបស់អ្នកដឹងអ្វីខ្លះ អំពីបញ្ហានេះ? តើវាមានពាក់ព័ន្ធដល់ពួកគេដែរឬទេ ហើយវាងាយស្រួលយល់ដែរឬទេ? តើអ្នកបានរៀបចំសិស្សនិស្សិតរបស់អ្នកឲ្យពាក់ព័ន្ធជាមួយប្រធានបទនេះដែរឬទេ? តើអ្នកបានគិតគូរអំពីផែនការត្រួតពិនិត្យតាមដានដែរឬទេ?

### វិធីសាស្ត្រ

ការរៀនសូត្រ អំពីសិទ្ធិមនុស្ស ប្រើប្រាស់យុទ្ធវិធីអន្តរកម្ម និង ការចូលរួម ដើម្បីដាក់ឲ្យសិស្សនិស្សិតមានការពាក់ព័ន្ធ។ ដើម្បីកំណត់វិធីសាស្ត្រដែលល្អបំផុត សម្រាប់សិស្សនិស្សិតរបស់អ្នក, ត្រូវគិតគូរ អំពីមាតិកា និង ថាតើយុទ្ធវិធីជាក់លាក់មួយ អាចពន្យល់អំពីបញ្ហាតាមរបៀបណា?

តើការសម្តែងលើប្រធានបទពលកម្មកុមារ អាចជួយបំភ្លឺការយល់ដឹងរបស់សិស្សនិស្សិតរបស់អ្នកទេ ឬ ការសម្តែងនេះ នឹងធ្វើឲ្យពួកគេមានភាពខុសគ្នាច្រើន បណ្តាលឲ្យផលប៉ះពាល់មានការបាត់បង់? អ្នកស្គាល់កូនសិស្សរបស់អ្នក។ ហើយតាមការយល់ដឹង និង ភាពកក់ក្តៅរបស់អ្នក អំពីបញ្ហាលំបាកច្រើនដែលកើតឡើង, លទ្ធភាពរបស់អ្នកក្នុងការប្រើវិធី

សាស្ត្រនានា នឹងមានតម្លៃ ហើយមានអត្ថន័យច្រើន សម្រាប់ទាំងខ្លួនអ្នក និង កូនសិស្សរបស់អ្នក។

គួរកត់សម្គាល់ថា បញ្ហាសិទ្ធិមនុស្សជាច្រើន គឺមានការលំបាកក្នុងការស្វែងយល់ ហើយស្ថិតឆ្ងាយពីជីវិតរស់នៅប្រចាំថ្ងៃរបស់សិស្សនិស្សិតភាគច្រើន។ គម្លាតរវាង ការលាតត្រដាង និង ការគក់ស្លុត, បង្កើតការយល់ចិត្ត និង ការពេញចិត្ត, ឬ ការបង្កើតឱកាសពិតប្រាកដ ក្នុងការចាត់វិធានការ ឬ ការលើកកម្ពស់ព្រឹត្តិការណ៍ ដែលជានិមិត្តរូបបន្ថែមទៀត គឺជាឧបាយកល។ គម្រោង *សេចក្តីក្លាហានគ្មានព្រំដែន* រួមជាមួយដៃគូនៅកម្ពុជា ស៊ីវីកហ្គ័ស៖ មជ្ឈមណ្ឌលអប់រំដើម្បីពលរដ្ឋខ្មែរ (CIVICUS: Center for Cambodian Civic Education) នឹងធ្វើការជាមួយអ្នក តាមមធ្យោបាយជាច្រើន ក្នុងការគាំទ្រការងារសំខាន់នេះ។

## វិធីសាស្ត្របង្រៀន

មុនពេលចាប់ផ្តើមសកម្មភាពក្នុងថ្នាក់ណាមួយ សូមបង្កើតច្បាប់ បទដ្ឋាន (ground rules) ដែលសិស្សទាំងអស់ បានចូលរួមចំណែក និង ឯកភាព។

### ការសម្តែងតួ

ការសម្តែងតួ គឺជាល្ខោនខ្លី ដែលបានសម្តែងដោយសិស្សនិស្សិត។ ការថ្លែងសុន្ទរកថាដោយឥតព្រាងទុកនាំមកនូវ កាលៈទេសៈ និង ព្រឹត្តិការណ៍សម្រាប់ជីវិត។ ការសម្តែងតួលើកកម្ពស់ការយល់ដឹងអំពីស្ថានភាព និង ជម្រុញឲ្យមានការយល់ចិត្ត។

#### ព័ត៌មាន (Tips)

- អនុញ្ញាតឲ្យសិស្សឈប់ធ្វើសកម្មភាព នៅពេលពួកគេមានសំណួរ ឬ ប្រសិនបើពួកគេចង់ផ្លាស់ប្តូរទិសដៅ នៃការសម្តែងតួ។
- ទុកពេលទំនេរ នៅពេលចុងបញ្ចប់ នៃការសម្តែងតួ ដើម្បីពិនិត្យសារឡើងវិញ និង ពង្រឹងគោលបំណង នៃសកម្មភាព និងគោលបំណងនៃការរៀនសូត្រ។
- ទុកពេលសម្រាប់ការសញ្ជឹងគិត
- បើសិន ការសម្តែងតួមិនដំណើរការតាមផែនការ សូមសួរសិស្សថាតើការសម្តែងតួនេះ អាចមានការកែលម្អ ឬ គួរមានការផ្លាស់ប្តូរដែរឬទេ។
- ដោយសារការសម្តែងតួយកលំនាំតាម ស្ថានភាព ឬ ព្រឹត្តិការណ៍ជីវិតជាក់ស្តែង, ពួកគេអាចលើកឡើងសំណួរផ្សេងៗ ដែលមានចម្លើយពិបាកឆ្លើយ។ គួរមានភាពកក់ក្តៅជាមួយ ការសម្តែងតួ និង ការងារជាមួយសិស្ស ក្នុងការស្វែងយល់ និង ក្នុងចម្លើយផ្ទាល់ខ្លួនរបស់ពួកគេ។
- សូមយល់ដឹង និង គោរពអារម្មណ៍និងរចនាសម្ព័ន្ធសង្គម នៃថ្នាក់រៀនរបស់អ្នក និង ប្រើការសម្តែងតួ ដោយយកចិត្តទុកដាក់អំពីអារម្មណ៍។

### ការបំផុសគំនិត (Brainstorming)

ការបំផុសគំនិតនេះ លើកទឹកចិត្តដល់ ការច្នៃប្រឌិត និង បង្កើតគំនិតច្រើនយ៉ាងរហ័ស។ ការបំផុសគំនិតនេះ អាចប្រើប្រាស់សម្រាប់ការដោះស្រាយបញ្ហា ឬ ឆ្លើយសំណួរទាំងអស់នោះបាន។

#### ព័ត៌មាន (Tips)

- សូមសម្រេចចិត្តលើបញ្ហាជាក់លាក់ ដែលអ្នកចង់ដោះស្រាយ និងរៀបចំជាសំណួរ។
- ស្នើសុំសិស្សឲ្យចូលរួមគំនិត។ ពួកគេអាចចូលរួមជាបុគ្គល, ជាគូ, ឬ ជាក្រុមតូច មុនពេលធ្វើរបាយការណ៍ជូនដល់ក្រុមទាំងមូល។
- សូមអនុញ្ញាតឲ្យមានការផ្លាស់ប្តូរគំនិត ដោយសេរី និង រលូន។ សូមកុំឲ្យសិស្សបង្អាក់គំនិតរបស់ពួកគេ។
- សូមស្វាគមន៍ ចំពោះការបញ្ចេញរាល់គំនិតទាំងអស់, ប៉ុន្តែ សិស្សមិនគួរលើកគំនិតដដែលៗ ដែលបានលើកឡើងរួចហើយ ឬ ផ្តល់យោបល់លើគំនិតផ្សេងៗ ចាំដល់ពេលចុងក្រោយ។
- មនុស្សម្នាក់ៗ គួរចូលរួមចំណែក។ ប៉ុន្តែ អនុញ្ញាតឲ្យសិស្សចូលរួមតាមសម្រួល តាមពេលវេលារបស់ពួកគាត់ មិនមែនតាមការបញ្ជាទេ។
- ស្នើឲ្យផ្តល់វិភាគទានដោយមានភាពថ្លា។ ប្រសិនបើសិស្សណាមិនយល់ សូមសួរជាសំណួរ។
- សូមសរសេរគំនិតថ្មីទាំងអស់ និង បញ្ឈប់នៅពេលអស់គំនិត។

### ការចោទសួរសំណួរ

ក្នុងការបង្កើតសំណួរដេញដោល និង ការយល់ដឹងអំពីបញ្ហាសិទ្ធិមនុស្ស, សូមរៀបចំសំណួរបើកចំហ និង លើកទឹកចិត្តដល់ការចូលរួមនិងការវិភាគ។

#### ព័ត៌មាន (Tips)

- សូមរៀបចំសំណួររបស់អ្នក ដើម្បីផ្លាស់ប្តូរសិស្សរបស់អ្នក ពីការគិត និង ការវិភាគកម្រិតទាបមកកម្រិតខ្ពស់។ ដូច្នេះហើយ អ្នកត្រូវកសាងជំនឿទុកចិត្តរបស់សិស្ស និង បង្កើនការយល់ដឹង អំពីបញ្ហាស្មុគស្មាញនានា។
- ប្រភេទសំណួរដែលត្រូវប្រើប្រាស់៖ មានសម្មតិកម្ម (ជាឧទាហរណ៍), ការស្ទង់មើល, ការលើកទឹកចិត្ត (ការគាំទ្រ), ការស្វែងរកគំនិតយោបល់, ការអង្កេត, ការបំភ្លឺ (ការសង្ខេប), និង ការកំណត់កិច្ចព្រមព្រៀង។

### ការគូរគំនូរ

ការគូរគំនូរ បង្កើតជំនាញស៊ើបអង្កេត, ការស្រមើស្រមៃ, និង ការយល់ចិត្ត ចំពោះមនុស្សនៅក្នុងរូបភាព។ គំនូរទាំងនេះ មានសារៈសំខាន់

នៅពេលបង្ហាត់បង្រៀន អំពីសិទ្ធិមនុស្ស ពីព្រោះថាកិច្ចការនេះ គេអាចតាំងពិព័រណ៍នៅក្នុងថ្នាក់រៀន និង សាលារៀនជាមូលដ្ឋានមួយ សម្រាប់ការឆ្លុះបញ្ចាំងនិងការពិភាក្សាបន្ថែម ក្នុងការប្រាស្រ័យទាក់ទងជាមួយតម្លៃ និង បញ្ហានៃសិទ្ធិមនុស្ស។

### ព័ត៌មាន (Tip)

សិល្បៈ គឺជាលក្ខណៈផ្ទាល់ខ្លួន ដែលយើងគួរគោរព និង ផ្តល់តម្លៃ។

### រូបភាព និង រូបថត

រូបភាព និង រូបថត អាចជាឧបករណ៍ដ៏មានប្រសិទ្ធភាព សម្រាប់ការបង្ហាត់បង្រៀនសិស្ស នៅក្នុងខណៈពេលយើងក្រឡេកមើលលើរូបអ្វីមួយ យើងអាចឃើញផ្សេងគ្នា ឬ យល់ផ្សេងគ្នា។

### ព័ត៌មាន (Tip)

រូបភាព និង រូបថត ចាប់ឱកាសក្នុងពេលវេលាមួយ ហើយសិស្សត្រូវគិតអំពីតួនាទីរបស់អ្នកថតរូបនិពន្ធ (photojournalists) នៅក្នុងការធ្វើសេចក្តីរាយការណ៍ និង ការរៀបចំឯកសារ អំពីបញ្ហាសិទ្ធិមនុស្សផ្សេងៗ។

### ប្រព័ន្ធព័ត៌មាន៖ គ្រប់ប្រព័ន្ធព័ត៌មានទាំងអស់

ប្រព័ន្ធព័ត៌មាន គឺជាសមាសធាតុដ៏សំខាន់មួយក្នុងសង្គមលទ្ធិប្រជាធិបតេយ្យ។ ម្យ៉ាងវិញទៀត ជាពិសេស ជាមួយការប្រើប្រាស់ អ៊ិនធឺណិត, គោលបំណងដែលធ្វើសេចក្តីរាយការណ៍ ឬ ក៏យល់ដឹង អំពីអ្វីដែលកំពុងរាយការណ៍ និង អ្វីដែលជាមតិយោបល់ គួរតែត្រូវបានបំភ្លឺយ៉ាងច្បាស់។

### ការធ្វើបទសម្ភាស

គម្រោង *សេចក្តីក្លាហានគ្មានព្រំដែន* មានមូលដ្ឋាននៅក្នុងការធ្វើបទសម្ភាស ជាមួយ អ្នកការពារសិទ្ធិមនុស្ស។ ការធ្វើបទសម្ភាសផ្តល់ ការសិក្សាស្រាវជ្រាវជាបឋមផ្ទាល់ខ្លួន និង ឱកាសរៀនសូត្រ។ ការធ្វើបទសម្ភាសនេះផងដែរ ផ្តល់ឱកាស ដើម្បីចែករំលែកនូវ អ្វីដែលសិស្សកំពុងរៀនសូត្រជាមួយ សាលារៀន និង ជុំវិញសហគមន៍។

### ព័ត៌មាន (Tip)

សូមចំណាយពេលវេលា សួរសំណួរជាមួយសិស្សម្នាក់ៗ។ ដោយពឹងផ្អែកលើបញ្ហា និង អ្នកដែលត្រូវធ្វើបទសម្ភាសនោះ, សូមប្រើពេលវេលានេះ ដើម្បីបង្ហាត់បង្រៀនមិនត្រឹមតែ អំពីដំណើរការសរសេរសំណួរប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងបញ្ហាសំខាន់ជាច្រើនទៀត អំពីការយល់អារម្មណ៍, ភាពទាក់ទិន និង ការទទួលខុសត្រូវ ចំពោះការទទួលបាននូវព័ត៌មានផ្ទាល់ខ្លួន។

### ការធ្វើបទបង្ហាញអំពីព័ត៌មាន

មធ្យោបាយដ៏ប្រសើរបំផុតមួយ ចំពោះការយល់ដឹង និង ការវិភាគព័ត៌មានពេលយើងយកវាមកធ្វើបទបង្ហាញដោយមានទ្រង់ទ្រាយប្លែកពីមុន។ ជាឧទាហរណ៍ ក្រោយពីបានរៀន អំពីពលកម្មកុមាររួចមក, សូមជម្រុញសិស្សឲ្យជ្រើសរើសយុទ្ធសាស្ត្រប្រសើរបំផុត ក្នុងការអប់រំអ្នកដទៃទៀត អំពីបញ្ហាទាំងនេះ។

### ព័ត៌មាន (Tips)

- សូមធ្វើការជាមួយសិស្ស ដើម្បីកំណត់ប្រភពដើមដំបូងនៃព័ត៌មានដែលទាក់ទងនឹងបញ្ហាទាំងនេះ។
- សូមផ្តល់វិធីសាស្ត្រមួយចំនួនដល់សិស្ស ដើម្បីណែនាំខ្លួន និង/ឬ អប់រំអ្នកដទៃទៀត អំពីបញ្ហាទាំងនេះ។ សូមលើកទឹកចិត្តសិស្សឲ្យចេះវិភាគទូលំទូលាយ ("think outside the box") ក្នុងការជ្រើសរើសវិធីសាស្ត្រផ្ទាល់របស់ពួកគេ។
- សូមផ្តល់ឱកាសដល់សិស្ស ដើម្បីផ្តល់ព័ត៌មានថ្មីៗ ដោយដេញដោលរកហេតុផលថា តើហេតុអ្វីវាមានសារៈសំខាន់។

វិធីសាស្ត្របន្ថែមទៀត រួមបញ្ចូល គម្រោង, កិច្ចពិភាក្សាក្រុមតូច និង កិច្ចពិភាក្សាក្នុងថ្នាក់។

## ការរៀនសូត្របន្ថែម៖

### តារាងកាលវិភាគ (កាលប្បវត្តិ, Timeline)

តារាងកាលវិភាគក្នុងគម្រោងនេះ គូសបញ្ជាក់ អំពីព្រឹត្តការណ៍សំខាន់ៗ, ខណៈពេលវេលាសំខាន់ៗ, ឬ ភាពជឿនលឿននៃសន្ទិសញ្ញា ស្តីពីសិទ្ធិមនុស្ស។ ក្នុងការពង្រីកចំណេះដឹងរបស់សិស្សនិស្សិត លើបញ្ហាជាក់លាក់, ចលនាសង្គម, ស្ថាប័នតំបន់ឬអន្តរជាតិ, សូមឲ្យសិស្សសិក្សាស្រាវជ្រាវលើប្រធានបទជាក់លាក់ បន្ទាប់មក សូមដាក់បញ្ចូលវាទៅក្នុងតារាងកាលវិភាគនៃសិទ្ធិមនុស្ស។

សំណួរពិភាក្សា ដែលទាក់ទងទៅនឹងតារាងកាលវិភាគ និង ការរៀនសូត្រដែលត្រូវបន្ត៖

១. អ្វីដែលអ្នកដឹងច្បាស់? អ្វីដែលជារបស់ថ្មី? អ្វីដែលធ្វើឲ្យអ្នកភ្ញាក់ផ្អើល?

២. គួរមានអ្វីផ្សេងទៀតសម្រាប់ដាក់ក្នុងតារាងកាលវិភាគនេះ?

៣. អ្វីដែលអ្នកបានកត់សម្គាល់ទាក់ទងនឹងការវិវត្ត នៃសិទ្ធិមនុស្សដូចដែលបានដាក់ចេញនៅក្នុងតារាងកាលវិភាគនេះ?

៤. ប្រធានបទដែលអ្នកស្រាវជ្រាវបានលើកឡើងលើកដំបូង ក្នុងការវិវត្តសិទ្ធិមនុស្សនៅពេលណា?

៥. តើអ្នកគិតថា វាគួរតែត្រូវបានលើកឡើងនៅពេលណា? ហើយមូលហេតុអ្វី?

៦. តើអនាគតនៃសិទ្ធិមនុស្សមើលទៅដូចម្តេច? តើអ្នកចង់ឃើញសន្ទិសញ្ញា ឬ ព្រឹត្តការណ៍ណាខ្លះ គួរកើតឡើងនៅក្នុងរយៈពេល ១០ឆ្នាំខាងមុខនេះ?

"FEW ARE WILLING TO BRAVE THE DISAPPROVAL OF THEIR FELLOWS, THE CENSURE OF THEIR COLLEAGUES, THE WRATH OF THEIR SOCIETY. MORAL COURAGE IS A RARER COMMODITY THAN BRAVERY IN BATTLE OR GREAT INTELLIGENCE. YET IT IS THE ONE ESSENTIAL, VITAL QUALITY OF THOSE WHO SEEK TO CHANGE A WORLD WHICH YIELDS MOST PAINFULLY TO CHANGE. AND THOSE WITH THE COURAGE TO ENTER THE MORAL CONFLICT WILL FIND THEMSELVES WITH COMPANIONS IN EVERY CORNER OF THE GLOBE."

— ROBERT F. KENNEDY



## * កាលប្បវត្តិវិជ្ជានៃសិទ្ធិមនុស្ស (Chronology of Human Rights)

**C.២១០០ B.C.** មានន័យថា ២១០០ឆ្នាំមុនកំណើត ព្រះគ្រិស្ត

នៅប្រទេសអ៊ីរ៉ាក់ (Iraq), ច្បាប់ហាមូរ៉ាប៊ី (Laws of Hammurabi) គឺជាក្រមច្បាប់ បានសរសេរជាលាយល័ក្ខអក្សរ មុនដំបូងគេបង្អស់, អះអាង "ធ្វើឲ្យយុត្តិធម៌ សោយរាជ្យ ក្នុងព្រះរាជាណាចក្រ, បំផ្លាញអ្នកអាក្រក់ និងឃោរឃៅ, បំភ្លឺប្រទេសជាតិ និង លើកកម្ពស់សេចក្តីល្អ របស់មនុស្ស"។

**C.៥៧០ B.C.** មានន័យថា ៥៧០ឆ្នាំមុនកំណើត ព្រះគ្រិស្ត

ធម្មនុញ្ញនៃព្រះមហាក្សត្រ ស៊ីរ៉ាស់ (Charter of Cyrus) ត្រូវបានបង្កើតឡើងដោយព្រះមហាក្សត្រ ស៊ីរ៉ាស់ ដ៏ ឧត្តុងឧត្តម (King of Persia, Cyrus the Great) ពីប្រទេស ផើសហ្ស៊ី (Persia) ឥឡូវនេះ ជាប្រទេស អ៊ីរ៉ាន (Iran) សម្រាប់ប្រជាពលរដ្ឋ នៃ ព្រះរាជាណាចក្ររបស់ព្រះអង្គ ដោយទទួលស្គាល់នូវ សិទ្ធិសេរីភាព, សិទ្ធិសុវត្ថិភាព, សិទ្ធិធ្វើដំណើរ, សិទ្ធិផ្តល់កម្មសិទ្ធិមាន ទ្រព្យសម្បត្តិ, និង សិទ្ធិសេដ្ឋកិច្ចនិងសង្គមកិច្ច។

# តើសិទ្ធិមនុស្សគឺជាអ្វី ?

សិទ្ធិមនុស្ស គឺជាសិទ្ធិ ដែលមនុស្សមានពីធម្មជាតិ ពីព្រោះថា គេជាមនុស្ស។ មនុស្សគ្រប់រូបមានសិទ្ធិមនុស្ស ដោយស្មើភាពគ្នា, ជាសកល និង ជារៀងនិរន្តរ៍។ សិទ្ធិមនុស្ស គឺជាសិទ្ធិ ដែលមិនអាចដកហូតយកបាន៖ អ្នកមិនអាចបាត់បង់សិទ្ធិទាំងនេះណាមួយ ដូចដែលអ្នកមិនអាចបាត់បង់ភាពជាមនុស្ស។ សិទ្ធិមនុស្ស គឺជាសិទ្ធិមិនអាចបែងចែកបាន៖ គ្មាននរណាអាចបដិសេធសិទ្ធិរបស់អ្នកទេ ព្រោះថា សិទ្ធិនេះ "គឺមិនសូវសំខាន់" ឬ "មិនចាំបាច់"។ សិទ្ធិមនុស្ស គឺជាសិទ្ធិអាស្រ័យគ្នាទៅវិញទៅមក៖ សិទ្ធិមនុស្សទាំងអស់នេះ គឺជាផ្នែកមួយ នៃក្របខ័ណ្ឌពាក់ព័ន្ធ។ ជាឧទាហរណ៍ សមត្ថភាពរបស់អ្នក ចំពោះការចូលរួម នៅក្នុងរដ្ឋាភិបាលតម្រូវឲ្យអ្នកមានសិទ្ធិបញ្ចេញមតិយោបល់, សិទ្ធិទទួលបាននូវការអប់រំ, និង សិទ្ធិទទួលបាននូវតម្រូវការចាំបាច់សម្រាប់ជីវិត។

ការរំលោភសិទ្ធិមនុស្សរបស់បុគ្គលណាម្នាក់ គឺជាការប្រព្រឹត្តចំពោះបុគ្គលនោះ ដោយគ្មានសេចក្តីថ្លៃថ្នូរ ដូចគេមិនមែនជាមនុស្ស។ ការតស៊ូមតិឲ្យមាន សិទ្ធិមនុស្ស គឺជាការទាមទារឲ្យគេគោរពសេចក្តីថ្លៃថ្នូររបស់មនុស្សទាំងអស់គ្នា។ ក្នុងការទាមទារសិទ្ធិមនុស្សទាំងអស់នេះ, មនុស្សគ្រប់រូបទទួលស្គាល់នូវ ការទទួលខុសត្រូវ មិនរំលោភសិទ្ធិរបស់អ្នកដទៃ និង គាំទ្របុគ្គលទាំងនោះ ដែលសិទ្ធិរបស់ពួកគេ ត្រូវបានគេរំលោភ និង បដិសេធ។

សិទ្ធិមនុស្សមាន ភាពជាការលើកទឹកចិត្ត និង ភាពជាក់ស្តែង។ គោលការណ៍សិទ្ធិមនុស្ស ប្រកាន់ខ្ជាប់នូវទស្សនៈវិស័យ នៃពិភពលោកមួយ ដោយមាន សេរីភាព, យុត្តិធម៌ និង សន្តិភាព, ហើយ កំណត់បទដ្ឋានអប្បបរមា ចំពោះនីតិវិធី ដែលបុគ្គលម្នាក់ៗ និង ស្ថាប័ននីមួយៗ គួរប្រព្រឹត្តចំពោះមនុស្សគ្រប់ទីកន្លែង។

សិទ្ធិមនុស្ស បានផ្តល់សិទ្ធិអំណាចដល់មនុស្សក្នុងក្របខ័ណ្ឌមួយសម្រាប់សកម្មភាព ក្នុងពេលដែលគេមិនបំពេញបទដ្ឋានអប្បបរមានោះ ព្រោះថា មនុស្សនៅតែមានសិទ្ធិ ទោះបីច្បាប់ ឬ អ្នកមានអំណាច មិនទទួលស្គាល់ឬការពារនូវសិទ្ធិទាំងនោះក៏ដោយ។

យើងពិសោធមើលសិទ្ធិមនុស្សរបស់យើងរៀងរាល់ថ្ងៃ នៅពេលដែលយើងគោរព យោងតាមជំនឿរបស់យើង ឬ យើងជ្រើសរើសមិនមានជំនឿ។ នៅពេលដែលយើង ពិភាក្សា និង រិះគន់លើគោលនយោបាយរបស់រដ្ឋាភិបាល។ នៅពេលដែលយើងចូលរួមសហជីពពាណិជ្ជកម្ម។ នៅពេលដែលយើងធ្វើដំណើរទៅកាន់តំបន់ដទៃទៀតនៃប្រទេស ឬ ឯនាយសមុទ្រ។ ទោះបីយើងយល់សកម្មភាពទាំងអស់នេះថា ជាការត្រឹមត្រូវ, មនុស្សនៅក្នុងប្រទេសក្តី និង ក្រៅប្រទេសក្តី មិនមានការទទួលសេរីភាពបែបនេះដោយស្មើភាពគ្នាទេ។ ការរំលោភសិទ្ធិមនុស្សកើតឡើងនៅពេលដែលឪពុកម្តាយ រំលោភលើកូន, នៅពេលដែលគ្រួសារមួយគ្មានផ្ទះសម្បែង, នៅពេលដែលសាលារៀនផ្តល់ការអប់រំមិនគ្រប់គ្រាន់, នៅពេលដែលស្ត្រីត្រូវបានគេបង់ប្រាក់ឲ្យតិចជាងបុរស, ឬ នៅពេលដែលមនុស្សម្នាក់លួចរបស់ពីនរណាម្នាក់។ សិទ្ធិមនុស្សគឺជាបញ្ហាប្រចាំថ្ងៃ។



ចន ហ៊ែសហ្វឺណិន (John Heffernan), លោកស្រី វេជ្ជបណ្ឌិត ពុង ឈីវហ្គេច, ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ឃែរ៉ល រ៉ាឌលី (Carol Rodley), ឯកឧត្តម បណ្ឌិត កុល ផេង, ឯកឧត្តម ឱម យិនទៀង, លោកស្រី ឃៃរីខិណ្ឌិឌី, អ្នកនាង សេង ធារី, លោកឪពុក ចន វ៉េស័រ (John Visser) នៅទីក្រុងភ្នំពេញ ខែកុម្ភៈ ឆ្នាំ២០១១។

**១២១៥**

មកពី ការសម្ពាធពី ប្រជាពលរដ្ឋ, ព្រះមហាក្សត្រ ចន នៃប្រទេសអង់គ្លេស (King John of England) ចុះហត្ថលេខា លើច្បាប់ មែកណា ខាតា (Magna Carta) ដែលបង្កើតការដាក់កម្រិតលើ អំណាច ពីសិទ្ធិតាមអំពើចិត្ត ទៅនីតិវិធីច្បាប់។

**១៦៤៨**

សន្ធិសញ្ញាវែសហ្វៃលីយ៉ា (Treaty of Westphalia) នៅប្រទេសអាល្លឺម៉ង់ ជា សន្ធិសញ្ញាអន្តរជាតិច្បាប់មានពីមុនមក, បង្កើតសមភាពសិទ្ធិរវាង សាសនាគ្រិស្តផ្នែកកាតូលិក (Catholics) និង ផ្នែកប្រូតេស្តង់ (Protestants)។

**១៦៧៩**

ច្បាប់តម្រូវឲ្យមានវត្តមាន (Habeas Corpus Act) នៅប្រទេសអង់គ្លេស ផ្តល់សិទ្ធិ ទទួលបានការកាត់ក្តីដោយ យុត្តិធម៌ ក្នុងរយៈពេលពិតប្រាកដមួយឲ្យនរណាម្នាក់ជាប់ឃុំឃាំង។

# សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (សង្ខេប)

ABRREVIATED VERSION OF THE UNIVERSAL DECLARATION OF HUMAN RIGHTS

មាត្រា១៖ សិទ្ធិស្មើភាពគ្នា / សិទ្ធិសេរីភាពស្មើគ្នា
មាត្រា២៖ សេរីភាពរួចផុតពីការរើសអើង អំពីពូជសាសន៍, ពណ៌សម្បុរ, ភេទ, ភាសា និង សាសនា
មាត្រា៣៖ សិទ្ធិរស់រានមានជីវិត, សេរីភាព និង សន្តិសុខផ្ទាល់ខ្លួន
មាត្រា៤៖ សេរីភាពរួចផុតពីទាសភាព
មាត្រា៥៖ សេរីភាពរួចផុតពីទារុណកម្ម, ទណ្ឌកម្ម ឬ ប្រព្រឹត្តកម្ម
មាត្រា ៦៖ សិទ្ធិទទួលស្គាល់ពីបុគ្គលិកលក្ខណៈគតិយុត្តរបស់ខ្លួន នៅចំពោះមុខច្បាប់
មាត្រា ៧៖ សិទ្ធិស្មើគ្នាចំពោះមុខច្បាប់
មាត្រា ៨៖ សិទ្ធិរកដំណោះស្រាយជាក់ស្តែងនៅចំពោះមុខសាលាជម្រះក្តី
មាត្រា ៩៖ សេរីភាពរួចផុតពីការចាប់ខ្លួន ឃុំខ្លួន ឬ និរទេសខ្លួន
មាត្រា ១០៖ សិទ្ធិស្មើភាពគ្នាចំពោះការស្តាប់ជាសាធារណៈ
មាត្រា ១១៖ សិទ្ធិក្នុងការពិចារណាថា គ្មានទោសរហូតដល់ពិរុទ្ធភាពត្រូវបានរកឃើញ
មាត្រា ១២៖ សេរីភាពរួចផុតពីការរំលោភជ្រៀតជ្រែកតាមអំពើចិត្តក្នុង ជីវិតឯកជន, គ្រួសារ, ទីលំនៅ និង ការឆ្លើយឆ្លង
មាត្រា ១៣៖ សិទ្ធិធ្វើដំណើរដោយសេរី ទាំងក្នុង និង ក្រៅប្រទេស
មាត្រា ១៤៖ សិទ្ធិស្វែងរក និង ទទួលកន្លែងជ្រកកោនក្នុងប្រទេសដទៃទៀតក្នុងករណីមានការធ្វើទុក្ខបុកម្នេញ
មាត្រា ១៥៖ សិទ្ធិទទួលបានសញ្ជាតិ និង សេរីភាពក្នុងការផ្លាស់ប្តូរសញ្ជាតិ
មាត្រា ១៦៖ សិទ្ធិរៀបអាពាហ៍ពិពាហ៍ និង កសាងគ្រួសារ
មាត្រា ១៧៖ សិទ្ធិជាម្ចាស់កម្មសិទ្ធិ
មាត្រា ១៨៖ សិទ្ធិសេរីភាព ខាងជំនឿ និង សាសនា
មាត្រា ១៩៖ សិទ្ធិសេរីភាព ក្នុងការសម្តែងមតិ និង ព័ត៌មាន
មាត្រា ២០៖ សិទ្ធិសេរីភាព ក្នុងការប្រជុំ ឬ ការបង្កើតសមាគមដោយសន្តិវិធី
មាត្រា ២១៖ សិទ្ធិចូលរួមក្រុមអ្នកគ្រប់គ្រង និង បោះឆ្នោតដោយសេរី
មាត្រា ២២៖ សិទ្ធិទទួលបានសន្តិសុខសង្គម
មាត្រា ២៣៖ សិទ្ធិធ្វើការងារ ក្នុងល័ក្ខខ័ណ្ឌត្រឹមត្រូវ និង ការចូលរួមសហភាពពាណិជ្ជកម្ម
មាត្រា ២៤៖ សិទ្ធិឈប់សម្រាក និង លំហែកំសាន្ត
មាត្រា ២៥៖ សិទ្ធិទទួលបានកម្រិតជីវភាពរស់នៅស្របតាមមាត្រដ្ឋាន
មាត្រា ២៦៖ សិទ្ធិទទួលបានការអប់រំ
មាត្រា ២៧៖ សិទ្ធិចូលរួមដោយសេរីក្នុងជីវភាពវប្បធម៌របស់សហគមន៍
មាត្រា ២៨៖ សិទ្ធិចូលរួមគ្រប់គ្រងសណ្តាប់ធ្នាប់សង្គមដែលចែងក្នុងសេចក្តីប្រកាសនេះ
មាត្រា ២៩៖ សិទ្ធិមានករណីកិច្ច ចំពោះសហគមន៍ ដែលជាកន្លែងតែមួយគត់អាចបង្កើតបានការរីកចម្រើនដោយសេរី
មាត្រា ៣០៖ សិទ្ធិសេរីភាពពីការបំផ្លិចបំផ្លាញដោយរដ្ឋ ឬ បុគ្គលណាម្នាក់លើសិទ្ធិដែលមានចែងនៅក្នុងសេចក្តីប្រកាសនេះ

**១៦៨៩**
កម្រងសិទ្ធិឯកត្តជន (Bill of Rights) របស់ប្រទេសអង់គ្លេស តម្កល់ឧត្តមភាព នៃសភា លើ ព្រះមហាក្សត្រ, និង ផ្តល់ សេរីភាព ក្នុងការបញ្ចេញមតិ, សិទ្ធិបង់ប្រាក់ធានា, សេរីភាពរួចផុតពីការធ្វើទារុណកម្ម, ការបោះឆ្នោតសេរី និង ការកាត់ក្តីដោយតុលាការ។

**១៧៨៩**
សេចក្តីប្រកាសរបស់ ប្រទេសបារាំង ស្តីពីសិទ្ធិមនុស្ស និង សិទ្ធិពលរដ្ឋ (French Declaration of the Rights of Man and Citizens) ត្រូវបានបង្កើតឡើង នៅពេលដែលមហាក្សត្ររបស់ ប្រទេសបារាំង ត្រូវបានផ្តួលរំលំដោយប្រជាពលរដ្ឋ។

**១៧៩១**
កម្រងសិទ្ធិឯកត្តជន (Bill of Rights) និង រដ្ឋធម្មនុញ្ញ (Constitution) របស់អាមេរិកកាំង ចុះបញ្ជីសិទ្ធិស៊ីវិលនិង សិទ្ធិនយោបាយជាមូលដ្ឋានរបស់ប្រជាពលរដ្ឋ, រួមបញ្ចូលទាំងសេរីភាពក្នុងការបញ្ចេញមតិ និង នីតិរដ្ឋ។

# សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស

## សកបរិវត្តន៍សាមញ្ញ (Simplified Version)

### មាត្រា ១

មនុស្សទាំងអស់កើតមកមានសេរីភាព និង សមភាពក្នុងផ្នែកសេចក្ដីថ្លៃថ្នូរ និង សិទ្ធិ។ មនុស្សមានវិចារណញ្ញាណ និង សតិសម្បជញ្ញៈ ជាប់ពីកំណើត ហើយគប្បីប្រព្រឹត្តចំពោះគ្នាទៅវិញទៅមកក្នុងស្មារតីភាពជាបងប្អូន។

### មាត្រា ២

មនុស្សម្នាក់ៗអាចប្រើប្រាស់សិទ្ធិ និង សេរីភាពទាំងអស់ ដែលបានប្រកាសក្នុងសេចក្ដីប្រកាសនេះ ដោយគ្មានការប្រកាន់បែងចែកបែបណាមួយ មានជាអាទិ៍ ពូជសាសន៍, ពណ៌សម្បុរ, ភេទ, ភាសា, សាសនា, មតិនយោបាយឬមតិផ្សេងៗទៀត ដើមកំណើតជាតិឬសង្គម, ទ្រព្យសម្បត្តិ, កំណើតឬស្ថានភាពដទៃៗផ្សេងទៀតឡើយ។

### មាត្រា ៣

បុគ្គលម្នាក់ៗ មានសិទ្ធិរស់រានមានជីវិត, សេរីភាព និង សន្តិសុខផ្ទាល់ខ្លួន។

### មាត្រា ៤

គ្មានជនណាម្នាក់ត្រូវស្ថិតក្នុងទាសភាព ឬស្ថិតក្នុងភាពជាអ្នកបម្រើដាច់ថ្លៃឡើយ។ ទាសភាព និង ទាសពាណិជ្ជកម្មត្រូវហាមឃាត់ ទោះតាមទម្រង់ណាក៏ដោយ។

### មាត្រា ៥

គ្មានជនណាម្នាក់ត្រូវទទួលទារុណកម្ម, ទណ្ឌកម្ម ឬ ប្រព្រឹត្តកម្មកាចសាហាវឥតមនុស្សធម៌ ឬ ថោកទាបបានឡើយ។

### មាត្រា ៦

មនុស្សម្នាក់ៗ មានសិទ្ធិឲ្យទទួលស្គាល់ពីបុគ្គលិកលក្ខណៈគតិយុត្តរបស់ខ្លួននៅគ្រប់ទីកន្លែង។

### មាត្រា ៧

មនុស្សគ្រប់រូប មានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ និងមានសិទ្ធិទទួលការការពារ ពីច្បាប់ស្មើៗគ្នា ដោយគ្មានការរើសអើង។ មនុស្សគ្រប់រូប មានសិទ្ធិទទួលការការពារស្មើៗគ្នា ប្រឆាំងនឹងការរើសអើងណា ដែលរំលោភលើសេចក្ដីប្រកាសនេះ ព្រមទាំងប្រឆាំងនឹងការញុះញង់ឲ្យមានការរើសអើង ។

### មាត្រា ៨

មនុស្សគ្រប់រូប មានសិទ្ធិរកដំណោះស្រាយជាក់ស្ដែងមួយ នៅចំពោះមុខសាលាជម្រះក្ដីជាតិ ដែលមានសមត្ថកិច្ចចំពោះអំពើទាំងឡាយណា ដែលរំលោភសិទ្ធិមូលដ្ឋានរបស់ខ្លួន ដែលត្រូវបានទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញ ឬ ដោយច្បាប់ ។

### មាត្រា ៩

គ្មានជនណាម្នាក់ ត្រូវបានចាប់ខ្លួន ឃុំខ្លួន ឬ និរទេសខ្លួនដោយបំពានឡើយ។

### មាត្រា ១០

មនុស្សគ្រប់រូប មានសិទ្ធិស្មើគ្នាពេញលេញ សុំឲ្យតុលាការឯករាជ្យ និង មិនលំអៀង ពិនិត្យរឿងក្ដីរបស់ខ្លួនជាសាធារណៈ និង ដោយសមធម៌ ដើម្បីសម្រេចលើសិទ្ធិកាតព្វកិច្ច និង ភាពសមហេតុផលចំពោះការចោទប្រកាន់ទាំងឡាយខាងបទព្រហ្មទណ្ឌ។

### មាត្រា ១១

១. ជនណាដែលជាប់ចោទពីបទល្មើសព្រហ្មទណ្ឌ ត្រូវសន្មត់ជាជនគ្មានទោស រហូតដល់ពិរុទ្ធភាព ត្រូវបានរកឃើញនៅក្នុងសវនាការជាសាធារណៈ ដែលមានការធានាចាំបាច់ ដើម្បីការពារសិទ្ធិជនជាប់ចោទពីបទល្មើសព្រហ្មទណ្ឌ។

២. គ្មានជនណាម្នាក់ត្រូវបានផ្ដន្ទាទោស ពីបទល្មើសព្រហ្មទណ្ឌ ដោយបានប្រព្រឹត្ត ឬ ភ្លាំងភ្លាត់ប្រព្រឹត្ត ដែលអំពើនេះមិនបានចែងក្នុងច្បាប់ជាតិ ឬ អន្តរជាតិ ។ មិនត្រូវផ្ដន្ទាទោសឲ្យធ្ងន់ជាងទោស ដែលបានកំណត់ឲ្យអនុវត្តន៍ក្នុងអំឡុងពេលបទល្មើសបានកើតឡើងឡើយ ។

### មាត្រា ១២

គ្មានមនុស្សណាម្នាក់ ត្រូវរងការរំលោភជ្រៀតជ្រែកតាមអំពើចិត្ត ក្នុងជីវិតឯកជន គ្រួសារ ទីលំនៅ ការឆ្លើយឆ្លង ឬ ការធ្វើឲ្យប៉ះពាល់កិត្តិយស និង កេរ្ដិ៍ឈ្មោះរបស់ខ្លួនបានឡើយ។ ជនគ្រប់រូប មានសិទ្ធិទទួលការការពារពីច្បាប់ប្រឆាំងនឹងការជ្រៀតជ្រែក ឬ ការប៉ះពាល់ទាំងនេះ។

### មាត្រា ១៣

១. មនុស្សគ្រប់រូបមានសិទ្ធិធ្វើដំណើរដោយសេរី និង មានសិទ្ធិជ្រើសរើសនិវេសនដ្ឋានក្នុងរដ្ឋមួយ។

**១៨៦៣**

កម្ពុជា ស្ថិតក្រោមអាណានិគមនិយមបារាំង។

**១៨៦៤**

អនុសញ្ញាស្ដីពី សុវឌ្ឍនកម្មនៃលក្ខន្តិកៈ កងទ័ពនៅក្នុងសមរភូមិ (Convention for the Amelioration of the Condition of Armies) គឺជាអនុសញ្ញាហ្សឺណែវទីមួយ (First Geneva Convention), ជាសន្ធិសញ្ញា អន្តរជាតិរបស់ គណៈកម្មការកាកបាទក្រហម អន្តរជាតិ (International Committee of the Red Cross), ការពារជនដែលរងរបួស និង មានជម្ងឺ ដោយសារសង្គ្រាម, និង ផ្ដល់អភ័យឯកសិទ្ធិដល់បុគ្គលិកមន្ទីរពេទ្យនិងកាកបាទក្រហម។

២. មនុស្សគ្រប់រូប មានសិទ្ធិចាកចេញពីប្រទេសណាមួយរួមទាំងប្រទេសរបស់ខ្លួនផង និង មានសិទ្ធិវិលត្រលប់មកប្រទេសរបស់ខ្លួនវិញ។

## មាត្រា ១៤

១. មនុស្សគ្រប់រូបមានសិទ្ធិស្វែងរក និង ទទួលកន្លែងជ្រកកោនក្នុងប្រទេសដទៃទៀត ក្នុងករណីមានការធ្វើទុក្ខបុកម្នេញមកលើខ្លួន។

២. សិទ្ធិសុំជ្រកកោននេះមិនអាចលើកមកសម្អាងបានទេ ក្នុងករណីមានការចោទប្រកាន់ពីបទល្មើស នៃនីតិរួម ឬ ពីការប្រព្រឹត្តណាដែលផ្ទុយពីគោលបំណង និង គោលការណ៍ទាំងឡាយរបស់សហប្រជាជាតិ ។

## មាត្រា ១៥

១. មនុស្សគ្រប់រូបមានសិទ្ធិទទួលបានសញ្ជាតិមួយ។

២. គ្មានជនណាម្នាក់អាចត្រូវដកហូតសញ្ជាតិ ឬរារាំងសិទ្ធិប្តូរសញ្ជាតិរបស់ខ្លួន ដោយរំលោភបានឡើយ ។

## មាត្រា ១៦

១. បុរសនិងស្ត្រី មានសិទ្ធិរៀបអាពាហ៍ពិពាហ៍ និង កសាងគ្រួសារដោយមិនប្រកាន់ពូជសាសន៍ សញ្ជាតិ ឬ សាសនាឡើយ ។ បុរសនិងស្ត្រីមានសិទ្ធិស្មើគ្នាក្នុងការរៀបអាពាហ៍ពិពាហ៍ក្នុងចំណងអាពាហ៍ពិពាហ៍ និង ក្នុងពេលរំលាយអាពាហ៍ពិពាហ៍ ។

២. អាពាហ៍ពិពាហ៍អាចប្រព្រឹត្តទៅបាន លុះត្រាតែមានការព្រមព្រៀងដោយសេរី និង ពេញលេញពីអនាគតគូស្វាមីភរិយា។

៣. គ្រួសារជាធាតុធម្មជាតិ និងជាធាតុមូលដ្ឋានរបស់សង្គម ហើយគ្រួសារមានសិទ្ធិទទួលការការពារពីសង្គម និង រដ្ឋ។

## មាត្រា ១៧

១. មនុស្សគ្រប់រូប ទោះជាបុគ្គលក្តី សមូហភាពក្តី មានសិទ្ធិជាម្ចាស់កម្មសិទ្ធិ ។

២. គ្មានជនណាម្នាក់ត្រូវបានដកហូតកម្មសិទ្ធិដោយបំពានឡើយ ។

## មាត្រា ១៨

មនុស្សគ្រប់រូប មានសិទ្ធិសេរីភាពខាងការគិត សតិសម្បជញ្ញៈ និង សាសនា ។ សិទ្ធិនេះរាប់បញ្ចូលទាំងសេរីភាពផ្លាស់ប្តូរសាសនា ឬ ជំនឿ ព្រមទាំងសេរីភាពសម្តែងសាសនា ឬ ជំនឿរបស់ខ្លួនតែម្នាក់ឯង ឬ ជារួម ជាសាធារណៈ ឬ ជាឯកជន តាមការបង្ហាត់បង្រៀន ការអនុវត្តជាទម្លាប់គោរពបូជា ព្រមទាំងតាមការប្រារព្ធពិធីសក្ការៈផ្សេងៗ។

## មាត្រា ១៩

មនុស្សគ្រប់រូប មានសិទ្ធិសេរីភាពក្នុងការមានមតិ និង ការសម្តែងមតិ។ សិទ្ធិនេះរាប់បញ្ចូលទាំង សេរីភាពក្នុងការប្រកាន់មតិដោយគ្មានការជ្រៀតជ្រែក និង សេរីភាពក្នុងការស្វែងរកការទទួល និង ការផ្សព្វផ្សាយព័ត៌មាន និងគំនិតនានាដោយគ្មានព្រំដែន ទោះតាមរយៈមធ្យោបាយសម្តែងមតិណាមួយក៏ដោយ។

## មាត្រា ២០

១. មនុស្សគ្រប់រូប មានសិទ្ធិសេរីភាពក្នុងការប្រជុំ ឬ ការបង្កើតសមាគមដោយសន្តិវិធី។

២. គ្មានជនណាម្នាក់ត្រូវបានបង្ខិតបង្ខំឲ្យចូលរួមក្នុងសមាគមណាមួយឡើយ។

## មាត្រា ២១

១. មនុស្សគ្រប់រូប មានសិទ្ធិចូលរួមក្នុងការដឹកនាំកិច្ចការសាធារណៈនៃប្រទេសរបស់ខ្លួនដោយផ្ទាល់ ឬ តាមរយៈតំណាងដែលបានជ្រើសរើសដោយសេរី។

២. មនុស្សគ្រប់រូបមានសិទ្ធិចូលបម្រើមុខងារសាធារណៈ នៃប្រទេសរបស់ខ្លួនក្នុងល័ក្ខខ័ណ្ឌសមភាព។

៣. ឆន្ទៈរបស់ប្រជាពលរដ្ឋ ជាមូលដ្ឋានអំណាចនៃការដឹកនាំកិច្ចការសាធារណៈ។ ឆន្ទៈនេះត្រូវសម្តែងចេញតាមរយៈ ការបោះឆ្នោតយ៉ាងទៀងទាត់ តាមពេលកំណត់ និង ពិតប្រាកដមានលក្ខណៈសកល ស្មើភាព និង បោះឆ្នោតដោយសម្ងាត់ ឬ តាមនីតិវិធីសមមូល ដែលធានាសេរីភាពនៃការបោះឆ្នោត។

## មាត្រា ២២

ក្នុងឋានៈជាសមាជិកនៃសង្គមមនុស្សគ្រប់រូប មានសិទ្ធិទទួលបានសន្តិសុខសង្គម និង មានបុព្វសិទ្ធិទទួលបានសិទ្ធិខាង សេដ្ឋកិច្ច, សង្គមកិច្ច និង វប្បធម៌ ដែលចាំបាច់សម្រាប់សេចក្តីថ្លៃថ្នូរ និង ការរីកចម្រើនដោយសេរីភាពនៃបុគ្គលិកលក្ខណៈរបស់ខ្លួន តាមរយៈការខិតខំរបស់ជាតិ និង កិច្ចសហប្រតិបត្តិការអន្តរជាតិ ស្របតាម

**១៨៩៩ ដល់ ១៩០៧**

អនុសញ្ញាក្រុងឡាអេ (The Hague Conventions) មួយចំនួន ត្រូវបានធ្វើសេចក្តីព្រាង, ដោយបង្កើតច្បាប់មនុស្សធម៌អន្តរជាតិសម្រាប់ ថែទាំមើលខុសត្រូវលើជនស៊ីវិល, អ្នកទោសសង្គ្រាម និង ជនរងរបួសដោយសង្គ្រាម។

**១៩១៩**

សន្ធិសញ្ញាវែកសាយ (Treaty of Versailles) បានបង្កើតសហព័ន្ធប្រជាជាតិ (League of Nations) និង អង្គការពលកម្ម អន្តរជាតិ (International Labor Organization) ដើម្បីកែលម្អ ល័ក្ខខ័ណ្ឌការងារ និង លើកកម្ពស់យុត្តិធម៌សង្គម។

**១៩៤១**

ព្រះអង្គម្ចាស់ នរោត្តម សីហនុ សោយរាជ្យជាព្រះមហាក្សត្រ។ កម្ពុជាបានគ្រប់គ្រងដោយប្រទេសជប៉ុន ក្នុងសង្គ្រាមលោក លើកទី២។

ការរៀបចំ និង តាមធនធានរបស់ប្រទេសនីមួយៗ។

## មាត្រា ២៣

១. មនុស្សគ្រប់រូប មានសិទ្ធិធ្វើការងារ, ជ្រើសរើសការងារដោយសេរី និង ធ្វើការងារក្នុងល័ក្ខខ័ណ្ឌត្រឹមត្រូវ និង ពេញចិត្ត ព្រមទាំងការពារប្រឆាំងនឹងភាពអត់ការងារធ្វើ។
២. មនុស្សគ្រប់រូបមានសិទ្ធិទទួលប្រាក់បៀវត្សរ៍ស្មើៗគ្នាចំពោះការងារដូចគ្នា ដោយគ្មានការរើសអើង។
៣. អ្នកធ្វើការងារមានសិទ្ធិទទួលបានលាភការដោយសមធម៌ និង ពេញចិត្ត ដើម្បីធានាអត្ថិភាពរស់នៅរបស់ខ្លួន និង គ្រួសារឲ្យសមស្របនឹងសេចក្តីថ្លៃថ្នូរនៃមនុស្ស និង ត្រូវបានបំពេញបន្ថែមទៀត តាមមធ្យោបាយផ្សេងៗនៃការការពារផ្នែកសង្គមប្រសិនបើចាំបាច់។
៤. មនុស្សគ្រប់រូប មានសិទ្ធិបង្កើត និង ចូលរួមសហជីពដើម្បីការពារផលប្រយោជន៍របស់ខ្លួន។

## មាត្រា ២៤

មនុស្សគ្រប់រូប មានសិទ្ធិឈប់សម្រាក និង លំហែកំសាន្ត រួមបញ្ចូលទាំងកម្រិតម៉ោងការងារ សមហេតុផល និង ការឈប់សម្រាកដោយ បានប្រាក់បៀវត្សរ៍តាមពេលកំណត់។

## មាត្រា ២៥

១. មនុស្សគ្រប់រូប មានសិទ្ធិទទួលបានកម្រិតជីវភាពគ្រប់គ្រាន់ ដើម្បីធានាសុខភាព និង សុខុមាលភាពរបស់ខ្លួន និង គ្រួសាររួមមានចំណីអាហារ, សំលៀកបំពាក់, លំនៅដ្ឋាន, ការថែទាំសុខភាព និង សេវាសង្គមកិច្ចចាំបាច់ផ្សេងៗទៀត។ មនុស្សគ្រប់រូបមានសិទ្ធិទទួលបានការគាំពារនៅពេលគ្មានការងារធ្វើ, មានជម្ងឺ, ពិការ, មេម៉ាយឬពោះម៉ាយ, ចាស់ជរាឬនៅពេលបាត់បង់មធ្យោបាយធានាជីវភាព ដែលបណ្តាលមកពីកាលៈទេសៈផុតពីឆន្ទៈរបស់ខ្លួន។

## មាត្រា ២៦

១. មនុស្សគ្រប់រូប មានសិទ្ធិទទួលបានការអប់រំ។ ការអប់រំត្រូវតែតបង់ថ្លៃ យ៉ាងហោចណាស់សម្រាប់អប់រំបឋមសិក្សា និង អប់រំមូលដ្ឋាន។ ការអប់រំបឋមសិក្សា គឺជាកាតព្វកិច្ច។ ការអប់រំខាងបច្ចេកទេស និង វិជ្ជាជីវៈ ត្រូវរៀបចំឲ្យមានជាទូទៅ។ ការអប់រំឧត្តមសិក្សា ត្រូវបើកឲ្យចូលរៀនស្មើភាពគ្នា ដោយឈរលើមូលដ្ឋានសមត្ថភាព។
២. ការអប់រំត្រូវសំដៅទៅរកការរីកលូតលាស់ពេញលេញនៃបុគ្គលិកលក្ខណៈរបស់មនុស្ស និង ការពង្រឹងការគោរពសិទ្ធិមនុស្ស និង សេរីភាពជាមូលដ្ឋាន។ ការអប់រំនេះត្រូវលើកកម្ពស់ ការយល់ដឹង, ការអត់ឱន, ការអធ្យាស្រ័យ និង មិត្តភាពរវាងប្រជាជាតិនិងក្រុមពូជសាសន៍ ឬ ក្រុមសាសនាទាំងអស់ព្រមទាំងការអភិវឌ្ឍសកម្មភាពរបស់សហប្រជាជាតិក្នុងការថែរក្សាសន្តិភាព។

## មាត្រា ២៧

១. មនុស្សគ្រប់រូបមានសិទ្ធិចូលរួមដោយសេរីក្នុងជីវភាពវប្បធម៌របស់សហគមន៍ រីករាយនឹងសិល្បៈ និងចូលរួមចំណែកវឌ្ឍនភាពវិទ្យាសាស្រ្ត និង បានទទួលផលប្រយោជន៍ពីលទ្ធផលវឌ្ឍនភាពនេះ។
២. មនុស្សគ្រប់រូបមានសិទ្ធិទទួលបានការការពារផលប្រយោជន៍ខាងសីលធម៌ និង សម្ភារៈដែលបានមកពីផលិតកម្មខាងវិទ្យាសាស្រ្ត ឬ សិល្បៈដែលជាស្នាដៃរបស់ខ្លួន។

## មាត្រា ២៨

មនុស្សគ្រប់រូប មានសិទ្ធិចូលរួមគ្រប់គ្រងសណ្តាប់ធ្នាប់សង្គម និង អន្តរជាតិដែលសិទ្ធិ និង សេរីភាព ចែងក្នុងសេចក្តីប្រកាសនេះ អាចត្រូវសម្រេចឲ្យបានដោយពេញលេញ។

## មាត្រា២៩

១. មនុស្សគ្រប់រូប មានករណីយកិច្ចចំពោះសហគមន៍ ដែលជាកន្លែងតែមួយគត់អាចបង្កើតបានការរីកចម្រើនដោយសេរី និង ពេញបរិបូរណ៍នូវបុគ្គលិកលក្ខណៈរបស់ខ្លួន។
២. ក្នុងការប្រើសិទ្ធិ និង សេរីភាពរបស់ខ្លួន មនុស្សគ្រប់រូប ត្រូវស្ថិតនៅត្រឹមកម្រិតដែលច្បាប់បានកំណត់តែប៉ុណ្ណោះ ក្នុងគោលបំណងធានាការទទួលស្គាល់ និង ការគោរពសិទ្ធិ និង សេរីភាពរបស់អ្នកដទៃ និង ដើម្បីបំពេញសេចក្តីត្រូវការយ៉ាងត្រឹមត្រូវ ខាងសីលធម៌,

**១៩៤២**
គណៈកម្មការឧក្រិដ្ឋកម្មសង្រ្គាមរបស់ អង្គការសហប្រជាជាតិ (UN War Crimes Commission) បានបង្កើតសវនាការកាត់ទោសឧក្រិដ្ឋកម្មសង្រ្គាម អន្តរជាតិ នៅទីក្រុង ណ័រឹមបឺក (Nuremberg) និង ទីក្រុងតូក្យូ ដែលបានកើតឡើងបន្ទាប់ពីសង្រ្គាមលោកលើកទី២។

**១៩៤៥**
ធម្មនុញ្ញអង្គការសហប្រជាជាតិ (UN Charter) កំណត់នូវគោលបំណង, ភារកិច្ច និង ការទទួលខុសត្រូវ។

**១៩៤៥**
ការគ្រប់គ្រងរបស់ជប៉ុនបានបញ្ចប់។

**១៩៤៦**
អាណានិគមបារាំងគ្រប់គ្រងកម្ពុជាវិញ។ រដ្ឋធម្មនុញ្ញថ្មីមួយ អនុញ្ញាតឲ្យកម្ពុជាបង្កើតគណបក្សនយោបាយ។ ក្រុមឧទាមកុម្មុយនីស្ត ចាប់ផ្តើមយុទ្ធនាការអាវុធប្រឆាំងនឹងអាណានិគមបារាំង។

សណ្តាប់ធ្នាប់សាធារណៈ និង សុខុមាលភាពទូទៅនៅក្នុងសង្គមប្រជាធិបតេយ្យ។

៣. គ្មានករណីណាមួយ ដែលសិទ្ធិ និង សេរីភាពទាំងនេះ អាចយកទៅប្រើប្រាស់ផ្ទុយនឹងគោលការណ៍ទាំងឡាយរបស់សហប្រជាជាតិឡើយ។

## មាត្រា ៣០

គ្មានបទពិសោធណាមួយ នៃសេចក្តីប្រកាសនេះ អាចត្រូវបានបកស្រាយ ដែលបណ្តាលឲ្យរដ្ឋណាមួយ, ក្រុមណាមួយ ឬ បុគ្គលណាម្នាក់ មានសិទ្ធិបែបណាមួយ ដើម្បីធ្វើសកម្មភាព ឬ ប្រព្រឹត្តអំពើអ្វីមួយសំដៅបំផ្លិចបំផ្លាញ នូវសិទ្ធិ និង សេរីភាពទាំងឡាយដែលមានចែងនៅក្នុងសេចក្តីប្រកាសនេះឡើយ។



តំណាងរាស្ត្រ, មន្ត្រីរដ្ឋាភិបាល, លោកគ្រូ អ្នកគ្រូ, អ្នកកាសែតជាតិ និង អន្តរជាតិ, តំណាងស្ថានទូត, និស្សិត និង ភ្ញៀវកិត្តិយសផ្សេងៗទៀត ចូលរួមសម្ពោធន៍ គម្រោង *សេចក្តីក្លាហានគ្មានព្រំដែន* នៅ សាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា ខែកុម្ភៈ ឆ្នាំ២០១១។

* អាផាថាយស៍, ពីមុនគេហៅថា អាផាធីត (អានតាមបារាំង)

**១៩៤៧**
ការបែងចែកប្រទេសឥណ្ឌា គ្រប់គ្រងដោយអាណានិគមអង់គ្លេស ធ្វើឲ្យប្រជាជន ជិត ១២.៥លាននាក់ គ្មានលំនៅដ្ឋាន, មានការបាត់បង់ជីវិត ប្រហាក់ប្រហែល ពីរាប់រយពាន់ដល់ មួយលាននាក់។

**១៩៤៨**
ប្រព័ន្ធឡោហ្គាយ (Laogai) ចិន គឺជាជំរុំពលកម្មបង្ខំ បានកើតឡើង។ មនុស្សប្រហែល ៥០លាននាក់ ត្រូវបានបញ្ជូនទៅកាន់ជំរុំឡោហ្គាយ។

**១៩៤៨**
ប្រព័ន្ធរើសអើងពូជសាសន៍ អាផាថាយស៍ (Apartheid) គឺជាការបែងចែកតាមពូជសាសន៍ ស្របច្បាប់ បានអនុវត្តន៍នៅប្រទេសអាហ្វ្រិកខាងត្បូង (South Africa)។

**១៩៥៣**
កម្ពុជាទទួលឯករាជ្យភាពពីប្រទេសបារាំង។ ហើយក្លាយជាព្រះរាជាណាចក្រកម្ពុជា។

# ប្រវត្តិសង្ខេបនៃសិទ្ធិមនុស្ស

ដោយសារមនុស្សធម៌របស់មនុស្សម្នាក់, ជំនឿដែលមនុស្សម្នាក់ៗមានអំណាចទទួលបាននូវសិទ្ធិមនុស្ស គឺជាជំនឿថ្មី ដែលបានកើតឡើងក្នុងរយៈពេលខ្លី។ ប៉ុន្តែ ឫសគល់នៃជំនឿនេះ គឺផ្សាភ្ជាប់ជាមួយប្រពៃណីសម័យដើម និង ការបង្ហាត់បង្រៀនពីវប្បធម៌ជាច្រើន។ សង្គ្រាមលោកលើកទីពីរ នាំឲ្យរុញច្រានសិទ្ធិមនុស្សចូលទៅក្នុងដំណាក់កាលពិភពលោក និង មនសិការពិភពលោក។

តាមប្រវត្តិសាស្ត្រដ៏យូរលង់ មនុស្សទទួលបាននូវសិទ្ធិ និង ការទទួលខុសត្រូវផ្សេងៗ តាមរយៈសមាជិកភាពរបស់គេនៅក្នុងក្រុមៈ គឺជាគ្រួសារ, ប្រជាជាតិជនជាតិដើមភាគតិច, សាសនា, វណ្ណៈ, សហគមន៍, ឬ រដ្ឋ។ សង្គមភាគច្រើនមានប្រពៃណី ដែលស្រដៀងគ្នាទៅនឹងច្បាប់មាស (“golden rule”) ដែលនិយាយថា “បើអ្នករាល់គ្នាចង់ឲ្យអ្នកដទៃប្រព្រឹត្តចំពោះខ្លួនបែបណា ត្រូវប្រព្រឹត្តចំពោះគេបែបនោះដែរ”។ សាសនាហិណ្ឌូវេទ (Hindu Vedas), ច្បាប់ក្រមបាប៊ីឡូននៃហាមូ៉រាប៊ី (Babylonian Code of Hammurabi), ព្រះគម្ពីរដ៏បរិសុទ្ធ (Holy Bible), ព្រះគម្ពីរគូ៉រាន (Koran), និង ពាក្យពេចន៍របស់ព្រះតេជគុណខុនហ្វូសឺស (Analects of Confucius) គឺជាប្រភពលាយល័ក្ខអក្សរ ដ៏ចំណាស់ប្រាំ នៅក្នុងចំណោមប្រភពលាយល័ក្ខអក្សរដ៏ចំណាស់ជាច្រើន ដែលដោះស្រាយសំណួរ អំពីករណីយកិច្ច, សិទ្ធិ, និង ការទទួលខុសត្រូវរបស់មនុស្ស។ លើសពីនេះទៀត ច្បាប់ក្រមសីលធម៌ និង យុត្តិធម៌របស់ពួជ អ៊ីនកា និង ពួជ អាស្ទិក (Inca and Aztec Indians) ហើយច្បាប់ធម្មនុញ្ញរបស់ អៀរ៉ូខ្វា (Iroquois) គឺជាប្រភពច្បាប់ដើមរបស់ឥណ្ឌាអាមេរិកកាំង ដែលមានវត្តមានដ៏យូរលង់មុនសតវត្សរ៍ទីដប់ប្រាំបី។ គ្រប់សង្គមទាំងអស់ ទោះបីជាប្រពៃណីជាពាក្យសម្តី ឬ ជាលាយល័ក្ខអក្សរ ពិតជាមានប្រព័ន្ធ ត្រឹមត្រូវ និង យុត្តិធម៌ ព្រមទាំងមធ្យោបាយនៃនិន្នាការថែរក្សាសុខភាព និង សុខុមាលភាព នៃសមាជិករបស់ពួកគេផងដែរ។

## ព្រឹត្តិការណ៍មុន ឯកសារស្តីពីសិទ្ធិមនុស្សក្នុងសតវត្សរ៍ទីម្ភៃ

ឯកសារ ដែលបញ្ចូលសិទ្ធិមនុស្សបុគ្គល ដូចជា ឯកសារ មែកណាខាតា (Magna Carta) (១២១៥), ឯកសារប្រទេសអង់គ្លេសស្តីកម្រងសិទ្ធិឯកត្តជន (Bill of Rights) (១៦៨៩), សេចក្តីប្រកាសរបស់ប្រទេសបារាំង ស្តីពីសិទ្ធិរបស់មនុស្ស និង ពលរដ្ឋ (១៧៨៩), និងរដ្ឋធម្មនុញ្ញរបស់ សហរដ្ឋអាមេរិក (១៧៩១) គឺជាឯកសារដើមជាលាយល័ក្ខអក្សរ ដែល ទាក់ទងនឹងឯកសារ ស្តីពីសិទ្ធិមនុស្សជាច្រើនក្នុងពេលបច្ចុប្បន្ននេះ។ ប៉ុន្តែ ឯកសារនេះភាគច្រើន នៅពេលនោះបានប្រព្រឹត្តគោលនយោបាយ ដែលបដិសេធសិទ្ធិរបស់ស្ត្រី, របស់មនុស្សមិនមានសម្បុរស, និង របស់សមាជិកនៃក្រុមសង្គម, សាសនា, សេដ្ឋកិច្ច, និង នយោបាយ។ ទោះបីជាយ៉ាងណាក៏ដោយ, មនុស្សដែលគេជិះជាន់នៅទូទាំងពិភពលោក បានស្រង់គោលនយោបាយនានា ពីឯកសារទាំងអស់នេះ ក្នុងការគាំទ្រការធ្វើបដិវត្តន៍ ដែលទាមទារសិទ្ធិស្វ័យសម្រេច ឬ ក្នុងការការពារសិទ្ធិ បុគ្គលម្នាក់ៗ។

ច្បាប់សិទ្ធិមនុស្សអន្តរជាតិបច្ចុប្បន្ន និង ការបង្កើត អង្គការសហប្រជាជាតិ (UN) ផុសចេញពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រសំខាន់ៗមួយចំនួន។ កិច្ចប្រឹងប្រែងនៅក្នុងសតវត្សរ៍ទីដប់ប្រាំបួន ចំពោះការហាមប្រាមពាណិជ្ជកម្មទាសករ និង ការកំណត់ភាពឃោរឃៅនៃសង្គ្រាម គឺជាឧទាហរណ៍។ ក្នុងឆ្នាំ១៩១៩ បណ្តាប្រទេសជាច្រើនបានបង្កើតអង្គការពលកម្មអន្តរជាតិ (ILO) ដើម្បីពិនិត្យមើលសន្ធិសញ្ញានានាដែលការពារកម្មករទាក់ទងនឹងសិទ្ធិរបស់ពួកគេ ដោយរួមបញ្ចូលទាំងសុខភាព និង សុវត្ថិភាពរបស់ពួកគេ។ ការព្រួយបារម្ភ អំពីការការពារក្រុមជនជាតិដើមភាគតិចមួយចំនួន ត្រូវបានលើកឡើង ដោយសហព័ន្ធប្រជាជាតិ (League of Nations) នៅចុងសង្គ្រាមលោកលើកទីមួយ។ ប៉ុន្តែ អង្គការសន្តិភាព និង សហព័ន្ធប្រជាជាតិ, ដែលបានបង្កើតឡើងដោយសម្ព័ន្ធភាពអឺរ៉ុបដ៏ជោគជ័យ, មិនដែលបានសម្រេចនូវគោលដៅរបស់ខ្លួនទេ។ សម្ព័ន្ធភាពនេះ បានបរាជ័យ មកពីសហរដ្ឋអាមេរិកបានបដិសេធមិនចូលរួម, ហើយសម្ព័ន្ធភាពនេះ បានខកខានមិនបានការពារការឈ្លានពានរបស់ ជប៉ុន មកលើ ប្រទេសចិន និង តំបន់មែនឈឿរី (Manchuria) (១៩៣១) និង មិនបានទប់ស្កាត់ការវាយប្រហាររបស់ប្រទេស អ៊ីតាលី មកលើប្រទេស អ៊ីហ្យូពី (Ethiopia) (១៩៣៥)។ នៅទីបញ្ចប់ សហព័ន្ធប្រជាជាតិ (League of Nations) បានរលាយនៅដើមដំបូង នៃសង្គ្រាមលោកលើកទីពីរ (១៩៣៩)។

## ថ្ងៃកំណើតនៃអង្គការសហប្រជាជាតិ

គំនិតជុំវិញសិទ្ធិមនុស្ស បានលេចឡើងយ៉ាងខ្លាំង ក្រោយពីសង្គ្រាមលោកលើកទីពីរ។ ការបំផ្លិចបំផ្លាញដោយ រដ្ឋាភិបាលណាត់ស៊ី នៅប្រទេស អាល្លឺម៉ង់ លើពលរដ្ឋជាង ប្រាំមួយលាននាក់ ជាពួក ជ្វីហ្វ (Jews), ក្រុមជីបស៊ី (ស៊ីនទី និង រ៉ូម៉ានី), មនុស្ស ដែលរួមភេទដូចគ្នា,

**១៩៦៦**

កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ (International Convenant on Civil and Political Rights) និង កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិសេដ្ឋកិច្ច, សង្គមកិច្ច និង វប្បធម៌ (International Convenant on Economic, Social and Cultural Rights) ត្រូវបានផ្តល់សច្ចាប័នដោយអង្គការសហប្រជាជាតិ។ ទន្ទឹមជាមួយ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (UDHR), ទាំងអស់នេះ គឺជាកម្រងសិទ្ធិមនុស្ស អន្តរជាតិ។

**១៩៧០**

ព្រះអង្គម្ចាស់ នរោត្តម សីហនុ ត្រូវបានទម្លាក់ដោយរដ្ឋប្រហារ ខណៈនៅក្រៅប្រទេស។ នាយករដ្ឋមន្ត្រី ឧត្តមសេនីយ៍ លន់ នល ទទួលកាន់កាប់អំណាច។ កម្ពុជា ក្លាយជា សាធារណៈរដ្ឋខ្មែរ។

និង មនុស្សដែលអសមត្ថភាព បានធ្វើឲ្យពិភពលោកភ្ញាក់ផ្អើលយ៉ាងខ្លាំង។ សវនាការកាត់ក្តីនេះ បានធ្វើឡើងនៅក្នុងទីក្រុង ណ័រឹមបឺក (Nuremberg) និង ទីក្រុង តូក្យូ (Tokyo), បន្ទាប់ពីសង្គ្រាមលោកលើកទីពីរ។ មន្ត្រីដែលមកពីបណ្តាប្រទេសរណប (ដែលបានបរាជ័យ) ត្រូវបានដាក់ទណ្ឌកម្ម អំពីបទប្រព្រឹត្តឧក្រិដ្ឋកម្មសង្គ្រាម, "ឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព" ហើយ "ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សធម៌"។

នៅពេលនោះ រដ្ឋាភិបាលមួយចំនួនបានប្តេជ្ញាបង្កើត អង្គការសហប្រជាជាតិ ដោយមានគោលបំណងជាលើកដំបូងក្នុងការគាំទ្រសន្តិភាពអន្តរជាតិ និង រារាំងជម្លោះ។ ប្រជាជនចង់ធានាថា អត់អាចកើតឡើងម្តងទៀត ដែលមនុស្សត្រូវបានគេបដិសេធយ៉ាងអយុត្តិធម៌ចំពោះ ជីវិត, សេរីភាព, ជម្រក ឬ ប្រជាជាតិ។ ខ្លឹមសារនៃគោលការណ៍សិទ្ធិមនុស្ស ដែលបានលេចឡើង ត្រូវបានលើកឡើងដោយ លោកប្រធានាធិបតី ហ្វ្រេងគ្លីន ដេលាណូ រូស្វែវែលដ៍ (Franklin Delano Roosevelt), ក្នុងសេចក្តីថ្លែងការណ៍ជូនទៅពលរដ្ឋ សហរដ្ឋអាមេរិកក្នុងឆ្នាំ១៩៤១។ នៅពេលនោះ គាត់បាននិយាយអំពីពិភពលោកមួយដែលបានបង្កើតឡើងដោយផ្អែកលើសេរីភាពដ៏សំខាន់ៗចំនួនបួន ៖ សេរីភាពក្នុងការបញ្ចេញមតិ, សេរីភាពផ្នែកសាសនា, សេរីភាពពីការខ្វះខាត និង សេរីភាពពីការភ័យខ្លាច។ ការអំពាវនាវបានកើតឡើងនៅទូទាំងពិភពលោកសុំឲ្យមាន បទដ្ឋានសិទ្ធិមនុស្ស ក្នុងការការពារពលរដ្ឋមិនឲ្យមានការរំលោភពីរដ្ឋាភិបាលរបស់ពួកគេ, ហើយបទដ្ឋានប្រឆាំងនឹងប្រជាជាតិណាមួយ ក្នុងការទាមទារឲ្យមានការទទួលខុសត្រូវចំពោះការប្រព្រឹត្តិរបស់បុគ្គលទាំងឡាយណា ដែលរស់នៅក្នុងព្រំដែនរបស់ពួកគេ។ សម្លេងទាំងអស់នេះបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការបង្កើត ធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ (UN Charter) ក្នុងឆ្នាំ១៩៤៥។ ឯកសារដើមរបស់ អង្គការសហប្រជាជាតិនេះ បានចែងអំពីគោលដៅ, ភារកិច្ច និង ការទទួលខុសត្រូវរបស់ខ្លួន។

Eleanor Roosevelt , New York, 1949




## សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស

រដ្ឋជាសមាជិករបស់អង្គការសហប្រជាជាតិ បានប្តេជ្ញាលើកកម្ពស់ការគោរពសិទ្ធិមនុស្សសម្រាប់ទាំងអស់គ្នា។ ដើម្បីកែលម្អនូវគោលដៅនេះ, អង្គការសហប្រជាជាតិ បានបង្កើត គណៈកម្មការស្តីពីសិទ្ធិមនុស្ស (Commission on Human Rights) ដែលទទួលបន្ទុកកិច្ចការ ធ្វើពង្រាងឯកសារ ដែលបកស្រាយអំពីអត្ថន័យ នៃសិទ្ធិ និង សេរីភាពជាសារវ័ន្តដែលបានប្រកាសនៅក្នុងធម្មនុញ្ញនេះ។ គណៈកម្មការនេះ ណែនាំដោយថ្នាក់ដឹកនាំដ៏មានអំណាច ជាលោកស្រី អ៊ែលិណូ រូស្វែវែល (Eleanor Roosevelt) បានទាញអារម្មណ៍ពិភពលោក។ នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (Universal Declaration of Human Rights) ត្រូវបានអនុម័តដោយរដ្ឋជាសមាជិក ៥៦ របស់អង្គការសហប្រជាជាតិ។ សម្លេងឆ្នោតនេះ គឺជាឯកច្ឆ័ន្ទ ប៉ុន្តែ ប្រទេសចំនួន៨ បានជ្រើសរើសមិនបោះឆ្នោត។ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ឬ យើងអាចហៅថា មែកណាខាតាអន្តរជាតិ (International Magna Carta) បានពង្រឹងច្បាប់អន្តរជាតិ ដែលធម្មនុញ្ញអង្គការសហប្រជាជាតិបានបំផុសឡើង, ជាពិសេស ស្តីពីរបៀបរដ្ឋាភិបាលណាមួយ ក្នុងការប្រព្រឹត្តចំពោះពលរដ្ឋផ្ទាល់របស់ខ្លួនថា នេះគឺជាបញ្ហានៃកង្វល់អន្តរជាតិស្របច្បាប់ និង មិនត្រឹមតែជាបញ្ហាក្នុងស្រុកទេ។ គេអះអាងថា សិទ្ធិទាំងអស់ គឺជាសិទ្ធិដែលអាស្រ័យគ្នាទៅវិញទៅមក និង មិនអាចបែងចែកបាន។ បុព្វកថា នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស បានអះអាងថា "ការទទួលស្គាល់សេចក្តីថ្លៃថ្នូរជាប់ពីកំណើតរបស់សមាជិកទាំងអស់នៃគ្រួសារមនុស្ស ហើយនិងការទទួលស្គាល់សិទ្ធិស្មើភាពគ្នា និង សិទ្ធិមិនអាចលក់ដូរ, ផ្ទេរ ឬ ដកហូតបានជាគ្រឹះនៃសេរីភាព, យុត្តិធម៌ និង សន្តិភាពក្នុងពិភពលោក"។

ឥទ្ធិពលនៃ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស បានរីកធំឡើងៗ។ គោលការណ៍នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ឥឡូវនេះ

**១៩៧១**

ការរំលោភសិទ្ធិមនុស្ស ដោយរីករាលដាលនៅប្រទេសប៉ាគីស្ថាន ខាងកើត (ឥឡូវនេះ ប្រទេស បង់ក្លាដេស) ដែលពលរដ្ឋស៊ីវិល ប្រហែល២០០,០០០ ទៅ ៣លាន នាក់ ត្រូវបានសម្លាប់ និង មនុស្ស រាប់លាននាក់ បានភៀសខ្លួនទៅកាន់ប្រទេសឥណ្ឌា។

**១៩៧៣**

លោក អកហ្គ័ស្តូ ភីណូហេ្ស (Augusto Pinochet) ជាមេដឹកនាំផ្តាច់ការ របស់ ប្រទេសឈីលី (Chile) ធ្វើរដ្ឋប្រហារមួយ ដែលបានផ្តួចផ្តើមឲ្យមានការបាត់ខ្លួនយ៉ាងច្រើន, ការឃុំខ្លួនខុសច្បាប់, ការធ្វើទារុណកម្ម និង ការសម្លាប់ក្រៅប្រព័ន្ធតុលាការ។

**១៩៧៥ ដល់១៩៧៩**

ប្រជាជនកម្ពុជាពី ១.៧ ទៅ ៣លាននាក់ ត្រូវបានស្លាប់ ក្រោមរបបគ្រប់គ្រងខ្មែរក្រហម របស់ សាឡុត ស ហៅ ប៉ុល ពត។

ត្រូវបានដាក់បញ្ចូលទៅក្នុងធម្មនុញ្ញនៃបណ្តាប្រទេសច្រើនជាង ១៨៥ នៅក្នុងអង្គការសហប្រជាជាតិ។ ទោះបីជាសេចក្តីប្រកាសមួយ មិនមែនជាឯកសារជាប់កាតព្វកិច្ចច្បាប់ក៏ដោយ ក៏សេចក្តីប្រកាសជាសកលនេះ បានបំពេញឋានៈតាមច្បាប់អន្តរជាតិជាសកល ព្រោះថា មនុស្សចាត់ទុកវា "ជាបទដ្ឋានរួម នៃសមិទ្ធិផលមួយសម្រាប់មនុស្សទាំងអស់គ្នា និងប្រជាជាតិទាំងអស់"។

## អនុសញ្ញាស្តីពីសិទ្ធិមនុស្ស

ជាមួយគោលបំណង នៃការបង្កើតយន្តការសម្រាប់ការពង្រឹងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សនេះ គណៈកម្មការស្តីពីសិទ្ធិមនុស្ស (Commission on Human Rights) របស់ អង្គការសហប្រជាជាតិ បានចាប់ផ្តើមព្រាងសន្ធិសញ្ញាចំនួនពីរ ក្នុងឆ្នាំ១៩៦៦៖ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ (ICCPR) និង អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច, សង្គមកិច្ច និង វប្បធម៌ (ICESCR)។ រួមគ្នាជាមួយសេចក្តីប្រកាសជាសកលនេះ កតិកាសញ្ញានេះ ត្រូវបានចាត់ទុកថា ជាច្បាប់អន្តរជាតិស្តីពីសិទ្ធិមនុស្ស (International Bill of Human Rights)។ កតិកាសញ្ញា ICCPR ផ្តោតទៅលើបញ្ហានានា ដូចជា សិទ្ធិរស់រានមានជីវិត, សេរីភាពក្នុងការបញ្ចេញមតិ, សេរីភាពផ្នែកសាសនា, និង សិទ្ធិបោះឆ្នោត។ កតិកាសញ្ញា ICESCR ផ្តោតទៅលើបញ្ហានានា ដូចជា ស្បៀងអាហារ, ការអប់រំ, សុខភាព, និង ជម្រក។ កតិកាសញ្ញាទាំងពីរនេះ ប្រកាសការផ្សព្វផ្សាយ សិទ្ធិ ដល់មនុស្សទាំងអស់គ្នា និងហាមប្រាម អំពីការរើសអើង។

ក្នុងឆ្នាំ២០១០ ប្រជាជាតិចំនួនជាង ១៦០ បានផ្តល់សច្ចាប័នលើកតិកាសញ្ញាទាំងនេះ។

## ឯកសារបន្ទាប់បន្សំស្តីពីសិទ្ធិមនុស្ស

បន្ថែមទៅលើកតិកាសញ្ញា យើងបានហៅថា ជាច្បាប់អន្តរជាតិស្តីពីសិទ្ធិមនុស្ស (International Bill of Human Rights), អង្គការសហប្រជាជាតិ បានអនុម័តសន្ធិសញ្ញាគោលការណ៍ច្រើនជាង ២០ ដែលបានពិពណ៌នាបន្ថែមអំពីសិទ្ធិមនុស្ស។ ទាំងអស់នេះ រួមបញ្ចូលទាំងអនុសញ្ញានានា ដើម្បីរារាំង និង ហាមប្រាមការរំលោភ ជាក់ស្តែង ដូចជា ការធ្វើទារុណកម្ម និង ប្រល័យពូជសាសន៍ ហើយនិង ការការពារជាពិសេសសម្រាប់ប្រជាជនងាយស្រួលរងគ្រោះ ដូចជា ជនភៀសខ្លួន (អនុសញ្ញាទាក់ទងនឹងស្ថានភាពជនភៀសខ្លួន ក្នុងឆ្នាំ១៩៥០), ស្ត្រី (អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងចំពោះស្ត្រីក្នុងឆ្នាំ១៩៧៩), និង កុមារ (អនុសញ្ញាស្តីពីសិទ្ធិកុមារ ក្នុងឆ្នាំ១៩៨៩)។

ឯកសារមួយចំនួនក្នុងតំបន់នៅអឺរ៉ុប, អាមេរិកខាងជើងនិងខាងត្បូង និង អាហ្វ្រិក, សម្រាប់ការការពារ និង ការលើកកម្ពស់សិទ្ធិមនុស្សពង្រីកវិសាលភាពច្បាប់អន្តរជាតិស្តីពីសិទ្ធិមនុស្ស (International Bill of Human Rights)។ ជាឧទាហរណ៍ រដ្ឋអាហ្វ្រិកជាច្រើនបានបង្កើតធម្មនុញ្ញស្តីពីសិទ្ធិមនុស្សនិងសិទ្ធិពលរដ្ឋ (Charter of Human and People's Rights) (១៩៨១) និង រដ្ឋមូស្លីមជាច្រើនបានបង្កើត សេចក្តីប្រកាសខៃរ៉ូស្តីពីសិទ្ធិមនុស្សនៅអ៊ីស្លាម (Cairo Declaration on Human Rights in Islam) (១៩៩០)។ការផ្លាស់ប្តូរយ៉ាងឆាប់រហ័ស នៅអឺរ៉ុបខាងកើត, អាហ្វ្រិក និង អាមេរិកឡាទីន កាលពី២០ឆ្នាំមុន បានធ្វើបាតុកម្ម ពុះកញ្ជ្រោលឡើងដោយមានឥទ្ធិពលទាមទារឲ្យមានការគោរពសិទ្ធិមនុស្ស។ ចលនាដ៏មានប្រជាប្រិយភាពនៅក្នុងប្រទេស ចិន, កូរ៉េ និង ប្រទេសនៅអាស៊ីដទៃទៀត បង្ហាញអំពីការប្តេជ្ញាចិត្តស្រដៀងគ្នា ចំពោះការគោរពគោលការណ៍ទាំងនេះ។

## តួនាទីរបស់អង្គការក្រៅរដ្ឋាភិបាល (NGO)

ជាសាកល អ្នកជើងឯកខាងសិទ្ធិមនុស្សភាគច្រើន គឺជាប្រជាពលរដ្ឋមិនមែនមន្ត្រីរដ្ឋាភិបាល។ ជាពិសេស អង្គការក្រៅរដ្ឋាភិបាល (NGO) បានដើរតួនាទីដ៏សំខាន់ក្នុងការទាញអារម្មណ៍របស់ សហគមន៍អន្តរជាតិអំពីបញ្ហាសិទ្ធិមនុស្ស។ ជាឧទាហរណ៍ សកម្មភាព NGO នៅជុំវិញសន្និសីទពិភពលោកទីបួន ស្តីពីស្ត្រីរបស់ អង្គការសហប្រជាជាតិ (UN Fourth World Conference on Women) ឆ្នាំ១៩៩៥ នៅទីក្រុង ប៉េកាំង ប្រទេសចិន បានទាញអារម្មណ៍ដែលមិនធ្លាប់មានចំពោះការរំលោភសិទ្ធិស្ត្រីយ៉ាងធ្ងន់ធ្ងរ។ អង្គការក្រៅរដ្ឋាភិបាល ដូចជា អង្គការលើកលែងទោសអន្តរជាតិ (Amnesty International), អង្គការប្រឆាំងទាសភាពអន្តរជាតិ (Anti-Slavery International), គណៈកម្មការអ្នកច្បាប់អន្តរជាតិ (International Commission of Jurists), ក្រុមការងារអន្តរជាតិស្តីពីជនជាតិដើមភាគតិច (International Working Group on Indigenous Affairs), អង្គការឃ្លាំមើលសិទ្ធិមនុស្ស (Human Rights Watch), មជ្ឈមណ្ឌល រ៉ូបឺត អ៊ែហ្វ ខិណ្ណឌី ដើម្បីយុត្តិធម៌ និង សិទ្ធិមនុស្ស

**១៩៧៩**
អនុសញ្ញាអន្តរជាតិ ស្តីពីការលុបបំបាត់រាល់ទម្រង់ នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ (CEDAW) ត្រូវបានផ្តល់សច្ចាប័ន ដោយ អង្គការសហប្រជាជាតិ។

**១៩៨៤**
អនុសញ្ញាអន្តរជាតិ ប្រឆាំងនឹង ការធ្វើទារុណកម្ម និង ការប្រព្រឹត្តិដ៏ឃោរឃៅ អមនុស្សធម៌ ឬ ថោកទាប ឬ ក៏ការដាក់ទោស បានផ្តល់សច្ចាប័ន ដោយអង្គការសហប្រជាជាតិ។

**១៩៨៥**
លោក ហ៊ុន សែន ក្លាយជា នាយករដ្ឋមន្ត្រី។

**១៩៨៩**
ការសម្លាប់រង្គាលនៅទីលាន ធានណាមែន (Tiananmen Square Massacre) នៅប្រទេសចិន កើតឡើង បន្ទាប់ពីធ្វើបាតុកម្មប្រកបដោយសន្តិវិធី ជាច្រើនសប្តាហ៍, ក្នុងការទាមទារឲ្យមានកំណែទម្រង់នយោបាយ។ ក្រុមទាហាន រដ្ឋាភិបាល បាញ់មកលើក្រុមបាតុករ, ដោយសម្លាប់ មនុស្ស រាប់ពាន់នាក់។



(Robert F. Kennedy Center for Justice and Human Rights), អង្គការគ្រូពេទ្យសម្រាប់សិទ្ធិមនុស្ស (Physicians for Human Rigths), អង្គការសិទ្ធិមនុស្សដំបូង (Human Rights First), មូលនិធិសិក្សាស្រាវជ្រាវឡោហ្គាយ (Laogai Research Foundation), សមាគមតៃវ៉ាន់ដើម្បីសិទ្ធិមនុស្ស (Taiwanese Association for Human Rights), និង មូលនិធិសម្រាប់សិទ្ធិមនុស្ស (Foundation for Human Rights) តាមដានសកម្មភាពរបស់រដ្ឋាភិបាល និង ជម្រុញឲ្យរដ្ឋាភិបាលប្រព្រឹត្តស្របតាមគោលការណ៍សិទ្ធិមនុស្ស។

មន្ត្រីរដ្ឋាភិបាលដែលយល់ដឹង អំពីក្របខ័ណ្ឌសិទ្ធិមនុស្ស អាចធ្វើឲ្យមានប្រសិទ្ធភាពដល់ការផ្លាស់ប្តូរទូលំទូលាយ ដើម្បីសេរីភាព។ មេដឹកនាំពិភពលោកជាច្រើន ដូចជា លោក អាប្រាហាម លីងគុន (Abraham Lincoln), លោកស្រី អេលិន ចនសិន សឺលីវ (Ellen Johnson-Sirleaf), លោកស្រី មីហ្សែល បាសែលេ ជេរីអា (Michelle Bachelet Jeria), និង លោក ជីមី ខាធើ (Jimmy Carter) បានប្រកាន់ជំហរយ៉ាងម៉ឺងម៉ាត់ ដើម្បីសិទ្ធិមនុស្ស។ នៅក្នុងបណ្តាប្រទេសនានា មេដឹកនាំជាច្រើន ដូចជា លោក ណែលសិន ម៉ែនដេលា (Nelson Mandela), លោក មហាម៉ាត់ គន្ធី (Mahatma Gandhi), លោក ដាក ហាមាស្គូលដ៍ (Dag Hammarskjold), លោកស្រី ហ្គ្រាសា ម៉ាហ្សែល (Graca Machel), លោកស្រី វ៉ាងហ្គារី ម៉ាថាយ (Wangari Maathai), និង លោក វ៉ាក្លាវ ហាវែល (Vaclav Havel), បានធ្វើឲ្យមានការផ្លាស់ប្តូរយ៉ាងធំធេងស្ថិតក្រោមបដានៃសិទ្ធិមនុស្ស។

## ការវិវត្តនៃច្បាប់សិទ្ធិមនុស្ស

ចាប់ផ្តើមឆ្នាំ១៩៤៨ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស គឺជាគ្រឹះសម្រាប់ អនុសញ្ញាស្តីពីសិទ្ធិមនុស្ស សំខាន់ៗចំនួន២០។ អនុសញ្ញាជាច្រើនស្តីពីសិទ្ធិមនុស្សបានចូលជាធរមាន។ អនុសញ្ញាមួយចំនួននៅតែស្ថិតនៅក្នុងដំណើរការនៃការធ្វើសច្ចាប័ននៅឡើយ។ អនុសញ្ញាដទៃទៀត ដូចជា អនុសញ្ញាមួយ ស្តីពីសិទ្ធិជនជាតិដើមភាគតិច និង អនុសញ្ញាមួយទៀត ស្តីពីសិទ្ធិថែរក្សាបរិស្ថាន ឥឡូវនេះ ត្រូវបានធ្វើពង្រាង។ ច្បាប់ស្តីពីសិទ្ធិមនុស្សអន្តរជាតិ បន្តការវិវត្តដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ក្រុមមនុស្សមួយចំនួន ដែលបានទទួលស្គាល់និងកំណត់។ ហើយបន្តការវិវត្តដើម្បីឆ្លើយតបចំពោះ ព្រឹត្តិការណ៍ពិភពលោកមួយចំនួន ដែលចង្អុលបង្ហាញនូវតម្រូវការសម្រាប់ ការផ្សព្វផ្សាយការយល់ដឹង និង សកម្មភាព ស្តីពីបញ្ហាសិទ្ធិមនុស្ស។ គោលបំណងចុងក្រោយ គឺដើម្បីការពារ និង លើកកម្ពស់សិទ្ធិជាមូលដ្ឋានរបស់មនុស្សម្នាក់ៗនៅគ្រប់ទីកន្លែង។

ទោះបីជាមានការរីកចម្រើនច្រើន នៅក្នុងការការពារសិទ្ធិមនុស្ស នៅទូទាំងពិភពលោកក៏ដោយ ក៏ភាពជាក់ស្តែងធ្វើឲ្យមានការព្រួយបារម្ភ ពីព្រោះថា មនុស្សដែលបានសម្លាប់, បានធ្វើទារុណកម្ម និង បានរំលោភ ក្នុងទ្រង់ទ្រាយដ៏ធំ គឺនៅតែគេចវេសបានពីការដាក់ទណ្ឌកម្មផងដែរ។

បន្ទាប់ពីការរៀបចំជាច្រើនឆ្នាំមក រដ្ឋាភិបាលបានជួបពិភាក្សាគ្នានៅក្នុងឆ្នាំ១៩៩៨ក្នុងទីក្រុងរ៉ូម ប្រទេសអ៊ីតាលី ដើម្បីអនុម័តលក្ខន្តិកៈដែលបានបង្កើត តុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC)។ នៅក្នុង

**១៩៨៩**
កងទ័ពវៀតណាមដកចេញពីកម្ពុជា។

**១៩៩១**
កិច្ចព្រមព្រៀងទីក្រុងប៉ារីស បង្កើតអ៊ុនតាក់ (UNTAC)។

**១៩៩១**
លោកស្រី អ៊ុង សានស៊ូជី ជាសកម្មជន លទ្ធិប្រជាធិបតេយ្យប្រទេសភូមា បានទទួល រង្វាន់ណូបែលសន្តិភាព (Nobel Peace Prize)។ លោកស្រី ត្រូវបានគេឃុំខ្លួន នៅក្នុងផ្ទះ ទោះបីជាមានការអំពាវនាវ ដដែលៗពី សហគមន៍អន្តរជាតិឲ្យមានការដោះលែងក៏ដោយ។

**១៩៩២**
កម្ពុជាទទួលស្គាល់ស៊ីដរ (CEDAW) និង ឲ្យសច្ចាប័នលើ កតិកាសញ្ញា អន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ (ICCPR)។

ឆ្នាំ២០០២ រដ្ឋចំនួន៦០ បានផ្តល់សច្ចាប័នលើលក្ខន្តិកៈទីក្រុងរ៉ូម (Rome Statute) ដើម្បីអនុវត្តន៍ជាផ្លូវការនូវការប្រព្រឹត្តទៅរបស់តុលាការ ICC នេះ ក្នុងគោលដៅកាត់ទោសបទឧក្រិដ្ឋកម្មពិភពលោកដ៏ធ្ងន់ធ្ងរបំផុត។ នៅក្នុងឆ្នាំ២០០៩ លក្ខន្តិកៈនេះ ត្រូវបានផ្តល់សច្ចាប័នដោយបណ្តារដ្ឋចំនួន ១០៩។

តុលាការ ICC គឺជាតុលាការយុត្តិធម៌អចិន្ត្រៃយ៍មួយ ដោយមានយុត្តាធិការសកល ដើម្បីកាត់ទោសបុគ្គលដែលបានប្រព្រឹត្តបទឧក្រិដ្ឋកម្មដ៏អាក្រក់បំផុតនៅក្នុងពិភពលោក ដូចជា អំពើប្រល័យពូជសាសន៍, បទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និង បទឧក្រិដ្ឋកម្មសង្គ្រាម។

## ចលនាសិទ្ធិមនុស្សបច្ចុប្បន្ន

ការអនុម័តនូវ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស នៅក្នុងឆ្នាំ១៩៤៨ ត្រូវបានគេយកមកគិតថា ជាការចាប់ផ្តើមនៃចលនាសិទ្ធិមនុស្សបច្ចុប្បន្ន។ ចលនាសិទ្ធិមនុស្សបច្ចុប្បន្ននេះ បានឃើញនូវការផ្លាស់ប្តូរសង្គមដ៏ជ្រាលជ្រៅ៖ ចលនាសិទ្ធិស្ត្រី បានទទួលនូវសមភាពច្រើនសម្រាប់ស្ត្រី ដូចជា សិទ្ធិបោះឆ្នោត។ ចលនាប្រឆាំងនឹងការរើសអើងពូជសាសន៍ (anti-apartheid) នៅអាហ្វ្រិកខាងត្បូង និង នៅទូទាំងពិភពលោក បានបង្ហាញអំពីខ្លឹមសារនៃ “សកម្មភាពនិយមឆ្លងប្រទេស” ដែលបានរួមចំណែកដល់ ការបង្កើតរដ្ឋាភិបាលប្រជាធិបតេយ្យ ដោយផ្អែកលើស្វ័យសម្រេច (self-determination) និង សមភាព។

សិទ្ធិមនុស្ស គឺជាគំនិតមួយទាន់សម័យ។ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស គឺជាការស្រែករក សេរីភាព និង យុត្តិធម៌ សម្រាប់មនុស្សនៅទូទាំងពិភពលោក។ រៀងរាល់ថ្ងៃ រដ្ឋាភិបាលដែលបានរំលោភសិទ្ធិពលរដ្ឋរបស់ខ្លួន នឹងទទួលនូវការប្រឈមមុខនិងការទិតៀន។ រៀងរាល់ថ្ងៃ មនុស្សនៅទូទាំងពិភពលោកប្រមូលផ្តុំគ្នា ដើម្បីឆ្លើយតបទៅនឹងអយុត្តិធម៌ និង អមនុស្សធម៌។ ដូចជា ដំណក់ទឹកធ្លាក់លើដុំថ្ម ពួកគេទម្លុះកម្លាំងគាបសង្កត់និងរំកិលមកជិតការសម្រេចបាននូវគោលការណ៍ទាំងអស់នេះ ដែលមានចែងនៅក្នុងសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស។

ប្រភព៖ ដកស្រង់លំនាំពី David Shiman បង្រៀនអំពីសិទ្ធិមនុស្ស (Denver: មជ្ឈមណ្ឌលបង្រៀនអំពីការផ្សព្វផ្សាយទំនាក់ទំនងអន្តរជាតិ មហាវិទ្យាល័យ Denver, ១៩៩៣)

**១៩៩៣**
អាជ្ញាធរអន្តរកាល អង្គការសហប្រជាជាតិ(អ៊ុនតាក់)បានរៀបចំការ បោះឆ្នោត ពហុបក្ស នៅប្រទេសកម្ពុជា។

**១៩៩៣**
មានការបោះឆ្នោតពហុបក្ស ដែលរៀបចំដោយ អ៊ុនតាក់។

**១៩៩៤**
ក្រុមទុតស៊ី (Tutsi) និង ក្រុមហ៊ូទូ (Hutu) អ្នកនិយមកណ្តាលប្រហែល ចំនួន ៨០០,០០០នាក់ ត្រូវបានសម្លាប់ ក្នុងរបបអំពើប្រល័យពូជសាសន៍ នៃប្រទេសរ៉្វាន់ដា (Rwanda)។

**១៩៩៤**
ប្រព័ន្ធរើសអើង ពូជសាសន៍ អាផាថាយស៍ (Apartheid) នៅប្រទេសអាហ្វ្រិកខាងត្បូង បានបញ្ចប់ជាផ្លូវការ។

# ក្លាយជាអ្នកការពារ

បុគ្គលម្នាក់ៗ អាចក្លាយជាអ្នកការពារ ទោះជាអ្នកមានពេលមួយថ្ងៃ ឬ មានពេលគ្រប់ឆ្នាំសិក្សាទាំងមូលក៏ដោយ។ មានឧទាហរណ៍មួយចំនួន ដូចខាងក្រោម ដែលទាក់ទងទៅនឹងរបៀប ដែលអ្នកអាចគាំទ្រសិស្ស របស់អ្នក ក្នុងកិច្ចប្រឹងប្រែងការពារសិទ្ធិមនុស្ស។

## ព័ត៌មាន (Tips)

មានយុទ្ធសាស្រ្ត គឺ៖

- កំណត់បញ្ហាដើម្បីដោះស្រាយ
- សិក្សាស្រាវជ្រាវបញ្ហា៖ ហេតុអ្វីជាបញ្ហា? តើនរណាអាចធ្វើឲ្យមានការផ្លាស់ប្តូរ? តើមានដំណោះស្រាយអ្វីខ្លះ ដែលបានសាកល្បងហើយ?(បញ្ហាមួយចំនួន បានគ្របដណ្តប់នៅក្នុងមេរៀននេះ)។
- តើអ្នកចង់ផ្លាស់ប្តូរអ្វីខ្លះ?
- កំណត់សកម្មភាពរបស់អ្នក និង បញ្ជាក់ឲ្យច្បាស់ថា តើអ្នកផ្តោតគោលដៅទៅលើអ្នកណា? នរណាអាចធ្វើឲ្យការផ្លាស់ប្តូរនេះកើតឡើង?
- តើអ្នកអាចទាក់ទាញអ្នកដទៃឲ្យចូលរួមតាមរបៀបណា?
- តើអ្នកនឹងវាស់ផលប៉ះពាល់របស់អ្នកដូចម្តេច?

## មួយថ្ងៃ

សូមជ្រើសរើសសកម្មភាពដែលមានលក្ខណៈសាមញ្ញ និង ចាប់អារម្មណ៍ ដូចជា ការសរសេរលិខិត ឬ ទិវាប្រកាសព័ត៌មាននៅក្នុងសាលារៀនរបស់អ្នក។

### ជាឧទាហរណ៍

- ដោយធ្វើការរួមគ្នា សូមបង្កើត ច្បាប់ស្តីពីសិទ្ធិមនុស្ស (Bill of Human Rights) សម្រាប់ថ្នាក់ ឬ សាលារៀនរបស់អ្នក។ ក្រោយមកទៀត សូមបិទប្រកាសនោះសម្រាប់ឲ្យមនុស្សគ្រប់គ្នាដែលចូលមកក្នុងថ្នាក់ ឬ ក្នុងសាលារៀនរបស់អ្នកអាចយល់ដឹងអំពីវប្បធម៌ដែលសិស្សចង់បាន។
- រៀបចំកិច្ចប្រជុំមួយជាមួយមេដឹកនាំសហគមន៍អំពីបញ្ហាមូលដ្ឋាន ដែលសំខាន់សម្រាប់សាលារៀនរបស់អ្នក។ ស្នើសុំឲ្យពួកគេចាត់វិធានការណាមួយ ឬ ប្រកាន់យកតួនាទីណាមួយ។
- រៀបចំទិវាសម្រាប់ការសរសេរលិខិត។
- រៀបចំទិវាផ្សព្វផ្សាយយល់ដឹងដោយមានផ្ទាំងក្រដាស និង ព័ត៌មានអប់រំសាលារៀនរបស់អ្នក អំពីបញ្ហាអន្តរជាតិជាក់លាក់។ បើសិនអ្នកមានពេលវេលារៀនមុនគ្រប់គ្រាន់ សូមដាក់បញ្ចូលញត្តិប្តឹងទៅអាជ្ញាធរដែនដី។



ក្រុមអ្នកគ្រូ ទស្សនាការតាំងពិព័រណ៍រូបថត នៅមជ្ឈមណ្ឌលវប្បធម៌ កម្ពុជា-អាឡឺម៉ង់ មេត្តាហោស(ភ្នំពេញ, ខែកញ្ញា ឆ្នាំ២០១១)

**១៩៩៥**

សន្និសីទពិភពលោកស្តីពីស្ត្រីលើកទី៤ ត្រូវបានរៀបចំធ្វើឡើងនៅទីក្រុងប៉េកាំងនៃប្រទេសចិន។ អ្នកចូលរួមទាំងអស់ បានយល់ព្រមលើផែនការសកម្មភាពរយៈពេល៥ឆ្នាំ ក្នុងបំណងលើកកម្ពស់នូវការផ្តល់សិទ្ធិអំណាចខាង សង្គមកិច្ច, សេដ្ឋកិច្ច និង នយោបាយដល់ស្ត្រី, កែលម្អសុខភាពរបស់ ពួកគាត់, ផ្តល់បុរេប្រទានដល់ការអប់រំរបស់ពួកគាត់ និង លើកកម្ពស់សិទ្ធិអាពាហ៍ពិពាហ៍និងសិទ្ធិ ខាងផ្លូវភេទ។

**១៩៩៥**

ការសម្លាប់រង្គាលនៅតំបន់ ស្រេប្រេនីកា (Srebrenica) បុរស និង ក្មេងប្រុសច្រើនជាង ៨,០០០នាក់បានសម្លាប់នៅ ក្នុងមហាឃាតកម្មដ៏ធំនៅទ្វីបអឺរ៉ុប ចាប់ តាំងពីសង្គ្រាមលោកលើកទីពីរ។

## មួយសប្តាហ៍

ក្នុងមួយសប្តាហ៍ សូមផ្តោតទៅលើ ព្រឹត្តិការណ៍ ឬ កម្មវិធីណាមួយ ដែល កសាងឡើងពីការផ្សព្វផ្សាយនៃការយល់ដឹងមកធ្វើសកម្មភាព។

### ជាឧទាហរណ៍៖

សូមរៀបចំមួយសប្តាហ៍ ដើម្បីធ្វើការផ្លាស់ប្តូរ។ សូមចាប់ផ្តើមកំណត់ គណៈកម្មាធិការរៀបចំមួយ។ សូមស្រង់ព័ត៌មានអំពីសហគមន៍នៅក្នុង សាលារៀន និង កំណត់បញ្ហាកំពូលៗចំនួន៥ ដែលសហគមន៍នេះ ចង់ធ្វើការផ្លាស់ប្តូរ។ សូមផ្តល់ជម្រើសឲ្យស្របទៅនឹងសិទ្ធិមនុស្ស នៅក្នុង សាលារៀនរបស់អ្នក និង ក្នុងសហគមន៍ទាំងជាតិនិងអន្តរជាតិ។ ក្នុងដំណើរការមួយសប្តាហ៍ សូមអប់រំសហគមន៍គោលដៅរបស់អ្នក អំពីបញ្ហានេះ ហើយបន្ទាប់មក សូមផ្តល់សកម្មភាពជាបន្តបន្ទាប់ដែល មនុស្សទាំងអស់នោះអាចធ្វើបាន។

## មួយឆមាស

សូមបង្កើតកម្មវិធីមួយ ដែលដាក់បញ្ចូលការរៀនសូត្រក្នុងថ្នាក់របស់ អ្នកជាមួយគម្រោងដ៏ទូលំទូលាយ និង មានច្រើនស្រទាប់។ សូមរៀបចំ គម្រោងសហគមន៍មួយ ផ្អែកសិទ្ធិមនុស្ស។ គម្រោងសហគមន៍អាច ទាក់ទងទៅនឹងគោលបំណងនៃការរៀនសូត្រ ទៅនឹងគោលបំណង នៃសេវាកម្មជាមួយនឹងគោលដៅ ដែលអ្នកចូលរួមទទួលបាននូវ ជំនាញ, គុណតម្លៃ និង ចំណេះដឹង។ ហើយអ្នកចូលរួមនឹងទទួលនូវផលប្រយោជន៍ ពីសេវាកម្មគម្រោង។

គំរូយ៉ាងនៃបញ្ហាដែលបានដោះស្រាយដោយគម្រោងសហគមន៍ ដែល ស្របទៅនឹងអ្នកការពារ និង បញ្ហាដែលបានលើកឡើងនៅក្នុងកម្មវិធី សិក្សានេះ រួមមាន៖

- ប្រល័យពូជសាសន៍
- អំពើហិង្សាក្នុងគ្រួសារ
- ទាសភាពផ្លូវភេទ
- សេរីភាពក្នុងការបញ្ចេញមតិ
- សិទ្ធិក្នុងការទទួលបានឥណទាន
- ការបង្រួបបង្រួម
- ពលកម្មកុមារ
- ការទទួលខុសត្រូវរបស់ក្រុមហ៊ុនក្នុងសង្គម (Corporate Social Responsibility)

### ១៩៩៨

លក្ខន្តិកៈ នៃទីក្រុងរ៉ូម (Rome Statute) បានចុះហត្ថលេខាដោយបណ្តាប្រទេសចំនួន ១២០ រួមបញ្ចូល ទាំងប្រទេសកម្ពុជា នៅឆ្នាំ១៩៩៨, បានចូលជាធរមាននៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០២ ដោយបង្កើត មូលដ្ឋានច្បាប់សម្រាប់ តុលាការឧក្រិដ្ឋកម្មអន្តរជាតិ (ICC)។ តុលាការឧក្រិដ្ឋកម្មអន្តរជាតិ (ICC) នេះ មាន អំណាចច្បាប់មកលើឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរបំផុត ដែលពាក់ព័ន្ធជាមួយសហគមន៍អន្តរជាតិ, ដូចជា អំពើ ប្រល័យពូជសាសន៍, ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និង ឧក្រិដ្ឋកម្មសង្គ្រាម។

### ១៩៩៨ ដល់ ២០០៨

ប្រជាជនប្រហែល ៥.៤លាននាក់ បានស្លាប់ នៅ ប្រទេសកុងហ្គោ (Congo)។



## ២០០១

សន្និសីទពិភពលោកប្រឆាំងនឹងពូជសាសន៍និយម។ អ្នកតំណាង នៃប្រទេសជាសមាជិក អង្គការសហប្រជាជាតិ នីមួយៗ បានជួបប្រជុំនៅទីក្រុងឌើបៃន(Durban)នៅប្រទេសអាហ្វ្រិកខាងត្បូង ដើម្បីដោះស្រាយបញ្ហា សិទ្ធិជនជាតិភាគតិច និង ជនជាតិដើមភាគតិច, ការជួញដូរមនុស្ស, ទេសន្តរប្រវេសន៍ និង ការរើសអើង។ សេចក្តីប្រកាសទីក្រុង ឌើបៃន (Durban Declaration) បានដាក់ចេញនូវផែនការសកម្មភាព ក្នុងការអនុវត្ត គោលដៅនៃសន្និសីទនេះ។

## ២០០១

ព្រឹទ្ធសភាអនុម័តច្បាប់ ក្នុង ការបង្កើតសាលាក្តី ដើម្បី ចោទប្រកាន់មេដឹកនាំខ្មែរ ក្រហម អំពីអំពើប្រល័យពូជសាសន៍។



“គ្មាននរណាម្នាក់កើតមក
ដោយស្អប់អ្នកដទៃ
មកពីព័ណ៌សម្បុរស្បែករបស់គេ,
ឬ មកពីជីវប្រវត្តិរបស់គេ
ឬ មកពីសាសនារបស់គេទេ។
មនុស្សត្រូវតែរៀនចេះស្អប់
ហើយប្រសិនបើ ពួកគេ
អាចរៀនចេះស្អប់
ពួកគេអាចបង្រៀនឲ្យ
ចេះស្រឡាញ់ ពីព្រោះថា
សេចក្តីស្រឡាញ់
កើតឡើងពីធម្មជាតិ
ចំពោះបេះដូងមនុស្សច្រើនជាង
បដិបក្ខរបស់វា”។

—លោក ណែលសិន មែនដែលា

(Nelson Mandela)

**២០០៦**
អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ECCC) បានចាប់ផ្តើមធ្វើការចោទប្រកាន់ ទៅលើមេដឹកនាំខ្មែរក្រហមជាន់ខ្ពស់ និង ជនដែលទទួលខុសត្រូវខ្ពស់បំផុត ចំពោះ ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (Democratic Kampuchea)។

**២០០៨**
ខួបលើកទី៦០ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស។

**២០០៩**
គណៈកម្មការអន្តររដ្ឋាភិបាលអាស៊ានស្តីពីសិទ្ធិមនុស្ស (AICHR)បានបង្កើត។

**២០១០**
លោកស្រី អ៊ុង សានស៊ូជី ត្រូវបានដោះលែង។

**២០១១**
សវនាការ ប្រឆាំងនឹងមេដឹកនាំខ្មែរក្រហម ជាន់ខ្ពស់ ដែលរស់រានមានជីវិត៖ នួន ជា, ខៀវ សំផន, អៀង សារី និង អៀង ធីរិទ្ធ។

# អ៊ីលី វីសែល ELIE WIESEL

“អ្វីដែលខ្ញុំចង់បាន និង អ្វីដែលខ្ញុំសង្ឃឹមក្នុងមួយជីវិតរបស់ខ្ញុំនោះ គឺកុំឲ្យអតីតកាលរបស់ខ្ញុំ ក្លាយជាអនាគតរបស់កូនៗរបស់អ្នក”។



Elie Wiesel, ©2000 Eddie Adams

លោក អ៊ីលី វីសែល (Elie Wiesel) ធំដឹងក្តីឡើងនៅក្នុងសហគមន៍ជ្វីហ្វមួយ ដែលមនុស្សម្នាទាំងឡាយចេះជួយយកអាសារគ្នាទៅវិញទៅមកនៅ ស៊ីហេត (Sighet) នៃតំបន់ ត្រេនស៊ីលវ៉ានៀ ប្រទេសរ៉ូម៉ានី។ នៅពេលដែលគាត់មានអាយុ១៥ឆ្នាំ គ្រួសាររបស់គាត់ត្រូវបានពួកណាស៊ី (Nazis) បញ្ជូនតាមរថភ្លើង និង ជម្លៀសទៅជំរុំមរណៈ អូស្វីច (Auschwitz)។ ម្តាយ និង ប្អូនស្រីម្នាក់របស់ លោកវីសែល បានស្លាប់នៅ អូស្វីច ហើយបងស្រីពីរនាក់ បានចៀសផុតពីការស្លាប់។ បន្ទាប់មក លោក វីសែល និង ឪពុករបស់គាត់ ត្រូវបានគេបញ្ជូនទៅ ប៊ូឆិនវ៉ាល់ (Buchenwald) ហើយនៅទីនោះ គឺជាកន្លែងដែលគេបានសម្លាប់ឪពុករបស់គាត់។ នៅក្នុងជីវប្រវត្តិរបស់គាត់ លោក វីសែល បានសរសេរថា “ខ្ញុំនឹងមិនអាចបំភ្លេចរាត្រីនោះបានទេ។ ក្នុងរាត្រីទីមួយ នៅក្នុងជំរុំជារាត្រីដែលបានប្រែជីវិតរបស់ខ្ញុំឲ្យធ្លាក់ចូលក្នុងរាត្រីមួយដ៏វែង គឺជាបណ្តាសាដាក់ខ្ញុំចំនួនប្រាំពីរដង និង មានភាពបិទងងឹតចំនួនប្រាំពីរដង។ ខ្ញុំនឹងមិនអាចបំភ្លេចមុខក្មេងតូចៗ ដែលខ្ញុំបានឃើញខ្លួនប្រាណរបស់ពួកគេក្លាយទៅជាកម្រងផ្សែង ក្រោមមេឃពណ៌ខៀវដ៏ស្ងប់ស្ងាត់។ ខ្ញុំនឹងមិនអាចបំភ្លេច នូវអណ្តាតភ្លើងដែលបានដុតបំផ្លាញសេចក្តីជំនឿជាអមតៈរបស់ខ្ញុំទ។ ខ្ញុំនឹងមិនអាចបំភ្លេចភាពស្ងប់ស្ងាត់នារាត្រីនោះ ជារាត្រីដែលបានឆក់យកភាពចង់រស់រានមានជីវិតបន្តទៅទៀតជានិរន្តរ៍របស់ខ្ញុំទៀតឡើយ។ ខ្ញុំនឹងមិនអាចបំភ្លេចរឿងរ៉ាវទាំងអស់នេះបានទេ ទោះបីជាខ្ញុំអាចមានជីវិតវែងដូចជា ព្រះជាម្ចាស់ ក៏ដោយចុះ។ ខ្ញុំមិនអាចបំភ្លេចបានទេ”។

លោក វីសែល បានលះបង់ជីវិតរបស់គាត់ ក្នុងការធ្វើយ៉ាងណា ដើម្បីកុំឲ្យពិភពលោកភ្លេច នូវមហាវិនាសកម្ម ដែលបង្កឡើងដោយពួកណាស៊ី និង កុំឲ្យមហាវិនាសកម្មនេះ កើតឡើងម្តងទៀត។ បន្ទាប់ពីសង្គ្រាមបានបញ្ចប់ទៅ លោក វីសែល បានក្លាយទៅជាអ្នកសារព័ត៌មាននៅទីក្រុងប៉ារីស ដោយបានបញ្ចប់ភាពស្ងប់ស្ងាត់របស់គាត់អំពី អំពើប្រល័យពូជសាសន៍ជ្វីហ្វ (Holocaust) តាមរយៈការបោះពុម្ពសៀវភៅដែលមានចំណងជើងថា “រាត្រីមួយនៅក្នុងឆ្នាំ១៩៥៨”។ ដោយមានការបកប្រែចំនួន២៥ភាសា និង ការបោះពុម្ពរាប់លានក្បាលជុំវិញពិភពលោកនោះ សៀវភៅ “រាត្រី” នេះ គឺជាសាច់រឿងយ៉ាងច្បាស់ស៊ីជម្រៅមួយរៀបរាប់អំពីជំរុំមរណៈរបស់ពួកណាស៊ី។ លោក វីសែល បានសរសេរសៀវភៅច្រើនជាង៤០ក្បាល ហើយបានទទួលរង្វាន់ជាច្រើនសម្រាប់ ការសរសេរ និង ការតស៊ូមតិរបស់គាត់។ គាត់ធ្លាប់ធ្វើជាប្រធាន គណៈកម្មការប្រធានាធិបតីស្តីពីអំពើប្រល័យពូជសាសន៍ជ្វីហ្វ (President’s Commission on the Holocaust) ហើយ លោក គឺជាប្រធានស្ថាបនិកក្រុមប្រឹក្សាការចងចាំអំពើប្រល័យពូជសាសន៍ជ្វីហ្វនៅសហរដ្ឋអាមេរិក (US Holocaust Memorial Council)។ សម្រាប់ការងារអក្សរសិល្ប៍ និង សកម្មភាពសិទ្ធិមនុស្ស គាត់បានទទួលរង្វាន់ ជាច្រើន រួមមាន មេដាយសេរីភាពរបស់ប្រធានាធិបតី (Presidential Medal of Freedom), មេដាយមាសសមាជអាមេរិក (US Congressional Gold Medal) និង រង្វាន់មេដាយសេរីភាព (Medal of Liberty Award) ព្រមទាំងទទួលបាន ឋានន្តរសក្តិ ក្នុងក្របខ័ណ្ឌកិត្តិយសរបស់ប្រទេសបារាំង (Grand-Croix French Legion of Honor)។ នៅក្នុងឆ្នាំ១៩៨៦ គាត់បានទទួលពានរង្វាន់ណូបែលសន្តិភាព (Nobel Peace Prize)។ លោក វីសែល បង្រៀននៅសាកលវិទ្យាល័យបូស្តុន (Boston University) និង ធ្វើដំណើរជុំវិញពិភពលោក ដើម្បីតស៊ូមតិលើផ្នែកសិទ្ធិមនុស្ស និង ការពិភាក្សាអំពីបញ្ហាក្រមសីលធម៌។

លោកស្រី យៃរី ខិណ្ឌិឌី ("KK")៖ ហេតុអ្វីបានជាអ្នកមិនព្រមចុះចាញ់? ចំពោះអ្វីដែលថា គ្មានបុគ្គលណាមួយអាចធ្វើអ្វីបាននោះទេ ចំពោះភាពអាក្រក់នៅក្នុងពិភពលោកនេះ? តើមានអ្វីជម្រុញឲ្យអ្នកចេះតែបន្តការងារនោះ?

លោកបណ្ឌិត វីសែល៖ នៅពេលដែលអ្នកគិតដល់អ្នកដទៃ អ្នកនឹងដឹងថា ត្រូវធ្វើអ្វីមួយ។ ប្រសិនបើខ្ញុំគិតអំពីខ្លួនខ្ញុំ ខ្ញុំប្រហែលជាមិនធ្វើរឿងបែបនេះច្រើននោះទេ។ តើមានអ្វីខ្លះដែលគេអាចធ្វើសម្រាប់ខ្ញុំ ហើយគេមិនទាន់បានធ្វើនៅឡើយនោះ? ខ្ញុំគិតដល់ក្មេងសព្វថ្ងៃដែលត្រូវការសម្លេងរបស់ពួកយើង, គ្នាអាចត្រូវការវត្តមានរបស់ពួកយើង, គ្នាអាចត្រូវការជំនួយរបស់ពួកយើង ហើយយ៉ាងហោចណាស់ គ្នាត្រូវការអារម្មណ៍របស់ពួកយើង។ ខ្ញុំបានគិតដល់ក្រុមជនភាគតិច រួមមាន៖ ក្រុមជនភាគតិចផ្នែកសង្គម, ក្រុមជនភាគតិចផ្នែកជាតិពន្ធ, ក្រុមជនភាគតិចផ្នែកសាសនា ឬ ក្រុមជនភាគតិចផ្នែកសុខភាព, ជនរងគ្រោះដោយសារជម្ងឺអេដស៍ ឬ មនុស្សចាស់រងគ្រោះដោយសារជម្ងឺវិកលចរិក។ ដូច្នេះហើយ អ្នកមិនមានសិទ្ធិនិយាយថា "ដោយសារខ្ញុំមិនអាចធ្វើអ្វីបាន, ខ្ញុំមិនគួរធ្វើអ្វីមួយនោះទេ"។ លោក កាមូ (Albert Camus) បាននិយាយនៅក្នុងស្នាដៃនិពន្ធជាច្រើនរបស់គាត់ (ហើយជាការលើកឡើងដ៏អស្ចារ្យ) ថា អ្នកត្រូវស្រមៃឃើញថា ស៊ីស៊ីផឺស (Sisyphus) រីករាយចិត្ត។ សម្រាប់ខ្ញុំ ខ្ញុំមិនស្រមៃឃើញ ស៊ីស៊ីផឺស រីករាយចិត្តនោះទេ ប៉ុន្តែ ខ្ញុំស្រមៃឃើញអ្នកផ្សេងទៀតមិនរីករាយចិត្ត។ ហើយដោយសារតែអ្នកផ្សេងមិនរីករាយចិត្តនោះ ខ្ញុំគ្មានសិទ្ធិមិនជួយកាត់បន្ថយភាពមិនរីករាយចិត្តរបស់ពួកគាត់នោះទេ។

KK៖ កាលនៅវ័យកុមារ តើអ្នកអាចបន្តរស់មានជីវិតយ៉ាងដូចម្តេច ក្រោយពេលដែលឪពុករបស់អ្នកស្លាប់បាត់បង់ជីវិតទៅ?

វីសែល៖ ក្រោយពេលគាត់ស្លាប់បាន ពីរ បីខែ ការរំដោះក៏បានកើតមានដែរ។ នៅក្នុងរយៈពេលប៉ុន្មានខែនោះ ខ្ញុំអាចនឹងស្លាប់គ្រប់ថ្ងៃ និង គ្រប់ពេល។ ខ្ញុំមិនមានឆន្ទៈដើម្បីរស់នោះទេ។ ហើយបើទោះបីជាខ្ញុំនិយាយនៅថ្ងៃនេះថា នៅពេលនោះខ្ញុំចង់រស់ដើម្បីផ្តល់កសិណសាក្សីនោះ ក៏វាមិនពិតដែរ។

KK៖ តើអ្នកគិតថា ព្រះជាម្ចាស់បានប្រទាននូវអំណោយពិសេសសម្រាប់អ្នកក្នុងការធ្វើជាសាក្សីចំពោះអំពើមហាវិនាសកម្មនោះ ឬ ការដែល អ្នកនៅរស់រានមានជីវិតជាការចៃដន្យ?

វីសែល៖ វាគឺជាការចៃដន្យ។ ខ្ញុំមិនចង់ហៅវាថា ជាអព្ភូតហេតុនោះទេ ពីព្រោះវាអាចនឹងមានន័យថា ព្រះជាម្ចាស់សម្តែងអព្ភូតហេតុសម្រាប់ខ្ញុំតែម្នាក់ឯង។ វាមានន័យថា ព្រះជាម្ចាស់គួរតែបានសម្តែងអព្ភូតហេតុច្រើនជាងនេះ សម្រាប់បុគ្គលដទៃទៀតដែលមានតម្លៃជាងរូបខ្ញុំ ឬ យ៉ាងហោចណាស់អ្នកដែលមិនអាក្រក់ជាងខ្ញុំ។ គឺថា ខ្ញុំមិនគិតអញ្ចឹងទេ។ វាគឺជាសំណាងបំផុតមួយ។ ខ្ញុំគ្រាន់តែបាននៅទីកន្លែងនោះ ហើយមានមនុស្សជាច្រើនឈរពីមុខខ្ញុំ។ គ្រាន់តែនៅពេលដែលពួកគេចេញផុតភ្លាម ទ្វារក៏បានបិទភ្លាមដែរ។ ខ្ញុំនៅទីនោះរាល់ថ្ងៃ និង នៅវិនាទីចុងក្រោយ មនុស្សដែលគេត្រូវយកទៅសម្លាប់មានចំនួនគ្រប់គ្រាន់ហើយ។ នៅពេលនោះ ប្រសិនបើខ្ញុំឈរនៅមុខប្រាំជួរ ពេលនេះ ខ្ញុំនឹងគ្មានវត្តមាននៅទីនេះទេ។

KK៖ តើអ្នកគិតថាមានផែនការរបស់ព្រះដែរឬទេ?

វីសែល៖ ទេ ខ្ញុំមិនជឿទេ។ ខ្ញុំមិនដឹងថាត្រូវមានប្រតិកម្មចំពោះរឿងនេះយ៉ាងម៉េចនោះទេ។ ខ្ញុំមិនអាចទទួលយកបាននោះទេ។ ខ្ញុំតែងតែចោទសួរពីបញ្ហាព្រះពេញមួយជីវិតរបស់ខ្ញុំហើយ។

KK៖ តើអ្នកអាចអធិប្បាយអំពីទំនាក់ទំនងរវាង សេចក្តីក្លាហាន និង សេចក្តីស្រលាញ់ តាមរយៈបទពិសោធន៍របស់អ្នកបានដែរឬទេ? តើសេចក្តីសង្ឃឹមរបស់អ្នកកើតចេញមកពីណា?

វីសែល៖ វាសាមញ្ញណាស់។ មានតែបុគ្គលម្នាក់ទេ ដែលអាចផ្តល់សេចក្តីសង្ឃឹមដល់ខ្ញុំបាន ហើយក៏មានតែបុគ្គលម្នាក់ដែរ ដែលអាចដកសេចក្តីសង្ឃឹមពីខ្ញុំបាន។ គឺមិនមែនព្រះជាម្ចាស់ទេ។ គឺបុគ្គលមួយរូបគឺជាមនុស្សលោក។ ជាចុងក្រោយ ទំនាក់ទំនងរបស់យើងជាមួយអ្នកដទៃ ជះឥទ្ធិពលលើជោគវាសនារបស់យើងផ្ទាល់។ ជាការពិតណាស់ ឥរិយាបថសីលធម៌ និង ជោគវាសនាផ្ទាល់ខ្លួនរបស់យើង (អាចជាសេចក្តីស្រលាញ់, ជាមិត្តភាព ជាជំនឿចិត្តដ៏មុតមាំ) មានទំនាក់ទំនងជាមួយអ្នកដទៃ។ ទោះជាវាមានអត្ថន័យយ៉ាងដូចម្តេចក៏ដោយ ក៏ទំនាក់ទំនងជាមួយនរណាម្នាក់ផ្សេងទៀត មិនមែនមានន័យថា ជាទំនាក់ទំនងរវាងខ្ញុំ និង ព្រះឡើយ។ រាល់ច្បាប់ និង សីលធម៌ទាំងអស់ បកស្រាយអំពីចំណងទាក់ទងរបស់មនុស្ស។ នៅក្នុងប្រពៃណីដែលខ្ញុំរស់នៅ នៅក្នុងជីវិតរបស់ខ្ញុំ យើងមិនដែលមានការគុំគួន មិនមានការអាក់អន់ស្រពន់ចិត្ត មិនមានការភ័យខ្លាចនៅក្នុងគ្រួសាររបស់ខ្ញុំនោះទេ។ វាជាប្រភព នៃកម្លាំង, នៃសេចក្តីជំនឿ តាមរយៈឪពុកនិងម្តាយរបស់ខ្ញុំ។ ប្រហែលជាខ្ញុំមានវ័យក្មេងពេក នៅពេលដែលខ្ញុំបានចាកចេញពីពួកគាត់។

KK៖ ១៥ឆ្នាំ?

វីសែល៖ ត្រូវហើយ។ ប្រសិនបើខ្ញុំបានរស់នៅជាមួយពួកគាត់យូរជាង

នេះ ខ្ញុំប្រហែលជាទទួលបាននូវបញ្ហាជាច្រើនជាមួយឪពុកម្តាយដូចដែលក្មេងៗបច្ចុប្បន្ននេះជួបប្រទះ។ ខ្ញុំមិនដឹងដែរ។ ប្រហែលជាអញ្ចឹង។

KK៖ ចុះកូនប្រុសរបស់លោកផ្ទាល់?

វីសែល៖ កូនប្រុសរបស់ខ្ញុំ គឺជាបណ្តូលជីវិតរបស់ខ្ញុំ។ គាត់ជាបណ្តូលនៃបណ្តូលជីវិតរបស់ខ្ញុំ។ ឥឡូវនេះ គាត់មានអាយុ២៦ឆ្នាំហើយ។ ខ្ញុំគឺជាឪពុកឆ្កួតម្នាក់។ ប៉ុន្តែ កូនប្រុសរបស់ខ្ញុំមិនចូលចិត្តឲ្យខ្ញុំនិយាយពីគាត់នោះទេ។

KK៖ លោកបានសរសេរថា អ្វីដែលបានជម្រុញទឹកចិត្តរបស់លោកគឺ ភាពក្លាហាន និង ការប្តេជ្ញាចិត្តរបស់ជនជាតិជ្វីហ្វ ក្នុងការស្មោះស្ម័គ្រនឹងសេចក្តីជំនឿរបស់ខ្លួន ទោះបីជាកំពុងប្រឈមមុខនឹងភាពទុច្ចរិត និង មិនមានអំណាចក្នុងការតស៊ូប្រឆាំងក៏ដោយ។ សូមចែករំលែកអំពីសមានចិត្តសណ្តោសប្រណីរបស់ លោក ចំពោះអ្នកដែលគ្មានអំណាច។

វីសែល៖ ចំពោះខ្ញុំ អ្នកដែលគ្មានអំណាច ជាមនុស្សសំខាន់បំផុត ជាអ្នកទន់ខ្សោយ និង ជាអ្នកតូចតាច។ អញ្ចឹងហើយ សម្រាប់ខ្ញុំ នៅក្នុងគ្រប់សៀវភៅរបស់ខ្ញុំ, នៅក្នុងគ្រប់ស្នាដៃប្រលោមលោករបស់ខ្ញុំតែងតែមានតួអង្គកុមារ, តែងតែមានតួអង្គមនុស្សចាស់ និង តួអង្គមនុស្សឆ្កួត។ ពីព្រោះ ពួកគេតែងតែត្រូវរដ្ឋាភិបាល និង សង្គមមិនយកចិត្តទុកដាក់ជាខ្លាំង។ ដូច្នេះ ខ្ញុំផ្តល់ជម្រកមួយដល់ពួកគេ។ ហើយនោះ ក្នុងកុមារភាពរបស់ខ្ញុំ ខ្ញុំបានចូលចិត្តជនជាតិជ្វីហ្វ ហើយនៅតែចូលចិត្តរហូតដល់សព្វថ្ងៃ។ កាលពីច្រើនឆ្នាំមុននោះ ខ្ញុំបានទៅចំណាយពេលពេញៗមួយរសៀល ជាមួយអ្នកនិពន្ធជ្វីហ្វ (Yiddish) ដែលមិនមានអ្នកអាន ដោយសារតែពួកគេត្រូវបានសង្គមផាត់ចោល។ ខ្ញុំធ្វើបែបនោះ ដើម្បីឲ្យពួកគាត់មានអារម្មណ៍ថា មានអ្នកអានស្នាដៃរបស់ពួកគាត់។

KK៖ វាជាការសំខាន់ក្នុងការចូលទៅដល់ជិតមនុស្សដែលត្រូវគេផាត់ចោល ...

វីសែល៖ ត្រូវហើយ គឺចូលទៅដល់ជិតមនុស្សដែលមានអារម្មណ៍ថាគ្មានអ្វីដែលមានតម្លៃនោះ និង អ្នកដែលមានអារម្មណ៍ថា ខ្លួនត្រូវគេបំភ្លេចចោល។ ជាការពិតណាស់ ចំពោះបញ្ហាការរំលោភសិទ្ធិមនុស្ស, ចំពោះអ្នកទោស គ្មានអ្វីដែលអាក្រក់ជាងការដែលខ្លួនមានអារម្មណ៍ថាខ្លួនត្រូវបានគេបំភ្លេចចោលនោះទេ។ ជាធម្មតា អ្នករំលោភសិទ្ធិអ្នកដទៃ និង អ្នកធ្វើទារុណកម្ម តែងប្រើទឡ្ហីករណ៍នេះ ដើម្បីបំផ្លាញទឹកចិត្តរបស់អ្នកទោស ដោយនិយាយថា អ្នកដឹងអត់ថា គ្មានអ្នកណាគេខ្វល់នោះទេ។ គ្មាននរណាខ្វល់នោះទេ។ ឧទាហរណ៍ ដូចនេះហើយបានជានៅក្នុងសន្និសីទមួយក្នុងទីក្រុងវ៉ាស៊ីនតោនស្តីពីស្នាដៃសិល្បៈ និង លុយដែលគេលួចយកទៅបាត់ ខ្ញុំបានសួរថា "ហេតុអ្វីក៏យឺតម្លេះ? ហេតុអ្វីទើបមានគំនាបសង្កត់នៅពេលនេះ?" រឿងដែលសំខាន់ គឺយើងភ្លេចជនរងគ្រោះភាគច្រើនដែលមិនមែនជាអ្នកមាន។ សត្រូវបានលួចយកភាពក្រីក្ររបស់ពួកយើង ហើយគ្មានអ្នកណាម្នាក់និយាយអំពីរឿងនេះសោះ។ គេនិយាយតែពីទ្រព្យសំណាង និង វិចិត្រសាលរបស់អ្នកមានតែប៉ុណ្ណោះ។ ចុះចំណែកបញ្ហាភាពក្រីក្ររបស់អ្នកក្រវិញ? ពេលខ្លះនៅពេលដែលខ្ញុំនិយាយ គេស្តាប់ ប៉ុន្តែ ពួកគេមិនឮនោះទេ។

ខ្ញុំជំពាក់អ្វីម្យ៉ាងចំពោះមនុស្សដែលត្រូវគេបំភ្លេចចោលទាំងនេះ។ ពួកយើងដែលអាចមានភាពពេញចិត្តចំពោះជីវិត, ដែលអបអរសាទរយុវវ័យ, ដែលអបអរសាទរភាពខ្លាំងរបស់ខ្លួន យើងបានមើលឃើញពាសពេញពីការផ្សាយពាណិជ្ជកម្មតាមទូរទស្សន៍ ដែលមានតែស្រីស្រស់ស្អាត, មានតែបុរសវ័យក្មេងមានសុខភាពល្អ នេះហើយជាការបង្ហាញ ពីការបដិសេធមួយបែបចំពោះអ្នកដែលមិនមានវ័យក្មេង, អ្នកដែលមិនមានសុខភាពល្អ និង អ្នកដែលមិនមែនជាអ្នកមាន។ ដូច្នេះហើយ បានជាខ្ញុំមានអារម្មណ៍ថា ខ្ញុំជំពាក់អ្វីម្យ៉ាងចំពោះពួកគាត់។ ហើយនេះក៏ជាមូលហេតុដែលខ្ញុំសរសេរ។ ហើយនេះជាអ្វីដែលខ្ញុំសរសេរ។ ខ្ញុំបានសរសេរសៀវភៅច្រើនជាង ៤០ក្បាល ប៉ុន្តែ មានតិចតួចប៉ុណ្ណោះដែលខ្ញុំសរសេរអំពីសង្គ្រាម។ ហេតុអ្វីបានជាដូច្នេះ? ពីព្រោះ ខ្ញុំជឿទៅលើការចែករំលែក។ ខ្ញុំបានដឹងរឿងរ៉ាវទាំងនោះ ដូច្នេះ ខ្ញុំត្រូវតែចែករំលែករឿងដែលខ្ញុំបានដឹង។ ខ្ញុំមានជំនក់ចិត្តយ៉ាងខ្លាំង ចំពោះការរៀនសូត្រ និង ការបង្រៀន។ ដូច្នេះហើយ សៀវភៅរបស់ខ្ញុំភាគច្រើនទាក់ទងនឹងការរៀនសូត្រ រួមមាន ពីព្រះគម្ពីរ, ពីព្យាការី, ពីជំនឿអធម្មជាតិ។

KK៖ តើមនុស្សមានភាពឃោរឃៅដោយសារអ្វី? សូមនិយាយអំពីការស្អប់ខ្ពើម។

វីសែល៖ យ៉ាងហោចណាស់ ពួកយើងស្ថិតនៅក្នុងស្ថានភាពមួយដែលយើងដឹងពីផលកម្មល្អ ឬ អាក្រក់ដែលផ្តល់ឲ្យ។ អ្វីដែលអ្នកស្អប់គេ មិនយល់ គឺថា នៅពេលដែលគេស្អប់ក្រុមណាមួយ តាមពិតទៅគេស្អប់គ្រប់ក្រុមទាំងអស់។ ការស្អប់ មានភាពឆ្លងរាលដាល ដូចជាជម្ងឺមហារីកដែរ។ វាឆ្លងពីកោសិកាមួយទៅកោសិកាមួយ, ពីឫសមួយទៅឫសមួយ, ពីមនុស្សម្នាក់ទៅមនុស្សម្នាក់, ពីក្រុមមួយទៅក្រុមមួយ។ ប្រសិនបើគេមិនបញ្ឈប់វាទេ វានឹងវាយលុកចូលទៅដល់ប្រទេសទាំងមូល ពិភពលោកទាំងមូល។ អ្នកស្អប់គេ មិនយល់ទេថា តាមពិតទៅនៅពេលដែលគេបំផ្លាញអ្នកដទៃ គេនឹងបំផ្លាញខ្លួនឯងនៅពេលក្រោយ

មក។ ការបង្ហាញពីលទ្ធផល គឺជាការបង្ហាញពីភាពដែលគួរឲ្យស្អប់ខ្ពើម។ ការសម្លាប់មនុស្សមិនដែលមានភាពរុងរឿងទេ ហើយការបន្ទាបបន្ថោកអ្នកដទៃ ក៏មិនដែលមានភាពរុងរឿងដែរ។ ភាពរុងរឿងមិនដែលកើតឡើងដោយសារការធ្វើទុក្ខបុកម្នេញលើអ្នកដទៃដែរ។ ហើយនេះជាមេរៀនដ៏សំខាន់មួយ។

KK៖ គេបានបង្រៀនអំពីរឿងនេះម្តងហើយម្តងទៀត។ តើការធ្វើដដែលៗបែបនេះមានប្រយោជន៍អ្វីទៅ?

វីសែល៖ ខ្ញុំយល់ អ្នកកំពុងចង់និយាយអំពីអ្វី។ ជាការពិតណាស់ វាមានប្រយោជន៍។ ប៉ុន្តែ ត្រលប់ទៅអ្វីដែលខ្ញុំបាននិយាយពីដំបូង ខ្ញុំដឹងថា ខ្ញុំមិនចេះអូសទាញមនុស្សឲ្យមានការផ្លាស់ប្តូរនោះទេ ប៉ុន្តែខ្ញុំបានផ្លាស់ប្តូរមនុស្ស។ មានរឿងមួយ៖ បុរសដែលមានយុត្តិធម៌ក្នុងខ្លួនម្នាក់ បានសម្រេចចិត្តថា គាត់ត្រូវតែសង្គ្រោះមនុស្សជាតិ។ ដូច្នេះគាត់បានជ្រើសរើសយកទីក្រុងមួយ ជាទីក្រុងដែលមានអំពើបាបច្រើនជាងគេបំផុត។ ឧបមាថា ជាទីក្រុង សូដុម (Sodom)។ អញ្ចឹង គាត់បានសិក្សាអំពីទីក្រុងនោះ។ គាត់បានចេះដឹងអំពីសិល្បៈនៃការជម្រុញទឹកចិត្តមនុស្ស, ការផ្លាស់ប្តូរចិត្តគំនិត, ការផ្លាស់ប្តូរទឹកចិត្ត។ គាត់បានទៅរកមនុស្សប្រុសម្នាក់ និង ស្រីម្នាក់ ហើយគាត់និយាយថា “សូមកុំភ្លេចថា ការពិឃាត មិនមែនជាអំពើល្អទេ វាជាទង្វើខុសឆ្គង”។ នៅពេលដំបូង មានមនុស្សជាច្រើនមកចោមរោមស្តាប់គាត់ វាចម្លែកណាស់ ដូចជាការលេងសៀកអញ្ចឹង។ មនុស្សម្នាមកចោមរោម និង ស្តាប់គាត់និយាយ។ គាត់ចេះតែបន្តការនិយាយមិនឈប់ឈរ។ ច្រើនថ្ងៃកន្លងផុតទៅ។ ច្រើនសប្តាហ៍កន្លងផុតទៅ។ គេលែងស្តាប់គាត់ទៀត។ ក្រោយមកជាច្រើនឆ្នាំ ក្មេងម្នាក់បានបញ្ឈប់គាត់ ហើយនិយាយថា “តើលោកកំពុងធ្វើអ្វី? លោកមិនឃើញទេឬ ថាមិនមាននរណាម្នាក់កំពុងតែស្តាប់ទេ? មូលហេតុអ្វីបានជាលោកបន្តក្នុងការស្រែកខ្លាំងឡើងម្តងហើយម្តងទៀត? មូលហេតុអ្វី?” បុរសនោះក៏បានឆ្លើយទៅកាន់ក្មេងនោះថា “ខ្ញុំនឹងនិយាយប្រាប់ថាហេតុអ្វី។ ពេលដំបូង ខ្ញុំជឿជាក់ថា ប្រសិនបើខ្ញុំស្រែកឲ្យបានឮគ្រប់គ្រាន់ ពួកគេនឹងមានការកែប្រែ។ ឥឡូវខ្ញុំដឹងថា ពួកគេនឹងមិនកែប្រែទេ។ ប៉ុន្តែ ប្រសិនបើខ្ញុំ ស្រែកកាន់តែឮជាងមុន គឺដោយសារតែខ្ញុំមិនចង់ឲ្យពួកគេកែប្រែខ្ញុំបាន។”

KK៖ បន្ទាប់ពីការស្រែកបែបនោះមក តើលោកគិតថា លោកបានធ្វើឲ្យមានការផ្លាស់ប្តូរដែរឬទេ?

វីសែល៖ អាច កន្លែងនេះបន្តិច កន្លែងនោះបន្តិច។ ខ្ញុំបានទទួលសំបុត្រមួយចំនួន យ៉ាងហោចណាស់ មួយរយសំបុត្រក្នុងមួយខែ ពីក្មេងៗដែលបានអានសៀវភៅរបស់ខ្ញុំ។ ខ្ញុំបានឆ្លើយតបទៅគ្រប់សំបុត្រទាំងអស់វិញ។ សៀវភៅដំបូងបំផុតរបស់ខ្ញុំបានចេញផ្សាយកាលពី ៤២ឆ្នាំមុន។ ខ្ញុំដឹងថា វាបានជះឥទ្ធិពលទៅលើមនុស្សមួយចំនួន។ ខ្ញុំដឹងថា វាពិតជាអញ្ចឹង។

KK៖ តើយើងអាចមានសេចក្តីក្លាហាន និង មានការប្តេជ្ញាចិត្ត ក្នុងការធ្វើឲ្យមានការផ្លាស់ប្តូរក្នុងជីវិតរបស់អ្នកដទៃ ដោយមិនធ្វើឲ្យខ្លួនយើងឈឺចាប់ដែរឬទេ?

វីសែល៖ ពិតជាអាច តាមរយៈការសិក្សាពីការឈឺចាប់របស់អ្នកដទៃ។ ហើយអ្នកអាចធ្វើបានតាមរបៀបមួយដ៏សមសួន តាមរបៀបមួយជាក់លាក់។ ប្រសិនបើបុគ្គលណាម្នាក់ទទួលរងនូវការឈឺចាប់ អ្នកមិនអាចបន្ថយការឈឺចាប់នោះបានទេ ប៉ុន្តែ មានរឿងមួយដែលអ្នកអាចទទួលបាននោះ គឺធ្វើយ៉ាងណាកុំឲ្យការឈឺចាប់ ក្លាយទៅជាឫសគល់នៃសារជាតិរបស់មនុស្ស។

KK៖ តើសេចក្តីក្លាហានមានន័យយ៉ាងដូចម្តេចសម្រាប់អ្នក?

វីសែល៖ សម្រាប់ខ្ញុំ សេចក្តីក្លាហាន គឺជាមាគ៌ាដែលយើងឲ្យនិយមន័យ។ ខ្ញុំមិនបានត្រលប់ក្រោយវិញទេ។ ក្នុងចិត្តរបស់ខ្ញុំ ខ្ញុំនៅតែជាជនភៀសខ្លួន។ ខ្ញុំខ្លាចប៉ូលីស។ ដូចនេះហើយ នៅពេលដែលខ្ញុំជួបប៉ូលីសដោយចៃដន្យ ខ្ញុំឈប់ ហើយចេញទៅឲ្យឆ្ងាយ។ ខ្ញុំទុកឲ្យប្រពន្ធរបស់ខ្ញុំជាអ្នកដោះស្រាយជាមួយប៉ូលីស។ ខ្ញុំមានការភ័យខ្លាចចំពោះឯកសណ្ឋានរបស់ពួកគេ។ ពួកឧត្តមសេនីយ៍ បានធ្វើឲ្យខ្ញុំមានការភ័យខ្លាច។ មិនមែនសេចក្តីក្លាហានទេចំពោះខ្ញុំ ដែលខ្ញុំបានប្រាប់លោកប្រធានាធិបតី រ៉ូណាល់ រីហ្គេន (Ronald Reagan) កុំឲ្យទៅប៊ីតប៊ឺក (Bitburg)។ វាជារឿងធម្មតា។ ខ្ញុំគិតថា ព្យាការី មានសេចក្តីក្លាហានដោយសារពួកគេមិនមានកន្លែងពិតប្រាកដ ហើយក៏គ្មាននរណាម្នាក់ការពារពួកគេដែរ។

KK៖ តើពួកគេមិនមានតួអង្គដ៏មានអំណាចខ្លាំងក្លាណាមួយការពារពួកគេទេឬ?

វីសែល៖ សូមបង្ហាញភស្តុតាងមក។ តើអ្នកមានអត្តសញ្ញាណជាលាយលក្ខណ៍អក្សរចារថា យើងជាព្រះជាម្ចាស់របស់សកលលោកបានតែងតាំងរូបអ្នកដែរឬទេ? គ្រាន់តែមានពួកព្យាការី ដែលបាននិយាយថា “ព្រះជាម្ចាស់បានបញ្ជូនខ្ញុំមក”។

សូមរកភស្តុតាងមកបញ្ជាក់ទៅ។ ប៉ុន្តែ គឺដោយសារបុគ្គលិកលក្ខណៈដោយសារពាក្យសម្តី គាត់និយាយតាមរយៈព្រះជាម្ចាស់។ ហើយនោះ

គឺជាសេចក្តីក្លាហានក្នុងការនិយាយការពិត។ អំណាច អាចជារបស់ប្រធានាធិបតី ឬ របស់ ព្រះមហាក្សត្រ។ អំណាច អាចជាអ្នកបំផ្លាញមនុស្ស។ ហើយអំណាចអាចជាអ្វីមួយ ដែលអ្នកត្រូវសម្តែងចេញជាមួយនឹងសេចក្តីក្លាហាន ដែលនោះ គឺការពិត។ បញ្ហាគឺថា តើអ្នកអាចរកវាបានដោយវិធីណា? ...អ្វីដែលខ្ញុំចង់បាន និង អ្វីដែលខ្ញុំសង្ឃឹមក្នុងមួយជីវិតរបស់ខ្ញុំនោះ គឺកុំឲ្យអតីតកាលរបស់ខ្ញុំ ក្លាយជាអនាគតរបស់កូនៗរបស់អ្នក។



John Heffernan, Kerry Kennedy, កូនស្រី របស់គាត់ Michaela Kennedy-Cuomo, លោក វ៉ាន់ ណាត (សារៈមន្ទីរទួលស្លែង, ខែកុម្ភៈ ឆ្នាំ២០១១)

# ការនិយាយការពិតឆ្លើយតបទៅនឹងអំពើប្រល័យពូជសាសន៍

## លោក អ៊ុលី វីសែល (Elie Wiesel)

## បញ្ហាសិទ្ធិមនុស្ស៖ អំពើប្រល័យពូជសាសន៍

### សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស

- មាត្រា ៣៖ សិទ្ធិក្នុងការរស់រានមានជីវិត,
សិទ្ធិមានសេរីភាព, សិទ្ធិមានសន្តិសុខផ្ទាល់ខ្លួន

### សំណួរណែនាំ

- តើយើងអាចក្លាយទៅ លោក អ៊ីលី វីសែល តាមរបៀបណា?
- តើថ្នាក់នេះអាចធ្វើអ្វីខ្លះក្នុងការចងចាំអំពី
អំពើប្រល័យពូជសាសន៍ជ្វីហ្វ (Holocaust) និង ក្លាយជាអ្នកការពារ
សិទ្ធិមនុស្សប្រឆាំងនឹងអំពើប្រល័យពូជសាសន៍តាមរបៀបណា?

### តម្រូវការពេលវេលា

៤០ ទៅ ៨០នាទី

### គោលបំណង

បន្ទាប់ពីមេរៀននេះ សិស្សនឹងអាច៖

- យល់ដឹងថា តើលោក Elie Wiesel ជានរណា និង មូលហេតុអ្វី
បានជាគាត់ក្លាយជាអ្នកការពារសិទ្ធមនុស្ស។
- រៀនថា តើឧទាហរណ៍របស់គាត់អាចផ្តល់ការលើកទឹកចិត្តដល់
សិស្សក្នុងការក្រោកឈរប្រឆាំងនឹងអំពើប្រល័យពូជសាសន៍ ក្នុង
ពេលបច្ចុប្បន្ននេះដូចម្តេច។

### ជំនាញរបស់សិស្ស

- ការគិតពិចារណា
- ការធ្វើសេចក្តីសន្និដ្ឋាន
- ការរៀបចំ និងការបកស្រាយព័ត៌មាន
- ការចូលរួមជាក្រុមលើផែនការ និងកិច្ចពិភាក្សា
- ការសហការគ្នា ដើម្បីសម្រេចនូវគោលដៅ

### វាក្យស័ព្ទ៖

- អ្នកការពារ
- អំពើប្រល័យពូជសាសន៍
- សិទ្ធមនុស្ស
- អំពើប្រល័យពូជសាសន៍ជ្វីហ្វ / ហលឡូខស៍ (Holocaust)
- គ្រីស្តលណាជ៍ (Kristallnacht)
- ភាពធម្មតានៃទុច្ចរិតភាព ("Banality of Evil")
- តុលាការ ណឺរឹមប៊ឺក (Nuremburg Tribunal)
- សារៈមន្ទីរការចងចាំ
- ការប៉ះទង្គិចផ្លូវចិត្ត / ការព្យាបាល
- អ្នករស់រានជីវិតទួលស្លែង៖
    - លោក វ៉ាន់ ណាត
    - លោក ប៊ូ ម៉េង
    - លោក ជុំ ម៉ី

### គោលគំនិត

- សិទ្ធិមនុស្ស
- ភាពជាពលរដ្ឋពិភពលោក
- យុត្តិធម៌
- រដ្ឋាភិបាល
- អំណាច
- ការទទួលខុសត្រូវបុគ្គលម្នាក់ៗ

### ព័ត៌មានសម្រាប់គ្រូបង្រៀន៖

- សិស្សគួរតែមានការយល់ដឹង អំពើប្រល័យពូជសាសន៍ជ្វីហ្វ
(Holocaust)។

### សម្ភារៈសិក្សា

- ក្តាផ្ទាំងក្រដាសមាំ (posters) សម្រាប់សិស្សនិស្សិតនីមួយៗ
- ឯកសារអំពី អ៊ុលី វីសែល

# សកម្មភាពរបស់សិស្សនិស្សិត

## ស្ថានភាពព្រាងទុក

- ចែកជូននូវឯកសារការធ្វើបទសម្ភាស របស់ លោក អ៊ីលី វីសែល (Elie Wiesel) ដល់សិស្សនិស្សិត
- គ្រូបង្រៀន គួរតែគូសបញ្ជាក់ អំពីឥទ្ធិពល របស់ លោក វីសែល ក្នុងការនិយាយអំពី សន្តិភាពនៅជុំវិញពិភពលោក។ ប្រហែលជា សមិទ្ធិផល ដ៏ធំធេងរបស់ លោក វីសែល គឺការជួយបង្កើត សារៈមន្ទីរការចងចាំអំពី អំពើប្រល័យ ពូជសាសន៍ជ្វីហ្វ (US Holocaust Memorial Museum) នៅក្នុងទីក្រុង វ៉ាស៊ីនតោនឌីស៊ី។ នៅក្នុងនោះ គាត់ជា ប្រធានស្ថាបនិក។ គ្រូបង្រៀនគួរពន្យល់ថា ជាឥទ្ធិពលរបស់ លោក វីសែល ដែល សារៈមន្ទីរបានចាប់ផ្តើមនៅក្នុងឆ្នាំ១៩៩៣ ជាសារៈមន្ទីរចងចាំដោយរស់រវើករបស់ ជនរងគ្រោះនៃ អំពើប្រល័យពូជសាសន៍ ជ្វីហ្វ (Holocaust) ហើយជាការរំលឹកមួយ នៃតម្លៃសម្ងប់នៅក្នុងពិភពលោក។ តាំងពីនោះមកភ្ញៀវទេសចរជាង ៣៤លាននាក់ បានមកទស្សនាការតាំង ពិព័ណ៌នោះ ភាគច្រើនគេ អាចមើលឃើញ តាមរយៈវីដេអូខ្លីៗផលិតដោយសារៈមន្ទីរ នោះ។ www.ushmm.org
- សារៈមន្ទីរការចងចាំអំពី អំពើប្រល័យ ពូជសាសន៍ជ្វីហ្វ (US Holocaust Memorial Museum) www.Youtube.com

## សកម្មភាព

- គ្រូបង្រៀន នឹងស្នើសុំថាមធ្យោបាយមួយ ដែលសិស្ស អាចអនុវត្តតាមជំហានរបស់ លោក វីសែល គឺលើកកម្ពស់ការយល់ដឹង អំពីអំពើប្រល័យពូជសាសន៍ ចំពោះ សិស្ស និង សហគមន៍ ក្នុងការបង្កើតក្នុង ថ្នាក់សារៈមន្ទីរការចង់ចាំ របស់ពួកគេ។
- សិស្សម្នាក់ៗ នឹងត្រូវបាន ផ្តល់ឲ្យក្តារ ផ្ទាំងក្រដាសមាំ (posters) មួយសន្លឹក ធំ។ ហើយបន្ទាប់មកទៀត បានស្នើសុំឲ្យ ជ្រើសរើសដោយចៃដន្យនូវប្រធានបទ ដូចខាងក្រោម៖
  - ជីវិតរស់នៅជ្វីហ្វ នៅ អឺរ៉ុប មុន ហូឡូខស៍ (Holocaust)
  - តួនាទីនៃឃោសនាណាស៊ី ក្នុងការ បង្កើតហូឡូខស៍ (Holocaust)
  - ក្រុមយុវជន យុវនារី របស់ អ៊ីត្លែ (Hitler)
  - គ្រីស្តុលណាដ៍ (Kristallnacht)
  - ច្បាប់ ណ័រឹមបឺក (Nuremberg)
  - ប្រព័ន្ធមណ្ឌលមរណៈ
  - ពេលណាស៊ី គ្រប់គ្រងអឺរ៉ុប
  - ក្រុមពិឃាតចល័ត គេហៅថា អែនសាតគ្រូពែន (Einsatzgruppen)
  - ប្រព័ន្ធហ្គេតូ (ghetto)
  - អូស្វីដ៍ (Auschwitz)
  - កុមារនៅ ហូឡូខ័ស៍ (Holocaust)
  - តួនាទីរបស់ អ្នកឈរមើល ស្ងៀមស្ងាត់
  - អូស្កា សិនឡើ (Oscar Schindler) ជាអ្នកជួយរំដោះ ហូឡូខស៍ (Holocaust)
  - រ៉ូល វលលែនបឹក (Raoul Wallenberg) ជាអ្នកជួយរំដោះ ហូឡូខស៍ (Holocaust)
  - ការរណបជ័យនៃណាស៊ី និង ការសង្គ្រោះមណ្ឌលមរណៈ
  - សវនាការ ណួរឹមបឺក (Nuremberg) និង តួនាទីព្រះរាជអាជ្ញា រ៉ូបឺត អេដ៍ ចាកសិន (Robert H. Jackson)
  - ការនឹករំលឹកដល់ ហូឡូខស៍ (Holocaust) ដោយសារៈមន្ទីរ ចងចាំជុំវិញពិភពលោក ក្នុង ពេលបច្ចុប្បន្ន។
  - សារៈមន្ទីរការចងចាំអំពី អំពើ ប្រល័យពូជសាសន៍ជ្វីហ្វ (US Holocaust Memorial Museum)
  - អំពើប្រល័យពូជសាសន៍ នៅ ប្រទេស អាម៉ានី (Armenia)
  - អំពើប្រល័យពូជសាសន៍នៅ កម្ពុជា
  - អំពើប្រល័យពូជសាសន៍នៅ ប្រទេស រ៉្វាន់ដា(Rwanda)
  - អំពើប្រល័យពូជសាសន៍នៅតំបន់ ដាហ្វ៊ូរ (Darfur)
  - សិទ្ធិមនុស្សនៅប្រទេស កុងហ្គោ (Congo)
  - ផ្ទាំងក្រដាសមួយ (poster) អំពី ការជោគជ័យរបស់ លោក អ៊ីលី វីសែល ជាអ្នកការពារសិទ្ធិមនុស្ស
  - ផ្ទាំងក្រដាសមួយ (poster) អំពី សៀវភៅ"សេចក្តីក្លាហានគ្មាន ព្រំដែន" និពន្ធដោយ លោកស្រី ឃែរី ខិណ្ឌិឌី
  - ផ្ទាំងក្រដាសមួយ (poster) ពន្យល់អំពីគោលការណ៍នៃ គម្រោងនេះ (ក្លាយជាអ្នកការពារ ប្រឆាំងអំពើប្រល័យពូជសាសន៍ ដូច លោក អ៊ីលី វីសែល)។ ផ្ទាំងក្រដាសនេះ (poster) គួរមាន ការចុះ ហត្ថលេខាពីសិស្សនិស្សិត ក្នុងការបង្ហាញការប្តេជ្ញាចិត្តរបស់ ពួកគេជាអ្នកការពារ
  - ធ្វើកិច្ចការនៅក្នុងថ្នាក់ ឬ នៅផ្ទះ រវាង ពីរ បី ថ្ងៃ, សិស្សនិស្សិតនឹង បង្កើតផ្ទាំងក្រដាសមួយដែល ពន្យល់អំពីគម្រោង។ ដោយមាន មគ្គុទេសគូសបញ្ជាក់ពីលោកគ្រូ អ្នកគ្រូ មក។

# ក្លាយជាអ្នកការពារ

ពេលបានបំពេញផ្ទាំងក្រដាស (posters) ទាំងអស់នេះ រួចរាល់ហើយ សិស្សទាំងអស់នោះ នឹងគោរពចំពោះស្នាដៃរបស់លោក វីសែល ដោយ បង្កើតសារៈមន្ទីរចងចាំរស់រវើកអំពី អំពើប្រល័យពូជសាសន៍ធ្វីហ្វ របស់ពួកគេ។ ក្នុងកិច្ចការ គ្រូបង្រៀនគួរតែអនុវត្តន៍នូវវិធានការ ដូចតទៅ៖

- ចាត់សិស្សទាំងអស់នេះជាក្រុម និង ប្រមូលផ្ទាំងក្រដាស (posters) របស់ពួកគេដាក់តាមលំដាប់កាលប្បវត្តិនៃប្រធានបទនីមួយៗ។ បន្ទាប់មក រៀបចំផ្ទាំងក្រដាស (posters) នេះនៅក្នុងបន្ទប់រៀន ឬ ដាក់នៅបន្ទប់ទូលាយណាមួយទៀត ដូចជា បណ្ណាល័យ, រោងសម្រាប់បរិភោគអាហារ។ល។

- ស្នើឲ្យសិស្សមកឈរនៅចំពីមុខផ្ទាំងក្រដាសរបស់ពួកគេ ដើម្បីពន្យល់អំពីប្រធានបទដល់ សិស្សនិស្សិតផ្សេងៗទៀត ក្នុងថ្នាក់របស់គេ ឬ ថ្នាក់ផ្សេងទៀត ដែលមិនទាន់បានសិក្សា អំពើប្រល័យពូជសាសន៍ធ្វីហ្វ (Holocaust)។ ការធ្វើដូច្នេះ ផ្តល់ប្រយោជន៍បន្ថែមក្នុងការ ធ្វើឲ្យក្លាយជាអ្នកការពារ ដែលជាគម្រោងរបស់យើង។

- គ្រូបង្រៀនអាចអញ្ជើញអ្នករស់រានមានជីវិតពី អំពើប្រល័យពូជសាសន៍ បន្ទាប់ពីការណែនាំរបស់សិស្សនិស្សិត។ សិស្សនិស្សិត និង អ្នករស់រានមានជីវិតអាចប្រៀបធៀបអំពី អំពើប្រល័យពូជសាសន៍នៅកម្ពុជា និង អំពីអំពើប្រល័យពូជសាសន៍ធ្វីហ្វ (Holocaust)។ ធ្វើបែបនេះ ជួយឲ្យការរៀនសូត្រស៊ីជម្រៅ, លើកកម្ពស់កិច្ចការរបស់សិស្សនិស្សិត និង ផ្តល់ការគោរព ជូនដល់អ្នករស់រានមានជីវិត។

- ប្រសិនបើចង់បានព័ត៌មានបន្ថែមក្នុងការបញ្ចូលមេរៀនទៅក្នុងថ្ងៃការចងចាំអំពី អំពើប្រល័យពូជសាសន៍ សូមទាក់ទងស៊ីវីកហ៊ុស៖ មជ្ឈមណ្ឌលអប់រំដើម្បីពលរដ្ឋខ្មែរ និង សមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យ។

# ព័ត៌មានបន្ថែម

### មូលនិធិអេជីស (AEGIS Trust)

www.aegiestrust.org

អង្គការមិនយកកម្រៃមួយ ដែលធ្វើយុទ្ធនាការប្រឆាំងនឹង អំពើប្រល័យពូជសាសន៍ និង ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ អង្គការមូលនិធិអេជីស (Aegis Trust) ផងដែរ រៀបចំ មជ្ឈមណ្ឌលរំឭក (Kigali Memorial Center) នៅប្រទេសរ៉្វាន់ដា, និង មជ្ឈមណ្ឌលរំឭក និង អប់រំមហាវិនាសកម្ម អំពើប្រល័យពូជសាសន៍ធ្វីហ្វ (Holocaust Memorial and Educational Center) នៅប្រទេសអង់គ្លេស ដើម្បីបង្រៀនដល់សាធារណជន អំពីសច្ចភាព នៃ អំពើប្រល័យពូជសាសន៍។

### សមាគមជនរងគ្រោះក្នុងរបបខ្មែរក្រហមនៅកម្ពុជា (Association of Khmer Rouge Victims in Cambodia)

www.akrvictims.org

### វាលពិឃាតជើងឯក (Choeung Ek Killing Fields)

www.cekillingfield.com

### ស៊ីវីហ្គ័ស៖ មជ្ឈមណ្ឌលអប់រំដើម្បីពលរដ្ឋខ្មែរ (CIVICUS: Center for Cambodian Civic Education)

www.civicus-cam.org

### មជ្ឈមណ្ឌលឯកសារកម្ពុជា (Documentation Center of Cambodia, DC-Cam)

www.dccam.org

### អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (Extraorindary Chambers in the Courts of Cambodia, ECCC, or Khmer Rouge Tribunal)

www.eccc.gov.kh

# ព័ត៌មានបន្ថែម

## ការធ្វើអន្តរាគមន៍ចំពោះ អំពើប្រល័យពូជសាសន៍ (Genocide Intervention)

www.genocideintervention.net

ផ្តល់សិទ្ធិអំណាចដល់បុគ្គលម្នាក់ៗ និង សហគមន៍ ឲ្យមាន ឧបករណ៍ ដែល បានផ្តល់ដោយ មណ្ឌលបោះឆ្នោតដ៏ធំទូលាយរបស់ សហរដ្ឋអាមេរិក ដែលរួមបញ្ចូលជំពូក ស្តីពីសិស្ស ចំនួន ១,០០០នាក់ នៅសាកលវិទ្យាល័យ និង វិទ្យាល័យ, ការធ្វើអន្តរាគមន៍ ចំពោះ អំពើប្រល័យពូជសាសន៍ ធ្វើការដើម្បីបញ្ចប់នូវស្ថានភាព អំពើ ប្រល័យពូជសាសន៍ និង មហាវិនាសកម្ម។

## គម្រោងល្មមហើយ (Enough)

www.enoughproject.org

អង្គការមិនយកកម្រៃ ដែលប្រើវិធីសាស្រ្ត ទប់ស្កាត់ នូវអំពើប្រល័យ ពូជសាសន៍ និង ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ខណៈដែលកំពុង ធ្វើការផងដែរ ក្នុង ការបញ្ឈប់ អំពើប្រល័យពូជសាសន៍ ក្នុងពេល បច្ចុប្បន្ន និង ពេលកំពុងបន្ត។

## ការទប់ស្កាត់អំពើប្រល័យពូជសាសន៍ ឥឡូវនេះ (Genocide Prevention Now)

www.genocidepreventionnow.org

ការទប់ស្កាត់អំពើប្រល័យពូជសាសន៍ឥឡូវនេះ គឺជា ការអង្កេតមួយ ដែលបានបោះពុម្ពផ្សព្វផ្សាយ តាមអ៊ិនធឺណិត អំពីព័ត៌មានស្តីពី មហាវិនាសកម្ម អំពើប្រល័យពូជសាសន៍ជ្វីហ្វ និង អំពើប្រល័យ ពូជសាសន៍។

## គណៈកម្មការសង្គ្រោះអន្តរជាតិ (International Rescue Committee)

www.theirc.org

គណៈកម្មការសង្គ្រោះអន្តរជាតិនេះ ធ្វើការជួយមនុស្ស ឲ្យរួចផុតពី វិបត្តិមនុស្សធម៌ ហើយក្រោយមកទៀត ចាប់ផ្តើមដំណើរការកសាង ឡើងវិញ។ គេធ្វើការនៅក្នុង ប្រទេសចំនួន ៤០ និង រដ្ឋអាមេរិកចំនួន ២២ ក្នុងការប៉ុនប៉ងស្តារឡើងវិញ នូវសុវត្ថិភាព, សេចក្តីថ្លៃថ្នូរ និង ក្តីសង្ឃឹម ដល់មនុស្សរាប់លាននាក់។

## ក្រុមវិបត្តិអន្តរជាតិ (International Crisis Group)

www.crisisgroup.org

អង្គការក្រៅរដ្ឋាភិបាល ដែលផ្តោតទៅលើ ការដោះស្រាយ និង ការ ការពារជម្លោះបណ្តាលឲ្យស្លាប់គ្រប់ប្រភេទ។ ការងាររបស់ពួកគេ ផ្តោតទៅលើ ការចែកចាយរបាយការណ៍ព័ត៌មាន ស្តីពីប្រភេទនៃ ជម្លោះទាំងនេះ។

## ក្រុមការងារទប់ស្កាត់អំពើប្រល័យពូជសាសន៍ (Genocide Prevention Task Force)

www.usip.org/genocide_taskforce

ក្រុមការងារនេះ មានការផ្សព្វផ្សាយអំពី វិទ្យាស្ថានអាមេរិក ដើម្បី សន្តិភាព ដែលមានបំណងធ្វើការទប់ស្កាត់ អំពើប្រល័យពូជសាសន៍ ជាអាទិភាពជាតិ របស់ សហរដ្ឋអាមេរិក និង ផ្តល់អនុសាសន៍ គោលនយោបាយ ដល់មេដឹកនាំ ក្នុងការជួយទប់ស្កាត់ អំពើ ប្រល័យពូជសាសន៍ នាពេលអនាគត។

## សារៈមន្ទីរជ្វីហ្វនៅទីក្រុងប៊ែរឡាំង (Jewish Museum in Berlin)

www.jmberlin.de

## សារៈមន្ទីរការចងចាំអំពី អំពើប្រល័យពូជសាសន៍ជ្វីហ្វ របស់សហរដ្ឋអាមេរិក (US Holocaust Memorial Museum)

www.ushmm.org

ផ្តល់សម្ភារៈបង្រៀនដល់ គ្រូបង្រៀន និង សិស្ស ដើម្បីជួយសិក្សា អំពីប្រវត្តិ នៃ សារៈមន្ទីរការចងចាំអំពី អំពើប្រល័យពូជសាសន៍ជ្វីហ្វ, ឆ្លុះបញ្ចាំងអំពី សំណួរសីលធម៌ និង សុជីវធម៌ ដែលបានលើកឡើង ពីប្រវត្តិនោះ និង ពិចារណា លើការជាប់ទំនាក់ទំនងនឹង អំពើ ប្រល័យពូជសាសន៍ ក្នុងពេលបច្ចុប្បន្ននេះ។

## សារៈមន្ទីរប្រល័យពូជសាសន៍ទួលស្លែង (Tuol Sleng Genocide Museum)

www.tuolslengmuseum.com

"FEW WILL HAVE THE

GREATNESS TO BEND

HISTORY ITSELF; BUT

EACH OF US CAN WORK

TO CHANGE A SMALL

PORTION OF EVENTS,

AND IN THE TOTAL OF

THOSE ACTS WILL BE

WRITTEN THE HISTORY

OF OUR GENERATION."

— ROBERT F. KENNEDY

# លោកស្រី ម៉ារីណា ពីសក្លាក្ល៉ូវ៉ា (Marina Pisklakova)

"ស្ត្រីម្នាក់បានទូរស័ព្ទទៅកាន់បណ្ដាញទូរស័ព្ទពិសេសមួយ (Hotline) ហើយនិយាយថា ប្ដីរបស់នាងមានផែនការសម្លាប់នាង។ ខ្ញុំបានទូរស័ព្ទទៅរកប៉ូលីស ប៉ុន្ដែ មន្ដ្រីប៉ូលីសនោះទូរស័ព្ទភ្លាមទៅរកប្ដី ដោយនិយាយថា 'មើលហ្ន៎! ប្រសិនបើលោកនឹងធ្វើ, ធ្វើដោយស្ងៀមស្ងាត់។' ហើយខ្ញុំបានដឹងថា មានការអស់សង្ឃឹម"។

លោកស្រី ម៉ារីណា ពីសក្លាក្ល៉ូវ៉ា (Marina Pisklakova) គឺជាសកម្មជន សិទ្ធិនារីដ៏ឆ្នើមម្នាក់ (នាំមុខ) របស់ប្រទេសរុស្ស៊ី។ នាងបានសិក្សាវិស្វកម្មយន្ដហោះនៅទីក្រុង ម៉ូស្គូ ហើយខណៈដែលកំពុងធ្វើការសិក្សាស្រាវជ្រាវ នៅសាលាបណ្ឌិតសភាវិទ្យាសាស្ត្ររុស្ស៊ី (Russian Academy of Sciences) មានការភ្ញាក់ផ្អើលពីការឃើញនូវអំពើហិង្សាបានរាលដាលដល់ទំហំធំធេងមួយ។ ដោយសារតែកិច្ចខិតខំប្រឹងប្រែងរបស់នាង, មន្ដ្រីរុស្ស៊ី ចាប់ផ្ដើមតាមដានអំពើហិង្សាក្នុងគ្រួសារ និង ប៉ាន់ស្មានថា ក្នុងមួយឆ្នាំស្ត្រីជិត ១៥,០០០នាក់ ត្រូវបានគេសម្លាប់ ហើយស្ត្រី ៥០,០០០នាក់ ត្រូវបានសម្រាកព្យាបាលនៅមន្ទីរពេទ្យ។ មានត្រឹមតែ មួយភាគបី ទៅ មួយភាគប្រាំក្នុងចំណោមស្ត្រីទាំងអស់ ដែលទទួលរងនូវអំពើហិង្សាត្រូវបានទទួលជំនួយព្យាបាល។ ដោយសារគ្មានច្បាប់ប្រឆាំងអំពើហិង្សា ក៏ធ្វើឲ្យគ្មានយន្ដការអនុវត្ដន៍ គ្មានក្រុមគាំពារ ឬ គ្មានភ្នាក់ងារការពារជនរងគ្រោះ។ កាលពីខែកក្កដា ឆ្នាំ១៩៩៣, លោកស្រី ម៉ារីណា ពីសក្លាក្ល៉ូវ៉ា បានបង្កើតលេខទូរស័ព្ទពិសេសមួយ សម្រាប់ស្ត្រីដែលមានទុក្ខព្រួយ។ បន្ទាប់មកនាងបានពង្រីកកិច្ចការ មជ្ឈមណ្ឌលវិបត្ដិស្ត្រីលើកទីមួយ នៅក្នុងប្រទេស។ នាងបានតស៊ូមតិជម្រុញឲ្យបង្កើតច្បាប់ហាមប្រាមការរំលោភ, ហើយនាងបានធ្វើកិច្ចការជាមួយគ្រឹះស្ថានអនុវត្ដន៍ច្បាប់ ដោយមានភាពជំទាស់ចំហ ក្នុងការបង្កើតជំនួយជូនដល់ស្ត្រី និង កាត់ទោសឧក្រិដ្ឋជន។ នាងបានចាប់ផ្ដើមយុទ្ធនាការឃោសនាផ្សព្វផ្សាយព័ត៌មាន ដើម្បីលាតត្រដាងអំពីបញ្ហាអំពើហិង្សាលើស្ត្រី និង ដើម្បីអប់រំស្ត្រីអំពីសិទ្ធិ។ ហើយគាត់មានសម្លេងតាមវិទ្យុ និង ទូរទស្សន៍ទៀងទាត់ ក្នុងការ លើកកម្ពស់ការគោរពចំពោះសិទ្ធិស្ត្រី។ បច្ចុប្បន្ននេះ អង្គការរបស់ នាងឈ្មោះ អាណា (ANNA) (មជ្ឈមណ្ឌលជាតិសម្រាប់ការទប់ស្កាត់អំពើហិង្សា) សហការណ៍ជាមួយបណ្ដាញនៃ មជ្ឈមណ្ឌលវិបត្ដិចំនួន១៧០ នៅទូទាំងប្រទេសរុស្ស៊ី និង អតីតសហភាពសូវៀត។ ឥឡូវនេះ នាងកំពុងសកម្មមិនមែនត្រឹមតែប្រយុទ្ធប្រឆាំងនឹងបុព្វហេតុនៃអំពើហិង្សាប្រឆាំងនឹងស្ត្រីប៉ុណ្ណោះទេ ប៉ុន្ដែថែមទាំងការរត់ពន្ធស្ត្រី និង កុមារ។ ក្នុងឆ្នាំ២០០៤, នាង គឺជាអ្នកទទួលពានរង្វាន់ភាពជាអ្នកដឹកនាំពិភពលោកអំពីសិទ្ធិមនុស្ស (Human Rights Global Leadership Award)។ កិច្ចប្រឹងប្រែងរបស់នាង ពីសក្លាក្ល៉ូវ៉ា បានជួយសង្គ្រោះជីវិតមនុស្សរាប់មិនអស់ដោយប្រឈមនឹងគ្រោះថ្នាក់យ៉ាងច្រើនចំពោះខ្លួននាង។



Marina Pisklakova, ©2000 Eddie Adams

## ការសម្ភាសន៍

**នៅពេលដែលខ្ញុំបង្កើតបណ្ដាញទូរស័ព្ទពិសេសលើកទីមួយ អំពីអំពើហិង្សាក្នុងគ្រួសារនៅក្នុងប្រទេសរុស្ស៊ី ក្នុងឆ្នាំ១៩៩៣ (មានឈ្មោះថា អាណា ANNA), មានតែខ្ញុំម្នាក់ឯងឆ្លើយទូរស័ព្ទរយៈពេលបួនម៉ោងក្នុងមួយថ្ងៃ, រៀងរាល់ថ្ងៃ, ក្នុងរយៈពេល៦ខែ។ ហើយក្នុងបួនម៉ោងទៀត ខ្ញុំជួបជាមួយស្ត្រីក្នុងការផ្ដល់ប្រឹក្សាយោបល់។ ខ្ញុំមិនអាចបដិសេធទេ ទោះមានស្ត្រីច្រើនក៏ដោយ។ ខ្ញុំអត់ដែលទទួលបានការបណ្ដុះបណ្ដាលទេ, ខ្ញុំគ្មានពេលចន្លោះទេ គ្មានព្រំដែនទេ។ ប៉ុន្ដែ ស្របពេលជាមួយគ្នានោះដែរ ខ្ញុំក៏មិនដឹងថា ខ្ញុំអាចកែអ្វីដែលខ្ញុំបានធ្វើតាមរបៀបណានោះទេ។**

**ដោយមិនដឹងខ្លួន ខ្ញុំបានចាប់ផ្ដើមកិច្ចការនេះក្នុងពេលដែលខ្ញុំជានិស្សិតស្រាវជ្រាវនៅ សាលាបណ្ឌិតសភាវិទ្យាសាស្ត្ររុស្ស៊ី (Russian Academy of Sciences) ផ្នែកសិក្សាចំនួនមនុស្សទាក់ទិនដល់សង្គម និង សេដ្ឋកិច្ច។ ខណៈដែលកំពុងសម្របសម្រួលការ**

ស្ទង់មតិថ្នាក់ជាតិមួយ អំពីបញ្ហាស្ត្រី, នៅថ្ងៃមួយ ខ្ញុំបានទទួលនូវការឆ្លើយតបពីការស្ទង់មតិនេះ ដែលខ្ញុំមិនដឹងថា គួរកំណត់បែបណា។ ចម្លើយនេះបានពិពណ៌នា អំពីការឈឺចាប់ និង ទុក្ខវេទនារបស់ស្ត្រីម្នាក់ដោយស្នាដៃប្តីរបស់គាត់។ ខ្ញុំបានបង្ហាញវា ដល់សហសេវិកមួយចំនួន ហើយសហសេវិកម្នាក់បានប្រាប់ខ្ញុំថា "អ្នកទើបតែបានអានករណីអំពើហិង្សាក្នុងគ្រួសារមួយ"។ ខ្ញុំមិនដែលធ្លាប់ឮពាក្យនេះពីមុនមកទេ។ ពីព្រោះ ជារឿងដែលមិនមាន ការទទួលស្គាល់ក្នុងសម័យ រុស្ស៊ី ក្រោយការបាក់បែកសូវៀត, លើសពីនេះទៀតគ្មានការពិភាក្សាសោះឡើយ។ ខ្ញុំបានសម្រេចចិត្តថា ខ្ញុំត្រូវតែរៀនឲ្យបានច្រើនពីបាតុភូតអាថ៌កំបាំងនេះ។

តាំងពីពេលនោះមក ខ្ញុំបានជួបម្តាយរបស់មិត្តភក្តិកូនរបស់ខ្ញុំ នៅមុខសាលារៀន។ ពាក់កណ្តាលមុខរបស់នាង មានស្នាមជាំខ្លាំង។ នាងបដិសេធមិនប្រាប់ខ្ញុំ អំពីអ្វីដែលបានកើតឡើងទេ។ ល្ងាចថ្ងៃមួយ, ពីរបីថ្ងៃក្រោយមក នាងបានទូរស័ព្ទមករកខ្ញុំ។ រឿងរ៉ាវរបស់នាងធ្វើឲ្យខ្ញុំរន្ធត់។ នៅពេលដែលប្តីរបស់នាង ស្លៀកសំលៀកបំពាក់ ហើយក្រោយមក ឡេវអាវបានជ្រុះ។ ភ្លាមៗនោះ វាមិនទាន់បានដាក់ (ភ្ជាប់)។ គាត់បានយកស្បែកជើងវាយមុខប្រពន្ធរបស់គាត់។ នាងមិនអាចចេញទៅក្រៅអស់រយៈពេលពីរសប្តាហ៍។ នាងពិតជាឈឺចាប់ខ្លាំងណាស់ គឺឈឺចាប់ទាំងផ្លូវកាយ, ទាំងផ្លូវចិត្ត ពីព្រោះពាក់កណ្តាលមុខរបស់នាងគឺជាំខ្មៅ និង ខៀវខ្លាំង។ ខ្ញុំបានសួរនាងថា "ហេតុអ្វីបានជាអ្នកមិនចាកចេញពីគាត់?" នេះជាសំណួរធម្មតា។ ហើយនាងបាននិយាយថា "ខ្ញុំនឹងទៅរស់នៅឯណា?" ខ្ញុំបាននិយាយថា "លែងលះគាត់ទៅទៅជួលផ្ទះល្វែងមួយទៀតទៅ"។ នាងបាននិយាយថា "ខ្ញុំបានពឹងផ្អែកទៅលើគាត់ទាំងស្រុង"។ ក្នុងការជជែកគ្នានេះ ខ្ញុំបានយល់ច្បាស់៖ មធ្យោបាយអ្នករំលោភ គឺការពង្រឹងការត្រួតត្រា, បន្ថយការជឿជាក់លើខ្លួនស្ត្រី, និង បង្អន់តម្លៃផ្ទាល់ខ្លួនរបស់ស្ត្រី។ ខ្ញុំផងដែរ បានឮប្រវត្តិរឿងរបស់នាង អំពីរបៀបដែលប្តីត្រលប់មកផ្ទះ និង ទៅចង្ក្រាន, ហើយយកដៃគាសលើកម្រាលឥដ្ឋ, ហើយប្រសិនបើ មានធូលីតិចតួចប្តីសួរដោយមើលងាយថា "តើឯងបានធ្វើអីខ្លះថ្ងៃនេះ"។ កម្រាលឥដ្ឋនៅក្នុងចង្ក្រានរបស់ប្រទេសរុស្ស៊ី តែងតែមានធូលីតិចតួចខ្លះ ជាពិសេសបើសិនជាអ្នកមានកូននៅផ្ទះនរណារត់លេងនៅជុំវិញ គឺថាចង្ក្រាន គឺជាមជ្ឈមណ្ឌលជីវិតគ្រួសារ នៅក្នុងផ្ទះល្វែងតូចរបស់យើង។ ចំពោះអ្នកមើលមកពីក្រៅ, អ្វីដែលខ្ញុំបានពិពណ៌នានេះអាចធ្វើឲ្យគេអស់សំណើច, ប៉ុន្តែ ខ្ញុំបានយល់ឃើញថា រឿងបែបនេះជារឿងធម្មតា។ សម្រាប់ស្ត្រីរូបនេះ ការសន្ទនារបស់យើង គឺជាឱកាសមួយ ក្នុងការទំនាក់ទំនងជាមួយនរណាម្នាក់ ដែលមិនបានដាក់ទោសនាង, ដែល មិនបាននិយាយ "អ្នកបានធ្វើអ្វីខុស?" ដោយមិនដឹងខ្លួន ខ្ញុំបានចាប់ផ្តើមផ្តល់ប្រឹក្សាយោបល់ដល់នាង។ ប៉ុន្តែ ខ្ញុំបានយល់ដឹងពីរឿងរបស់នាងដែលថា អំពើហិង្សារូបកាយ កើតមកពីអំពើហិង្សាផ្លូវចិត្ត។

ដូច្នេះហើយ ខ្ញុំបានចាប់ផ្តើមគិតថា ខ្ញុំគួរតែជួយនាង, ខ្ញុំគួរតែបង្វែរនាងឲ្យទៅនរណាម្នាក់ដែលអាចជួយ។ បន្ទាប់មកទៀត ខ្ញុំបានយល់ថា មិនមានកន្លែងសម្រាប់បញ្ហានេះ។ ខ្ញុំមិនអាចប្រាប់អ្នកអំពីអារម្មណ៍របស់ខ្ញុំបានទេ។ ខ្ញុំពិតជាអស់សង្ឃឹម និង តែលតោល។ នៅក្នុងប្រទេសរុស្ស៊ី មានពាក្យស្លោកមួយនិយាយថា "គេវាយតប់អ្នកនោះមានន័យថា គេស្រឡាញ់អ្នក"។ ឥឡូវនេះ ខ្ញុំបានយល់ដឹង អំពីអត្ថន័យ នៃពាក្យស្លោកនោះហើយ។ ខ្ញុំបានសួរខ្លួនខ្ញុំថា "តើអ្នកអាចធ្វើអ្វីខ្លះ អំពីអាកប្បកិរិយាវប្បធម៌បែបនេះ?" ប៉ុន្តែ ខ្ញុំដឹងថា ខ្ញុំត្រូវធ្វើអ្វីហើយ។ ខ្ញុំបានបង្កើតបណ្តាញទូរស័ព្ទពិសេស (Hotline)។ នៅថ្ងៃដ៏ត្រជាក់មួយក្នុងខែមករា ស្ត្រីម្នាក់បានទូរស័ព្ទចូលមក ហើយខ្ញុំបានចាប់ផ្តើមជជែកជាមួយនាង។ ពីរ បីនាទីក្រោយមក នាងឈប់ ហើយនិយាយថា "ខ្ញុំមិនជជែកជាមួយអ្នកតាមទូរស័ព្ទទេ។ ខ្ញុំចាំបាច់ជួបអ្នកផ្ទាល់"។ ដូច្នេះ ខ្ញុំនិយាយថា "ព្រម"។ ហើយនៅពេលដែលនាងបានចូលមកពាក្យពេចន៍ប្រកបដោយទឹកភ្នែក លើកទីមួយរបស់នាង គឺ "ខ្ញុំខ្លាចថាប្តីរបស់ខ្ញុំនឹងសម្លាប់ខ្ញុំ ហើយគ្មាននរណាម្នាក់នឹងដឹងទេ"។ នាងបានប្រាប់ខ្ញុំអំពីប្រវត្តិរឿងរបស់នាង។ មុននឹងនាងប្រាប់ប្តីថា នាងមានផ្ទៃពោះ ប្តីនៅល្អចំពោះនាង។ បន្ទាប់មកអ្វីៗទាំងអស់បានផ្លាស់ប្តូរ។ គាត់បានត្រួតត្រាយ៉ាងរឹងមាំ។ នាងងាយរងគ្រោះ និង បាត់បង់ឯករាជ្យភាព៖ "ខ្ញុំបានរន្ធត់, ហើយទឹកមុខរបស់គាត់ គឺមិនសប្បាយចិត្តទេ។ វាដូចជាថា គាត់បានទទួលជោគជ័យ។ ប្រៀបដូចគាត់គិតថា 'នេះវេនអញហើយ អញអាចធ្វើអ្វីឯងក៏បានដែរ'"។ ភាពគ្រោះថ្នាក់មានពិតប្រាកដ។

ប្រតិកម្មលើកដំបូងរបស់ខ្ញុំ "ឱ! ព្រះជាម្ចាស់លោកអើយ ឥឡូវនេះខ្ញុំនឹងត្រូវធ្វើអ្វី?" ខ្ញុំដឹងថា ប៉ូលីសមិនអាចធ្វើអ្វីកើតទេ។ ប៉ុន្តែ ទោះជាយ៉ាងណាក្តី ខ្ញុំបានទូរស័ព្ទទៅរកប៉ូលីសនៅក្នុងស្រុករបស់នាង។ មន្ត្រីប៉ូលីសនោះ ទំនងជាចិត្តល្អ, ប៉ុន្តែ នៅពេលនោះ គាត់បានទូរស័ព្ទទៅរកប្តីរបស់ខ្ញុំភ្លាមៗ ហើយបាននិយាយទៅកាន់គាត់ថា "តើប្រពន្ធរបស់អ្នកកំពុងធ្វើអ្វី? ហើយហេតុអ្វីបានជានាងជជែកអំពីបញ្ហាគ្រួសារ? 'មើលនែ ប្រសិនលោកនឹងធ្វើ ធ្វើដោយស្ងៀមស្ងាត់។' ខ្ញុំដឹងថា ពិតជាមានបញ្ហាអស់សង្ឃឹមសម្រាប់នាងមែន។ បញ្ហារបស់នាង បានក្លាយទៅជាបញ្ហារបស់ខ្ញុំ។ ខ្ញុំមិនអាចដកខ្លួនចេញបានទេ។ ខ្ញុំបានទូរស័ព្ទទៅរកស្ត្រីម្នាក់ដែលខ្ញុំស្គាល់ គឺជាមេធាវីចូលនិវត្តម្នាក់ ហើយបានប្រាប់គាត់ថា "ខ្ញុំមិនមានលុយកាក់ទេ ហើយស្ត្រីនេះ ក៏មិនមានលុយដែរ។ ប៉ុន្តែ នាងត្រូវការជំនួយ។ នាងត្រូវការ ការលែងលះគ្នា និង ត្រូវការទីកន្លែងរស់នៅ"។ នៅទីក្រុងមូស្គូ ការមានផ្ទះសម្បែងជា បញ្ហាធំមួយ។ នៅពេលដែលស្ត្រីរូបនេះ បានរៀបការជាមួយប្តីរបស់នាង នាងបានផ្ទេរផ្ទះល្វែងរបស់នាងឲ្យទៅគ្រួសារខាងប្តី, ហើយឥឡូវនេះ បងប្អូនប្រុសរបស់គាត់ម្នាក់បានរស់នៅទីនោះ។ ដូច្នេះ នាងគ្មាន ទីកន្លែងណាមួយដើម្បីទៅទេ។ នាងបានជាប់អន្ទាក់។ ប្រវត្តិរឿង របស់នាងបានក្លាយទៅជាអាក្រក់ទៅៗ។ ពេលកូនច្បងមានអាយុ ៩ខែ, ប្តីរបស់នាងបានព្យាយាមសម្លាប់នាង។ នាងបានប្រាប់ខ្ញុំថា "ខ្ញុំមិនដឹងថា តើខ្ញុំរួចផុតពីស្លាប់ដោយរបៀបណាទេ។ មេធាវី និង ខ្ញុំបានជួយនាងដាក់ពាក្យប្តឹងសុំលែងលះគ្នា។ នោះគឺដល់ពេល ដែលប្តីរបស់នាងបានប្រាប់នាងហើយ "អញនឹងសម្លាប់ឯង ហើយគ្មាននរណាម្នាក់ដឹងទេ។ ហើយអញនឹងប្រាប់គេទាំងអស់គ្នាថា ឯងបានផិតជាមួយ

ប្រុសម្នាក់ទៀត ហើយនឹងរត់ចោលកូន”។ ខ្ញុំបានចាប់ផ្តើមទូរស័ព្ទទៅរកនាងរៀងរាល់ព្រឹកដើម្បីបញ្ជាក់ថានាងពិតជានៅរស់។ អស់រយៈពេលបីខែ មេធាវី បានផ្តល់យោបល់ដល់យើង នៅដំណាក់កាលនីមួយៗ ហើយបានជួយយើងកសាងផែនការទៀតផង។

នៅក្នុងចំណោមបញ្ហាទាំងអស់នេះ ស្ថានភាពនេះបានប្រែក្លាយទៅជារឿងគួររន្ធត់។ ស្ត្រីម្នាក់នោះ បានទូរស័ព្ទមកប្រាប់ថា៖ “ពួកគេបានដឹងអំពីអ្វីទាំងអស់ដែលយើងបានពិភាក្សាគ្នា!” ម្តាយក្មេក របស់នាង ធ្វើការនៅក្រុមហ៊ុនទូរស័ព្ទ ហើយធ្វើឲ្យយើងចាប់ អារម្មណ៍ថា គាត់ស្តាប់បានការជជែករបស់យើង។ ខ្ញុំឆ្លើយទៅនាងថា “មែនហើយ នេះជាភាពប្រសើរ។ ឲ្យគេស្តាប់អំពីការគាំទ្រទាំងអស់ ដែលអ្នកទទួលមកពីខាងក្រៅ”។ ដូច្នេះយើង បានចាប់ផ្តើមធ្វើពើ ដូចជាថា យើងបានធ្វើច្រើនជាងយើងមានជាក់ស្តែង។ បន្ទាប់មក ពេលយើងជជែកតាមទូរស័ព្ទ ខ្ញុំបាននិយាយថា “ហ្នឹងហើយ ដូច្នេះ ហើយ មន្ត្រីប៉ូលីសហ្នឹងមិនអាចជួយបាន ប៉ុន្តែ មានប៉ូលីសជាច្រើនទៀត ខ្ញុំនឹងទៅជជែកជាមួយអំពីរឿងរ៉ាវនេះ ហើយមេធាវីអ្នកនឹងធ្វើ ដូច្នេះដែរ។ ដូច្នេះ សូមកុំបារម្ភអី”។ នៅពេលក្រោយទៀត នាងមកជួបខ្ញុំ ហើយនាងនិយាយថា “ពួកគេយកចិត្តទុកដាក់ច្រើន បន្ទាប់ពីយើងបានជជែកគ្នាពីរឿងហ្នឹងមក”។ ជាយថាហេតុ ប្តីរបស់នាងបាន ចាកចេញពីផ្ទះ, ម្យ៉ាងដោយសារ មេធាវីបានប្រាប់យើងអំពីរបៀប ដែលធ្វើឲ្យគាត់ចាកចេញ, ហើយម្យ៉ាងទៀតដោយសារគាត់ និង គ្រួសាររបស់គាត់បានដឹងថាឥឡូវនេះ នាងបានយល់ដឹង អំពីសិទ្ធិរបស់នាង។ នៅទីបំផុត ពួកគេបានលែងលះគ្នា។ ឪពុកក្មេក របស់នាង បានមកជួបនាង ហើយនិយាយថា “អ្នកបានទទួលជោគជ័យហើយ ចូរលែងលះគ្នាទៅ ហើយយកផ្ទះល្វែងនាងវិញទៅ។ អ្នកលែងបានជួបកូនប្រុសរបស់ខ្ញុំទៀតហើយ”។

បន្ទាប់ពីទទួលជោគជ័យនេះភ្លាមៗ មិត្តភក្តិរបស់នាងក្នុងសភាពការណ៍ស្រដៀងនាង បានប្តឹងអតីតប្តីរបស់នាងដែរ ហើយក៏ទទួលបានផ្ទះល្វែងរបស់នាងវិញ។ ខ្ញុំរីករាយណាស់! លើកទីមួយហើយដែលខ្ញុំបានទទួលការលើកទឹកចិត្ត! សូម្បីនៅក្នុងសង្គមរុស្ស៊ីទាំងមូល, ដែលគ្មានច្បាប់ប្រឆាំងអំពើហិង្សាពីមុនមក, យើងឃើញថាស្ត្រីម្នាក់ដែលមានឆន្ទៈខ្លាំង អាចទទួលបានជោគជ័យក្នុងការទាមទារសិទ្ធិរបស់នាង។ ប៉ុន្តែ នេះជារឿងតូចមួយ នៃមនុស្សរាប់ពាន់នាក់ ដែលយើងទទួលដឹងឮជារៀងរាល់ថ្ងៃ។ ជាអកុសល ស្ត្រីភាគច្រើនដែលទូរស័ព្ទមករកពួកយើង មិនយល់ដឹងអំពីសិទ្ធិរបស់ខ្លួន។ ហើយគេក៏មិនដឹងថា គេមិនបាច់ទទួលអ្វីដែលមិនគួរទទួល។

ក្នុងកិច្ចការនេះ មានរឿងរ៉ាវអាក្រក់ខ្លះបានកើតឡើង។ ពេលមួយដែលខ្ញុំបានទទួលទូរស័ព្ទ ហើយសម្លេងបុរសម្នាក់ បានចាប់ផ្តើមនិយាយថា “តើនេះជាលេខទូរស័ព្ទអ្វី?” ខ្ញុំបានប្រយ័ត្នប្រយែងពីព្រោះវាមិនមែនជារឿងធម្មតាដែលមានបុរសទូរស័ព្ទមក បណ្តាញទូរស័ព្ទពិសេសដូច្នេះ។ ខ្ញុំឆ្លើយតបថា “ម៉េចដែរ, លោកបានទូរស័ព្ទទៅលេខណាដែរ?” ហើយគាត់បាននិយាយថា “ខ្ញុំបានរកឃើញលេខទូរស័ព្ទនេះនៅក្នុងកំណត់ហេតុ របស់ប្រពន្ធខ្ញុំ ហើយខ្ញុំគ្រាន់តែចង់ដឹងថា នេះជាលេខអ្វី?” ខ្ញុំបានប្រាប់គាត់ថា “ហេតុអ្វីបានជាអ្នកមិនសួរប្រពន្ធរបស់អ្នក? ហេតុអ្វីបានជាអ្នកទូរស័ព្ទមករកខ្ញុំ?” មុនដំបូង គាត់មានភាពស្ងប់ស្ងៀម និង គួរសម ដោយនិយាយថា “មើលនែ! ខ្ញុំគ្រាន់តែចង់ឲ្យអ្នកប្រាប់ខ្ញុំនេះជាអ្វី”។ ហើយខ្ញុំឆ្លើយតបថា “បើសិនជាអ្នកមិនជឿប្រពន្ធរបស់អ្នកទេ វាជាបញ្ហារបស់អ្នក។ ខ្ញុំមិនប្រាប់អ្នកថាវាជាអ្វីទេ ហើយខ្ញុំក៏មិនសួរ ឈ្មោះរបស់អ្នកឯងដែរ។ បើសិនជាអ្នកណែនាំខ្លួនអ្នកឲ្យខ្ញុំស្គាល់ ប្រហែលជាយើងអាចនឹងជជែកគ្នាបាន”។ បន្ទាប់មកគាត់បានចាប់ផ្តើមដំឡើងសម្លេងជេរ ហើយនិយាយថា “អញដឹងថាឯងជានរណា។ អញស្គាល់ឈ្មោះឯង។ អញដឹងថា កន្លែងនៅឯណា។ អញដឹងថា ឯងរស់នៅទីកន្លែងណា។ ហើយអញនឹងទៅទីនោះ ជាមួយក្រុមអញ ហើយសម្លាប់ឯង”។ នៅពេលនោះប្តីរបស់ខ្ញុំ នៅជា មួយខ្ញុំ ហើយបានឃើញថា ខ្ញុំរន្ធត់ ប៉ុន្តែ ខ្ញុំនៅតែនិយាយទៅកាន់បុរសនោះ “ខ្ញុំមិនភ័យខ្លាចចំពោះលោកទេ” ហើយខ្ញុំទម្លាក់ទូរស័ព្ទភ្លាម។ ខ្ញុំនៅតែមិនស្គាល់ថា តើគាត់ជាប្តីរបស់នាងណា។ គាត់មិនដែលមកទេ។ នៅពេលមួយទៀត ទូរស័ព្ទផ្ទះរបស់ខ្ញុំបានរោទិ៍ នៅពេលយប់ជ្រៅ ហើយបុរសម្នាក់បាននិយាយថា “បើសិនជាអ្នកមិនឈប់ទេ អ្នកគួរតែប្រុងប្រយ័ត្នចំពោះកូនប្រុសរបស់អ្នក”។ ភាសានេះ ធ្វើឲ្យខ្ញុំរន្ធត់មែនទែន។ ខ្ញុំបានប្តូរកូនប្រុសរបស់ខ្ញុំឲ្យទៅរស់នៅផ្ទះ របស់ឪពុកម្តាយខ្ញុំរយៈពេលពីរបីខែ។ នោះគឺជាការលំបាកណាស់ សម្រាប់ម្តាយម្នាក់។

មានការប៉ាន់ប្រមាណផ្សេងៗគ្នា អំពីអំពើហិង្សាក្នុងគ្រួសារ នៅប្រទេសរុស្ស៊ី។ ឥឡូវនេះ អ្នកខ្លះនិយាយថា ៣០ ទៅ ៤០ភាគរយ នៃគ្រួសារទាំងអស់បានជួបប្រទះនូវបញ្ហានេះ។ ក្នុងឆ្នាំ១៩៩៥, ក្រោយពីសន្និសីទស្ត្រីនៅទីក្រុង ប៉េកាំង (Beijing), មានស្ថិតិលើកដំបូងគួរជឿជាក់ ត្រូវបានផ្សព្វផ្សាយនៅក្នុងប្រទេស រុស្ស៊ី ដោយបញ្ជាក់ថាស្ត្រីចំនួន ១៤,៥០០នាក់ ក្នុងមួយឆ្នាំ ត្រូវបានប្តីសម្លាប់។ ប៉ុន្តែ សូម្បីតែបច្ចុប្បន្ននេះ ប៉ូលីសមិនបានរក្សាទុកស្ថិតិទាំងអស់នោះទេ ប៉ុន្តែ ការប៉ាន់ស្មានជាផ្លូវការរបស់ពួកគេគឺថា ប្រហែលជាស្ត្រីចំនួន ១២,០០០នាក់ក្នុងមួយឆ្នាំត្រូវបានសម្លាប់នៅប្រទេសរុស្ស៊ីដោយសារតែអំពើហិង្សាក្នុងគ្រួសារ។ មានការទទួលស្គាល់ខ្លះៗ អំពីទំហំនៃបញ្ហានេះ បានលេចឡើង។

ម្យ៉ាងវិញទៀត, មានតែ អំពើហិង្សាក្នុងគ្រួសារ ដែលនាំឲ្យមានការរបួសស្នាម ដោយបង្កឲ្យបុគ្គលលែងមានការងារធ្វើ (យ៉ាងហោចណាស់អស់រយៈពេល២ឆ្នាំ), ហើយមានតែ អំពើហិង្សានាំឲ្យមានឃាតកម្មដែលចាត់ទុកថា ជាអំពើឧក្រិដ្ឋកម្មស្ថិតក្រោមច្បាប់រុស្ស៊ី។ មិនមានច្បាប់ដទៃណាមួយ ដែលដោះស្រាយពី អំពើហិង្សាក្នុងគ្រួសារ ទោះបីមានកិច្ចប្រឹងប្រែងជាច្រើនឆ្នាំ ក្នុងការទាមទារឲ្យមានច្បាប់នេះអនុម័ត ដោយរដ្ឋសភារុស្ស៊ី ឌូម៉ា (Duma) ក៏ដោយ។ ចំពោះកិច្ចការរបស់ខ្ញុំ និងចលនាស្ត្រី ដែលទើបតែកើតឡើងរបស់យើង, យើងផ្ទាល់ខ្លួនបានពង្រីកនិយមន័យ ដែលអាចប្រើបាននៃ អំពើហិង្សាក្នុងគ្រួសារ ក្នុងការដាក់បញ្ចូល៖ ការរំលោភផ្លូវភេទក្នុងអាពាហ៍ពិពាហ៍, អំពើហិង្សាក្នុងអាពាហ៍ពិពាហ៍ ឬ ដោយសង្សារ, អំពើហិង្សាខាងផ្លូវចិត្ត, ការឃាំងឲ្យរស់នៅឯកោ, និង ការត្រួតត្រាខាងសេដ្ឋកិច្ច។ ផ្នែកចុងក្រោយនេះបានក្លាយទៅជាទម្រង់កលល្បិច និង លាក់លៀមមួយ នៃអំពើហិង្សា

ក្នុងគ្រួសារ ព្រោះថាស្ត្រីមាន ៦០ភាគរយ នៃចំនួនប្រជាជនអត់ការងារធ្វើ ហើយប្រាក់ខែរបស់ស្ត្រី គឺប្រហែល ៦០ភាគរយ នៃប្រាក់ខែរបស់បុរស សម្រាប់ការងារដូចគ្នា។

មិត្តម្នាក់បានចាប់ផ្តើមធ្វើការជាមួយខ្ញុំនៅខែមករា ឆ្នាំ១៩៩៤ ហើយ នៅអំឡុងរដូវក្តៅ, យើងបានបណ្តុះបណ្តាលក្រុមស្ត្រីទីមួយ របស់យើង ដែលចាប់ផ្តើមធ្វើការជាមួយយើងជា អ្នកផ្តល់យោបល់តាមទូរស័ព្ទ។ នៅក្នុងឆ្នាំ១៩៩៥ ខ្ញុំបានចាប់ផ្តើមធ្វើដំណើរទៅកាន់ទីក្រុងដទៃទៀត ក្នុងប្រទេសរុស្ស៊ី ដោយរៀបចំការហ្វឹកហ្វឺនបណ្តុះបណ្តាល សម្រាប់ក្រុមស្ត្រីដទៃទៀត ដែលបានចាប់ផ្តើមហើបឡើង ហើយដែលចង់ឲ្យយើងបង្កើតប្រព័ន្ធទូរស័ព្ទពិសេសហាតឡាញស៍ (hotlines) ឬ មជ្ឈមណ្ឌលវិបត្តិមួយចំនួន។ បន្ទាប់មកទៀត យើងចាប់ផ្តើមបង្កើតកម្មវិធីផ្តល់ការពិគ្រោះយោបល់ផ្នែកចិត្តសាស្ត្រ និង ផ្នែកច្បាប់សម្រាប់ជនរងគ្រោះពី អំពើហិង្សាក្នុងគ្រួសារ។

នៅក្នុងឆ្នាំ១៩៩៧ យើងបានចាប់បង្កើតកម្មវិធីថ្មីមួយ ដើម្បីបណ្តុះបណ្តាលមេធាវី អំពីរបៀបដោះស្រាយករណីរំលោភក្នុងគ្រួសារ។ ស្ថិតក្រោមច្បាប់រុស្ស៊ីបច្ចុប្បន្ន ការបង្កអំពើហិង្សា គឺជាការការពារមួយ ដែលគេអាចអះអាងនៅក្នុងតុលាការ ដើម្បីបន្ធូរបន្ថយការដាក់ទណ្ឌកម្ម។ នេះប្រហែលជាទម្រង់ឃោរឃៅបំផុតមួយនៃការរំលោភខាងផ្លូវចិត្ត ព្រោះថាវាកើតឡើងនៅក្នុងបន្ទប់តុលាការ នៅចំពោះមុខនៃជនរងគ្រោះ។ បែបនេះធ្វើឲ្យនាងដូចជាអ្នកមានការទទួលខុសត្រូវ។ ជនរងគ្រោះត្រូវបានស្តីបន្ទោសជាចំហ ដោយអ្នកប្រព្រឹត្តបទល្មើស។ ជាការសោកស្តាយ នៅតែមានចៅក្រមជាច្រើន ដែលនៅមានជំនឿថា នាងមានការទទួលខុសត្រូវក្នុងរឿងរ៉ាវទាំងនេះ, ហើយដោះលែងឲ្យអ្នកប្រព្រឹត្តបទល្មើសជៀសផុតពីការទទួលខុសត្រូវ ចំពោះសកម្មភាពទាំងឡាយរបស់គេ។ ការប៉ះទង្គិចផ្លូវចិត្តចុងបំផុតបានប្រព្រឹត្ត។

ក្នុងការចាប់ផ្តើមសហស្សវត្សថ្មី, យើងមានមជ្ឈមណ្ឌលវិបត្តិស្ត្រីជាង៤០ កំពុងធ្វើកិច្ចការពាសពេញប្រទេស រុស្ស៊ី, ហើយថ្មីៗនេះ យើងបានបង្កើតសមាគមមជ្ឈមណ្ឌលវិបត្តិស្ត្រីរុស្ស៊ី ដែលត្រូវបានចុះឈ្មោះជាផ្លូវការ និង បានទទួលស្គាល់ដោយរដ្ឋាភិបាលរុស្ស៊ី។ ខ្ញុំមានកិត្តិយស ដែលគេបានជាប់ឆ្នោតជាប្រធានទីមួយនៃសមាគមនេះ។

ឪពុកម្តាយរបស់ខ្ញុំ បានគាំទ្រហួសនិស្ស័យនូវការងាររបស់ខ្ញុំ។ ឪពុករបស់ខ្ញុំ, ជាមន្ត្រីទាហានចូលនិវត្តម្នាក់, បាននិយាយមកកាន់ខ្ញុំថា "ក្រោមសម័យសូវៀត ជាក់ស្តែងកូនជាអ្នកប្រឆាំងហើយ ?" ហើយខ្ញុំឆ្លើយតបទៅគាត់វិញ "ប្រហែលមែនហើយ, ពីព្រោះសម័យសូវៀត គេរក្សាទេវកថានៃឧត្តមគតិមួយ គឺថា អំពើហិង្សាក្នុងគ្រួសារមិនមានកើតឡើងជាផ្លូវការទេ"។ អាកប្បកិរិយា នៅក្នុងអំឡុងរបបសូវៀត គឺថា បើសិនស្ត្រីត្រូវបានប្តីវាយដំ មកពីស្ត្រីនោះបានបរាជ័យជាស្ត្រី និង ជាភរិយា។ ពេលនោះ គឺតួនាទីរបស់ស្ត្រីនៅក្នុងសង្គមយើងក្នុងការ បង្កើតបរិយាកាសគ្រួសារ។ គឺជាតួនាទីរបស់នាងក្នុងការថែរក្សា ឧត្តមគតិនេះ។ មកពីគំនិតនេះហើយ ស្ត្រី ដែលត្រូវបានគេវាយធ្វើបាប អស់រយៈពេល២៦ឆ្នាំ បានមកជួបខ្ញុំ។ ខ្ញុំជាមនុស្សទីមួយ ដែលពួកគេអាចមករកដោយបើកចំហ, ហើយពួកគេអាចចែករំលែកជាមួយខ្ញុំដោយភាពកក់ក្តៅ ដែលគេបានលាក់ទុកនៅក្នុងខ្លួន។ នេះគឺជាការពិតដែលកើតឡើងច្រើនក្នុងពេលបច្ចុប្បន្ននេះ។

ខ្ញុំមិនជាមនុស្សវិសាមញ្ញទេ។ ស្ត្រីណាក៏អាចធ្វើដូចខ្ញុំបានដែរ។ ទោះបីជាយ៉ាងណាក៏ដោយ ខ្ញុំគិតថា ខ្ញុំគឺពិតជាមានសំណាងណាស់ ព្រោះថា ខ្ញុំបានចាប់ផ្តើមអ្វីថ្មីមួយ, គឺជាការអភិវឌ្ឍធំមួយក្នុងប្រទេសរុស្ស៊ី គឺជាឥរិយាបថថ្មីមួយ។ ឥឡូវនេះ មនុស្សគ្រប់រូបកំពុងជជែកគ្នាអំពីអំពើហិង្សាក្នុងគ្រួសារ។ ហើយមនុស្សជាច្រើនកំពុងឆ្លើយតបទៅនឹងបញ្ហានេះ (អំពើហិង្សាក្នុងគ្រួសារ)។



អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្ស សូរិយា ស៊ូបេឌី (Surya Subedi), ស៊ីវីកហ្វ័សកម្ពុជា សេង ធារី, លោកស្រី ឃែរី ខិណ្ណិឌី, លោកជំទាវ មូរ សុខហួ, មជ្ឈមណ្ឌល រ៉ូបឺត អ៊ែហ្វ ខិណ្ណិឌី ចន ហ៊ីវហ្វើនិន (John Heffernan) នៅទីក្រុងភ្នំពេញ ខែកុម្ភៈ ឆ្នាំ២០១១។

# អំពើហិង្សាក្នុងគ្រួសារប្រឆាំងនឹងស្ត្រី

លោកស្ត្រី ម៉ារីណា ពីសក្លាកូវ៉ា

បញ្ហាសិទ្ធិមនុស្ស៖ សិទ្ធិស្ត្រី, សេរីភាពរួចផុតពី អំពើហិង្សាក្នុងគ្រួសារ និង សុចរិតភាពបុគ្គលម្នាក់ៗ

សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស

- មាត្រា៣៖ សិទ្ធិក្នុងការរស់រានមានជីវិត, សិទ្ធិមាន សេរីភាព និង សិទ្ធិមានសន្តិសុខផ្ទាល់ខ្លួន
- មាត្រា៥៖ សេរីភាពរួចផុតពីការធ្វើទារុណកម្ម និង ការប្រព្រឹត្តថោកទាប

តម្រូវការពេលវេលា៖ ៨០ នាទី

## ព័ត៌មានអំពីគ្រូបង្រៀន៖

អំពើហិង្សាក្នុងគ្រួសារ គឺមានការលំបាកដែលតម្រូវឲ្យមានដំណោះស្រាយ ព្រោះថា គេបានលាក់បិទបាំងជានិច្ច និង ជាបុព្វហេតុ នៃ សេចក្តីអៀនខ្មាស សម្រាប់ជនរងគ្រោះ និង អ្នកជិតដិតនឹងជនរងគ្រោះ។ ក្នុងការត្រៀមរៀបចំបង្រៀនអំពីប្រធានបទនេះ ចូរមានបញ្ជីឈ្មោះ និង ការទំនាក់ទំនងអង្គការក្រៅរដ្ឋាភិបាលក្នុងសហគមន៍ ចំពោះការគាំទ្របុគ្គលម្នាក់ៗ ដែលមានការប៉ះពាល់ដោយ អំពើហិង្សាក្នុងគ្រួសារ។ មានសារៈសំខាន់ផងដែរ ក្នុងការពន្យល់ថា តើអំពើហិង្សាក្នុងគ្រួសារជាអ្វី? អំពើហិង្សាក្នុងគ្រួសារ គឺជាឥរិយាបថបន្តបន្ទាប់ ដែលបានប្រព្រឹត្ត ដោយបុគ្គលម្នាក់ លើការត្រួតត្រាម្នាក់ទៀត។

## តើមានឥរិយាបថបែបណា ដែលគេចាត់ទុកថា ជាអំពើហិង្សាក្នុងគ្រួសារ?

បើសិនជាដៃគូរបស់អ្នក៖

- ធ្វើឲ្យអាម៉ាស់មុខ ឬ ធ្វើឲ្យខូចកេរ្តិ៍ខ្មាសអ្នក ដោយចេតនា
- ត្រួតត្រាសកម្មភាពណា មួយរបស់អ្នក, ដូចជា អ្នកណាដែល អ្នកអាចជួប ឬ អាចជជែកជាមួយ ឬ ក៏ទីកន្លែងណា ដែលអ្នកអាចទៅ
- ប្រាប់អ្នកថា អ្នកគឺជា ម្តាយដ៏អាក្រក់ ឬ គម្រាមកំហែងយក ឬ ក៏ធ្វើ ឲ្យគ្រោះថ្នាក់ ដល់ កូនរបស់អ្នក
- ធ្វើសេចក្តីសម្រេច ចិត្តទាំងអស់ជំនួសអ្នក
- រារាំង អ្នកមិនឲ្យជួបមនុស្សជាទីស្រឡាញ់ ដូចជា មិត្ត និង គ្រួសារ របស់អ្នក
- រំលោភរាងកាយអ្នក តាមបែបណាមួយ
- យកទ្រព្យសម្បត្តិ ឬ លុយកាក់ របស់អ្នក និង ដកហូតវាពីអ្នក
- គម្រាមកំហែងអ្នក ដោយអាវុធ
- បំផ្លិចបំផ្លាញទ្រព្យសម្បត្តិ របស់អ្នក ឬ គម្រាមកំហែង សម្លាប់សត្វចិញ្ចឹម របស់អ្នក
- ប៉ុនប៉ងបំភ័យអ្នក
- គម្រាមកំហែងធ្វើឲ្យអន្តរាយរាងកាយ ដល់ពួកគេ ឬ គម្រាមកំហែងអ្នក ដោយប្រើអំពើហិង្សារាងកាយ
- រារាំងអ្នកមិនឲ្យទៅធ្វើការ ឬ ទៅសាលារៀន

## សំណួរណែនាំ

- តើវាមានន័យយ៉ាងម្តេច ចំពោះសុវត្ថិភាព?
- តើគេរំពឹងថា នឹងមានសុវត្ថិភាព នៅទីកន្លែងណា?
- ហេតុអ្វីបានជាអ្នកបង្កើត សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ប្រើ ភាសា "សន្តិសុខផ្ទាល់ខ្លួន"?
- តើអំពើហិង្សាក្នុងគ្រួសារបានកើតឡើង នៅទីកន្លែងណា?

## គោលដៅ

បន្ទាប់ពីមេរៀននេះ សិស្ស នឹងអាច៖

- កំណត់ និង យល់ដឹង ពាក្យ "អំពើហិង្សាផ្នែកយេនឌ័រ"
- ពិនិត្យ និង វិភាគ ការពិតនិងតួលេខ ទាក់ទងនឹងអំពើហិង្សាក្នុងគ្រួសារ
- ដឹងថា តើលោកស្រី ម៉ារីណា ពីសក្លាកូវ៉ា ជានរណា, ហើយ ការងាររបស់នាង សម្រាប់អ្នករួចផុតពី អំពើហិង្សា

## ជំនាញសិស្ស

- ការគិតពិចារណា
- ការធ្វើសេចក្តីសន្និដ្ឋាន
- ការរៀបចំ និង ការបកស្រាយ ព័ត៌មាន
- ការចូលរួម ក្នុងការធ្វើផែនការ និង កិច្ចពិភាក្សាជាក្រុម
- តក្កវិទ្យា(critical thinking)

| វាក្យស័ព្ទ | គោលគំនិត | សម្ភារៈនានា |
| --- | --- | --- |

**វាក្យស័ព្ទ**

- អំពើហិង្សា ផ្នែកយេនឌ័រ
- សន្តិសុខផ្ទាល់ខ្លួន
- អំពើហិង្សាក្នុងគ្រួសារ
- ការទប់ស្កាត់
- ការទំនាក់ទំនង (relationship)
- អ្នកប្រឆាំង

**គោលគំនិត**

- ការយល់ចិត្តគ្នា
- អត្តសញ្ញាណ
- យុត្តិធម៌
- អំណាច
- ការធ្វើសេចក្តីសម្រេចចិត្ត
- តម្លៃពលរដ្ឋ
- សិទ្ធិមនុស្ស

**សម្ភារៈនានា**

- សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស
  www.un.org
- អំពើហិង្សាក្នុងគ្រួសារ
  www.domesticviolence.org
- ការធ្វើបទសម្ភាសជាមួយលោកស្រី
  www.speaktruth.org



លោកគ្រូ អ្នកគ្រូ កំពុងជួយត្រួតពិនិត្យអក្ខរាវិរុទ្ធ នៅភ្នំពេញ ខែសីហា ឆ្នាំ២០១១

# សកម្មភាពរបស់សិស្ស

## ស្ថានភាពព្រាងទុក

- បង្រៀនសិស្សឲ្យអាន មាត្រា៣ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស។
- បង្រៀនសិស្សឲ្យអាននិយមន័យនៃអំពើហិង្សាក្នុងគ្រួសារ និង ការពិត និងតួលេខ www.unifem.org។
- បន្ទាប់ពីការអាន, សូមបង្រៀនសិស្សឲ្យរៀបពាក្យឡើងវិញ នូវមាត្រា៣ ដោយផ្អែកលើ ការយល់ដឹងអំពី អំពើហិង្សាក្នុងគ្រួសារ។
- ស្នើសិស្ស ឲ្យធ្វើ របាយការណ៍ផ្ទាល់មាត់ ទៅកាន់ថ្នាក់។ តាមរយៈកិច្ចពិភាក្សាដែលសម្របសម្រួលដោយ គ្រូបង្រៀន។

## សកម្មភាពទី១

ចូរចែកការសម្ភាសន៍ របស់ លោកស្រី ម៉ារីណា ពីសក្លាគូវ៉ា, ហើយសូមសួរសិស្ស នូវសំណួរនានា ដូចខាងក្រោម៖

- តើហេតុអ្វីបានជា លោកស្រី ម៉ារីណា ពីសក្លាគូវ៉ា ចាប់ផ្តើមធ្វើការងាររបស់នាង ដើម្បីបញ្ចប់ អំពើហិង្សាក្នុងគ្រួសារ នៅក្នុងប្រទេសរុស្ស៊ី?
- តើមានលក្ខណៈអ្វីខ្លះ នៃ អំពើហិង្សាក្នុងគ្រួសារ ដែល ស្រដៀងគ្នា ពី ករណីមួយ ទៅករណីមួយ?
- តើអ្វីទៅ ជា និយមន័យ មុខងារ នៃអំពើហិង្សាក្នុងគ្រួសារ របស់លោកស្រី ម៉ារីណា ពីសក្លាគូវ៉ា?
- តើអ្វីទៅ ជា ការប្រឆាំងជំទាស់? ហេតុអ្វីបានជាឪពុករបស់ លោកស្រី ម៉ារីណា ហៅនាងថា ជាអ្នកប្រឆាំងជំទាស់?
- សូមធ្វើការអត្ថាធិប្បាយថា តើលោកស្រី ម៉ារីណា បានជួយស្ត្រីរុស្ស៊ីដោយរបៀបណា។

## សកម្មភាពទី២

- រៀបចំអនុវត្តន៍គូសផែនទីសហគមន៍ ដើម្បីរៀនអំពីថា តើអ្នករួចផុតពីអំពើហិង្សាក្នុងគ្រួសារ អាចទទួលជំនួយ និង ការគាំទ្រ នៅក្នុងទីកន្លែងណា ក្នុងសហគមន៍របស់អ្នក។ ដាក់បញ្ចូល អ្នកផ្តល់សេវាសុខភព, អ្នកអនុវត្តន៍ច្បាប់, អង្គការក្រៅរដ្ឋាភិបាល នៅ សហគមន៍ និង ប្រព័ន្ធយុត្តិធម៌។
- បន្ទាប់ពីគម្រោងគូសផែនទីនេះ បានបញ្ចប់, សូមផ្តុំសិស្សទាំងអស់នេះ, ហើយសូមឲ្យពួកគេ ជ្រើសរើសអង្គការមួយ ដើម្បីធ្វើបទសម្ភាស។
- មុននឹងធ្វើបទសម្ភាស, ថ្នាក់ទាំងមូល គួរតែ បង្កើតសំណួរយ៉ាងហោចណាស់ដប់សំណួរ, ដើម្បីសួរអង្គការនីមួយៗ។ កម្រងសំណួររួមគ្នាមួយ នឹងជួយឲ្យថ្នាក់អាចបង្កើតរបាយការណ៍ ស្តីពីសមត្ថភាពសហគមន៍ ក្នុងការជួយជនរងគ្រោះ ឲ្យរួចផុត ពី អំពើហិង្សាក្នុងគ្រួសារ។
- នៅពេលដែលការធ្វើបទសម្ភាស បានបញ្ចប់, សិស្ស គួរតែធ្វើការជាក្រុម, មានគ្នាចំនួន៤នាក់, ដើម្បីអង្កេតនូវ ការឆ្លើយតបពីការធ្វើបទសម្ភាស របស់ពួកគេ និង ពង្រាង ឯកសាររួមគ្នា។
- បន្ទាប់ពីក្រុមបានជួបជុំគ្នារួចមក, សូមកោះប្រជុំ ថ្នាក់ទាំងមូល ដើម្បីពង្រាងឯកសារមួយ ដោយគូសបញ្ជាក់នូវចំណុចស្រដៀងគ្នា និង ចំណុចខុសគ្នា ដោយផ្អែកទៅលើ សំណួរដែលបានធ្វើបទសម្ភាស និង ទៅលើ របៀបដែលអង្គការសហគមន៍នីមួយៗ បានបំពេញនូវ បេសកកម្មរបស់ខ្លួន ដើម្បីជួយជនរងគ្រោះ ពី អំពើហិង្សាក្នុងគ្រួសារ។
- សិស្ស គួរតែចែករំលែក ឯកសារនេះ ជាមួយអង្គការ។
- ដោយសារសកម្មភាពនេះ សិស្ស អាចបង្កើត ផែនការសកម្មភាពមួយ ដើម្បីផ្លាស់ប្តូរទិដ្ឋភាពខ្លះ នៃ បណ្តាញសុវត្ថិភាព, សង្គម ឬ ចំណេះដឹង នៅក្នុងទីក្រុង ឬ ទីប្រជុំជន សម្រាប់ធ្វើកិច្ចការឲ្យបានល្អ។

# ក្លាយទៅជាអ្នកការពារ

- ចូររៀបចំ ទិវាសុវត្ថិភាព ផ្ទាល់ខ្លួន។ រួមបញ្ចូល ទាំងវាគ្មិន និង អ្នកធ្វើបទបង្ហាញពី អង្គការសហគមន៍មួយចំនួន ដែលអ្នកបានរៀន នៅក្នុងការអនុវត្ត គូសផែនទីសហគមន៍ របស់អ្នក។ សូមរៀបចំថ្នាក់ស្វ័យការពារមួយ។
- សូមអញ្ជើញវាគ្មិនម្នាក់ មកធ្វើបទបង្ហាញ អំពីបញ្ហា នៃ អំពើហិង្សា ក្នុងពេលកំពុងស្គាល់គ្នា (dating)។
- សូមបង្កើត តារាងមួយ ដាក់នៅកន្លែងមានប្រជាប្រិយភាព និង ផ្តល់ព័ត៌មានអំពី អំពើហិង្សាក្នុងគ្រួសារ, អង្គការ ដែលធ្វើការ ដើម្បីបញ្ឈប់វា និង ឱកាសនានា សម្រាប់បុគ្គលម្នាក់ៗ ដែលចង់ចាត់វិធានការឆ្លើយតប។
- មានការចុះហត្ថលេខាលើញត្តិមួយ ក្នុងការគាំទ្រ ទាំងច្បាប់កម្ពុជា ទាំងច្បាប់អន្តរជាតិ ដើម្បី ការពារស្ត្រី និង  បញ្ឈប់ អំពើហិង្សា ក្នុងគ្រួសារ ប្រឆាំងនឹងស្ត្រី និង កុមារ។

# ព័ត៌មានបន្ថែម

**ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី**
**(Cambodian National Council for Women)**

www.cncw.gov.kh

**ក្រសួងកិច្ចការនារី (Ministry of Women's Affairs)**

www.mwa.gov.kh

**អង្គការសុខភាពពិភពលោក**
**(World Health Organization, WHO)**

www.who.int

**មូលនិធិអង្គការសហប្រជាជាតិដើម្បីការអភិវឌ្ឍសម្រាប់ស្ត្រី**
**(United Nations Development Fund for Women)**

www.unifem.org

**មូលនិធិអង្គការសហប្រជាជាតិស្តីពីពលរដ្ឋ**
**(United Nations Population Fund)**

www.unfpa.org

**អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ**
**(Cambodian Women's Crisis Center)**

www.cwcc.org.kh

**របាយការណ៍ របស់ យូនីសេហ្វអំពី អំពើហិង្សាក្នុងគ្រួសារ**
**(UNICEF Report on Domestic Violence)**

www.unicef-irc.org

"SOME SEE THE WORLD

AS IT IS TODAY AND ASK,

WHY. I SEE THE WORLD

AS IT COULD BE AND

ASK, WHY NOT."

— ROBERT F. KENNEDY

# លោកស្រី ជូលីអាណា ដកបាតហ្ស៊ី (JULIANA DOGBADZI)

"មានស្ត្រីជាច្រើន ដែលរស់នៅក្នុងទីសក្ការៈ (shrine) ដែលត្រូវការជំនួយ។ គ្មានអ្នកណាម្នាក់នឹងត្រូវបានតំណាងឲ្យពួកគេ ប្រសើរជាងមនុស្សម្នាក់ ដែលធ្លាប់បានស្នាក់អាស្រ័យនៅក្នុងទីសក្ការៈនោះ ហើយនឹងបានឆ្លងកាត់ការឈឺចាប់...។ ដោយមានសង្ឃឹមតិចតួចណាស់ ដែលខ្ញុំបានសម្រេចចិត្តទទួលខុសត្រូវចំពោះការដោះស្រាយ បញ្ហានេះ និង បានធ្វើដូច្នេះចាប់តាំងពីពេលនោះមក"។

ដោយបានជាប់ខ្លួនជាទាសករ នៅក្នុងទីសក្ការៈមួយនៅប្រទេសហ្គាណា (Ghana) ជាប្រទេសកំណើតជាក្មេងស្រីម្នាក់ស្ថិតក្រោមទំនៀមទំលាប់មួយ ដែលគេហៅថា "ត្រូកូស៊ី" (Trokosi), លោកស្រីជូលីអាណា ដកបាតហ្ស៊ី (Juliana Dogbadzi) ត្រូវបានគេបង្ខំឲ្យធ្វើការដោយគ្មានកម្រៃ, គ្មានស្បៀងអាហារ ឬសំលៀកបំពាក់, ហើយនឹងត្រូវបម្រើសេវាផ្លូវភេទឲ្យអាចារ្យកាន់សីលម្នាក់ (holy man)។ ១៧ឆ្នាំកន្លងមក នាងបានគេចផុត ពេលនាងមានអាយុ ២៣ឆ្នាំ, ក្រោយពីការសាកល្បងបរាជ័យច្រើនដងច្រើនសា។ ត្រូកូស៊ី (Trokosi) បានមកពីភាសាអ៊ីវ (Ewe) ហើយពាក្យនេះមានន័យថា "ទាសីរបស់ព្រះអាទិទេព" (ឬ "ទាសកររបស់ព្រះអាទិទេព"), ហើយដែលគេយល់ថា ការបដិបត្តិសាសនា និងទំនៀមទំលាប់ ដែលនៅក្នុងនោះ ក្មេងស្រីភាគច្រើនជាក្មេងព្រហ្មចារិនី ត្រូវបានបញ្ជូលទៅបម្រើអស់មួយជីវិត ដើម្បីលាងបាបកម្ម អំពីបទឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តរបស់សាច់ញាតិរបស់ពួកគេ។ ក្នុងឆ្នាំ១៩៩៧ គេបាន ប៉ាន់ស្មានថា ក្មេងស្រី និង ស្ត្រី ប្រហែល ៥ពាន់នាក់ ត្រូវបានឃុំគ្រងទុកនៅក្នុងទីសក្ការៈចំនួន



Juliana Dogbadzi, ©2000 Eddie Adams

៣៤៥ នៅប៉ែកអាស៊ីអាគ្នេយ៍ នៃប្រទេសហ្គាណា។ តាមរយៈការហ៊ានគេចខ្លួនរបស់ជូលីអាណា ដកបាដហ្ស៊ី និង ការព្យាយាមបន្តបន្ទាប់របស់នាង ក្នុងការរិះគន់ប្រព័ន្ធនេះ, ការអនុវត្តទំនៀមទំលាប់ ត្រូកូស៊ី (Trokosi) ត្រូវបានហាមឃាត់នៅក្នុងប្រទេសហ្គាណា ក្នុងឆ្នាំ១៩៩៩។ ទោះបីជាយ៉ាងណាក៏ដោយ ការអនុវត្តច្បាប់ប្រឆាំងនឹង ត្រូកូស៊ី គឺនៅតែធូររលុងនៅឡើយ។ លោកស្រី ដកបាដហ្ស៊ី (Dogbadzi) នៅតែបន្តក្នុងការនិយាយឆ្លើយតបទៅនឹងទំនៀមទំលាប់ ត្រូកូស៊ី (Trokosi) ដោយធ្វើដំណើរពាសពេញប្រទេស, ជួបប្រជុំជាមួយទាសករ និង ព្យាយាមទាមទារសេរីភាពឲ្យពួកគាត់។

ខ្ញុំមិនដែលបាននៅក្នុងថ្នាក់រៀនទេ។ ខ្ញុំមិនដែលបានទៅសាលារៀនទេ។ នៅពេលដែលខ្ញុំមានអាយុ៧ឆ្នាំ, ឪពុកម្ដាយរបស់ខ្ញុំ បានយកខ្ញុំចេញពីផ្ទះរបស់យើង ហើយបានបញ្ជូនខ្ញុំទៅកាន់ទីសក្ការៈមួយ ដែលខ្ញុំបានក្លាយជាទាសកររបស់អាចារ្យកាន់សីលម្នាក់ (fetish priest) អស់រយៈពេល១៧ឆ្នាំ។ ពួកគេបាននិយាយថា ជីតារបស់ខ្ញុំ បានលួចលុយ២ដុល្លារ។ នៅពេលដែលគាត់ត្រូវបានសង្ស័យពី បទឧក្រិដ្ឋកម្ម ហើយបានទាមទារឲ្យសងលុយវិញ គាត់បានការពារភាពគ្មានទោសពៃរបស់គាត់។ ស្ត្រីម្នាក់ដែលបានចោទប្រកាន់គាត់ ពីបទឧក្រិដ្ឋកម្ម បានទៅកាន់ទីកន្លែងសក្ការៈនោះ ហើយបានដាក់បណ្ដាសារ មកលើក្រុមគ្រួសារជីតារបស់ខ្ញុំ។ បន្ទាប់មក សមាជិកគ្រួសារខ្ញុំបានចាប់ផ្ដើមស្លាប់។ ដើម្បីបញ្ឈប់ការស្លាប់នេះ គ្រូទាយ (soothsayer) បានប្រាប់យើងថា ជីតារបស់ខ្ញុំ ត្រូវការវាយការណ៍ទៅកាន់ទីកន្លែងសក្ការៈ ត្រូកូស៊ី (Trokosi)។ អាចារ្យកាន់សីល បានប្រាប់ក្រុមគ្រួសារខ្ញុំថា ត្រូវតែនាំក្មេងស្រីម្នាក់មកកាន់ទីកន្លែងសក្ការៈនេះ ដើម្បីបន្ធូរស្រាលដល់ ព្រះអាទិទេព។ ប្អូនស្រីម្នាក់ ត្រូវ បានបញ្ជូនទៅកាន់ទីកន្លែងសក្ការៈនោះ នៅ ខេបេនូ (Kebenu) មានចម្ងាយប្រាំមួយរយម៉ាយ (ប្រហែល ១,០០០ គីឡូម៉ែត) ប៉ុន្តែ ពីរបីឆ្នាំ ក្រោយមក នាងបានស្លាប់។ ចាប់តាំងពីខ្ញុំបានកើតមក ក្រោយពី មរណៈភាពជីតារបស់ខ្ញុំ, ខ្ញុំបានជំនួសប្អូនស្រីខ្ញុំនៅក្នុងទីសក្ការៈ។

ខ្ញុំបានរស់នៅ និង បានធ្វើការនៅវាលស្រែរបស់អាចារ្យកាន់សីល និង បោសសម្អាតបរិវេណ។ ខណៈដែលកំពុងធ្វើការងារ ខ្ញុំត្រូវបានគាត់ចាប់រំលោភម្ដងហើយម្ដងទៀត នៅលើកន្ទេលដាច់ដោចមួយនៅលើកម្រាលដ៏ត្រជាក់នៃខ្ទមដែលគ្មានបង្អួច។ ទាសករស្ត្រីផ្សេងៗទៀត និង ខ្ញុំមិនបានទទួលទាំងអាហារហូបចុក និង ទាំងការព្យាបាលជម្ងឺ។ យើងត្រូវរកពេលវេលា បន្ទាប់ពីធ្វើការនៅលើវាលស្រែចំការរបស់អាចារ្យកាន់សីល ដើម្បីដុតធ្យូងអុស និង លក់អុស នៅក្នុងទីប្រជុំជនដែលនៅជិត ក្នុងគោលបំណងរកលុយគ្រប់គ្រាន់ ដើម្បីទិញម្ហូបអាហារ។ មានពេលវេលាជាច្រើន ដែលយើងរស់នៅពឹងផ្អែកលើម្ទេសស្រស់ ឬ សាច់គ្រាប់ត្នោត ដើម្បីរស់។

ដោយសារខ្ញុំនៅមានភាពជាកុមារ ខ្ញុំមិនដឹងថា ត្រូវធ្វើអ្វីនោះទេ។ មានស្ត្រីចំណាស់ម្នាក់ ដែលជាទាសករ និង បានមើលថែរក្សាខ្ញុំ។ គាត់មិនអាចជួយខ្ញុំបានច្រើនទេ ពីព្រោះគាត់មានកូនច្រើន ដោយសារការរំលោភពីអាចារ្យកាន់សីល។ នាងបាននិយាយថា "មើលហ្ន៎, កូនស្រីអើយ, សូមថែរក្សាខ្លួន បើមិនអញ្ចឹងទេ អ្នកប្រាកដនឹងស្លាប់"។ ធ្លាប់មានទាសករជាស្ត្រី ១០០នាក់ នៅក្នុងទីកន្លែងសក្ការៈនេះ, ប៉ុន្តែ អាចារ្យកាន់សីល បានបញ្ជូនពួកគេប្រហែល៩០នាក់ ឲ្យទៅធ្វើស្រែចំការរបស់គាត់ នៅក្នុងភូមិដទៃទៀត។ បូកសរុបមក, ពួកគេមានក្មេងប្រហែល ៦៥នាក់ និង ត្រូវធ្វើការដើម្បីមើលថែទាំក្មេងៗទាំងអស់នោះ។

យើងមានចំនួន១២នាក់ (ស្ត្រីចំនួន៤ និង កុមារចំនួន៨នាក់) បានរស់នៅក្នុងផ្ទះមានបន្ទប់មួយ ដំបូលប្រក់ស្បូវ។ ផ្ទះនេះកសាងអំពីភក់ និង គ្មានបង្អួចនិងទ្វារទេ។ ភ្លៀងបានសាចចូលក្នុងផ្ទះ។ ពស់បានវារចូលក្នុងផ្ទះ។ បន្ទប់មានបណ្ដោយទំហំ ២០ជំហាន និង ទទឹង ១២ជំហាន។ ខ្ទមនេះមានដំបូលទាប, ហួសក្បាលយើងបន្តិច, ហើយយើងទាំងអស់គ្នា ដេករួមគ្នានៅលើកន្ទេលមួយលើឥដ្ឋ។ នេះ គឺមិនមែនជាអ្វីគ្រប់យ៉ាង ដែលខ្ញុំអាចចងចាំបានទាំងអស់នោះទេ, ប៉ុន្តែ ក្នុងការនិយាយនេះ ការចងចាំហើបឡើងវិញ អំពីការឈឺចាប់។ វាមានការលំបាក ក្នុងការចងចាំក្នុងការត្រលប់ទៅកាន់ពិសោធន៍ទាំងអស់នោះឡើងវិញ។

អ្នកឃើញទេ នៅក្នុងទីកន្លែងសក្ការៈ មិនមាននរណាមានសិទ្ធិពាក់ស្បែកជើង ឬ ពាក់មួក ដើម្បីការពារកំដៅព្រះអាទិត្យទេ។ បើសិនកំពុងភ្លៀង ឬ រងា, ពួកយើងមានត្រឹមតែបំណែកតូចមួយ នៃសំលៀកបំពាក់នៅជុំវិញខ្លួនរបស់យើងប៉ុណ្ណោះ។ ថ្ងៃធម្មតា នៅក្នុងទីកន្លែងសក្ការៈ គឺមានដូចតទៅ៖ ពួកយើងត្រូវភ្ញាក់ពីម៉ោង៥ព្រឹក, ធ្វើដំណើរទៅអូរក្នុងចំងាយ ៥គីឡូម៉ែត្រ ដើម្បីដងទឹកសម្រាប់ប្រើប្រាស់ក្នុងបរិវេណ, បោសសម្អាត, រៀបចំអាហារជូនអាចារ្យកាន់សីល (មិនទុកខ្លះសម្រាប់ពួកយើងញាំទេ), ធ្វើដំណើរទៅស្រែចំការ, ធ្វើការរហូតដល់ម៉ោង៦ល្ងាច, និង ត្រលប់មកគេងដោយគ្មានអាហារហូប ឬ ទទួលបានសំណល់តិចតួច។ នៅពេលយប់, អាចារ្យកាន់សីលនឹងហៅយើងម្នាក់ឲ្យមកបន្ទប់របស់គាត់ ហើយរំលោភយើង។ ខ្ញុំមានអាយុប្រហែល១២ឆ្នាំ ពេលគាត់បានរំលោភខ្ញុំលើកទីមួយ។

មានការកាន់ជើង សូម្បី ក្នុងនាមជាទាសភាពក៏ដោយ។ អាចារ្យកាន់សីលនោះ បានចូលចិត្តក្មេងស្រីទាំងឡាយណា ដែលយល់ព្រមទៅនឹងតម្រូវការខាងផ្លូវភេទរបស់គាត់ ហើយស្អប់ក្មេងស្រីទាំងឡាយណា ដែលប្រឆាំងនឹងតម្រូវការរបស់គាត់។ ដូច្នេះហើយ ក្មេងស្រីទាំងនោះ ត្រូវបាន គាត់វាយធ្វើបាប។ ក្មេងស្រីទាំងឡាយណា ដែលគាត់ចូលចិត្ត តែងតែនិយាយថា ពួកគេឆ្លាតណាស់ ពីព្រោះពួកគេបានជៀសផុតពីការវាយធ្វើបាបនោះ, ខណៈដែលគ្នាយើងខ្លះ អះអាងថា ពួកគេជាមនុស្សឆ្កួត ហើយមានការរួមភេទជាមួយមនុស្ស ដែលពួកគេមិនបានស្រឡាញ់នោះ។ នៅពេលដែលខ្ញុំបានឃើញមនុស្សដែលមកកាន់ភូមិ ដើម្បីទិញម្ហូបអាហារ ដោយស្លៀកពាក់ស្អាតៗ, ខ្ញុំចាប់ផ្ដើមគិតថា ខ្ញុំត្រូវធ្វើអ្វីមួយ សម្រាប់ខ្លួនខ្ញុំ។ ខ្ញុំត្រូវតែទទួលបានសេរីភាព។

ខ្ញុំត្រូវធ្វើអ្វីមួយ ដែលអាចនឹងផ្លាស់ប្ដូរជីវិតរបស់ខ្ញុំ។ ខ្ញុំបានគេចផុតជាច្រើនលើក។ លើកទីមួយដែលខ្ញុំបានជៀសផុត គឺខ្ញុំបានទៅជួបឪពុកម្ដាយរបស់ខ្ញុំ។ ខ្ញុំបានប្រាប់ពួកគាត់ថា ខ្ញុំបានទទួលរងទុក្ខវេទនា នៅក្នុងទីកន្លែងសក្ការៈនោះ, ប៉ុន្តែ ពួកគាត់បានភ័យខ្លាចក្នុងការឲ្យខ្ញុំនៅជាមួយគាត់។ ពួកគាត់បាននិយាយថា ប្រសិនបើពួកគាត់ឲ្យខ្ញុំនៅ ព្រះអាទិទេពនឹងដាក់ទណ្ឌកម្មពួកគាត់រហូតដល់ស្លាប់។ ពួកគាត់ បញ្ជូនខ្ញុំត្រលប់ទៅអាចារ្យកាន់សីលនោះវិញ ដើម្បីឲ្យទទួលរងនូវការ ឈឺចាប់

ដូចមុនសារជាថ្មីម្តងទៀត។ ខ្ញុំបានគិតថា, មិនទៀតទេ។ រឿងនេះ ខ្ញុំនឹងមិនឲ្យកើតឡើងសារជាថ្មីទេ។ ខ្ញុំត្រូវស្វែងរកមធ្យោបាយមួយ ដើម្បីរំដោះខ្លួនខ្ញុំ និង រំដោះស្ត្រី ដទៃទៀតផងដែរ។

លើកទីពីរ ដែលខ្ញុំបានគេចផុត, គឺខ្ញុំបានទៅកាន់ភូមិមួយ ដែលនៅក្បែរនោះ។ បុរសក្មេងម្នាក់បានផ្តល់ម្ហូបអាហារឲ្យខ្ញុំ ហើយបានយកខ្ញុំទៅជាមួយគាត់។ គាត់បានកេងប្រវ័ញ្ចលើខ្ញុំ ហើយបានធ្វើឲ្យខ្ញុំមានផ្ទៃពោះ។ នៅពេលដែលអាចារ្យកាន់សីលនោះបានដឹង គាត់បានប្រើក្មេងប្រុសៗ ឲ្យដើរតាមភូមិ ដើម្បីស្វែងរកខ្ញុំ។ ពួកគេបានវាយធ្វើបាបខ្ញុំដោយគ្មានទីបញ្ចប់ ហើយខ្ញុំមានស្នាមជាំជាច្រើនលើខ្លួនប្រាណ។ ខ្ញុំបានដួលសន្លប់ និង បាត់ស្មារតីជិតស្លាប់។ បុរសក្មេងដែលជាឪពុករបស់ កូនខ្ញុំ ចង់មកយកពួកយើងទៅថែទាំ ប៉ុន្តែ អាចារ្យកាន់សីលនោះបានគម្រាមកំហែងសម្លាប់គាត់។ ក្មេងប្រុស ដែលបានមើលថែរក្សាខ្ញុំនោះ, គឺត្រូវបានអាចារ្យកាន់សីលនោះបង្ខំឲ្យបង់លុយទៅលើស្រាជាច្រើនដប និង សត្វស្លាបមួយក្បាល ហើយបានព្រមានឲ្យនៅឆ្ងាយពីខ្ញុំ, បើមិនអញ្ចឹងទេនឹងស្លាប់។ ចាប់តាំងពីពេលនោះមក ខ្ញុំមិនដែលបានជួបគាត់ទេ ហើយគាត់មិនបានឃើញកូនរបស់យើងដែរ។

លើកទីបី ដែលខ្ញុំបានគេចផុត គឺខ្ញុំបានតាំងចិត្តថា ខ្ញុំនឹងមិនត្រលប់ទៅកាន់ទីកន្លែងសក្ការៈនោះសារជាថ្មីវិញទេ។ នៅពេលនេះ ខ្ញុំមានផ្ទៃពោះបីខែ, ដោយសារពីការរំលោភម្តងទៀតពីអាចារ្យកាន់សីលនេះ។ ខ្ញុំមិនសូវស្រួលខ្លួន។ ខ្ញុំបានអត់អាហារអស់រយៈពេល ពីរ បីថ្ងៃហើយ។ ខ្ញុំមានផ្ទៃពោះ ហើយខ្ញុំចាំបាច់ហូបអាហារខ្លះ។ បើមិនដូច្នោះទេ ខ្ញុំនឹងស្លាប់។ ខ្ញុំបានសម្រេចចិត្តទៅកាន់កសិដ្ឋានក្បែរនោះមួយ ដែលជាកម្មសិទ្ធិរបស់អាចារ្យកាន់សីលនេះ ដើម្បីបេះផ្លែពោតពីចំការដែលទាសករដទៃទៀត ក្នុងទីកន្លែងសក្ការៈនោះ និង ខ្ញុំបានដាំ។ ខ្ញុំត្រូវបានគេចាប់កំហុសបានពីការលួចផ្លែពោត, ហើយអាចារ្យកាន់សីលនោះ បញ្ជាក្មេងប្រុសៗពីក្នុងភូមិ ដើម្បីតាមវាយធ្វើបាបខ្ញុំរហូតដល់ខ្ញុំ សន្លប់បាត់ស្មារតី។ នៅពេលដែលខ្ញុំបានដឹងខ្លួនឡើងវិញ, ខ្ញុំបាន ឃើញស្នាមជាំ និង ស្នាមរបួសនៅលើខ្លួនប្រាណ, ហើយខ្ញុំស្ទើរ តែបាត់បង់កូន ដែលនៅក្នុងផ្ទៃរបស់ខ្ញុំផងដែរ។ ខ្ញុំបានសម្រេចចិត្តថា ខ្ញុំត្រូវតែចាកចេញ, បើមិនអញ្ចឹងទេខ្ញុំត្រូវស្លាប់។ ប៉ុន្តែ វាមិនត្រូវកើតឡើងអញ្ចឹងទេ។ ខ្ញុំភ័យខ្លាចណាស់, ហើយខ្ញុំបានត្រលប់ទៅកាន់ទីកន្លែងសក្ការៈសារជាថ្មីវិញ។ ប៉ុន្តែ ពេលវេលានោះជាចំណុច ផ្លាស់ប្តូរ។ ខ្ញុំមានអាយុ១៧ ឬ ១៨ឆ្នាំ នៅពេលនោះ, ហើយខ្ញុំបាន តាំងចិត្តថា ខ្ញុំនឹងធ្វើកិច្ចការនេះ ដើម្បីជួយមនុស្សដទៃទៀត ដែលកំពុង រស់នៅក្នុងទីកន្លែងសក្ការៈនោះ។

ថ្ងៃមួយ បុរសម្នាក់ដែលតំណាងឲ្យអង្គការមិនយកកម្រៃមួយ ដែលហៅថា តម្រូវការអន្តរជាតិ ហ្គាណា (International Needs-Ghana) បានមកកាន់ទីកន្លែងសក្ការៈនោះ ដើម្បីជជែកជាមួយអាចារ្យកាន់សីល។ នេះគឺជាឱកាសរបស់ខ្ញុំ។ ខ្ញុំមិនដឹងថា តើជំនឿទុកចិត្តភ្លាមៗរបស់ខ្ញុំ បានកើតឡើងមកពីណាទេ។ តែយ៉ាងណាក៏ដោយ ភាពភ័យខ្លាចទាំងអស់របស់ខ្ញុំ បានរលាយបាត់អស់។ ខ្ញុំលែងភ័យខ្លាចពីការស្លាប់ ហើយខ្ញុំបានត្រៀមស្លាប់ដើម្បីអ្នកដទៃទៀត។ អរគុណព្រះជាម្ចាស់ ដែលធ្វើឲ្យខ្ញុំមានអារម្មណ៍បែបនោះ! ខ្ញុំមិនបានគេចវេសភ្លាមៗទេ ពីព្រោះខ្ញុំមានកម្លាំងខ្សោយណាស់។ ដំណើរមានគត៌របស់ខ្ញុំជិតគ្រប់ខែហើយ ធ្វើឲ្យខ្ញុំមិនអាចដើរបានឆ្ងាយទេ។ សំណាងល្អណាស់, ពីរបីសប្តាហ៍ក្រោយមក ខ្ញុំបានសម្រាលកូន។ ជាមួយកូនង៉ា ដែលបានចងភ្ជាប់នឹងខ្នងរបស់ខ្ញុំ និង កូនច្បងឈ្មោះ វ៉នឌឺ (Wonder) កាន់ដៃខ្ញុំ, ខ្ញុំបានរត់គេចផុត តាមគុម្ពោធព្រៃទៅកាន់ដងផ្លូវធំ, ដែលគេបានជូនដំណើរខ្ញុំទៅដល់ អាឌីឌុម (Adidome), ហើយនឹងបានមកដល់ទីកន្លែងរបស់អង្គការតម្រូវការអន្តរជាតិ ហ្គាណា (International Needs-Ghana )។

សមាជិករបស់អង្គការនេះ បានបង្រៀនខ្ញុំអំពីជំនាញជាច្រើន និងឲ្យខ្ញុំនៅឆ្ងាយពីអាចារ្យកាន់សីលនោះ។ ពួកគេបានបណ្តុះបណ្តាលខ្ញុំអំពីការដុតនំបុ័ង និង វិជ្ជាជីវៈផ្សេងៗ។ ទោះជាយ៉ាងណាក៏ដោយ ខ្ញុំបានគិតថា, “មានស្ត្រីជាច្រើនកំពុងរស់នៅក្នុងទីកន្លែងសក្ការៈ ដែលត្រូវការជំនួយ។ គ្មានអ្នកណាម្នាក់នឹងត្រូវបានតំណាងឲ្យពួកគេ ប្រសើរជាងមនុស្សម្នាក់ ដែលធ្លាប់បានស្នាក់អាស្រ័យនៅក្នុងទីសក្ការៈនោះ ហើយនឹងបានឆ្លងកាត់ការឈឺចាប់, មនុស្សម្នាក់ដែលអាចប្រាប់ពិភពលោកអំពីអ្វីកំពុងកើតឡើងនៅក្នុងទីកន្លែងសក្ការៈនោះ។ ប្រសិនបើ គ្មាននរណាម្នាក់បញ្ឈប់ទំនៀមទំលាប់នេះទេ, យើងនឹងត្រូវស្លាប់ដោយសារការឈឺចាប់នេះ”។ ដោយមានសង្ឃឹមតិចតួចបំផុត ខ្ញុំបានសម្រេចចិត្តធ្វើការទទួលខុសត្រូវលើការដោះស្រាយបញ្ហានេះ, ហើយបានធ្វើការបែបនេះចាប់តាំងពីពេលនោះមក។ ខ្ញុំបានទៅកាន់ទីកន្លែងសក្ការៈ ជាច្រើន, ហើយបាននិយាយទៅកាន់មនុស្ស ដែលគេបង្ខាំងទុកទាំងនោះ។ ខ្ញុំបានប្រាប់ពួកគាត់ថា ពួកគាត់ត្រូវតែប្រមូលផ្តុំសេចក្តីក្លាហានដូចខ្ញុំមាន, ដើម្បីគេចផុតពីភាពនេះ។

ទីកន្លែងសក្ការៈនោះ ទាមទារអំណាចដែលវាមិនមាន ដើម្បីបណ្តុះបណ្តាលភាពភ័យខ្លាចចំពោះទាសករទាំងអស់, និង ដើម្បីបញ្ឈប់ពួកគេពីការរត់គេច។ ទំនៀមទំលាប់ ត្រូកូស៊ី នេះ គឺជាការប៉ុនប៉ងដោយចេតនាមួយ ដែលធ្វើឡើងដោយបុរសៗ ក្នុងបំណងដាក់ស្ត្រី ឲ្យស្ថិតក្រោមអំណាចរបស់គេ។ បុរសប្រព្រឹត្តឧក្រិដ្ឋកម្ម, ហើយស្ត្រីត្រូវការបង់ថ្លៃសម្រាប់ឧក្រិដ្ឋកម្មនោះ។ នោះគឺមិនអាចទទួលយកបានទេ។ ដូចគ្នាដែរ, ទីកន្លែងសក្ការៈ គឺជាឧក្រិដ្ឋកម្មប្រឆាំងនឹងកុមារ។ កូនរបស់ទាសករម្នាក់ ចែករំលែកនូវស្ថានភាពអាក្រក់របស់ម្តាយគាត់។ នៅពេលដែលម្តាយមានអាហារហូបចុក, ក្មេងនោះ ក៏មានអាហារហូបដែរ។ ប្រសិនបើនាងមិនមានអាហារហូបចុក, ក្មេងនោះ ក៏អត់ឃ្លានផងដែរ។ ប្រសិនបើនាងមានសំលៀកបំពាក់, ក្មេងនោះ ក៏មានសំលៀកបំពាក់ផងដែរ។ ប្រសិនបើនាងមិនមានទេ នោះ គឺចប់ហើយ។ ប្រសិនបើនាងទៅស្រែចំការ, ក្មេងនោះក៏ទៅជាមួយដែរ។ មានទាសករជាស្ត្រី ត្រូកូស៊ី រាប់ពាន់នាក់ ដែលមានកូនត្រូវការគេជួយ។ មនុស្សទាំងឡាយ ដែល

ត្រូវបានគេរំដោះ ត្រូវការជំនួយផងដែរ ក្នុងគោលបំណងរួចផុតពីការឈឺចាប់ ដែលបានអត់ទ្រាំនៅក្នុងទីកន្លែងសក្ការៈនោះ។

មិនដូចក្មេងស្រី និង ស្ត្រីភាគច្រើនដទៃទៀតទេ, ខ្ញុំបានរួចផុតពីភាពភ័យខ្លាច ដែលបានកើតឡើងពីប្រព័ន្ធ ត្រូកូស៊ី។ នេះ គឺជាអាវុធរបស់ខ្ញុំ។ ឥឡូវខ្ញុំបានគេចផុតពីបញ្ហានេះ, គឺខ្ញុំចង់ជួយបន្ធូរបន្ថយ នូវភាពភ័យខ្លាចរបស់ស្ត្រី ដោយប្រាប់ពួកគាត់អំពីប្រវត្តិរបស់ខ្ញុំ។ ខ្ញុំប្រាប់ពួកគាត់ អំពីអ្វីដែលខ្ញុំកំពុងធ្វើ, ខ្ញុំនៅតែរស់រានមានជីវិតនៅឡើយ, មិនបានស្លាប់ ដូចពួកគេត្រូវបានគេបង្ខំឲ្យជឿ។ ខ្ញុំព្យាយាមជួយអាចារ្យកាន់សីលច្រើននាក់ ដើម្បីឲ្យ យល់ដឹងអំពីការឈឺចាប់ ដែលស្ត្រីបានអត់ទ្រាំយូរមកហើយ។ អ្នកខ្លះហាមឃាត់ឈប់ឲ្យខ្ញុំ ចូលក្នុងទីកន្លែងសក្ការៈរបស់ពួកគាត់។ នៅពេលដែលខ្ញុំនៅក្នុងទីក្រុង, ខ្ញុំអប់រំមនុស្សអំពីជីវិតរស់នៅក្នុងទីកន្លែងសក្ការៈនោះ និង តស៊ូមតិ ឲ្យបញ្ឈប់ទំនៀមទំលាប់ ត្រូកូស៊ីនេះ។

អ្វីដែលខ្ញុំកំពុងធ្វើ មានភាពគ្រោះថ្នាក់, ប៉ុន្តែ ខ្ញុំត្រៀមខ្លួនទទួលការស្លាប់ចំពោះ បុព្វហេតុល្អ។ មនុស្សជាច្រើនបានផ្ញើបន្តលិខិតគម្រាមកំហែងដល់ខ្ញុំ, និង មនុស្សដទៃទៀត ប្រឈមជាមួយនឹងខ្ញុំដោយបើកចំហ។ អរគុណ ព្រះជាម្ចាស់ មនុស្សដែលខ្ញុំធ្វើការជាមួយ គឺសុទ្ធតែជាមនុស្សខ្លាំង ហើយលើកទឹកចិត្តខ្ញុំ។ នៅខណៈពេលនេះ ក្មេងស្រីចំនួន៨នាក់ បានចូលរួមធ្វើកិច្ចការជាមួយខ្ញុំនៅអង្គការ។ ជំហានបន្ទាប់របស់ខ្ញុំ គឺធ្វើឲ្យបែកខ្ញែកដល់ទំនៀមទំលាប់ ត្រូកូស៊ី ដោយជម្រុញឲ្យមានការអនុវត្តច្បាប់ និង ដើម្បីចងសម្ព័ន្ធជាមួយប្រទេសសាធារណៈតូហ្គូ (Republic of Togo) និង ប្រទេស សាធារណៈបេនីន (Republic of Benin) ក្នុងការបញ្ឈប់នូវទំនៀមទំលាប់នេះ នៅបណ្តាប្រទេសរៀងៗខ្លួនរបស់ពួកគេ។

ខ្ញុំជឿថា ខ្ញុំមានមុខរបរមួយច្បាស់លាស់ ព្រោះថា វាចម្លែកណាស់ដែលខ្ញុំនៅរស់ និង មានចិត្តជាប្រក្រតី, ហើយធ្វើការបន្ទាប់ពីបានឆ្លងកាត់នូវអ្វី ដែលខ្ញុំបានឆ្លងកាត់រួចមកហើយនោះ។ ជំនួយដែលខ្ញុំបានទទួលពី អង្គការតម្រូវការអន្តរជាតិ (International Needs) និង ជំនឿទុកចិត្តផ្ទាល់របស់ខ្ញុំ បានធ្វើឲ្យមានការផ្លាស់ប្តូរទាំងអស់។ ជារួម ខ្ញុំបានអធ្យាស្រ័យដល់ឪពុកម្តាយរបស់ខ្ញុំ ពីព្រោះខ្ញុំដឹងថា អ្វីដែលពួកគាត់បានធ្វើចំពោះខ្ញុំ គឺបានធ្វើដោយភាពងងឹតងងុល និង ភាពភ័យខ្លាច។ ខ្ញុំមិនចង់ឲ្យពួកគាត់មានអារម្មណ៍ធ្ងន់ដោយកំហុសរបស់គាត់, ដូច្នេះហើយ ខ្ញុំជៀសវាងការនិយាយប្រាប់ពួកគាត់អំពីបទពិសោធន៍ផ្ទាល់របស់ខ្ញុំ។ ទោះជាយ៉ាងណាក៏ដោយ ខ្ញុំមិនបានជួបពួកគាត់ជាញឹកញាប់ទេ។ ខ្ញុំរីករាយក្នុងការជូនដំណឹងថា ឥឡូវនេះ ខ្ញុំបានរៀបការដោយរីករាយ, ហើយទើបតែមានកូនមួយ ជាមួយបុរស ដែលខ្ញុំស្រឡាញ់។ បច្ចុប្បន្ននេះ ជីវិតរបស់ខ្ញុំ គឺដូចជាជីវិតរបស់ក្មេងស្រីដទៃៗទៀតដែរ។



ប្រារព្ធពិធីបើកការតាំងពិព័រណ៍រូបថត នៅ មជ្ឈមណ្ឌលវប្បធម៌ កម្ពុជា-អាឡឺម៉ង់ Meta House នៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១១

# អ្នកការពារ ប្រឆាំងនឹង ទាសភាព និង ការជួញដូរ

លោកស្រី ជូលីអាណា ដកបាតហ្សី

បញ្ហាសិទ្ធិមនុស្ស៖ ទាសភាព និង ការជួញដូរ

## សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស៖

- មាត្រា១៖ សិទ្ធិមានសមភាព
- មាត្រា២៖ សេរីភាពរួចផុតពីការរើសអើង
- មាត្រា៣៖ សិទ្ធិ ក្នុងការរស់រានមានជីវិត, សិទ្ធិមានសេរីភាព និង សិទ្ធិមានសន្តិសុខផ្ទាល់ខ្លួន
- មាត្រា៤៖ សេរីភាព រួចផុតពី  ទាសភាព
- មាត្រា៥៖ សេរីភាពរួចផុត ពីការធ្វើទារុណកម្ម និង ការប្រព្រឹត្តិថោកទាប
- មាត្រា៦៖ សិទ្ធិ ក្នុងការទទួលស្គាល់ជាបុគ្គល មុខច្បាប់
- មាត្រា៧៖ សិទ្ធិ មានសមភាព មុខច្បាប់

## សំណួរណែនាំ

- បើសិនជាទាសភាពនេះខុសច្បាប់ ចុះហេតុអ្វីបានជាទាសភាពនេះ កើតឡើងនៅទូទាំងពិភពលោក ក្នុងពេលបច្ចុប្បន្ន?
- មូលហេតុអ្វីខ្លះ ដែលរដ្ឋាភិបាល ធ្វើមិនដឹងមិនឮ ចំពោះ ការជួញដូរ និង ទាសភាពមនុស្ស?
- តើការផ្លាស់ប្តូរដ៏មានប្រសិទ្ធភាព អាចកើតឡើង យ៉ាងដូចម្តេច?

## តម្រូវការពេលវេលា៖ ៤០នាទី

## គោលបំណង៖

បន្ទាប់ពីមេរៀននេះ សិស្សអាចនឹង៖

- យល់អំពីបញ្ហា ការជួញដូរមនុស្ស និង ការទំនាក់ទំនងគ្នាទៅនឹង ការជួញដូរមនុស្សទៅនឹងទាសភាព។
- សញ្ជឹងគិតអំពី លោកស្រី ជូលីអាណា ដកបាតហ្សី និង ពិភាក្សា អំពីប្រភពនៃការយកធ្វើជា ទាសភាព និង ចុងក្រោយនៃ ស្ថានភាព របស់នាង។
- ឆ្លុះបញ្ចាំង អំពី គោលគំនិត នៃការបង់សងសម្រាប់ទង្វើខុសរបស់មនុស្សមួយទៀត ក្នុងគោលបំណង ទទួលស្គាល់នូវមធ្យោបាយនានា ដែលនៅក្នុងនោះបញ្ហានេះ គឺទាក់ទងនឹង ជីវិតផ្ទាល់ខ្លួន របស់ពួកគេ។
- បំផុសគំនិត អំពី ការចាត់វិធានការប្រឆាំងនឹងការ រំលោភសិទ្ធិមនុស្ស ទាំងអស់នេះ។
- ចូរសរសេរ ចំពោះការឆ្លុះបញ្ចាំងផ្ទាល់ខ្លួន ក្នុងការវាយតម្លៃ ទៅលើការយល់ដឹង អំពីបញ្ហានេះ។
- ស្នើសុំវិធានការ និង អនុវត្តន៍សកម្មភាព។

## ជំនាញរបស់សិស្ស

- ទាក់ទងទៅនឹង ការរំលោភ សិទ្ធិមនុស្ស ចំពោះ ជីវិតផ្ទាល់ខ្លួន របស់ពួកគេ
- ធ្វើការពិចារណា, ធ្វើសេចក្តីសន្និដ្ឋាន និង វាយតម្លៃ
- ប្រមូល ព័ត៌មាន
- ធ្វើសំយោគព័ត៌មាន
- បកស្រាយ ព័ត៌មាន
- សរសេរ ចំពោះការឆ្លុះបញ្ចាំងផ្ទាល់ខ្លួន
- ទទួលស្គាល់ នូវទស្សនៈ ជំទាស់ ដោយមានការគោរព
- ចូលរួម ក្នុង កិច្ចពិភាក្សា ជាក្រុម
- សហប្រតិបត្តិការ ដើម្បីសម្រេចនូវគោលដៅ
- មានការទទួលខុសត្រូវ  ចំពោះការអនុវត្តភារកិច្ច
- អនុវត្តន៍ សកម្មភាពតស៊ូមតិ និង កម្មវិធី

## វាក្យស័ព្ទ

- ការរត់ពន្ធ / ការជួញដូរ
- ទំនៀមទម្លាប់ ត្រូកូស៊ី (Trokosi)
- ទីកន្លែងសក្ការៈ (shrine)
- អាចារ្យកាន់សីល (fetish priest)
- អង្គការក្រៅរដ្ឋាភិបាល
- ការតស៊ូមតិ
- ច្បាប់ការពារជនរងគ្រោះពីការរត់ពន្ធ

## គោលគំនិត

- ការជួញដូរមនុស្ស
- ទាសភាពផ្លូវភេទ
- ភាពភ័យខ្លាច
- ការដាក់ឲ្យក្រោមអំណាច
- ការតស៊ូមតិ

ព័ត៌មានគ្រូបង្រៀន ទាំង វាក្យស័ព្ទ និង គោលគំនិត  ត្រូវបង្រៀន មុន មេរៀននេះ

## សម្ភារៈសិក្សានានា

- កាតសន្ទស្សន៍
- ក្តារខៀន
- ឯកសារ ដកស្រង់ ពី សេចក្តីក្លាហានគ្មានព្រំដែន
- សទ្ទានុក្រម នៃពាក្យពាក់ព័ន្ធ
- សំណួរពិភាក្សា

# សកម្មភាពរបស់សិស្ស

## ស្ថានភាពព្រាងទុក

- ស្នើសុំឲ្យសិស្ស ពិចារណា លើសំណួរខាងក្រោម និង ស្វង់មតិចម្លើយរបស់ពួកគេ
  - តើ ទាសភាពស្របច្បាប់ មាននៅកន្លែងណា ក្នុងពិភពលោក ពេលបច្ចុប្បន្ននេះ ?
  - ប្រសិនបើ ទាសភាព មានពេលបច្ចុប្បន្ននេះ តើអ្នកគិតថាមាន ទាសករចំនួន ប៉ុន្មាននាក់ ?
  - តើ មានទាសករនៅក្នុងប្រទេសកម្ពុជា ពេលបច្ចុប្បន្ននេះ ដែរឬ ទេ ?

- បង្ហាញ អំពី យូធូបវីដេអូ អំពីទាសភាពដ៏ទំនើប និង បង្វែរសំណួរមុនៗ សម្រាប់កិច្ចពិភាក្សាក្នុងថ្នាក់ បន្ទាប់ពីការអង្កេត( និមិត្តសញ្ញាទាក់ទងនឹងវីដេអូ )

**ព័ត៌មានរបស់គ្រូបង្រៀន៖** មានសំណួរចំនួន៣ ដែលបានដាក់លើក្ដារខៀន និង ស្នើសុំសិស្ស ឲ្យគិតពិចារណា លើសំណួរទាំងអស់នោះ មុនពេលថ្នាក់ចប់។

## សកម្មភាពទី១

- ផ្ដល់ជីវប្រវត្តិសង្ខេប អំពី លោកស្រី ជូលីអាណា ដកបាតហ្វ៊ី។ អានសេចក្ដីដកស្រង់ ពី សេចក្ដីក្លាហានគ្មានព្រំដែន នៅក្នុងថ្នាក់ ដោយមានសិស្ស ធ្វើកំណត់ហេតុ ស្ដីពី ឯកសារចែកដោយដៃ និង មានសំណួរ សម្រាប់ការពិភាក្សា។
- បែងចែកសំណួរ សម្រាប់ការពិភាក្សា ( និមិត្តសញ្ញា ដែលទាក់ទងនឹងឯកសារ )
- បន្ទាប់ពីការអានត្រូវបានបញ្ចប់ សូមផ្ដល់ពេលវេលាតិចតួច សម្រាប់ការពិភាក្សា ដែលឆ្លើយតប ទៅនឹង សំណួរទាំងអស់នេះ។

## សកម្មភាពទី២

- បំផុសមធ្យោបាយ ដែលនៅក្នុងនោះសិស្ស អាចចាត់វិធានការ និង អាចក្លាយជាអ្នកការពារ។

# ក្លាយជាអ្នកការពារ

សិស្ស ត្រូវតែជ្រើសរើស នូវគម្រោងខាងក្រោមមួយ ដើម្បីគាំទ្រចំពោះការបញ្ចប់នូវទាសភាព

- សិក្សាស្រាវជ្រាវ កិច្ចប្រឹងប្រែង ដែលបានធ្វើឡើង ដោយ អង្គការក្រៅរដ្ឋាភិបាល (NGO) ជាក់លាក់មួយ ក្នុងបំណងបញ្ឈប់ ការរត់ពន្ធមនុស្ស និង សរសេរអត្ថបទមួយ ស្ដីពី កិច្ចប្រឹងប្រែង របស់ពួកគេឲ្យកាសែត របស់សាលារៀន។
- ផលិតវីដេអូ ដោយបង្ហាញ អំពី អយុត្តិធម៌នៃការរត់ពន្ធមនុស្សដែលអាចដាក់បញ្ចាំងចែកជូនដល់ស្ថាប័នសិស្ស។
- ទំនាក់ទំនងជាមួយ អង្គការក្រៅរដ្ឋាភិបាលមួយដែលធ្វើការប្រឆាំងនឹងការរត់ពន្ធមនុស្ស និង រៀបចំសម្រាប់វាគ្មិនម្នាក់ ដែលបានចូលមកកាន់ថ្នាក់របស់អ្នក, សាលារៀន ឬ ព្រឹត្តិការណ៍សហគមន៍ ក្នុងគោលបំណង លើកកម្ពស់ការយល់ដឹង។

**ព័ត៌មានរបស់គ្រូបង្រៀន៖** មេរៀននេះអាចងាយស្រួល ពង្រីកបន្ថែម ក្នុងរយៈពេលច្រើនជាង ៤០នាទី។ ប្រសិនបើ គេត្រូវការពេលវេលាកិច្ចពិភាក្សាបន្ថែម គេនឹងផ្ដល់អនុសាសន៍ ពង្រីកបន្ថែមទៀត។ ធនធានបន្ថែម នឹងជួយឲ្យគ្រូបង្រៀន និង សិស្ស រៀនបានច្រើនថែមទៀត អំពីបញ្ហាដ៏ទូលំទូលាយ នៃការរត់ពន្ធមនុស្ស និង ទាសភាព នៅក្នុងពិភពលោកបច្ចុប្បន្ននេះ, សហការណ៍គ្នាធ្វើការដោយឯករាជ្យ។

# ព័ត៌មានបន្ថែម

**Freetheslaves.net**

www.freetheslaves.net

សទ្ទានុក្រមពាក្យច្រើន ដែលទាក់ទងនឹងការរត់ពន្ធមនុស្ស។ ទីកន្លែងមានព័ត៌មានចម្រុះជាច្រើន ស្តីពី ការរត់ពន្ធមនុស្ស និង ការស្វែងរកដំណោះស្រាយ ក្នុងការបញ្ចប់ ទាសភាព នៅក្នុងអំឡុងពេលរស់នៅរបស់យើង។

**អង្គការ អាហ្វេស៊ីប កម្ពុជា (AFESIP)**

www.afesip.org

**ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី (The Cambodian National Council for Women)**

www.cncw.gov.kh

**កូនស្រីខ្មែរក្នុងទាសភាព (Captive Daughters)**

www.captivedaughters.org

**កូនស្រីខ្មែរ (Daughters of Cambodia)**

www.daughtersofcambodia.org

**សហពលកម្មប្រឆាំងនឹងការជួញដូរស្ត្រី (Coalition Against Trafficking in Women)**

www.catwinternational.org

**អង្គការ អេកផាត អន្តរជាតិ (ECPAT International)**

www.ecpat.net

**អង្គការ ហាហ្គា អន្តរជាតិ (Hagar International)**

www.hagarinternational.org

**បេសកកម្មយុត្តិធម៌អន្តរជាតិ (International Justice Mission, IJM)**

www.ijm.org

**អង្គការ បណ្តាញ ណូមី (NomiNetwork)**

www.nominetwork.org

**ឯកសារផ្តល់យោបល់អំពី "ស្ត្រីផ្តល់ភាពកក់ក្តៅ" (Recommendations on the Issue of "Comfort Women")**

Japan Federation of Bar Association, 1995

**គណៈកម្មការអន្តរជាតិអ្នកច្បាប់–ស្ត្រីផ្តល់ភាពកក់ក្តៅ៖ បញ្ហាមិនទាន់ចប់ (International Commission of Jurists – Comfort Women: An Unfinished Ordeal)**

I.C.J (Geneva, 1994)

**លាលីយ៉ា ជានិច្ចនិរន្តរ៍ (Lilya 4-Ever)**

A Swedish/Danish film, 1994

**ភាពយន្តភ្លើងក្រហម (REDLIGHT Movie)**

www.redlightthemovie.com

**ដំណើររបស់ ស្វេតឡាណា (Svetlana's Journey)**

www.svetlanasjourney.com

**សម្ព័ន្ធមិត្តពិភពលោកប្រឆាំងនឹងការជួញដូរស្ត្រី (Global Alliance Against Traffick in Women)**

www.gaatw.net

**មូលនិធិ ម៉ម សុម៉ាលី (Somaly Mam Foundation)**

www.somaly.org

**របាយការណ៍នៃការជួញដូរមនុស្សក្នុងឆ្នាំ២០១០ (Trafficking in Persons Report 2010)**

www.state.gov

ប្រភពព័ត៌មានល្អបច្ចុប្បន្ននេះ ស្តីពីការរត់ពន្ធមនុស្ស ដោយរួមទាំងផែនទីទំនាក់ទំនង របាយការណ៍ពិពណ៌នាស្តីពីប្រទេសដោយពិភាក្សាលើកម្រិត នៃការពាក់ព័ន្ធរបស់ពួកគេ កិច្ចប្រឹងប្រែងរបស់ពួកគេក្នុងការលុបបំបាត់បញ្ហានេះ និង អនុសាសន៍ក្នុងការបង្កើនប្រសិទ្ធភាពនៃកិច្ចប្រឹងប្រែង ជ័យជំនះរបស់ជនរងគ្រោះ និង ធនធានជាច្រើនដទៃទៀត។

**មជ្ឈមណ្ឌលសកម្មភាពគម្រោង ផូឡារីស (Polaris Project Action Center)**

www.actioncenter.polarisproject.org

ប្រភពព័ត៌មានជាច្រើនទៀត បានមកពីអង្គការក្រៅរដ្ឋាភិបាល ។

**កម្មវិធី ហ្វ្រន់ឡាញ របស់បណ្តាញទូរទស្សន៍ ភីប៊ីអេស (PBS Frontline)**

www.pbs.org

ធនធានដ៏រមុខជាមួយការភ្ជាប់ទំនាក់ទំនង ដ៏មានតម្លៃ ទៅនឹង

អង្គការក្រៅរដ្ឋាភិបាល (NGO) និង មាត្រាជាច្រើនទៀត មានឯកសារ របស់ កម្មវិធី ហ្វ្រន់ឡាញ (Frontline) ដោនឡូត ដោយសេរី ស្តីពី ទាសភាពផ្លូវភេទ។ ដោយរួមបញ្ចូល ការបរិយាយ អំពីកម្មវិធី និង ពាក្យអត្ថាធិប្បាយ។មានការទំនាក់ទំនងតភ្ជាប់ទៅនឹងឯកសារពីរ ផ្សេងទៀត ស្តីពី ទាសភាពដ៏ទំនើប។

ការភ្ជាប់ទំនាក់ទំនងនេះ នាំអ្នកចូលទៅកាន់ ភីប៊ីអេស (PBS) - ផែនទីទំនាក់ទំនងរបស់ កម្មវិធី ហ្វ្រន់ឡាញ (Frontline) ដែលអមជាមួយប្រវត្តិរឿងស្តីពីទាសករផ្លូវភេទ ។

## ទំនៀមទំលាប់ត្រូកូស៊ី នៅប្រទេសហ្គាណា

## (The Trokosi in Ghana)

www.sos-sexisme.org

មាត្រាស្តីពី ទំនៀមទំលាប់ត្រូកូស៊ី នៅប្រទេសហ្គាណា

## អង្គការតម្រូវការអន្តរជាតិ ហ្គាណា ដែលកំពុងផ្លាស់ប្តូរជីវិតស្ត្រី (International Needs Transforming the Lives of Women in Ghana)

www.internationalneeds.org.au

ព័ត៌មានទូលំទូលាយស្តីពី ទំនៀមទំលាប់ត្រូកូស៊ី នៅប្រទេសហ្គាណា និង កិច្ចការរបស់អង្គការក្រៅរដ្ឋាភិបាល កំពុងដំណើរការបញ្ចប់ការបដិបត្តិនេះ។

## រឿងរបស់ អ្នករស់រានមានជីវិតម្នាក់

## (A Survivor's Story)

www.innetwork.org

ប្រវត្តិរបស់អ្នកនៅរស់៖ សម្លេងខ្លីៗ (កិច្ចពិភាក្សាអំពី ទំនៀមទំលាប់ត្រូកូស៊ី ក្នុងការសាកល្បង។ នៅខាងចុងនេះ មានការទាក់ទងនឹងការស្តាប់ប្រវត្តិផ្ទាល់ របស់ក្មេងស្រី ដែលជាបទពិសោធន៍របស់នាង)

## ទាសភាព ហ្គាណា សម្រាប់ក្រុមព្រះអាទិទេព

## (Ghana's Slaves to the Gods)

www.wcl.american.edu

អត្ថបទល្អៗ ស្តីពីការបដិបត្តិ នៅប្រទេសហ្គាណា និង លោកស្រី ជូលីអាណា ដកបាតហ្ស៊ី

## ទាសភាព ក្នុងសតវត្សរ៍ទី២១ (21st Century Slaves)

www.ngm.nationalgeographic.com

ភូមិសាស្ត្រជាតិ៖ ព័ត៌មាន និង ទំនាក់ទំនងច្រើននឹងធនធាន



លោកគ្រូ អ្នកគ្រូ កំពុងជួយត្រួតពិនិត្យអក្ខរាវិរុទ្ធ នៅភ្នំពេញ, ថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០១១

# លោក វ៉ាក្លាវ ហាវែល (Vaclav Havel)

លោក វ៉ាក្លាវ ហាវែល (Vaclav Havel) គឺជាសម្លេងមួយក្នុងចំណោមសម្លេងដែលមានសារសំខាន់បំផុតសម្រាប់លទ្ធិប្រជាធិបតេយ្យ។ ជាមួយនឹងការតម្រង់ទិសផ្ទាល់ខ្លួនប្រកបដោយ សីលធម៌, ដោយគ្មានភាពវៀចវេរ, រួមជាមួយនឹងវោហារកោសល្យលេចធ្លោជាងគេ ក្នុងឆាកនយោបាយ, លោក ហាវែល បាននិយាយដោយភាពស្មោះត្រង់ ក្នុងនាមជាអ្នកប្រឆាំងម្នាក់ មកពីវិមានប្រធានាធិបតីក្នុងទីក្រុង ប្រាហ្គ (Prague)។ ក្នុងនាមជាអ្នកនិពន្ធផលិតកម្មសម្តែងនាដកម្មល្បីជាងគេ ក្នុងប្រទេសឆេកូស្លូវ៉ាគី និង ជាជនរងគ្រោះអស់រយៈពេលដ៏យូរ ក្រោមការគាបសង្កត់របស់រដ្ឋ របបកុម្មុយនីស, គាត់មានភាពល្បីល្បាញ និង ទទួលបានការកោតសរសើរតាមរយៈ និពន្ធផលិតកម្មសម្តែងនាដកម្ម ដែលគួរឲ្យអស់សំណើចហួសចិត្តជាច្រើន,រួមមាន៖ *ពិធីជប់លៀងក្នុងសួនច្បារ* (The Garden Party), *ការលំបាកកាន់តែធ្ងន់ធ្ងរ ក្នុងការប្រមូលអារម្មណ៍* (The Increased Difficulty of Concentration), *អនុស្សារណៈយោគយល់* (The Memorandum), *ឡាហ្គូ ដេសូឡាតូ* (Largo Desolota), និង *ការប៉ុនប៉ង* (Temptation)។ លោក ហាវែល កើតក្នុងឆ្នាំ១៩៣៦ ជាស្ថាបនិកអង្គការសិទ្ធិមនុស្ស និង ប្រជាធិបតេយ្យ ឈ្មោះ ធម្មនុញ្ញចិតសិបប្រាំពីរ (Charter 77) ដែលបានប្រឈមមុខតទល់ជាមួយនឹងការគ្រប់គ្រង របស់ប្រទេសសូវៀត។ គាត់បាននិពន្ធអត្ថបទជាច្រើន ដែលបានទាក់ទាញការចាប់អារម្មណ៍យ៉ាងខ្លាំង ស្តីពីការគាបសង្កត់ និង ការប្រឆាំង, ហើយស្នាដៃរបស់គាត់មួយ នៅក្នុងឆ្នាំ ១៩៧៨ ដែលមានចំណងជើងថា *អំណាចរបស់អ្នកគ្មានអំណាច* (The Power of the Powerless) គឺជាអត្ថបទនយោបាយដ៏ល្អបំផុត ដែលមិនធ្លាប់មានអ្នកសរសេរ។ ក្នុងឆ្នាំ១៩៧៩ សម្រាប់ជាការសងសឹកទៅលើ សកម្មភាពសិទ្ធិមនុស្ស របស់គាត់ លោក ហាវែល ត្រូវបានកាត់ទោសឲ្យធ្វើការធ្ងន់ធ្ងររយៈពេល៤ឆ្នាំកន្លះ, ហើយក្នុងអំឡុងពេលនោះ គាត់បាននិពន្ធរឿង *លិខិតផ្ញើទៅកាន់អូលហ្គា* (Letters to Olga)។ ក្នុងនាមជានាយកអ្នក នាំពាក្យរបស់អង្គការវេទិកាស៊ីវិល (Civic Forum), ដែលគាត់ជាសហស្ថាបនិកក្នុងឆ្នាំ១៩៨៩,ហើយ តាមរយៈភាពជាអ្នកដឹកនាំចំណេះប្រាជ្ញាផ្នែក នយោបាយ និង ភាពអូសទាញផ្នែកសីលធម៌ របស់គាត់, លោក ហាវែល



Vaclav Havel, ©2000 Eddie Adams

"អ្នកមិនចង់មានការជាប់ពាក់ព័ន្ធជាមួយនឹងរឿងអាក្រក់ៗ ដែលនៅជុំវិញខ្លួនរបស់អ្នក ហើយនៅថ្ងៃមួយ, នៅពេលដែល អ្នកភ្ញាក់ពីដេក អ្នកស្រាប់តែយល់ថា អ្នកគឺជាអ្នកប្រឆាំងម្នាក់, យល់ថា អ្នកគឺជាសកម្មជនការពារសិទ្ធិមនុស្សមួយរូប"។

បានជួយទម្លាក់របបកុម្មុយនីស ឲ្យធ្លាក់ដល់បាត និង បានចរចារឲ្យមានការផ្លាស់ប្តូរដោយសន្តិវិធីទៅជារបបប្រជាធិបតេយ្យ។ រដ្ឋថ្មីមួយ បានកើតចេញមកពីកម្អែលគ្រប់គ្រងរបស់ប្រទេសសូវៀត ដោយផ្អែកទៅលើ សេរីភាពនៃការបញ្ចេញមតិ, ការចូលរួមក្នុងនយោបាយ, សង្គមស៊ីវិល និង ឆន្ទៈក្នុងការទទួលបាននីតិរដ្ឋ។ ក្នុងឆ្នាំ១៩៨៩ លោក ហាវែល បានជាប់ឆ្នោតជាប្រធានាធិបតីនៃរបបមិនមែនកុម្មុយនីសទីមួយ របស់ប្រទេស ឆេកូស្លូវ៉ាគី ក្នុងរយៈពេល៤០ឆ្នាំ។ ក្នុងឆ្នាំ ២០០២ គាត់ជាបុគ្គលទីបី ដែលបាន ទទួលរង្វាន់ ភាពជាពលរដ្ឋរបស់ ហាណូ អ. អែលឡិនបូជិន (Hanno R. Ellenbogen Citizenship Award) ដែលបានផ្តល់ដោយសង្គមសហប្រតិបត្តិការអន្តរជាតិ ទីក្រុងប្រាហ្គ (Prague Society for International Cooperation)។ ក្នុងឆ្នាំ២០០៣ គាត់បានទទួលរង្វាន់សន្តិភាពគន្ធីអន្តរជាតិ (International Gandhi Peace Prize) ដែលបានយកតាមឈ្មោះ ម៉ូហាន់ដាស ការាមចាន គន្ធី (Mohandas Karamchand Gandhi) របស់រដ្ឋាភិបាលឥណ្ឌា សម្រាប់ការរួមចំណែកដ៏ឆ្នើមរបស់គាត់ ក្នុងការទទួលបានសន្តិភាពពិភពលោក និង លើកកម្ពស់សិទ្ធិមនុស្សនៅក្នុងស្ថានភាពដ៏លំបាកបំផុត តាមមធ្យោបាយ

របស់ លោក គន្ទី។ ក្នុងឆ្នាំ២០០៣ លោក ហាវែល ជាអ្នកទទួលបាន រង្វាន់អគ្គរដ្ឋទូតសតិសម្បជញ្ញៈរបស់ អង្គការលើកលែងទោសអន្តរជាតិ (Amnesty International's Ambassador of Conscience Award) លើកដំបូងគេ សម្រាប់ការងាររបស់គាត់ ក្នុងការលើកកម្ពស់សិទ្ធិមនុស្ស។ ក្នុងឆ្នាំ២០០៣ នេះដែរ គាត់បានទទួល មេដាយសេរីភាពរបស់ ប្រធានាធិបតីអាមេរិក (U.S. Presidential Medal of Freedom) ហើយ ក្នុងឆ្នាំ២០០៨ អង្គការទស្សនៈខុសគ្នា (A Different View) មាន មូលដ្ឋាននៅអឺរ៉ុប បានហៅ លោក ហាវែល ថា ជាជើងឯកម្នាក់ ក្នុង ចំណោម ជើងឯកប្រជាធិបតេយ្យ របស់ពិភពលោក រួមជាមួយនឹង ណែលសិន ម៉ែនដេលា (Nelson Mandela),ឡេច វ៉ាឡេសា (Lech Walesa) និង កូរ៉ាហ្សូន អាឃ្វីណូ (Corazon Aquino)។

## ទាក់ទងនឹងភាពជាអ្នកដឹកនាំ និង សេចក្តីក្លាហាន

វិបត្តិរបស់អាជ្ញាធរជាមូលហេតុមួយ ក្នុងចំណោមមូលហេតុជាច្រើន ដែលបណ្តាលឲ្យកើតមានមហាវិនាសកម្មទាំងឡាយ ដែលយើងបានឃើញក្នុងពិភពលោកនាពេលបច្ចុប្បន្ននេះ។ ពិភពលោកក្រោយរបបកុម្មុយនីស បានផ្តល់នូវឱកាសមួយសម្រាប់អ្នកដឹកនាំ ដែលមានសីលធម៌ថ្មីៗ, ពីព្រោះនៅអំឡុងពេលអន្តរកាល ប្រទេសទាំងនោះមិនមានអ្នកនយោបាយអាជីពទេ។ ករណីនេះ ផ្តល់ឱកាសដល់ អ្នកបញ្ញវ័ន្តបានចូលនៅក្នុងឆាកនយោបាយ, ហើយតាមរយៈការចូលក្នុងឆាកនយោបាយនេះ ពួកគេបានបញ្ចូលស្មារតីថ្មីចូលទៅក្នុងដំណើរការនយោបាយ។ ប៉ុន្តែ នៅពេលបន្តបន្ទាប់ក្រោយមក បញ្ញវ័ន្តទាំងនេះបានទទួលរងការគាបសង្កត់, ដោយប្រព័ន្ធចាស់បានបង្ក្រាបពួកគេឲ្យរាបអស់, ហើយឱកាសភាគច្រើនបានបាត់បង់។ មានអ្នកដឹកនាំមួយចំនួន ដែលអ្នកអាចគោរពបាន, ហើយខ្ញុំពិតជាបានគោរព, រួមមានដាឡៃ ឡាម៉ា។ ខ្ញុំសរសើរថា ជាញឹកញាប់ ទោះបីជាពួកគាត់មិនមានសង្ឃឹម ឬ ពន្លឺ នៃជោគជ័យសូម្បីតែបន្តិចបន្តួចក៏ដោយ, ក៏ពួកគេបានត្រៀមខ្លួនហើយជានិច្ចក្នុងការបូជាជីវិត, និង បូជាសេរីភាពរបស់ពួកគេដែរ។ ពួកគេបានត្រៀមខ្លួនរួចជាស្រេច ក្នុងការទទួលយកការទទួលខុសត្រូវសម្រាប់ពិភពលោក, ឬ យ៉ាងហោចណាស់សម្រាប់កន្លែង ដែលពួកគេកំពុងរស់នៅ។ ខ្ញុំតែងតែគោរពអ្នកទាំងអស់នោះ ហើយតែងតែកោតសរសើរ អំពីអ្វីដែលពួកគេធ្វើ។ សេចក្តីក្លាហាននៅក្នុងឆាកសាធារណៈមានន័យថា បុគ្គលរូបនោះត្រូវប្រឆាំងនឹងទស្សនៈរបស់ មនុស្សភាគច្រើន (ហើយទន្ទឹមនឹងនោះ កំពុងប្រឈមនឹងការបាត់បង់តួនាទីរបស់ខ្លួនទៀតផង) ដើម្បីបុព្វហេតុការពិត។ ខ្ញុំក៏តែងតែមានការកោតសរសើរយ៉ាងខ្លាំង ចំពោះបុគ្គលជាប្រវត្តិសាស្ត្រ ដែលអាចធ្វើរឿងទាំងអស់នេះបាន។

ការក្លាយទៅជាអ្នកប្រឆាំង មិនមែនជាអ្វីដែលកើតឡើងភ្លាមៗនោះទេ។ អ្នកមិនមែនគ្រាន់តែសម្រេចចិត្តថា ចង់ក្លាយជាអ្នកប្រឆាំង ហើយបានក្លាយទៅជា អ្នកប្រឆាំងនោះទេ។ វាជាដំណើរការដ៏វែង ដែលរួមមាន ដំណាក់កាល និង សកម្មភាពជាច្រើន។ ជារឿយៗ នៅក្នុងអំឡុងពេលនៃដំណើរការនេះ, អ្នកមិនបានធ្វើការឆ្លុះបញ្ចាំងឲ្យបានពិតប្រាកដ ទៅលើអ្វីដែលកំពុងតែកើតឡើងនោះទេ។ អ្នកគ្រាន់តែដឹងថា អ្នកចង់ចៀសវាងបំណុលមួយចំនួន ដែលអាចនឹងធ្វើឲ្យសៅហ្មងដល់ជីវិតរបស់អ្នកតែប៉ុណ្ណោះ។ អ្នកមិនចង់មានការជាប់ពាក់ព័ន្ធជាមួយ នឹងរឿងអាក្រក់ៗ ដែលនៅជុំវិញខ្លួនរបស់អ្នក, ហើយនៅថ្ងៃមួយ នៅពេលដែលអ្នកភ្ញាក់ពីដេក អ្នកស្រាប់តែយល់ថា អ្នកគឺជាអ្នកប្រឆាំងម្នាក់, យល់ថា អ្នកគឺជា សកម្មជនការពារសិទ្ធិមនុស្សមួយរូប។សម្រាប់រូបខ្ញុំរឿងរ៉ាវរបស់ខ្ញុំមានលក្ខណៈស្រដៀងនេះដែរ។ វាគ្រាន់តែថា វាកើតឡើងនៅវេលាក្រោយមក, នៅពេលដែលខ្ញុំជាប់ក្នុងពន្ធនាគារ, ដែលខ្ញុំបានចាប់ផ្តើមឆ្លុះបញ្ចាំងទៅលើដំណើរការនោះ និង ទៅលើមូលហេតុអ្វីដែលខ្ញុំបានធ្វើ។ ប្រាកដជាមាន មនុស្សមួយចំនួន ដែលហៅរឿងនេះថា ជា "អព្ភូតហេតុ", ជាប្រភពនៃថាមពល ដែលជួយអ្នកជម្នះលើការលះបង់ទាំងឡាយ។ ឥឡូវ មានមនុស្សមួយចំនួន ដែលប្រហែលជាមិនយល់ស្របនឹងគំនិត អំពីថាមពល អព្ភូតហេតុនេះ, ប៉ុន្តែ ខ្ញុំមានអារម្មណ៍បែបនោះ។ នៅពេលដែលខ្ញុំនៅក្នុងពន្ធនាគារ ជួនកាលខ្ញុំបានគិតថា ហេតុអ្វីបានជាបុគ្គលមួយរូបសុខចិត្តនៅក្នុងភាពគួរសម, សុខចិត្តនៅជាអ្នកប្រកាន់ខ្ជាប់នូវសុចរិតភាព, សូម្បីតែ ក្នុងស្ថានភាពកំពុង តែនៅម្នាក់ឯង, ក្នុងស្ថានភាពដែលមិនមាននរណាម្នាក់ ដឹងអំពីសកម្មភាព និង គំនិតរបស់អ្នក, ក្រៅតែពីរូបអ្នកខ្លួនឯង។ សូម្បីតែ នៅក្នុងស្ថានភាពទាំងនេះ, បុគ្គលមួយរូបអាចមានអារម្មណ៍មិនល្អ, អាចមានសតិសម្បជញ្ញៈមិនល្អ, អាចមានវិប្បដិសារី។ តើហេតុអ្វីបានជាយ៉ាងដូច្នេះ? តើហេតុអ្វីបានជាវាអាចកើតឡើងដូច្នេះបាន? ហើយចម្លើយរបស់ខ្ញុំចំពោះបញ្ហានេះ គឺថា ប្រាកដជាមានភ្នែកមួយកំពុងសម្លឹងមក, ដែលមិនមែនមានតែមនុស្សដែលនៅ ជុំវិញអ្នកនោះទេ ដែលបានធ្វើឲ្យមានការផ្លាស់ប្តូរ។ ខ្ញុំមិនមានភស្តុតាងសម្រាប់បញ្ជាក់អំពីវត្តមាន នៃភ្នែកមួយនេះទេ, ប៉ុន្តែ ខ្ញុំផ្អែកទៅលើតថភាពគំរូគំនិតអរូបី សម្រាប់បញ្ជាក់អំពី វត្តមាន នៃភ្នែកមួយនោះ។

## ទាក់ទងនឹងភាពភ័យខ្លាច

ខ្ញុំធ្លាប់បានជួបប្រទះ និង នៅតែបន្តជួបប្រទះគ្រប់រូបភាព នៃការភ័យខ្លាច។ ការភ័យខ្លាចរបស់ខ្ញុំមួយចំនួន មានសភាពតានតឹងជាងភាពភ័យខ្លាច របស់អ្នកដទៃ។ ក៏ប៉ុន្តែ ការប្រឹងប្រែងដើម្បីពុះពារជម្នះការភ័យខ្លាចទាំងនោះ ក៏ប្រហែលជាមានសភាពតានតឹងជាងដែរ។ ការភ័យខ្លាចដ៏ចម្បងនោះ គឺការស្រមៃថា ខ្ញុំអាចនឹងឲ្យអ្នកដទៃបរាជ័យ, ថា ខ្ញុំនឹងអាចធ្វើឲ្យអ្នកដទៃអស់សង្ឃឹម, ហើយបន្ទាប់មក អាចមានអារម្មណ៍ថា មានកំហុសក្នុងការធ្វើដូច្នោះ។ ឧទាហរណ៍, នៅពេលគេ

ដេញខ្ញុំឲ្យទៅនៅ ប្រទេសមួយ ដែលមិនមានគេស្គាល់នៅអាមេរិកឡាទីន នោះ, គេបានសុំខ្ញុំឲ្យនិយាយថ្លែងទៅកាន់រដ្ឋសភា។ ខ្ញុំបាននិយាយ, ខ្ញុំបានប្រើពាក្យល្អៗជាច្រើន និង ធ្វើឲ្យមានការចាប់អារម្មណ៍ខ្លាំង។ ខ្ញុំបានថ្លែងដូចការរំពឹងទុក។ ប៉ុន្តែ នៅពេលបញ្ចប់ ខ្ញុំតែងតែសួរទៅនរណាម្នាក់ថា “តើការថ្លែងរបស់ខ្ញុំយ៉ាងម៉េចដែរ? តើវាល្អទេ? តើខ្ញុំធ្វើបានដូចការរំពឹងទុកឬទេ?” ខ្ញុំតែងមានអារម្មណ៍មិនប្រាកដយ៉ាងដូច្នោះ។ ពីព្រោះ ខ្ញុំជាមនុស្សដែលតែងតែទទួល ការឈឺចាប់ ដោយសារមានការភ័យខ្លាច កើតចេញពី ការភ័យខ្លាចពេលនិយាយនៅលើឆាក និង ការភ័យខ្លាចផ្សេងៗទៀត។ ការភ័យខ្លាច តែងតែនៅជាមួយខ្ញុំ, តែទោះជាយ៉ាងនេះក្តី ខ្ញុំនៅតែធ្វើសកម្មភាព។

## ទាក់ទងនឹងសំណើច

នៅពេលដែល បុរស ឬ ស្ត្រី ណាម្នាក់ បានត្រៀមខ្លួនរួចរាល់ ក្នុងការលះបង់អ្វីៗសព្វបែបយ៉ាងសម្រាប់បញ្ហាធ្ងន់ធ្ងរណាមួយនោះ, អ្វីដែលកើតឡើងនៅចុងបញ្ចប់នោះ គឺថា បុគ្គលនោះ បានគិតខ្លួនជា មនុស្សម៉ឹងម៉ាត់ពេក។ ទឹកមុខរបស់បុគ្គលទាំងនោះ មានសភាពរឹងមាំខ្លាំងណាស់, ស្ទើរតែមិនដូចមនុស្ស, ហើយមនុស្សនោះ បានក្លាយទៅជារូបចម្លាក់។ យើងដឹងហើយថា, រូបចម្លាក់ធ្វើឡើងពីថ្ម ឬ ពីជ័រផ្លាស្ទិក, ហើយវាមានការពិបាកធ្វើចលនាខ្លាំងណាស់។ ចលនារបស់រូបចម្លាក់មានភាពផ្គងខ្លាំងណាស់។ ប្រសិនបើនរណាម្នាក់ចង់រក្សាមនុស្សធម៌, រក្សាភាពជាមនុស្ស, វាមានសារៈសំខាន់ដែលមនុស្សនោះមានគម្លាតខ្លះពីរឿងរ៉ាវ។ ដើម្បីរក្សាគម្លាតនេះ អ្នកត្រូវមានសមត្ថភាពយល់ដឹងថា នៅក្នុងទង្វើរបស់ជនណាមួយនោះ តែងតែមានចំណែកនៃភាពអស់សំណើច ឬ ការសើចចំអក។

## ទាក់ទងនឹងសេចក្តីសង្ឃឹម

ជារឿយៗ មានមនុស្សជាច្រើនដែលមានការភ័ន្តច្រឡំរវាង សេចក្តីសង្ឃឹម និង បុរេនិមិត្ត។ បុរេនិមិត្ត ជាវិទ្យាសាស្ត្រ នៃការសិក្សាពីអ្វីៗសព្វបែបយ៉ាង ដែលកើតឡើងជុំវិញខ្លួនយើង ក្នុងលោកយើងនោះ។ តាមរយៈការសិក្សានេះ អ្នកនឹងអាចបង្កើតជាបុរេនិមិត្តវិជ្ជមាន (ពីព្រោះអ្នកជាសុទិដ្ឋិបុគ្គល), ឬ អាចបង្កើតជាបុរេនិមិត្តអវិជ្ជមាន (ដែលអាចនឹងមានផលប៉ះពាល់បែបទុទិដ្ឋិនិយម ទៅលើមនុស្សដែលនៅជុំវិញអ្នក)។ ប៉ុន្តែ វាសំខាន់ណាស់ដែលយើងត្រូវធ្វើការបែងចែកឲ្យដាច់ពីគ្នា។ សេចក្តីសង្ឃឹមមិនមែនជា បុរេនិមិត្តទេ។ សេចក្តីសង្ឃឹម ជាអ្វីដែលខ្ញុំមើលឃើញថា ជាលក្ខណៈនៃស្មារតី។ ប្រសិនបើ ជីវិតគ្មានវិញ្ញាណទេ, វាក៏គ្មានសេចក្តីសង្ឃឹមដែរ, ពីព្រោះថាវិញ្ញាណរបស់ជីវិត, អត្ថន័យរបស់ជីវិត, មានការពាក់ព័ន្ធយ៉ាងជិតស្និទ្ធជាមួយ សេចក្តីសង្ឃឹម។

## ទាក់ទងនឹង សេរីភាព និង ការទទួលខុសត្រូវ

សេរីភាពដែលគ្មានការទទួលខុសត្រូវ គឺប្រហែលជាអ្វីដែលមាន នៅក្នុងសុបិនរបស់មនុស្សស្ទើរតែគ្រប់គ្នា ក្នុងការចង់ធ្វើអ្វីសព្វបែបយ៉ាងដែលខ្លួនប្រាថ្នាចង់ធ្វើ, ហើយមិនចង់ទទួលខុសត្រូវ ចំពោះអ្វីដែលខ្លួនបានប្រព្រឹត្ត។ ប៉ុន្តែ បែបនេះពិតប្រាកដហើយជាជីវិត ល្អឥតខ្ចោះដោយស្រមៃមួយ (utopia)។ ប៉ុន្តែ ជីវិតដែលគ្មានការទទួលខុសត្រូវ មិនមែនជារឿងត្រឹមត្រូវឡើយ។ ដូច្នេះហើយ បានជាខ្ញុំគិតថា តម្លៃរបស់ សេរីភាពមានការជាប់ពាក់ព័ន្ធជាមួយនឹងការទទួលខុសត្រូវ។ ហើយប្រសិនបើសេរីភាពមិនមានការទទួលខុសត្រូវនៅជាប់ជាមួយនោះទេ, វានឹងបាត់ខ្លឹមសារ, វានឹងបាត់អត្ថន័យ, ហើយ វាក៏នឹងបាត់បង់ទម្ងន់ដែរ។



ព្រះសង្ឃ, លោកគ្រូ អ្នកគ្រូ កំពុងជួយត្រួតពិនិត្យអក្ខរាវិរុទ្ធ
នៅវត្តដំណាក់ ខេត្តសៀមរាប, ខែសីហា ឆ្នាំ២០១១

# តើសេរីភាពក្នុងការបញ្ចេញមតិមានន័យដូចម្ដេច?

លោក វ៉ាក្លាវ ហាវែល

បញ្ហាសិទ្ធិមនុស្ស៖ សេរីភាព ក្នុងការបញ្ចេញមតិ

## សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស

- មាត្រា១៩: សេរីភាព ក្នុងការបញ្ចេញមតិ និង ព័ត៌មាន

## តម្រូវការពេលវេលា៖ ៩០នាទី

## សំណួរណែនាំ

- តើ សេរីភាព ក្នុងការបញ្ចេញមតិ មានន័យដូចម្ដេច?
- តើ មូលហេតុអ្វី បានជា អ្នកបង្កើតសេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស ដាក់បញ្ចូលទាំង សេរីភាពក្នុងការបញ្ចេញមតិ នៅក្នុងឯកសាររបស់ពួកគេ?
- តើមូលហេតុអ្វី បានជាយើងត្រូវការ ទទួលបាននូវ ព័ត៌មាន ក្នុងការរស់នៅក្នុង សង្គមមានសេរីភាពពិតប្រាកដមួយ។

## គោលបំណង

បន្ទាប់ពីមេរៀននេះ សិស្ស អាចនឹង៖

- កំណត់ និង យល់ដឹង អំពី ពាក្យ "សេរីភាពក្នុងការបញ្ចេញមតិ"។
- យល់អំពី ខ្លឹមសារ នៃការថែរក្សាសេរីភាពក្នុងការបញ្ចេញមតិថាជាសិទ្ធិមនុស្ស ជាសកល និងជាមូលដ្ឋានគ្រឹះ នៃសង្គមប្រជាធិបតេយ្យ។
- ពិនិត្យ និង វិភាគ តួនាទីរបស់អ្នកនិពន្ធកវី អ្នកនិពន្ធរឿងល្ខោន អ្នកកាសែត និង អ្នកសរសេរអត្ថបទ ក្នុងការថែរក្សាសេរីភាពក្នុងការបញ្ចេញមតិថា ជាសិទ្ធិមនុស្ស។
- យល់អំពី បញ្ហាប្រឈម ដែលប្រឈមដោយ ជនដែលបានអនុវត្តន៍ និង ការពារសិទ្ធិ នៃសេរីភាពក្នុងការបញ្ចេញមតិ ព្រោះថា គេបានប្រើប្រាស់ ការអនុម័តនូវការផ្លាស់ប្ដូរសង្គម។
- យល់ដឹងនូវមធ្យោបាយក្នុងការបង្ក្រាបជន (ដែលបានឡើងនិយាយក្នុងការអនុម័តការផ្លាស់ប្ដូរសង្គម) ឲ្យស្ងៀមស្ងាត់។

## ជំនាញរបស់សិស្ស

- តក្កវិទ្យា (critical thinking)
- ឯកសារស្រាវជ្រាវ
- ការវិភាគ (analysis)
- ការគស៊ូមតិ

## វាក្យស័ព្ទ

- អ្នកប្រឆាំង(dissident)
- ជាសកល
- យុត្តិធម៌សង្គម
- ការបង្ក្រាប (repression)
- អ្នកការពារ
- អំណាច
- អនុម័ត
- យល់ព្រម

## តម្រូវការខាងបច្ចេកទេស

- ការដាក់បញ្ចូលក្នុង អ៊ិនធឺណិត (internet)
- ស៊ីឌី (CD)

## សម្ភារៈសិក្សា

បញ្ជីអត្ថបទ នៃ សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស

www.udhr.org

- ជីវប្រវត្តិរបស់ លោក វ៉ាក្លាវ ហាវែល
  www.vaclavhavel.cz
- និយមន័យ នៃសេរីភាពក្នុងការបញ្ចេញមតិ
  www.hrea.org
- សេរីភាពក្នុងការបញ្ចេញមតិ
  www.democracyweb.org
- អំណាច នៃអ្នកមិនមានអំណាច ("The Power of the powerless") ដោយ លោក វ៉ាក្លាវ ហាវែល
  www.history.hanover.edu
- វ៉ាក្លាវ ហាវែល ("Vaclav Havel") ដោយ (Jan Culic)
  www.art.gla.ac.uk

## ព័ត៌មានរបស់គ្រូបង្រៀន

- គេត្រូវតែកត់ចំណាំថា សិស្ស ជាញឹកញាប់ ត្រូវការ ការបញ្ជាក់លើពាក្យពេចន៍មួយចំនួន ថ្វីបើវាស្រដៀងគ្នាក៏ដោយ ក៏មិនអាចច្បាស់លាស់ទាំងស្រុងនោះដែរ។ បរិបទ មានប្រយោជន៍មួយ សម្រាប់គំនិត នៃសេរីភាពក្នុងការបញ្ចេញមតិ ត្រូវបានកត់សម្គាល់ នៅក្នុង មាត្រា១៩ នៃ សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស។
- ជាដំបូងសិស្សត្រូវតែមានការយល់ដឹងមួយ ដែលថា វាអាចមានត្រឹមតែ លទ្ធិប្រជាធិបតេយ្យប៉ុណ្ណោះ ប្រសិនបើមានលំហូរ ដោយសេរី និង ចំហ នៃសារព័ត៌មាន និង ជនដែលស្វះស្វែងដើម្បីត្រួតត្រាអ្នកដទៃ ជាញឹកញាប់ព្យាយាម ក្នុងការទប់ស្កាត់ ការរិះគន់។

# សកម្មភាពរបស់សិស្ស

## ស្ថានភាពព្រាងទុក

- សូមណែនាំសិស្ស ឲ្យអាន មាត្រា១៩ នៃ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស។
- បន្ទាប់ពីការអាន សូមណែនាំសិស្ស ឲ្យរៀបចំមាត្រានេះឡើងវិញ ដាក់តាមពាក្យផ្ទាល់ របស់ពួកគេ។
- សូមស្នើ ឲ្យសិស្ស រាយការណ៍ផ្ទាល់មាត់ ទៅកាន់ថ្នាក់ តាមរយៈកិច្ចពិភាក្សា ដែលបានសម្របសម្រួល ដោយ គ្រូបង្រៀន។

## សកម្មភាពទី១

- បែងចែកឯកសារមាត្រាជាច្រើនច្បាប់ដល់សិស្ស ដែលបរិយាយ អំពី សេរីភាពក្នុងការបញ្ចេញមតិ និង មាត្រា ដែលបរិយាយ អំពី ប្រវត្តិរឿង នៃសេរីភាពក្នុងការបញ្ចេញមតិ។
- បែងចែកជាបីក្រុម ក្នុងថ្នាក់នីមួយៗ។
- ក្រុមនីមួយៗ ត្រូវតែចាត់ឲ្យធ្វើ សកម្មភាពមួយ ដូចខាងក្រោម
  - បកស្រាយ មាត្រា១៩
  - បកស្រាយ គំនិតទូទៅ នៃ សេរីភាពក្នុងការបញ្ចេញមតិ
  - បកស្រាយ សេរីភាពក្នុងការបញ្ចេញមតិ
- ណែនាំសិស្ស ឲ្យអាន, វិភាគ និង ពិភាក្សាលើមាត្រាទាំងអស់នេះ។
- បន្ទាប់ពីការវិភាគលើសម្ភារៈសិក្សាទាំងអស់នេះ  ក្រុម ត្រូវតែ យល់ព្រម លើការយល់ដឹង បរិបទ របស់ពួកគេ នៃ មាត្រានីមួយៗ ដោយធ្វើ កំណត់ហេតុ  ដែលតំណាងឲ្យទស្សនៈយល់ដឹង របស់ក្រុមនីមួយៗ។
- ឲ្យសិស្សរាយការណ៍ អំពី លទ្ធផលយល់ឃើញ របស់ពួកគេ។ ក្រុមដទៃទៀត គួរតែធ្វើ កំណត់ហេតុ អំពី ព័ត៌មាន។
- ណែនាំក្រុមទាំងអស់ ឲ្យធ្វើពង្រាងផ្នែកសេរីភាពក្នុងការបញ្ចេញមតិ នៃ រដ្ឋធម្មនុញ្ញ របស់រដ្ឋាភិបាលថ្មី។
- នៅពេលដែលបានបញ្ចប់រួចហើយ សូមឲ្យក្រុមទាំងអស់ ប្រជុំឡើងវិញ ជាថ្នាក់ និង ដាក់បញ្ចូលសេចក្តីពង្រាងគំនិត នៃ សេរីភាពក្នុងការបញ្ចេញមតិ ទៅក្នុងឯកសារមួយ។

## សកម្មភាពទី២

- បែងចែកថ្នាក់ នូវការធ្វើបទសម្ភាស របស់ លោក វ៉ាក្លាវ ហាវែល ដែលទាក់ទង អំពី គេហទំព័រ *សេចក្តីក្លាហានគ្មានព្រំដែន*

  www.rfkcenter.org
- បែងចែកថ្នាក់ នូវការអាន ស្តីពី "សេចក្តីក្លាហានគ្មានព្រំដែន"។
- បង្រៀនសិស្ស ឲ្យចេះប្រើប្រាស់សំណួរ ខាងក្រោម  ជាការណែនាំ នៅពេលដែល កំពុងអាន ផ្នែកទាំងពីរនេះ គឺ៖
  - តើក្រុមមួយ ដែលមានការត្រួតត្រា អាចធ្វើអ្វីខ្លះ  ចំពោះ អ្នកដែលហ៊ាននិយាយប្រឆាំងនឹងគេ?
  - តើមូលហេតុអ្វីបានជា រដ្ឋាភិបាលរបស់ លោក វ៉ាក្លាវ ហាវែល បានចាប់ផ្តើមធ្វើឲ្យគាត់ស្ងៀមស្ងាត់?
  - តើមានមធ្យោបាយស្រពិចស្រពិលណាមួយ ក្នុងការធ្វើឲ្យ ការរិះគន់នោះ ស្ងប់ស្ងាត់ដែរ ឬ ទេ?
- នៅពេលនោះ គ្រូបង្រៀន នឹងត្រូវដឹកនាំ និង ពាក់ព័ន្ធជាមួយសិស្ស ក្នុងកិច្ចពិភាក្សាមួយ ស្តីពី មធ្យោបាយ ដែល ក្នុងនោះ លោក វ៉ាក្លាវ ហាវែល ត្រូវបាន គេរំលោភ និង ដាក់គុក ចំពោះ ទស្សនៈរបស់គាត់។

# ក្លាយជាអ្នកការពារ

- សិស្ស នឹងត្រូវផ្សព្វផ្សាយ អត្ថបទរបស់ពួកគេ ជាសៀវភៅមួយ សម្រាប់ការចែកចាយ នៅក្នុងចំណោម សិស្ស ឬ សរសេររឿងល្ខោនខ្លីៗ ដែលនៅក្នុងនោះ បញ្ហាទាក់ទងនឹង សេចក្ដីសង្ខេប អំពី សេរីភាពក្នុង ការបញ្ចេញមតិ ត្រូវបានបង្ហាញ។

- សិស្សអាចសិក្សា និង បកស្រាយ ជាភាសាសមស្រប ទៅនឹងសទ្ធានុក្រម និង អត្ថប្រយោជន៍ជាក់លាក់របស់សិស្ស, សរសេរ និង បែងចែក នៅក្នុង សហគមន៍, សាលារៀន កំណែថ្មី នៃសេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស រួមគ្នាជាមួយកំណែដើមដំបូង។

- សិស្ស អាចជាសមាជិក អង្គការសិទ្ធិមនុស្សជាតិ ឬ អន្តរជាតិ, អង្គការសិទ្ធិពលរដ្ឋ ឬ អង្គការយុត្តិធម៌សង្គម, ដើម្បីជ្រាបជាព័ត៌មាន អំពី ការគម្រាមកំហែង ក្នុងស្រុក និង អន្តរជាតិ ចំពោះសេរីភាពក្នុងការបញ្ចេញមតិ និង សិទ្ធិមនុស្សជាទូទៅ។

- សិស្ស អាចបង្កើត និង ថែរក្សា គេហទំព័រ ការឃ្លាំមើលក្រុមអ្នកកាសែត (media watchdog) ដើម្បី រាយការណ៍ជូនសាលារៀន, សហគមន៍ និង ប្រជាជនពិភពលោក  នូវបញ្ហានានាស្ដីពី ប្រវត្តិរឿងព័ត៌មាន ដែលបានរិះគន់, សេចក្ដីសង្ខេប អំពីសេរីភាពក្នុងការបញ្ចេញមតិ  និង ការធ្វើបាបក្រុមអ្នកកាសែត។

- សិស្ស អាចប្រមូលចងក្រង នូវបញ្ជី របស់ អ្នកកាសែត និង អ្នកដទៃទៀត ដែល សិទ្ធិរបស់ពួកគេ ចំពោះ សេរីភាពក្នុងការបញ្ចេញមតិ  ត្រូវបានគាបសង្កត់ ទាំងក្នុងស្រុក ទាំងអន្តរជាតិ, និង អញ្ជើញពួកគេធ្វើ ជាអ្នកនិពន្ធ ជាភ្ញៀវសម្រាប់គេហទំព័ររបស់ពួកគេ។

- សិស្ស អាចសិក្សាស្រាវជ្រាវ នូវមនុស្សទាំងឡាយណា ដែលសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ របស់ពួកគេ ត្រូវបានគេរំលោភ និង ស្នើពួកគេ ឲ្យធ្វើជាវាគ្មិនជាភ្ញៀវ នៅក្នុងសាលារៀន និង សហគមន៍ របស់ពួកគេ។

## ពង្រីកឱកាសនានា

- អង្គការឃ្លាំមើលសិទ្ធិមនុស្ស (Human Rights Watch)៖ ក្រុមពិនិត្យតាមដានសិទ្ធិមនុស្ស ដែលបានឃ្លាំមើល នូវការរំលោភនូវ សិទ្ធិមនុស្ស  www.hrw.org។

- អង្គការសេរីភាពកុមារៈ ការស្នើសុំអំពីរបៀបដែលសិស្សអាចពាក់ព័ន្ធ នៅក្នុងគម្រោងរបស់សកម្មជនស្ដីពីបញ្ហាផ្សេងៗ www.freechild.org ។
- សៀវភៅស្ដីពីសម្លេងយុវជនវ៉ាស៊ីនតោន (Washington Youth Voice Handbook)  ការណែនាំ ចំពោះរបៀបដែលសិស្សអាចពាក់ព័ន្ធ នៅក្នុងការធ្វើគោលនយោបាយរបស់រដ្ឋាភិបាល និង មានសម្លេងមួយដែលទាក់ទងនឹងបញ្ហាសង្គមនានា www.youthrights.net។



ស៊ីវីកហ្គ័សកម្ពុជា សេង ធារី, លោកស្រី ឃៃរី ខិណ្ឌិឌី,  លោក រ៉ុង ឈុន, លោក ម៉ៃកូល ហេយស៍ (Michael Hayes), ឯកឧត្ដម សឺន ស៊ូបែរ្ត៍ នៅគេហដ្ឋាន លោកជំទាវ មួរ សុខហួ ទីក្រុងភ្នំពេញ ខែកុម្ភៈ ឆ្នាំ២០១១

# ព័ត៌មានបន្ថែម

### សេរីភាពក្នុងការបញ្ចេញមតិ៖ ការតស៊ូ និង ការបង្ក្រាប នៅក្នុងយុគសម័យ នៃ ទ្រព្យកម្មសិទ្ធិបញ្ញា

www.mediaed.org

ផ្សព្វផ្សាយដោយ មូលនិធិអប់រំព័ត៌មាន

### "ការគម្រាមកំហែងថ្មី ចំពោះសេរីភាពក្នុងការបញ្ចេញមតិ"

www.csmonitor.com

### "បច្ចេកទេសឃោសនាផ្សព្វផ្សាយដ៏ទំនើប" Free Republic.com

www.freerepublic.com

### Fairness and Accuracy in Media (FAIR)

www.fair.org

ក្រុមឃ្លាំមើលព័ត៌មានជាតិ ដែលធ្វើការ ដើម្បីពង្រឹងវិសោធនកម្មជាលើកទីមួយ ដោយគាំទ្រ ចំពោះភាពចំរុះមុខដ៏ច្រើននៅក្នុងវិស័យសារព័ត៌មាន និង ដោយពិនិត្យពិច័យ ការអនុវត្តផ្សព្វផ្សាយព័ត៌មាន ដែលធ្វើឲ្យបន្ទាប់បន្សំនូវ ផលប្រយោជន៍សាធារណៈ សម្លេងភាគតិច និង ទស្សនៈខ្វែងគំនិត។

### អង្គការឃ្លាំមើលសិទ្ធិមនុស្ស (Human Rights Watch)

www.hrw.org

### អង្គការលើកលែងទោសអន្តរជាតិ (Amnesty International)

www.amnesty.org

### សហព័ន្ធអន្តរជាតិដើម្បីសិទ្ធិមនុស្ស (International Federation for Human Rights)

www.fidh.org

### គណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា (Cambodian Human Rights Action Committee)

www.chrac.org

### សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស លីកាដូ (LICADHO)

www.licadho-cambodia.org

### មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (Cambodian Center for Human Rights)

www.cchrcambodia.org

### ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា (UN Office of High Commissioner for Human Rights)

www.ohchr.org

### សមាគមអាដហុក (ADHOC)

www.adhoc-cambodia.org

### គណៈកម្មាធិការការពារអ្នកកាសែត (Committee to Protect Journalists)

www.cpj.org

គណៈកម្មាធិការការពារអ្នកកាសែត (CPJ) គឺជា អង្គការឯករាជ្យមិនយកកម្រៃ បានបង្កើតឡើង ក្នុងឆ្នាំ១៩៨១។ ពួកគេ លើកកម្ពស់សេរីភាពសារព័ត៌មាន ទូទាំងពិភពលោក ដោយការ ការពារនូវសិទ្ធិរបស់អ្នកកាសែត ក្នុងការរាយការណ៍ព័ត៌មាន ដោយគ្មានភាពភ័យខ្លាចពីការផ្ចាញ់ផ្ចាល។

# លោក ម៉ូហាម៉ែត យូណែស (MUHAMMAD YUNUS)

“ពេលស្រ្តីទទួលសិទ្ធិអំណាច, ពួកគេសំឡឹងមើលនូវខ្លួនពួកគេ,និង នូវអ្វីដែលពួកគេអាចធ្វើបាន។ ពួកគេ កំពុងធ្វើឲ្យសេដ្ឋកិច្ចរីកចម្រើន ទន្ទឹមនឹងនេះដែរ, កំពុងសម្រេចសេចក្តី អំពីជីវភាពរស់នៅផ្ទាល់របស់ពួកគេ”។



Muhammad Yunus, ©2000 Eddie Adams

អ្នកស្ថាបនិក នៃធនាគារក្រាមីន (Grameen), ជាវិទ្យាស្ថានមីក្រូឥណទានធំបំផុត និង ជោគជ័យបំផុត, លោក ម៉ូហាមែត យូណែស (Muhammad Yunus) បានកើតនៅក្នុងទីកន្លែងក្រីក្របំផុតមួយ នៅលើភពផែនដីនេះ, ជាប្រទេសបង់ក្លាដែស (Bangladesh), ពីមុនមក ជាប្រទេសប៉ាគីស្ថាន (Pakistan)។ ជាសាស្ត្រាចារ្យផ្នែកសេដ្ឋកិច្ច, គាត់ត្រូវបានវាយប្រហារដោយភាពមិនស្របគ្នារវាង ទ្រឹស្តីសេដ្ឋកិច្ច ដែលបានបង្រៀននៅក្នុងសាកលវិទ្យាល័យ និង ភាពក្រីក្របំផុត នៅជុំវិញគាត់។ ដោយទទួលស្គាល់ថា អ្នកក្រីក្រនៅតែក្រីក្រ ពីព្រោះ ពួកគេមិនបានទទួលនូវដើមទុន, និង ប្រាក់ធានាសម្រាប់ប្រាក់កម្ចី, ហើយការសុំខ្ចីប្រាក់តម្រូវការតិចតួចនេះ ដែលថា ប្រាក់កម្ចីគឺមិនមានប្រសិទ្ធភាព សម្រាប់ធនាគារធំៗ ក្នុងការដាក់ឲ្យដំណើរការ នូវតម្រូវការរបស់ពួកគេ, លោក យូណែស (Yunus) បានចាប់ផ្តើមធ្វើការសាកល្បងនូវ ប្រាក់កម្ចី ដោយរួចផុតពីការធានាតិចតួច ចំពោះកសិករតាមជនបទ ដែលគ្មានដី និង ស្ត្រីក្រីក្រ។ ក្នុងឆ្នាំ១៩៨៣, គាត់បានបង្កើតធនាគារក្រាមីន (Grameen) នេះ។ វិធានការរបស់ ធនាគារក្រាមីន នេះ គឺមានលក្ខណៈតឹងរ៉ឹងណាស់។ អតិថិជនស្វែងរកមិត្តបានបួននាក់ដើម្បី ខ្ចីលុយ។ ប្រសិនបើម្នាក់ ក្នុងចំណោមមនុស្ស៥នាក់ មិនអាចបំពេញតួនាទីអ្នកទាំងអស់គ្នាត្រូវទទួលខុសត្រូវ,ដោយកសាងការប្តេជ្ញាចិត្ត និង ផ្តល់ការគាំទ្រដល់សហគមន៍។ ប្រាក់កម្ចីដើមដំបូង គឺតិចតួច, ឧទាហរណ៍ ១០ដុល្លារ, ហើយត្រូវបង់នូវការប្រាក់វិញ ២០ភាគរយ។ ជិត ២០ឆ្នាំក្រោយមក, ធនាគារ បដិវត្តនេះបានលូតលាស់ខ្លាំងណាស់, ដោយមាន សាខាជាង១០៥០ ដោយផ្តល់ សេវាកម្មដល់ភូមិ ៣៥,០០០ និង អតិថិជន ២លាននាក់, ពួកគេ៩៤ភាគរយ ជាស្ត្រី។ អ្នកសុំខ្ចីរបស់ធនាគារក្រាមីន ៩៨ភាគរយ ត្រូវបានបង់សងវិញ នូវប្រាក់ កម្ចីរបស់ពួកគេទាំងអស់, ជាអត្រាបង់សងវិញ ដែលគួរកត់សម្គាល់មួយ ខ្ពស់ជាងអត្រា ប្រាក់កម្រៃសងវិញរបស់អ្នកមាន និង អ្នកមានអំណាច។ សំខាន់ជាងនេះទៅទៀត, អតិថិជនបានផ្លាស់ប្តូរជីវភាពរស់នៅរបស់ពួកគេ៖ គឺពីភាពគ្មានអំណាច និង ពឹងផ្អែក ទៅភាពពឹងផ្អែកលើខ្លួនឯង, ឯករាជ្យ និង ភាពប៉ិនប្រសប់ខាងនយោបាយ។ ការផ្លាស់ប្តូរ ពិតប្រាកដ នឹងជះឥទ្ធិពលទៅជំនាន់ក្រោយ៖ គឺជំនាន់មួយ ដែលមានស្បៀងអាហារគ្រប់គ្រាន់, ការអប់រំប្រសើរ, ការព្យាបាលល្អប្រសើរ, និង ការពេញចិត្តត្រួតត្រាលើជីវិតផ្ទាល់របស់ពួកគេ, ដោយសារតែចក្ខុវិស័យ, ការច្នៃប្រឌិត និង ការលើកទឹកចិត្តរបស់ លោក យូណែស (Yunus)។ នៅក្នុងចំណោមរង្វាន់ជាច្រើន, លោក យូណែស (Yunus) ត្រូវបាន ទទួលរង្វាន់ណូបែលសន្តិភាព (Nobel Peace Prize) ក្នុងឆ្នាំ២០០៦ និង មេដៃ សេរីភាពប្រធានាធិបតីសហរដ្ឋអាមេរិក (U.S. Presidential Medal of Freedom) ក្នុងឆ្នាំ២០០៩។ រួមគ្នាជាមួយ លោក ណែលសិន មែនដេលា (Nelson Mandela), លោក ដេសមិន ធូធូ (Archbishop Desmond Tutu), និង រដ្ឋមន្ត្រីសំខាន់ៗ, មេដឹកនាំសិទ្ធិមនុស្ស និង ឥស្សរជនសំខាន់ៗទៀត, លោក យូណែស (Yunus) គឺជាសមាជិកម្នាក់ នៃក្រុមព្រឹទ្ធបុរសពិភពលោក (Global Elders) ។

នៅពេលដែលខ្ញុំបានចាប់ផ្តើមអនុវត្តកម្មវិធីក្រាមីន ក្នុងការផ្តល់ឲ្យនូវការទទួលបាននូវឥណទាន សម្រាប់អ្នកក្រីក្រ, ខ្ញុំបានប្រឈម នឹងឧបសគ្គចម្បងពីរ។ ទីមួយ, ធនាគារពាណិជ្ជកម្ម មាននិន្នាការ ប្រឆាំងជាស្ថាប័នទៅលើស្ត្រី។ ទីពីរ ពួកគេបានរារាំងការផ្តល់ឥណទានទាំស្រុង ចំពោះអ្នកក្រីក្រ ដោយទាមទារអ្វីមួយដែលអ្នកក្រីក្រអាចទទួលបាន, គឺជាប្រាក់ធានា (collateral)។

ដោយបានពុះពារលើឧបសគ្គទីពីរ, ខ្ញុំបានដោះស្រាយ នូវបញ្ហាទីមួយនៅក្នុងគម្រោងខ្ញុំ ខ្ញុំចង់បានពាក់កណ្តាល នៃអ្នកខ្ចីលុយពីធនាគារ ជាស្ត្រី, នេះជាបញ្ហាប្រឈមមុខមួយ។ មុនដំបូង, ស្ត្រីមានភាពស្ទាក់ស្ទើរក្នុងការទទួលយកនូវប្រាក់កម្ចីទាំងនេះ។ ពួកគេបាននិយាយថា “ទេ, ទេ ខ្ញុំមិនដែលបានប៉ះពាល់លុយកាក់ក្នុងជីវិតខ្ញុំ។ សូមអ្នកទៅជួបជាមួយប្តីរបស់ខ្ញុំវិញ។ គាត់យល់ដឹងអំពីលុយកាក់។ សូមផ្តល់លុយកាក់នេះជូនគាត់ទៅ”។ ដូច្នេះ ខ្ញុំត្រូវព្យាយាមពន្យល់អំពីផលប្រយោជន៍របស់ប្រាក់កម្ចីនេះចំពោះក្រុមគ្រួសារគាត់។ ប៉ុន្តែ ពេលខ្ញុំកាន់តែព្យាយាមចូលមករកស្ត្រី, ពួកគេកាន់តែរត់គេចចេញពីខ្ញុំ។ សហការីរបស់ខ្ញុំ និង ខ្ញុំបានធ្វើការយ៉ាងលំបាកក្នុងការគិតរកមធ្យោបាយមួយដែលយើងអាចកសាងទំនុកចិត្តចំពោះស្ត្រី ដើម្បីឲ្យពួកគាត់អាចនឹងទទួលប្រាក់កម្ចីពីបុរសៗ។ យើងបានបន្ថយការងាររបស់យើង ដើម្បីរួមបញ្ចូលទាំងស្ត្រីជាច្រើន, ពីព្រោះការកសាងជំនឿទុកចិត្តនេះត្រូវប្រើពេលវេលាច្រើន។

៦ឆ្នាំក្រោយមក, ដោយមោទនៈភាពថា ប្រាក់កម្ចីដែលយើងផ្តល់ឲ្យបានពាក់កណ្តាលទៅស្ត្រី, យើងបានចាប់ផ្តើមមើលឃើញអ្វីមួយដែលកើតឡើងគួរឲ្យកត់សំគាល់នោះ។ ប្រាក់ដែលផ្តល់ទៅឲ្យគ្រួសារទាំងនោះតាមរយៈស្ត្រី បានជួយគ្រួសារទាំងនោះច្រើនជាងចំនួនប្រាក់ដូចគ្នាទៅឲ្យបុរស។ មិនដូចពួកបុរស, ស្ត្រីមានការប្រុងប្រយ័ត្នណាស់ជាមួយលុយ ហើយបានផ្តល់ផលប្រយោជន៍ទៅឲ្យកូនរបស់ពួកគាត់ភ្លាម។ ពួកគាត់បានរៀនរបៀបក្នុងការចាត់ចែងធនធានដោយកម្រ។ ហើយស្ត្រីមានទស្សនៈវែងឆ្ងាយ។ ពួកគាត់អាចមើលឃើញមធ្យោបាយរួចផុតពីភាពក្រីក្រ និង មានវិន័យក្នុងការអនុវត្តផែនការរបស់ពួកគាត់។ ប្រហែលជា ដោយសារតែស្ត្រីទទួលរងការឈឺចាប់ពីភាពក្រីក្រច្រើនជាងបុរស, ពួកគាត់មានការជំរុញលើកទឹកចិត្តច្រើនក្នុងការជៀសវាងពីភាព ក្រីក្រ ។

ផ្ទុយទៅវិញ បុរសៗមានភាពធូរលុងជាមួយលុយកាក់។ ពួកគាត់ចាយលុយកាក់ភ្លាមៗ, មិនរង់ចាំនៅថ្ងៃស្អែកទេ។ ពួកស្ត្រីតែងតែកសាងអ្វីៗគ្រប់យ៉ាងសម្រាប់អនាគត, សម្រាប់ពួកគេផ្ទាល់, សម្រាប់កូនរបស់ពួកគាត់ និង សម្រាប់ក្រុមគ្រួសារ។ យើងបានមើលឃើញការខុសគ្នាមួយចំនួនរវាងបុរស និង ស្ត្រី។

យើងបានសម្រេចចិត្តព្យាយាមរួមកំលាំងគ្នា ក្នុងការទាក់ទាញអតិថិជនស្ត្រី ពីព្រោះយើងបានទទួលប្រាក់ផលច្រើនចេញពីចំនួនប្រាក់ដូចគ្នាទាំងអស់នេះ។ ដូច្នេះ ខ្ញុំបានបង្កើតភាពលើកទឹកចិត្តសម្រាប់មន្ត្រីផ្តល់ប្រាក់កម្ចីរបស់យើង ពីព្រោះពួកគាត់មានការលំបាកក្នុងការបញ្ចុះបញ្ចូលស្ត្រីឲ្យខ្ចីប្រាក់ពីធនាគារនេះ។ បច្ចុប្បន្ននេះ ៩៤% នៃប្រាក់កម្ចីរបស់យើងបានផ្តល់ឲ្យស្ត្រី។

យើងមិនបានរំពឹងទុកដល់ផលច្រើនដែលបានកើតឡើង។ ឧទាហរណ៍, អ្នកសុំខ្ចីប្រាក់ជាស្ត្រី បានប្តេជ្ញាចិត្តចំពោះខ្លួនគេ ពាក្យសន្យាមួយចំនួនដែលពួកគេបានហៅថា "សេចក្តីសម្រេច១៦ចំណុច"។ មានការប្តេជ្ញាចិត្ត ចំពោះការកែលម្អសុខុមាលភាពរបស់អ្នកសុំខ្ចីប្រាក់ និង គ្រួសាររបស់ពួកគាត់ លើសពីប្រាក់ដែលយើងបានឲ្យខ្ចី។ ពួកគាត់បានយល់ព្រមបញ្ជូនកូនរបស់ពួកគាត់ទៅសាលារៀន, ពួកគាត់បានសម្រេចចិត្តថែរក្សាវិន័យ, បង្កើតសាមគ្គីភាព, ធ្វើសកម្មភាពដោយមានសេចក្តីក្លាហាន, និង ខំធ្វើការគ្រប់បែបយ៉ាងដោយសេចក្តីព្យាយាម។ ពួកគាត់បានយល់ព្រមកុំឲ្យមានកូនច្រើន, បញ្ជូនកូនរបស់ពួកគាត់ទៅសាលារៀន, ដាំកូនឈើជាច្រើនតាមលទ្ធភាព, ហើយនឹងព្រមញ៉ាំបន្លែ។ នេះជាដំណោះស្រាយមួយចំនួនដែលក្រុមស្ត្រីបានបង្កើត, មិនមែនជាការទាមទារដោយធនាគារទេ។ បំណងប្រាថ្នាទាំងនេះ គឺមានសារៈសំខាន់ណាស់ចំពោះជីវិតរបស់ពួកគាត់។ ក្នុងការស្តាប់គាត់, យើងឃើញថាស្ត្រី ធ្វើឲ្យមានការផ្លាស់ប្តូរ។

ប្រាក់កម្ចីលើកដំបូង ជាធម្មតា គឺ៣៥ដុល្លារ។ មួយយប់មុនពេលស្ត្រីទៅទទួលយកប្រាក់កម្ចីពីធនាគារ, នាងគេងមិនលក់ដោយមានភាពជ្រួលច្របល់ក្នុងចិត្ត ក្នុងការសម្រេចថា តើនាងត្រៀមសម្រាប់វារួចស្រាចហើយឬនៅ។ នាងមានការភ័យខ្លាចថា ប្រហែលនឹងមានអ្វីអាក្រក់កើតឡើងដល់នាង។ ហើយនៅចុងបញ្ចប់ នៅពេលព្រឹក មិត្តភក្តិរបស់នាងនឹងមកដល់ ហើយពួកគាត់នឹងបានបញ្ចុះបញ្ចូលនាង “តោះ យើងនឹងធ្វើអ្វីដែលយើងបានសម្រេច។ ប្រសិនបើអ្នកមិនទៅ, យើងក៏មិនអាចដែរ។ យើងមិនអាចបារម្ភជានិច្ចកាលដូចនេះទេ។ វាមិនងាយស្រួលមកដល់ចំណុចនេះទេ។ តោះ យើងទៅ”។ ហើយនៅចុងបញ្ចប់ដោយមានការលើកទឹកចិត្តពីពួកគេ នាងនឹងបានមកដល់ធនាគារ។

នៅពេលដែលនាងកាន់លុយនោះ, វាមានចំនួនច្រើននៅក្នុងដៃរបស់នាង, ប្រៀបដូចការកាន់សេចក្តីសង្ឃឹម និង ការកាន់ទ្រព្យសម្បត្តិមួយដែលនាងមិនបានស្រមៃដល់។ នាងនឹងញាប់ញ័រខ្លាំង, ទឹកភ្នែកនឹងស្រក់លើថ្ពាល់របស់នាង, ហើយនាងមិនជឿថា យើងអាចមានការជឿជាក់លើនាងជាមួយចំនួនលុយដ៏ច្រើននេះ។ ហើយនាងសន្យាថានាងនឹងសងលុយនេះវិញ, ពីព្រោះលុយនេះ គឺជានិមិត្តសញ្ញានៃការជឿជាក់លើនាង ហើយនាងមិនចង់ក្បត់នូវជំនឿទុកចិត្តនោះទេ។

ហើយបន្ទាប់មក នាងពុះពារនៅក្នុងការសងប្រាក់កម្ចីលើកដំបូងនោះ, ជាការសងបណ្តាក់លើកដំបូង, ដែលមានកាលបរិច្ឆេទនៅសប្តាហ៍ក្រោយ, ហើយជាការសងបណ្តាក់លើកទី២ ដែលត្រូវបង់នៅសប្តាហ៍ក្រោយផងដែរ, ហើយការសងបណ្តាក់នេះ គឺបន្តទៅដល់

សប្តាហ៍ទី៥០ជាបន្តបន្ទាប់។ រៀងរាល់ពេលដែលនាងសងបណ្តាក់មួយទៅបណ្តាក់មួយ ធ្វើឲ្យនាងមានការជឿជាក់ខ្លាំងឡើងៗ! ហើយនៅពេលដែលនាងបញ្ចប់នូវការសងបណ្តាក់លើកទី៥០, ជាលើកចុងក្រោយបង្អស់, ហើយឥឡូវដែលនាងបានសងពេញលេញ, នាងអាចនិយាយថា "ខ្ញុំបានធ្វើវាហើយ!" នាងមានសេចក្តីរីករាយ។ វាមិនមែនត្រឹមតែជាការដោះដូរលុយកាក់ ដែលត្រូវបានបញ្ចប់ប៉ុណ្ណោះទេ, វាជាការផ្លាស់ប្តូរបុគ្គលនោះ។ នៅពេលចាប់ផ្តើម, នាងបានញាប់ញ័រ, នាងបានរសាប់រសល់, នាងបានមានអារម្មណ៍ថា នាងមិនជានរណាហើយក៏មិនមានតម្លៃដែរ។ ឥឡូវនេះ នាងជាស្ត្រីម្នាក់ដែលមានអារម្មណ៍ថានាងជាមនុស្សមានតម្លៃ។ ឥឡូវនេះ នាងអាចងើបឈរ និង ប្រឈមមុខនឹងពិភពលោកទាំងមូលដោយស្រែកថា "ខ្ញុំអាចធ្វើបាន, ខ្ញុំអាចធ្វើបានដោយខ្លួនឯង"។ ដូច្នេះ នេះជាដំណើរការមួយនៃការផ្លាស់ប្តូរ និងការស្វែងរកឃើញតម្លៃខ្លួន, គឺថានាងអាចថែរក្សាខ្លួនដោយខ្លួនឯង។

ប្រសិនបើ អ្នកត្រឹមតែក្រឡេកមើលកម្មវិធីឲ្យខ្ចីប្រាក់កម្ចីរបស់ធនាគារក្រាមីន (Grameen), អ្នកមិនបានឃើញលទ្ធផលទទួលបានពេញលេញទេ។ ធនាគារក្រាមីន បានពាក់ព័ន្ធនៅក្នុង ដំណើរការនៃការផ្លាស់ប្តូរ។ សេចក្តីសម្រេច១៦ចំណុច គឺជាឧទាហរណ៍ គំរូ៖ យើងបានឃើញថា កុមារក្រាមីន ចូលសាលាដោយ មានចំនួនច្រើន ពីព្រោះម្តាយរបស់ពួកគេ ពិតជាបានប្តេជ្ញាចិត្តយ៉ាង មុតមាំ។ ហើយឥឡូវនេះកុមារជាច្រើនកំពុងបន្តនៅក្នុងសាកលវិទ្យាល័យ, មហាវិទ្យាល័យបន្តទៅសាលាពេទ្យជាដើម។ ពិតជាគួរឲ្យចាប់អារម្មណ៍ ក្នុងការមើលឃើញកុមារា និង កុមារី បន្តចូលរៀននៅកម្រិតអប់រំខ្ពស់។ កម្មវិធីនេះបានទទួលជោគជ័យយ៉ាងធំធេងដែលឥឡូវនេះ យើងដឹងថា នឹងមានសិស្សនិស្សិតច្រើននឹងត្រូវការប្រាក់កម្ចីនា ពេលអនាគត។ ដូច្នេះ ថ្មីៗនេះយើងបានរៀបចំគម្រោងការឲ្យខ្ចីប្រាក់កម្ចីមួយទៀត សម្រាប់ការអប់រំកម្រិតខ្ពស់ក្នុងសាលារៀនវិជ្ជាជីវៈផ្សេងៗ ដល់កុមារា កុមារីក្រាមីនទាំងអស់គ្នា។ ឥឡូវនេះ ពួកគេ មិនត្រូវព្រួយ បារម្ភណ៍ថា តើឪពុកម្តាយរបស់ពួកគេអាចបង់ថ្លៃឈ្នួល សាលាបាន ឬទេ ពេលប្រាក់សាលា (tuition) វាថ្លៃ។

ការសិក្សាថ្មីៗនេះក្នុងប្រទេសបង់ក្លាដែស (Bangladesh) បានបង្ហាញថា កុមារនៅក្នុងគ្រួសារក្រាមីន មានសុខភាព ប្រសើរជាងកុមារមិនមែនក្រាមីន។ ទស្សនាវដ្តីរបស់ សហរដ្ឋអាមេរិកមួយ (Scientific American) បានធ្វើការសិក្សាស្រាវជ្រាវអំពីកំណើនប្រជាពលរដ្ឋនៅក្នុងប្រទេសបង់ក្លាដែស(Bangladesh)ដោយបង្ហាញថា ចំនួនមធ្យមភាគនៃកុមារក្នុងគ្រួសារនីមួយៗ កាលពី ម្ភៃឆ្នាំមុន គឺមាន៧, ប៉ុន្តែឥឡូវនេះបានធ្លាក់ចុះដល់៣។ តើមានអ្វីកើត ឡើង ? ហេតុអ្វីបានជាវាកើតឡើង ? ទស្សនាវដ្តីនេះ (Scientific American) បានជម្រុញឲ្យមានជម្លោះទាស់ទែងគ្នាដោយបានលើកឡើងថាការផ្លាស់ប្តូរនេះកើតឡើងដោយគម្រោងរបស់យើង។ ខណៈ ស្ត្រីពោរពេញដោយអំណាច, ពួកគាត់ពឹងផ្អែកលើខ្លួនគាត់ ហើយមើល នូវអ្វីដែលពួកគាត់អាចធ្វើបាន។ ពួកគាត់កំពុងធ្វើឲ្យសេដ្ឋកិច្ចរីកចម្រើន ហើយទន្ទឹមនឹងនេះដែរ ពួកគាត់កំពុងសម្រេចអំពីជីវិតផ្ទាល់ខ្លួនរបស់គាត់ ហើយអំពីកូន ថាគួរមានប៉ុន្មាននាក់។ មាត្រា១៦ ក្នុងសេចក្តីសម្រេចមួយចែងថា យើងគួរថែរក្សាក្រុមគ្រួសាររបស់យើងឲ្យមានចំនួនតិច។ ដូច្នេះ នេះគឺជាផ្នែកសំខាន់មួយ នៃការគិតគូរ។ ក្នុងកិច្ចប្រជុំ ស្តីពីចំនួនមនុស្សនៅទីក្រុងកែរ៉ូ (Cairo), គ្រប់កិច្ចប្រជុំទាំងអស់បាន និយាយអំពីគំរូក្រាមីន, ពីព្រោះការអនុម័ត នៃទំនៀមទំលាប់ ការរៀបចំក្រុមគ្រួសារ (family planning) របស់ស្ត្រីក្នុងគម្រោងយើង គឺមានកម្រិតខ្ពស់ពីរដង ជាងមធ្យមភាគជាតិ។ មើលទៅ, យើងមិនមែនជាកម្មវិធី ស្តីពីចំនួនមនុស្សទេ (population program), ប៉ុន្តែ នេះជា ផលល្អដែលបានកើតឡើង។

មានផលប្រសើរផ្សេងៗទៀតដែលបានកើតឡើង។ ចាប់ផ្តើមពីប្រាំពីរឆ្នាំមុន, យើងបានលើកទឹកចិត្តអ្នកសុំខ្ចីប្រាក់ក្រាមីន ឲ្យចូលរួមនៅក្នុងដំណើរការនយោបាយដោយបោះឆ្នោត។ ប្រតិកម្ម លើកដំបូងរបស់ពួកគាត់ គឺអវិជ្ជមាន។ ពួកគាត់បាននិយាយថា "បេក្ខជន ទាំងអស់នេះគឺសុទ្ធតែជាមនុស្សអាក្រក់, ដូច្នេះ តើហេតុអ្វីបានជាយើង ត្រូវបោះឆ្នោតជូនពួកគាត់ ?" ចម្លើយនេះ បានធ្វើឲ្យយើងមានភាព ក្រៀមក្រំយ៉ាងខ្លាំង ដែលប្រជាជនបានយល់ឃើញអំពីនីតិវិធីបោះ ឆ្នោតបែបនេះ។

ដូច្នេះហើយយើងបានឆ្លើយតបថា "មែនហើយ យល់ព្រម, ពួកគាត់គឺសុទ្ធតែជាមនុស្សអាក្រក់, ប៉ុន្តែប្រសិនបើអ្នកមិនទៅបោះឆ្នោតទេ, មនុស្សអាក្រក់បំផុតនោះនឹងបានជាប់បោះឆ្នោត។ ដូច្នេះ សូមអញ្ជើញទៅអង្គុយនៅក្នុងមជ្ឈមណ្ឌលរបស់យើង, សូមពិភាក្សាថា តើនរណាអាចជាមនុស្សអាក្រក់ជាងគេបំផុត, អ្វីអាចកើតឡើងប្រសិនបើគេបានជាប់ឆ្នោត, ហើយប្រសិនបើអ្នកមើលឃើញ សេចក្តីសង្ឃឹមនេះថាអាក្រក់ ក្រោយមកអ្នកមានឱកាសមួយក្នុងការជ្រើសរើសនៅក្នុងចំណោមមនុស្សអាក្រក់ទាំងនោះ, ដែលជាមនុស្សអាក្រក់តិចបំផុត"។ ភ្លាមៗនោះ ប្រជាជនបានទទួលនូវក្តីរំភើប, ហើយយើងបានទទួលការចូលរួមជិត១០០ភាគរយ នៅក្នុងដំណើរការបោះឆ្នោតលើកដំបូងនោះ។

គេបានរៀបចំល្អណាស់។ គ្រួសារក្រាមីន (Grameen) ទាំងអស់បានជួបជុំគ្នានៅព្រឹកថ្ងៃបោះឆ្នោត, ហើយពួកគាត់បានទៅកាន់មណ្ឌលបោះឆ្នោតរួមគ្នា, ដើម្បីធ្វើឲ្យអ្នកនយោបាយកត់សម្គាល់នូវចំនួនដ៏ច្រើនសន្ធឹកសន្ធាប់របស់ពួកគាត់, ដើម្បីឲ្យពួកអ្នកនយោបាយយកចិត្តទុកដាក់យ៉ាងម៉ត់ចត់អំពីវត្តមានរបស់ពួកគាត់។ នៅក្នុងដំណើរការបោះឆ្នោតបន្ទាប់, យើងបានរៀបចំគ្រួសារក្រាមីន (Grameen) ដើម្បីបោះឆ្នោតដោយខ្លួនពួកគាត់ផ្ទាល់ ហើយបាននាំមិត្តភ័ក្តិ និង អ្នកជិតខាងរបស់ពួកគាត់មកបោះឆ្នោត, ជាពិសេសស្ត្រី។

លទ្ធផលដែលបានទទួលពីការបោះឆ្នោតឆ្នាំ១៩៩៦ នៅប្រទេសបង់ក្លាដែស (Bangladesh) ក្នុងការចូលរួមរបស់អ្នកបោះឆ្នោត គឺ៧៣ភាគរយ ដែលជាភាគរយខ្ពស់បំផុត។ ហើយអ្វីដែលបានធ្វើឲ្យមនុស្ស

គ្រប់រូបតក់ស្លុតខ្លាំងនោះ គឺថាជាទូទៅចំនួនស្ត្រីបានបោះឆ្នោតច្រើនជាងបុរស។ ជាការពិតណាស់, ស្ត្រីបានរងចាំអស់ជាច្រើនម៉ោង, ពីព្រោះនៅពេលដែលគេបានធ្វើការរៀបចំបោះឆ្នោតនោះ អាជ្ញាធរបានរំពឹងថា មានត្រឹមតែពាក់កណ្ដាលប៉ុណ្ណោះ នឹងមកបោះឆ្នោត។

លទ្ធផលនេះបានធ្វើការផ្លាស់ប្ដូរទេសភាពនយោបាយ។ នៅក្នុងអាណត្តិសភាមុន, គណបក្សសាសនានិយម មានអាសនៈចំនួន១៧។ ក្នុងការបោះឆ្នោតឆ្នាំ១៩៩៦, ចំនួនអាសនៈរបស់ពួកគាត់ត្រូវបានធ្លាក់ចុះទៅដល់៣, ពីព្រោះស្ត្រីបានយល់ឃើញថា មិនមានអ្វីដែលគួរឲ្យចាប់អារម្មណ៍ នៅក្នុងកម្មវិធីរបស់គណបក្សសាសនានិយមនោះទេ។ នេះបានបង្ហាញ អំពីការតម្កើងអំណាចរបស់ស្ត្រី, គួរឲ្យចាប់អារម្មណ៍មែន។

បន្ទាប់មកទៀត, នៅក្នុងការបោះឆ្នោតថ្នាក់មូលដ្ឋានកាលពីឆ្នាំមុន, យើងភ្ញាក់ផ្អើលយ៉ាងខ្លាំងដែលឃើញថា សមាជិកក្រាមីន (Grameen) ជាច្រើនបានជាប់ឆ្នោត។ ដូច្នេះ ខ្ញុំបានធ្វើដំណើរ និង ជជែកទៅកាន់មនុស្សទាំងអស់នោះ, ហើយបានសួរថា តើហេតុអ្វីបានជាពួកគាត់បានជ្រើសរើសឈរឈ្មោះបោះឆ្នោត។ ពួកគាត់បាននិយាយថា, "អ្នកបានប្រាប់យើងឲ្យជ្រើសរើសមនុស្សអាក្រក់តិចតួចបំផុត, ហើយយើងបានព្យាយាម, ប៉ុន្តែ វាជាការងារស្អប់ខ្ពើមមួយដែលធ្វើឲ្យយើងដល់ក, ហើយយើងបានចាប់ផ្ដើមសម្លឹងមើលគ្នាទៅវិញទៅមក, ដោយគិតថា "តើហេតុអ្វីបានជាយើងត្រូវស្វែងរកមនុស្សអាក្រក់តិចតួចបំផុត, នៅពេលដែលយើងមានមនុស្សល្អនៅទីនេះ? តើហេតុអ្វីបានជាយើងមិនឈរឈ្មោះដោយខ្លួនយើង?" នេះជាអ្វីដែលបានបង្កើតចលនា ដែលបានផ្ដល់ឲ្យមានសមាជិកក្រាមីន ច្រើនជាង៤ពាន់នាក់ ដែលបានជាប់ឆ្នោតកាន់តំណែងនៅថ្នាក់មូលដ្ឋាន។ វាអស្ចារ្យមែន។ ហើយរបៀបពួកគាត់ជជែកគ្នាមានភាពខុសគ្នាទាំងស្រុង។ ខ្ញុំ មិនដែល បានឮស្ត្រីនៅក្នុងប្រទេសបង់ក្លាដែស (Bangladesh) ជជែកគ្នាបែប នេះទេ។ ពួកគាត់ហ៊ានប្រឈមមុខ នឹងរដ្ឋាភិបាល។ ពួកគាត់និយាយ ថា "រដ្ឋាភិបាល មិនអាចប្រាប់យើង អំពីរបៀបក្នុងការបោះឆ្នោតនោះទេ។ យើងបានប្ដេជ្ញាចិត្តចំពោះអ្នកបោះឆ្នោតរបស់យើង"។ នេះជាអ្វីដែលបានកើតឡើង។ ដូច្នេះ នៅក្នុងការថែរក្សាសុខភាព, នៅក្នុងការចូលរួមផ្នែកនយោបាយ, ក្នុងការទំនាក់ទំនងរវាងម្ដាយ និង កូន ហើយរវាងប្ដី និង ប្រពន្ធ, យើងឃើញថា សង្គមមានការផ្លាស់ប្ដូរ។

ឥឡូវនេះ មនុស្សអាចជជែកដោយសេរី, មនុស្សអាចធ្វើអ្វីក៏បាន, មនុស្សអាចស្វែងយល់អំពីទេពកោសល្យ និង សមត្ថភាពផ្ទាល់ខ្លួន, ហើយមើលទៅពិភពលោកក្នុងរបៀបមួយប្លែកពីមុន។ ពីព្រោះក្រាមីនផ្ដល់ឱកាសឲ្យក្លាយជាផ្នែកមួយ នៃវិទ្យាស្ថានមួយ, ដោយមានការគាំទ្រផ្នែកហិរញ្ញវត្ថុ ចំពោះការធ្វើកិច្ចការផ្ទាល់ខ្លួនរបស់មនុស្ស។ អតិថិជនរបស់យើងប្រៀបដូចជាអ្នកចូលរួមផ្នែកពាណិជ្ជកម្ម, គឺជាទំនាក់ទំនងពាណិជ្ជកម្មមួយ ដែលធ្វើឲ្យមានការផ្លាស់ប្ដូរជីវិតរបស់ពួកគាត់។

ជាធម្មតា វាមានការជំទាស់។ ការជំទាស់លើកដំបូងបានកើតមកពីប្ដី ដែលមានអារម្មណ៍ថាគេមាក់ងាយគាត់, គេបានធ្វើឲ្យបាក់មុខមាត់, ហើយពួកគាត់បានគិតថា មានការគម្រាមកំហែងពីប្រពន្ធដែលត្រូវបានទទួលប្រាក់កម្ចី ដែលពួកគាត់មិនបានទទួល។ ភាពតានតឹងនៅក្នុងរចនាសម្ព័ន្ធគ្រួសារ ជួនកាលអាចនាំឲ្យមានអំពើហិង្សាដល់ស្ត្រី។ ដូច្នេះ យើងបានផ្អាកមួយរយៈពេល ហើយបន្ទាប់មកទៀត យើងបាននឹកឃើញគំនិតមួយ។ យើងបានចាប់ផ្ដើមជួបជាមួយប្ដី និង ពន្យល់អំពីកម្មវិធីក្នុងមធ្យោបាយមួយ ដែលពួកគាត់អាចយល់ដឹងអំពីផលប្រយោជន៍ដល់ក្រុមគ្រួសារគាត់។ ហើយយើងព្យាយាមក្នុងការជួបជាមួយប្ដី និង ប្រពន្ធរួមគ្នា ដើម្បីឲ្យអ្នកទាំងពីរបានយល់ដឹងអំពីអ្វីជាការរំពឹងទុកពីពួកគាត់។ ធ្វើរបៀបនេះបានកាត់បន្ថយច្រើនទៅលើការជំទាស់ដំបូងពីប្ដី។

ប្រុសៗជិតខាងក៏បានធ្វើការជំទាស់, ហើយបានបិទបាំងអារម្មណ៍ភ័យខ្លាចជាក់ស្ដែងរបស់ពួកគេ ពីការតម្កើងអំណាចស្ត្រី, ក្នុងការប្រើភាសាសាសនា។ យើងបានពិនិត្យដោយយកចិត្តទុកដាក់អំពីថា តើកម្មវិធីរបស់យើង មានលក្ខណៈប្រឆាំងនឹងសាសនាខ្លះដែរឬទេ។ ប៉ុន្តែពួកគាត់បានពួនពីក្រោយសាសនា ដោយមិនទទួលស្គាល់ថា ពួកគាត់ត្រូវបានគេមើលរំលង។ វាគឺជាអាត្មានិយមខាងប្រុសៗ ដែលបាននិយាយជាពាក្យពេចន៍ខាងសាសនា។

ការអះអាងជំទាស់ប្រសើរបំផុតរបស់យើង គឺត្រូវផ្ដល់ពេលវេលាឲ្យ។ យើងបានឃើញច្បាស់ថា អ្នកខ្ចីលុយរបស់យើងនៅតែបំពេញតួនាទីផ្នែកសាសនារបស់ពួកគាត់, ហើយស្របពេលជាមួយគ្នានេះដែរពួកគាត់នឹងរកប្រាក់បាន និង មានការជឿជាក់លើខ្លួន។ ស្ត្រីបានចាប់ផ្ដើមប្រឈមមុខនឹងមនុស្សអ្នកកាន់សាសនា។ ពួកគាត់បាននិយាយថា "អ្នកគិតថា ការយកប្រាក់ពីធនាគារក្រាមីន គឺជាគំនិតអាក្រក់មួយឬ? អញ្ចឹង, យើងឈប់ទទួលប្រាក់ពីក្រាមីន, ប្រសិនបើលោកអ្នកនឹងឲ្យប្រាក់យើងខ្ចីវិញ។ យើងមិនខ្វល់ថា តើ នរណាឲ្យយើងខ្ចីទេ, ប៉ុន្តែបើសិនគ្មានប្រាក់យើងមិនអាចធ្វើអ្វីកើតទេ"។ ហើយតាមពិតទៅអ្នកគាំទ្រផ្នែកសាសនាបាននិយាយថា "ទេ ទេ យើងមិនអាចឲ្យប្រាក់ដល់អ្នកបានទេ"។ ហើយរឿងនេះ បានចប់ ត្រឹមហ្នឹងទៅ។

យើងផងដែរបានទទួលនូវការរិះគន់ ពីអ្នកមានវិជ្ជាជីវៈខាងផ្នែកអភិវឌ្ឍ ដែលបានទទូចថា ការផ្ដល់ប្រាក់បន្តិចបន្តួចដល់ ស្ត្រី ដែលមិនមានចំណេះដឹង និង ជំនាញ មិនបានបង្កើតឲ្យមានការផ្លាស់ប្ដូររចនាសម្ព័ន្ធនៅក្នុងប្រទេស ឬ ក្នុងភូមិ, ហើយហេតុដូច្នេះ វាមិនមែនជាការអភិវឌ្ឍពិតប្រាកដនោះទេ។ ពួកគាត់បាននិយាយថា ការអភិវឌ្ឍពាក់ព័ន្ធនៅក្នុងប្រាក់កម្ចីច្រើនលានដុល្លារ សម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធធំៗ។ យើងមិនដែលរំពឹងទុកថា មានការជំទាស់ណាមួយពីវិស័យអភិវឌ្ឍនោះទេ, ប៉ុន្តែវាបានកើតឡើង, ហើយវាកើតមានជម្លោះទាស់ទែងគ្នា។ ពីព្រោះអ្វីដែលយើងធ្វើ គឺមិនមាននៅក្នុងសៀវភៅរបស់

ពួកគាត់។ ពួកគាត់មិនអាចចាត់ទុកយើងជាផ្នែកណាមួយបានទេ, ទោះជា ស្តាំក្តី, ឆ្វេងក្តី, អភិរក្សក្តី ឬ សេរីក្តី។ យើងនិយាយអំពី ទីផ្សារសេរី, ប៉ុន្តែ ស្របពេលជាមួយគ្នានោះដែរ យើងមានការគាំទ្រអ្នកក្រីក្រ។ ពួកគាត់ បានយល់ច្រឡំទាំងស្រុង។

ប៉ុន្តែប្រសិនបើមនុស្សស្ថិតក្នុងស្ថានភាពថ្នាក់រៀន, មនុស្សនោះគិតរវើរវាយជុំវិញទ្រឹស្តី, ហើយសម្រេចថាគម្រោងមីក្រូឥណទាននេះមានភាពអស់សំណើច ពីព្រោះវាមិនស្របជាមួយនឹងពិភពទ្រឹស្តីថ្នាក់រៀន។ ប៉ុន្តែ ខ្ញុំធ្វើការជាមួយមនុស្សជាក់ស្តែងនៅក្នុងពិភពលោកជាក់ស្តែង។ ដូច្នេះ នៅពេលដែលបណ្ឌិតសភា ឬ អ្នកមានវិជ្ជាជីវៈធ្វើសេចក្តីសន្និដ្ឋានទាំងនេះ, ខ្ញុំមានអារម្មណ៍អាក់អន់ចិត្ត ហើយខ្ញុំត្រលប់ទៅរក និង ធ្វើការជាមួយអ្នកសុំខ្ចីប្រាក់របស់ខ្ញុំ, ហើយខ្ញុំនឹងដឹងថានរណាគេត្រូវ។

ស្នាមញញឹមដ៏ធំបំផុត គឺកើតមកពីស្ត្រីម្នាក់ ដែលទើបបានផ្លាស់ប្តូរមធ្យោបាយ នៃជីវភាពរស់នៅរបស់នាង។ ភាពរំជួលចិត្ត ដែលនាងបានជួបប្រទះជាមួយកូនរបស់នាង, ដោយផ្លាស់ប្តូរពីថ្នាក់មួយទៅថ្នាក់មួយ, គឺគួរឲ្យរំភើបចិត្តយ៉ាងខ្លាំង, ដែលមានភាពជាក់ស្តែងធ្វើឲ្យយើងភ្លេចអំពីការវែកញែកដែលបានធ្វើឡើង នៅសាលជប់លៀង នៃសណ្ឋាគារ រវាងអ្នកជំនាញអន្តរជាតិជាច្រើន, ក្នុងការបោះសម្តីថា នេះគឺគ្មានអ្វីគួរឲ្យកត់សម្គាល់ទេ។ ដូច្នេះ នោះជារបៀបដែលខ្ញុំបានទទួលកម្លាំង, គឺបានមកពីប្រជាជន។

ឥឡូវនេះ ធនាគារក្រាមីន (Grameen) គឺមាននៅទូទាំងប្រទេសបង់ក្លាដែស (Bangladesh), ដោយមានគ្រួសារចំនួន២.៤លាន។ សូម្បីនៅក្នុងគ្រាលំបាកនេះ, ដូចជាទឹកជំនន់ដ៏អាក្រក់នៅក្នុងឆ្នាំនេះ, ប្រជាជននៅតែសងប្រាក់វិញដោយចេតនា, ហើយយើងកំពុងទទួលប្រាក់កម្ចីល្អច្រើន។ ឧទាហរណ៍នេះបានបង្ហាញ អំពីសមត្ថភាពមូលដ្ឋានរបស់ប្រជាជន ក្នុងការបំពេញលើកិច្ចការអ្វីមួយដែលគាត់មានជំនឿ ទោះជាអ្នកដទៃបាននិយាយអ្វីក៏ដោយ។ ប្រជាជនបានសួរថា, តើមានហេតុផលអ្វីដែលយើងបានទទួលជោគជ័យ, ដែលយើងអាចធ្វើបាន, នៅពេលដែលមនុស្សគ្រប់រូបបាននិយាយថា យើងមិនអាចធ្វើវាបានទេ។ ខ្ញុំនៅតែនិយាយថា ខ្ញុំជាមនុស្សក្បាលរឹង។ ដូច្នេះ នៅពេលដែលអ្នកសួរថា តើវាមានសេចក្តីក្លាហានឬយ៉ាងណា, ខ្ញុំនឹងឆ្លើយតបថា មិនមែនជាសេចក្តីក្លាហានទេ ប៉ុន្តែ ជាភាពក្បាលរឹង។ ទោះជាអ្នកផ្តល់ការពន្យល់ពិរោះបែបណាក៏ដោយ ភាពក្បាលរឹងនេះហើយ គឺអ្វីដែលត្រូវមានក្នុងការឲ្យរឿងកើតឡើង។




ទីស្នាក់ការកណ្តាល របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី នៅភ្នំពេញ

# ប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រ

លោក ម៉ូហាមែត យូណែស　　　　បញ្ហាសិទ្ធិមនុស្ស៖ មីក្រូឥណទាន

## សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស

- មាត្រា២៣៖ សិទ្ធិមានការងារ តាមប្រាថ្នា
- មាត្រា២៥៖ សិទ្ធិមានស្តង់ដារជីវភាពគ្រប់គ្រាន់

## តម្រូវការពេលវេលា៖ ១៦០នាទី

## គោលបំណង

បន្ទាប់ពីមេរៀននេះ សិស្សអាចនឹង៖

- ពន្យល់អំពី "ភាពក្រីក្រ" និងប្រសិទ្ធភាពដ៏យូរអង្វែងរបស់ភាពក្រីក្រ
- យល់ដឹងអំពីវិធីសាស្ត្រផ្តល់ មីក្រូឥណទាន របស់ លោក ម៉ូហាមែត យូណែស
- វិភាគ នូវ ផលប្រយោជន៍ នៃ ការផ្តល់ឥណទាន ព្រមទាំង បញ្ហាប្រឈម

## សំណួរណែនាំ

- តើរស់នៅក្នុងភាពក្រីក្រ វាមានន័យដូចម្តេច ?
- តើអ្វីទៅជា ប្រសិទ្ធភាពដ៏យូរអង្វែង របស់ភាពក្រីក្រ ?
- តើ យើងអាចចាត់ទុក ភាពក្រីក្រថា ជារឿងអតីតកាល បានដែរ ឬ ទេ ?

## ជំនាញរបស់សិស្ស

- ធ្វើសេចក្តីសន្និដ្ឋាន
- ធ្វើការប្រៀបធៀប និង ភាពផ្ទុយគ្នា
- វាយតម្លៃ
- វិភាគ និង ប្រើប្រាស់ព័ត៌មាន
- គាំទ្រ មុខដំណែង
- ចូលរួមធ្វើផែនការ និង កិច្ចពិភាក្សាជាក្រុម

## គោលគំនិត

- ប្រព័ន្ធសេដ្ឋកិច្ច
- តម្លៃ ឬ សីលធម៌ (morals or values)
- ជម្រើស
- ភាពយល់ចិត្ត (empathy)
- សេចក្តីត្រូវការ និង តម្រូវការជាក់ស្តែង (needs and wants)
- កត្តា នៃ ផលិតកម្ម (factors of production)
- យុត្តិធម៌
- ការធ្វើសេចក្តីសម្រេចចិត្ត
- តម្លៃពលរដ្ឋ (civic values)
- សិទ្ធិមនុស្ស

## វាក្យស័ព្ទ៖

- ភាពក្រីក្រ
- កម្ចីធនាគារ (bank loans)
- ឥណទាន (credit)
- ចរិតលក្ខណៈ, មូលធន/ប្រាក់ធានា, សមត្ថភាព (3 C's: character, capital / collateral, capacity)
- វត្ថុបញ្ចាំ (collateral)
- មីក្រូឥណទាន
- ធនាគារក្រាមីន

## សម្ភារៈសិក្សា

- ក្រដាសផាត (chart)
- ឯកសារ ខ្ញុំសូមខ្ចីលុយ (May I Have a Loan? Worksheet)
- លោក ម៉ូហាមែត យូណែស
- www.speaktruth.org

# សកម្មភាពរបស់សិស្ស

## ស្ពានភាពព្រាងទុក

- សូមរៀបចំ កិច្ចពិភាក្សា ក្នុងថ្នាក់រយៈពេលខ្លី, ការបំផុសអំពីនិយមន័យមួយ ឬ អត្ថាធិប្បាយ អំពី "ភាពក្រីក្រ" និង របៀបនៃផលប៉ះពាល់លើ ជីវភាពរស់នៅ របស់ប្រជាជន។
    - កត់ត្រានូវចម្លើយរបស់សិស្ស នៅលើក្រដាសធាត ដើម្បីទុក សម្រាប់ពេលក្រោយ ក្នុងអំឡុងពេល បង្ហាញមេរៀននេះ។
- សួរសិស្ស អំពី មធ្យោបាយ ក្នុងការបញ្ចប់ភាពក្រីក្រ។ តាមរយៈកិច្ចពិភាក្សានេះ គ្រូបង្រៀន គួរតែដឹកនាំថ្នាក់ ក្នុងការធ្វើសេចក្តីសន្និដ្ឋានថា អ្នកក្រីក្រ ត្រូវការប្រាក់ដើម្បីកែលម្អនូវជីវភាពរស់នៅ របស់ពួកគេ។ ទីកន្លែងមួយ ដែលសុំខ្ចីប្រាក់នោះ គឺធនាគារ។

## សកម្មភាពទី១

- បែងចែកសិស្ស ជាក្រុមតូចៗ។ ក្រុមនីមួយៗ គឺត្រូវធ្វើឲ្យដូច ប្រធានផ្នែកគ្រប់គ្រងធនាគារ ទទួលបន្ទុកផ្តល់ប្រាក់កម្ចី។
- ចែកចាយ ឯកសារ ខ្ញុំសូមខ្ចីលុយ
- អង្កេតនូវសូចនាករ (indicators) ដែលធនាគារជាទូទៅត្រូវពិនិត្យមើល, តើបុគ្គលម្នាក់ អាចបញ្ជាក់ប្រាប់ អំពី វត្ថុបញ្ចាំ, និង ចរិតលក្ខណៈ, មូលធន/ប្រាក់ធានា, សមត្ថភាព (3 C's: character, capital/collateral, capacity)។
- បង្រៀនសិស្ស ឲ្យចេះពិភាក្សានូវ ផលល្អ និង ផលអាក្រក់ នៃការ ផ្តល់ឲ្យប្រជាជនធ្វើអត្ថាធិប្បាយ លើឯកសារសំណួរ អំពីប្រាក់កម្ចី។
- បន្ទាប់មក ស្នើសិស្សឲ្យចែករំលែកនូវសេចក្តីសម្រេចចិត្តរបស់ពួកគេ ដល់ថ្នាក់ ដោយកំណត់ថា តើពួកគេនឹង យល់ព្រមលើប្រាក់កម្ចី ឬ ទេ។
- គ្រូបង្រៀន នឹងត្រលប់ទៅរក កិច្ចពិភាក្សាមុនៗ និង សំណួរសំខាន់ៗ គឺ៖ តើយើងអាចចាត់ទុក ភាពក្រីក្រ ថា ជារឿងអតីតកាល បានដែរ ឬ ទេ ប្រសិនបើធនាគារនេះ មិនបានផ្តល់ ប្រាក់កម្ចីដល់ប្រជាជននោះ? តើមានគំនិតយោបល់ ឬ ដំណោះស្រាយផ្សេងដែរ ឬ ទេ?

## កិច្ចការផ្ទះ (homework)

- សិស្ស គួរតែឆ្លុះបញ្ចាំង នូវកិច្ចការរបស់ពួកគេ នៅក្នុងថ្នាក់ ដោយអង្កេតនូវចម្លើយដើមដំបូងរបស់ពួកគេ ចំពោះឯកសារ ខ្ញុំសូមខ្ចីលុយ (May I Have a Loan? Worksheet) ដោយសរសេរ មួយកថាខណ្ឌ ឆ្លើយតបទៅនឹង សំណួរខាងក្រោម៖
    - ហេតុអ្វី អ្នកក្រីក្រ មិនអាចទទួលបាននូវប្រាក់កម្ចី ពី ធនាគារ?
    - តើមាន គំនិត ឬ យោបល់អ្វីខ្លះ អាចដោះស្រាយ បញ្ហានេះបាន?

## សកម្មភាពទី២

អង្កេតចម្លើយ ពីសកម្មភាពទី១នៅក្នុងកិច្ចពិភាក្សាក្នុងថ្នាក់ ដោយសង្ខេបនូវបញ្ហាសំខាន់ៗ, ដូចជា កង្វះខាត នៃឥណទានឲ្យអ្នកក្រីក្រ និង បន្តវដ្ត នៃភាពក្រីក្រ។ ពិភាក្សា ជាមួយសិស្សលើរបៀប អំពីការទម្លុះទម្លាយនូវវដ្ត នៃភាពក្រីក្រនេះ។

ស្នើសិស្ស ឲ្យសញ្ជឹងគិត អំពីវិធីសាស្ត្រ របស់លោក ម៉ូហាមែត យូណែស ក្នុងការផ្តល់ប្រាក់កម្ចីទៅឲ្យអ្នកក្រីក្រ និង វិធីសាស្ត្រ របស់ពួកគេនៅ សកម្មភាពទី១៖

- តើគំនិត របស់ លោក ម៉ូហាមែត យូណែស ខុសគ្នាដូចម្តេច ពីការឲ្យខ្ចីប្រាក់ លក្ខណៈប្រពៃណី?
- តើ គំនិត របស់ លោក ម៉ូហាមែត យូណែស មានផលប្រយោជន៍អ្វីខ្លះ?
- ស្នើសិស្ស ឲ្យសរសេរ នូវចម្លើយតប ជាលាយលក្ខណ៍អក្សរ ចំពោះសំណួរ៖
    - តើធនាគារ មានការទទួលខុសត្រូវ ចំពោះការជួយបញ្ចប់ ភាពក្រីក្រ?
    - តើគួរមាន ការផ្លាស់ប្តូរ ចំពោះការអនុវត្តប្រាក់កម្ចីទេ?

## សកម្មភាពទី៣

- បែងចែក ឯកសារ ស្តីពី លោក ម៉ូហាមែត យូណែស ដើម្បី ឲ្យសិស្សអានក្នុងថ្នាក់។
- អង្កេតនូវ គំនិតទាំងពីរ ដែលថា ការផ្តល់មីក្រូឥណទាន គឺជួយការបញ្ចប់វដ្តនៃភាពក្រីក្រ ព្រមទាំងសំណួរណែនាំ។
- ស្នើសិស្ស ឲ្យពិនិត្យសារជាថ្មី នូវចម្លើយតបដំបូងរបស់ពួកគេ ចំពោះ សំណួរណែនាំ
    - តើរស់នៅក្នុងភាពក្រីក្រ វាមានន័យដូចម្តេច?
    - តើអ្វីទៅជាប្រសិទ្ធភាព ដ៏យូរអង្វែងរបស់ភាពក្រីក្រ?
- ស្នើសិស្ស ឲ្យឆ្លើយតបទៅនឹង សំណួរខាងក្រោម នៅក្នុងកិច្ចពិភាក្សាក្នុងថ្នាក់៖
    - នៅពេលដែល គេដោះស្រាយបញ្ហាសេដ្ឋកិច្ចបាន តើវាអាចជាលទ្ធផលបែបណា?
    - តើមីក្រូឥណទាន អាចជួយធ្វើឲ្យភាពក្រីក្រ ទៅជារឿងអតីតកាលទេ?

# ក្លាយជាអ្នកការពារ

សិស្ស គួរតែជ្រើសរើស នូវ សកម្មភាព ខាងក្រោមមួយះ

- សិស្ស គួរតែសញ្ជឹងគិត លើវិធីសាស្ត្រថ្មី របស់ លោក ម៉ូហាមែត យូណែស ក្នុងការប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រ។ តើសិស្សនឹងឲ្យអ្នកដទៃទៀត យល់ដឹងអំពីអ្វី ដែលពួកគេបានសិក្សានោះ? សិស្ស អាចនឹងបង្កើត ឯកសារជាលាយល័ក្ខអក្សរ ឬ សិប្បកម្ម ដើម្បីចែករំលែកជាមួយ សមាជិកគ្រួសារទាំងអស់នេះ។ សិស្ស គួរតែរៀន "គិតក្រៅប្រអប់" (“thinking outside the box”, creativity, imagination) ដូច លោក ម៉ូហាមែត យូណែស។

- សិស្ស គួរតែអនុវត្តន៍ បទពិសោធន៍ ដែលបានរៀនពី លោក ម៉ូហាមែត យូណែស ចំពោះ បញ្ហាភាពក្រីក្រមូលដ្ឋាន ដោយសិក្សាស្រាវជ្រាវ នូវព្រឹត្តិការណ៍ថ្មីៗ នៅសហគមន៍។

- បន្ទាប់ពីការរកឃើញ ស្ថិតិ ឬ ព័ត៌មាន អំពី ភាពក្រីក្រនៅមូលដ្ឋាន, សិស្ស គួរតែសញ្ជឹងគិត អំពី សំណួរទាំងអស់នេះ គឺះ

  - តើភាពក្រីក្រ ប៉ះពាល់ដល់ សហគមន៍ និង រដ្ឋ នៅមូលដ្ឋាន របស់អ្នក ដោយរបៀបណា?

  - តើមីក្រូឥណទាន អាចជាដំណោះស្រាយមួយ នៅក្នុងការដោះស្រាយបញ្ហានេះ បានដែរ ឬ ទេ?

  - សិស្សគួរតែសរសេរលិខិតមួយ ផ្ញើជូនអ្នកផ្ទៀងផ្ទាត់ ឬ ធនាគារ នៅមូលដ្ឋានដោយពន្យល់ថា អ្វីដែលពួកគេបានសិក្សាអំពីមីក្រូឥណទាន ហើយមូលហេតុអ្វី ដែលពួកគេបានជឿជាក់នោះ ហើយវាអាចមានផលប្រយោជន៍ នៅក្នុងការបញ្ចប់ភាពក្រីក្រ នៅមូលដ្ឋាន។

- លោក ម៉ូហាមែត យូណែស បានជួយ ប្រទេសបង់ក្លាដែស ក្នុងការប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រ។ ប៉ុន្តែ មីក្រូឥណទាន តែម្យ៉ាង មិនអាចបំបាត់ពិតពភាពក្រីក្រនោះបានទេ។ តើយើងអាចធ្វើអ្វីទៀត?




សាខា ធនាគារ អេស៊ីលីដា ភីអិលស៊ី ខេត្តកំពង់ឆ្នាំង, ខែតុលា ឆ្នាំ២០១១

# ព័ត៌មានបន្ថែម

## ធនាគារ អេស៊ីលីដា ភីអិលស៊ី (ACLEDA Bank)

www.acledabank.com/kh

## ធនាគារក្រាមីន (The Grameen Bank)

www.grameen.com

គេហទំព័រ ធនាគារក្រាមីន ផ្តល់ព័ត៌មាន អំពី ប្រវត្តិនៃ មីក្រូឥណទាន និង ពន្យល់ ដោយពិស្តារនូវការប្រព្រឹត្តិទៅ របស់ ធនាគារ ក្នុងពេលបច្ចុប្បន្ន, ហើយថា តើធនាគារនេះ បន្តជួយប្រជាជន ដោយការទទួលបាននូវ ឥណទាន ដូចម្តេច។

## មជ្ឈមណ្ឌលយូណៃស (The Yunus Center)

www.muhammadyunus.org

មជ្ឈមណ្ឌល យូណៃស ជាអង្គការផ្ទាល់ របស់ លោកបណ្ឌិត ម៉ូហាមែត យូណៃស ធ្វើការឆ្ពោះទៅរកការបង្កើតពិភពលោករួចផុតពីភាពក្រីក្រ។ គេហទំព័រនេះ ធ្វើជាមជ្ឈមណ្ឌលសម្រាប់ព័ត៌មាន និង ឱកាសនានា ដែលទាក់ទងទៅនឹងស្នាដៃ របស់ លោកបណ្ឌិត ម៉ូហាមែត យូណៃស និង សង្គមពាណិជ្ជកម្មដទៃទៀត និង សហគ្រាស ដែលទាក់ទងនឹង មីក្រូហិរញ្ញវត្ថុ។

## កិច្ចប្រជុំកំពូលអំពី មីក្រូឥណទាន (The Microcredit Summit)

www.microcreditsummit.org

កិច្ចប្រជុំកំពូលអំពី មីក្រូឥណទាន លើកដំបូង (First Microcredit Summit) ត្រូវបានធ្វើឡើង ក្នុងខែកុម្ភៈ ឆ្នាំ១៩៩៧ ក្នុងទីក្រុង វ៉ាស៊ីនតោន ឌីស៊ី (Washington, D.C.)។ ពួកគេបានចាប់ផ្តើមយុទ្ធនាការរយៈពេល ៩ឆ្នាំ ដើម្បីឈានទៅដល់គ្រួសារក្រីក្របំផុត ចំនួន ១០០លាននាក់ ក្នុងពិភពលោក, ជាពិសេស ស្ត្រី ដោយមានឥណទាន សម្រាប់ ការងារផ្ទាល់ សេវាហិរញ្ញវត្ថុ និង ពាណិជ្ជកម្មដទៃទៀត ត្រឹមឆ្នាំ២០០៥។ ពួកគេស្ទើរតែសម្រេចគោលដៅនោះ ក្នុងឆ្នាំ២០០៥, និង ចាប់តាំងពីពេលនោះមក បានកោះប្រជុំឡើងវិញ ដើម្បីដាក់ចេញគោលដៅថ្មី។ គេហទំព័រ ផ្តល់ព័ត៌មានជាច្រើនអំពី ជំនួប និង យុទ្ធនាការកំពុងដំណើរការ។

## មីក្រូឥណទាន នៅរដ្ឋ ញូ ហាមហ្សៀ (MicroCredit-NH)

www.microcreditnh.org

ក្រុមផ្តល់ឥណទាន ដែលមានមូលដ្ឋាននៅ សហរដ្ឋអាមេរិក ធ្វើការជាពិសេសនៅ រដ្ឋ ញូ ហាមហ្សៀ (New Hampshire) ដើម្បីនាំប្រាក់កម្ចីខ្នាតតូច មកឲ្យ ពាណិជ្ជកម្មខ្នាតតូច។

## កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (United Nations Development Program, UNDP)

www.undp.org

## សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (International Finance Corporation, IFC)

www.ifc.org

## អង្គការទស្សនៈពិភពលោកកម្ពុជា (World Vision Cambodia)

www.worldvision.org

“THE FUTURE IS NOT A GIFT: IT IS AN ACHIEVEMENT. EVERY GENERATION HELPS MAKE ITS OWN FUTURE.
THIS IS THE ESSENTIAL CHALLENGE OF THE PRESENT.”

— ROBERT F. KENNEDY

# លោក ដែសមិន ធូធូ (Desmond Tutu)

“យើងមានព្រះជាម្ចាស់ដែលមិនមានបន្ទូលថា 'អុះ!... ចាប់ឯងបានហើយ!' មិនមែនទេ។ ព្រះជាម្ចាស់និយាយថា 'ចូរក្រោកឡើង។' ហើយព្រះជាម្ចាស់បបោសយើងឲ្យស្អាត ហើយមានបន្ទូលថា 'ចូរព្យាយាមម្តងទៀត'”។

ការងាររបស់មេជំនុំ ដែសមិន ធូធូ (Archbishop Desmond Tutu) ក្នុងការប្រឈមមុខនឹងភាពរើសអើង និង អំពើហិង្សា ដែលបានកើតឡើងក្រោមប្រព័ន្ធគ្រប់គ្រងដោយជនជាតិភាគតិចស្បែកស លើជនជាតិភាគ ច្រើនស្បែកខ្មៅ នៅប្រទេសអាហ្វ្រិកខាងត្បូង, ដែលយើងហៅ ការបែងចែកប្រជាជនបែបនេះថា អាផាថាយ (Apartheid), បានធ្វើឲ្យគាត់ទទួលបានរង្វាន់ណូបែលសន្តិភាពនៅក្នុងឆ្នាំ១៩៨៤ (Nobel Peace Prize)។ គាត់កើតនៅក្នុងឆ្នាំ១៩៣១ នៅតំបន់ក្លឹកស្តហ្វ (Klerksdorf), ហើយបានបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យអាហ្វ្រិក ខាងត្បូង (University of South Africa) ក្នុងឆ្នាំ១៩៥៤, ហើយគាត់បានទទួលការតែងតាំងជាអាចារ្យ (priest) ក្នុងឆ្នាំ១៩៦០។ គាត់បានសិក្សា និង បង្រៀន ក្នុងប្រទេសអង់គ្លេស និង ប្រទេសអាហ្វ្រិកខាងត្បូង, ហើយនៅក្នុងឆ្នាំ១៩៧៥ គាត់បានទទួលការតែងតាំងជាប្រធានវិហារ សេនម៉ារី (St. Mary's Cathedral) ក្នុងទីក្រុងចូហានណេសប៊ឺក (Johannesburg), គាត់គឺជាជនជាតិអាហ្វ្រិកខាងត្បូងស្បែកខ្មៅទីមួយ ដែលបានកាន់តំណែងនេះ។ ក្នុងឆ្នាំ១៩៧៨ គាត់បានក្លាយទៅជា អគ្គលេខាធិការស្បែកខ្មៅទីមួយ របស់ក្រុមប្រឹក្សាព្រះវិហារនៅអាហ្វ្រិក (South African Council of Churches)។ ដោយសារតែការនិយាយដោយឥតលាក់លៀមប្រឆាំងនឹងអំពើអាក្រក់នៃរបបអាផាថាយ (Apartheid) គាត់បានទទួលរងការមួលបង្កាច់ពីសំណាក់មិត្តភក្តិ និង សត្រូវ, ពីសំណាក់សារព័ត៌មាន និង អ្នកនយោបាយ, ប៉ុន្តែ គាត់ជំនះបាននូវរាល់ឧបសគ្គ តាមរយៈភាពជាតិនិយមដ៏អស្ចារ្យ, និង ការប្តេជ្ញាចិត្តរបស់គាត់ ចំពោះមនុស្សធម៌, ចំពោះ ចក្ខុវិស័យ, និង ទីបំផុត ចំពោះសេចក្តីជំនឿ។ បន្ទាប់ពីការបោះឆ្នោតបែបប្រជាធិបតេយ្យមិនប្រកាន់ពូជសាសន៍លើកដំបូង ក្នុងប្រទេសអាហ្វ្រិកខាងត្បូង



Archbishop Desmond Tutu, ©2000 Eddie Adams

ក្នុងឆ្នាំ១៩៩៤, ដែលបាននាំទៅដល់ការបញ្ចប់ការដឹកនាំរបស់ ក្រុមភាគតិចស្បែកសអស់រយៈកាល៨០ឆ្នាំ ដោយជោគជ័យមក, សភាថ្មីបានបង្កើត គណៈកម្មការស្វែងរកការពិត និង ការបង្រួបបង្រួម (Truth and Reconciliation Commission), ដោយបានតែងតាំង លោក ធូធូ ជាប្រធានក្នុងការដឹកនាំប្រទេសនេះ ក្នុងការប្រឈមមុខដ៏ឈឺចាប់ និង រឹងមាំទល់នឹងភាពព្រៃផ្សៃដែលបានកើតឡើងនៅក្នុងអតីតកាល។ សេចក្តីជំនឿរបស់គាត់ទៅលើព្រះជាម្ចាស់ គឺជាការគូសបញ្ជាក់អំពី ជំនឿរបស់គាត់ លើព្រះបន្ទូលដែលបានកើតមកជាមនុស្ស, សមរភូមិទាមទារជោគជ័យសម្រាប់អំពើល្អ អាចឈ្នះ, អាចចាញ់, មិនមែនដោយសារតែការបន់ស្រន់នោះទេ, តែដោយសារសកម្មភាពដែលបានប្រព្រឹត្តប្រឈមតទល់នឹង អំពើអាក្រក់នៅលើផែនដីនេះ។

សព្វថ្ងៃនេះ មេជំនុំ ដែសមិន ធូធូ (Archbishop Desmond Tutu) ជាប្រធាន “ក្រុមព្រឹទ្ធាចារ្យ” (the Elders), ដែលមានសមាជិកជាអ្នកដឹកនាំពិភពលោកល្បីល្បាញ ក្នុងការបរិច្ចាគសុចរិតភាព និង សមិទ្ធិផលសីលធម៌របស់ខ្លួន ដើម្បីរួមចំណែកដល់ការដោះស្រាយបញ្ហាដែលមានភាពចាំបាច់ខ្លាំង នៅក្នុងពិភពលោក។ សមាជិករួមមាន ណែលសិន ម៉ែនដេឡា (Nelson Mandela), កូហ្វី អាណាន់ (Kofi Annan), ម៉ារី រ៉ូប៊ីនសិន (Mary Robinson), អ៊ុងសាន ស៊ូជី (Aung San Suu Kyi), និង សមាជិកអ្នកការពារសិទ្ធិរបស់ គម្រោងសេចក្តីក្លាហានគ្មានព្រំដែន (Speak Truth to Power) គឺ ម៉ូហាម៉ែត យូណែស (Muhammad Yunus)។

អាត្រាគ្មានការងារដ៏ខ្ពស់ នៅប្រទេសអាហ្វ្រិកខាងត្បូង បានជួយជម្រុញឲ្យមាន អំពើឧក្រិដ្ឋកម្ម ក្នុងកម្រិតដ៏ធ្ងន់ធ្ងរមួយ។ បញ្ហានេះ បានជម្រុញគ្នាទៅវិញទៅមក ដោយសារថា អំពើឧក្រិដ្ឋកម្មទំនងជាបានធ្វើឲ្យអ្នកវិនិយោគបរទេសមានការភ័យខ្លាច។ ហើយអ្នកវិនិយោគមានចំនួនមិនគ្រប់គ្រាន់ ក្នុងការជះឥទ្ធិពលសំខាន់ទៅលើសេដ្ឋកិច្ច ដើម្បីអាចឲ្យដោះស្រាយកេរ្តិ៍ដំណែលដ៏គួរឲ្យរន្ធត់របស់អាផាថាយ, រួមមាន ការខ្វះខាត ផ្នែកផ្ទះសម្បែង, ផ្នែកអប់រំ, និង ផ្នែកសុខភាព។

ប្រសិនបើយើងនិយាយក្នុងភាពរស់រវើកមួយនោះ, អ្នកអាចនិយាយថាបុរសម្នាក់ និង ស្ត្រីម្នាក់នេះ បានរស់នៅក្នុងសំណង់អាណាធិបតេយ្យនៅមុនខែមេសា ឆ្នាំ១៩៩៤។ ហើយឥឡូវនេះ, បួនឆ្នាំតទៅមុខ, បុរស និង ស្ត្រីដដែលនោះ នៅតែរស់នៅក្នុងសំណង់អាណាធិបតេយ្យដដែល។ គេអាចនិយាយបានថា ប្រជាធិបតេយ្យមិនបានធ្វើឲ្យមានការកែប្រែលើការរស់នៅជាក់ស្ដែងនោះទេ, ប៉ុន្តែ នោះគ្រាន់តែជាការយល់រាក់កម្ភែលតែប៉ុណ្ណោះ។

មានការផ្លាស់ប្ដូរយ៉ាងច្រើន។មានរឿងជាច្រើនបានផ្លាស់ប្ដូរយ៉ាងសំខាន់ សម្រាប់រដ្ឋាភិបាល, ទោះបីជាមានការរឹតបន្តឹង ចំពោះធនធានជាច្រើនក៏ដោយ។ អព្ភូតហេតុ នៃឆ្នាំ១៩៩៤ នៅតែមានវត្តមាន និងបន្តមានតទៅទៀត ទោះបីជាមានកត្តារឹតបន្តឹងទាំងអស់នេះ ដែលបង្ករឲ្យមានអស្ថេរភាព។ រដ្ឋាភិបាលបានផ្ដល់ការថែទាំសុខភាព ដោយមិនចាំបាច់បង់ប្រាក់សម្រាប់កុមារអាយុក្រោម ៦ឆ្នាំ និង ម្ដាយ ដែលត្រូវឆ្លងទន្លេ។ រដ្ឋាភិបាលបានផ្ដល់អាហារនៅសាលារៀន ដោយមិនចាំបាច់បង់ប្រាក់ និង ការអប់រំមិនបង់ប្រាក់សម្រាប់ថ្នាក់បឋមសិក្សាទាំងមូល។ ប៉ុន្តែ ការផ្លាស់ប្ដូរដ៏មានសារៈសំខាន់បំផុត គឺអ្វីដែលមនុស្សមិនធ្លាប់រស់នៅក្រោមការគាបសង្កត់ មិនអាចយល់បាននោះ, គឺអ្វីដែលមានន័យថា សេរីភាព។ ខ្ញុំមានសេរីភាព។

តើឲ្យខ្ញុំពិពណ៌នាបែបណា ចំពោះអ្នកដែលធ្លាប់តែស្គាល់សេរីភាព? ឥឡូវនេះ ខ្ញុំអាចដើរបានត្រង់ខ្លួន, ពើងទ្រូង និង មានមោទនភាព ពីព្រោះថា សេចក្ដីថ្លៃថ្នូររបស់ខ្ញុំ, ដែលត្រូវគេជាន់ឈ្លីក្រោមបាតជើងយូរអង្វែងពីមុនមក, ត្រូវបានផ្ដល់ត្រលប់មកខ្ញុំវិញហើយ។ ខ្ញុំមានប្រធានាធិបតីមួយរូប ដែលខ្ញុំស្រឡាញ់, ដែលមានការកោតសរសើរទូទាំងពិភពលោក។ ពេលនេះ ខ្ញុំរស់នៅក្នុងប្រទេសមួយ ដែលអ្នកតំណាងមិនចាំបាច់ត្រាច់ចរស្ងាត់ៗ ទៅជួបសហគមន៍អន្តរជាតិទៀតឡើយ។ យើងមានការទទួលស្គាល់ពីថ្នាក់អន្តរជាតិ, ទាំងក្នុងវិស័យកីឡា និងវិស័យផ្សេងៗទៀត។ ដូច្នេះ មានការផ្លាស់ប្ដូរមួយចំនួនយ៉ាងពេញទំហឹង, ហើយក៏មានបញ្ហាមួយចំនួនទៀត មិនទាន់មានការផ្លាស់ប្ដូរនៅឡើយទេ។

នៅពេលដែលខ្ញុំបានក្លាយជាមេជំនុំ (archbishop) ក្នុងឆ្នាំ១៩៨៦, គឺជាបទល្មើសមួយ នៅពេលដែលខ្ញុំទៅរស់នៅក្នុងកន្លែងរបស់មេជំនុំ (Bishopscourt), ដែលជាទីស្នាក់នៅជាផ្លូវការរបស់ គ្រូគង្វាលគ្រិស្តសាសនា (Anglican archbishop) នៅក្នុងទីក្រុង ខេបថោន (Cape Town)។ ឥឡូវនេះ យើងរស់នៅក្នុងភូមិដែលធ្លាប់មានតែជនជាតិស្បែកស, ហើយមិនមាននរណាម្នាក់ចាប់អារម្មណ៍។ វាហាក់បីដូចជាអ្វីដែលយើងបានធ្វើជាធម្មតាក្នុងជីវិតរបស់ពួកយើង។ នៅសាលារៀនគេធ្លាប់មានការបែងចែកយ៉ាងតឹងរ៉ឹងតាមពូជសាសន៍។ ឥឡូវនេះ នៅសាលារៀន គេរៀនចូលគ្នា ដោយមិនមានការបែងចែក។ ជាការពិតណាស់ ដែលថា ជនជាតិស្បែកសមានលទ្ធភាពច្រើនជាង ក្នុងការបង់លុយរៀន នៅសាលាឯកជន។ ប៉ុន្តែ សាលារដ្ឋ ដែលពីមុនមកធ្លាប់មានការបែងចែកឥឡូវនេះលែងមានការបែងចែកដូចនោះទៀតហើយ។ បច្ចុប្បន្ននេះ អ្នកអាចមើលឃើញថា ចំនួនសិស្សនៅក្នុងសាលា ឆ្លុះបញ្ចាំងពីប្រជាសាស្ត្រចម្រុះ នៅក្នុងប្រទេសរបស់យើងទាំងមូល។

ខ្ញុំបានតស៊ូមតិ ដើម្បីឲ្យមានការដាក់ទណ្ឌកម្ម ហើយជាលទ្ធផល, សហគមន៍ជនស្បែកសភាគច្រើន បានចាត់ទុកខ្ញុំជាមនុស្សដែលគេស្អប់បំផុត។ គេធ្លាប់បាននិយាយថា “ការដាក់ទណ្ឌកម្មនឹងធ្វើឲ្យជនស្បែកខ្មៅទទួលរងទុក្ខវេទនា”។ ប៉ុន្តែ ប្រទេសអាហ្វ្រិកខាងត្បូង បានរីកចម្រើនមួយភាគធំ ដោយសារពលកម្មមានតម្លៃទាប, តាមរយៈការប្រើប្រាស់ប្រព័ន្ធកម្លាំងពលកម្មចល័តដែលគួរឲ្យស្អប់ខ្ពើម, ដោយនៅក្នុងប្រព័ន្ធនេះ បុរសស្បែកខ្មៅ បានរស់នៅក្នុងកន្លែងស្នាក់ ដែលមានតែប្រុសៗរយៈពេល ១១ខែ ក្នុងមួយឆ្នាំ។ សូម្បីតែមនុស្សនៅក្នុងមណ្ឌលរបស់ខ្ញុំ ក៏មានភាពស្រពិចស្រពិលមកលើខ្ញុំដែរ។ ហើយមានការសរសេរតាមជញ្ជាំង តាមផ្លូវថា “ខ្ញុំបានក្លាយជាអ្នកសាសនាគ្រិស្ត (Anglican) ទាល់តែខ្ញុំបានបូក “ធូ” [two] និង “ធូ” [two] ចូលគ្នា”។ មានការសរសេរខ្លះគួរឲ្យអស់សំណើចណាស់ដូចជា ថា “ព្រះស្រលាញ់ធូធូ” ហើយបន្ថែមថា “ព្រះពិតជាឆ្កួតមែន”។ ប្រសិនបើការសម្លក់អាចសម្លាប់មនុស្សបាន គេបានសម្លាប់ខ្ញុំអស់ច្រើនដងហើយ។ នៅពេលខ្ញុំឡើងជិះយន្តហោះនៅទីក្រុងចូហានណេសបឺក (Johannesburg), ឬ ជិះរថភ្លើងនៅទីក្រុងខេបថោន (Cape Town), ការសម្លក់ដែលខ្ញុំបានទទួលពីគេអាចសមល្មមនឹងធ្វើឲ្យទឹកដោះគោ ផ្អូមខាប់បាន (to curdle milk)។

ខ្ញុំបានទទួលការគម្រាមសម្លាប់ជាច្រើន, ប៉ុន្តែ នោះមិនមែនជារឿងភ្ញាក់ផ្អើលទេ ដែលមិនរំពឹងថា នឹងកើតឡើងនោះឡើយ។ ប្រសិនបើអ្នកជ្រើសរើសចូលរួមក្នុងការតស៊ូ, អ្នកនឹងក្លាយជាគោលដៅបែបនេះ។ មានមនុស្សស្លាប់ជាច្រើននៅក្នុងការតស៊ូ។ ជាការពិតណាស់ វាមិនមែនជារឿងល្អនោះទេ ដែលបានទទួលការគម្រាមកំហែង និង បញ្ហាទាំងនោះ។ ប៉ុន្តែ វាជារឿងធម្មតាទេ សម្រាប់បុព្វហេតុទាំងអស់នោះ។

នៅពេលដែលពួកគេគម្រាមកូនរបស់ខ្ញុំ, វាបានធ្វើឲ្យខ្ញុំពិបាកចិត្តណាស់, វាបានធ្វើឲ្យខ្ញុំដុនដាបខ្លាំងណាស់។ ប្រសិនបើមាននរណាម្នាក់មានបំណងគម្រាមខ្ញុំ, នោះវាមិនអីទេ។ ប៉ុន្តែ ទង្វើរបស់ពួកគេមិនមានសីលធម៌ ឬ ការគោរពសូម្បីតែបន្តិចណាសោះ។ ពួកគេអាចព្យួតាមទូរស័ព្ទថា មិនមែនជាខ្ញុំ, មិនមែនជាប្រពន្ធខ្ញុំ, ហើយវាគ្រាន់តែជាកូន

ក្មេងប៉ុណ្ណោះ។ ពួកគេ គួរតែដាក់ទូរស័ព្ទចុះ ឬ និយាយ "ហៅឪពុករបស់ឯងមក ឬ ហៅម្តាយរបស់ឯងមក"។ ប៉ុន្តែ ពួកគេមិនបានធ្វើដូចនេះទេ។

ការគម្រាមកំហែងមួយ ចេញមកពីក្រុម ដែលមានឈ្មោះថា "កម្ម៉ង់ដូពណ៌ស"។ ពួកគេបាននិយាយថា ខ្ញុំត្រូវតែចាកចេញពីក្នុងប្រទេសឲ្យបានមុនថ្ងៃកំណត់មួយ, បើមិនដូច្នោះទេ ពួកគេនឹងកម្ទេចខ្ញុំចោល។ យើងបានប្រាប់ប៉ូលីស, ដែលបានបង្ហាញភាពកំប្លែងស្ងួតមួយក្នុងការនិយាយថា "តើលោកអាចជួយពួកយើងបានទេ គឺថាដល់ពេលថ្ងៃកំណត់នោះ សូមលោកនៅលើគ្រែបានដែរឬទេ ?"

ខ្ញុំគិតថា គ្រួសាររបស់ខ្ញុំនឹងមានអារម្មណ៍ថា ពួកគេមិនស្មោះត្រង់នឹងខ្ញុំ ប្រសិនបើ ពួកគេគាបសង្កត់ឲ្យខ្ញុំផ្លាស់ប្តូរ។ ខ្ញុំបានសួរប្រពន្ធខ្ញុំឈ្មោះ លេអា (Leah) មួយដងថា "តើអូនចង់ឲ្យបងនៅស្ងាត់ស្ងៀមដែរឬទេ ?" ខ្ញុំមិនដែលទទួលបានការបញ្ជាក់អះអាងដ៏អស្ចារ្យជាងពេលដែលប្រពន្ធរបស់ខ្ញុំនិយាយថា "ពួកយើងសុខចិត្តរស់នៅក្នុងភាពមិនសប្បាយចិត្ត ប្រសិនបើ គេចាប់បងដាក់លើកោះរ៉ូបិន (ជាគុកលើកោះនៅក្នុងប្រទេស អាហ្វ្រិកខាងត្បូង សម្រាប់ដាក់អ្នកទោសនយោបាយស្បែកខ្មៅ), ជាងឃើញបងមិនសប្បាយចិត្តដោយគិតថា ខ្លួនឯងមានសេរីភាព (ក្នុងន័យថា ខ្ញុំមិនស្មោះស្ម័គ្រចំពោះអ្វីដែលខ្ញុំជឿថា ព្រះ ជាអ្នកជម្រុញចិត្តរបស់ខ្ញុំ)"។ ក្រៅពីនេះ អ្វីទាំងអស់នឹងមានរស់ជាតិដូចផេះអញ្ចឹង។ វានឹងជាការរស់នៅក្នុងភាពកុហក។ ហើយ វាមិនមានហេតុផលអ្វី ដែលត្រូវរស់នៅក្នុងសភាពបែបនោះទេ។ ខ្ញុំបានគិតថា ខ្ញុំគួរតែបានក្លាយជាចំណែកមួយ ក្នុងការតស៊ូ ក្នុងតំណែងមួយ ដែលមិនសូវមានការចាប់អារម្មណ៍។ ប៉ុន្តែ ព្រះជាម្ចាស់បាន, ដូចភាសាគេច្រើនតែប្រើ, ថា "ទាញកអាវខ្ញុំពីខាងក្រោយ" ដូចព្យាការីយេរេមា (Jeremiah) ដែលខ្ញុំគិតថា ជាតួអង្គ ដែលមានភាពទាក់ទាញខ្លាំង ដោយសារគាត់បានត្អូញត្អែរថា "ព្រះអង្គ, ព្រះអង្គបានបោកប្រាស់ខ្ញុំ។ ព្រះអង្គបានមានបន្ទូលថា ខ្ញុំនឹងបានក្លាយទៅជាព្យាការី (prophet)។ ប៉ុន្តែ អ្វីគ្រប់យ៉ាងដែលព្រះអង្គបានឲ្យខ្ញុំធ្វើ គឺខ្ញុំត្រូវនិយាយ អំពីសេចក្តីវិនាស, ការកាត់សេចក្តី និង ការរិះគន់ប្រឆាំងនឹងមនុស្ស ដែលខ្ញុំស្រលាញ់យ៉ាងខ្លាំង។ ប៉ុន្តែ ប្រសិនបើ ខ្ញុំព្យាយាមមិននិយាយពាក្យរបស់ ព្រះអង្គ ចង់ឲ្យខ្ញុំនិយាយទេ, វាដូចជាមានភ្លើងឆេះនៅក្នុងដើមទ្រូងរបស់ខ្ញុំអញ្ចឹង, ហើយវាធ្វើឲ្យខ្ញុំមិនអាចទ្រាំបានទេ"។

ឥឡូវនេះ អ្នកមិនជឿទេថា វាជាប្រទេសដដែល។ ភាពរីករាយក្នុងការសម្របខ្លួនពិតជាអស្ចារ្យណាស់។ ឥឡូវនេះ វាសឹងតែផ្ទុយគ្នាស្រឡះ។ ខ្ញុំចង់និយាយថា នៅតាមផ្លូវ មនុស្សឈប់តាមផ្លូវដើម្បី ចាប់ដៃ និង ជជែកជាមួយខ្ញុំ។ ពេលដែលយើងដឹងថា ខ្ញុំមានជម្ងឺមហារីក ខ្ញុំបានទទួលលិខិតជូនពរពីតំបន់ដែលយើងមិនស្មានដល់។ តិចណាស់ក្នុងពេលមួយ, មានស្ត្រីស្បែកសម្នាក់ បានចង់ជួយលើកកាតាបរបស់ខ្ញុំ ហើយគ្រួសាររបស់គាត់បានផ្តល់កន្លែងអង្គុយមកឲ្យខ្ញុំ។ ត្រូវហើយ វាជាការផ្លាស់ប្តូរមួយ វាហាក់ដូចជា យើងកំពុងស្ថិតនៅក្នុងប្រទេសមួយផ្សេងទៀត។

យើងដឹងថា ប្រទេសរបស់យើងមានជម្រើសមិនសូវច្រើនប៉ុន្មានទេ។ យើងមិនអាចជ្រើសយកជម្រើសតាមរយៈ ការកាត់ទោសបែបតុលាការនៅទីក្រុងណ៍រឹមប៊ឹក (Nuremberg trial) នោះទេ ពីព្រោះយើងមិនមាន អ្នកឈ្នះ និង អ្នកចាញ់ ពិតប្រាកដលាស់។ យើងអាចនឹងជ្រើសជម្រើសការលើកទោសទាំងស្រុង ហើយនិយាយថា បំភ្លេចរឿងអតីតកាលចោល រួចចាប់ផ្តើមសារជាថ្មី។ ប៉ុន្តែ យើងមិនបានជ្រើសយកជម្រើសណាមួយនោះទេ។ យើងមិនបានជ្រើសយកផ្លូវសងសឹក, ប៉ុន្តែ យើងបានជ្រើសរើសយកផ្លូវលើកលែងទោសសម្រាប់បុគ្គល, ផ្តល់សេរីភាពសម្រាប់ប្តូរយកការពិត, សម្រាប់អ្នកដែលបានដាក់ពាក្យសុំការអភ័យទោសនៅក្នុងវេទិកាបើកចំហ, ដើម្បីឲ្យពិភពលោក និង អ្នកដែលមានការពាក់ព័ន្ធជិតស្និទ្ធនឹងរឿងរ៉ាវទាំងនេះ បានដឹងពីអ្វីដែលបានកើតឡើង។ យើងបានគិតគូរជាពិសេស ចំពោះដំណើរការក្នុង នីតិវិធីអន្តរកាល ដែលមានភាពផុយស្រួយយ៉ាងខ្លាំង។ យើងបាននិយាយថា យើងចង់បានស្ថេរភាព, ប៉ុន្តែ វាត្រូវតែពឹងផ្អែកទៅលើការពិត ដើម្បីឲ្យការបញ្ចប់អាចកើតឡើងបានលឿនបំផុត។

យើងមិនគួរខ្លាចការប្រឈមមុខជាមួយនឹងមនុស្ស ដែលបានប្រព្រឹត្តខុសនោះទេ។ ការអភ័យទោសមិនមែនមានន័យថា ជាការប្រែខ្លួនយើងឲ្យក្លាយទៅជាកម្រាលដាក់នៅមាត់ទ្វារ សម្រាប់គេជូតជើងឡើយ។ ព្រះអង្គរបស់យើងតែងតែអត់អោនទោសខ្លាំងណាស់។ ប៉ុន្តែ ព្រះរបស់យើងតែងតែប្រឈមមុខនឹងអ្នកដែលមានអំណួតពោរពេញខ្លួន, និង បានប្រព្រឹត្តអំពើអាក្រក់, ហើយព្រះអង្គបានហៅពួកនោះថាជា "ជំនាន់ពស់វែក"។

ការអភ័យទោសមិនមែនមានន័យថា ជាការធ្វើពុតមិនដឹងមិនឮថាមិនមានរឿងកើតឡើងនោះទេ។ ការអភ័យទោស គឺជាការទទួលស្គាល់ថា ភាពឃោរឃៅបានកើតឡើង។ ហើយការអភ័យទោសមិនមែនជាការព្យាយាមលាក់បាំងកំហុស ហើយមិនព្រមដោះស្រាយ, ដូចដែលគ្រប់គ្នាតែងតែនិយាយថា "រឿងមិនល្អពីអតីតកាលកុំរំឭកអី បំភ្លេចវាចោលទៅ"។ ពីព្រោះ វាមិនអាចបំភ្លេចបាននោះទេ។ អតីតកាលនេះមានសមត្ថភាពយ៉ាងអស្ចារ្យ ក្នុងការត្រលប់មកលងអ្នកទៀត។ ការអភ័យទោសមានន័យថា ជនរងគ្រោះ និង ពិរុទ្ធជន ត្រូវទទួលស្គាល់ថារឿងរ៉ាវនោះបានកើតឡើង។ ហើយ ចាំបាច់ត្រូវមានវិធានការសម្រាប់ការប្រឈមនេះ។ ជួនកាលគេគិតថា អ្នកមិនគួរធ្វើជ្រុលពេកនោះទេ។ ក៏ប៉ុន្តែ ជួនកាល អ្នកត្រូវតែធ្វើឲ្យជនណាម្នាក់ទទួលស្គាល់ថា គេបានធ្វើខុស។ នៅពេលដែលជនប្រព្រឹត្តខុសនោះបាននិយាយថា "ខ្ញុំសូមទោស," ពេលនោះ ជនដែលបានរងគ្រោះត្រូវតែមានភារកិច្ចក្នុងការលើកលែងទោស ពិសេសប្រសិនបើជនរងគ្រោះនោះជាគ្រិស្តសាសនិក។ ហើយការអភ័យទោសមានន័យថា ជាការផ្តល់ឱកាសជាក់ស្តែងសម្រាប់ការចាប់ផ្តើមសារជាថ្មី។

វាប្រៀបដូចជា នរណាម្នាក់កំពុងអង្គុយ នៅក្នុងបន្ទប់សើម ហើយត្រជាក់, មានក្លិនឃ្វើះៗ។ បិទបង្អួចជិត និង ទាញវាំងនននបិទជិត។ ប៉ុន្តែ នៅខាងក្រៅបន្ទប់ មានកំដៅថ្ងៃចាំង។ មានខ្យល់អាកាសបរិសុទ្ធ។ ការអភ័យទោស ប្រៀបបាននឹងការ បើកវាំងនន, បើកបង្អួច, មានពន្លឺ និង ខ្យល់ បានចូលទៅក្នុងជីវិតរបស់បុគ្គល ដែលមានសភាពដូចជាបន្ទប់សើមហើយត្រជាក់នោះ, ហើយផ្ដល់ឱកាសដល់ពួកគេក្នុងការចាប់ផ្ដើមសារជាថ្មី។ អ្នក និង ខ្ញុំ ដែលជាគ្រិស្តសាសនិក គឺជាអ្នកដែលមានសេចក្ដីជំនឿល្អ ពីព្រោះ វាជាសេចក្ដីជំនឿ ដែលថា ការចាប់ផ្ដើមសារជាថ្មីតែងតែអាចកើតឡើងវិញបាន។ "យើងមានព្រះជាម្ចាស់ ដែលមិនមានបន្ទូលថា 'អុះ!... ចាប់ឯងបានហើយ!' មិនមែនទេ។ ព្រះជាម្ចាស់និយាយថា 'ចូរក្រោកឡើង។' ហើយព្រះជាម្ចាស់បបោសយើងឲ្យស្អាត ហើយមានបន្ទូលថា 'ចូរព្យាយាមម្ដងទៀត'"។

មានឧទាហរណ៍មួយ, ខ្ញុំបានបង្រៀន នៅក្នុងព្រះវិហារល្អឆើតឆាយមួយ ដែលមានមនុស្សឋានៈខ្ពស់ៗមួយចំនួន នៅក្នុងសហគមន៍ជនស្បែកស (Afrikaans) ជាវិហាររបស់ពួកស្បែកសនេះ (Dutch Reformed Church), ហើយខ្ញុំប្រហែលជាជនស្បែកខ្មៅដំបូងបំផុត ដែលបានធ្វើការងារនេះ។

ខ្ញុំបាននិយាយអំពី អ្វីដែលយើងបានរកឃើញនៅក្នុង គណៈកម្មការស្វែងរកការពិតនិងការបង្រួបបង្រួម (Truth and Reconciliation Commission)។ ឧទាហរណ៍ រដ្ឋាភិបាលមុនបានបង្កើតកម្មវិធីសង្គ្រាមជីវសាស្ត្រ និង គីមីសាស្ត្រ ដែលមិនមែនសម្រាប់តែការការពារទេ, ហើយគេថែមទាំងបានស្វែងរកមេរោគ ដែលអាចវាយប្រហារតែទៅលើជនស្បែកខ្មៅ។ ពួកគេចង់បំពុល លោក ណែលសិន ម៉ែនដេឡា (Nelson Mandela) ដើម្បីកុំឲ្យគាត់រស់បានយូរក្រោយពេលគេដោះលែងគាត់ពីពន្ធនាគារ។ មានគ្រូគង្វាលម្នាក់ នៅក្នុងព្រះវិហារនោះ បានចូលមកកន្លែងខ្ញុំឈរ, ហើយទ្រហោយំ និង បាននិយាយថា គាត់ជាអ្នកអប់រំសាសនាដល់ពួកយោធាអស់រយៈពេល៣០ឆ្នាំ តែមិនបានដឹងរឿងទាំងនោះសោះ។ គាត់សង្ឃឹមថា គាត់នឹងត្រូវគេលើកលែងទោសឲ្យ ហើយខ្ញុំក៏បានឱបគាត់។ ក៏មានអ្នកខ្លះទៀត ដែលមិនមានភាពស្មោះត្រង់។ ប៉ុន្តែ ជាទូទៅក៏មានមនុស្សផ្សេងទៀត ដែលបាននិយាយថា "ខ្ញុំសូមទោស"។ ប្រជាជនរបស់យើងភាគច្រើន បានត្រៀមខ្លួនរួចជាស្រេចក្នុងការអភ័យទោស។

ប៉ុន្តែ ក៏មានមនុស្សដែលមិនទាន់អាចអភ័យទោសដល់អ្នកដទៃបាន ដូចជា គ្រួសាររបស់ ស្ទីវ ប៊ីកូ (Steve Biko)។ នេះបង្ហាញថា ពួកយើងកំពុងដោះស្រាយជាមួយរឿងរ៉ាវ ដែលមិនមែនគ្រាន់តែរាក់កំផ្លែលនោះទេ។ ការអភ័យទោសនេះ មិនមែនជារឿងដែលគ្មានតម្លៃនោះទេ។ វាមិនមែនជារឿងងាយស្រួលនោះទេ។ ការទទួលបានការបង្រួបបង្រួមក្នុងចិត្ត មិនមែនជារឿងងាយស្រួលនោះទេ។ ហើយរឿងទាំងអស់នេះធ្វើឲ្យយើងមានការចាប់រំពុកអំពីនេះ។

រឿងដ៏អស្ចារ្យមួយ ក្នុងចំណោមរឿងជាច្រើននោះ គឺចំនួនអ្នកដែលបានរងការឈឺចាប់ដ៏ធ្ងន់ធ្ងរបំផុត បានត្រៀមខ្លួនរួចជាស្រេចក្នុងការអភ័យទោស, គឺអ្នកដែលយើងគិតថា អាចនឹងបន្តរស់នៅក្នុងភាពល្វីងជូរចត់ និង គំនុំគំគួនចង់តែសងសឹក។ ការសម្លាប់រង្គាលមួយ បានកើតឡើង នៅពេលដែលពួកទាហានបើកការបាញ់រះ ទៅលើការធ្វើបាតុកម្មមួយដឹកនាំដោយ សមាជជាតិអាហ្វ្រិក (African National Congress ឬ ANC), ដែលក្នុងនោះបានធ្វើឲ្យស្លាប់មនុស្សប្រហែល ២០នាក់ និង របួស ជាច្រើននាក់ផ្សេងទៀត។ យើងបានរៀបចំសវនាការមួយ ដែលមានមនុស្សចូលរួមពេញ ហើយអ្នកទាំងនោះជាអ្នកដែលមានសមាជិកគ្រួសារស្លាប់ ឬ របួសក្នុងព្រឹត្តិការណ៍នោះ។ មានមន្ត្រី ៤នាក់, ជនស្បែកសម្នាក់ និង ជនស្បែកខ្មៅ ៣នាក់, បានបង្ហាញខ្លួន។ ជនស្បែកសនោះ បាននិយាយថា "យើងបានផ្ដល់បញ្ជាឲ្យទាហានបើកការបាញ់ប្រហារ", ហើយនៅក្នុងបន្ទប់នោះ ភាពតានតឹងកាន់តែមានភាពតឹងតែងឡើង។ ហើយគាត់បានបែរទៅកាន់អ្នកចូលរួម, រួចនិយាយថា "សូមអភ័យទោសឲ្យខ្ញុំផង ហើយសូមមេត្តាទទួល សហការី របស់ខ្ញុំត្រលប់ទៅក្នុងសហគមន៍វិញផង"។ អ្នកចូលរួម ដែលកំពុងតែមានការខឹងសម្បារបានទះដៃយ៉ាងខ្លាំងស្ទើរបែកក្រដាសត្រចៀក។ វាជាវេលាមួយមិនគួរឲ្យជឿ។ ខ្ញុំបាននិយាយថា "សូមយើងរក្សាភាពស្ងៀមស្ងាត់, ពីព្រោះយើងកំពុងស្ថិតក្នុងវត្តមាននៃភាពបរិសុទ្ធ"។



វេទិកាសាធារណៈស្ដីពី យុត្តិធម៌ និង ការបង្រួបបង្រួម
នៅខេត្តតាកែវ ឆ្នាំ២០០៨

# ការបង្រួបបង្រួម

## លោក ដែសមិន ធូធូ — បញ្ហាសិទ្ធិមនុស្ស៖ យុត្តិធម៌

### សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស
- មាត្រា៦៖ សិទ្ធិ ក្នុងការទទួលស្គាល់ជាបុគ្គល មុខច្បាប់
- មាត្រា៧៖ សិទ្ធិ មានសមភាព មុខច្បាប់
- មាត្រា៨៖ សិទ្ធិមានមធ្យោបាយដោះស្រាយតាមតុលាការមានសមត្ថកិច្ច

### សំណួរណែនាំ
- តើអ្វីជាវិធីសាស្ត្រដើម្បីដោះស្រាយជម្លោះ?
- តើអ្វីជា តម្រូវការ ដើម្បីសមស្របសម្រាប់ការបង្រួបបង្រួម ឲ្យបានជោគជ័យ?

### តម្រូវការពេលវេលា៖ ៨០នាទី

### គោលបំណង
បន្ទាប់ពីមេរៀននេះ សិស្សនឹងអាច៖
- យល់ដឹងថា តើ លោក ដែសមិន ធូធូ ជាអ្នកណា, ហើយមូលហេតុអ្វី បានជាគាត់ក្លាយជាអ្នកទទួលបានពានរង្វាន់ ណូបែលសន្តិភាព និង ជាអ្នកការពារសិទ្ធិមនុស្ស។
- បញ្ជាក់ច្បាស់អំពី វិធីសាស្ត្រ ខុសគ្នា ក្នុងការសម្រេចបាននូវ យុត្តិធម៌ និង ដោះស្រាយនូវជម្លោះ។
- ធ្វើឲ្យរីកចម្រើននូវ មធ្យោបាយសន្តិភាព ចំពោះដំណោះស្រាយជម្លោះ។

### ជំនាញរបស់សិស្ស
- ធ្វើការពិចារណា
- ធ្វើសេចក្តីសន្និដ្ឋាន
- រៀបចំ និង បកស្រាយ ព័ត៌មាន
- ការរិះរក និង តក្កវិទ្យា
- កិច្ចពិភាក្សាជាក្រុម

### វាក្យស័ព្ទ
- ការបង្រួបបង្រួម (reconciliation)
- អាផាថាយ (Apartheid)
- ជនស្បែកសភាគតិចនៅអាហ្វ្រិកខាងត្បូង (Afrikaner)
- ស្នេហាមាតុភូមិ (patriotism)
- ការស្តារឡើងវិញនូវយុត្តិធម៌ (restorative justice)
- ការបង្ក្រាប (repression)
- មុនជម្លោះ (post-conflict)
- ការសងសឹក
- ប្រល័យពូជសាសន៍ (genocide)
- ការលើកលែងទោស (amnesty)
- សមាជជាតិអាហ្វ្រិក (African National Congress)

### គោលគំនិត
- យុត្តិធម៌
- សិទ្ធិមនុស្ស
- ការទទួលខុសត្រូវបុគ្គល

### ព័ត៌មានគ្រូបង្រៀន
- សិស្ស គួរតែមានការណែនាំលើ ករណីមួយនៃជម្លោះផ្ទៃក្នុងនយោបាយ និង ជាតិសាសន៍។
- ត្រូវបង្រៀនមេរៀននេះ ក្រោយពីសិស្សបានសិក្សាអំពីបញ្ហាក្រោយសង្គ្រាមលោកលើកទី២ និង បញ្ហាពិភពលោក។

### សម្ភារៈសិក្សា
ធ្វើបទសម្ភាស ជាមួយ លោក ដែសមិន ធូធូ សេចក្តីក្លាហានគ្មានព្រំដែន
www.speaktruth.org




វេទិកាសាធារណៈស្តីពី យុត្តិធម៌ និង ការបង្រួបបង្រួម
នៅខេត្តឧត្តរមានជ័យ ឆ្នាំ២០០៨

# សកម្មភាពរបស់សិស្ស

## ស្ថានភាពព្រាងទុក

- គ្រូបង្រៀន ត្រូវស្នើសិស្ស ឲ្យអាន បទសម្ភាស ជាមួយ លោក ដេសមិន ធូធូ និង "សច្ចភាព និង ការផ្សះផ្សា"។ (និមិត្តសញ្ញា សម្រាប់ ការទំនាក់ទំនង នៅក្នុងមេរៀននេះ សិស្ស នឹងទទួលបាន ការយល់ដឹងទូលំទូលាយ អំពីមធ្យោបាយ នានា ក្នុងការដោះស្រាយជម្លោះ។
- បន្ទាប់ពីការអាន បទសម្ភាស និង ការពិនិត្យមើល វីដេអូ, សូមរៀបចំ កិច្ចពិភាក្សា ក្នុងថ្នាក់ ដោយផ្អែកលើ សំណួរទាំងអស់នោះ។

  ធ្វើបទសម្ភាសៈ

  - តើ លោក ដេសមិន ធូធូ កំណត់នូវ ភាពអត់អោន ដូចម្ដេច?
  - តើគាត់សរសេរអំពី ឧទាហរណ៍ នៃភាពអត់អោន ដូចម្ដេច?

  វីដេអូៈ

  - តើអ្វីទៅជា មធ្យោបាយទាំងបី ដែល លោក ដេសមិន ធូធូ ផ្ដល់ឲ្យជា ឧទាហរណ៍ លើរបៀបដោះស្រាយ នូវ ការបង្រួបបង្រួមមុនពេលជម្លោះ? សូមអ្នកធ្វើការបកស្រាយអំពី ឧទាហរណ៍នីមួយៗ
- តើលោក ដេសមិន ធូធូ មានន័យ ដូចម្ដេច នៅពេលដែលគាត់បាន និយាយថា, "អតីតកាលមិនឈប់សម្រាកនៅស្ងៀម ទេ" ("The past refuses to lie down quietly") ដែលទាក់ទងនឹងការបង្រួបបង្រួម បន្ទាប់ពី អាផាថាយ (Apartheid) ត្រូវបាន ដាក់នៅក្រៅច្បាប់?

## សកម្មភាពទី១

- សកម្មភាពចលនាៈ
  - សូមសរសេរ ពាក្យខាងក្រោម នៅលើ ផ្ទាំងក្រដាស និង បិទ វា នៅលើជញ្ជាំង ថ្នាក់រៀន, គឺៈ ការដាក់ទណ្ឌកម្ម, ការសងសឹក, ការបង្រួបបង្រួម និង កម្មពៀរ (retribution)។
  - ស្នើសិស្ស ឲ្យសរសេរ "គំនិតដំបូង" របស់ពួកគេ អំពីពាក្យនីមួយៗ។
  - បន្ទាប់ពីពួកគេ បានបញ្ចប់ការឆ្លើយតប ទៅនឹងពាក្យនីមួយៗ, សូមស្នើសិស្សឲ្យ សរសេរពាក្យមួយ ឬ សេចក្ដីថ្លែងការណ៍ ស្របតាមពាក្យសមរម្យ។
  - សូមបែងចែកសិស្ស ជា ៤ក្រុម និង ចែកពាក្យមួយ ទៅក្រុមមួយ។ សូមឲ្យក្រុមនីមួយៗ ពិភាក្សាគ្នា និង ផ្ដល់គំនិតរួមគ្នា អំពីពាក្យដែលបាន ផ្ដល់ឲ្យ។
- ក្នុងថ្នាក់ សូមពិភាក្សា អំពីការឆ្លើយតប និង សម្រេចថា តើវិធីសាស្ត្រមួយណានឹង បង្កើតឲ្យមានដំណោះស្រាយ ល្អបំផុត។

## សកម្មភាពទី២

- សូមផ្ដល់ ឲ្យសិស្សនូវ សេចក្ដីដកស្រង់ ដូចខាងក្រោម និងពិភាក្សា អំពីអត្ថន័យ របស់វាៈ
  - "ប្រសិនបើយើងមិនអាចអធ្យាស្រ័យ បានទេ យើងមិនអាចមានសេរីភាព ទេ"។ លោក ណែលសិន ម៉ែនដេលា (Nelson Mandela) ជាសកម្មជន ប្រឆាំងនឹងការរើសអើងពូជសាសន៍, ជា អតីតប្រធានាធិបតី ប្រទេស អាហ្វ្រិកខាងត្បូង)
  - "ប្រសិនបើ អ្នកចង់បានសន្តិភាព ជាមួយសត្រូវ របស់អ្នក, អ្នកត្រូវ ធ្វើការជាមួយសត្រូវរបស់អ្នក។ បន្ទាប់មក គេនឹងក្លាយជាដៃគូ របស់អ្នក"។ (Nelson Mandela)
  - "ការបង្រួបបង្រួម គឺដើម្បីយល់ដឹងអំពី គូភាគីទាំងពីរ។ ទៅកាន់ភាគីម្ខាង, ហើយ បរិយាយ អំពី ការឈឺចាប់ ដែលភាគីមួយទៀត បានទទួល រងការអត់ធ្មត់, ហើយបន្ទាប់មកទៀត ទៅកាន់ភាគីមួយទៀត និង អត់ទ្រាំនូវ ការឈឺចាប់ ដែលភាគីទីមួយ បាន ទទួល"។ លោក ធីក ណាត ហាន (Thich Nhat Hanh) ជា ព្រះសង្ឃ និង សកម្មជន វៀតណាម)
- សូមបែងចែក សិស្សជាពីរក្រុម សម្រាប់ ការពិភាក្សាគ្នា។ សូមទុកពេលឲ្យសិស្ស ដើម្បីពិភាក្សាគ្នា អំពី យុទ្ធសាស្ត្ររបស់ ពួកគេ សម្រាប់ការពិភាក្សា និង សរសេរ អំពីចំណុចពិភាក្សា។
  - ភាគីមួយ ត្រូវអះអាងថា ការ បង្រួបបង្រួម គឺជាការចាំបាច់។
  - ភាគីមួយទៀត ត្រូវតែអះអាងប្រឆាំង នឹងការបង្រួបបង្រួម។
- ការបង្រួបបង្រួម ដាក់បញ្ចូលទាំងយុត្តិធម៌។
- ប្រើប្រាស់នូវសេចក្ដីដកស្រង់នេះៈ
  - "ការបង្រួបបង្រួម ត្រូវអមដោយ យុត្តិធម៌, បើមិនដូច្នោះទេ វានឹង មិនប្រព្រឹត្តទៅបានទេ។ ខណៈដែល យើងទាំងអស់គ្នា មានសង្ឃឹមថា នឹង មានសន្តិភាព វានឹងមិនមានសន្តិភាព ទេ ទោះក្នុងតម្លៃណាមួយក៏ដោយ ប៉ុន្តែ សន្តិភាពបានពឹងផ្អែកលើ គោលការណ៍ និង យុត្តិធម៌"។

(Corazon Aquino ជាអតីតប្រធានាធិបតី នៃប្រទេសហ្វីលីពីន, ជាប្រធានាធិបតីស្ត្រីទីមួយនៅទ្វីបអាស៊ី )

- សូមចង្អុលប្រាប់ បញ្ហា ដែលកំពុងបន្តក្នុងបណ្តាប្រទេស ឬ សម្រាប់ក្រុមមិនមានការបង្រួបបង្រួម។
- សូម ឲ្យសិស្សព្យាយាម គិតអំពីប្រទេសផ្សេងៗទៀត ដែលក្នុងនោះការបង្រួបបង្រួម បានទទួលជោគជ័យ ឬ បរាជ័យ។
- សិស្ស គួរតែជ្រើសរើស ប្រទេស ឬ តំបន់មួយ ដែលបានជ្រើសរើស និង សរសេរ អំពីការអត់អោនមួយ កថាខ័ណ្ឌពី ទស្សនៈយល់ឃើញ នៃ ភាគីនីមួយៗទៅឲ្យភាគីមួយទៀត។

## ក្លាយជាអ្នកការពារ

ក្លាយជាអ្នកការពារ

- សូមចាប់ផ្តើមកម្មវិធីបង្រួបបង្រួម នៅសាលារបស់អ្នក។

ហើយ សូមចូលរួម ។




សហព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជា នៅខេត្តព្រៃវែង ឆ្នាំ២០០៩



ព្រះសង្ឃចូលរួមវេទិកាសាធារណៈស្តីពី យុត្តិធម៌ និង ការបង្រួបបង្រួម នៅខេត្តព្រៃវែង ឆ្នាំ២០០៩

# ព័ត៌មានបន្ថែម

### បណ្តាញធនធានបង្រួបបង្រួម
### (Reconciliation Resource Nework)

www.idea.int

បណ្តាញធនធានបង្រួបបង្រួមនេះ គឺជាកម្មវិធីផ្តួចផ្តើម តាមប្រព័ន្ធអ៊ីនធឺណិតមួយ ដែលបានសម្របសម្រួលដោយ អង្គការអាយឌៀ អន្តរជាតិ (International IDEA)។ បណ្តាញនេះ មានអ្នកជំនាញខាងការបង្រួបបង្រួម និង រៀបចំកិច្ចប្រជុំតាមពេលកំណត់ ដើម្បីគាំទ្រការអភិវឌ្ឍជារួម នៃកិច្ចការរបស់បណ្តានេះ។

### អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (Extraordinary Chambers in the Courts of Cambodia, ECCC)

www.eccc.gov.kh

### សារៈមន្ទីរប្រល័យពូជសាសន៍ទួលស្លែង
### (Tuol Sleng Genocide Museum)

www.tuolslengmuseum.com

### មជ្ឈមណ្ឌលឯកសារកម្ពុជា
### (Documentation Center of Cambodia, DC-Cam)

www.dccam.org

### ស៊ីវីកហ្គុស៖ មជ្ឈមណ្ឌលអប់រំអំពីពលរដ្ឋខ្មែរ
### (CIVICUS: Center for Cambodian Civic Education)

www.civicus-cam.org

### ភាពយន្តអំពី ស-២១៖ ម៉ាស៊ីនពិឃាតខ្មែរក្រហម ផលិតដោយ លោក ប៉ាន់ រិទ្ធី (Documentary S-21: The Khmer Rouge Killing Machine, Rithy Panh)

www.en.wikipedia.org

### ភាពយន្ត ប្រឈមមុខនឹងអំពើប្រល័យពូជសាសន៍ ផលិតដោយ ក្រុមហ៊ុនស្តូរី នៅប្រទេសស៊ុយអែត (Documentary Facing Genocide, Story Production, Sweden)

www.story.se

### ភាពយន្ត *សត្រូវរបស់ប្រជាពលរដ្ឋ* ផលិតដោយ លោក ថេត សម្បត្តិ និង លោក រ៉ប់ ឡែមគីន (Documentary Enemy of the People, Thet Sambath, Rob Lemkin)

www.enemiesofthepeoplemovie.com

### អង្គការក្រៅរដ្ឋាភិបាល
### (Non-Governmental Organizations)

www.loc.gov

បញ្ជី នៃអង្គការនានា ដែលធ្វើការឆ្ពោះទៅរកការបង្រួបបង្រួម នៅប្រទេសអាហ្វ្រិក។

### ការផ្លាស់ប្តូរជម្លោះ និង ការបង្រួបបង្រួម នៅប្រទេសរ្វ៉ាន់ដា (Conflict Transformation and Reconciliation in Rwanda)

www.peacemakers.ca

### RwandaPeaceLinks.html

គេហទំព័រនេះ បង្ហាញពីបញ្ជីរបស់អង្គការនានា ដែលធ្វើការកសាងសន្តិភាព នៅក្នុងប្រទេស រ្វ៉ាន់ដា (Rwanda)។ បញ្ជីនេះ មានរដ្ឋាភិបាលពីរ និង អង្គការសង្គមស៊ីវិល ហើយត្រូវបានពិនិត្យផ្ទៀងផ្ទាត់ដ៏ទូលំទូលាយ ដោយថ្នាក់ដឹកនាំរបស់ខ្លួន។

### ពណ៌សម្បុរ និង ការបង្រួបបង្រួម
### (Race and Reconciliation)

www.mott.org

មូលនិធិ Charles Stewart Mott ផ្តល់មូលនិធិដល់អង្គការជាច្រើន ដែលធ្វើការនៅ អាហ្វ្រិកខាងត្បូង និង ប៉ាល់កាន់បស្ចឹម ក្នុងគោលបំណងពុះពារលើកេរ្តិ៍ដំណែលជម្លោះហិង្សាពូជសាសន៍ ឬ ជាតិសាសន៍។

### ការទំនាក់ទំនងស្និទ្ធស្នាល នៃការបង្រួបបង្រួម
### (The Fellowship of Reconciliation)

www.forusa.org

អង្គការ ទំនាក់ទំនងស្និទ្ធស្នាល នៃការបង្រួបបង្រួម (Fellowship of Reconciliation), ដោយមានប្រវត្តិការងារ ជិត១០០ឆ្នាំ ធ្វើការដើម្បីសន្តិភាព, យុត្តិធម៌ និង លុបបំបាត់អំពើហិង្សា, ផ្តោតទៅលើ អំណាចនៃ សកម្មភាព ប្រកបដោយការអាណិតអាសូរ ដោយបុគ្គលម្នាក់ៗ នៅទូទាំងពិភពលោក ចំពោះកិច្ចការ របស់ពួកគេ ដើម្បីការការបង្រួបបង្រួមគ្នា។

"THE FUTURE DOES NOT BELONG TO THOSE WHO ARE CONTENT WITH TODAY, APATHETIC TOWARD COMMON PROBLEMS AND THEIR FELLOW MAN ALIKE, TIMID AND FEARFUL IN THE FACE OF BOLD PROJECTS AND NEW IDEAS. RATHER, IT WILL BELONG TO THOSE WHO CAN BLEND PASSION, REASON AND COURAGE IN A PERSONAL COMMITMENT TO THE GREAT ENTERPRISES AND IDEALS OF AMERICAN SOCIETY."

— ROBERT F. KENNEDY

# កា ហ្សា វ៉ា (Ka Hsaw Wa)

“ខ្ញុំគិតខ្លួនឯងថា តើខ្ញុំកំពុងធ្វើអ្វី? ខ្ញុំមិនទទួលបានអ្វីសោះ សម្រាប់ខ្លួនខ្ញុំ ហើយហាក់ដូចជា ខ្ញុំមិនធ្វើអ្វីសោះ ក្នុងការកាត់បន្ថយ នូវការឈឺចាប់ របស់អ្នកភូមិ។ នៅពេលជាមួយគ្នានេះ, ប្រសិនបើខ្ញុំឈប់ ហើយដើរចេញ នោះនឹងគ្មាននរណាម្នាក់ ដោះស្រាយបញ្ហា ទាំងនេះទេ”។



Ka Hsaw Wa, ©2000 Eddie Adams

កា ហ្សា វ៉ា (Ka Hsaw Wa) គឺជាអ្នកបង្កើត អង្គការសិទ្ធិដីធ្លីអន្តរជាតិ (EarthRights International) ជាអង្គការក្រៅរដ្ឋាភិបាលមួយ ដែលបានដាក់ពាក្យបណ្តឹងលើកដំបូងបង្អស់ប្រឆាំងនឹងសាជីវកម្មមួយនៅសហរដ្ឋអាមេរិកពី អំពើទារុណកម្ម ដែលបានប្រព្រឹត្តដោយភ្នាក់ងាររបស់ក្រុមហ៊ុននេះ នៅបរទេស។ ពាក្យបណ្តឹងចោទប្រកាន់ថា ភ្នាក់ងាររដ្ឋាភិបាលរបស់ប្រទេសភូមា ដែលត្រូវបានជួលដោយ ក្រុមហ៊ុនយូណូខាល (Unocal), ជាក្រុមហ៊ុនប្រេងមួយដែលមានមូលដ្ឋាននៅសហរដ្ឋអាមេរិក, ដើម្បីផ្តល់ការគាំទ្រផ្នែកសន្តិសុខ, ផ្នែកដឹកជញ្ជូន, និង ផ្នែកហេដ្ឋារចនាសម្ព័ន្ធសម្រាប់បំពង់បង្ហូរប្រេង, បានប្រព្រឹត្តអំពើជម្រិតទារប្រាក់, ទារុណកម្ម, ការរំលោភសេពសន្ថវៈ, ការបង្ខំឲ្យធ្វើការ, និង ការសម្លាប់ក្រៅប្រព័ន្ធតុលាការ (extrajudicial killings) លើជនជាតិដើមភាគតិចមូលដ្ឋាន។ លោក កា ហ្សា វ៉ា (Ka Hsaw Wa) យល់ដោយបទពិសោធន៍ផ្ទាល់ខ្លួនអំពីអំពើរំលោភបំពាន ដែលប្រព្រឹត្តដោយរបបយោធានេះ។ គាត់បានចំណាយជាច្រើនឆ្នាំធ្វើដំណើររាប់ពាន់ម៉ៃល៍ (miles) ដោយ ១ម៉ៃល៍ ស្មើនឹង ១.៦១ គីឡូម៉ែត, ឆ្លងកាត់តាមព្រៃនៃប្រទេសភូមា ដើម្បីសម្ភាសន៍ សាក្សី និង កត់ត្រាសក្ខីភាពរបស់ជនរងគ្រោះពីការរំលោភបំពានសិទ្ធិមនុស្ស។ គាត់បានបង្រៀនមនុស្សរាប់រយនាក់ឲ្យចេះស៊ើបអង្កេត, រៀបចំឯកសារ, និង ធ្វើបទបង្ហាញអំពីការរំលោភ សិទ្ធិមនុស្សអន្តរជាតិ។ នៅពេលគាត់ជាប្រធាន ក្រុមនិស្សិតនៅក្នុងទសវត្សរ៍ឆ្នាំ១៩៨០, លោក កា ហ្សា វ៉ា បានរៀបចំបាតុកម្មគាំទ្រប្រជាធិបតេយ្យនៅទីក្រុងរ៉ង់ហ្គូន (Rangoon)។ គាត់ត្រូវបានគេចាប់ និង ធ្វើទារុណកម្មដោយភ្នាក់ងារនៃរបបយោធារបស់ប្រទេសភូមា, ដែលកាន់អំណាច តាំងពីឆ្នាំ១៩៦២ (ដោយបានកែឈ្មោះទៅជាទីប្រឹក្សារក្សាច្បាប់រដ្ឋ និង សណ្តាប់ធ្នាប់ស្លូក (SLORC), នៅចុងឆ្នាំ១៩៨៨)។ នៅពេលនគរបាល បានបើកការបាញ់ប្រហារលើបាតុករដោយសន្តិវិធី, មិត្តភក្តិជិតស្និទ្ធរបស់ លោក កា ហ្សា វ៉ា បានស្លាប់នៅក្នុងដៃរបស់គាត់។ លោក កា ហ្សា វ៉ា បានភៀសខ្លួនតាមបណ្តោយព្រំដែនប្រទេសថៃ។ ដើម្បីការពារសមាជិកគ្រួសារ គាត់បានផ្លាស់ឈ្មោះថ្មីទៅជា កា ហ្សា វ៉ា (Ka Hsaw Wa) ដែលមានន័យថា “ដំរីស”។ ឯកសារដែលបានរៀបចំយ៉ាងល្អិតល្អន់ដោយ លោក កា ហ្សា វ៉ា អំពីការរំលោភសេពសន្ថវៈជាប្រព័ន្ធ និង ពលកម្មបង្ខំ, ត្រូវបាន ជឿទុកចិត្ត និង បានយកមកប្រើដោយ អង្គការលើកលែងទោសអន្តរជាតិ (Amnesty International), អង្គការឃ្លាំមើលសិទ្ធិមនុស្ស (Human Rights Watch), និង អង្គការអន្តរជាតិផ្សេងទៀត។ គាត់បានសហប្រតិបត្តិការក្នុងការសរសេរសៀវភៅមួយចំនួន អំពីការរំលោភបំពាន, រាប់បញ្ចូលទាំងសៀវភៅដែលមានចំណងជើងថា សាលាសម្រាប់ការរំលោភសេពសន្ថវៈ (១៩៨៨) (School for Rape): “ចាប់បុរសចំនួន៣០០,០០០នាក់ ក្នុងចំណោមពួកគេទាំងនោះ គឺមានអាយុក្រោម១៧ឆ្នាំ និង មួយចំនួនធំគ្មានការអប់រំ។ បង្ខំដោយចុងកាំភ្លើងឲ្យធ្វើទាហាន, និង សន្យាទាំងអស់គ្នាឲ្យប្រាក់បៀវត្សរ៍ដែលគេនឹងមិនបាន។ ឲ្យកាំភ្លើង និង គ្រាប់បែក ទៅពួកគេ។ បង្រៀនពួកគេឲ្យចេះបាញ់, ចេះលូនចូលព្រៃនៅពេលយប់, ចេះវាយឆ្មក់។ បញ្ចុះបញ្ចូលពួកគេថា សត្រូវរបស់ពួកគេ គឺជនជាតិដើមភាគតិច, ពួកនិស្សិត, ពួកស្ត្រី, ហើយនរណាក៏ដោយ ដែលមិនឯកភាពជាមួយរដ្ឋាភិបាល, ហើយបញ្ចុះបញ្ចូលថា មនុស្សរាប់លាននាក់នេះ គឺជាជនក្បត់ជាតិ ឬ ជនក្បត់សាសនា (infidel)។

បង្អត់បាយពួកគេ។ ដកហូតសំបុត្រ និង មិនអនុញ្ញាតឲ្យពួកគេផ្ញើសំបុត្រណាមួយឡើយ។ ឃាត់ឃាំង ពួកគេមិនឲ្យសួរសុខទុក្ខគ្រួសារ។ បង្ខំពួកគេឲ្យវាយដំគ្នាទៅវិញទៅមកសម្រាប់ការពិន័យ។ បោះបង់ពួកគេមួយចំនួនចោល ប្រសិនបើពួកគេឈឺខ្លាំងដើរមិនរួច។ រំលោភបំពានពួកគេ ជាពាក្យសំដី និង រាងកាយជារៀងរាល់ថ្ងៃ។ អនុញ្ញាតឲ្យពួកគេផឹកស្រាឲ្យច្រើន និង ប្រើប្រាស់គ្រឿងញៀនឲ្យច្រើន។អ្នកទើបតែបានបង្កើត ទាហាននៃរបបគ្រប់គ្រងអំណាច ដោយយោធារបស់ប្រទេសភូមា”។ លោក កា ហ្សា វ៉ា (Ka Hsaw Wa) នៅបន្តកិច្ចការដោយមានភាពគ្រោះថ្នាក់ខ្ពស់ដល់ខ្លួនគាត់ នៅក្នុងព្រៃនៃប្រទេសភូមា។ លោក កា ហ្សា វ៉ា បានទទួលពានរង្វាន់ ផ្នែកបរិស្ថានហ្គោលមែន (Goldman Environmental Prize), រង្វាន់ផ្នែកសិទ្ធិមនុស្សរីបាក (Reebok Human Rights Award), មូលនិធិវីតលីសម្រាប់ធម្មជាតិ (Whitley Fund for Nature) ឬ ហៅថា រង្វាន់ស្ទីង និង ជ្រូឌី ស្តាយលើ សម្រាប់សិទ្ធិមនុស្ស និង បរិស្ថាន (Sting and Trudie Styler Award for Human Rights and Environment), រង្វាន់ផ្នែក បរិស្ថានខនដេណាស (Conde Nast Environmental Award), និង រង្វាន់រ៉េមិន ម៉ែកសេយសេយ សម្រាប់ភាពជាអ្នកដឹកនាំដែលផុសឡើង (Ramon Magsaysay Award for Emergent Leadership) សម្រាប់ការងាររបស់គាត់ ក្នុងការការពារសិទ្ធិមនុស្ស និង បរិស្ថាន។ លោក កា ហ្សា វ៉ា បែងចែកពេលវេលារបស់គាត់រវាង សហរដ្ឋអាមេរិក និង ការិយាល័យ នៅតំបន់អាស៊ីអាគ្នេយ៍ នៃអង្គការសិទ្ធិដីធ្លីអន្តរជាតិ។

ខ្ញុំបានធ្វើការងារនេះអស់រយៈពេល១១ឆ្នាំ។ ភាគច្រើននៃពេលវេលាទាំងនោះ ខ្ញុំសម្របសម្រួលការងារចុះមូលដ្ឋាន, ប្រមូលព័ត៌មាន, រៀបចំបេសកកម្មស្វែងរកការពិត, និង បណ្ដុះបណ្ដាលបុគ្គលិករបស់ខ្ញុំឲ្យធ្វើការដូចគ្នា, ជាពិសេសនៅក្នុងតំបន់បំពង់បង្ហូរប្រេងនៃក្រុមហ៊ុនប្រេងយូណូខល (Unocal)។បច្ចុប្បន្ន យើងមានបណ្ដឹងមិនទាន់ចប់នៅឡើយជាមួយយូណូខល (Unocal)។ ចំណុចសំខាន់នៃករណីនេះ គឺថាក្រុមហ៊ុនអាមេរិកមួយ កំពុងប្រើការរំលោភសិទ្ធិមនុស្ស ដើម្បីបង្កើនប្រាក់ចំណេញបន្ថែមរបស់ពួកគេ។

យើងសម្ភាសន៍ជាមួយមនុស្សនៅក្នុងប្រទេសភូមា ហើយបានសួរសំណួរអំពីការរំលោភសិទ្ធិមនុស្សដែលបានប្រព្រឹត្តដោយរដ្ឋាភិបាលយោធា។ យើងឮអំពីករណី នៃការធ្វើទារុណកម្ម និង ពលកម្មបង្ខំ, នៃការបង្ខំឲ្យលីសែង និង ការរំលោភសេពសន្ថវៈ, និង នៃការសម្លាប់ក្រៅប្រព័ន្ធតុលាការ (extrajudicial killings) ជាច្រើន។ ជួនកាលខ្ញុំប្រមូលព័ត៌មានខាងក្រៅប្រទេសភូមា តាមបណ្ដោយព្រំដែនប្រទេសថៃ, ហើយពេលខ្លះទៀតខ្ញុំប្រមូលព័ត៌មាននៅក្នុងជំរុំជនភៀសខ្លួន។

អ្នកភូមិដែលគាំទ្រយើងរក្សាទំនាក់ទំនងយ៉ាងសម្ងាត់ ឬ តាមលេខកូដ។ យើងប្រើ វិទ្យុទាក់ទង និង តាមប្រព័ន្ធមើលភូមិសាស្ត្រជាសកល(GPS)ក្នុងការស្វែងរកផ្លូវនៅក្នុងព្រៃ។វាមានភាពគ្រោះថ្នាក់ណាស់។ មានទីតាំងយោធាជាច្រើន។ យើងស្តាប់វិទ្យុទាក់ទងដើម្បីពិនិត្យមើលការធ្វើចលនារបស់ទាហាន និង ដើម្បីជៀសវាងការជួបគ្នា។ ខ្ញុំស្លៀកពាក់ខោអាវខ្មៅ និង យួរកាបូបមួយ។ យើងធ្វើដំណើរជាមួយមនុស្សអតិបរមាចំនួនបីនាក់ក្នុងមួយដង។ ជួនកាលទាហានដើរកាត់ផ្លូវនៅពីមុខយើង, ជិតគ្នាមែនទែនដែលយើងអាចប៉ះពួកគេបាន។ យើងមានការប្រយ័ត្នប្រយែងខ្លាំងបំផុត ខ្ញុំត្រូវបានគេបាញ់ចំនួនពីរដង។

យើងធ្វើការសម្រេចរបស់យើងផ្អែកលើ ការធ្វើចលនារបស់ទាហាន។ ជាធម្មតា យើងមិនចូលទៅក្នុងភូមិទេ ពីព្រោះវាមានភាពគ្រោះថ្នាក់។ ជំនួសការមិនចូលទៅក្នុងភូមិ, យើងសុំឲ្យប្រជាជនមកជួបយើងនៅក្នុងព្រៃយ៉ាងស្ងាត់ ពីព្រោះ យើងមិនចង់បង្ហាញខ្លួន ចំពោះពួកគាត់នោះឡើយ, ហើយពីព្រោះយើងមិនចង់ឲ្យពួកគាត់មានគ្រោះថ្នាក់ផងដែរ។ ក្នុងចំណោមអ្នកភូមិទាំងនោះ, មានអ្នកស៊ើបការឲ្យរដ្ឋាភិបាលយោធាស្លក (SLORC) គឺជាក្រុមយោធាមូលដ្ឋាន។ ដូច្នេះ យើងត្រូវប្រយ័ត្នប្រយែងបំផុត។

មានការរំលោភសិទ្ធិមនុស្សជាច្រើនដែលពាក់ព័ន្ធដោយផ្ទាល់ទៅនឹង បំពង់បង្ហូរប្រេងរបស់ក្រុមហ៊ុនយូណូខល (Unocal)។ ករណីច្រើនបំផុត គឺពលកម្មបង្ខំ និង បង្ខំឲ្យលីសែង។ ការបង្ខំឲ្យលីសែងនេះកើតឡើងនៅពេលទាហាន បង្ខំឲ្យអ្នកភូមិ លីសែង អាវុធយុទ្ធភ័ណ្ឌ, សម្ភារៈផ្គត់ផ្គង់, និង ម្ហូបអាហាររបស់ពួកគេ។ អ្នកលីសែងមិនត្រូវបានទទួលប្រាក់កម្រៃពលកម្មឡើយ, ហើយនៅពេលខ្លះ ពួកគេសាករត់គេច និងធ្វើរបាយការណ៍អំពីឧក្រិដ្ឋកម្មទាំងនេះដល់អាជ្ញាធរ។ ប្រសិនបើត្រូវបានគេចាប់ កម្មករលីសែងនេះ អាចទទួលរងនូវការធ្វើទារុណកម្ម, ដាក់គុក, ឬ ត្រូវគេសម្លាប់ចោល ដោយពួកសមាជិកស្លក (SLORC)។ ករណីនេះបានកើតឡើងនាពេលថ្មីៗនេះ លើមិត្តភក្តិជិតស្និទ្ធរបស់ខ្ញុំម្នាក់។ គាត់ និង ក្រុមអ្នកភូមិដទៃទៀត កំពុងត្រូវបានប្រមូលព័ត៌មានឲ្យខ្ញុំ ដើម្បីជួយដល់ខ្លួនពួកគាត់ និង ដើម្បីលើកកម្ពស់ការយល់ដឹងដល់សាធារណជនអំពីការរំលោភសិទ្ធិមនុស្សនៅមូលដ្ឋាន។ ស្លក (SLORC) បានសង្ស័យគាត់ចំពោះ សកម្មភាពទាំងនេះ ហើយបានសម្លាប់គាត់។

ករណីស្រដៀងនេះ នៅក្នុងបួន ឬ ប្រាំឆ្នាំមុននេះ, ខ្ញុំបានឮករណីចាប់រំលោភសេពសន្ថវៈលើស្ត្រីមូលដ្ឋាន ចំនួនពី១២ករណី ទៅ១៥ករណីពីសំណាក់យោធាស្លក ដែលកំពុងការពារសន្តិសុខតំបន់បំពង់បង្ហូរប្រេងរបស់ក្រុមហ៊ុនយូណូខល (Unocal)។ ជនរងគ្រោះនៃការចាប់រំលោភសេពសន្ថវៈពីរនាក់ ក្នុងចំណោមជនរងគ្រោះទាំងនោះ គឺជាដើមក្ដីនៅក្នុងការប្ដឹងរបស់យើង។ តំបន់ទាំងមូលពោរពេញទៅដោយទាហាន, ហើយស្ត្រីទាំងនេះត្រូវបានចាប់រំលោភសេពសន្ថវៈ ខណៈដែលពួកគេកំពុងដើររវាង ភូមិ និង ចំការជិតខាង។

ឆ្លើយតបទៅនឹងការរំលោភបំពានបែបនេះ, ខ្ញុំបានរៀបចំក្រុមនិស្សិតមួយក្រុមនៅក្នុងឆ្នាំ១៩៨៨ ដើម្បីប្រឆាំងនឹងស្លក (SLORC) និង ដើម្បីគាំទ្រលទ្ធិប្រជាធិបតេយ្យ។ ទោះបីជាខ្ញុំកំពុងរស់នៅក្នុងទីក្រុងរ៉ង់ហ្គូន

ក៏ដោយ ក៏និស្សិតម្នាក់ៗនៃក្រុមរបស់ខ្ញុំបានរៀបចំនូវបាតុកម្មមួយនៅក្នុងក្រុងនានា ក្រៅពីទីក្រុងរ៉ង់ហ្គូន។ បន្ទាប់មក មានការតវ៉ាពាសពេញប្រទេសភូមាឲ្យមានការអប់រំប្រជាជន អំពីលទ្ធិប្រជាធិបតេយ្យ និង ធ្វើការតទល់នឹងស្លក (SLORC)។ អំឡុងពេលបាតុកម្មមួយ, នៅក្នុងទីក្រុងរ៉ង់ហ្គូន មិត្តភក្តិពីរនាក់របស់ខ្ញុំត្រូវបានគេបាញ់។ មិត្តភក្តិម្នាក់បានស្លាប់មុខខ្ញុំ។ ហើយម្នាក់ទៀតត្រូវបានគេបាញ់ធ្លាយមាត់ និង ថ្គាម។ ខ្ញុំបានគ្រាគាត់ទៅកាន់មន្ទីរពេទ្យ, ប៉ុន្តែ ខ្ញុំបានទុកគាត់ចោល ដើម្បីគេចខ្លួន។

ខ្ញុំមិនចង់ចាកចេញពីប្រទេសភូមានិងឪពុកម្តាយចាស់ជរារបស់ខ្ញុំ ដូច្នេះខ្ញុំបានសម្រេចចិត្តចាកចេញទៅកាន់តំបន់មួយនៅក្រៅទីក្រុងរ៉ង់ហ្គូន។ ហើយនៅពេលជាមួយគ្នានោះ ខ្ញុំបានស្នាក់នៅក្នុងព្រៃ និង សង្កេតមើល អំពីជីវិតពិបាកវេទនារបស់អ្នកភូមិ។ នៅពេលព្រឹក អ្នកភូមិបានកាន់ចប និង កន្ត្រក់ ហើយត្រូវបានគេបង្ខំឲ្យសាងសង់អ្វីមួយសម្រាប់យោធា។ ថ្ងៃមួយ ម្ចាស់ផ្ទះដែលខ្ញុំកំពុងស្នាក់នៅបាននិយាយថា "ថ្ងៃស្អែកខ្ញុំត្រូវទៅ និង ធ្វើការឲ្យពួកឆ្កែទៀតហើយ"។ "តើអ្នកកំពុងនិយាយអំពីអ្វី?" ខ្ញុំបានសួរគាត់ "អ្នកភូមិសំដៅទៅដល់យោធាដូចជា សត្វឆ្កែ ពីព្រោះអ្នកភូមិស្អប់ពួកយោធា" គាត់បានឆ្លើយប្រាប់ខ្ញុំ។ "យើងមិនមានពេលធ្វើអ្វីផ្សេងដែលយើងត្រូវធ្វើនោះទេ ពីព្រោះយើងជានិច្ចកាល ត្រូវធ្វើការសម្រាប់ពួកគេ។ យើងមិនដែលទទួលបានកម្រៃអ្វីនោះទេ"។ បន្ទាប់មក ខ្ញុំបានទទួលសំបុត្រពីម្តាយរបស់ខ្ញុំដែលនិយាយថា "កូនប្រុសវាមានគ្រោះថ្នាក់ណាស់។សូមរង់ចាំម្តាយសិនម្តាយនឹងទៅជួបកូន"។ ម្តាយរបស់ខ្ញុំបានមកជួបខ្ញុំ ហើយខ្ញុំបានជម្រាបលាគាត់។

ខ្ញុំបានដើរកាត់ព្រៃអស់រយៈពេល៥ថ្ងៃ ទៅកាន់តំបន់ការ៉ែន (Karen) ជាមួយនិស្សិត និង អ្នកភូមិផ្សេងទៀត។ នៅពេលដែលយើងធ្វើ ដំណើរជិតដល់ភូមិ ខ្ញុំបានមើលឃើញនូវរូបភាពមួយ ដែលខ្ញុំនឹងមិនអាចបំភ្លេចបាន។ខ្ញុំបានឃើញសាកសពស្ត្រីម្នាក់ដែលមានមែកឈើធំមួយដោតក្នុងប្រដាប់ភេទរបស់នាង។ ខ្ញុំបានដើរទៅក្នុងភូមិ ហើយបានសាកសួរ អំពីរឿងរ៉ាវរបស់នាង។ អ្នកភូមិបានប្រាប់ខ្ញុំថា នាង គឺជាគិលានុបដ្ឋាយិកាម្នាក់ ហើយដែលក្រុមយោធាបាននាំនាងទៅឲ្យព្យាបាលពួកម៉ាកម្នាក់របស់ពួកគេ ដែលមានជម្ងឺគ្រុនចាញ់។ ជាជាងធ្វើបែបនេះ, ពួកគេបានចាប់រំលោភ ហើយបានសម្លាប់នាង។ វាមានការតក់ស្លុតយ៉ាងខ្លាំង។

ខ្ញុំបានស្នាក់នៅភូមិនោះអស់មួយរយៈពេល។ ទិដ្ឋភាពនេះ បានផ្លាស់ប្តូរជីវិតខ្ញុំទាំងស្រុង។ នៅពេលដែលគ្មាននរណាម្នាក់ធ្វើការសម្ភាសន៍នៅពេលនោះ ខ្ញុំបានសម្រេចចិត្តធ្វើការសម្ភាសន៍មួយចំនួន។ ខ្ញុំបាននិយាយជាមួយអ្នកគ្រប់គ្នា។ ខ្ញុំបាននិយាយទៅកាន់ម្តាយម្នាក់ដែលកូនប្រុសរបស់គាត់បានធ្វើអត្តឃាត ដោយសារក្រុមយោធាបានបង្ខំគាត់ឲ្យរួមភេទជាមួយម្តាយរបស់ខ្លួន។ បន្ទាប់មក ក្រុមយោធាបានទះដៃ ហើយហៅក្មេងប្រុសនោះ "អាចុយម្តាយ"។ ក្រោយមកកូនប្រុសរបស់គាត់បានធ្វើអត្តឃាតខ្លួនឯងដោយសារភាពអាម៉ាស។ ម្តាយមានការឈឺចាប់យ៉ាងខ្លាំង។ បន្ទាប់ពីខ្ញុំបានឮដូច្នេះ ខ្ញុំបានសម្រេចចិត្តធ្វើការងារសម្រាប់ពួកគេទាំងនេះ។

នៅពេលចាប់ផ្តើម ខ្ញុំគ្មានទាំងប៊ិច គ្មានទាំងសៀវភៅសម្រាប់ធ្វើការងារនេះឡើយ។ ខ្ញុំបានធ្វើដំណើរទៅកាន់ អាជ្ញាធរក្រុមអ្នកតស៊ូសហព័ន្ធជាតិការ៉ែន (Karen National Union), ហើយពួកគេមិនបានយកចិត្តទុកដាក់មកលើខ្ញុំ ពីព្រោះគេស្មានថា ខ្ញុំជានិស្សិតក្មេងម្នាក់ដែលមិនដឹងអី។ សហព័ន្ធនេះបានប្រាប់ខ្ញុំថា ឧប្បហេតុបែបនេះ បានកើតឡើងរាល់ពេល ហើយគ្មាននរណាម្នាក់គិតគូរឡើយ។ ពួកគេបានប្រាប់ខ្ញុំកុំឲ្យរវីរវល់, យកកម្លាំងមកកាន់កាំភ្លើង ហើយតទល់ជាមួយយោធាវិញ។ ខ្ញុំមិនបានដឹងថា ធ្វើការដែលខ្ញុំចង់នេះ ដោយរបៀបណានោះឡើយ ដែលមិនមានធនធានចាំបាច់ និង ការគាំទ្រគ្រប់គ្រាន់។ ខ្ញុំបានព្យាយាមទៅរកសហព័ន្ធជាតិការ៉ែន (Karen National Union) ហើយបានសុំឲ្យពួកគេទិញប្រដាប់ថតសម្លេង, ក្រដាស និង ប៊ិចសម្រាប់ខ្ញុំសរសេរ និង ធ្វើការបញ្ជូនព័ត៌មាន សំខាន់ៗទៅឲ្យមនុស្សពាក់ព័ន្ធ។ ពួកគេ បានប្រាប់ខ្ញុំថា កុំឆ្កួតពេក។

ខ្ញុំបានសម្រេចចិត្តក្នុងការស្រង់សក្ខីភាព។ អ្វីទាំងឡាយដែលខ្ញុំអាចធ្វើបាន គឺនិយាយជាមួយប្រជាជន និង ស៊ីជម្រៅអំពីរឿងរ៉ាវនានារបស់ពួកគេតាមដែលអាចធ្វើទៅបាន។ យើងបានរស់នៅកណ្តាលព្រៃ, ដូច្នេះ ខ្ញុំបានសម្រេចចិត្តទៅកាន់ទីក្រុងដើម្បីទៅរកក្រដាស និង ប៊ិច។ ខ្ញុំបានប្រើប្រាស់ធនធានទាំងនេះ សម្រាប់សរសេរសារទៅឲ្យប្រជាជន, ប៉ុន្តែ គ្មាននរណាម្នាក់បានស្តាប់ និង ខ្វល់ខ្វាយឡើយ។ ខ្ញុំបានគិតថា "តើខ្ញុំកំពុងធ្វើអ្វី?" ខ្ញុំមានការរសាប់រសល់ក្នុងចិត្ត។

ជាចុងក្រោយ នៅដើមឆ្នាំ១៩៩២, ខ្ញុំបានជួបបុរសម្នាក់ដែលមានឈ្មោះ ខេវិន ហេបណឺ (Kevin Heppner)។ គាត់គឺជាជនជាតិកាណាដា ហើយយើងពីរនាក់បានចាប់ផ្តើមរៀបចំឯកសារសិទ្ធិមនុស្ស។ ខ្ញុំបានបកប្រែសក្ខីភាពរបស់ប្រជាជនទៅជាភាសារអង់គ្លេស, ហើយគាត់បានវាយអង្គុលីលេខឯកសារនេះ, ហើយយើងបានបញ្ជូនទៅឲ្យនរណាដែលចាប់អារម្មណ៍។ ខេវិន (Kevin) ច្រើនតែបានផ្ញើព័ត៌មានទៅឲ្យក្រុមសិទ្ធិមនុស្ស ដូចជា អង្គការលើកលែងទោសអន្តរជាតិ (Amnesty International), ពីព្រោះ ខ្ញុំមិនមានឯកសារឆ្លងដែនចូលប្រទេសថៃ។ ខ្ញុំត្រូវបានគេឃាត់ខ្លួនចំនួន បួន ទៅ ប្រាំដង នៅក្នុងប្រទេសថៃ ពីព្រោះខ្ញុំឆ្លងដែនដោយខុសច្បាប់។ ពួកគេបានចាប់ខ្ញុំដាក់គុករយៈពេលប្រាំពីរថ្ងៃ ហើយបន្ទាប់មកធ្វើការដោះលែងខ្ញុំ។ វាមានការលំបាកយ៉ាងខ្លាំង។ នៅពេលចាប់ផ្តើម យើងក្រីក្រមែនទែន។ ចុងក្រោយ យើងបានជួបស្ត្រីម្នាក់មកពីប្រទេសបារាំង ដែលបានឲ្យលុយ សម្រាប់ទិញក្រដាស និង ការផ្ញើលិខិត។ ខ្ញុំមានការសប្បាយចិត្តជាខ្លាំង ដែលនៅចុងបញ្ចប់ យើងអាចធ្វើអ្វីៗបាន។

នៅក្នុងប្រទេសភូមា, ខ្ញុំត្រូវបានគេឃាត់ខ្លួនមុនពួកនិស្សិតបះបោរ

ហើយត្រូវបានគេធ្វើទារុណកម្មផងដែរ។ មិត្តភក្តិរបស់ខ្ញុំម្នាក់ បានវាយតប់ជាមួយកូនរបស់អាជ្ញាធរ, ហើយបន្ទាប់មកគាត់បានបាត់ខ្លួន។ ថ្វីបើខ្ញុំមិនបានដឹងថា មិត្តម្នាក់នោះបានទៅណាហើយ, អាជ្ញាធរបានធ្វើទារុណកម្មខ្ញុំ ហើយជម្រុញឲ្យខ្ញុំប្រាប់អំពីទីកន្លែងរបស់មិត្តនោះ។

ការធ្វើទារុណកម្មបានចាប់ផ្តើមជាមួយអ្វីមួយដែលហៅថា "ការជិះម៉ូតូ", ដែលក្នុងនោះ ខ្ញុំត្រូវបានគេបង្ខំឲ្យធ្វើកាយវិការណាមួយ ហើយឲ្យរោទិ៍សម្លេង "រ៉ូម! រ៉ូម! រ៉ូម!"។ នៅពេលខ្ញុំអស់កម្លាំង, ពួកគេវាយឆ្អឹងស្មងជើងរបស់ខ្ញុំជាមួយឧបករណ៍ពិសេសមួយ ដែលមានភាពរឹងមាំពីខាងក្រៅ និង មានបណ្តូលដែក។ បន្ទាប់មកទៀត ខ្ញុំត្រូវបានគេបញ្ជាឲ្យធ្វើកាយវិការបើក "ផ្លូវរថភ្លើង"។ ខ្ញុំត្រូវបានគេឲ្យធ្វើដូចជិះលើផ្លូវរថភ្លើង និង ហៅឈ្មោះកន្លែងឈប់នីមួយៗ។

ប្រសិនបើខ្ញុំមិនដឹងឈ្មោះ ឬ ហៅឈ្មោះមិនត្រឹមត្រូវ ខ្ញុំត្រូវបានគេវាយ។ ពួកគេបានវាយខ្ញុំមិនឈប់ឈរ, ហើយនៅពេលដែលឲ្យខ្ញុំសម្រាក គេសួរសំណួរខ្ញុំដដែលៗម្តងហើយម្តងទៀត។ ចុងក្រោយខ្ញុំមិនអាចនិយាយអ្វីបន្ថែម ហើយពួកគេមិនជឿខ្ញុំ។ មុនពេលខ្ញុំដួលសន្លប់, ខ្ញុំត្រូវបានគេធ្វើទារុណកម្មម្តងទៀត។ មានបេតុងស៊ីម៉ង់ត៍ដែលមានថ្មជ្រុងស្រួចៗមួយគំនរ។ ថ្មទាំងនេះត្រូវបានប្រើប្រាស់សម្រាប់ផ្លូវថ្នល់ និង ការសាងសង់។ គេបានបង្ខំខ្ញុំឲ្យផ្តួលខ្លួនលើគំនរថ្មនេះក្នុងការជម្រុញឲ្យខ្ញុំនិយាយ។ ខ្ញុំបាននិយាយថា "ខ្ញុំមិនអាចនិយាយអ្វីទេ"។ ពួកគេបានបន្តធ្វើទារុណកម្មខ្ញុំ រហូតដល់ការឈឺចាប់នោះមិនអាចទ្រាំបាន។ ពួកគេបានដើរជាន់លើខ្នងរបស់ខ្ញុំ ហើយសួរខ្ញុំថាឥឡូវនិយាយឬអត់។ សារជាថ្មីទៀត ខ្ញុំបានឆ្លើយតបថា ខ្ញុំមិនមានអ្វីទៀតដែលត្រូវនិយាយទេ ហើយពួកគេបានទាត់ខ្ញុំ។ ពីរនាក់ក្នុងចំណោមក្រុមទាហាននេះ, មុខរបស់ពួកគេបានបិទបាំង បានចាប់ខ្ញុំហើយបន្តដាល់និងទាត់ខ្ញុំ។ ខ្ញុំខឹងយ៉ាងខ្លាំង ប៉ុន្តែអ្វីដែលខ្ញុំអាចធ្វើកើត គឺគ្រាន់តែមើលទៅពួកគេ។ ទីបញ្ចប់ខ្ញុំចាប់ផ្តើមហូរឈាមយ៉ាងច្រើន និង សន្លប់។ ទោះបីបទពិសោធន៍នេះ បានកើតឡើងរយៈពេល៣ថ្ងៃក៏ដោយ, ក៏ខ្ញុំនៅតែបានឃើញស្ថានការណ៍អាក្រក់ឃោរឃៅជាងនេះទៀត។ មិត្តភក្តិខ្ញុំខ្លះ ត្រូវបានគេបាញ់ និង សម្លាប់។

ឥឡូវនេះ មិត្តរួមថ្នាក់របស់ខ្ញុំជាច្រើននាក់ មានសញ្ញាប័ត្របណ្ឌិតនៅសហរដ្ឋអាមេរិក។ ពួកគេបានទទួលនូវការអប់រំ ហើយត្រលប់មកវិញដោយមានលុយ។ ខ្ញុំបានគិតចំពោះខ្លួនខ្ញុំផ្ទាល់ថា "តើខ្ញុំកំពុងធ្វើអ្វី?" ខ្ញុំមិនបានទទួលនូវអ្វីសម្រាប់ខ្លួនខ្ញុំទេ, ហើយខ្ញុំទំនងជា មិនអាចធ្វើអ្វីៗ ដើម្បីបន្ធូរបន្ថយនូវការឈឺចាប់របស់អ្នកភូមិបានដែរ។ ខ្ញុំមើលឃើញស្ថានភាពកាន់តែអាក្រក់ឡើងៗ ហើយខ្ញុំបាន ស្តីបន្ទោសខ្លួនខ្ញុំ ចំពោះការដែលមិនអាចធ្វើអ្វីបានគ្រប់គ្រាន់។ ស្របពេលជាមួយគ្នានោះដែរ ខ្ញុំមិនអាចឈប់បានទេ។ ប្រសិនបើខ្ញុំបែរខ្នង និង គេចចេញពីរឿងរ៉ាវអស់នេះ, នឹងមិនមាននរណាម្នាក់អាចដោះស្រាយបញ្ហានោះបានទេ។

ក្នុងឆ្នាំ១៩៩៤ មិត្តរបស់ខ្ញុំម្នាក់បានស្លាប់ ហើយខ្ញុំចង់បោះបង់ចោល។ ខ្ញុំបានសម្រេចចិត្តថា ខ្ញុំត្រូវធ្វើអ្វីៗ សម្រាប់ខ្លួនខ្ញុំ។ ខ្ញុំត្រូវការប្រាក់ចំណូលមួយ ដែលអាចផ្តល់លុយឲ្យប្រជាពលរដ្ឋបាន។ ខ្ញុំបានគិតថា "ប្រសិនបើខ្ញុំបែរខ្នង នរណានឹងធ្វើកិច្ចការនេះ?" ការឈឺចាប់នេះ នឹងមិនអាចបញ្ចប់បានទេ។ ទោះបី វាជាសេចក្តីសម្រេចដ៏លំបាកក៏ដោយ, ក៏ខ្ញុំមិនបានសម្រេចចិត្តបញ្ឈប់ការធ្វើការជូនប្រជាជនដែរ។ ខ្ញុំបានប្តេជ្ញាចិត្តទទួលភាពក្រីក្រ, ដោយរស់នៅក្នុងព្រៃដោយមានអាហារបន្តិចបន្តួច។ មានពេលមួយដែលខ្ញុំចង់បាញ់សម្លាប់ខ្លួនខ្ញុំ នៅពេលដែលមិនមានទឹកប្រើប្រាស់សម្រាប់ដាំបាយ ហើយយើងត្រូវហូបអង្ករ។ យើងមិនអាចចំអិនអាហារបានទេព្រោះខ្លាចក្រែងថា ទាហានអាចមើលឃើញភ្លើង។ គ្នាយើងម្នាក់បានឆ្លងជម្ងឺគ្រុនចាញ់ ហើយយើងមិនមានថ្នាំលេបទេ។ វាមានអាកាសធាតុត្រជាក់ណាស់នៅតាមជើងភ្នំ ហើយអ្វីដែលយើងមានត្រឹមតែកៅស៊ូមួយផ្ទាំង និង ភួយ សម្រាប់គ្របដណ្តប់លើខ្លួន។ មនុស្សខ្លះមានចិត្តអាណិត ហើយបានផ្តល់អង្រឹងឲ្យយើង។ នៅក្នុងរដូវវស្សា, ជីវិតមានស្ថានភាពលំបាកណាស់។ ទោះបីជាយើងបានចងអង្រឹង ដើម្បីជៀសវាងឈ្លើងនៅលើដីយ៉ាងណាក៏ដោយ, នៅពេលព្រឹកយើងដឹងថា ឈ្លើងបានធ្លាក់ចុះពីដើមឈើ ហើយបឺតឈាមយើង។

យើងដឹងអំពីស្ថានភាពលំបាក, ប៉ុន្តែ ប្រសិនបើយើងចង់ជួយប្រជាពលរដ្ឋ, យើងត្រូវតែធ្វើការលះបង់យ៉ាងធំ។ ជួនកាលយើងមានអារម្មណ៍ស្រឡាំងកាំង ពីព្រោះយើងបានលះបង់ពេលវេលាដ៏ច្រើនដោយមិនបានឃើញលទ្ធផលធំដុំណាមួយទេ។ នៅត្រង់ចំណុចមួយ, ខ្ញុំបាន ឃើញឯកសារដែលយើងបានធ្វើការយ៉ាងលំបាក នៅក្នុងធុងសម្រាម។ ឯកសារនេះត្រូវបានគេឈ្លី ហើយបោះចោល។ ខ្ញុំអាក់អន់ចិត្តយ៉ាងខ្លាំង, ថ្វីបើខ្ញុំបានយល់ដឹងថា បញ្ហាដែលគេជួបប្រទះនោះ គឺមានលក្ខណៈខុសគ្នាពីបញ្ហារបស់យើង។ ខ្ញុំបានបើកចិត្តឲ្យទូលាយ ហើយបានយល់អំពីស្ថានភាពនោះ។ វាមានការលំបាកណាស់សម្រាប់យើង ដើម្បីយកឯកសារមួយនោះផ្ញើចេញ, ហើយដើម្បីកត់ត្រាការឈឺចាប់ដែលមនុស្សទាំងអស់នោះបានអត់ទ្រាំ។ យើងមានគោលបំណងឧត្តមគតិមួយគឺ៖ យើងចង់ឲ្យគេរាក់ទាក់ប្រជាជនដូចជាមនុស្ស។

ខ្ញុំមិនដឹងថា តើសេចក្តីក្លាហាន កើតចេញពីអំណាច ឬ ពីការឈឺចាប់។ ខ្ញុំចាំបាននៅពេលមួយ ខ្ញុំបានស្តាប់ឮសក្ខីកម្មរបស់មនុស្សម្នាក់ ហើយរាងកាយទាំងមូលរបស់ខ្ញុំបានចាប់ផ្តើមញ័ររន្ធត់។ វាគឺជារឿងអាក្រក់ព្រៃផ្សៃមួយដែលខ្ញុំបានឮ។ ប្រពន្ធរបស់អ្នកធ្វើបដិវត្តម្នាក់ត្រូវបានគេចាប់ខ្លួននៅពេលគាត់ទៅជួបប្តី។ ក្រុមយោធាបានសម្លាប់ និង ដុតកូនង៉ារបស់ពួកគាត់, ហើយបង្ខំឲ្យម្តាយស៊ីសាច់កូនខ្លួនឯងពីព្រោះឪពុកមិនបានត្រលប់មកទេ។ រឿងរ៉ាវបែបនេះធ្វើឲ្យខ្ញុំស្អប់ខ្ពើម, ហើយនៅពេលដំណាលគ្នានេះដែរ, ផ្តល់សេចក្តីក្លាហានដល់ខ្ញុំ។ ការឈឺចាប់ដែលខ្ញុំបានអត់ទ្រាំនោះ គឺពុំមានអ្វីដែលប្រៀបធៀបនឹងការឈឺចាប់របស់ពួកគាត់ទេ។ តម្រូវការរបស់មនុស្សទាំងអស់នោះ គឺមានទំហំធំជាងតម្រូវការផ្ទាល់របស់ខ្ញុំទៅទៀត។

# ការទទួលខុសត្រូវសង្គម នៃក្រុមហ៊ុន

លោក កា ហ្សា៉វា     បញ្ហាសិទ្ធិមនុស្ស៖ បរិស្ថាន

## សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស

- មាត្រា២៖ សេរីភាពរួចផុតពីការរើសអើង
- មាត្រា៣៖ សិទ្ធិរស់រានមានជីវិត សិទ្ធិមានសេរីភាព និងសន្តិសុខផ្ទាល់ខ្លួន
- មាត្រា៥៖: សេរីភាពរួចផុតពីការធ្វើទារុណកម្ម និងការប្រព្រឹត្តិថោកទាប
- មាត្រា៧៖ សិទ្ធិស្មើគ្នាចំពោះមុខច្បាប់
- មាត្រា១៩៖ សេរីភាពក្នុងការផ្តល់យោបល់ និង ព័ត៌មាន
- មាត្រា២០៖ សិទ្ធិបើកអង្គប្រជុំ និងបង្កើតសមាគមដោយសន្តិវិធី
- មាត្រា២៣៖ សិទ្ធិធ្វើការងារតាមពេញចិត្ត និងចូលរួមសហជីព
- មាត្រា២៥៖ សិទ្ធិទទួលបានកម្រិតជីវភាពគ្រប់គ្រាន់
- មាត្រា៣០៖ សេរីភាពរួចផុតពីរដ្ឋណាមួយ ឬ ការជ្រៀតជ្រែកបុគ្គលណាមួយ នៅក្នុងសិទ្ធិ ខាងលើនេះ

## ស្ថានភាពគ្រោងទុកជាមុន៖ ៨០នាទី

## ផលវិបាកមិនអាចជៀសរួច នៃការក្លាយជាអ្នកការពារ

សមាជិកសង្គម គឺដើម្បីជួបប្រទះ ឬ មើលឃើញការរើសអើង ឬ ការជិះជាន់។ តើអ្វីទៅជាមធ្យោបាយ របស់ មនុស្សចូលរួមចំណែក ដោះស្រាយ ឬ ឲ្យជៀសវាងបាតុភូតនេះ? តើភាពព្រងើយកន្តើយ (apathy) និង សេចក្តីក្លាហាន មានតួនាទីដូចម្តេច?

តើចំណុចនេះ ត្រូវអនុវត្តន៍ ចំពោះ ជនល្មើស, ជនរងគ្រោះ, អ្នកឈរមើល និង អ្នកការពារក្តី ក្នុងស្ថានភាពជាក់លាក់ ដែលពាក់ព័ន្ធ នៅក្នុងព្រៃរបស់ ប្រទេសភូមា ពិធីដុតមនុស្សបូជា ឬ ជីវិតផ្ទាល់ខ្លួនរបស់និស្សិត តាមរបៀបណា?

បន្ទាប់ពីមេរៀននេះ សិស្ស អាចនឹង៖

- កំណត់ កត្តាអន្តរកម្ម ដ៏ចាំបាច់, រួមបញ្ចូលទាំង និមិត្តសញ្ញា, និមិត្តរូប, ការសើចចំអក នៅក្នុង បទកំណាព្យ និង ប្រើប្រាស់កត្តា ដែលអាចជួយបង្កើត ឧបករណ៍កំណាព្យដើម ដើម្បីបកស្រាយការងារ។
- និពន្ធ កំណាព្យដើម ដែលផ្តោតលើ ទស្សនទាន នៃភាពព្រងើយកន្តើយ, សេចក្តីក្លាហាន និង ការព្យាយាម។
- ស្តាប់ និង និយាយ អំពីបទពិសោធន៍ផ្ទាល់ខ្លួន ដែលទាក់ទងនឹងព័ត៌មានថ្មីៗ។
- វាយតម្លៃ និង ប្រើពាក្យវាក្យស័ព្ទ នៅក្នុងបរិបទនានា ដើម្បី សម្របសម្រួល ការផ្សព្វផ្សាយជាទូទៅ។ ប្រមូលទិន្នន័យ, ហេតុការពិត និង គំនិតនានា របស់ លោក កា ហ្សា៉វា និង ការទទួលខុសត្រូវសាជីវកម្ម/ចូលរួមការទទួលខុសត្រូវក្នុងសង្គម (corporate social responsibility), ស្វែងរកការទំនាក់ទំនងទស្សនទាន និង ការផ្សព្វផ្សាយ ទូទៅ ដែលដាក់បញ្ចូល ពិធីដុតមនុស្សបូជាជីវិត របស់ លោក កា ហ្សា៉វា និង បទពិសោធន៍ផ្ទាល់ខ្លួន របស់ពួកគេ។
- បង្កើត ព័ត៌មាន ដោយមានសម្ភារៈគាំទ្រ ដូចជា ការទំនាក់ទំនងផ្នែកកាយវិញ្ញាណ, កំណត់ហេតុអ្នកសារព័ត៌មាន, ហេតុពិត, សេចក្តីលម្អិត, ឧទាហរណ៍ និង សម្ភារៈខាងក្រៅ។
- ធ្វើសំយោគព័ត៌មាន ដើម្បីជ្រើសរើស, រៀបចំ និង ចាត់ចំណាត់ថ្នាក់ព័ត៌មាន ដើម្បីនិពន្ធកំណាព្យដើម និង បញ្ចាំងស្លាយ ជាជំហ៊ានបន្តបន្ទាប់។
- វិភាគ និង វាយតម្លៃ ព័ត៌មាន អំពីទស្សនៈផ្សេងៗ និង ទទួលស្គាល់ សុពលភាព ទំនាក់ទំនង នៃទស្សនៈខ្វែងគំនិតគ្នា។
- ស្តាប់អ្នកដទៃ ដោយយកចិត្តទុកដាក់ និងកសាង ផ្អែកលើ គំនិតរបស់អ្នកដទៃ ក្នុងកិច្ចសន្ទនា និង កិច្ចពិភាក្សា ក្នុងថ្នាក់។ ការនិពន្ធ និង ការអនុវត្តដំណើរការនិពន្ធ។ ការនិពន្ធក្នុងរឿងអង្គជាតិផ្សេងៗ វេយ្យាករណ៍ និង យន្តការី។ ប្រមូល និង ប្រើប្រាស់ព័ត៌មាន សម្រាប់ការសិក្សាស្រាវជ្រាវ។ តក្កវិទ្យា និង ការដោះស្រាយបញ្ហា។

## ស្ថានភាពគ្រោងទុកជាមុន

- ចាប់ផ្តើមពិភាក្សាជាមួយសិស្ស អំពីនិយមន័យ នៃ ការងើបឈរប្រឆាំង នឹងអំពើអយុត្តិធម៌។
- បង្រៀនសិស្សឲ្យនិពន្ធរឿងនិទានខ្លី, ដោយរៀបរាប់ អំពី ពេលវេលាដែលពួកគេបានក្រោកឈរការពារអ្នកដទៃទៀត។
- នៅពេលដែលសិស្សបានបញ្ចប់, ស្នើសុំឲ្យពួកគេ ចែករំលែក ស្ថានភាព និង បទពិសោធន៍របស់ពួកគេ នៅក្នុង កិច្ចពិភាក្សាក្នុងថ្នាក់។
- សរសេរឈ្មោះនៅលើក្តារខៀន
    - ជនល្មើស
    - ជនរងគ្រោះ
    - អ្នកឈរមើលព្រឹត្តិការណ៍(សាក្សី)

## អ្នកការពារក្តី

- ពិភាក្សា និង បំផុសគំនិត អំពី លក្ខណៈ វិនិច្ឆ័យរបស់បុគ្គលម្នាក់ៗ។ ឲ្យសិស្ស សរសេរ ការបរិយាយ នៅក្នុង ចំណងជើង រឿងសមស្រប។

## សកម្មភាពទី១

- ចែកឯកសារសិស្ស និង បញ្ជីវាក្យស័ព្ទ
- សិស្សត្រូវធ្វើការជាគូរ ដើម្បីស្វែងរក និយមន័យ នៃពាក្យនីមួយៗ
- នៅពេលដែលសិស្សបានកំណត់ និយមន័យពាក្យពេចន៍, ពួកគេ ត្រូវតែ បង្កើត សំណង់ប្រយោគ ដោយប្រើប្រាស់ ពាក្យទាំងអស់នេះ ឲ្យបានសមរម្យ ។
- សិស្សនឹងចែករំលែក និយមន័យ និង សំណង់ប្រយោគទាំងអស់នេះ នៅក្នុង កិច្ចពិភាក្សាក្នុងថ្នាក់។

## ទុកជាមុន, វាក្យស័ព្ទ

(scavenger hunt)

- នៅពេលដើរចូលក្នុងថ្នាក់ សិស្សត្រូវបាន ផ្តល់ឲ្យនូវ កំណត់ត្រា ជាមួយទាំង និយមន័យ ទាំងវាក្យស័ព្ទនានា។
- ពេលវេលាដែលសិស្សមើល គឺត្រូវ ចំណាយពេលយ៉ាងច្រើន នៅក្នុង ការស្វែងរកដៃគូ។ សិស្សអង្គុយភ្លាម នៅពេលដែលពួកគេស្វែងរកបានដៃគូ ម្នាក់។ ពិនិត្យឡើងវិញនូវ ពាក្យពេចន៍ និង និយមន័យ, និង ពិភាក្សាអំពីថា តើពាក្យពេចន៍ទាំងអស់នេះ ត្រូវបានប្រើប្រាស់ដូចម្តេច។

## សកម្មភាពទី២

ឲ្យសិស្សធ្វើការជា ដៃគូ។ ចាត់សិស្សឲ្យ ជ្រើសរើស ពាក្យស័ព្ទ និង និយមន័យ អប្បបរមា ចំនួន១៥ពាក្យ។ សិស្ស ត្រូវ សរសេររឿងខ្លីមួយ ដោយប្រើពាក្យស័ព្ទ នៅ ក្នុងបរិបទត្រឹមត្រូវ។ ចំណុចនេះ រៀបរាប់ ពីសំណួរ។



វត្តអម្ពវនារាម, ខែតុលា ឆ្នាំ២០១១

# ព័ត៌មានបន្ថែម

ការចងក្រងបណ្ដាញសម្រាប់ ការទទួលខុសត្រូវសង្គម នៅអាស៊ីអាគ្នេយ៍ (Affiliated Network for Social Accountability in the East Asia and Pacific, ANSA-EAP)
www.ansa-eap.net

អង្គការពលកម្មអន្តរជាតិ
(International Labor Organization)
www.ilo.org

អង្គការមូលនិធិកុមារនៅកម្ពុជា
(Cambodian Children's Fund)
www.cambodianchildrensfund.org

ក្រសួងអប់រំ យុវជន និង កីឡា (Ministry of Education, Youth and Sport)
www.moeys.gov.kh

អង្គការទស្សនៈពិភពលោកកម្ពុជា
(World Vision Cambodia)
www.worldvision.org.kh

អង្គការលើកលែងទោសអន្តរជាតិភ្ជាប់ទៅនឹងអាជីវកម្ម
(Amnesty International linked to Business)
www.amnesty.org.uk

មជ្ឈមណ្ឌល អាជីវកម្ម និង ធនធានសិទ្ធិមនុស្ស
(Business and Human Rights Resource Center)
www.business-humanrights.org

អង្គការ សាជីវកម្ម និង សិទ្ធិមនុស្ស
(Corporations and Human Rights)
www.hrw.org

អង្គការផ្តួចផ្តើម ធ្វើរបាយការណ៍ពិភពលោក
(Global Reporting Initiative)
www.globalreporting.org

កតិកាសញ្ញាជាសកល អង្គការសហប្រជាជាតិ
(United Nations Global Compact)
www.unglobalcompact.org

សហពលកម្មអឺរ៉ុបសម្រាប់យុត្តិធម៌សាជីវកម្ម
(European Coalition for Corporate Justice)
www.corporatejustice.org

អង្គការតម្លាភាពអន្តរជាតិ (Transparency International)
www.transparency.org

អង្គការឃ្លាំមើលសាជីវកម្ម (CorpWatch)
www.corpwatch.org

សម្ព័ន្ធភាពកម្ពុជា ដើម្បីតម្លាភាពចំណូលធនធាន
(Cambodians for Resource Revenue Transparency)
www.crrt-cambodia.org

អង្គការអ្នកសាក្សីពិភពលោក (Global Witness)
www.globalwitness.org



ព្រះចៅអធិការ វត្តអម្ពវនារាម, ខែតុលា ឆ្នាំ២០១១



“មានមនុស្សតិចតួចព្រមប្រឈមមុខ
នឹងការជំទាស់ របស់អ្នកដទៃ,
នឹងការទិតៀនរបស់ សហការី,
នឹងសេចក្តីក្រោធ របស់សង្គម។
សេចក្តីក្លាហាន ផ្នែកសីលធម៌
គឺជាគុណភាពដ៏មានតម្លៃ
កម្ររកបានមួយ ជាងភាពអង់អាច
ក្លាហាន ក្នុងសមរភូមិ ឬ ជាង បញ្ញា
ដ៏ធំធេង។ ប៉ុន្តែ វាគឺជា គុណភាព
ដ៏ចាំបាច់ និង មានសារៈសំខាន់មួយ
សម្រាប់បុគ្គល ទាំងឡាយណា ដែល
ខំស្វះស្វែង ដើម្បីផ្លាស់ប្តូរពិភពលោក
ដែលនាំមកនូវ ការឈឺចាប់ដ៏ធំធេង
ក្នុងការផ្លាស់ប្តូរ។ ហើយ ជនដែល
មានសេចក្តីក្លាហាន ក្នុងការចូល
ទៅក្នុងជម្លោះខាងសីលធម៌
នឹងរកបានមិត្តភក្តិ និង អ្នកធ្វើដំណើរ
ជាមួយ នៅទូទាំងពិភពលោក”។

— រ៉ូបឺត អ៊ែហ្វ ខិណ្ណិឌី

ROBERT F. KENNEDY

# លោក កៃឡាស៍ សាទីអាទី (Kailash Satyarthi)

"កុមារតូចៗមានអាយុ ៦ឆ្នាំ ៧ឆ្នាំ និង ចាស់ជាងនេះ ត្រូវបានគេបង្ខំឲ្យធ្វើការ ១៤ម៉ោង ក្នុងមួយថ្ងៃ, ដោយគ្មានពេលសម្រាក ឬ ថ្ងៃសម្រាក។ ប្រសិនបើពួកគេយំស្រែកទាររកឪពុកម្តាយ, ពួកគេត្រូវបានគេវាយធ្វើបាបយ៉ាងខ្លាំង, ជួនកាលចងព្យួរក្បាលចុះក្រោមពីលើដើមឈើ ហើយបានធ្វើឲ្យមានស្លាកស្នាម ឬ ដុតដោយបារី"។



Kailash Satyarthi, ©2000 Eddie Adams

លោក កៃឡាស៍ សាទីអាទី (Kailash Satyarthi) គឺជាផ្កាយចែងចាំងបង្ហាញផ្លូវមួយ របស់ប្រទេសឥណ្ឌា ចំពោះការលុបបំបាត់ចោលនូវកម្លាំងពលកម្មកុមារ។ ចាប់តាំងពីឆ្នាំ១៩៨០, គាត់បានដឹកនាំជួយសង្គ្រោះទាសករដែលបានបង់ប្រាក់ធានា និង កុមារច្រើនជាង ៧៥,០០០នាក់ នៅក្នុងប្រទេសឥណ្ឌា, ហើយបានអភិវឌ្ឍន៍គំរូដ៏ជោគជ័យមួយ សម្រាប់ការអប់រំ និង នីតិសម្បទារបស់ពួកគេ។ លោក កៃឡាស៍ (Kailash) បានរំដោះកុមាររាប់ពាន់នាក់ ពីកម្លាំងពលកម្មជាប់ប្រាក់ធានា, គឺជាទម្រង់ទាសភាពមួយពេលក្រុមគ្រួសារបាក់ទឹកចិត្តនីមួយៗ ទៅខ្ចីលុយពីអ្នកឲ្យខ្ចីម្នាក់ (ចំនួនតិចតួច៣៥ដុល្លារ), និង ត្រូវបានគេបង្ខំឲ្យប្រគល់កូនធ្វើជាប្រាក់ធានា រហូតដល់មូលនិធិនេះអាចត្រូវបានបង់សងវិញ។ ប៉ុន្តែប្រាក់នេះជាញឹកញាប់មិនដែលត្រូវបានគេបង់សងវិញទេ, ហើយកុមារនេះត្រូវបានគេលក់ ហើយលក់បន្តពីចៅហ្វាយមួយទៅចៅហ្វាយមួយទៀត។ កម្មករដោយជាប់ប្រាក់ធានាធ្វើការនៅ ក្នុងផលិតកម្មកែច្នៃត្បូងពេជ្រ, កាត់ថ្ម, ផលិតកម្ម និង ឧស្សាហកម្មនានា។ កុមារបែបនេះ ជាពិសេស ធ្វើការពាសពេញនៅក្នុងវិស័យកម្រាលព្រំសម្រាប់នាំចេញ, ដែលពួកគេបានចងកម្រាលព្រំទាំងអស់នោះ សម្រាប់ ទីផ្សារសហរដ្ឋអាមេរិក និង ទីផ្សារដទៃ។ លោក កៃឡាស៍ ធ្វើការសង្គ្រោះកុមារ និង ស្ត្រីពីការយកធ្វើជាទាសករនៅក្នុងរោងចក្រ ដែលមានកម្មករច្រើនលើសលុប, ស្មោកគ្រោក និង ស្ថិតនៅឆ្ងាយ, ដែលស្ថានភាពបរិស្ថានមានលក្ខណៈមិនល្អ, ទីកន្លែងធ្វើការជាច្រើនម៉ោងគ្មានមនុស្សធម៌, គ្មានសុវត្ថិភាព, មានការដាក់ទណ្ឌកម្មរីករាលដាល, និង ការរំលោភខាងផ្លូវភេទ។ លោក កៃឡាស៍ (Kailash) បានប្រឈមមុខនឹងការចោទប្រកាន់ក្លែងបន្លំ និង ការគម្រាមកំហែងលើជីវិតដោយសារកិច្ចការរបស់គាត់។ ការគម្រាមកំហែងលើជីវិតជាញឹកញាប់ គួរចាប់អារម្មណ៍ ពីព្រោះសហការីពីរនាក់របស់ លោក សាទីអាទី (Satyarthi) ត្រូវបានគេសម្លាប់។ គាត់ត្រូវបានគេទទួលស្គាល់នៅជុំវិញពិភពលោក ចំពោះកិច្ចការបស់គាត់ ក្នុងការលុបបំបាត់ចោលនូវកម្លាំងពលកម្មកុមារ។ លោក សាទីអាទី បានរៀបចំ និង បានដឹកនាំការដង្ហែរក្បួនយ៉ាងធំចំនួនពីរនៅទូទាំងប្រទេសឥណ្ឌា ក្នុងការផ្សព្វផ្សាយការយល់ដឹងអំពីកម្លាំងពលកម្មកុមារ។ ក្នុងឆាកពិភពលោក គាត់បានក្លាយជាស្ថាបនិក នៃបណ្តាញសង្គមស៊ីវិលដ៏ធំបំផុត សម្រាប់កុមារដែលត្រូវបានធ្វើអាជីវកម្មធ្ងន់ធ្ងរ, ហៅថា "ក្បួនដង្ហែពិភពលោកប្រឆាំងនឹងកម្លាំងពលកម្មកុមារ" ដែលមានសកម្មភាពនៅបណ្តាប្រទេសចំនួន១៤០។ លោក កៃឡាស៍ សាទីអាទី បានទទួលរង្វាន់សិទ្ធិមនុស្ស រ៉ូប៊ឺត អ៊ែហ្វ ខេណ្ណឌី (Robert F. Kennedy Human Rights Award) នៅឆ្នាំ១៩៩៥ និង រង្វាន់សិទ្ធិមនុស្ស រ៉ូល វ៉លិនប៊ឺក (Raoul Wallenberg Human Rights Award) នៅឆ្នាំ២០០២។ របាយការណ៍ស្តីពីការរត់ពន្ធមនុស្សឆ្នាំ២០០៧ របស់ក្រសួងការបរទេសសហរដ្ឋអាមេរិក បានហៅគាត់ថា ជាវីរជនធ្វើការបំបាត់ទាសភាពបច្ចុប្បន្ន (Hero Acting to End Modern Day Slavery)។

លោក សាទីអាទី (Satyarthi) សង្គ្រោះកុមារ និង ស្រ្តីពីទាសភាព នៅក្នុងរោងចក្រ ដែលមានកម្មករច្រើនលើសលុប, ស្មោកគ្រោក, និង ស្ថិតនៅឯកោ ដែលស្ថានភាពបរិស្ថានមានលក្ខណៈមិនល្អ, ជាមួយពេលវេលាធ្វើការច្រើនម៉ោងគ្មានមនុស្សធម៌, ទីកន្លែងធ្វើការគ្មានសុវត្ថិភាព, ការដាក់ទណ្ឌកម្មរឹករាលដាល, និង ការរំលោភខាងផ្លូវភេទ។ ឥឡូវនេះ លោកសាទីអាទីគឺស្ថិតនៅក្រៅឃុំដោយមានការចោទប្រកាន់ក្លែងបន្លំបានធ្វើឡើង ប្រឆាំងនឹងរូបគាត់ ដោយនាយកប្រតិបត្តិក្រុមហ៊ុននាំចេញផលិតផលកម្រាលព្រំដែលខឹងនឹងគាត់, បន្ទាប់ពី លោក សាទីអាទី បានបង្ហាញសេចក្តីថ្លែងការណ៍ ដែលចាក់ផ្សាយនៅតាមទូរទស្សន៍អឺរ៉ុប។ ការគម្រាមសម្លាប់ជាញឹកញាប់ មានការចាប់អារម្មណ៍ដោយធ្ងន់ធ្ងរ ពីព្រោះសហការីពីរនាក់របស់ លោក សាទីអាទី ត្រូវបានគេសម្លាប់។ លោក សាទីអាទី ដឹកនាំសហព័ន្ធអាស៊ីខាងត្បូងស្តីពីទាសភាពកុមារ (South Asian Coalition on Child Servitude),ដែលគាត់ជាសហស្ថាបនិក ក្នុងឆ្នាំ១៩៨៩។ ស្ថិតនៅក្រោមការដឹកនាំរបស់គាត់ សហព័ន្ធអាស៊ីខាងត្បូងស្តីពីទាសភាពកុមារ អនុវត្តន៍ យុទ្ធនាការផ្សព្វផ្សាយការយល់ដឹងជាសាធារណៈ, ការតស៊ូមតិ, វិធានការច្បាប់, និង ការធ្វើអន្តរាគមន៍ដោយផ្ទាល់ ដើម្បីរំដោះកុមារនិងស្ត្រី ឲ្យរួចផុតពីកម្លាំងពលកម្មទាសភាព និង ពលកម្មកុមារ។ សហព័ន្ធអាស៊ីខាងត្បូងស្តីពីទាសភាពកុមារ ប្រមូលផ្តុំនូវវិទ្យាស្ថានជាតិនិងអន្តរជាតិ និង អង្គការក្រៅរដ្ឋាភិបាល ដើម្បីដាក់សម្ពាធទៅលើរដ្ឋាភិបាល, រោងចក្រផលិតកម្ម និង ក្រុមហ៊ុននាំចូលនានា ក្នុងការបញ្ឈប់ការធ្វើអាជីវកម្មកម្លាំងពលកម្មខុសច្បាប់។ លោក សាទីអាទី បានរៀបចំ និងបានដឹកនាំការដង្ហែក្បួនយ៉ាងធំចំនួនពីរ នៅទូទាំងប្រទេសឥណ្ឌា ក្នុងការផ្សព្វផ្សាយការយល់ដឹង អំពីកម្លាំងពលកម្មកុមារ, ហើយក្នុងឆ្នាំ១៩៩៨ គាត់បានរៀបចំជាង ១០,០០០ អង្គការក្រៅរដ្ឋាភិបាលនៅទូទាំងពិភពលោក ដើម្បីចូលរួមនៅក្នុង ក្បួនដង្ហែពិភពលោកប្រឆាំងនឹងកម្លាំងពលកម្មកុមារ (Global March Against Child Labor)។ នៅមានការងារជាច្រើន ដែលត្រូវធ្វើ។ គ្រាន់តែនៅប្រទេសឥណ្ឌា មានកុមារពី ៦ ទៅ ១០ លាននាក់ នៅក្នុងកម្លាំងពលកម្មទាសភាព។ មានកុមារ ២៥០លាននាក់ ដែលត្រូវបានបង្ខំឲ្យធ្វើការនៅក្នុងកម្លាំងពលកម្មកុមារនៅទូទាំងពិភពលោក, ដោយរួមបញ្ចូលទាំងកុមារចំនួន ២៤៦,០០០នាក់ ដែលធ្វើការនៅក្នុងកម្លាំងពលកម្មកសិកម្ម និង នៅក្នុងហាងអាវយឺតនានា ក្នុងសហរដ្ឋអាមេរិក។ ការងាររបស់ លោក សាទីអាទី ទើបតែបានចាប់ផ្តើម។

កម្លាំងពលកម្មដែលបង់ប្រាក់ធានា គឺជាទម្រង់មួយ នៃទាសភាពសម័យថ្មី, ដែលមនុស្សសាមញ្ញបាត់បង់សេរីភាព មូលដ្ឋាននៃចលនា, សេរីភាពនៃជម្រើស។ ពួកគេត្រូវបានបង្ខំឲ្យធ្វើការជាច្រើនម៉ោង ដោយមានការឈប់សម្រាកបន្តិចបន្តួច។ កុមារចំនួនជាង ៥លាននាក់ បានកើតក្នុងភាពជាទាសករបែបនេះ។ ឪពុកម្តាយ ឬ ជីដូនជីតារបស់ពួកគេបានសុំខ្ចីប្រាក់ចំនួនបន្តិចបន្តួចពីម្ចាស់ដីនៅមូលដ្ឋាន, ហើយបន្ទាប់មកពួកគេពីជំនាន់មួយទៅជំនាន់មួយ ត្រូវតែធ្វើការឲ្យចៅហ្វាយតែមួយ។ ពួកគេ គឺជាអ្នកជាប់គុក, ត្រូវបានហាមឃាត់មិនឲ្យចាកចេញ។ កុមារចំនួន៥លាននាក់ផ្សេងទៀត ត្រូវបានគេបញ្ជូនទៅធ្វើការ នៅពេលដែលឪពុកម្តាយរបស់ពួកគេ ទទួលប្រាក់បុរេប្បទាន (ប្រាក់កក់មួយចំនួនតូចជាមុន), ហើយប្រាក់ដ៏តិចតួចនេះ ត្រូវបានគេចងក្រងពួកគាត់ ឲ្យធ្វើកិច្ចការឥតឈប់ឈរជាច្រើនឆ្នាំ ដោយទុក្ខវេទនា។

ស្ថានភាព នៃកម្លាំងពលកម្មទាសភាព គឺជាអមនុស្សធម៌ទាំងស្រុង។ កុមារតូចៗ អាយុ៦ឆ្នាំ ៧ឆ្នាំ ហើយចាស់ជាងនេះ ត្រូវបានបង្ខំឲ្យធ្វើការ១៤ម៉ោង ក្នុង១ថ្ងៃ ដោយគ្មានម៉ោងសម្រាក ឬ ថ្ងៃសម្រាក។ ប្រសិនបើកុមារទាំងអស់នោះ ស្រែកយំទាររកឪពុកម្តាយរបស់ពួកគេ, ពួកគេត្រូវបានគេវាយធ្វើបាបដោយធ្ងន់ធ្ងរ, ជួនកាលចងព្យួរក្បាលចុះក្រោមពីលើដើមឈើ ហើយបានធ្វើឲ្យមានស្លាកស្នាម ឬ ដុតដោយបារី។ ជាញឹកញាប់ ពួកគេមិនទទួលបានអាហារគ្រប់គ្រាន់ ដោយសារតែនិយោជកទាំងអស់ គិតថាប្រសិនបើពួកគេហូបអាហារគ្រប់គ្រាន់, ពួកគេនឹងងងុយដេក និង យឺតយ៉ាវនៅក្នុងការងារ។ ក្នុងករណីជាច្រើន ពួកគេមិនត្រូវបានអនុញ្ញាតឲ្យជជែកគ្នា ឬ លេងសើចខ្លាំង ពីព្រោះវាបន្ថយប្រសិទ្ធភាពការងារ។ នេះជាទាសភាពយុគសម័យកណ្តាល, ប្រៀបដូចស្ថានភាព១,០០០ឆ្នាំមុន។

យើងជឿជាក់ថា គ្មានទម្រង់ដទៃណានៃការរំលោភសិទ្ធិមនុស្ស អាចអាក្រក់ជាងនេះទេ។ នេះគឺជាបរាជ័យ ដ៏អាម៉ាស់មុខបំផុតនៃច្បាប់ឥណ្ឌា, ជារដ្ឋធម្មនុញ្ញរបស់ប្រទេសយើង និង ធម្មនុញ្ញនៃអង្គការសហប្រជាជាតិ។ អាវុធដ៏មានប្រសិទ្ធភាពបំផុតរបស់យើង នៅក្នុងស្ថានភាពបែបនេះ គឺអប់រំមហាជន និង បង្កើតការចាប់អារម្មណ៍និងការផ្សព្វផ្សាយការយល់ដឹង ប្រឆាំងនឹងសង្គមអាក្រក់នេះ។ លើសពីនេះទៀត យើងប៉ុនប៉ង កំណត់តំបន់ដែលមានទាសភាពកុមារច្រើន។ យើងធ្វើការវាយសម្រុកចូលដោយសម្ងាត់ ទៅរំដោះកុមារទាំងអស់នេះ ហើយបញ្ជូនគេទៅក្រុមគ្រួសារវិញ។ ការពិនិត្យតាមដាននូវការអប់រំ និង នីតិសម្បទារបស់ពួកគេ គឺជាជំហានដ៏សំខាន់ស្មើភាពគ្នាមួយនៅក្នុងដំណើរការទាំងមូល។ យើងតស៊ូមតិជាមួយវិស័យផ្សេងៗក្នុងសង្គម, ជាមួយតំណាងរាស្ត្រ, ជាមួយក្រុមសាសនា, ជាមួយសហជីព ហើយ ជាមួយអ្នកផ្សេងៗទៀត ដែលយើងជឿជាក់ថា អាចមានឥទ្ធិពលលើស្ថានភាពទាំងអស់នេះ។ យើងមានសហការីធ្វើការពេញម៉ោង និង ពាក់កណ្តាលម៉ោងប្រហែល ១០០នាក់ ក្នុងក្រុមយើង។ ប៉ុន្តែយើងផងដែរបានបង្កើតបណ្តាញមួយដែលមានអង្គការក្រៅរដ្ឋាភិបាល ចំនួនជាង ៤៧០ ក្នុងប្រទេសឥណ្ឌា និង ប្រទេសខាងត្បូងមួយចំនួនទៀត។

សម្រាប់យើង, ធ្វើការជាមួយកុមារទាសករ មិនមែនជាកិច្ចការស្រួលទេ។ វាពាក់ព័ន្ធទៅនឹងស្ថានភាពប៉ះទង្គិចផ្លូវចិត្តជាញឹកញាប់។ កុមារទាំងអស់នេះបានជាប់ទាសភាពតាំងពីគេអាចចងចាំបាន។ សេរីភាព គឺពាក្យមួយដែលមិនមានន័យចំពោះពួកគេ។ ពួកគេមិនស្គាល់អ្វីហៅថា "សេរីភាព"។ សម្រាប់យើង, ឧបសគ្គចម្បង គឺធ្វើយ៉ាងណាឲ្យកុមារទាំងនេះទទួលភាពជាកុមារវិញ។ វាមិនមែនងាយស្រួលដូចដែលយើងនិយាយទេ។ យើងត្រូវខិតខំធ្វើការឲ្យក្លាយជាភាពជាក់ស្ដែង។ ឧទាហរណ៍៖ កុមារាអាយុ១៤ឆ្នាំម្នាក់ឈ្មោះ ណាហ្គេស៊ីវ៉ា ដែលយើងបានរំដោះ ត្រូវបានគេដំឲ្យមានស្លាកស្នាមដោយដែកក្ដៅ។ ស្របពេលជា មួយគ្នានោះដែរ មន្ត្រីម្នាក់មកពី មជ្ឈមណ្ឌល រ៉ូបឺត អ៊ែហ្វ ខិណ្ណិឌី ដើម្បី យុត្តិធម៌ និង សិទ្ធិមនុស្ស (Robert F. Kennedy Center for Justice and Human Rights) ដែលមានវត្តមាននៅប្រទេសឥណ្ឌា បានជួបកុមារានេះ នៅទីក្រុងញ៉ូដេលី (New Delhi)។ ការប៉ះទង្គិចផ្លូវចិត្ត ដែល ណាហ្គេស៊ីវ៉ា បានឆ្លងកាត់ ធ្វើឲ្យគាត់បាត់បង់ភាពនិយាយ។ គាត់មិនអាចពន្យល់នូវស្ថានភាពរបស់គាត់បានទេ។ ក្រោយមកទើបយើងបានដឹងអំពីអ្វីៗដែលបានកើតឡើងចំពោះគាត់ តាមរយៈកុមារផ្សេងៗទៀត។ ជាការពិតណាស់ យើងមានការលំបាកក្នុងការទាក់ទាញកុមារបែបនេះ។

ដូចដែលអ្នកអាចដឹងហើយ, ការដើរដង្ហែក្បួន និង ការធ្វើដំណើរ គឺជាផ្នែកសំខាន់មួយនៃប្រពៃណីឥណ្ឌារបស់យើង។ លោក មហាម៉ាត់ គន្ធី (Mahatma Gandhi) បានដើរដង្ហែក្បួនជាច្រើនលើកជាច្រើនសារ ដើម្បីអប់រំមហាជន (ហើយផងដែរ ដើម្បីអប់រំខ្លួនគាត់)។ ដោយយើងយល់អំពីឥទ្ធិពលខ្លាំងពីការដើរដង្ហែក្បួន ជាពិសេស ក្នុងការប្រមូលផ្ដុំមហាជន, ការដង្ហែក្បួននេះ បានទទួលអាទិភាពខ្ពស់បំផុត ក្នុងយុទ្ធសាស្ត្រទូទៅរបស់យើង ក្នុងការប្រយុទ្ធប្រឆាំងនឹងទាសភាពកុមារ។ ការដើរដង្ហែក្បួន មិនមានន័យថា យើងទាមទារអ្វីៗទាំងស្រុងនោះទេ។ ការធ្វើបាតុកម្មរបស់យើង មានអ្នកចូលរួមប្រហែលពី ២០០ ទៅ ២៥០នាក់ ក្នុងនោះពាក់កណ្ដាលជាកុមារ, កុមារដែលបានរំដោះរួចផុតពីទាសភាព និង ទាសករ។ ពួកគេដើរតួជាគំរូជាក់ស្ដែង ដើម្បីអប់រំប្រជាជនអំពីផលប៉ះពាល់អវិជ្ជមាននៃប្រព័ន្ធកម្លាំងពលកម្មទាសភាព និង ផលប៉ះពាល់វិជ្ជមាននៃសេរីភាព ដែលពួកគេបានទទួលថ្មីៗ។ អ្នកដើរដង្ហែក្បួនដទៃទៀត គឺជាអ្នកតំណាងមកពីអង្គការសិទ្ធិមនុស្ស, សហជីព និង អង្គការសង្គមនានា ដែលបានចូលរួមសាមគ្គីគ្នា។ យើងធ្វើដំណើរទៅភូមិផ្សេងៗ ជារៀងរាល់ថ្ងៃ, និង រៀបចំប្រជុំជាសាធារណៈ, រឿងល្ខោនតាមដងផ្លូវនានា, សកម្មភាពវប្បធម៌, និង សន្និសីទសារព័ត៌មាន ដើម្បីផ្ញើសាររបស់យើងទៅកាន់មហាជន។

កាលពីពីរឆ្នាំមុន យើងបានស្វាគមន៍កិច្ចសន្យារបស់នាយករដ្ឋមន្ត្រី ក្នុងការប្រឆាំងនឹងកម្លាំងពលកម្មកុមារ រួមនឹង ពលកម្មទាសភាព។ យើងបានសង្ឃឹមថា នឹងមានលទ្ធផលវិជ្ជមានមួយចំនួន, មានកម្លាំងជម្រុញចិត្តមួយចំនួន ក្នុងការកែទម្រង់។ ប៉ុន្តែ តាំងពីពេលនោះមក គ្មានសកម្មភាពណាមួយបានកើតឡើងទេ។ វាគឺជាអកុសលណាស់។ សេចក្ដីប្រកាសនេះ មុនដំបូង បានបង្កើតភាពភ័យខ្លាចដល់និយោជក, ប៉ុន្តែឥឡូវនេះ វាបានបង្កើតផលផ្ទុយទៅនឹងកំណែទម្រង់នេះវិញ។

ឥឡូវនេះ មនុស្សបានយល់ដឹងថា វាគ្មានអ្វីច្រើនជាងគ្រឿងបំភាន់ខាងនយោបាយទេ ហើយថា វាគ្មានឆន្ទៈពិតប្រាកដនៅពីក្រោយវាទេ។ និយោជិកមានភាពផ្សេងៗគ្នា។ នៅពេលដែលកុមារម្នាក់ជាទាសករក្នុងភោជនីយដ្ឋានដងផ្លូវមួយ,ធម្មតា និយោជកជាមនុស្សសាមញ្ញម្នាក់នៅក្នុងភូមិ ឬ ទីប្រជុំជនដាច់ស្រយាលណាមួយ។ ប៉ុន្តែ នៅពេលដែលកុមារ ត្រូវបានគេជួលឲ្យធ្វើការនៅក្នុង ឧស្សាហកម្មតម្បាញកម្រាលព្រំ, ឬឧស្សាហកម្មកែវ ឬ ឧស្សាហកម្មផលិតផលទង់ដែង, ជាធម្មតានិយោជក គឺជាមនុស្ស "អ្នកធំ"។ ពួកគេ បង្កើតឲ្យមានទីផ្សារប្ដូរប្រាក់បរទេសជាច្រើនកន្លែង តាមរយៈការនាំទំនិញចេញ, ហើយពួកគេបានទទួលការពេញចិត្តដោយរដ្ឋាភិបាល។

ទោះបីជាយ៉ាងនេះក៏ដោយ, ខ្ញុំមិនគាំទ្រនូវការធ្វើពហិការទាំងស្រុង ឬការហាមប្រាមទាំងអស់នេះដែរ ទៅលើការនាំចេញកម្រាលព្រំឥណ្ឌា។ ផ្ទុយទៅវិញ ខ្ញុំបានស្នើសុំថា អតិថិជន គួរតែទិញកម្រាលព្រំទាំងឡាយណាដែលបានធានាថា បានធ្វើឡើងដោយគ្មានកម្លាំងពលកម្មកុមារ។ ការអប់រំអតិថិជន គឺជាកត្តាចាំបាច់មួយ ក្នុងការបង្កើតឲ្យមានតម្រូវការសម្រាប់កម្រាលព្រំបែបនេះ។ យើងជឿជាក់ថា ប្រសិនបើអតិថិជនមានគ្នាច្រើនឡើងៗ បានដាក់គំនាបលើបញ្ហានេះ, ក៏តម្រូវឲ្យនិយោជកច្រើនឡើងៗ ទទួលការបង្ខិតបង្ខំដោះលែងកម្មករកុមារ ឲ្យជំនួសដោយកម្មករវ័យចាស់វិញ។ ជាអកុសល នៅក្នុងរយៈពេលពីរបីឆ្នាំកន្លងទៅនេះ នៅក្នុងប្រទេសឥណ្ឌា, ប្រទេសប៉ាគីស្ថាន និង ប្រទេសនេប៉ាល់, ចំនួនកុមារក្នុងទាសភាពបានកើនឡើង, ទន្ទឹមទៅនឹងកំណើនទំនិញនាំចេញ។ ឧទាហរណ៍៖ បច្ចុប្បន្ននេះ នៅក្នុងប្រទេសឥណ្ឌា យើងមានកុមារប្រហែល៣០០,០០០នាក់ ដែលបម្រើការនៅក្នុងឧស្សាហកម្មកម្រាលព្រំ ដោយមានទីផ្សារនាំចេញ គឺជាង៦០០លានដុល្លារសហរដ្ឋអាមេរិកក្នុង១ឆ្នាំ។ កាលពី ១០ ឬ ១៥ឆ្នាំមុននោះ, ចំនួនកុមារមានរវាង ៧៥,០០០ ទៅ ១០០,០០០នាក់ ហើយពេលនោះ ទំនិញនាំចេញមិនលើសពី ១០០លានដុល្លារសហរដ្ឋអាមេរិកទេ។ ការទំនាក់ទំនងផ្ទាល់នៅក្នុងចំណោមតួលេខទាំងពីរនេះ គឺជាភស្តុតាងជាក់ច្បាស់មួយ។ ហេតុការណ៍ពិតនេះ បានបង្ខិតបង្ខំយើងឲ្យចាប់ផ្ដើមបើកយុទ្ធនាការអតិថិជន ក្រៅប្រទេសមួយ។ សុខភាព និង បរិស្ថាន គឺជាបញ្ហាកង្វល់ដំបូងក្នុងចំណោមអតិថិជននៅបស្ចិមប្រទេស, គឺក្នុងប្រទេសអាល្លឺម៉ង់ និង ក្នុងសហរដ្ឋអាមេរិក។ ប៉ុន្តែ បញ្ហាកុមារ គឺមិនដែល បានភ្ជាប់ទៅ

នឹងការយល់ដឹងរបស់អតិថិជននេះទេ។ ប្រជាជន បានគិតអំពី បរិស្ថាន និង សិទ្ធិសត្វ, ប៉ុន្តែ ពួកគេមិនដែលគិត អំពីបញ្ហាកុមារទេ។ ប៉ុន្តែ នៅក្នុងរយៈពេលពីរបីឆ្នាំកន្លងទៅនេះ ខ្ញុំមានមោទនភាពយ៉ាងខ្លាំងដែលថា បញ្ហាកម្លាំងពលកម្មកុមារ បានទទួលនូវកម្លាំងចលករ និង បានក្លាយទៅជាយុទ្ធនាការដ៏ធំមួយ នៅក្នុងពិភពលោក។ អ្វីដែលបានចាប់ផ្តើមដោយមានការផ្សព្វផ្សាយការយល់ដឹង និង ការផ្សព្វផ្សាយជាសាធារណៈឥឡូវនេះ បានពង្រីកទៅលើ បញ្ហានៃការអនុវត្តតាម។

យើងបានស្នើសុំឲ្យមានការបង្កើត ស្ថាប័នឯករាជ្យ, មានវិជ្ជាជីវៈ និង ជំនឿជឿជាក់ជាអន្តរជាតិមួយ ដើម្បីធ្វើអធិការកិច្ច, ពិនិត្យតាមដាន, ហើយចុងបញ្ចប់ ផ្តល់សញ្ញាទទួលស្គាល់កម្រាលព្រំ និង ផលិតផលដទៃទៀត បានធ្វើឡើងដោយគ្មានកម្លាំងពលកម្មកុមារ។ យើងបានបង្កើតមូលនិធិរ៉ុកម៉ាក (Rugmark Foundation) ជាស្ថាប័នឯករាជ្យមួយជាមួយអង្គការក្រៅរដ្ឋាភិបាលដូចជា មូលនិធិសហប្រជាជាតិដើម្បីកុមារ ( យូនីសេហ្វ / UNICEF )។ ពួកគេតែងតាំងអធិការកិច្ចមូលដ្ឋានជាច្រើន, និង ផ្តល់តួលេខបញ្ជាក់ អំពីកម្រាលព្រំទាំងអស់នេះ ពិព័ណ៌នាសេចក្តីលម្អិតអំពីប្រវត្តិផលិតកម្មកម្រាលព្រំ។ ស្លាកទាំងអស់នេះ ត្រូវបានត្បាញនៅលើផ្នែកខាងខ្នងនៃកម្រាលព្រំ, ហើយ គ្មាននរណាម្នាក់អាចដកហូត ឬ ប្តូរផ្លាកបានទេ។ នេះ គឺជាជំហានដ៏សំខាន់មួយ នៅក្នុងការបញ្ចប់ការធ្វើអាជីវកម្មនេះ។

ប៉ុន្តែ សូម្បីតែ កិច្ចការនៃការអប់រំអតិថិជនបស្ចឹមប្រទេស គឺមិនងាយស្រួលពេកទេ។ វាមានហានិភ័យ។ ឧទាហរណ៍៖ បន្ទាប់ពីការសិក្សាស្រាវជ្រាវលើកដំបូង ក្រុមហ៊ុនទូរទស្សន៍អាល្លឺម៉ង់ បានចាក់បង្ហាញអំពីការងាររបស់កុមារនៅ ក្នុងក្រុមហ៊ុនឧស្សាហកម្មនាំចេញកម្រាលព្រំ។ រឿងនេះ ទាក់ទងក្រុមហ៊ុននាំចូលមួយ នៅក្នុងប្រទេសអាល្លឺម៉ង់ ឈ្មោះថា អាយឃីយ៉ា (IKEA) ដែលបានប្រកាសថា ផលិតផលរបស់ពួកគេគ្មានកម្លាំងពលកម្មកុមារទេ។ ដូច្នេះ អ្នកកាសែតបានចាប់ផ្តើមធ្វើការស៊ើបអង្កេត។ ពួកគេបានមកកាន់ការិយាល័យ និង អាស្រម (ashram) របស់ខ្ញុំ, ហើយបានធ្វើបទសម្ភាសជាមួយខ្ញុំ។ បទសម្ភាសនេះ គឺមានលក្ខណៈទូទៅ, ប៉ុន្តែ ក្រោយមកនៅពេលដែលភាពយន្តនេះត្រូវបានបង្ហាញ, គេបានលើកឈ្មោះ ក្រុមហ៊ុននាំចេញស៊ីណា (Sheena Export) ដោយ លម្អិត, ធ្វើឲ្យគ្មានការលុបចោលនូវការទិញធំមួយពីក្រុមហ៊ុន អាយឃីយ៉ា (IKEA)។ ក្រុមហ៊ុននាំចេញស៊ីណា (Sheena Export), ជាអ្នកដើរតួដ៏ធំបំផុតមួយនៅក្នុងវិស័យនេះ, គឺទទួលឈ្មោះអាក្រក់ មានការដឹងឮគ្រប់ៗគ្នា ធ្វើឲ្យមានការប៉ះពាល់ដល់ទំនិញនាំចេញរបស់ពួកគេទៅកាន់បណ្តាប្រទេសនានា, ដោយរួមបញ្ចូលទាំងសហរដ្ឋអាមេរិក ដែលមានតម្លៃ ២០០លានដុល្លារសហរដ្ឋអាមេរិកក្នុងមួយឆ្នាំ។ ក្រុមហ៊ុននេះ មានអំណាចខាងនយោបាយខ្លាំងណាស់ ( បងប្អូនប្រុសម្នាក់ គឺជារដ្ឋមន្ត្រីនៃ ក្រសួងដឹកបញ្ជូន និង សាធារណការនៅក្នុងរដ្ឋហាយ៉ាណា (Haryana), ហើយដូច្នេះ ពួកគេបានសម្រេចចិត្តក្នុងការប្រយុទ្ធតបត។

ខ្ញុំដឹងថា ក្រុមហ៊ុនឧស្សាហកម្មកម្រាលព្រំទាំងមូល ឬ ចំនួនភាគច្រើននៃក្រុមហ៊ុនឧស្សាហកម្មនេះ ប្រឆាំងនឹងរូបខ្ញុំ។ ពួកគេជឿជាក់ថា ខ្ញុំគឺជាសត្រូវរបស់ពួកគេ។ ពួកគេចង់សម្លាប់ខ្ញុំ។ ពួកគេចង់យកខ្ញុំទៅកាន់រដ្ឋហាយ៉ាណា, ជារដ្ឋដែលគេដឹងថា មានការរំលោភសិទ្ធិមនុស្សយ៉ាងអាក្រក់បំផុត, ឱកាសក្លែងបន្លំ (fake encounters), ការឃុំឃាំងខុសច្បាប់, និង ការសម្លាប់មនុស្ស នៅក្នុងពន្ធនាគារ និង ស្ថានីយ៍ប៉ូលីស។ ខ្ញុំត្រូវបានគេចាប់ខ្លួន នៅថ្ងៃទី១ខែមិថុនា។ ពួកគេចង់ចាប់ខ្លួនខ្ញុំដោយស្របច្បាប់, ប៉ុន្តែ ពួកគេមិនដែលបានប្រាប់បូលីសនៅទីក្រុងដេលី (Delhi) ប្រសិនបើស្របច្បាប់ប្រទេសឥណ្ឌា។ ពីព្រោះប៉ូលីសមកពីរដ្ឋផ្សេងៗ និង មិនមានអំណាចច្បាប់ទេ, ពួកគេមិនអាចចាប់ខ្លួនខ្ញុំនៅក្នុងផ្ទះរបស់ខ្ញុំ នៅទីក្រុងដេលី ដោយស្របច្បាប់ទេ។ ប៉ុន្តែ ពួកគេបានព្យាយាម។ ខ្ញុំបានទូរស័ព្ទពិគ្រោះយោបល់ជាមួយមនុស្សពីរបីនាក់លើបញ្ហានេះ, ហើយទីបញ្ចប់ ខ្ញុំបានប្រាប់ពួកគេថា ពួកគេមិនអាចចាប់ខ្លួនខ្ញុំបានទេ។ បូលីសនៅរដ្ឋហាយ៉ាណា មិនបានស្តាប់ខ្ញុំ និង បានគម្រាមកំហែងសម្រុកចូលផ្ទះខ្ញុំ។ ពួកគេបានទាញយកកាំភ្លើងចេញ។ ដូចដែលអ្នកអាចស្រមើស្រមៃ, វត្តមានរបស់ពួកគេ បានបង្កើតភាពតក់ស្លុតនៅជិតខាង។ ហើយចុងក្រោយ ខ្ញុំត្រូវបានគេចាប់ខ្លួន, និង ក្រោយមកទៀត ត្រូវបានគេដោះលែងឲ្យនៅក្រៅឃុំ។ វាមិនមានជាលើកទីមួយទេ, ថ្វីបើ វាជាលើកទីមួយដែលថា ផែនការដ៏ធំមួយ ត្រូវបានគេប្រឌិតឡើងប្រឆាំងនឹងរូបខ្ញុំក៏ដោយ។ កាលពីដើម ខ្ញុំជួនកាលបានប្រឈមនឹងការគម្រាមកំហែង។ សហការីរបស់ខ្ញុំពីរនាក់ត្រូវបានគេសម្លាប់ផងដែរ ។

ខ្ញុំគិតថា រឿងរ៉ាវទាំងអស់ ជាការសាកល្បង។ នេះ គឺជាការពិនិត្យទឹកចិត្តដែលគេត្រូវតែសាកល្បង។ ប្រសិនបើ អ្នកសម្រេចចិត្តក្រោកឈរប្រឆាំងនឹងសង្គមអាក្រក់បែបនេះ, អ្នកត្រូវតែត្រៀមខ្លួនទុកមុនជាស្រេច, មិនត្រឹមតែខាងផ្លូវកាយ ឬ ផ្លូវចិត្តប៉ុណ្ណោះទេ, ថែមទាំងផ្នែកស្មារតីទៀតផង។ ម្នាក់ៗត្រូវតែពង្រឹង និង បង្រួមស្មារតីរបស់ខ្លួន ដើម្បីពលីកម្មដ៏ឧត្តម, និងមនុស្សជាច្រើនបានធ្វើបែបនេះហើយ ពីអតីតកាល, ដូចជា លោក រ៉ូបឺត អ៊ែហ្វ ខិណ្ណិឌី (Robert F. Kennedy), លោក មហាម៉ាត់ គន្ធី (Mahatma Gandhi), លោកស្រី អ៊ិនឌីរ៉ា គន្ធី ( Indira Gandhi ), លោក ចន ខិណ្ណិឌី (John Kennedy) -- បញ្ជីឈ្មោះនេះអាចបន្តដោយគ្មានទីបញ្ចប់។ ការតស៊ូ គឺតែងតែមានជានិច្ច, យើងផងដែរត្រូវតែត្រៀមខ្លួនដើម្បីបុព្វហេតុនេះ។ មិនយូរមិនឆាប់ យើងនឹងត្រូវប្រឈមនឹងបញ្ហានេះ។ ហើយម្យ៉ាងវិញទៀត វាគឺជាប្រវត្តិសាស្ត្រនៃមនុស្សជាតិ។

# កម្លាំងពលកម្មកុមារ

លោក កៃឡាស់ សាទីអាទី　　　　បញ្ហាសិទ្ធិមនុស្ស៖ សិទ្ធិកុមារ និង កម្លាំងពលកម្ម

## សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស

- មាត្រា៤៖ សេរីភាពរួចផុតពីទាសភាព
- មាត្រា២៣៖ សិទ្ធិមានការងារ តាមបំណង និង ចូលរួមសហជីពពាណិជ្ជកម្ម
- មាត្រា២៤៖ សិទ្ធិមានការឈប់សម្រាក និង ការលំហែកំសាន្ត
- មាត្រា២៥៖ សិទ្ធិទទួលបានស្តង់ដារជីវភាពរស់នៅគ្រប់គ្រាន់
- មាត្រា២៦៖ សិទ្ធិទទួលបានការអប់រំ

## តម្រូវការពេលវេលា៖ ១២០នាទី

## សំណួរណែនាំ

- តើហេតុអ្វីបានមាន កម្លាំង ពលកម្មកុមារ?
- តើខ្ញុំអាចធ្វើឲ្យមានការផ្លាស់ប្តូរ នូវការបញ្ចប់កម្លាំងពលកម្មកុមារ តាមរបៀបណា?
- តើ ខ្ញុំអាចស្វែង រកឧទាហរណ៍ នៃ កម្លាំងពលកម្មកុមារ តាមរបៀបណា ជាប់ទាក់ទងនឹងសហគមន៍ របស់ខ្ញុំ។

## គោលបំណង

បន្ទាប់ពីមេរៀននេះសិស្ស នឹង អាច៖

- យល់ដឹងអំពី បុព្វហេតុ និងស្ថានភាព នៃ កម្លាំងពលកម្មកុមារ នៅ អាស៊ីខាងត្បូង។
- ពន្យល់នូវ របៀប ដែល លោក កៃឡាស់ សាទីអាទី ប្រយុទ្ធប្រឆាំង នឹង កម្លាំងពលកម្មកុមារ នៅ អាស៊ីខាងត្បូង។
- យល់ដឹង អំពីរបៀប ដែល ក្រុមហ៊ុន រ៉ាកម៉ាក (RugMark) និង ចលនាពាណិជ្ជកម្មយុត្តិធម៌ (Fair Trade) គាំទ្រការអនុវត្តកម្លាំងពលកម្មត្រឹមត្រូវ។
- កំណត់នូវ បុព្វហេតុ នៃកម្លាំងពលកម្មកុមារ និង នូវអ្វីដែលត្រូវធ្វើឡើង នៅក្នុងការទប់ស្កាត់។
- សិក្សាស្រាវជ្រាវ នូវ តំបន់ ឬ ឧស្សាហកម្មណាមួយ ដែលប្រើកម្លាំងពលកម្មកុមារ និង រៀបចំចាត់វិធានការដោះស្រាយ។
- បង្កើត ផែនការសកម្មភាព ក្នុងការប្រយុទ្ធប្រឆាំង នឹង កម្លាំងពលកម្មកុមារ។

## ជំនាញរបស់សិស្ស

- ប្រមូលទិន្នន័យ, អង្គហេតុ / ព័ត៌មាន និង គំនិតនានា។
- ស្វែងរក ការទំនាក់ទំនង, គោលគំនិត និង ការសិក្សាទូទៅ។
- ប្រើប្រាស់នូវ ចំណេះដឹង ពីប្រភពតាមមាត់, សរសេរជាលាយល័ក្ខអក្សរ និង តាមអេឡិចត្រូនិច។
- បកស្រាយ ព័ត៌មាន នៅក្នុងពាក្យពេចន៍ផ្ទាល់ខ្លួនរបស់ពួកគេ។
- អនុវត្តព័ត៌មាន ពី បរិបទមួយ ទៅ បរិបទមួយទៀត។

## សម្ភារៈសិក្សា

- កំណាព្យ "សំណួរ ពី បុគ្គលិកម្នាក់ ដែលអាន" ដោយ Bertold Brecht www.rethinkingschools.org
- ចេក (banana)
- ទិនានុប្បវត្តិ របស់សិស្ស
- បទសម្ភាសរបស់លោក កៃឡាស់ សាទីអាទី www.civicus-cam.org

## វាក្យស័ព្ទ

- កម្លាំងពលកម្មទាសភាព (bonded labor)
- សមាជិកតំណាងរាស្ត្រ
- ការប្រមូលផ្តុំមហាជន
- សាមគ្គីភាព (solidarity)
- ការធ្វើពហិការ (boycott)
- កម្មករ អន្តោប្រវេសន៍ / ចលនា (migrant worker)
- ការតស៊ូមតិ (advocacy)
- សេរីភាព (emanicipate)
- ប្រព័ន្ធវណ្ណៈ នៅប្រទេសឥណ្ឌា (caste system)
- ជនទាបជាងគេក្នុងប្រព័ន្ធវណ្ណៈ (untouchables)

## គោលគំនិត

- កម្លាំងពលកម្មទាសភាព (bonded labor)
- ទាសភាពកុមារ
- កម្លាំងពលកម្ម អន្តោប្រវេសន៍ / ចលនា (migrant labor)
- សេចក្តីថ្លៃថ្នូររបស់មនុស្ស (human dignity)
- សេចក្តីក្លាហាន

# សកម្មភាពរបស់សិស្ស

## ស្ថានភាពព្រាងទុក

- សូមបង្ហាញផ្ទៃចេកទៅសិស្ស៖
  - បង្គាត់សិស្ស ឲ្យបរិយាយ អំពី អ្វីដែល ពួកគេមើល នៅក្នុងទិនានុប្បវត្តិ របស់ពួកគេ។
- ស្នើសិស្ស ឲ្យចែករំលែកចម្លើយឆ្លើយតប ជាមួយដៃគូ។

## សកម្មភាពទី១

សូមឲ្យសិស្សអង្គុយជារង្វង់។

- ផ្តល់កំណាព្យ ឲ្យសិស្ស "សំណួរដែល យកមក ពី កម្មករម្នាក់ ដែលអាន"។
- ស្នើសិស្ស ឲ្យអាន កំណាព្យនេះដោយ ស្ងៀមស្ងាត់។
- បន្ទាប់មកទៀត អានឲ្យខ្លាំងៗ ដល់ពួកគេ។
- សូមប្រគល់ ឲ្យសិស្សនូវ អត្ថបទ ឃ្លាំមើលសិទ្ធិមនុស្ស។
- សូមបង្គាត់ សិស្ស ឲ្យអាន អត្ថបទជាមួយដៃគូម្នាក់។
  - សូមបង្គាត់ សិស្ស ឲ្យឆ្លើយសំណួរ ដោយស្វែងរក អត្ថបទគាំទ្រចម្លើយ ដោយគូសបន្ទាត់ពីក្រោម នូវព័ត៌មាន/ចម្លើយ នៅក្នុងអត្ថបទនេះ និង សរសេរចំនួនសំណួរ ដែលនៅជិតវា។
  - សូមឲ្យសិស្សបំពេញឯកសារសំណួរ អន្តរវិន័យថា"របាយការណ៍ស្តីពី ការឃ្លាំមើលសិទ្ធិមនុស្ស"

## សកម្មភាពទី២

- បន្ទាប់ពី ការអានបទសម្ភាស និង ឆ្លើយ សំណួរនានា សូមឲ្យសិស្សទាំងអស់ ដែលនៅក្នុងកិច្ចពិភាក្សា ក្នុងថ្នាក់ ឆ្លើយសំណួរ៖
  - តើកុមារ ដែលធ្វើការ នៅក្នុង រោងចក្រកម្រាលព្រំ នៅអាស៊ី ខាងត្បូង ជាទាសករ ដែរ ឬ ទេ? តើមូលហេតុអ្វី ឬ ក៏គ្មាន មូលហេតុអ្វីទេ?
  - តើមូលហេតុអ្វី បានកុមារទាំងអស់ នោះ ត្រូវបានគេលក់ធ្វើជាទាសករ?
  - តើមូលហេតុអ្វី បានជា រោងចក្រ នៅតែមានក្នុងប្រទេសឥណ្ឌា បើ កម្លាំងពលកម្មកុមារ បានចាត់ទុកថា ខុសច្បាប់នៅទីនោះក៏ដោយ?
  - តើមូលនិធិ រ៉ាកម៉ាក (Rugmark) ជួយ ប្រយុទ្ធប្រឆាំងនឹងកម្លាំងពលកម្មកុមារ យ៉ាងដូចម្តេច?
  - តើយើងអាចធ្វើដូច ពលរដ្ឋ សហរដ្ឋអាមេរិក ដូចម្តេច នៅក្នុងការការពារពលករកុមារ នៅប្រទេសកម្ពុជា?

## សកម្មភាពទី៣

- សូមស្នើសិស្ស ឲ្យឆ្លើយតបទៅនឹង សេចក្តីដកស្រង់ ខាងក្រោម និង ស្នើពួកគេ ឲ្យគិត អំពី របៀបដែល ខ្លួនបានស្នើសុំប្រវត្តិរឿងរ៉ាវ ឬ អត្ថបទ មួយចំនួន ដែលពួកគេបានអាននៅ ទូទាំងមេរៀននេះ។

"កុំមានមន្ទិលសង្ស័យថា មនុស្សមាន ភក្តីភាពមួយក្រុមតូច អាចធ្វើការផ្លាស់ប្តូរ ពិភពលោកឡើយ។ ជាការពិតណាស់ មានតែពួកគាត់ទេ ដែលធ្វើឲ្យកើតមាន ជាធម្មតា"។ ("Never doubt that a small group of people can change the world. Indeed, it is the only thing that ever has." Margaret Mead)

- សូមបង្គាត់សិស្ស ឲ្យជ្រើសរើស នូវ ប្រយោគ ខាងក្រោមមួយ ដើម្បី ក្លាយទៅជា អ្នកការពារសិទ្ធិមនុស្ស។
  - សរសេរកំណាព្យមួយ ដើម្បី ចែករំលែក អំពី ពលកម្មកុមារ។
  - បង្កើតផ្ទាំងក្រដាសមួយ ដែល បង្រៀនបញ្ហានេះ ដល់សិស្ស។ អ្នកត្រូវប្រើប្រាស់ យ៉ាងហោចណាស់ ប្រភពពីរ។ សូមសរសេរ ព័ត៌មាន នៅក្នុងពាក្យផ្ទាល់របស់អ្នក (គ្មានការ លួចចំលង), ហើយ មានក្រាហ្វិក (graphics) ដើម្បីបង្ហាញ អំពី ចំណុច សំខាន់ របស់អ្នក។ ក្រដាសផ្ទាំងរបស់ អ្នក នឹងត្រូវដាក់បង្ហាញ នៅសាលារៀន។
  - សរសេរប្រវត្តិរឿងមួយ ដើម្បី ចែករំលែកជាមួយថ្នាក់, ដូចជា សៀវភៅរបស់កុមារ ដែលបាន បង្ហាញស្រាប់ ។
- ផលិតបទចម្រៀងមួយ ឬ វីដេអូ (video) (អ្នកផងដែរ ចាំបាច់ ដាក់អមចំណុចនេះ ជាមួយនឹងកថាខ័ណ្ឌ ដោយពន្យល់ និង ការពារ នូវទស្សនៈ របស់អ្នក)។ អ្នកអាច សរសេរបទកាព្យខ្លីៗថ្មី ទៅដាក់បញ្ចូល បទចម្រៀង ដែលមានស្រាប់។ អ្នកត្រូវ តែច្រៀងចម្រៀងរបស់អ្នក ឬ បង្ហាញ វីដេអូ របស់អ្នក នៅក្នុងថ្នាក់។ អ្នកអាច ធ្វើលើការងារនេះជាមួយដៃគូម្នាក់។

# ព័ត៌មានបន្ថែម

**ភាពយន្ត កុមារភាពបាត់បង់ (Video: Stolen Childhoods (2005) Galen Films)**

www.stolenchildhoods.org

ឯកសារភាពយន្ត ស្តីពី កម្លាំងពលកម្មកុមារពិភពលោក, ភាគខ្លះ ស្តីពី កម្មករផ្ទេកកម្រាលព្រំ និង លោក គៃឡាស់ សាទីអាទី។

**អង្គការ យូនីសេហ្វ (UNICEF)**

www.unicef.org

**អនុសញ្ញាស្តីពីសិទ្ធិកុមារ (Convention on the Rights of the Child)**

www.unohchr.org

**អង្គការពលកម្មអន្តរជាតិ–ទម្រង់អាក្រក់ជាងគេនៃពលកម្មកុមារ (International Labor Organization – Worst Forms of Child Labor Convention)**

www.ilo.org

**លើកកម្ពស់កុមារទី១ (Children's First)**

www.childrensfirst.org.za

**អង្គការសង្គ្រោះកុមារ (Save the Children)**

www.savethechildren.org

**អង្គការទស្សនៈពិភពលោក (World Vision Cambodia)**

www.worldvision.org.kh

**អង្គការរំដោះកុមារ (Free the Children)**

www.freethechildren.org

**អង្គការអន្តរជាតិទេសន្តរប្រវេសន៍ (International Organization for Migration, IOM )**

www.iom.org

**អង្គការប្រឆាំងទាសភាពអន្តរជាតិ (Anti-Slavery International)**

www.antislavery.org



ឃែរី ខិណ្ណិឌី, អារៀល ដ័ហ្វមែន ជាអ្នកនិពន្ធការសម្តែង ជាមួយតារា ហូលីវូដ
នៅទីក្រុង ញូវយ៉ក ឆ្នាំ ២០១០

“អនាគត មិនមែន
ជាអំណោយទានទេ៖
វាជាសមិទ្ធិកម្ម។
រាល់ជំនាន់ជួយបង្កើត
អនាគតរបស់គេ។
នេះជាការប្រឈមមុខ
ដ៏សំខាន់ នៃបច្ចុប្បន្នកាល”។

— រ៉ូបឺត អ៊ែហ្វ ខិណ្ណិឌី
ROBERT F. KENNEDY



# សេចក្ដីក្លាហាន
# គ្មានព្រំដែន

## សម្លេងចេញពីទីងងឹត

ដោយ អារៀល ដ័ហ្វមែន (Ariel Dorfman)

ដកស្រង់ចេញពីសៀវភៅ *សេចក្ដីក្លាហានគ្មានព្រំដែន* (Speak Truth To Power)

និពន្ធដោយ លោកស្រី ឃែរី ខិណ្ណិឌី (Kerry Kennedy)

# សាររបស់អ្នកនិពន្ធ




វាមិនមែនជាការងាយស្រួលទេ ដែលសម្លេងទាំងអស់នោះបានមកដល់យើង។ ដំបូង ពួកគេត្រូវជំនះភាពភ័យខ្លាចជាមុនសិន។ ភាពភ័យខ្លាចជានិច្ចកាល តែងតែជាចំណុចចាប់ផ្តើម នៃរាល់ការធ្វើដំណើរទាំងនោះ។ ភាពភ័យខ្លាច, និង កូនភ្លោះដ៏អាក្រក់មួយទៀតគឺអំពើហិង្សា,តែងតែជាចំណុចចាប់ផ្តើមនៃរាល់ការធ្វើដំណើរទាំងនោះ ដើម្បីឆ្ពោះទៅរកភាពក្លាហាន។

រាងកាយសម្រាប់ផ្ទុកសម្លេងទាំងនោះ រមែងទទួលរងការឈឺចាប់ ដោយសារអំពើហិង្សាលើខ្លួនឯងផ្ទាល់ ឬ ពួកគេបានឃើញដោយផ្ទាល់ភ្នែកនូវអំពើហិង្សាដែលបានប្រព្រឹត្តិឡើងទៅលើ មនុស្សណាម្នាក់, ក្រុមណាមួយ ឬ ជាតិសាសន៍ណាមួយផ្សេងទៀត។ អ្នកខ្លះ បានឃើញ គេចាប់ជំរិតឪពុកម្នាក់ ឬ កូនប្រុសម្នាក់ ឬ ភរិយាម្នាក់ត្រូវពង្រត់ ហើយយកទៅបាត់នៅពេលយប់។ អ្នកខ្លះទៀត បានឃើញកុមារដែលត្រូវបានបង្ខំឲ្យក្លាយជាអ្នកធ្វើសង្គ្រាមនិងត្រូវគេបង្ខំឲ្យសម្លាប់ទាំងខ្លួននៅវ័យក្មេង។ រូបគេនីមួយៗ បានឃើញអ្វីមួយ ដែលមិនអាចអត់ឱនទោសឲ្យបាន, ដូចជា៖ បុរសម្នាក់ត្រូវបានសម្លាប់ដោយសារតែ ពណ៌សម្បុរស្បែករបស់គាត់ ឬ ពណ៌សម្បុរនៃទស្សនៈយោបល់របស់គាត់, មនុស្សដែលគេយកទៅដាក់ក្នុងបន្ទប់គ្មានខ្យល់ និង សម្លាប់ចោលស្រស់ៗ, ទាហានបាញ់ទៅលើមនុស្ស, ស្ត្រីទទួលរងការស្អប់ខ្ពើម ដោយសារតែ ការសម្រេចចិត្តលើបញ្ហាផ្លូវភេទ។ ពួកគេបានឃើញការប្លន់ដីដូនតាពីម្ចាស់ដើមរបស់គេ, ការបំផ្លាញព្រៃឈើ, ការហាមឃាត់មិនឲ្យប្រើភាសា។ ពួកគេបានឃើញ ការបាំងឃាំងសៀវភៅ, មិត្តភក្តិទទួលរងអំពើទារុណកម្ម, យុវជនត្រូវគេបង្ខំឲ្យក្លាយជាទាសករ។ ពួកគេបានឃើញ មេធាវីត្រូវជាប់ពន្ធធានាគារ និង បណ្តេញឲ្យចេញពីក្នុងប្រទេស ដោយសារ មេធាវីទាំងនោះការពារជនរងគ្រោះ។ ក្រោយមក មានអ្វីមួយបានកើតឡើង។ អ្វីមួយដែលវិសាមញ្ញ និង ស្ទើរតែជាអព្ភូតហេតុ។ ពួកគេបានរកឃើញវិធីក្នុងការនិយាយចេញមក, ហើយបានសម្រេចចិត្តថា ពួកគេពុំអាចរស់នៅកើតទៀតបានទេ បើសិនជាពួកគេមិនធ្វើអ្វីសោះនោះ, ពួកគេមិនអាចបំផ្លាញជីវិតខ្លួនឯង ដោយត្រូវនៅស្ងៀមមិនធ្វើអ្វីនោះទេ។ ហើយនៅពេលដែលពួកគេបាននិយាយចេញមក ពួកគេបានរកឃើញថា មិនមែនអំពើហិង្សាទេ តែគឺការភ័យខ្លាចទេ ដែលបានបាត់បង់ទៅបន្តិចម្តងៗ។ នៅពេលដែលពួកគេនិយាយចេញមក ហើយឃើញថាមានមនុស្សដទៃស្ថិតនៅលើផ្លូវជាមួយពួកគេ,មានសម្លេងដទៃមកពីទីជិតទីឆ្ងាយដែរនោះ,ពួកគេបានចាប់ផ្តើមរកឃើញវិធីក្នុងការគ្រប់គ្រងការភ័យខ្លាច, កុំឲ្យភាពភ័យខ្លាចមកត្រួតត្រាពួកគេ។

ខ្ញុំបាទរៀបចំខ្លួនពេញមួយជីវិតខ្ញុំហើយ សម្រាប់ឱកាសបានក្លាយជាស្ពានសម្រាប់ពួកគេ។ តាំងតែពីវ័យកុមារមក ហើយចាប់តាំងពីពេលដែលខ្ញុំមានអារម្មណ៍ក្តុកក្តួលក្នុងចិត្ត ដោយសារអំពើអយុត្តិធម៌ ដែលបានកើតឡើងជុំវិញខ្លួនខ្ញុំមក។ នៅពេលខ្ញុំធំដឹងក្តីនិងដឹងថាអំពើហិង្សាដែលមានទម្រង់គួរឲ្យសោកសង្រេងទាំងនោះ កំពុងកើតមាននៅក្បែរខ្លួនខ្ញុំសោះ។ បន្ទាប់មក នៅពេលខ្ញុំមានវ័យជាយុវជនម្នាក់ នៅពេលដែលខ្ញុំបាទឃើញផ្ទាល់ភ្នែក ពេលរបបផ្តាច់ការគ្រប់គ្រងប្រទេសឈីលី (Chile) របស់ខ្ញុំនោះ, ពេលខ្ញុំបានឃើញមិត្តភក្តិរបស់ខ្ញុំត្រូវគេធ្វើទុក្ខទោស និង សម្លាប់ខណៈពេលដែលខ្ញុំត្រូវគេសង្គ្រោះ, ហើយត្រូវធ្វើនិរទេស និង ត្រាច់ចរទៅគ្រប់ទិសទីក្នុងពិភពលោក, ហើយគ្រប់កន្លែងក្នុងពិភពលោកសុទ្ធតែមានដាននៃវិសមភាពដូចៗគ្នា បានកើតឡើងពីកន្លែងមួយទៅកន្លែងមួយ។

ពេលនោះ ដល់ពេលដែលខ្ញុំត្រូវព្យាយាម និងរកវិធីធ្វើយ៉ាងណា ដើម្បីឲ្យខ្ញុំអាចសរសេររឿងរ៉ាវ និងរកពាក្យពេចន៍មកថ្លាថ្លែង ទឹកចិត្តមនុស្ស ដែលរងភាពឈឺចាប់ខ្លោចផ្សាដ៏សែនក្រៃលែង និងថ្លាថ្លែង ពីភាពស្មុគស្មាញ និង អាថ៌កំបាំង កាន់តែជ្រាលជ្រៅនៃអំពើបិសាចទាំងនោះ។ ចាប់តាំងពីពេលនោះមក ខ្ញុំបានរង់ចាំឱកាសដើម្បីបញ្ចេញទេពកោសល្យសិល្បៈខ្ញុំម្តងទៀត ដើម្បីបំរើដល់អ្នកដែលបានជួយឲ្យខ្ញុំមានភាពកក់ក្តៅ នៅពេលដែលខ្ញុំកំពុងស្ថិតនៅក្នុងគ្រាដ៏លំបាកនោះ។

ខ្ញុំគិតថា ខ្ញុំមានភ័ព្វសំណាងគ្រប់គ្រាន់ ក្នុងការទទួលបានសម្លេងទាំងអស់នេះ ដូចដែលអ្នកបានទទួល ការប្រសិទ្ធពរជ័យនៅក្នុងទីងងឹត, ហើយខ្ញុំមានភ័ព្វសំណាងគ្រប់គ្រាន់ដែលបានប្រែសម្លេងទាំងអស់នេះជាទ្រង់ទ្រាយ ជាល្ខោនសម្តែងបែបនេះ។ ខ្ញុំបានចំណាយពេលពេញមួយជីវិតក្នុងការស្វែងរកសម្លេងមួយរបស់ខ្ញុំដើម្បីឲ្យស៊ីសង្វាក់ទៅនឹងសម្លេងទាំងអស់នោះ។

សូមអ្នក ទទួលយកសម្លេងទាំងនេះ ទៅផ្ទះវិញជាមួយអ្នក។ សូមអ្នកយកសម្លេងទាំងនេះ ទៅផ្សាយជុំវិញពិភពលោក។ ពីព្រោះ ពិភពលោកមួយនេះ ជាពិភពលោក ដែលត្រូវការ ការផ្លាស់ប្តូរ។ សូមអ្នកដឹងថា៖ ពិភពលោកនេះ មិនត្រូវស្ថិតនៅរបៀបដូចសព្វថ្ងៃនេះ ជារៀងរហូតនោះទេ។



នៅវត្តអារញ្ញ ក្នុងខេត្តកំពង់ឆ្នាំង, ថ្ងៃទី៩ ខែតុលា ឆ្នាំ២០១១

## អំពីរឿងសម្តែងនេះ

*សេចក្តីក្លាហានគ្មានព្រំដែន៖* សម្លេងចេញពីទីងងឹត (*Speak Truth To Power*: Voices from Beyond the Dark) ជារឿងសម្តែងមួយ ដែលមានតួអង្គសម្តែង ១០នាក់ (យកល្អគួរមានស្រី ៥នាក់, ប្រុស ៥នាក់, ទោះជាយើងនៅតែអាចសម្តែងបាន ដោយមាន ស្រី៤, ប្រុស៦ ក្តី)។ តួអង្គ ៨នាក់ (គឺ ប្រុស៤ ស្រី៤) នឹងដើរតួជាអ្នកការពារសិទ្ធិមនុស្ស។ ពីរនាក់ផ្សេងទៀត (ប្រុសមួយ ស្រីមួយ ឬ ប្រុសទាំងពីរនាក់) តំណាងឲ្យ តួអង្គភាពអាក្រក់, ដែលមានភាពម៉ត់ចត់ក្នុងការបង្ហាញ ពីគំនិតអាក្រក់ ការចង់បង្កការឈឺចាប់ដល់អ្នកដទៃ, លក្ខណៈចំអកឡកឡាយ ទាក់ទងនឹងការធ្វើឲ្យភ័យខ្លាច និង ការគាបសង្កត់។ នេះជាភាពចម្បង, ហើយ បន្ទាប់មកពេលសម្តែងបន្តទៅមុខ តួអង្គតំណាងភាពអាក្រក់នេះ ត្រូវបង្ហាញពីភាពព្រងើយកន្តើយសោះអង្គើយ ដែលផ្ទុយស្រឡះពីការស្រលាញ់។ តួអង្គជិះជាន់គេ ត្រូវស្លៀកពាក់ឲ្យខុសពីគេ, ប្រើភ្លើងចាំងខុសពីគេ, ធ្វើសកម្មភាពខុសពីគេ និង និយាយខុសពីអ្នកការពារសិទ្ធិមនុស្ស។ តួអង្គនេះ ត្រូវមានការបម្លាស់ទីច្រើនជាងគេ, ត្រូវអនុញ្ញាតិឲ្យដើរក្រវែលលើឆាកស្រេចចិត្ត, ត្រូវខ្សឹបខ្សៀវ, ត្រូវឆែកនេះ ឆែកនោះ, ត្រូវគម្រាមកំហែង, ត្រូវតាំងចិត្តថា ត្រូវបន្ទាបបន្ថោកគ្រប់សារទាំងអស់ ដែលចេញមកពីវីរជន និងវីរនារីទាំងអស់។ ការធ្វើឲ្យមានភាពខុសប្លែកពីគ្នានេះ មានសារៈសំខាន់ណាស់ ដើម្បីសាច់រឿងសម្តែងនេះមានវិនាដកម្ម។

*បញ្ចាំងភ្លើងខ្លាំងលើតួសម្ដែង៨នាក់, ប្រុស៤នាក់ ស្រី៤នាក់, ឲ្យតួអង្គឈរទន្ទឹមគ្នាជាជួរ។*

សម្លេងទីមួយ (ប្រុស)

ភាពក្លាហានផ្ដើមចេញពីសម្លេងមួយ។
វាជារឿងងាយអញ្ចឹងឯង។
ខ្ញុំបានធ្វើអ្វីដែលខ្ញុំត្រូវតែធ្វើ។
នោះជាអ្វី ដែលយើងដឹង។
អ្នកដើរចូលច្រកមរណៈហើយ, ហើយអ្នកក៏ដឹងដែរ។

*បញ្ចាំងភ្លើងលើបុរស និងស្ត្រី នៅជ្រុងម្ខាង ដាច់ចេញពីអ្នកការពារសិទ្ធិ។*

បុរស (MAN)

ពួកគេដឹង។ ពួកគេមិនអាចនិយាយថា ពួកគេមិនដឹងនោះទេ។

ស្ត្រី (WOMAN)

ពួកគេមិនអាចនិយាយថា ពួកគេមិនបានដើរចូលក្នុងទីនេះ ដោយបើកភ្នែកនោះទេ។

សម្លេងទីមួយ (ប្រុស)

*អ្នកដើរចូលច្រកមរណៈហើយ, ហើយអ្នកក៏ដឹងដែរ ។ អ្នកដឹងថា គ្រានេះអាចជាគ្រាចុងក្រោយនៃជីវិតរបស់អ្នក។*

សម្លេងទី២ (ស្រី)

អ្នកដើរចូលច្រកមរណៈហើយ...

សម្លេងទីមួយ (ប្រុស)

... ហើយអ្នកក៏ដឹងដែរ, អ្នកដឹងថា គ្រានេះអាចជាគ្រាចុងក្រោយនៃជីវិតរបស់អ្នក។

សម្លេងទី២ (ស្រី)

នោះ គឺអ្វីដែលអ្នកដឹង។

សម្លេងទី៤ (ស្រី)

ខ្ញុំស្គាល់ហើយថា ការរងចាំទារុណកម្ម ក្នុងទីងងឹត មានសភាពយ៉ាងម៉េចនោះ, ហើយថា ការរងចាំការពិតក្នុងទីងងឹត មានសភាពយ៉ាងម៉េចនោះ។ ខ្ញុំបានធ្វើនូវអ្វីដែលខ្ញុំត្រូវតែធ្វើ។ រឿងផ្សេងក្រៅពីនេះនឹងមានរសជាតិដូចផេះអញ្ចឹង។

ស្ត្រី (WOMAN)

ពួកគេមិនអាចនិយាយថា ពួកគេមិនដឹងនោះទេ។

សម្លេងទីបី (ប្រុស)

មានគេប្រាប់ខ្ញុំថា កាលនៅក្មេង ខ្ញុំបានទៅលេងជាមួយអ្នកដទៃ។ ខ្ញុំបានចងមិត្តជាមួយមនុស្សក្រិនស្បែកខ្មៅ [pigmies] ទោះបីជាក្នុងសហគមន៍ខ្ញុំ ក្នុងប្រទេសកុងហ្គោ [Congo] គេចាត់ទុកអ្នកទាំងនោះជាសត្វក៏ដោយ។ ខ្ញុំកាត់នំប៉័ងញ៉ាំជាមួយពួកគេ, ខ្ញុំបាននាំគេមកលេងផ្ទះ, ខ្ញុំឲ្យសំលៀកបំពាក់ទៅពួកគេ។ សង្គមមានការខ្ពើមរអើមខ្លាំងណាស់ នៅពេលដែលខ្ញុំរាប់អានជាមួយមនុស្សក្រិនស្បែកខ្មៅទាំងនោះ ប៉ុន្តែខ្ញុំគិតថាពួកគេជាមិត្តភក្តិខ្ញុំ ដូចអ្នកដទៃឯទៀតៗ ដែរ។

បុរស (MAN)

ហ្គីលឡូមី ងេហ្វា អាតុនដុកូ [Guillaume Ngefa Atondoko]។

*ស្ត្រីម្នាក់ធ្វើកាយវិការ និង ឈ្មោះ (ឬ រូបភាពរបស់) ហ្គីលឡូមី ងេហ្វា អាតុនដុកូ លេចចេញមុខនៅលើអេក្រង់ ។ ត្រូវហើយ។ គាត់បានចងមិត្តជាមួយមនុស្សក្រិនស្បែកខ្មៅ កាលគាត់នៅក្មេង។ ត្រូវហើយ។ មិនខុសទេ។*

សម្លេងទី៥ (ប្រុស)

អស់រយៈពេលមួយខែ ដែលគេបានកាត់ទោសប្រហារជីវិតខ្ញុំ, ខ្ញុំខ្លាចសម្បើមណាស់។

*បុរសម្នាក់ធ្វើកាយវិការ និង ឈ្មោះ (ឬ រូបភាពរបស់) វ៉ៃ ជីងសេង លេចចេញរូបលើអេក្រង់ ។*

ពេលនោះ ខ្ញុំគិតក្នុងចិត្តថា "វ៉ៃ ជីងសេង ទោះយ៉ាងណាក៏ដោយក៏ឯងត្រូវតែស្លាប់ដែរ។ ហេតុអ្វីក៏ត្រូវស្លាប់ ឲ្យសត្រូវ សើចចំអកឲ្យទៅវិញ?" គិតដូច្នោះហើយ ខ្ញុំបានគ្រប់គ្រងភាពភ័យខ្លាចរបស់ខ្ញុំ នៅក្នុងពេលកំពុងមានវិបត្តិនោះ, ហើយពេលនោះ ភាពភ័យខ្លាចក៏បានកន្លងផុតទៅ។ ប្រសិនបើអ្នក មិនអាចត្រៀមខ្លួនដើម្បីស្លាប់ទេនោះ អ្នកមិនគួរសម្រេចចិត្តប្រឆាំងនឹងរបបដឹកនាំនោះទេ។

សម្លេងទី៣ (ប្រុស)

អ្នកដើរចូលច្រកមរណៈហើយ...

សម្លេងទី១ (ប្រុស)

ខ្ញុំឈ្មោះ ហាហ្វិច អាប៊ូ ស៊ីដា [Hafez Abu Seada]។ ស្លាកស្នាមនៅលើមុខរបស់ខ្ញុំ កើតចេញមក នៅពេលគេរុញខ្ញុំចូលបង្គួច។ ពួកគេបានសួរខ្ញុំថា អ្នកណាទទួលខុសត្រូវចាត់ចែងការងារសព្វមុខនៅអង្គការ

សិទ្ធិមនុស្សអេហ្ស៊ីបនេះ [Egyptian Human Rights Organization]។ ខ្ញុំប្រាប់ពួកគេវិញថា គឺខ្ញុំ។ ខ្ញុំជាអ្នកសរសេរបាយការណ៍, ខ្ញុំអានរបាយការណ៍,ខ្ញុំពិនិត្យរបាយការណ៍ឡើងវិញ,ហើយខ្ញុំជាអ្នកសម្រេចចិត្តចុះផ្សាយរបាយការណ៍នោះ ក្នុងសារព័ត៌មាន។ នេះជាការងាររបស់យើង ក្នុងការចង្អុលបង្ហាញពីកំហុសឆ្គង របស់រដ្ឋាភិបាល។ បើពួកយើងមិនធ្វើទេ តើមានអ្នកណានឹងធ្វើ?

### បុរស (MAN)

ហាហ្វេ អាប៊ូ ស៊ីដា, ត្រូវហើយ។ នោះជាកិច្ចការរបស់គាត់។

### ស្ត្រី (WOMAN)

ហើយ គេច្រានគាត់ចេញតាមបង្អួច។ ត្រូវហើយ។

### សម្លេងទី២ (ស្រី)

បើយើងមិនធ្វើកិច្ចការនេះទេ, តើអ្នកណា នឹងធ្វើ? ខ្ញុំឈ្មោះ ឌីកណា អូចាវ [Digna Ochoa]។ ខ្ញុំជាដូនជី និង ជាមេធាវី។ ឪពុកខ្ញុំធ្លាប់ធ្វើជាមេដឹកនាំសហជីព នៅ វេរ៉ាគ្រូស ប្រទេសម៉ិចស៊ិក [Veracruz, Mexico]។ នៅក្នុងរោងចក្រស្ករ ដែលគាត់ធ្វើការ, គាត់បានចូលរួមតស៊ូដើម្បីទាមទារ ទឹកម៉ាស៊ីន, ផ្លូវថ្នល់, សំបុត្របញ្ជាក់ដីធ្លី។ ក្រោយមកគាត់ "បាត់ខ្លួន" និងទទួលរងទារុណកម្ម។ បទចោទប្រកាន់លើរូបគាត់ ត្រូវបានគេប្រឌិតឡើង។ បន្ទាប់មក ខ្ញុំក៏ "បាត់ខ្លួន" ដែរ ហើយត្រូវបានប៉ូលីសឃុំខ្លួនមិនឲ្យជួបអ្នកណាសោះ ចំនួន៨ថ្ងៃ។ ឥឡូវនេះ ខ្ញុំដឹងពីអារម្មណ៍ ដែលឪពុកធ្លាប់បានទទួល និង អារម្មណ៍របស់មនុស្ស ដែលបានទទួលរងការឈឺចាប់។ ខ្ញុំតែងតែកើតមានអារម្មណ៍ខឹងសម្បារ នៅពេលអ្នកដទៃទទួលរងការឈឺចាប់ខ្លោចផ្សា។ ប្រសិនបើ អំពើអយុត្តិធម៌ណាមួយ មិនធ្វើឲ្យខ្ញុំខឹងទេនោះ គេអាចយល់ថា ខ្ញុំជា មនុស្សព្រងើយកន្តើយ គ្មានបានការ។...មានពេលមួយ យើងបានប្តឹងសុំឲ្យមានដីការនាំខ្លួនមកតុលាការ លើបុរសម្នាក់ដែលបាន "បាត់ខ្លួន" ២០ថ្ងៃ។ អាជ្ញាធរបានបដិសេធថា មិនបានឃុំខ្លួនគាត់ទេ ហើយឃាត់យើងមិនឲ្យចូលទៅមន្ទីរពេទ្យរដ្ឋ ដែលយើងដឹងថា គាត់កំពុងត្រូវឃុំខ្លួននៅទីនោះ។ នៅពេលផ្លាស់វេនអ្នកយាម, ខ្ញុំបានលបចូល។ ខ្ញុំបានទៅដល់មាត់ទ្វារបន្ទប់គាត់, ខ្ញុំដកដង្ហើមមួយយ៉ាងវែង, រួចបើកទ្វារទាំងកំរោល និង ស្រែកសន្ធប់ដាក់មន្ត្រីនគរបាល យុត្តិធម៌សហព័ន្ធ ដែលនៅខាងក្នុង។ ខ្ញុំប្រាប់ពួកគេថា ត្រូវចេញជាបន្ទាន់ ពីព្រោះខ្ញុំជាមេធាវីរបស់គាត់ និងត្រូវការនិយាយជាមួយគាត់។ ពួកគេមិនដឹងធ្វើយ៉ាងម៉េច ក៏ចេញទៅ។ ខ្ញុំមានពេលតែ២នាទីប៉ុណ្ណោះ ប៉ុន្តែ វាល្មមគ្រប់គ្រាន់ ដើម្បីឲ្យគាត់ចុះហត្ថលេខាបញ្ជាក់ថា គាត់នៅក្នុងមន្ទីរពេទ្យ។ បន្ទាប់មក ប៉ូលីសបានត្រលប់មកវិញ។ ដោយសាហាវ។ ពួកគេមិនស្មានថា ខ្ញុំត្រៀមជំហរដើម្បីវាយប្រហារនោះទេ គឺខ្ញុំឈរក្នុងជំហរក្បាច់ការ៉ាតេ ដែលខ្ញុំបានចេះតាមការមើលភាពយន្ត។ ពិតណាស់ ខ្ញុំមិនចេះការ៉ាតេអីទេ តែពួកគេគិតថា ខ្ញុំនឹងវាយប្រហារ។ ទាំងញ័រក្នុងខ្លួន ខ្ញុំនិយាយថា បើពួកគេហ៊ានប៉ះខ្ញុំ ពួកគេនឹងដឹងថា មានរឿងអ្វីកើតឡើងហើយ។ ពួកគេក៏ថយ ទាំងនិយាយថា "អ្នកឯងគម្រាមយើង ឬ...។" ហើយខ្ញុំនិយាយថា "ចង់យល់ថាម៉េច យល់ទៅ!"

### សម្លេងទី៧ (ប្រុស)

ខ្ញុំឈ្មោះ ឌ័ន វៀត ហ៊ត [Doan Viet Hoat]។

*ស្រីធ្វើកាយវិការនិងឈ្មោះ (ឬរូបភាព) ឌ័ន វៀតហ៊ត លេចចេញលើអេក្រង់ ។*

### សម្លេងទី៧ (ប្រុស)

ខ្ញុំរស់នៅក្នុងពន្ធនាគារប្រទេសវៀតណាម ២០ឆ្នាំ។ កាលនោះ ខ្ញុំនៅដាច់ដោយឡែកតែឯងចំនួន ៤ឆ្នាំ។ គេហាមឃាត់មិនឲ្យខ្ញុំមានប៊ិច, ក្រដាស, សៀវភៅ អ្វីទាំងអស់។ ដើម្បីពង្រឹងស្មារតីឆន្ទៈខ្ញុំឲ្យរឹងមាំ ខ្ញុំច្រៀង, ខ្ញុំនិយាយមកកាន់ខ្លួនឯង។ ឆ្មាំគុកគិតថា ខ្ញុំឆ្កួតហើយ, តែខ្ញុំប្រាប់ពួកគេវិញថា បើខ្ញុំមិននិយាយតែម្នាក់ឯងទេ ខ្ញុំនឹងឆ្កួតហើយ។ ខ្ញុំព្យាយាមគិតថា បន្ទប់ឃុំឃាំងនោះ ជាផ្ទះរបស់ខ្ញុំ ប្រៀបបីដូចជា ខ្ញុំចូលមកសំណាក់ធម៌ ដូចព្រះសង្ឃអញ្ជឹងដែរ ។ ការសូត្រធម៌អធិដ្ឋានបែបពុទ្ធសាសនា, បានទាញអារម្មណ៍ឲ្យមើលលើផ្លូវចិត្ត។ ហើយខ្ញុំខិតខំបានសម្រេចក្នុងការសរសេររបាយការណ៍ជាសំងាត់ អំពីស្ថានភាពនៅក្នុងមន្ទីរឃុំឃាំង។ ខ្ញុំមានអារម្មណ៍ថា បើខ្ញុំនៅស្ងៀមក្នុងគុក នោះពួកផ្តាច់ការបានឈ្នះហើយ។ ខ្ញុំចង់បង្ហាញដល់ពួកគេថា ពួកគេមិនអាច, ដោយប្រើកម្លាំង, បំបិទមាត់ អ្នកដែលមិនស្របមតិជាមួយពួកគេបានទេ។ ខ្ញុំបន្តតស៊ូទៀត ទោះបីជាត្រូវធ្វើតាមជញ្ជាំងគុកក៏ដោយ។ បើយើងមិនធ្វើទេ តើអ្នកណាគេនឹងធ្វើ?

### សម្លេងទី៣ (ប្រុស)

ខ្ញុំឈ្មោះ អាប៊ូបាចា ស៊ុលតាន់ [Abubacar Sultan]។

*បុរសម្នាក់ធ្វើកាយវិការ និង ឈ្មោះ (ឬ រូបភាពរបស់) អាប៊ូបាចា ស៊ុលតាន់ លេចចេញនៅលើអេក្រង់ ។*

នៅពេលសង្គ្រាមផ្ទុះឡើង នៅប្រទេសម៉ូហ្សំប៊ិច [Mozambique], ខ្ញុំបានសម្រេចចិត្តថា ត្រូវធ្វើអ្វីមួយ អំពីបញ្ហាទាហានកុមារ។ ក្មេងប្រុសអាយុ ៧ឆ្នាំ ម្នាក់បានផ្លាស់ប្តូរជីវិតខ្ញុំ។ គាត់បានដកខ្លួនចេញពីពិភពលោកទាំងស្រុង។ គាត់អាចនឹងមានសភាពស្ងាត់ស្ងៀមមួយថ្ងៃ, ហើយគាត់អាចនឹងស្រែកយំមិនឈប់នៅថ្ងៃបន្ទាប់។ ទីបំផុត គាត់ក៏ចាប់ផ្តើមនិយាយចេញមក។ គាត់ថា យប់មួយនោះ នៅពេលដែលគាត់កំពុងរស់នៅជាមួយក្រុមគ្រួសារ មានទាហានឧទ្ទាមមួយក្រុមដាស់គាត់ឲ្យភ្ញាក់, ហើយពួកគេវាយដំគាត់, និងបានបង្ខំឲ្យគាត់ដុតផ្ទះខ្ទម ដែលឪពុកម្តាយរបស់គាត់កំពុងនៅខាងក្នុង។ ហើយនៅពេល គ្រួសាររបស់គាត់ព្យាយាម

គេចចេញពីក្នុងខ្ទមនោះ ពួកគេបានបាញ់គ្រួសាររបស់គាត់នៅចំពោះមុខគាត់ ហើយកាត់ជាកង់ៗ។ ខ្ញុំនឹងមិនបំភ្លេចអារម្មណ៍របស់ក្មេងនោះទេ, ពីព្រោះ គាត់បានអនុញ្ញាតឲ្យខ្ញុំបានដូចជា បានចូលទៅក្នុងខ្លួនរបស់គាត់។ ភាគច្រើននៃកុមារទាំងនេះ កំពុងនៅសមរភូមិមុខ, ដូច្នេះហើយ វាក៏ជាកន្លែងដែលយើងត្រូវទៅដែរ គឺទៅកន្លែងដែលសង្គ្រាមកើតមានជារៀងរាល់ថ្ងៃ។ មានពេលច្រើនដងណាស់ ដែលយើងស្ទើរតែត្រូវគេបាញ់ស្លាប់បាត់ទៅហើយ។ ប៉ុន្តែ ខ្ញុំមិនបញ្ឈប់ទេ។ ការពន្យល់មួយផ្នែក គឺអាស្រ័យលើសាសនា (ខ្ញុំគោរពបូជាសាសនាមូស្លីម)។ យ៉ាងណាមិញ នៅមានមនុស្សដូចខ្ញុំជាច្រើន ដែលមិនដែលបានគិតធ្វើអ្វីដែលខ្ញុំបានធ្វើនោះទេ។ វាត្រូវតែមានអ្វីមួយស៊ីជម្រៅ, អ្វីមួយចេញពីខាងក្នុងដួងចិត្តមក, ហើយប្រហែលជា អំណាចអ្វីម្យ៉ាង។

## សម្លេងទី១ (ប្រុស)

អ្នកដើរចូលច្រកមរណៈហើយ...

## សម្លេងទី៤ (ស្រី)

ខ្ញុំចង់បំភ្លេចរឿងចាស់ចោលឲ្យអស់។ នាងខ្ញុំមានឈ្មោះ ដាយអាណា អ័រទីស [Dianna Ortiz]។ ខ្ញុំចង់ឲ្យមានការជឿជាក់, ការទុកចិត្ត, ការផ្សងព្រេង និង មិនខ្វល់ពីអ្វីទាំងអស់ ដូចនៅឆ្នាំ១៩៨៧ ពេលខ្ញុំមកពី សហរដ្ឋអាមេរិក ទៅនៅខ្ពង់រាបខាងលិចប្រទេស ហ្គាតេម៉ាឡា [Guatemala], ជាពលរដ្ឋអាមេរិកម្នាក់ ដែលមានចំណង់ចំណូលចិត្តខ្លាំង ក្នុងការបង្រៀនដល់កូនក្មេងជនជាតិដើម ឲ្យចេះអាន និង ចេះសរសេរភាសាអេស្ប៉ាញ និង ភាសាដើមកំណើតរបស់ពួកគេ ហើយចង់ឲ្យពួកគេយល់ច្បាស់អំពីព្រះគម្ពីរនៅក្នុងវប្បធម៌របស់ពួកគេ។ ប៉ុន្តែ នៅថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ១៩៨៩, មនុស្ស ឈ្មោះ ដាយអាណា អរទីស ដែលខ្ញុំបានរៀបរាប់អម្បាញ់មិញនេះ លែងមានតទៅទៀតហើយ។ ឥឡូវនេះ នៅពេលនេះ ខ្ញុំស្ទើរតែមិនអាចចងចាំបានពីជីវិតខ្ញុំមុន ពេលដែលត្រូវចាប់ជំរិត នៅពេលមានអាយុ ៣១ឆ្នាំ។ អ្នកទាំងអស់គ្នាប្រហែលជាគិតថា វាហាក់បីដូចជាចម្លែកណាស់, ប៉ុន្តែ សូម្បីតែនៅពេលឥឡូវនេះក្តី ក៏ខ្ញុំនៅនឹកឃើញវត្តមានអ្នកធ្វើទារុណកម្ម ខ្ញុំនៅឡើយ, ខ្ញុំនៅធំក្លិនពួកគេ, នៅឮសម្រែក ស្រែកដាក់ត្រចៀកខ្ញុំ។ ខ្ញុំនៅចងចាំ។ ប៉ូលីសម្នាក់នោះ បានរំលោភខ្ញុំ ម្តងទៀត។ ក្រោយមកខ្ញុំត្រូវគេអូសទម្លាក់ទៅក្នុងរណ្តៅមួយពោរពេញទៅដោយសាកសព មាន កុមារ, បុរស, ស្ត្រី, អ្នកខ្លះត្រូវគេកាត់ក្បាលបាត់ ទាំងអស់, ប្រឡាក់ប្រឡូសដោយឈាម។ មានតិចគ្នាណាស់ដែលនៅរស់។ ខ្ញុំនៅឮសម្លេងពួកគេស្រែកថ្ងូរ។ មានម្នាក់ កំពុងយំខ្សឹកខ្សួល។ ខ្ញុំមិនដឹងថា ជាខ្ញុំ ឬ ជាអ្នកណាផ្សេងនោះទេ។

*ផ្អាក*

មនុស្សប្រុស ដែលធ្វើទារុណកម្មខ្ញុំ មិនដែលត្រូវបានគេយកទៅកាត់ទោសទេ។ ជនជាតិអាមេរិកម្នាក់ ដែលទទួលខុសត្រូវក្នុងការធ្វើទារុណកម្មលើរូបខ្ញុំ ក៏មិនដែលត្រូវបានគេនាំខ្លួនមករកយុត្តិធម៌ដែរ។ ឥឡូវនេះ ខ្ញុំបានដឹងពីអ្វីដែល ជនជាតិអាមេរិកតិចគ្នាណាស់ បានដឹង។ ខ្ញុំដឹងថា តើជនស៊ីវិលស្លូតត្រង់មួយរូប, ដែលត្រូវបានចោទប្រកាន់, សួរចម្លើយ និង ត្រូវគេធ្វើទារុណកម្មមកលើនោះ, មានរសជាតិដូចម្តេច។ ខ្ញុំបានដឹងថា តើវាមានរសជាតិយ៉ាងម៉េច នៅពេលដែលរដ្ឋាភិបាលរបស់ខ្ញុំបដិសេធ ការទាមទាររកយុត្តិធម៌របស់ខ្ញុំ និង ខំបំផ្លាញចារិក និង កេរ្តិ៍ឈ្មោះខ្ញុំ ព្រោះករណីរបស់ខ្ញុំ បង្កឲ្យមានបញ្ហានយោបាយរបស់ពួកគេ។ ខ្ញុំបានស្គាល់ថា តើការរង់ចាំក្នុងទីងងឹតឲ្យគេធ្វើទារុណកម្ម មានរសជាតិដូចម្តេច និង ខ្ញុំបានស្គាល់ថា តើការរង់ចាំការពិតក្នុងទីងងឹតមានរសជាតិយ៉ាងណា។ ខ្ញុំនៅតែរង់ចាំ។

## បុរស (MAN)

អញ្ចឹង នាងមិនអាចនិយាយថា នាងមិនមែនកំពុងដើរចូលច្រកនេះទាំងភ្នែកបើកនោះទេ, ហើយថា យើងមិនបានព្រមាននាងនោះទេ។ នាងមិនអាចនិយាយថា នាងមិនដឹងនោះទេ។

## សម្លេងទី៣ (ប្រុស)

នៅយប់មួយ ពេលដែលខ្ញុំរត់គេចទៅប្រទេស យូហ្គានដា [Uganda], មានមនុស្ស៥នាក់ សុទ្ធតែបិទមុខទាំងអស់ បានចាប់ខ្ញុំ, ហើយ នាំខ្លួនខ្ញុំទៅប្រទេសកេនយ៉ា [Kenya]។ ខ្ញុំភ្ញាក់ឡើងនៅក្នុងទឹកល្ហល្ហាច។ ខ្លួនខ្ញុំស្រាតនននលគក, ហើយ កំពុងអង្គុយនៅក្នុងបន្ទប់ក្រោមដីនោះពេញមួយយប់។ ខ្ញុំនៅក្នុងទឹកនោះ អស់រយៈពេលប្រហែលមួយខែ។ ពួកគេអាចធ្វើទឹកនោះឲ្យកក, ហើយទុកឲ្យត្រជាក់ញ័រខ្លួនចំប្រប់, រួចគេធ្វើទឹកនោះឲ្យក្តៅខ្លាំងវិញ រហូតធ្វើឲ្យយើងថប់ដង្ហើមវិញម្តង។ គេសួរចម្លើយខ្ញុំនៅពេលថ្ងៃ។ ពួកគេក៏បានគម្រាមបោះខ្ញុំចេញពីដំបូលទៀតផង។

## ស្ត្រី (WOMAN)

កុហក។ យើងមិនមែនគម្រាមបោះវាពីដំបូលទេ។ គ័យជី វ៉ាវ៉ាមវើ [Koigi wa Wamwere] កំពុងនិយាយកុហក។ ត្រូវហើយ កុហក!

## ប្រុស (MAN)

ត្រូវហើយ វានិយាយកុហក អំពីទង្វើរបស់កម្មករព្រៃឈើនៅប្រទេសកេនយ៉ា [Kenya]។ ហើយវាកុហក ពេល ដែលវាសរសេរអំពី អំពើពុករលួយនៅក្នុងក្រុមហ៊ុនត្រួតត្រាដោយរដ្ឋាភិបាលនៅប្រទេសកេនយ៉ា។

## ស្ត្រី (WOMAN)

វាកុហករហូតហ្នឹង។ យើងគួរតែបានបោះគាត់ចេញពីដំបូលមែន ទើបសម។

### សម្លេងទី៣ (ប្រុស)

នៅក្នុងគុកយ៉ាប់យ៉ឺនណាស់, ប៉ុន្តែ វាត្រូវការភាពក្លាហានមិនច្រើនប៉ុន្មានទេដើម្បីបន្តរស់ ខុសពីការដែលវាត្រូវការភាពក្លាហានច្រើន សម្រាប់ការចេញមកពីគុកវិញ ហើយបន្តនៅកន្លែងដែលយើងបានឈប់, ហើយដឹងថា អ្នកអាចត្រលប់ទៅវិញ។ ហើយខ្ញុំបានបន្ត។ ខ្ញុំបានបន្តទៀត។

### សម្លេងទី៦(ស្រី)

យើងទាំងអស់គ្នាបានបន្ត។

*បុរសម្នាក់ធ្វើកាយវិការ និង ឈ្មោះ (ឬ រូបភាពរបស់)*
*ហ៊ីណា ជីឡានី ចេញមុខមក។*

ជោគជ័យតិចតួច តែមានន័យធំធេង។ វាតិចតួចហើយ ម្តងម្កាលមែនតែចំណុចសំខាន់នោះ គឺវាមានអត្ថន័យ។ យើងមានអារម្មណ៍ថា មានអ្វីម្យ៉ាងនៅទីនោះ, គឺមានពន្លឺនៅខាងមុខ។ ហើយយើងបានឃើញពន្លឺនោះ ច្រើនដងហើយ។

### បុរស

មេធាវីមកពីប្រទេស ប៉ាគីស្ថាន [Pakistan], នាង ហ៊ីណា ជីឡានី នេះ [Hina Jilani]។

### ស្ត្រី

មិនមានតែ ហ៊ីណា ជីឡានី នៅទីនេះ ដូចជាមិនទាន់គ្រប់គ្រាន់សោះ គឺមានបងប្អូនស្រីវាម្នាក់ទៀត ។ មកពី ប៉ាគីស្ថាន ជាមេធាវីដែរ, អាស្មា ចាហ៊ីងហ្គៀ [Asma Jahangir]។

### សម្លេងទី៨ (ស្រី)

កូនខ្ញុំ ពួកគេមានការបារម្ភ អំពីការគម្រាមសម្លាប់ ដែលកើតឡើងមកលើខ្ញុំណាស់។ ខ្ញុំត្រូវអង្គុយជាមួយពួកគេ ហើយពន្យល់ពួកគេ និងពេលខ្លះនិយាយកំប្លែងលេងផង។ "ល្អហើយអញ្ចឹង, អ្វីដែលម៉ែត្រូវធ្វើគឺត្រូវទិញការធានារ៉ាប់រងជីវិត, ហើយនៅពេលម៉ែស្លាប់ទៅ កូនឯងទាំងអស់គ្នានឹងក្លាយទៅជាក្មេងអ្នកមានហើយ។" ប៉ុន្តែ ខ្ញុំដឹងថា គ្រួសារពួកយើងត្រូវតែលះបង់ ដើម្បីការតាំងចិត្តរបស់យើង។ គឺធ្វើដូចយើងដែរ, ដូចពួកយើងដែរ។

### សម្លេងទី៤ (ស្រី)

សម្លេងទូរស័ព្ទរោទ៍ឡើង ហើយសម្លេងមួយនិយាយថា, បុរសមួយនិយាយថា "អញដឹងថា ឯងជានរណា។ អញស្គាល់ឈ្មោះឯង។ និងអញដឹងថា ឯងរស់នៅកន្លែងណា។ អញនឹងនាំគ្នាទៅសម្លាប់ឯង"។

### បុរស (MAN)

ខ្ញុំស្គាល់ ឈ្មោះអ្នកឯង, ម៉ារីណា ពីសក្លាកូវ៉ា [Marina Pisklakova]។ ខ្ញុំដឹងថា អ្នកឯងរស់នៅកន្លែងណា, ម៉ារីណា, ឱម៉ារីណាខ្ញុំអើយ។ ខ្ញុំនឹងសម្លាប់ឯងចោល, ម៉ារីណា ពីសក្លាកូវ៉ា។

### សម្លេងទី៤ (ស្រី)

ខ្ញុំចាប់ផ្តើមបង្កើត បណ្តាញទូរស័ព្ទពិសេសមួយ (Hotline) សម្រាប់ករណីអំពើហិង្សាក្នុងគ្រួសារ ស្ទើរតែដោយភាពចៃដន្យនៅប្រទេស រុស្ស៊ីក្នុងឆ្នាំ១៩៩៣។ កូនប្រុសខ្ញុំមានមិត្តរួមថ្នាក់ម្នាក់ ហើយម្តាយគេសួរយោបល់ខ្ញុំ។ នៅពេលទ្បេវអាវមួយដាច់ចេញពីអាវរបស់ប្តីគាត់ ហើយគាត់ដេរដាក់វិញមិនទាន់, ប្តីគាត់យកស្បែកជើងវាយលើមុខរបស់គាត់។ គាត់មិនអាចចេញពីផ្ទះអស់ពីរសប្តាហ៍។ គាត់បានទូរស័ព្ទមកខ្ញុំនៅល្ងាចមួយ ទាំងអារម្មណ៍តានតឹងខ្លាំងមែនទែន, មុខរបស់គាត់មួយចំហៀងឡើងជាំខ្មៅ។ ខ្ញុំសួរទៅគាត់ថា "ហេតុអ្វីបងឯងមិនចាកចេញពីគាត់ទៅ?" គាត់តបវិញ ថា "ឲ្យខ្ញុំទៅនៅឯណា, ម៉ារីណា? ខ្ញុំពឹងលើគាត់ទាំងស្រុង។" ខ្ញុំផ្តើមគិតថា ខ្ញុំគួរឲ្យគាត់ទៅរកអ្នកផ្តល់ជំនួយណាម្នាក់។ ប៉ុន្តែ មិនមានទីកន្លែងដែលអាចផ្តល់ជំនួយ ឬ គ្មាននរណាដែលអាចជួយគាត់បានទេ។ ដូច្នេះ ខ្ញុំក៏ចាប់ផ្តើមបង្កើតបណ្តាញទូរស័ព្ទពិសេសមួយ, ហើយយើងក៏ចាប់ផ្តើម កម្មវិធីថ្មីបណ្តុះបណ្តាលមេធាវីធ្វើការករណីអំពើហិង្សាក្នុងគ្រួសារ។

### សម្លេងទី២ (ស្រី)

នាងខ្ញុំឈ្មោះ រ៉ាណា ហ៊ូសេនី [Rana Husseini]។ ដើម្បីកិត្តិយស, កុមារីជំទង់ អាយុ១៦ឆ្នាំ ម្នាក់ នៅប្រទេស ហ្សកដង់ [Jordan] ត្រូវគ្រួសារនាងសម្លាប់ចោល, ដោយហេតុថា នាងត្រូវបងប្រុសនាងរំលោភ។ នៅពេលខ្ញុំទៅស៊ើបអង្កេតឧក្រិដ្ឋកម្មនោះ, ខ្ញុំបានជួបពូរបស់នាងពីរនាក់។ ហេតុដូចម្តេច បានជានាងជាអ្នកមានកំហុសទៅវិញ នៅពេលដែលនាងត្រូវគេរំលោភនោះ? ហេតុអ្វី បានជាគ្រួសារនេះ មិនព្រមដាក់ទោសបងប្រុសរបស់នាង? ពួកគេឆ្លើយថា មកពីនាងបានលួងលោមទាក់ទាញបងប្រុសខ្លួនឯង។

### បុរស (MAN)

គឺវាបានលួងលោមទាក់ទាញបងប្រុសខ្លួនវា, យើងបានប្រាប់ទៅអ្នកកាសែតនោះ, មី រ៉ាណា ហ៊ូសេនី។

### សម្លេងទី២ (ស្រី)

ខ្ញុំសួរពួកគេទៀតថា, មានប្រុសនៅតាមផ្លូវរាប់លាននាក់ ហេតុអ្វីនាងមិនលួងលោមបែរជាទៅលួងលោមបងប្រុសខ្លួនទៅវិញ? ពួកគេ នៅតែនិយាយច្រំដែលថា នាងបានធ្វើឲ្យអាប់ឱនកិត្តិយសគ្រួសារ ដោយសារតែប្រព្រឹត្តអំពើអសីលធម៌។ ផ្លូវតែមួយគត់ ដើម្បីស្តារកិត្តិយសគ្រួសារបាន គឺត្រូវតែសម្លាប់នាងចោល។

## ស្ត្រី (WOMAN)

យកឈាមលាងកិត្តិយស។ សម្លាប់កុមារីចោល។ មានផ្លូវតែមួយគត់។

## សម្លេងទី៨ (ស្ត្រី)

ទោសដែលត្រូវទទួលពីបទសម្លាប់ដើម្បីរក្សាកិត្តិយស គឺត្រូវជាប់ពន្ធនាគារជាមធ្យមតែ ៧ខែកន្លះទេ។ តែអ្នកចាំចាប់ក៏ត្រូវដឹងដែរថា អ្នកសម្លាប់មនុស្សនោះ ក៏ជាជនរងគ្រោះដែរ។ បើគេមិនសម្លាប់ទេ, គេត្រូវទទួលខុសត្រូវ ចំពោះការបាត់បង់កិត្តិយសគ្រួសារ។ បើគេបានសម្លាប់, គេនឹងក្លាយជាវីរជន។

## សម្លេងទី៥ (ប្រុស)

មនុស្ស ជាច្រើន ដែលទទួលរងការឈឺផ្សាបំផុតនៅប្រទេសអាហ្វ្រិកខាងត្បូង បានត្រៀមខ្លួនរួចហើយ ក្នុងការអត់ឱនទោសដល់អ្នកដទៃ, គឺជា អ្នកដែលអស់លោកគិតថាមានភាពជូរចត់ក្នុងខ្លួន, ហើយប្រាថ្នាចង់សងសឹកមិនចេះឈប់ឈរនោះ។ យើងបានបើកសវនាការនៅគណៈកម្មការស្វែងរកការពិត ដែលមានមនុស្សណែនណាន់តាន់តាប់ ពួកគេជាអ្នកដែលមានមនុស្សជាទីស្រលាញ់បានបាត់បង់ជីវិត ដោយសារការសម្លាប់រង្គាល។ មន្ត្រី ៤នាក់ បានមកដល់, ស្បែកសម្នាក់ និងស្បែកខ្មៅបីនាក់។ ម្នាក់ស្បែកស និយាយថា៖ “យើងបានបញ្ជារឲ្យទាហានបាញ់”។ នៅក្នុងបន្ទប់នោះ ភាពតានតឹងកាន់តែមានភាពតឹងតែងឡើង។ ហើយគាត់បានបែរទៅកាន់អ្នកចូលរួម រួចនិយាយថា សូម"អភ័យទោសឲ្យខ្ញុំផង។ ហើយសូមមេត្តាទទួលសហការីរបស់ខ្ញុំត្រឡប់ទៅក្នុងសហគមន៍វិញផង”។ ហើយអ្នកស្តាប់ដែលកំពុងក្តៅក្រហាយ មានការផ្លាស់ប្តូរភ្លាម ក្នុងការទះដៃអបអរសាទរ យ៉ាងអធិកអធម។ ខ្ញុំបាននិយាយថា “សូមយើងស្ងាត់ស្ងៀម ពីព្រោះយើងកំពុងស្ថិតក្នុងវត្តមាននៃភាពបរិសុទ្ធ”។

*ផ្អាក*

ខ្ញុំឈ្មោះ ដេសមិន ធូធូ [Desmond Tutu]។
ខ្ញុំបានធ្វើអ្វី ដែលខ្ញុំត្រូវតែធ្វើ។ អ្វីផ្សេងក្រៅពីនេះ ហាក់មានរសជាតិដូចផេះផង់អញ្ចឹង។ វានឹងជាការរស់នៅក្នុងជីវិតភូតកុហក។ ខ្ញុំគួរតែបានចូលក្នុងការតស៊ូ ក្នុងតំណែងមួយ ដែលមិនសូវមានការចាប់អារម្មណ៍។ ប៉ុន្តែ ព្រះជាម្ចាស់បាន, ដូចភាសាគេច្រើនតែប្រើថា, “ទាញកអាវខ្ញុំពីខាងក្រោយ” ដូចព្យាការីយេរេមា [Jeremiah]។ យើងមានព្រះជាម្ចាស់ដែលមិនមានបន្ទូលថា “អុះ!... ចាប់ឯងបានហើយ!” មិនមែនទេ។ ព្រះជាម្ចាស់និយាយថា “ចូរក្រោកឡើង”។ ហើយព្រះជាម្ចាស់បបោសយើងឲ្យស្អាត ហើយមានបន្ទូលថា “ចូរព្យាយាមម្តងទៀត”។ ព្រះជាម្ចាស់ មានបន្ទូលថា “ចូរព្យាយាមម្តងទៀត”។

## សម្លេងទី៦ (ស្រី)

ពីព្រោះមានអ្វីមួយ នៅទីនោះហើយ [Because something is there]
ពន្លឺ នៅទីនោះ [A light is there]
ពន្លឺ នៅចុងមាត់រូងខាងណោះ។ [A light at the end of the tunnel.]

## សម្លេងទី១ (ប្រុស)

ខ្ញុំឈ្មោះ ម៉ូហាម៉ាដ យូនុស [Muhammad Yunus]។ ខ្ញុំចាប់ផ្តើមកម្មវិធីធនាគារហ្គ្រាមីន ដើម្បីផ្តល់លទ្ធភាព ដល់អ្នកក្រទទួលបានប្រាក់កម្ចី។ អ្នកមានឯកទេសវិជ្ជាជីវៈ និយាយថា ការអភិវឌ្ឍន៍ត្រូវមានការប្រាក់កម្ចីរាប់សិបលានដុល្លារ សម្រាប់គម្រោង ហេដ្ឋារចនាសម្ព័ន្ធធំៗ។ ប៉ុន្តែខ្ញុំធ្វើការជាមួយមនុស្សជាក់ស្តែង នៅក្នុងពិភពជាក់ស្តែង។ យប់មុន ពេលស្ត្រីម្នាក់ត្រូវទៅយកប្រាក់កម្ចី ៣៥ដុល្លារ ពីធនាគារនោះ, គាត់នៅវិលវល់ក្នុងការសម្រេចថា តើខ្លួនអាចមានលទ្ធភាពសងបំណុលវិញបានដែរឬទេ។ បន្ទាប់មក គាត់កាន់លុយ, ហើយ គាត់ចាប់ផ្តើមញាប់ញ័រ, ហើយដំណក់ទឹកភ្នែក រមៀលធ្លាក់លើផែនថ្ពាល់របស់គាត់។ ហើយនាងមិនជឿថា ពួកយើងទុកចិត្តឲ្យគាត់ខ្ចីលុយច្រើនអញ្ចឹងទេ។ សាមសិបប្រាំដុល្លារ! ហើយគាត់មានការលំបាក ក្នុងការបង់រំលោះដំណាក់កាលទីមួយ និង ដំណាក់កាលទីពីរ, គាត់បន្តសង៥០សប្តាហ៍ជាប់ៗគ្នា ហើយរាល់លើកដែលគាត់មកសងលុយ គាត់តែងមានភាពក្លាហានជាងមុន។ នៅពេលគាត់បញ្ចប់ការសងរំលោះជាលើកចុងក្រោយ គាត់ចង់អបអរសាទរ។ វាមិនគ្រាន់តែជាការដោះដូរជាប្រាក់កាសទេ ដែលត្រូវបានបញ្ចប់នោះ។ គាត់ធ្លាប់តែគិតខ្លួនឯងថា ខ្លួនគាត់ជាមនុស្សគ្មានមុខមាត់អ្វីនឹងគេទេ ហើយមិនមានរូបលើលោកនេះទៀតផង។ ឥឡូវគាត់ស្ទើរតែអាចងើបឈរដោយខ្លួនឯង ហើយជម្នះជាមួយពិភពលោកទាំងមូល, ដោយបានស្រែកថា “ខ្ញុំធ្វើបានសម្រេចហើយ, ខ្ញុំអាចធ្វើបានដោយខ្លួនឯងហើយ”។

## សម្លេងទី៨ (ស្រី)

សេចក្តីក្លាហានចាប់ផ្តើមពីសម្លេងម្នាក់។
ខ្ញុំឈ្មោះ ជូលាអាណា ដកបាដហ្ស៊ី [Juliana Dogbadzi]។

*បុរសម្នាក់ធ្វើកាយវិការ និង ឈ្មោះ (ឬ រូបភាពរបស់) ជូលាអាណា ដកបាដហ្ស៊ី លេចចេញមុខលើអេក្រង់*

ខ្ញុំមកពីប្រទេស ហ្គាណា [Ghana]។ ពេលខ្ញុំអាយុ ៧ឆ្នាំ ឪពុកម្តាយខ្ញុំយកខ្ញុំចេញពីផ្ទះ ហើយបញ្ជូនខ្ញុំឲ្យទៅនៅ ទីសក្ការៈ (shrine) មួយធ្វើជាទាសី របស់អាចារ្យកាន់សីលម្នាក់អស់រយៈពេល៧ឆ្នាំ។ គេនិយាយថា ជីតាខ្ញុំបានលួចប្រាក់គេ ពីរដុល្លារ។ នៅពេលសមាជិកគ្រួសារខ្ញុំចាប់ផ្តើមស្លាប់ គ្រូទាយម្នាក់ និយាយថា គ្រួសារខ្ញុំត្រូវនាំស្រីក្មេងម្នាក់ទៅទីសក្ការៈ ដើម្បីផ្គាប់ចិត្តព្រះជាម្ចាស់។

## សម្លេងទី២ (ស្រី)

ពួកយើង ១២នាក់, ស្រី៤នាក់ និង កុមារ ៨នាក់, រស់នៅក្នុងបន្ទប់ផ្ទះមួយ ដំបូលប្រក់ស្បូវ។ ផ្ទះនោះគ្មានបង្អួច, គ្មានទ្វារទាំងអស់។ ភ្លៀងហូរចូល។ ពស់ក៏ចូលដែរ។ ពិដានទាបត្រឹមក្បាលពួកយើង ហើយពួកយើងទាំងអស់គ្នាដេករួមគ្នាលើកន្ទេលក្រាលលើកំរាលឥដ្ឋ។ នៅថ្ងៃធម្មតា នៅក្នុងទីសក្ការៈនោះ៖ អ្នកត្រូវក្រោកម៉ោង ៥ព្រឹក, ទៅដងទឹកនៅព្រែកឆ្ងាយដើម្បីយកមកប្រើក្នុងទីសក្ការៈនោះ, បោសសំអាត, និងរៀបចំម្ហូបប្រគេនអាចារ្យកាន់សីលនោះ, ដោយមិនបានហូបអ្វីទាំងអស់, ធ្វើការក្នុងស្រែចំការ រហូតម៉ោង ៦ល្ងាច, ត្រឡប់មកដេកវិញ បន្ទាប់ពីកាយរកម្ហូបសេសសល់ហូប។ ពេលយប់ អាចារ្យកាន់សីលនោះ តែងតែហៅម្នាក់ក្នុងចំណោមពួកយើងទៅបន្ទប់គាត់។

## សម្លេងទី៨ (ស្រ្តី)

ខ្ញុំមានអាយុ១២ឆ្នាំ នៅពេលខ្ញុំត្រូវគេរំលោភគ្រាដំបូង។ ខ្ញុំត្រូវតែធ្វើអ្វីម្យ៉ាងដើម្បីផ្លាស់ប្តូរជីវិតខ្ញុំ។ ទីបញ្ចប់ ឱកាសបានមកដល់ ហើយខ្ញុំពុំដឹងថា តើទំនុកចិត្តដែលខ្ញុំមានភ្លាមនៅពេលនោះ បានមកពីណាទេ, ប៉ុន្តែ ភាពភិតភ័យ ហាក់រលាយបាត់អស់តែម្តង។ ខ្ញុំដាក់កូនតូចទើបនឹងកើតទៅនឹងខ្នងរបស់ខ្ញុំ ហើយដឹកដៃកូនបងឈ្មោះ វ៉ុនឌឺរ [Wonder] រត់គេចតាមព្រៃ។

ឥឡូវនេះដោយសារខ្ញុំគេចខ្លួនបានហើយ ខ្ញុំក៏ជួយបន្ថយការភ័យខ្លាចរបស់ស្ត្រី ដោយនិយាយប្រាប់រឿងខ្ញុំដល់ពួកគេ។ អ្វីដែលខ្ញុំធ្វើមានគ្រោះថ្នាក់ណាស់ តែខ្ញុំបានត្រៀមខ្លួនស្លាប់រួចហើយ ដើម្បីបុព្វហេតុល្អមួយ។ នេះជាអាវុធរបស់ខ្ញុំ និងវានៅតែជាអាវុធខ្ញុំដដែល។

## សម្លេងទី៧ (ប្រុស)

ខ្ញុំឈ្មោះ អលី វីសែល [Elie Wiesel]។ ខ្ញុំចូលចិត្តអ្នកទន់ខ្សោយ និងអ្នកតូចតាច។ អញ្ចឹងហើយ ទើបនៅគ្រប់សៀវភៅខ្ញុំសរសេរតែងតែមានកុមារ និងមនុស្សចាស់ជានិច្ច, មិនដែលខាន។ ដោយសារតែពួកគេត្រូវរដ្ឋាភិបាល និង សង្គមមិនគិតគូរទាល់តែសោះ។ ទើបខ្ញុំផ្តល់ជម្រកឲ្យពួកគេ។ ខ្ញុំគិតដល់កុមារសព្វថ្ងៃ ដែលត្រូវការសម្លេងរបស់យើង។ ខ្ញុំនៅជំពាក់អ្វីមួយដល់មនុស្ស ដែលត្រូវគេទុកចោលមិនរាប់រក។ ហើយខ្ញុំសង្ឃឹមថា អតីតកាលរបស់ខ្ញុំ នឹងមិនក្លាយជាអនាគតកាល របស់កូនចៅរបស់អ្នកទាំងអស់គ្នាទេ។

## សម្លេងទីមួយ (ប្រុស)

ខ្ញុំឈ្មោះ ហ្គាប័រ ហ្គូមបុស [Gabor Gombos]។

*បុរសម្នាក់ធ្វើកាយវិការ និងឈ្មោះ ( ឬរូបភាពរបស់ ) លោកហ្គាប័រ ហ្គូមបុស លេចមុខលើអេក្រង់។*

ខ្ញុំមកពីប្រទេសហុងគ្រី [Hungary]។ ថ្ងៃមួយ ពេលខ្ញុំធ្វើការ ខ្ញុំបានទៅកាន់ស្ថាប័នមួយ។ មានបុរសវ័យក្មេងម្នាក់មានបញ្ហាផ្លូវចិត្តធ្ងន់ធ្ងរនៅក្នុងទ្រុង។ យើងសួរទៅបុគ្គលិកធ្វើការទីនោះថា តើយុវជននេះត្រូវគេដាក់នៅទីនោះយូរប៉ុណ្ណាហើយ។ ចម្លើយ គឺថា ពេញមួយថ្ងៃ, លើកលែងតែពេលកន្លះម៉ោង ពេលបុគ្គលិកធ្វើការជាមួយគាត់។ ខ្ញុំបានសួរថា ហេតុអ្វីក៏ដាក់គាត់ក្នុងទ្រុងយ៉ាងនេះ?

## សម្លេងទីពីរ (ស្រី)

ពួកគេត្រូវការសម្លេងមួយ។ ហើយខ្ញុំបានក្លាយជាសម្លេងរបស់ពួកគេ។

## សម្លេងទី៣ (ប្រុស)

យើងមានការការពារខ្លះៗ។ បើសិនខ្ញុំប្រឈមមុខនឹងគ្រោះថ្នាក់ខ្លាំងជាងនោះ, ខ្ញុំពិតជាមិនអាចអះអាងថា ខ្ញុំអាចធ្វើបានដូចអ្វី ដែលខ្ញុំបានធ្វើនោះទេ។ ខ្ញុំមិនគិតថា ខ្ញុំមានសេចក្តីក្លាហានពីកំណើតនោះទេ។ ផ្ទុយទៅវិញ ខ្ញុំមានលក្ខណៈធម្មតា និង ព្យាយាមចៀសវាងគេចពីគ្រោះថ្នាក់តាមដែលអាចធ្វើបាន។ ជាចុងក្រោយ គ្រប់ភាពក្លាហានដែលខ្ញុំបានបញ្ចេញ គឺការរៀនសូត្រពីរបៀបរស់នៅជាមួយភាពភ័យខ្លាចតែប៉ុណ្ណោះ។ ក្រោយមក ខ្ញុំលែងគិតពីរឿងគ្រោះថ្នាក់ទៀតហើយ, ប្រៀបដូចគ្នាទៅនឹងពេទ្យវះកាត់ ដែលស៊ាំនឹងឈាមដូច្នោះដែរ។

## បុរស (MAN)

ចូសេ ហ្សាឡាកែត [Jose Zalaquett]។ បាទ ពិតហើយ។ គឺមេធាវីមកពីប្រទេស ឈីលី [Chile] រូបនេះ ដែលបានរៀបចំការពារក្តីអ្នកទោសនៅក្រោយពេលរដ្ឋប្រហារនោះ។ មេធាវីហ្នឹងឯង ដែលបានទៅជំរំប្រមូលផ្តុំមនុស្ស ដែលគ្មាននរណា ម្នាក់អាចទៅបាន។

## ស្ត្រី (WOMAN)

មេធាវីហ្នឹង ត្រូវយើងចាប់ដាក់គុកពីរលើក។ ឈ្មោះ ហ្សាឡាកែត។ ដូចគ្នានឹង មេធាវីមកពីប្រទេស អាហ្សង់ទីន [Argentina] ឈ្មោះ ជាន់ម៉ង់ដេស [Juan Mendez] ដែរ គឺវាចង់រកអ្នកបាត់ខ្លួន, desaparecidos។

## បុរស (MAN)

យើងបានធ្វើឲ្យវាបាត់ខ្លួនប៉ុន្មានថ្ងៃទៅ ដើម្បីឲ្យវាដឹងថា តើវាយ៉ាងម៉េច, ឲ្យវាសាកភ្លក់រសជាតិវាមើលទៅ, ធ្វើទារុណកម្ម ប្រាំដងក្នុងមួយថ្ងៃ ឲ្យវាឆាប់ស្គាល់ថ្នាំខ្លាំង។

## ស្ត្រី (WOMAN)

មេធាវី! មេធាវី! វាដូចជា, ឈ្មោះ មីអីគេនោះ? មី ប៉ាទ្រីយ៉ា ជីមេនេ [Patria Jimenez]។ មេធាវីស្រលាញ់ភេទដូចគ្នាមកពីប្រទេស ម៉ិចសិក [Mexico] ម្នាក់នោះ បានជាប់ឆ្នោតជាសមាជិកសភាផង។ ដូចគ្នាហ្នឹង មេធាវីមកពីប្រទេស បេឡារូស [Belarus] ដែរ, ឈ្មោះ វ៉ាវ៉ា ស្រ្តីមកូវស្កាយ៉ា

[Vera Stremkovskaya] ដែលគិតថា សេចក្ដីក្លាហានប្រៀបដូចជា ខ្សែពួរដែកនៅខាងក្នុងខ្លួនអញ្ចឹង។

### បុរស (MAN)

ដូចខ្សែពួរដែកខាងក្នុង។ ពិតមែនហើយ ពួកវាខ្លាចណាស់។

### ស្ត្រី (WOMAN)

មែនណា ភ័យខ្លាចណាស់ ដូច អាប្រុសម្នាក់នោះអញ្ចឹង...

### សម្លេងទី៥ (ប្រុស)

ខ្ញុំបានចូលរួមតស៊ូតាំងពីខ្ញុំអាយុ ១២ឆ្នាំ។ មានក្រុមមនុស្សមួយក្រុមបានគោះទ្វារផ្ទះពួកយើងនៅប្រទេសអៀកឡង់ខាងជើង [North Ireland] ហើយនិយាយថា "ម៉ាទីន អូប្រាយអិន [Martin O'Brien], តើ លោកចង់ចូលរួមដើរក្បួនសន្តិភាពធ្វើបាតុកម្មប្រឆាំងនឹងអំពើហិង្សាឬទេ?" ខ្ញុំក៏និយាយថា ខ្ញុំនឹងទៅ។ ខ្ញុំចាំបានថា មានការភិតភ័យណាស់។ ប៉ុន្តែ អ្វីដែលយ៉ាប់យ៉ឺនបំផុតនោះ គឺភាពតោះតើយ, សម្ងំស្ងៀមនៅចំពោះមុខអំពើអយុត្តិធម៌ ហើយគ្មានបាន ធ្វើការអ្វីសោះ។ ស្លាប់ឆាប់ទៅវាល្អជាង។

*ស្ត្រីម្នាក់ធ្វើកាយវិការ និង ឈ្មោះ(ឬ រូបភាពរបស់ហ្វូកស៊ីយ៉ា កាស់ស៊ីនថា) លេចមុខលើអេក្រង់។*

### សម្លេងទី៦ (ស្ត្រី)

ខ្ញុំអត់ធ្វើកើតទេ។ ខ្ញុំមិនរៀបការជាមួយបុរសនោះទេ។ ខ្ញុំអាយុតែ ១៧ឆ្នាំ ឯគាត់វិញអាយុដល់ទៅ ៤៥ឆ្នាំ, ហើយធ្លាប់មានប្រពន្ធបីរួចហើយ។ តែម្ដាយមីងខ្ញុំនិយាយថា "មីងដឹង ឯងមិនស្រលាញ់គាត់ទេ, តែពេលឯងបាន 'កាគីយ៉ា' [kakiya], ឯងនឹងចេះស្រលាញ់គាត់ហើយ។ ស្អែកនេះជាថ្ងៃ កាគីយ៉ា [kakiya] ហើយ។" ប៉ុន្តែ ជាមួយការជួយរបស់បងស្រីខ្ញុំ ខ្ញុំបានរត់គេចចេញពីប្រទេសថូហ្គោ [Togo], ខ្ញុំបានទៅកាន់សហរដ្ឋអាមេរិកជាមួយលិខិតឆ្លងដែនក្លែងក្លាយមួយ។ ខ្ញុំបានប្រាប់នគរបាលអន្តោប្រវេសន៍ នៅព្រលានយន្តហោះ ណេវ៉ាក [Newark Airport] ថា ខ្ញុំចង់សុំសិទ្ធិជ្រកកោន។ ខ្ញុំបានប្រាប់រឿងរ៉ាវទាំងអស់... មែនទែន, មិនមែនទាំងអស់ទេព្រោះខ្ញុំអៀនខ្មាសពេក។ខ្ញុំមិនបានប្រាប់គាត់អំពីកាគីយ៉ា [kakiya] មកពីខ្ញុំគិតថា ប្រហែលជាគាត់ក៏មិនយល់ដែរ។ ខ្ញុំបានសិទ្ធិជ្រកកោន ឬ អត់អាស្រ័យលើចៅក្រមទេ ដូច្នេះ គាត់និយាយថា ខ្ញុំត្រូវជាប់ពន្ធនាគារសិន។ គេដាក់ច្រវ៉ាក់ខ្ញុំ។ ក្នុងមន្ទីរឃុំឃាំងនៅរដ្ឋញូវ ជឺស៊ី [New Jersey] ខ្ញុំបានជួបជាមួយ សេស៊ីលីយ៉ា ជេហ្វ្រី [Cecelia Jeffrey] ដែលជាអ្នកទោសម្នាក់ទៀត។ សេស៊ីលីយ៉ា រាប់អានខ្ញុំដូចកូនស្រីគាត់។ នៅពេលដែលខ្ញុំចូលទៅសម្រាកគាត់ជួយទាញកម្រាលពូកឲ្យខ្ញុំ។ ពេលដែលខ្ញុំឈឺខ្លាំង គេមិនឲ្យថ្នាំដល់ខ្ញុំទេ, ហើយខ្ញុំគិតថា "បើសិន ជាខ្ញុំត្រូវស្លាប់នៅទីនេះដដែល, ហេតុអ្វីក៏មិនត្រលប់ទៅស្រុកកំណើតវិញ?" សេស៊ីលីយ៉ា បាននិយាយថា "ឯងឆ្កួតទេអី ហ្វូហ្សីយ៉ា? ឯងដឹងថាត្រលប់ទៅស្រុកវិញធ្វើអ្វីទេ? អ្នកមានដឹងអត់?"

### សម្លេងទី៤ (ស្ត្រី)

ទោះជាស្ថិតក្នុងពេលវេលាងងឹតសូន្យសុង, មហាសូន្យសុងយ៉ាងណាក្តីក៏មានមនុស្សក្រោកឈរដើម្បីការពារអ្នកដទៃដែរ។ យ៉ាងហោចណាស់ក៏មានមនុស្សម្នាក់ ដែលក្រោកឈរការពារអ្នកដទៃដែរ។ ឲ្យទាំងអស់គ្នាដឹងថា ក្នុងគ្រាលំបាកបែបនេះក៏ដោយ ក៏មានមនុស្សយ៉ាងតិចម្នាក់ដែលក្រោកឈរជួយការពារអ្នកដទៃ។

### សម្លេងទី៦ (ស្រី)

"ហ្វូស៊ីយ៉ា, ឯងឆ្កួតទេឬ?" គាត់និយាយត "ឯងចង់ត្រឡប់ទៅ ប្រទេសតូហ្គោ វិញ?" ថ្ងៃបន្ទាប់ សេស៊ីលីយ៉ា បានទៅងូតទឹក ហើយហៅខ្ញុំមកជាមួយ, ហើយគាត់ឈរនៅទីនេះ ហើយកន្ត្រៃកជើង រួចនិយាយថា "មើលទៅ តើនេះជាអ្វី ដែលឯងចង់ត្រឡប់ទៅវិញនោះ?" ខ្ញុំមិនបានដឹងថា ខ្ញុំបានឃើញអ្វីនោះទេ។ "ឯងដឹងទេនេះជាស្អី?" ខ្ញុំមិនបានដឹងទេ។ វាមើលទៅមិនដូចជាប្រដាប់ភេទមនុស្សស្រីទេ។ មើលទៅរាងដូចរបស់សំប៉ែតមួយ ដូចបាតដៃខ្ញុំអញ្ចឹង។ អ្វីម៉្យាងគត់ ដែលអ្នកអាចឃើញ គឺជាសម្លាក ដូចស្នាមដេរអញ្ចឹងដែរ, ហើយមានរន្ធតូចមួយតែប៉ុណ្ណោះ។ មានតែប៉ុណ្ណឹង គ្មានបបូរទេ, គ្មានអ្វីសោះ។ កាគីយ៉ា [Kakiya]។ ខ្ញុំនិយាយថា "អ្នករស់ក្នុងសភាពបែបនេះ?" គាត់ក៏ឆ្លើយថា "ពេញមួយជីវិតខ្ញុំហើយ, ខ្ញុំយំរហូតពេលខ្ញុំឃើញវា, ខ្ញុំក្តុកក្តួលក្នុងចិត្តណាស់, ខ្ញុំមានអារម្មណ៍ទន់ខ្សោយណាស់ និង មានអារម្មណ៍ចុះចាញ់គ្រប់ពេល។" រួចខ្ញុំ ក៏សម្លឹងមើលគាត់ ខ្ញុំក៏បានឃើញស្ត្រីដែលរឹងមាំជាងគេបង្អស់លើលោក។ មើលពីខាងក្រៅ គ្មានអ្នកណាដឹងថា គាត់ឈឺចាប់ទេ។ គាត់ជាមនុស្សគួរឲ្យស្រលាញ់ជាទីបំផុត ដែលខ្ញុំមិនធ្លាប់បានជួប។ គាត់ជាអ្នកធ្វើឲ្យខ្ញុំនៅទីនោះតទៅទៀត, ហើយគាត់បានជួយឲ្យខ្ញុំឈ្នះក្តី។

### សម្លេងទី៤ (ស្រី)

មានតិចតួច និង ម្តងម្កាល
យើងបានឃើញពន្លឺនោះច្រើនដងហើយ។

### បុរស (MAN)

ពួកគេបានឃើញ? ពួកគេធ្លាប់ឃើញពន្លឺនោះច្រើនដងឬ? តើមានពន្លឺប៉ុន្មានដែលពួកគេពិតជាបានឃើញនោះ? តើពួកគេបានសង្គ្រោះជីវិតមនុស្សប៉ុន្មាននាក់ហើយ? គឺតិចតួច និង ម្តងម្កាលអ្វីដែលពួកគេដឹង៖ ការដើរចូលច្រកមរណៈនេះ។

### ស្ត្រី (WOMAN)

នេះជា អ្វីដែលពួកគេភ័យខ្លាចមែនទែន៖ គឺភ័យថា គ្មាននរណាគេខ្វល់,

ភ័យថា មនុស្សម្នាទាំងឡាយ គេបានភ្លេចបាត់ទៅហើយ, គេមើលទូរទស្សន៍ហើយ គេនិយាយថា វាមិនមែនជារឿងរបស់ខ្លួនគេទេ ហើយគេទៅហូបបាយ រួចគេទៅដេក។ គេចូលដេកអស់បាត់ហើយ។

បុរស (MAN)

មនុស្សចូលដេកបាត់អស់ហើយ។ នោះ ជាអ្វីដែលគេដឹង និងភ័យខ្លាច។ ពួកគេដឹងថា មនុស្ស ៣,០០០លាននាក់ កំពុងរស់ក្នុងភាពក្រីក្រ ហើយក្មេង ៤០,០០០ នាក់ ស្លាប់ជារៀងរាល់ថ្ងៃ ដោយសារជម្ងឺដែលអាចបង្ការបាន។

ស្ត្រី (WOMAN)

ពួកគេដឹងថា នរណា៣នាក់ ជាអ្នកកំពូលមានជាងគេ ក្នុងពិភពលោក...

បុរស (MAN)

...ពួកគេនោះ មានទ្រព្យច្រើនជាងផលិតផលក្នុងស្រុកសរុប នៃប្រទេសក្រីក្របំផុត ចំនួន៤៨បូកចូលគ្នា។ ហើយរឿងនេះវានឹងមិនមានការផ្លាស់ប្តូរអ្វីទេ ដោយគ្រាន់តែសង្គ្រោះជីវិតមនុស្សម្នាក់, ហើយម្នាក់ទៀត ហើយថែមម្នាក់ទៀតនោះ។ គ្មានអ្វីដែលនឹងអាចផ្លាស់ប្តូរកើតនោះទេ។ នេះ ជាអ្វីដែលពួកគេភ័យ៖ គឺគ្មាននរណាខ្វល់នោះទេ។

សម្លេងទីមួយ (ប្រុស)

ខ្ញុំឈ្មោះ អូស្កា អារីយ៉ាស សាន់ចេ [Oscar Arias Sanchez]។ ហើយខ្ញុំខ្វល់។

*ស្ត្រីម្នាក់ធ្វើកាយវិការ និង ឈ្មោះ(ឬ រូបភាពរបស់) អូស្កាអារីយ៉ាសសានចេ លេចចេញមុខលើអេក្រង់ ។*

ការចំណាយយោធាមិនមែនគ្រាន់តែជាការចំណាយដ៏លើសលប់ប៉ុណ្ណោះទេ, ប៉ុន្តែ ផ្ទុយទៅវិញ វាតំណាងឲ្យការបំផ្លាញធំបំផុត ចំពោះអាទិភាពក្នុងសម័យកាលរបស់យើង៖ ទឹកប្រាក់ ៧៨០ ពាន់លានដុល្លារ ក្នុងមួយឆ្នាំត្រូវចំណាយទៅលើឧបករណ៍សម្លាប់មនុស្ស, ទៅលើកាំភ្លើង, ទៅលើយន្តហោះចំបាំង សម្រាប់ប្រល័យមនុស្ស ដែលលុយនោះ អាចយកទៅចំណាយលើការអភិវឌ្ឍន៍មនុស្សវិញបាន។ បើគ្រាន់តែ យើងចែករំលែកប្រាក់ចំណាយនោះតែ ៥% នៃតួលេខនេះ សម្រាប់ពេល ១០ឆ្នាំខាងមុខ, គឺគ្រាន់តែ ៥% នៃប្រាក់ច្រើនរយពាន់លានដុល្លារនោះ, ទៅក្នុងកម្មវិធីប្រឆាំងនឹងភាពក្រីក្រវិញនោះ, ប្រជាពលរដ្ឋក្នុងពិភពលោកទាំងអស់នឹងទទួលបានសេវាកម្មជាមូលដ្ឋានហើយ។ អ្នកក្រីក្រក្នុងពិភពលោកកំពុងស្រែកទាមទារចង់បានសាលា និងគ្រូពេទ្យ, មិនមែនកាំភ្លើង និងឧត្តមសេនីយ៍នោះទេ។

បុរស (MAN)

មែនហើយ! អ្នកក្រីក្រក្នុងពិភពលោកកំពុងស្រែកទាមទារអញ្ចឹងមែន។ ប៉ុន្តែ មានអ្នកណាទៅខ្វល់គិតគូនោះ?

ស្ត្រី (WOMAN)

មានអ្នកណាគេខ្វល់?

សម្លេងទី៣ (ប្រុស)

នៅពេលនោះ ខ្ញុំស្នាក់នៅក្នុងព្រៃ និងសង្កេតឃើញជីវិតដ៏សែនលំបាកលំបិនរបស់អ្នកភូមិ នៅប្រទេសភូមា [Burma]។

*បុរសម្នាក់ធ្វើកាយវិការ និងឈ្មោះ (ឬ រូបភាពរបស់) កាស៉ាវ៉ា លេចមុខតាមអេក្រង់។*

ពេលព្រឹក អ្នកភូមិចាប់ចបកាប់ និងកន្ត្រក, ហើយ គឺត្រូវគេបង្ខំឲ្យកសាងកន្លែងសម្រាប់យោធា។ ពួកគេអត់បានប្រាក់កម្រៃអ្វីទាំងអស់។ ខ្ញុំបាននិយាយជាមួយម្តាយម្នាក់ ដែលកូនប្រុសគាត់បានសម្លាប់ខ្លួន ព្រោះក្រុមទាហានបានបង្ខំឲ្យរួមភេទជាមួយម្តាយ។ កូនប្រុសគាត់សម្លាប់ខ្លួនឯង ដោយសារភាពអាម៉ាស់។ គឺពេលនោះហើយ ដែលនាំឲ្យខ្ញុំសម្រេចចិត្តធ្វើការឲ្យប្រជារាស្ត្រទាំងនោះ។ ពីដំបូង ខ្ញុំគ្មានទាំងប៊ិច, គ្មានទាំងក្រដាសធ្វើការទេ។ អ្នកកតស៊ូបានប្រាប់ខ្ញុំ អំពីហេតុការណ៍នេះកើតឡើងជារឿយៗ ហើយគ្មាននរណាខ្វល់ទេ ហើយថាខ្ញុំត្រូវចាប់អាវុធ និងប្រយុទ្ធតស៊ូ។ ប៉ុន្តែ ខ្ញុំសម្រេចបន្តធ្វើការ ទាក់ទងនឹងការប្រមូលរឿងរ៉ាវរបស់ពួកគេ, តាមលទ្ធភាពដែលខ្ញុំអាចធ្វើបាន។ ខ្ញុំងារមែនទែននៅតំបន់ទួលនោះ ហើយអ្វីដែលយើងមាន គឺកម្រាលផ្លាស្ទិកមួយសម្រាប់ដណ្តប់ខ្លួន។ ទោះបីយើងចងអង្រឹងកុំឲ្យឈ្លើងចេញមកទាមយើងក៏ដោយ ក៏នៅពេលព្រឹកឡើង យើងដឹងថា ឈ្លើងធ្លាក់មកពីលើដើមឈើ ហើយបឺតឈាមរបស់យើង។ មានពេលមួយ ខ្ញុំចង់បាញ់សម្លាប់ខ្លួនឯង នៅពេលដែលយើងគ្មានទឹកសោះ ហើយយើងត្រូវហូបអង្ករឆៅ។ ប៉ុន្តែ យើងនៅតែបន្តប្រមូលរឿងរ៉ាវតទៅទៀត។ ទីបំផុតយើងបានស្ត្រីម្នាក់មកពីប្រទេសបារាំង ដែលបានឲ្យលុយយើងទិញក្រដាស និង ផ្ញើសំបុត្រ។ ខ្ញុំរីករាយមែនទែន ដោយសារចុងក្រោយយើងអាចធ្វើអ្វីមួយបាន។ ថ្ងៃមួយ ខ្ញុំបានទៅអង្គការសិទ្ធិមនុស្សមួយ ដែលធ្វើការលើរឿងផ្សេង។ នៅទីនោះ ខ្ញុំបានឃើញឯកសារ ដែលយើងប្រឹងធ្វើការយ៉ាងខ្លាំងដើម្បីធ្វើបាននោះ នៅក្នុងធុងសំរាម។ វាជាការលំបាកណាស់ ទម្រាំបានក្រដាសទាំងនោះផ្ញើទៅ និង លំបាកណាស់ ក្នុងការកត់ត្រាការឈឺចាប់ ដែលមនុស្សទាំងនោះ ត្រូវទ្រាំរស់ទាំងត្រដរ។ ឯកសារទាំងនោះ ត្រូវបានគេស្នូរឡើងខ្មេច រួចបោះចោល។

បុរស (MAN)

កា សា វ៉ា [Ka Hsaw Wa] មកពីប្រទេសភូមា។ ត្រូវហើយ។ វាមាន

អារម្មណ៍ខ្មេចខ្មាំក្នុងចិត្ត។ ត្រូវហើយ។ ប៉ុន្តែ យើងបានប្រាប់ វាហើយ ថា វាគ្មានបានការអីទេ។

### ស្ត្រី (WOMAN)

យើងបានប្រាប់វាហើយ។ យើងបានប្រាប់វាហើយថា វាកំពុងខ្ជះខ្ជាយជីវិតរបស់វា។ គ្មាននរណាស្តាប់ ហើយក៏គ្មាននរណាគេខ្វល់ដែរ។

### សម្លេងទី២ (ស្រី)

ស្ត្រីជាច្រើន ក្នុងប្រទេស កេនយ៉ា [Kenya] មិនមានអុសសម្រាប់ដុតទេ។ ពួកគេត្រូវការផ្លែឈើ ដើម្បីព្យាបាលជម្ងឺខ្វះជីវជាតិក្នុងខ្លួនកូនរបស់ពួកគេ និង ត្រូវការទឹកស្អាតសម្រាប់ផឹក។ ប៉ុន្តែ ថ្នាំសម្លាប់សត្វល្អិត និង សារជាតិគីមី ដែលគេប្រើក្នុងស្រែចំការបានបំពុលទឹកអស់។ យើងបានលើកទឹកចិត្តពួកគេឲ្យដាំដើមឈើ។ យើងទៅប្រមូលពូជពីដើម ហើយយកមកដាំតាមវិធី ដែលស្ត្រីបានធ្វើជាមួយនឹងពូជដទៃទៀត។ នេះជារបៀប៖ យកផើងមួយ, ដាក់ដី និង ពូជចូល។ ដាក់ផើងនោះឲ្យខ្ពស់ ដើម្បីកុំឲ្យ មាន់ ឬ ពពែ មកស៊ី។ យើងដាំបានជាង ២០លានដើម តែក្នុងប្រទេសកេនយ៉ា មួយ។ ហើយ ចលនាក្រវ៉ាត់ខៀវ [Green Belt Movement] បានចាប់ផ្តើមកម្មវិធី នៅក្នុងប្រទេសប្រហែល២០។

*ស្ត្រីម្នាក់ធ្វើកាយវិការ និង ឈ្មោះ (ឬ រូបភាពរបស់) វ៉ាន់ហ្គារី ម៉ាថៃ លេចមុខតាមអេក្រង់។*

### សម្លេងទី២ (ស្រី)

ទង្វើនេះមិនបានធ្វើឲ្យមេដឹកនាំចូលចិត្តយើងនោះទេ។ ពួកគេវាយប្រហារយើង វាយប្រហារខ្ញុំ។ ប៉ុន្តែ សំណាងល្អ ស្បែកខ្ញុំក្រាស់ដូចស្បែកដំរីអញ្ចឹង។ ខ្ញុំឈ្មោះ វ៉ាន់ហ្គារី ម៉ាថៃ [Wangari Maathai]។

### សម្លេងទី១ (បុរស)

ខ្ញុំឈ្មោះ កៃឡាស៍ សាទីអាទី [Kailash Satyarthi]។

*បុរសម្នាក់ធ្វើកាយវិការ និង ឈ្មោះ (ឬ រូបភាពរបស់កៃឡាស៍ សាទីអាទី លេចមុខតាមអេក្រង់។*

នៅពេលដែលខ្ញុំមានអាយុ ៥ ឬ ៦ឆ្នាំ នៅថ្ងៃដំបូង ដែលខ្ញុំទៅរៀន, ខ្ញុំបានឃើញអ្នកដេរស្បែកជើង និង កូនប្រុសរបស់គាត់ អង្គុយនៅចំមាត់ទ្វារសាលា, ពួកគាត់កំពុងអង្គុយសម្អាត និង ខាត់ស្បែកជើងឲ្យក្មេងដទៃទៀត។ ពេលខ្ញុំចូលទៅដល់ ខ្ញុំឃើញមានភាពរីករាយសប្បាយមែនទែន។ ខ្ញុំកាន់សៀវភៅថ្មី, សំពាតថ្មី, ខោអាវថ្មី, ឯកសណ្ឋានថ្មី, អ្វីៗសុទ្ធតែថ្មីទាំងអស់ ហើយនៅពេលខ្ញុំឃើញក្មេងនោះ ខ្ញុំក៏ឈប់មួយសន្ទុះ ពីព្រោះតាមចំណេះដឹង និង សម្បជញ្ញៈខ្ញុំ វាជាលើកដំបូង ហើយ ដែលខ្ញុំជួបប្រទះរឿងបែបនេះ។ ដូច្នេះ ខ្ញុំចាប់មានគំនិតពិចារណាថា ហេតុអ្វី ក៏ក្មេងអាយុប៉ុនខ្ញុំ បែរជាអង្គុយខាត់ស្បែកជើងឲ្យក្មេងៗដូចខ្ញុំវិញ ហើយហេតុអ្វីខ្ញុំត្រូវទៅរៀន? ខ្ញុំចង់សួរសំណួរនេះទៅក្មេងនេះ តែខ្ញុំមិនមានក្តីក្លាហានគ្រប់គ្រាន់សោះ, ទើបខ្ញុំចូលថ្នាក់ ហើយគ្រូបង្រៀនស្វាគមន៍ខ្ញុំ តែខ្ញុំពុំបានសួរសំណួរនេះទេ ទោះជាខ្ញុំនៅមានអារម្មណ៍ក្នុងចិត្តថា ត្រូវសួរក្តី។ ប៉ុន្តែ ពីរម៉ោងក្រោយ ទើបខ្ញុំប្រមូលផ្តុំភាពក្លាហានទាំងអស់របស់ខ្ញុំសួរទៅលោកគ្រូថា “លោកគ្រូ ហេតុអ្វី ក៏ក្មេងអាយុស្របាលខ្ញុំបែរជាអង្គុយមុខទ្វារសាលាខាត់ស្បែកជើងវិញ? គាត់សម្លឹងមកខ្ញុំវិញយ៉ាងចម្លែក ហើយនិយាយថា ឯងសួរស្អី ឯងមករៀននៅទីនេះមិនមែនមកសម្រាប់ខ្វល់រឿងអត់បានការ ហើយសំណួរនេះមិនមែនជាកិច្ចការរបស់ឯងទេ”។ ខ្ញុំបានខឹង។ ខ្ញុំគិតថា ពេលទៅផ្ទះ នឹងសួរសំណួរទៅម្តាយខ្ញុំ។ពេលខ្ញុំសួរគាត់ថា“អ្ហេ!ឯងមិនឃើញក្មេងគេធ្វើការច្រើនគ្នាទេអី? វាជាវាសនារបស់គេ ព្រោះគេក្រីក្រ ពួកគេត្រូវខំធ្វើការ” ហើយគាត់ថា កុំឲ្យគិតរឿងនេះ។ តែថ្ងៃមួយ ខ្ញុំបានទៅជួបឪពុក ដែលជាអ្នកជួសជុលស្បែកជើងនោះ ហើយនិយាយទៅកាន់គាត់ថា “ខ្ញុំមើលក្មេងនេះរាល់ថ្ងៃ ខ្ញុំមានសំណួរមួយថា ហេតុអ្វីមិនបញ្ជូនកូនទៅរៀន?” ប្រហែលពីរនាទី ទើបគាត់ឆ្លើយយឺតៗថា “ពួកខ្ញុំកើតក្នុងវណ្ណៈទាសករ (untouchables), យើងកើតមកសម្រាប់ធ្វើការ។” ហេតុនេះខ្ញុំមិនអាចយល់ថា ហេតុអ្វីមានមនុស្សខ្លះកើតឡើងសម្រាប់ធ្វើការ និងខ្លះទៀតដូចយើងកើតមកសម្រាប់ទៅសាលារៀន។ វាកើតចេញមកពីណាមក? វាធ្វើឲ្យគំនិតខ្ញុំប្រទាំងប្រទើសបន្តិច ព្រោះគ្មាននរណាមួយអាចឆ្លើយសំណួរខ្ញុំបាន។ តើខ្ញុំត្រូវសួរនរណាគេ? លោកគ្រូខ្ញុំអត់ឆ្លើយ។ គ្មាននរណាម្នាក់ឆ្លើយសំណួរបានល្អទេ។ ខ្ញុំទុករឿងនេះដក់ក្នុងចិត្តខ្ញុំអស់ពេលច្រើនឆ្នាំ។ ឥឡូវនេះ ខ្ញុំកំពុងធ្វើកិច្ចការអំពីរឿងនេះខ្លះហើយ។ មានកុមារនៅប្រទេសឥណ្ឌា ៥លាននាក់ កើតមកសម្រាប់តែបំរើជាទាសករ។ ក្មេងអាយុត្រឹម ៦-៧ ឆ្នាំ ត្រូវបង្ខំឲ្យធ្វើការ ១៤ម៉ោងមួយថ្ងៃ។ បើពួកគេយំរកឪពុកម្តាយ ពួកគេនឹងត្រូវគេវាយយ៉ាងចាស់ដៃ, ពេលខ្លះ គេចងព្យួរជើងឡើងលើ ក្បាលចុះក្រោមលើដើមឈើ, ហើយ ត្រូវបានគេដំឲ្យមានស្លាកស្នាមដោយដែកក្តៅ ឬ យកភ្លើងបារីអុជ។ ចំនួនក្មេងទាសករកើនឡើងតាមអាត្រាកំណើននាំចេញ។ កំណើននាំចេញកម្រាលព្រំកើនឡើង ចំនួនកុមារជាខ្ញុំកញ្ជះក្នុងឧស្សាហកម្មព្រំនេះក៏កើនឡើងរហូតដែរ។ អញ្ចឹង ទើបយើងធ្វើយុទ្ធនាការជាមួយអ្នកប្រើកម្រាលព្រំ។ និងចាត់សកម្មភាពផ្ទាល់៖ ចុះឆែកឆេរជាសម្ងាត់ និង ដោះលែងកុមារទាំងនោះឲ្យត្រលប់ទៅនៅជាមួយគ្រួសារពួកគេវិញ។ ប៉ុន្តែពេលយើងលែងពួកគេ, ការងារនេះទើបតែចាប់ផ្តើមតែប៉ុណ្ណោះ។

### សម្លេងទី៧ (ប្រុស)

វាពិបាកនឹងធ្វើឲ្យគេឮសម្លេងយើងណាស់។
យើង ជនជាតិ ប៉ាលេស្ទីន...

*បុរសធ្វើកាយវិការ និង ឈ្មោះ (ឬ រូបភាពរបស់) រ៉ាជី ស្នូរ៉ានី លេចមុខលើអេក្រង់។*

...ស្ទើរតែជាប្រជាជនដែលគេបំភ្លេចចោលបាត់ទៅហើយ, ត្រូវគេចាត់ទុកប្រទេសជជុះថោកទាបជាងគេហើយ។ គ្មាននរណាត្រូវការសន្តិភាព, គឺសន្តិភាព ដែលមានយុត្តិធម៌, ជាងអ្នកដែលត្រូវគេជិះជាន់ទេ។ ខ្ញុំមកពីតំបន់ ហ្គាសា [Gaza]។ ខ្ញុំចាប់ផ្ដើមប្រយុទ្ធដើម្បីសន្តិភាពតាំងពីវ័យក្មេងបំផុត។ អ្នកមើលឃើញនរកនៃជីវភាពប្រចាំថ្ងៃរបស់យើង ហើយអ្នកសួរថា៖ ហេតុដូចម្ដេច បានជាភាពអយុត្តិធម៌នេះកើតឡើងបាន? ហេតុអ្វីក៏ផ្ទះអ្នកជិតខាងយើងត្រូវគេកម្ទេច? ហេតុអ្វីក៏បងប្រុសខ្ញុំត្រូវជាប់គុក? ហើយខ្ញុំនិយាយអំពី អំពើទារុណកម្ម។ ខ្ញុំពុំអាចមិននិយាយអំពី អំពើទារុណកម្មបានទេ។ យើងត្រូវតែមានស្តង់ដារតែមួយ សម្រាប់គ្រប់មនុស្សទាំងអស់, ទាំង អ៊ីស្រាអែល និង ប៉ាឡេស្ទីន, ព្រោះថា ជីវិតមនុស្សជារបស់ពិសិដ្ឋ មិនថា សញ្ជាតិ, ពូជសាសន៍ និង សាសនាអ្វីទេ។

## សម្លេងទី៥ (ប្រុស)

អ្នកដែលបាត់ខ្លួនទាំងនោះជាកសិករ។

*បុរសម្នាក់ធ្វើកាយវិការ និង ឈ្មោះ (ឬ រូបភាពរបស់) ហ្វ្រាន់ស៊ីស្កូ សូបេរ៉ុន លេចមុខលើអេក្រង់។*

កសិករ អង់ដេស [Andean] មានភាសាចម្បង គឺ ក្វេជួ [Quechua] មិនមែនភាសាអេស្ប៉ាញទេ។ ពួកគេត្រូវចាត់ទុកជាពលរដ្ឋថោកទាបជាងប្រជាពលរដ្ឋផ្សេងទៀត។ អញ្ចឹងហើយបានជា មិនសូវមានគេអើពើឡើយ។

## សម្លេងទី៥ (ប្រុស)

គ្មានអ្វីអាក្រក់សម្រាប់អ្នកទោស ជាជាងការមានអារម្មណ៍ថា គាត់ត្រូវគេបំភ្លេចចោលនោះឡើយ។ ជារឿយៗ អ្នកធ្វើទារុណកម្ម ប្រើភាសាបែបនេះ ដើម្បីបំបាត់ស្មារតីអ្នកទោស ដោយគេនិយាយថា, ឯងដឹងទេ? គ្មាន អ្នកណាគេខ្វល់ទេ។

## ស្ត្រី

យើងបានប្រាប់វា។ យើងនិយាយថា អ្នកឯងដឹងទេ គ្មានអ្នកណា គេខ្វល់ជាមួយអ្នកឯងទេ។

## សម្លេងទី៧ (ប្រុស)

នាឆ្នាំដំបូង នៅគ្រាជាប់គុកនៅប្រទេសចិន ខ្ញុំយំស្ទើររាល់ថ្ងៃ។ ខ្ញុំនឹកគ្រួសារខ្ញុំ ពិសេសម្ដាយខ្ញុំដែលបានធ្វើអត្តឃាត ដោយសារគេចាប់ខ្លួនខ្ញុំ។ ខ្ញុំកាន់សាសនា កាតូលិក [Catholic], ដូច្នេះ ខ្ញុំបានបន់ស្រន់ព្រះ។ ប៉ុន្តែ ពីរឆ្នាំក្រោយមក ខ្ញុំលែងមានទឹកភ្នែកទៀតហើយ។ យើងមានជីវិតតែម្ដងគត់។ គេបានវាយបំបាក់ឆ្អឹងខ្នងរបស់ខ្ញុំ។ ក្រោយមក នៅពេលខ្ញុំរស់នៅនិរទេសខ្លួន មនុស្សម្នា ហៅ ហារី វូ [Harry Wu] ថា ជាវីរជន។

*ស្ត្រីធ្វើកាយវិការ និង ឈ្មោះ (ឬ រូបភាពរបស់) ហារី វូ លេចមុខលើអេក្រង់។*

ប៉ុន្តែ វីរជនពិតនោះ នឹងស្លាប់ទៅហើយ។ បើខ្ញុំជាវីរជនពិតប្រាកដដូចអ្នកដែលខ្ញុំបានជួបនៅជំរុំឃុំឃាំងនោះ ខ្ញុំប្រហែលជាធ្វើអត្តឃាតបាត់ហើយ។ ឥឡូវនេះ ខ្ញុំចង់ឃើញពាក្យ ឡាវហ្គៃ [laogai] ក្លាយជាពាក្យមាននៅគ្រប់វចនានុក្រម។ "ឡាវ" មានន័យថា ពលកម្ម, "ហ្គៃ" គឺ កំណែទម្រង់។ ពួកគេកែទម្រង់មនុស្ស។ មុនឆ្នាំ១៩៧៤, ហ្គូឡាក់ [gulag] គឺមិនមែនជាពាក្យមួយទេ។ ឥឡូវនេះ វាក្លាយជាពាក្យមួយ។ ដូច្នេះ យើងត្រូវលាតត្រដាងពាក្យឡាវហ្គៃ៖ ថាមានជនរងគ្រោះប៉ុន្មាននាក់នៅទីនោះ? តើពួកគេត្រូវស៊ូទ្រាំរស់ក្នុងល័ក្ខខ័ណ្ឌបែបណា? ខ្ញុំចង់ឲ្យមនុស្សម្នាដឹង អំពីផលិតផលនៅប្រទេសចិន ដែលផលិតដោយអ្នកទោស៖ របស់ក្មេងលេង, បាល់ទាត់, ស្រោមដៃវះកាត់។ ខ្ញុំចង់ឲ្យពិភពលោកដឹងថា បច្ចុប្បន្ននេះប្រជាជនចិនមានសិទ្ធិជ្រើសរើសម៉ាកយីហោ សាប៊ូកក់សក់, ប៉ុន្តែ ពួកគេនៅពុំមានសិទ្ធិនិយាយអ្វី ដែលពួកគេចង់និយាយពិតៗនោះទេ។

*បុរសម្នាក់ធ្វើកាយវិការ និង ឈ្មោះ (ឬ រូបភាពរបស់) ប៊ីកញូ ប៊ូចាក់ លេចមុខលើអេក្រង់។*

## សម្លេងទី៣ (ប្រុស)

ការដើរមួយជំហានពីមុខប៉ូលីសសម្ងាត់នោះ ជាអ្វីដែលយើងត្រូវធ្វើ ដើម្បីរស់រានមានជីវិត។ អ្នកដទៃទៀត នៅក្នុងចលនាសាមគ្គីភាពមិនបានដឹងថា យើងរស់នៅទីណាទេ ឬ មិនបានដឹងថា អ្នកណារៀបចំសម្រាប់យើងទេ។ រៀងរាល់ខែ យើងត្រូវផ្លាស់ប្ដូរលំនៅដ្ឋាន និង រូបរាងយើង និង កែបន្លំខ្លួន។ យើងត្រូវទុកចិត្តលើជន ដែលយើងមិនដែលស្គាល់សោះ។ រង្វាន់សម្រាប់លក់ខ្លួនពួកយើងបានច្រើនណាស់ គឺ ២០,០០០ ដុល្លា ព្រមជាមួយនឹងទិដ្ឋាការចេញជាអចិន្ត្រៃយ៍ពី ប្រទេសប៉ូឡូញ [Poland]។ ប៉ុន្តែ គេក្បត់តែម្ដងគត់។

## សម្លេងទី៧ (ប្រុស)

យើងដាក់ការទុកចិត្តលើជន ដែលយើងមិនដែលស្គាល់សោះ។ គេក្បត់តែម្ដងគត់។

## សម្លេងទី៥

យើងគ្មានសិទ្ធិត្រូវបាត់ក្ដីសង្ឃឹមទេ។

ខ្ញុំឈ្មោះ បបប៊ី មូឡឺ [Bobby Muller]។

*បុរសម្នាក់ធ្វើកាយវិការ និង ឈ្មោះ (ឬ រូបភាពរបស់) បបប៊ី មូឡឺ លេចចេញមុខលើអេក្រង់។*

រឿងមួយដែលចម្រៃបំផុត គឺពេលដែលយើងត្រូវគេប្រគល់រង្វាន់ ណូបែល សន្តិភាព [Nobel Peace Prize] សម្រាប់កិច្ចការរបស់យើងក្នុងការប្រឆាំងគ្រាប់មីនកប់ក្នុងដីនោះ គឺប្រព្រឹត្តិបែបមនោសញ្ចេតនាក្នុងប្រព័ន្ធផ្សព្វផ្សាយ ដើម្បីធ្វើឲ្យមនុស្សម្នាមានអារម្មណ៍ល្អ, មានការផ្តល់កម្លាំងបណ្តាលចិត្ត។ វាជាអាចម៍សេះ!។ មនុស្សម្នាតែងគិតថា ដោយសារមានសន្ធិសញ្ញាអន្តរជាតិ, វាជារឿងស្រេចហើយ, អស់ការងារត្រូវធ្វើហើយ។ ចូរមើលចុះ, យើងរស់ក្នុងជីវិត ដែលដាច់ចេញយ៉ាងខ្លាំង ជម្រៅនៃភាពអស់សង្ឃឹម,នៃការឈឺចាប់និងការប៉ះទង្គិចផ្លូវចិត្តយ៉ាងខ្លាំង។ ដូច្នេះហើយ បានជាខ្ញុំមានអារម្មណ៍យ៉ាងខ្លាំងក្នុងការទាមទារឲ្យមានការគោរពច្បាប់ និង ត្រូវគោរពពិតប្រាកដ, ជាជំនឿដែលអ្នកមិនអាចអនុញ្ញាតឲ្យមានបទប្រល័យពូជសាសន៍កើតមាននៅ ប្រទេសកម្ពុជា នៅប្រទេសរ៉្វាន់ដា [Rwanda] និង នៅក្នុងពិភពលោក។ ព្រោះថាវាអាចនឹងសាបព្រោះបណ្តុះគ្រាប់ពូជ នៃការបំផ្លិចបំផ្លាញឡើងវិញ។ ថ្ងៃណាមួយ កម្រិតនៃភាពឆ្កួតលីលានេះ នឹងរីករាលដាលឆ្លងទៅដល់តំបន់រស់នៅរបស់យើង។

## សម្លេងទី៤ (ស្រី)

ខ្ញុំចង់ដកផ្កាពីសួន ហើយឲ្យទៅកុមារ។

*ស្ត្រីម្នាក់ធ្វើកាយវិការ និង ឈ្មោះ (ឬ រូបភាពរបស់) សែនហាល់ សាហ៊ីរ៉ាន លេចមុខលើអេក្រង់។*

ចំពោះកុមារ ដែលជាប់ពន្ធនាគារនៅ ប្រទេសទួរគី [Turkey] គឺពួកគេត្រូវឃុំឃាំងរាប់ឆ្នាំ ដោយមិនមានការចោទប្រកាន់។ ឲ្យផ្កាដល់ពួកគេ។ ខ្ញុំចង់ធ្វើឲ្យពួកក្មេងៗទាំងនោះ មានអារម្មណ៍ស្និទ្ធនឹងធម្មជាតិ។ ខ្ញុំចង់ធ្វើឲ្យពួកក្មេងៗទាំងនោះ មានអារម្មណ៍មិនសូវកណ្តោចកណ្តែងពេក។

## សម្លេងទី៥ (ប្រុស)

ខ្ញុំឈ្មោះ វ៉ាន់ ចូនស៍ [Van Jones]។

*បុរសធ្វើកាយវិការ និង ឈ្មោះ (ឬរូបភាពរបស់) វ៉ាន់ ចូនស៍ លេចមុខលើអេក្រង់។*

អង្គការ របស់យើងលាតត្រដាងពី ការរំលោភសិទ្ធិមនុស្ស, ពិសេសភាពឃោរឃៅរបស់នគរបាលនៅសហរដ្ឋអាមេរិច។ មានក្មេង ដែលមកដល់ផ្ទះដោយ បាក់ដៃ ឬ បាក់ថ្គាម ឬ បាក់ធ្មេញ។ មានក្មេងដែលត្រូវគេឃុំឃាំងក្នុងគុកអស់ ៤ -៥ ថ្ងៃ ដោយមិនមានបទចោទប្រកាន់អ្វីទាំងអស់។ មានការបាញ់ជ័រប្រេងនៅលើមុខក្មេង ជាជ័រដែលបិទជាប់ស្បែកហើយរលាក ហើយបន្តរលាករហូតទាល់តែលាងសំអាតចេញ។ រឿងអស់ទាំងនេះមិនឲ្យពិភពលោកយើង មានសុវត្ថិភាពទេ។ វាមិនធ្វើឲ្យការងារពង្រឹងច្បាប់ មានភាពងាយស្រួលតទៅទៀតទេ។ អង្គការ ឃ្លាំមើលប៉ូលីស កំពុងព្យាយាមបញ្ឈប់វា។

## សម្លេងទី៧ (ប្រុស)

ខ្ញុំឈ្មោះ ប្រ៊ូស ហារីស [Bruce Harris]។

*បុរសធ្វើកាយវិការ និង ឈ្មោះ (ឬ រូបភាពរបស់) ប្រ៊ូស ហារីស លេចមុខលើអេក្រង់។*

អ្វីដែលពួកយើងបាន និងកំពុងធ្វើនៅ កាសា អាលីយ៉ង់ហ្សា [Casa Alianza] ប្រទេសហ្គាតេម៉ាឡា [Guatemala] គឺផ្តល់កុមារភាព ដល់កុមារវិញ, បើសិនជា វាមិនទាន់យឺតពេលទេនោះ។ យើងបានចាប់ផ្តើមផ្តល់អាហារ និង ទីជម្រកដល់ពួកគេ, ប៉ុន្តែ នេះមិនមែនគ្រប់គ្រាន់ហើយមិនស៊ីជម្រៅ [that was naive]។ ខ្ញុំនៅតែគិតដល់សង្ឃរាជ [priest] ម្នាក់នៅប្រទេសប្រេស៊ីល [Brazil] ដែលនិយាយថា "នៅពេលដែលខ្ញុំផ្តល់អាហារដល់អ្នកអត់ឃ្លាន គេហៅខ្ញុំថា វីរជន។ នៅពេលដែលខ្ញុំសួរថា ហេតុអ្វីបានជាមនុស្សទាំងនោះ ជាជនអត់ឃ្លាន, គេហៅខ្ញុំថា ជាជនកុម្មុយនីស្ត"។ វាជាកាតព្វកិច្ចដ៏ប្រពៃក្នុងការផ្តល់ចំណីដល់អ្នកអត់ឃ្លាន, តែក្នុងនាមជាទីភ្នាក់ងារមួយ យើងអាចសួរថា ហេតុអ្វីក៏ក្មេងស្ថិតក្នុងភាពអត់ឃ្លាន, ហេតុអ្វីពួកគេត្រូវគេបំពាន និង ត្រូវគេសម្លាប់, ហេតុអ្វីក៏ប៉ូលីសសម្លាប់ក្មេងអនាថារស់តាមចិញ្ចើមថ្នល់។ មិនយូរប៉ុន្មាន,យើងក៏ទទួលការហៅទូរស័ព្ទចូលមក និង ការគម្រាមសម្លាប់។ រហូតមានថ្ងៃមួយ... ឡានទំនើប បេអឹមដុបលយូ [BMW] គ្មានស្លាកលេខមួយ, បិទកញ្ចក់ខ្មៅជិតបើកសំដៅមក មណ្ឌលអ្នកមានវិបត្តិ នៅកូវេណាន់ ហោស [Covenant House]។ បុរសបីនាក់ ចុះពីរថយន្តសួររកឈ្មោះខ្ញុំ និង សួរថា "តើ ប្រ៊ូស ហារី នៅឬទេ? យើងមកសម្លាប់វាហើយ"។ ពួកគេបាញ់រះដោយប្រើកាំភ្លើងស្វ័យប្រវត្តិ។ នៅពេលប៉ូលីសមកដល់, ប៉ូលីសរើសយកសំបកគ្រាប់ទៅអស់។ ពួកគេបានយកភស្តុតាងទៅអស់។ ពេលស្នាក់ការ កូវេណាន់ ហោស [Covenant House] នៅក្រុង ញ៉ូវយ៉ក [New York] ឮអំពីព្រឹត្តិការណ៍នេះ ពួកគេបានផ្ញើអាវក្រោះមកឲ្យខ្ញុំ។ អាវក្រោះនោះ មានស្លាកសរសេរថា ធានាអាចយកប្រាក់វិញបាន ប្រសិនបើវាមិនដំណើរការ!

## សម្លេងទីមួយ (ប្រុស)

ខ្ញុំជាមេធាវី។

*ស្ត្រីម្នាក់ធ្វើកាយវិការ និង ឈ្មោះ (ឬរូបភាពរបស់) សេជីន ទូរីគូលូ លេចមុខលើអេក្រង់។*

នៅពេលខ្ញុំនៅក្នុងតុលាការនៃ ប្រទេសទួរគី [Turkey] នេះ, ខ្ញុំសម្លឹងមើលចំភ្នែកមនុស្សដែលខ្ញុំកំពុងចោទប្រកាន់ អំពីអំពើទារុណកម្ម, ហើយ

ពេល ដែលពួកគេសម្លឹងមើលខ្ញុំ ខ្ញុំមិនងាកមុខចេញ, ហើយពេលដែលពួកគេសម្លឹងមើលខ្ញុំ ខ្ញុំមិនងាកមុខចេញ ខ្ញុំមានអារម្មណ៍ថា ខ្ញុំមានក្តីក្លាហានជាងពួកគេ។ តាមពិត ពួកគេតាមដានខ្ញុំរាល់ព្រឹក, តាំងពីខ្ញុំឈានជើងចេញពីផ្ទះម្ល៉េះ។ យើងមិនអាចធ្វើអ្វីបានទេ មានតែរករឿងកំប្លែងក្នុងស្ថានការណ៍បែបនេះ។ ភាគច្រើន ពេលមនុស្សត្រូវបានសម្លាប់ គឺពួកគេត្រូវទទួលរងឃាតកម្ម ដោយគេបាញ់គ្រាប់ចំពីក្រោយ។ នៅអង្គការសិទ្ធិមនុស្សពួកយើង, យើងនិយាយកំប្លែងលេង អំពីវិធីដាក់កញ្ចក់ឆ្លុះលើស្មា, ដូច្នេះ យើងអាចមើលឃើញអ្នកណាតាមយើង! អញ្ចឹងយើងអាចមើលអ្នកណាតាមពីក្រោយយើងស្ទាត់ៗ និង ប៉ុនប៉ង់សម្លាប់យើង។

## សម្លេងទី៦ (ស្រី)

រាល់ពេលដែលខ្ញុំមានអារម្មណ៍ភ័យខ្លាច, ខ្ញុំអញ្ជើញមិត្តភក្តិទាំងអស់, សកម្មជនដទៃទៀត មកជួបជុំគ្នា, ហើយយើងនិយាយសើចលេង។ ការផ្ទុះសំណើច និង ភាពកក់ក្តៅរបស់មនុស្សជុំវិញខ្លួន ធ្វើឲ្យខ្ញុំអាចរស់រានបាន។ បើសិនខ្ញុំអង្គុយតែឯង ខ្ញុំក្លាយទៅជាឆ្កួតបាត់ទៅហើយ។

## សម្លេងទី២ (ស្រី)

ពេលមនុស្សម្នាក់មកជួបអ្នក ហើយនិយាយថា “ខ្ញុំប្រហែលជាបានស្លាប់បាត់ទៅហើយ... ខ្ញុំប្រហែលជាស្លាប់ហើយ បើសិន មិនមានអ្នកនៅទីនេះទេ”, នោះជាការផ្តល់ ថាមពចិត្ត ថែមទៀតដល់យើង។ ខ្ញុំឈ្មោះ ពុង ឈីវហ្គេច [Kek Galabru] ហើយខ្ញុំបដិសេធមិនចេញពីប្រទេសកម្ពុជា”។

## សម្លេងទី៨ (ស្រី) (ពីទីងងឹត)

ខ្ញុំឈ្មោះ --

*ផ្អាក*

*បុរសម្នាក់ធ្វើកាយវិការ តែគ្មានអ្វីលេចចេញលើអេក្រង់ទេ ។*

ឈ្មោះរបស់ខ្ញុំ គឺ --

*ស្រីធ្វើកាយវិការម្តងទៀត ហើយនៅតែគ្មានអ្វីមួយលេចចេញមកទៀត។ ទាំងពីរនាក់ធ្វើកាយវិការបន្តតែ នៅមិនមានអ្វីលេចចេញមកសោះ។ អ្នកសម្តែងដទៃទៀតនាំគ្នាសើចឡើង។ សម្លេងទី៨ បន្តនិយាយចេញពីទីងងឹត។ ពន្លឺចាប់ផ្តើមថយចុះនៅលើបុរស និង ស្ត្រីនោះ។*

ខ្ញុំមិនអាចបង្ហើបប្រាប់ឈ្មោះខ្ញុំបានទេ។ ខ្ញុំមកពី ប្រទេសស៊ូដង់ [Sudan]។ ឪពុកម្តាយខ្ញុំ តែងណែនាំដល់យើងកាលពីនៅក្មេង ពីរបៀបស្រលាញ់មនុស្ស ទោះបីជាគេសាមញ្ញ, ទោះបីជាគេក្រីក្រយ៉ាងណាក្តី។ ផ្ទះខ្ញុំតែងតែមមារញឹកជានិច្ចរាល់ពេល មានមនុស្សឈឺមកព្យាបាល ឬ ឆ្លងទន្លេ។ ខ្ញុំរៀនចាត់ទុកជនជាតិស៊ូដង់ទាំងអស់ ជាគ្រួសារតែមួយ, ប៉ុន្តែខ្ញុំមិនអាចប្រាប់ឈ្មោះខ្ញុំបានទេ។ អ្នកទាំងឡាយ ដែលត្រូវរដ្ឋាភិបាលសង្ស័យថា ធ្វើការទាក់ទងនឹងសិទ្ធិមនុស្ស, ត្រូវចាប់ខ្លួន ហើយរមែងត្រូវធ្វើទារុណកម្មនៅផ្ទះខ្មោច, ឬ ប្រសិនបើ មានសំណាងល្អត្រឹមជាប់គុក។ បើខ្ញុំប្រាប់ឈ្មោះខ្ញុំ, ខ្ញុំមិនអាចធ្វើការខ្ញុំទេ។

## សម្លេងទី៥ (ប្រុស)

បើនាងបញ្ចេញឈ្មោះរបស់នាង គាត់លែងអាចធ្វើការកើតទៀតហើយ។ ពន្លឺបាត់អស់ពី ខ្លួនបុរសនិងស្ត្រី។

## សម្លេងទី៤ (ស្រី)

ខ្ញុំឈ្មោះ រីហ្គូប៊ែតា ម៉េនជូ [Rigoberta Menchu]។
អ្នកសម្តែងម្នាក់ធ្វើកាយវិការ និង ឈ្មោះ (ឬ រូបរបស់) រីហ្គូប៊ែតា ម៉េនជូ លេចមុខតាមអេក្រង់។

## សម្លេងទី៤ (ស្រី)

យើងត្រូវតែបង្កើតនូវក្តីសង្ឃឹម នៅគ្រប់ទិសទីឡើងវិញ។ យើងជាអ្នកដែលមានពាក្យនិយាយជាចុងក្រោយ, ហើយជាអ្នក នឹងមានពាក្យនិយាយចុងក្រោយ។

## សម្លេងទី២ (ស្ត្រី)

នៅសហរដ្ឋអាមេរិក យើងមានទ្រព្យធនជាច្រើនរហូតមិនដឹងថា ត្រូវយកទៅធ្វើអ្វីខ្លះទៀតផង, ប៉ុន្តែ យើងបានទុកឲ្យក្មេងរាប់លាននាក់រស់ក្នុងភាពអត់ឃ្លាន, គ្មានជម្រកជ្រក និង សម្ភារៈជាមូលដ្ឋានដទៃទៀតសម្រាប់រស់។ នៅក្នុងប្រជាជាតិមួយ ដែលមានសេដ្ឋកិច្ចដល់ទៅ ៩,000,000 លានដុល្លារ, បែរជាភាពក្រីក្រ កំពុងសម្លាប់ក្មេងៗយ៉ាងឃឹត ដូចអាវុធទៅវិញ។ ខ្ញុំច្បាស់ក្នុងចិត្តណាស់ថា បើយើងមិនសង្គ្រោះកុមារយើងទេ នោះយើងក៏នឹងមិនអាចសង្គ្រោះខ្លួនយើងបានដែរ។

*អ្នកសម្តែងមួយរូប ធ្វើកាយវិការ និង ឈ្មោះ (ឬ រូបភាព) ម៉ារៀន រ៉ាយ អេដែមមេន លេចមុខលើអេក្រង់។*

មនុស្សគ្រប់គ្នា ត្រូវបើកស្រោមកញ្ចប់ព្រលឹងរបស់ខ្លួន និង ទទួលយកការបញ្ជាពីខាងក្នុង។ គ្មាននរណាម្នាក់ ធ្លាប់និយាយថា ងាយស្រួលនោះទេ។ មិនចាំបាច់មើលកាំជណ្តើរទាំងអស់មុននឹងសម្រេចចិត្តបោះជំហានលើកាំទីមួយនោះទេ។ បើអ្នកមិនអាចរត់ទេ, អ្នកត្រូវដើរ។ បើដើរមិនបាន, ត្រូវលូន។ បើលូនមិនបាន ត្រូវតែកម្រើក។ បន្តការកម្រើកទៀត, ម៉ារៀន រ៉ាយ អ៊ីដែលមេន, ត្រូវបន្តការកម្រើកទៀត។

### សម្លេងទី៦ (ស្រី)
ខ្ញុំឈ្មោះ ហេឡែន ព្រីជិន [Helen Prejean]។

*អ្នកសម្តែងម្នាក់ធ្វើកាយវិការ និង ឈ្មោះ (ឬ រូបភាពរបស់) ហេឡែន ព្រីជិន លេចមុខលើអេក្រង់។*

នៅពេលដែលខ្ញុំចេញពី បន្ទប់ពិឃាតមនុស្ស ជាមួយ ប៉ាទ្រិច [Patrick] ជាលើកទីមួយ, ខ្ញុំបានឃើញបុរសម្នាក់ត្រូវគេសម្លាប់។ ខ្ញុំច្បាស់, ខ្ញុំច្បាស់ក្នុងចិត្ត។ អ្នកនឹងត្រូវស្ទះដោយសារអ្វីមួយ ឬ អ្នកត្រូវធ្វើអ្វីពីចិត្តថ្លើមមួយ។ អ្នកត្រូវធ្វើអ្វីពីចិត្តថ្លើមមួយ៖ គោលការណ៍សង្គ្រោះជីវិតពីបិសាច [resurrection principle of life] គឺជំនះការស្លាប់ និង ទប់ទល់ជាមួយអំពើទុរយស។ ប៉ាទ្រិច [Patrick] គាត់ស្លាប់បាត់ទៅហើយ តែខ្ញុំគ្មានជម្រើសទេ។ ខ្ញុំនឹងនាំមនុស្សទៅកាន់ទីនោះ តាមរយៈរឿងដែលខ្ញុំតែង។ យើងមិនដឹងថា ត្រូវធ្វើអ្វីនោះទេ, ដូចនេះហើយ យើងធ្វើត្រាប់តាមចារឹកអាក្រក់ជួរជាតិរបស់ជនឧក្រិដ្ឋ ដោយទោសប្រហារជីវិត, ដែលការសម្តែងពីភាពអស់សង្ឃឹមជាទីបំផុត។ ប៉ុន្តែ ខ្ញុំជឿថា បើយើងលើកទឹកចិត្តមនុស្សឲ្យធ្វើតាមបេះដូងល្អរបស់គេ, មនុស្សនឹងប្រតិកម្មតាមជាមិនខាន។

### សម្លេងទី៧ (បុរស)
ខ្ញុំឈ្មោះ ប៊ីសហ្សិប វីសសា [Bishop Wissa]។ គ្រូគង្វាល វីសសា, មកពី ប្រទេសអេហ្ស៊ីប។

*អ្នកដើរតួម្នាក់ធ្វើកាយវិការ និង ឈ្មោះ (ឬ រូបភាពរបស់) គ្រូគង្វាល វីសសា លេចមុខលើអេក្រង់។*

អ្នកទាំងនេះជាកូនខ្ញុំ។ ពួកគេមិនហៅឈ្មោះខ្ញុំជាឪពុកទេឬ? បើអ្នកនៅផ្ទះ ហើយមានមនុស្សមកវាយកូនរបស់អ្នក តើអ្នកឃាត់ទេ? ឃាត់ទេ? បើមិនឃាត់ទេ អ្នកណាគេឃាត់ជួស?

### សម្លេងទី១ (បុរស)
ខ្ញុំឈ្មោះ សាមុយអែល កូហ្វី វូត [Samuel Kofi Woods]។ ខ្ញុំមកពីប្រទេសលីបេរីយ៉ា [Liberia]។

*អ្នកសម្តែងម្នាក់ធ្វើកាយវិការ និង ឈ្មោះ (ឬ រូបភាពរបស់) សាមុយអែល កូហ្វីវូត លេចមុខតាមអេក្រង់។*

អ្នកកំពុងដើរចូលច្រកមរណៈ ហើយអ្នកដឹងថាវាអាចជាគ្រាចុងក្រោយបំផុត នៃជីវិតរបស់អ្នក។ ខ្ញុំបានឆ្លងកាត់រួចហើយ។ ប៉ុន្តែ នៅពេលដែលប្រទេសមួយ ពោរពេញដោយភាពទុរយសនោះ, វាពិតជាពិបាកនឹងមានជម្រើសផ្សេងទៀតណាស់, លុះត្រាតែមនុស្សដែលមានជំនឿមុតមាំក្រោកឡើងព្រមគ្នា តែប៉ុណ្ណោះ។ សូម្បីតែដឹងថា នេះជាគ្រាចុងក្រោយនៃជីវិតក៏ដោយក្តី។ បើយើងមិនធ្វើរឿងនេះទេ តើអ្នកណាគេនឹងធ្វើ?

### សម្លេងទី៣ (បុរស)
បើខ្ញុំបែរខ្នង ហើយដើរចេញ, តើអ្នកណាគេនឹងធ្វើការងារនេះ? បើយើងមិនធ្វើរឿងនេះទេ តើអ្នកណាគេនឹងធ្វើ?

### សម្លេងទី៦ (ស្រី)
គឺសេចក្តីក្លាហាន? ខ្ញុំអាចនិយាយបានថា វាត្រូវការភាពមានៈ។ ដូចខ្សែពួរដែក នៅពីខាងក្នុងខ្លួនអញ្ចឹង។

### សម្លេងទី១ (បុរស)
សេចក្តីក្លាហានផ្តើមចេញពីសម្លេងមួយ។
បើយើងមិនធ្វើរឿងនេះទេ តើអ្នកណាគេនឹងធ្វើ?

*ផ្អាកវែងបន្តិច*

### សម្លេងទី៨ (ចេញពីទីងងឹត)
បើយើងមិនធ្វើរឿងនេះទេ តើអ្នកណាគេនឹងធ្វើ?

*សម្លេងទី៨ (ចេញពីទីងងឹត)*

### សម្លេងទី៨ (ស្រី)
បើយើងមិនធ្វើរឿងនេះទេ តើអ្នកណាគេនឹងធ្វើ?

### ស្រ្តី (ចំអក)
បើយើងមិនធ្វើរឿងនេះទេ តើអ្នកណាគេនឹងធ្វើ?

### បុរស (MAN)
ត្រូវហើយ។ ឈ្មោះទាំងអស់នេះ។ ចូសេ រ៉ាម៉ូសហ័រតា [Jose Ramos Horta] មកពី ប្រទេសទីម័រខាងកើត [East Timor] និង រង្វាន់ណូបែលសន្តិភាព [Nobel Peace Prize] អត់បានការរបស់វានោះ, និង ព្រះសង្ឃដាឡៃឡាម៉ា[DalaiLama],និងចៅក្រមមកពីប្រទេសអេស្ប៉ាញស្អីនោះ, ឈ្មោះ បាល់តាសា ហ្គាហ្សុន [Baltasar Garzon], និង ហ្វ្រីដូម ណេរូដា [Freedom Neruda], អ្នកកាសែតស្អីនោះ មកពីប្រទេសកូដឌីវ័រ [Ivory Coast], មិនដឹងកន្លែងអីគេនោះទេ, ហើយ ម៉ារៀ តេរេសា ទូឡា [Maria Teresa Tula]...

### ស្រ្តី (WOMAN)
ម៉ារៀ តេរេសា ទូឡា មកពីប្រទេស អែលសាល់វ៉ាឌ័រ [El Salvador]

នោះត្រូវចាប់ខ្លួនជាច្រើនលើក ច្រើនសារ ហើយត្រូវគេគម្រាមច្រើនដងហើយ, ហើយនៅតែមិនឈប់ទៀត, វានៅតែមិនព្រមឈប់តាមរកអ្នកបាត់ខ្លួនសោះ។

### បុរស (MAN)

វានៅតែមិនព្រមឈប់...

### ស្ត្រី (WOMAN)

...ហើយ ណាតាសា កាន់ឌីក [Natasa Kandic] មហាសែនរំខានមកពីប្រទេស ស៊ែប៊ី [Serbia] និង ជេមី ព្រីអេតូ [Jaime Prieto] ដ៏មហាបង្កបញ្ហាមិនចេះហត់ មកពីប្រទេស កូឡុំប៊ី [Colombia], ហើយនឹង វ៉ាក្លាវ ហាវ៉ែល [Vaclav Havel] ព្រមទាំង ... ឈ្មោះទាំងអស់នោះ។ ឈ្មោះទាំងអស់ហ្នឹង អញនឹងមិនភ្លេចទេ។ អញមិនភ្លេចដាច់ខាត។

### បុរស

ឈ្មោះដែលយើងមិនបំភ្លេចបាននោះ។ អ្នកដទៃនឹងភ្លេច។

### ស្ត្រី

អ្នកដទៃទៀតនឹងភ្លេចឈ្មោះទាំងនោះ។ ឈ្មោះទាំងនោះ បានសាបរលាបពីការចងចាំទៅហើយ។ ថ្វីបើនៅទីបំផុត មានជោគជ័យធំធេង, ប្រឈមធំធេងក៏ដោយ។បើពួកយើងមិនធ្វើបែបនេះតើមានអាណាគេនឹងធ្វើ? ឥឡូវពន្លឺបានចាំងចំលើពួកគេ ហើយមានមនុស្សប្រមុងនឹងទះដៃសាទរពួកគេ, មកចោមរោមពួកគេ និង លួងលោមពួកគេ, ពន្លឺដែលចាប់ផ្ដើមខ្សោយទៅៗនោះ រលត់ម្ដងមួយៗ, នៅពេលដែលមនុស្ស ទះដៃសាទរនោះ ត្រលប់ទៅផ្ទះវិញ, អ្នកចោមរោមទាំងនោះ ត្រលប់ទៅផ្ទះវិញបើកទូរទស្សន៍មើល ហើយមុខមាត់មកពីឆ្ងាយ, ប្រហែលជាមុខពួកមនុស្សគេបានទះដៃសាទរនោះ, ផ្ទុះឡើងក្នុងភាពឈឺចាប់ ហើយបន្ទាប់មករលត់បាត់ទៅ ...

### បុរស

... ហើយ ដល់ពេលបាយល្ងាចហើយ, ហើយដល់ពេលដេកទៀតហើយ, ហើយនៅថ្ងៃស្អែក អ្វីនឹងត្រលប់ទៅកន្លែងដើមវិញ, ទីបំផុត គឺពួកវា និង ពួកយើងដដែល...

### ស្ត្រី

ពួកវា និង ពួកយើងដដែល, ពួកវា និង អញ, ហើយ ពួកវា ជាមួយ និង អញ ម្ដងហើយ ម្ដងទៀត។ ក៏ត្រូវដឹងថា នៅទីនោះ, នៅឆ្ងាយពីយើង, ឆ្ងាយពីពន្លឺដ៏ស្រអាប់នោះ គឺមានអ្នកផ្សេង,អ្នកដែលមិនដែលមានត្រូវគេចាប់អារម្មណ៍, អ្នកដែលសូម្បីតែខ្ញុំក៏មិនស្គាល់ឈ្មោះផង, អ្នកដទៃទៀតដែលនៅឆ្ងាយពីពន្លឺទាំងនេះ, សម្លេងពួកគេមិនដែលត្រូវបានថតទុក ឬ សរសេរទុក, ហើយរាងកាយពួកគេ យើងមិនមើលឃើញផង។

### បុរស

ពួកវា ជាមួយ និង អញ ម្ដងហើយម្ដងទៀត, ចែករំលែកជាមួយគ្នានៅក្នុងយប់ជ្រៅងងឹត។ ចែករំលែកជាមួយគ្នាចំណេះដឹងមួយផ្នែកតូចនេះ។ ជីវិតជាកម្មសិទ្ធរបស់អ្នក តែម្ដងប៉ុណ្ណោះ។ អញកំពុងរង់ចាំនៅទីនេះជាមួយនឹងការយល់ដឹងនេះ។ អញក៏ចេះរង់ចាំយ៉ាងដូចម្ដេចដែរ។

### ស្ត្រី

អញក៏ចេះរង់ចាំយ៉ាងដូចម្ដេចដែរ។ អញក៏ដឹងថា ការរង់ចាំក្នុងទីងងឹតមានសភាពដូចម្ដេច។ វេន របស់អញ តែងតែមកដល់ជានិច្ច។

*នៅពេលអ្នកការពារសិទ្ធិនិយាយជាលើកចុងក្រោយ ពន្លឺចាប់ខ្សោយៗ លើខ្លួនបុរស និង ស្ត្រី ។*

### សម្លេងទី១ (ប្រុស)

ខ្ញុំមិនក្លែងខ្លួន ធ្វើជាវីរជនអីទេ
ដើមដំបូង ខ្ញុំគ្មានទាំងប៊ិច, គ្មានទាំងក្រដាសសរសេរ សម្រាប់ធ្វើកិច្ចការផង

### សម្លេងទី៨ (ស្រី)

ប៉ុន្តែ យើងមិនរស់ក្នុងភាពភ័យខ្លាចទេ
ឆាប់ស្លាប់ទៅ វាល្អជាង បើវារស់របៀបនេះ
អ្វីផ្សេងទៀតនឹងមានរសជាតិដូចផេះផង់អញ្ចឹង
នោះហើយ ជាអ្វីដែលយើងដឹង

### សម្លេងទី៧ (ប្រុស)

មានអ្វីមួយនៅទីនោះ
មានពន្លឺមួយហើយ
ខ្ញុំបានធ្វើនូវអ្វី ដែលខ្ញុំត្រូវធ្វើ
ដោយដឹងថា ដោយដឹងថា
អ្នកក្រីក្រក្នុងលោកយើងនេះ កំពុងស្រែកដង្ហោយហៅ

### សម្លេងទី៦ (ស្រី)

នោះជាអ្វី ដែលអ្នកដឹង
អ្វីផ្សេងទៀតនឹងមានរសជាតិដូចផេះផង់អញ្ចឹង
នោះជាអ្វី ដែលអ្នកដឹង
អ្នកក្រីក្រក្នុងលោកយើងនេះ កំពុងស្រែកដង្ហោយហៅ
ទាមទារសាលារៀន និង គ្រូពេទ្យ,មិនមែន ទាមទារចង់បានឧត្តមសេនីយ៍ និង កាំភ្លើងទេ

## សម្លេងទី៥ (ប្រុស)

ខ្ញុំ មិនដែលឯកោទេ
នោះជាអ្វី ដែលអ្នកដឹង
យើងបានធ្វើ នូវអ្វីដែលយើងត្រូវធ្វើ, ប៉ុណ្ណឹងឯង

## សម្លេងទី៤ (ស្រី)

តើវាទាមទារសេចក្ដីក្លាហានទេ?
វាទាមទារភាពមាន:
ភាពមាន:
ដូចខ្សែពួរដែកនៅពីខាងក្នុងខ្លួនអញ្ចឹង
អារម្មណ៍ នៃកម្លាំងក្នុងចិត្ត ដូចខ្សែពួរដែកនៅពីខាងក្នុងខ្លួនអញ្ចឹង
អ្វីផ្សេងទៀតនឹងមានរសជាតិដូចផេះផង់អញ្ចឹង
ដោយដឹងថា ដោយដឹងថា
យើងជំពាក់អ្វីមួយ ដល់អ្នកដែលមិនមានគេអើពើ

## សម្លេងទី៣ (ប្រុស)

ព្រះជាម្ចាស់បបោសយើងឲ្យស្អាត ហើយមានបន្ទូលថា "ចូរព្យាយាមម្ដងទៀត"
ព្រះអង្គមានបន្ទូលថា "ចូរព្យាយាមម្ដងទៀត"។ ព្រះអង្គមានបន្ទូលថា ជីវិត ជាកម្មសិទ្ធិរបស់អ្នក តែម្ដងគត់។ អញ្ចឹងហើយ យើងបន្ត ដោយដឹងថា បើយើងលើកទឹកចិត្តមនុស្សឲ្យធ្វើតាមបេះដូងល្អរបស់គេ មនុស្សនឹងមានប្រតិកម្មឆ្លើយតបនោះជាអ្វីដែលអ្នកដឹងថាយើងមិនមែនឯកោទេ

## សម្លេងទី២ (ស្រី)

អញ្ចឹងយើងបន្ត
រង់ចាំ, រង់ចាំ,
រង់ចាំនៅក្នុងទីងងឹតដើម្បីរកការពិត
យើងពិតជាមិនមែននៅឯកោនោះទេ

## សម្លេងទី១ (ប្រុស)

ខ្ញុំមិនចង់ក្លែងខ្លួន ធ្វើជាវីរជនអីទេ
ខ្ញុំបានធ្វើ នូវអ្វីដែលខ្ញុំត្រូវធ្វើ, ប៉ុណ្ណឹងឯង
វាសាមញ្ញបំផុត
នោះជាអ្វីដែលអ្នកដឹង
ការងារនេះ ទើបតែបានចាប់ផ្ដើមទេ

## សម្លេងទី២ (ស្រី)

នោះជាអ្វីដែលអ្នកដឹង
យើងបានធ្វើ នូវអ្វីដែលយើងត្រូវធ្វើ
ការងារនេះ ទើបតែបានចាប់ផ្ដើមទេ។

*ពន្លឺចាំងបន្ថែមខ្លាំងទៅលើអ្នកសម្ដែង ទាំងប្រាំបីនាក់ជាលើកចុងក្រោយ ខណៈពេលដែលចាប់ខ្សោយទៅៗទៅលើ បុរស និង ស្ត្រីនោះ។*




The Phnom Penh Players សម្ដែងនៅសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា ខែកុម្ភៈ ឆ្នាំ២០១១

# A MESSAGE FROM THE PLAYWRIGHT

It has not been easy for these voices to reach us. First, they had to overcome fear. There is always fear at the beginning of every voyage, fear and its malignant twin, violence, at the beginning of every voyage into courage.

The bodies that housed these voices either suffered that violence personally or they witnessed that violence being visited upon another human being, a group, a nation. Some saw a father or a son or a wife abducted in the night and taken away. Others saw children made into warriors and forced to kill at an early age. Each one of them saw something intolerable: a man killed because of the color of his skin or the color of his opinions, people taken into airless chambers and executed in cold blood, soldiers turning their guns against the people, women hated because of their sexual choices. They saw ancestral lands being stolen from their owners, forests devastated, languages forbidden. They saw books censored, friends subjected to torture, youngsters made into slaves. They saw lawyers jailed and exiled because they defended the victims.

And then something happened. Something extraordinary and almost miraculous. They found a way of speaking out, decided that they could not live with themselves if they did nothing, they could not stain their lives by remaining silent. And as they spoke out, they discovered that not the violence, but the fear, slowly disappeared. When they spoke out and found others on the road with them, other voices, from near and far, they began to find ways of controlling that fear instead of letting the fear control them.

I had been preparing all my life for the chance to become a bridge for them. Ever since I was a child and was moved by the injustices I saw around me, and then as an adolescent as I realized that those outrages existed in far more grievous forms beyond my immediate horizon. Then as a young man when it was my turn to see a dictatorship take over my country, Chile, and watch my friends persecuted and murdered while I was spared, when it became my turn to go into exile and wander the globe and everywhere remark the same inequities mirrored in land after land, when it became my turn to try and figure out how I could write stories and find the words that explored the vast heart of human suffering and the vaster complexity and enigmas of evil, ever since then I had been waiting for the occasion to put my art yet one more time at the service of those who had kept me warm in the midst of my own struggles.

And I have been fortunate enough to have received those voices like you receive a blessing in the dark and to have given them a dramatic form. It took me my whole life to find a voice of my own to accompany these voices.
Take the voices home with you, carry them into the world. It is a world that needs changing. Knowing this, knowing this: the world does not have to forever be the way it is now.




*ARIEL DORFMAN, the Chilean-American writer and human rights activist, is a distinguished professor at Duke University and has written books in Spanish and English that have been translated into more than 40 languages. His plays have been staged in over 100 countries and have received numerous awards, including the Laurence Olivier Award (for "Death and the Maiden," which was made into a feature film by Roman Polanski). His latest novel is Americanos: Los pasos de Murietta, and Houghton Mifflin will bring out the second volume of his memoirs in 2011. In July 2010 he had the honor of delivering the Nelson Mandela Lecture in South Africa.*

## ABOUT THIS PLAY

Speak Truth To Power: Voices From Beyond the Dark is a play for ten actors (preferably five male and five female, though can also be cast, if necessary, with four female and six male actors). Eight of these actors, four male, four female, will represent the human rights defenders. The other two (a man and a woman, or two men) represent evangelists of evil, malicious and sarcastic embodiments of fear and repression first and then, as the play advances, of the indifference which is the perpetual opposite of love. These oppressors should be dressed differently, lit differently, act differently, and speak differently from the human rights defenders. They are supposed to have more mobility, should be allowed to roam the stage at will, whispering, probing, threatening, determined to undermine the message from the heroes and heroines. This differentiation is crucial to the drama of the play.

*LIGHTS RISE ON THE EIGHT ACTORS, FOUR MEN, FOUR WOMEN, GROUPED SYMMETRICALLY.*

FIRST VOICE (MALE)

Courage begins with one voice.
It's that simple.
I did what I had to do.
That is what we know.
You walk into the corridor of death and you know.

*LIGHTS RISE ON THE MAN AND WOMAN, TO ONE SIDE, SEPARATE FROM THE DEFENDERS.*

MAN

They know. They can't say they don't know.

WOMAN

They can't say they don't walk into this with their eyes open.

FIRST VOICE (MALE)

You walk into the corridor of death and you know. You know this moment might be your last.

SECOND VOICE (FEMALE)

You walk into the corridor of death…

FIRST VOICE (MALE)

…and you know, you know this moment might be your last.

SECOND VOICE (FEMALE)

That is what you know.

FOURTH VOICE (FEMALE)

I know what it is to wait in the dark for torture and what it is to wait in the dark for truth. I did what I had to do. Anything else would have tasted like ashes.

WOMAN

They can't say they don't know.

THIRD VOICE (MALE)

I am told that as a child I reached out to others. I befriended pygmies, even though in my community, in the Congo, they were considered to be animals. I cut bread with them, I brought them to our house, I gave them my clothes. It was sick to society that I associated with pygmies, but I saw them as my friends, just like anyone else.

MAN

Guillaume Ngefa Atondoko.

*WOMAN MAKES A GESTURE AND THE NAME (OR IMAGE OF) GUILLAU ME NGEFA ATONDOKO APPEARS ON THE SCREEN.*

Yes. He befriended pygmies as a child. Yes. Of course.

FIFTH VOICE (MALE)

For a month, I was sentenced to death and I had great fear.

*MAN MAKES A GESTURE AND THE NAME (OR IMAGE OF) WEI JINGSHENG APPEARS ON THE SCREEN.*

Then I thought to myself, "Wei Jingsheng, you will die anyway. Why die as a laughingstock to my enemies?" So I controlled my fear in that moment of crisis, and that moment passed. If you cannot prepare yourself for death, then you should not decide to defy the regime.

THIRD VOICE (MALE)

You walk into the corridor of death…

FIRST VOICE (MALE)

My name is Hafez Abu Seada. These scars across my face are from when they pushed me through a window. They asked me who was responsible for managing everything here at the Egyptian Human Rights Organization. I told them it was me. I wrote the report, I read it, I reviewed it, and I decided to publish it in a newspaper. This is our job, to point the finger at government errors. If we don't do this, who will?

MAN

Hafez Abu Seada, yes. That is his job.

WOMAN

And he was pushed through a window. Yes.

SECOND VOICE (FEMALE)

*សេចក្តីក្លាហានគ្មានព្រំដែន៖ សម្លេងចេញពីទីងងឹត* (Speak Truth To Power: Voices from Beyond the Dark) បានសរសេរសម្រាប់សម្លេងរបស់តួអង្គ ១០នាក់ ហើយ នោះគឺជាលេខល្អវិសេស សម្រាប់ការអនុវត្តរបស់ខ្លួន។ ម្យ៉ាងវិញទៀត គេអាចបង្កើតដោយមាន អ្នកសម្តែងតួតិច ឬ ច្រើន។ ប្រសិនបើមានគ្នាតិច, យ៉ាងហោចណាស់មាន៥នាក់ (អ្នកការពារ ប្រុសពីរនាក់, អ្នកការពារ ស្រីពីរនាក់, បុរសម្នាក់ ជាអ្នកប្រឆាំង)។ វាមិនចាំបាច់ទាំងស្រុងទេ នៅក្នុងការមានសម្លេងនីមួយៗ ដែលត្រូវឆ្លើយតបទៅនឹងតម្រូវការយេនឌ័រ នៃអ្នកការពារសិទ្ធិមនុស្សដើមដំបូង។ នៅក្នុងព្រឹត្តិការណ៍មួយ អ្នកសម្តែងតួចំនួនបីនាក់ អាចធ្វើវាបាន, ប៉ុន្តែ ចង្វាក់នៃការសម្តែងតួនោះ អាចបាត់បង់ ហើយជម្រើសបែបនេះ មិនត្រូវបានគាំទ្រដោយអ្នកនិពន្ធនោះទេ។ ផ្ទុយទៅវិញ៖ ការសម្តែងតួ អាចទទួលបានការគាំទ្រច្រើន ពីការមានសម្លេង និង អ្នកចូលរួមជាច្រើននាក់, ដរាបណា អ្នកដែលមានសុន្ទរកថាដ៏វែងផងដែរ ចូលមកនិយាយថ្លែងបទកាព្យខ្លី ហើយច្រើន ដើម្បីឲ្យលំហូ និង ចង្វាក់នៃការសម្តែងតួនោះមិនត្រូវបានរំខាន។ ប្រសិនបើការសម្តែងតួនោះមានអ្នកសម្តែងតួប្រឆាំង និង ជំទាស់ទៅនឹងក្រុមអ្នកការពារតែម្នាក់, វាគួរតែជាបុរសជានិច្ច។ (ក្នុងប្រវត្តិសាស្រ្ត, បុរសធម្មតា ជាអ្នកគាបសង្កត់)។ ប៉ុន្តែ គេបានផ្តល់អនុសាសន៍ថា គួរមានតួទាំងនេះ បំពេញដោយ បុរស និង ស្រ្តី។

ការសម្តែងតួនេះ ទាមទារឲ្យមានអេក្រង់បញ្ចាំងរូប (screen) ដែលឈ្មោះ ឬ រូបថត នៃក្រុមអ្នកការពារ ត្រូវបានដាក់បង្ហាញ។ ចំណុចនេះអាចត្រូវបានដាក់ជំនួស ដោយ ក្តារខៀនព៌ណខ្មៅ, ដែលអាចសរសេរដាក់ឈ្មោះនៅពីលើនោះ,ឬក្តារធំមាំដែលអាចយកទៅដាក់លើឆាក។ អ្វីដែលតម្រូវឲ្យឈ្មោះ ត្រូវបានគេមើលឃើញ និង កត់សម្គាល់, ហើយផងដែរ បង្កើនអំណាច នៃ តួអង្គបុរស (MAN) និង តួអង្គស្រ្តី(WOMAN) (ឬ បុរសទីពីរ, SECOND MAN), ហើយក្រោយមកទៀត បង្កើនអំណាច នៃក្រុមអ្នកការពារ ក្នុងការដាក់ឈ្មោះខ្លួនពួកគេផ្ទាល់។ រឿងដែលបានរ៉ាយរ៉ាប់ដោយតួឯក គឺមានលក្ខណៈឆាប់រំជួលចិត្តជានិច្ច ដូច្នេះមិនចាំបាច់ធ្វើកាយវិការខ្លាំងពេកទេក្នុងការតាំងអារម្មណ៍ (not overly dramatic, nor melodramatic)។ ចូរឲ្យសម្លេងទាំងអស់នោះ និយាយដោយខ្លួនឯង (let those voices speak for themselves), ហួរឆ្លងកាត់តាមរាងកាយ នៃតួសម្តែងប្រុស និង តួសម្តែងស្រី តាមលក្ខណៈធម្មតា។ ម្យ៉ាងវិញទៀត សូមប្រុងប្រយ័ត្នពី "ការចេញសម្តែង" (“acting out”) រឿង។ តួសម្តែងនីមួយៗ មិនគួរក្លាយបុគ្គលនោះទេ, ប៉ុន្តែគ្រាន់តែជាបណ្តាញតាមរយៈបុគ្គលនោះ ក្នុងការផ្តល់សារដល់ទស្សនិកជន។ ដូច្នេះ ហើយ វាមិនមែនជាគំនិតយោបល់ល្អ នៅក្នុងការប៉ុនប៉ងបង្កើតការសង្កត់សម្លេង ឬ តុង (អាស៊ី, អាហ្វ្រិក, ឡាទីន, ស្លាវិច។ល។) ដើម្បីបន្ថែមអត្តសញ្ញាណទៅនឹងសម្លេងនោះទេ។

យើងបានឃើញ, នៅក្នុងការសម្តែងជាវិជ្ជាជីវៈ, ដែលថា លក្ខណៈរបស់ តួអង្គបុរស (MAN) និង តួអង្គស្រ្តី (WOMAN) ត្រូវការពន្យល់បន្ថែមខ្លះទៀត។ ពួកគេ អ្នកនិពន្ធត្រូវបានបង្កើតឡើងឲ្យមានភាពដូចជា ទេវកថា (mythical incarnation), ដូចជា អ្នកផ្សព្វផ្សាយសាសនានៃសភាវៈអាក្រក់ជាច្រើន (Evangelists of multiple evils), ដែលរំឮកយើងដោយ ពាក្យពេចន៍ និង វត្តមានរបស់ពួកគេ អំពីអ្វី ដែលអ្នកការពារត្រូវប្រឈមមុខប្រឆាំង។ ពេលចាប់ផ្តើមការសម្តែង, យើងចាត់ទុកពួកគេជាអ្នកបង្កការគ្រោះថ្នាក់, ផ្លូវកាយ, ដោយមានវត្តមានលបចាំមើលទូទៅ នៅក្នុងរដ្ឋ និង សង្គម ដែលត្រៀមខ្លួន ដើម្បីចាត់វិធានការអាក្រក់នោះ។ ប៉ុន្តែ ដោយសារតែសម្លេងទាំងនេះ បានបង្ហាញដោយខ្លួនពួកគេថា ពួកគេមិនអាចត្រូវបានបញ្ឈប់ដោយការគម្រាមកំហែងនៃប្រភេទនេះទេ (ដាក់គុក, ដាក់ទណ្ឌកម្ម និង និរទេស), តួអង្គបុរស (MAN) និង តួអង្គស្រ្តី (WOMAN) ក្លាយជាអ្នកតំណាងនៃអ្វីៗ ដែលមានលក្ខណៈអាក្រក់ និង ពាសពេញ និង ស្ថិតនៅជិតយើងទាំងអស់គ្នា, ស្ថិតនៅជិតជនដែលសម្តែងតួនេះ និង ស្ថិតនៅជិតជនដែលចូលរួមទស្សនា៖ កម្លាំង នៃការមិនអើពើ និង ថាមពលនៃភាពស្ពឹក ទាំងនេះចុងបញ្ចប់ គឺជាសត្រូវដ៏អាក្រក់បំផុត នៃការតស៊ូ ដើម្បីពិភពលោកដ៏ប្រសើរ។ ហើយ ពួកគេ បញ្ជាក់អំពីការវាយប្រហាររបស់ពួកគេមកលើសកម្មជន ដោយការចំអក និង ការវាយប្រហារបន្ទាប ច្រើនជាងការគម្រាមកំហែង។ សរុបមក, ប្រសិនបើពិភពលោកមិនអើពើ មូលហេតុអ្វីអ្នកការពារត្រូវលះបង់ជីវិតពួកគេ? ក្នុងន័យនេះ តួអង្គបុរស (MAN) និង តួអង្គស្រ្តី (WOMAN) ក្លាយទៅជា (ក្នុងន័យចម្លែកមួយ) កញ្ចក់ឆ្លុះបង្ហាញ អំពីភាពភ័យខ្លាចផ្ទៃក្នុង របស់សកម្មជនសិទ្ធិមនុស្ស, ភាពមន្ទិលសង្ស័យដែលពួកគេអាចមាននោះ ជ្រាបចូលទៅក្នុងដួងវិញ្ញាណ ខណៈដែលពួកគេកំពុងប្រឈមមុខ។

តួឯកល្អរបស់យើង មានសេចក្តីក្លាហានក្នុងការប្រឈមនឹងការស្លាប់។ ជាសំណួរ៖ តើពួកគេមាន កម្លាំងតស៊ូយូរអង្វែង (stamina) និងសាមគ្គីភាពនៅក្នុងចំណោមពួកគេ នៅក្នុងការប្រឈមនឹងវិនាសកម្មដ៏ធ្ងន់ធ្ងរនៃការមិនអើពើនោះទេ? ជនដែលមានអំណាចនិយាយតែ

មាត់ទទេចំពោះសិទ្ធិមនុស្ស, ប៉ុន្តែ នៅពេលដែលយើងត្រូវការអ្វីៗមានច្រើនជាងពាក្យសម្ដី, ការធុញថប់អារម្មណ៍ខាងទ្រឹស្ដីអំពីសភាពសោកស្ដាយ នៃពិភពលោកជាញឹកញាប់បំផុតនោះ មិនអាចប្រែក្លាយទៅជាសកម្មភាពពិតប្រាកដនោះទេ។

ដូច្នេះ ផលិតកម្មសម្ដែងនាដកម្មនេះ សួរជាសំណួរថា៖ ប្រសិនបើបុរស និង ស្ត្រី ដែលប្រឈមមុខនឹងសេចក្ដីស្លាប់រាងកាយ ក្នុងគោលបំណងជួយជ្រោមជ្រែងបុព្វហេតុរបស់ពួកគេ ត្រូវមានសេចក្ដីក្លាហានក្នុងការប្រឈមមុខនឹងសេចក្ដីស្លាប់លាក់លៀមច្រើនបំផុត នៅក្នុងដួងព្រលឹងរបស់មនុស្ស ដែលធ្វើឲ្យយើងស្ពឹក ចំពោះសេចក្ដីទុក្ខវេទនារបស់អ្នកដទៃនោះ? ហើយ ផលិតកម្មសម្ដែងនាដកម្មនេះ មិនបានផ្ដល់ចម្លើយងាយស្រួលចំពោះបញ្ហានេះទេ, ប៉ុន្តែ លាតត្រដាងជម្លោះនេះនៅលើឆាក, ដោយបង្វែរសំណួរនោះទៅឲ្យទស្សនិកជនវិញ, ដោយតួអង្គបុរស (MAN) និង តួអង្គស្ត្រី (WOMAN) ដែលបង្ហាញខ្លួនក្នុងភាពម៉ឺងម៉ាត់ហ្មត់ចត់មួយ, ជ្រាបដោយសម្ដីមានភាពសុបិនអាក្រក់ និងដោយសម្ដីមានភាពធម្មតា ដែលស្របគ្នាជាមួយចង្វាក់បទកាព្យនេះ, នៃផ្នែកនីមួយៗ គឺជាចង្វាក់របស់ផលិតកម្មសម្ដែងនាដកម្មនេះ។

តួអង្គបុរស (MAN) និង តួអង្គស្ត្រី (WOMAN) អាចសម្ដែងដោយមានកាយវិការដ៏សកម្ម។ ពួកគេ អាចបញ្ជា អ្នកថតភាពយន្ត, អ្នកកាន់កាមេរ៉ា, ផ្លាស់ប្ដូរមនុស្ស, ផ្លាស់ប្ដូររូបថត (ប្រសិនបើមាន) ។ល។ ឧទាហរណ៍ ចូរឲ្យតួអង្គបុរស (MAN) និង តួអង្គស្ត្រី (WOMAN) ដើរពាសពេញលើចន្លោះឆាក, ខណៈដែលជនរងគ្រោះនៅនឹងមួយកន្លែង ដើម្បីពេលពួកគេរង “ការបរាជ័យ” បណ្ដោះអាសន្ន តាមរយៈកំប្លែងស្ងួត និង តាមរយៈសាមគ្គីភាព, ចំណុចនេះ នឹងធ្វើឲ្យមានរូបរាងកើតឡើងដោយស្មើភាពច្បាស់នឹងភ្នែក (visual equivalent)។ ប៉ុន្តែ តួអង្គប្រឆាំងនេះ (តួអង្គបុរស, តួអង្គស្ត្រី) មិនអាចបណ្ដេញចេញពីសុបិនរបស់យើង ទាល់តែយើងឃាំងតួអង្គបុរស និង តួអង្គស្ត្រីបែបនេះ ពីជីវិតយើង, តាមរយៈការងារដើម្បីយុត្តិធម៌ ក្នុងពិភពលោកជាក់ស្ដែងពីមួយថ្ងៃទៅមួយថ្ងៃ នៅជុំវិញយើង ជិតនិងឆ្ងាយ, ជាពិភពលោកដែលអាចប្រមូលផ្ដុំ គេ និង យើង, អ្នកនេះ អ្នកនោះ, ប្រមូលផ្ដុំទាំងអស់គ្នា ដែលរស់នៅក្នុងផែនដីនេះ។

# សម្រង់ពីលិខិតុបករណ៍អន្តរជាតិសិទ្ធិមនុស្ស

## Excerpts from International Human Rights Instruments

### កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ

(International Covenant on Civil and Political Rights)

កម្ពុជា, ចុះហត្ថលេខា នៅខែតុលា ឆ្នាំ១៩៨០, ឧបាគមន៍ (ការបានជាកម្មសិទ្ធិនូវវត្ថុរណប) ខែឧសភា ឆ្នាំ១៩៩២

#### មាត្រា ៧

គ្មានជនណាម្នាក់ត្រូវរងទារុណកម្ម ឬ ប្រព្រឹត្តកម្ម ឬ ទណ្ឌកម្ម ដែលឃោរឃៅអមនុស្សធម៌ ឬ ធ្វើឲ្យថោកទាបឡើយ។ ជាពិសេស ហាមយកជនណាម្នាក់មកធ្វើការពិសោធន៍ខាងវេជ្ជសាស្ត្រ ឬ វិទ្យាសាស្ត្រ ដោយគ្មានការយល់ព្រមដោយសេរីពីសាមីខ្លួនឡើយ។

#### មាត្រា ៨

១. គ្មានជនណាម្នាក់ ត្រូវជាប់ក្នុងទាសភាពឡើយ។ ទាសភាព និង ទាសពាណិជ្ជកម្មតាមគ្រប់ទម្រង់ទាំងអស់ត្រូវហាមឃាត់។

២. គ្មានជនណាម្នាក់ ត្រូវជាប់ក្នុងភាពជាខ្ញុំបម្រើដាច់ថ្លៃឡើយ។

៣. (ក) គ្មានជនណាម្នាក់តម្រូវឲ្យធ្វើការដោយបង្ខំ ឬ ខានមិនបានឡើយ។

(ខ) កថាខណ្ឌ ៣(ក) មិនត្រូវយកមកបកស្រាយថា ហាមឃាត់ការអនុវត្តទោសឲ្យធ្វើការដោយបង្ខំ ស្របតាមការវិនិច្ឆ័យទោសដោយ តុលាការមានសមត្ថកិច្ចក្នុងប្រទេស ដែលបទឧក្រិដ្ឋខ្លះអាចមានទោសជាប់គុកឲ្យធ្វើការដោយបង្ខំ។

(គ) បំណងនៃកថាខណ្ឌនេះ ពាក្យថា “ការងារដោយបង្ខំ ឬ ដោយខានមិនបាន” មិនត្រូវរាប់បញ្ចូលៈ

(i) ការងារ ឬ សេវាដែលគ្មានចែងក្នុងអនុកថាខណ្ឌ (ខ), និង ដែលតម្រូវជាធម្មតា ចំពោះជនជាប់ឃុំ តាមបទបញ្ជាស្របច្បាប់របស់តុលាការ ឬ ចំពោះជន ដែលតុលាការសម្រេចដោះលែងឲ្យមានសេរីភាព ដោយមានល័ក្ខខ័ណ្ឌ។

(ii) សេវាដែលមានលក្ខណៈយោធា និង កិច្ចការបម្រើជាតិដែលតម្រូវតាមច្បាប់សម្រាប់អ្នកប្រឆាំងសង្គ្រាម នៅក្នុងប្រទេសដែលទទួលស្គាល់សិទ្ធិប្រឆាំងសង្គ្រាម។

(iii) សេវាដែលតម្រូវក្នុងករណីមានអាសន្ន ឬ គ្រោះមហន្តរាយដែលគម្រាមកំហែងដល់អាយុជីវិត និង សុខមាលភាពសហគមន៍។

(iv) ការងារ ឬ សេវាដែលជាផ្នែកនៃកាតព្វកិច្ចធម្មតារបស់ប្រជាពលរដ្ឋ។

### កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិ សេដ្ឋកិច្ច, សង្គម និង វប្បធម៌

(International Covenant on Economic, Social and Cultural Rights)

#### មាត្រា ២១

សិទ្ធិប្រជុំដោយសន្តិវិធីត្រូវតែទទួលស្គាល់។ ការប្រើប្រាស់សិទ្ធិនេះអាចមានការរិតត្បិត ដែលកំណត់ដោយច្បាប់ប៉ុណ្ណោះ និង ដែលចាំបាច់ក្នុងសង្គមប្រជាធិបតេយ្យ ក្នុងផលប្រយោជន៍នៃសន្តិសុខជាតិ ឬ សុវត្ថិភាពសាធារណៈ, សណ្តាប់ធ្នាប់សាធារណៈ, ការការពារសុខភាពសាធារណៈ ឬ សីលធម៌ ឬ ការការពារសិទ្ធិនិងសេរីភាពរបស់អ្នកដទៃ។

#### មាត្រា ២៥

ដោយគ្មានការបែងចែក ដូចដែលបានចែងក្នុងមាត្រា២ និង ដោយគ្មានការរិតត្បិត ដែលមិនសមហេតុផល, ប្រជាពលរដ្ឋគ្រប់រូបមានសិទ្ធិ និង មានឱកាសៈ

(ក) រួមចំណែកក្នុងការដឹកនាំកិច្ចការសាធារណៈដោយផ្ទាល់ ឬ តាមរយៈតំណាង ដែលខ្លួនជ្រើសរើសដោយសេរី។

(ខ) បោះឆ្នោត និង ឈរឈ្មោះបោះឆ្នោត នៅក្នុងការបោះឆ្នោតពិតប្រាកដតាមកាលកំណត់ ទៀងទាត់ ជាសកល, ស្មើភាព និង ដោយសម្ងាត់ ដែលធានាការបញ្ចេញមតិដោយសេរី ពីឆន្ទៈអ្នកបោះឆ្នោត។

(គ) ចូលបម្រើមុខងារសាធារណៈក្នុងប្រទេសរបស់ខ្លួន ក្នុងល័ក្ខខ័ណ្ឌទូទៅដោយសមភាព។

### អនុសញ្ញា ស្តីពីសិទ្ធិកុមារ

(Convention on the Rights of the Child)

កម្ពុជា, ឧបាគមន៍ (ការបានជាកម្មសិទ្ធិនូវវត្ថុរណប) ខែតុលា ឆ្នាំ១៩៩២

#### មាត្រា ១២

១. រដ្ឋភាគី ត្រូវធានាអះអាងដល់កុមារ ដែលមានសមត្ថភាពបង្កើតទស្សនៈផ្ទាល់ខ្លួន នូវសិទ្ធិបញ្ចេញទស្សនៈទាំងនោះ ដោយសេរីលើគ្រប់បញ្ហាពាក់ព័ន្ធនឹងកុមារ។ ទស្សនៈទាំងនេះរបស់កុមារត្រូវបានយកទៅពិចារណាថ្លឹងថ្លែងដោយគិតទៅតាមវ័យ និង ភាពចាស់ទុំរបស់កុមារ។

២. ក្នុងទិសដៅនេះ កុមារត្រូវបានផ្តល់ជាពិសេស នូវឱកាសត្រូវបានគេស្តាប់នៅក្នុងនីតិវិធី តុលាការ និង រដ្ឋបាល ដែលពាក់ព័ន្ធនឹងកុមារ, ទោះដោយផ្ទាល់ ឬ តាមរយៈអ្នកតំណាង ឬ ស្ថាប័នសមស្រប ណាមួយ, ស្របតាមបទបញ្ញត្តិនីតិវិធីនៃច្បាប់ជាតិ។

#### មាត្រា ១៩

១. រដ្ឋភាគី ត្រូវចាត់វិធានការសមស្របខាង នីតិបញ្ញត្តិ, រដ្ឋបាល, សង្គមកិច្ច និង ខាងអប់រំ ដើម្បីការពារកុមារពីគ្រប់ទម្រង់ នៃអំពើ

ហិង្សា, ការធ្វើឲ្យរបួស ឬ ការរំលោភបំពានលើរាងកាយឬលើផ្លូវចិត្ត, ការទុកចោលមិនយកចិត្តទុកដាក់ ឬ ការមិនអើពើ, ការធ្វើបាប ឬ ការកេងប្រវ័ញ្ច, រួមទាំងការរំលោភបំពានផ្លូវភេទ, ក្នុងកំឡុងពេលដែលកុមារស្ថិតនៅក្រោមការចិញ្ចឹមបីបាច់របស់ឪពុកម្តាយទាំងពីរ ឬ ឪពុក ឬ ម្តាយ, ឬ អ្នកអាណាព្យាបាលស្របច្បាប់ ឬ បុគ្គលផ្សេងទៀត ដែលមានភារៈថែទាំកុមារ។

២. វិធានការការពារទាំងនេះ បើសមស្រប គួរបញ្ចូលនីតិវិធី ដែលមានប្រសិទ្ធិភាព ដើម្បីស្ថាបនាកម្មវិធីសង្គម ដែលផ្តល់ការគាំទ្រចាំបាច់ដល់កុមារ និង អ្នកដែលមានភារៈថែទាំកុមារ, និង ដើម្បីបង្ការតាមទម្រង់ផ្សេងៗ និង ដើម្បីកំណត់អត្តសញ្ញាណ, រាយការណ៍, បញ្ជូន, ស៊ើបអង្កេត, ព្យាបាល និង តាមដានលើកិច្ចអន្តរាគមន៍ពីតុលាការ។

## មាត្រា ៣២

១. រដ្ឋភាគី ទទួលស្គាល់សិទ្ធិការពារកុមារ ប្រឆាំងការកេងប្រវ័ញ្ចសេដ្ឋកិច្ច និង ការឲ្យធ្វើការងារប្រកបដោយគ្រោះថ្នាក់ ឬ ដែលអាចប៉ះពាល់ដល់ការសិក្សារបស់កុមារ, ឬ ដែលអាចបំផ្លាញសុខភាពឬការអភិវឌ្ឍ រាងកាយ, សតិ, បញ្ញា, ស្មារតី, សីលធម៌ ឬ សង្គម របស់កុមារ។

២. រដ្ឋភាគី ត្រូវចាត់វិធានការខាងផ្លូវច្បាប់, រដ្ឋបាល, សង្គម និង ការអប់រំដើម្បីធានាដល់ការអនុវត្ត មាត្រានេះ។ ក្នុងទិសដៅនេះ និង យោងតាមបទបញ្ញត្តិពាក់ព័ន្ធនឹងលិខិតុបករណ៍អន្តរជាតិ (international instruments) ផ្សេងទៀត, រដ្ឋភាគី ជាពិសេស៖

(ក) ត្រូវកំណត់អាយុអប្បបរមាមួយ ឬ អាយុអប្បបរមាច្រើនសម្រាប់ចូលធ្វើការ។

(ខ) ត្រូវចែងបទបញ្ជាសមស្របស្តីពីម៉ោងពេល និងល័ក្ខខ័ណ្ឌការងារ។

(គ) ត្រូវកំណត់ទោស ឬ ទណ្ឌកម្មសមស្របផ្សេងទៀត ដើម្បីធានាដល់ការអនុវត្តប្រកបដោយប្រសិទ្ធិភាពនូវមាត្រានេះ។

## មាត្រា ៣៤

រដ្ឋភាគី រ៉ាប់រងការពារកុមារ ឲ្យផុតពីគ្រប់ទម្រង់នៃការកេងប្រវ័ញ្ចផ្លូវភេទ និង ការរំលោភបំពានផ្លូវភេទ។ ក្នុងទិសដៅនេះ រដ្ឋភាគី ជាពិសេស ត្រូវចាត់វិធានការសមស្របនានា ក្នុងក្របខ័ណ្ឌជាតិ, ក្របខ័ណ្ឌទ្វេភាគី និង ពហុភាគី ដើម្បីទប់ស្កាត់៖

(ក) ការអូសទាញ ឬ ការបង្ខិតបង្ខំកុមារ ឲ្យចូលរួមក្នុងសកម្មភាពខាងផ្លូវភេទខុសច្បាប់។

(ខ) ការប្រើប្រាស់កុមារក្នុងពេស្យាកម្មកេងប្រវ័ញ្ច ឬ ប្រព្រឹត្តដោយខុសច្បាប់ខាងផ្លូវភេទផ្សេងទៀត។

(គ) ការប្រើប្រាស់កុមារដោយកេងប្រវ័ញ្ច នៅក្នុងការសម្តែងអាសអាភាស និង ផលិតសម្ភារៈ ឬ រូបភាពអាសអាភាស។

# អនុសញ្ញា ស្តីពីការលុបបំបាត់រាល់ទម្រង់ នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ (Convention on the Elimination of all Form of Discrimination againts Women, CEDAW)

កម្ពុជា, ចុះហត្ថលេខា នៅខែតុលា ឆ្នាំ១៩៨០, ឧបាគមន៍ (ការបានជាកម្មសិទ្ធិនូវវត្ថុណាប) ខែតុលា ឆ្នាំ១៩៩២

## មាត្រា ៣

ក្នុងគ្រប់វិស័យ ជាពិសេស វិស័យនយោបាយ, សង្គម, សេដ្ឋកិច្ច និង វប្បធម៌ រដ្ឋត្រូវចាត់វិធានការសមស្របទាំងអស់ រួមមានការធ្វើច្បាប់ផង ដើម្បីធានាការអភិវឌ្ឍ និង ការរីកចម្រើនពេញលេញរបស់ស្ត្រី ដើម្បីធានាឲ្យស្ត្រីប្រើប្រាស់ និង អាស្រ័យផលសិទ្ធិមនុស្ស និង សេរីភាពជាមូលដ្ឋាន ដោយសមភាពជាមួយបុរស។

## មាត្រា ៦

រដ្ឋភាគី ត្រូវប្រកាន់យកវិធានការសមស្របទាំងអស់ រួមមានការធ្វើច្បាប់ផង ដើម្បីបង្ក្រាបគ្រប់ទម្រង់នៃការជួញដូរស្ត្រី និង អាជីវកម្មពេស្យាកម្ម លើស្ត្រី។

## មាត្រា ១០

រដ្ឋភាគី ត្រូវប្រកាន់យកវិធានការសមស្របទាំងអស់ ដើម្បីលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រី ដើម្បីធានាឲ្យស្ត្រីមានសិទ្ធិស្មើនឹងបុរស ក្នុងវិស័យអប់រំ និង ជាពិសេស ដើម្បីធានាដល់ស្ត្រី ដោយផ្អែកលើមូលដ្ឋានសមភាពរវាង បុរស និង ស្ត្រី។

## មាត្រា ១៦

រដ្ឋភាគី ត្រូវចាត់វិធានការសមស្របទាំងអស់ ដើម្បីបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រី លើរាល់ បញ្ហាដែលទាក់ទងនឹងអាពាហ៍ពិពាហ៍ និង ទំនាក់ទំនងគ្រួសារ និង ជាពិសេស ដោយផ្អែកលើមូលដ្ឋានសមភាពរវាង បុរស និង ស្ត្រី។

# គណៈកម្មការអន្តររដ្ឋាភិបាលអាស៊ាន ស្តីពីសិទ្ធិមនុស្ស និង ធម្មនុញ្ញអាស៊ាន (ASEAN Inter-Governmental Commission on Human Rights and ASEAN Charter)

យើង ជាប្រមុខរដ្ឋ រដ្ឋាភិបាល នៃរដ្ឋសមាជិក នៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (ASEAN), នៅក្នុងឱកាសជំនួបកំពូលអាស៊ាន លើកទី១៥ ក្នុងប្រទេសថៃ។

ដោយរំឭកឡើងវិញ នូវមាត្រា១៤ នៃ ធម្មនុញ្ញអាស៊ាន (ASEAN Charter) ក្នុងការបង្កើតស្ថាប័នសិទ្ធិមនុស្សអាស៊ាន និង ការប្តេជ្ញាចិត្តរបស់អាស៊ានចំពោះការលើកកម្ពស់ និង ការការពារសិទ្ធិមនុស្សនិង សេរីភាពមូលដ្ឋាន។

ដោយស្វាគមន៍ នូវការចូលជាធរមាន នៃ លក្ខន្តិកៈបញ្ញាត់ (Terms of Reference) ជាមូលដ្ឋាននៃ គណៈកម្មការអន្តររដ្ឋាភិបាលអាស៊ានស្តីពីសិទ្ធិមនុស្ស (ASEAN Inter-Governmental Commission for Human Rights, AICHR)៖

៣. អបអរសាទរចំពោះការចាប់ផ្តើមរបស់គណៈកម្មការអន្តររដ្ឋាភិបាលអាស៊ានស្តីពីសិទ្ធិមនុស្ស (AICHR) ដូចដែលបានធ្វើការបញ្ជាក់យ៉ាងច្បាស់លាស់ចំពោះការអនុវត្ត នូវមាត្រា១៤ នៃធម្មនុញ្ញអាស៊ាន (ASEAN Charter) និង ការប្តេជ្ញាចិត្តរបស់អាស៊ានក្នុងការអនុវត្តយុទ្ធសាស្ត្រ ដើម្បីពង្រឹង សហប្រតិបត្តិការតំបន់ស្តីពីសិទ្ធិមនុស្ស។

៤. គាំទ្រនូវការអនុវត្ត នៃលក្ខន្តិកៈបញ្ញាត់ (Terms of Reference) របស់ គណៈកម្មការអន្តររដ្ឋាភិបាលអាស៊ានស្តីពីសិទ្ធិមនុស្ស (AICHR) ដូចដែលបានរៀបចំដោយ ក្រុមប្រឹក្សាត្រួតពិនិត្យថ្នាក់ខ្ពស់ (High Level Panel) និង បានសម្រេចជាផ្លូវការ ដោយរដ្ឋមន្ត្រីការបរទេសអាស៊ាន។

៥. អបអរសាទរអ្នកតំណាង នៃ គណៈកម្មការអន្តររដ្ឋាភិបាលអាស៊ានស្តីពីសិទ្ធិមនុស្ស (AICHR) លើការតែងតាំងរបស់ពួកគេ ដោយរដ្ឋសមាជិកអាស៊ាន (ASEAN Member States)។

៦. បញ្ជាក់សារៈសំខាន់ នៃ គណៈកម្មការអន្តររដ្ឋាភិបាលអាស៊ានស្តីពីសិទ្ធិមនុស្ស (AICHR) ជាគ្រឹះស្ថានប្រវត្តិសាស្ត្រ នៅក្នុងដំណើរការពង្រឹងសហគមន៍របស់អាស៊ាន, និង ជាយានសម្រាប់ការអភិវឌ្ឍ និង យុត្តិធម៌សង្គមជឿនលឿន, ការយល់ដឹងពេញលេញ នៃសេចក្តីថ្លៃថ្នូររបស់មនុស្ស និង ការទទួលបាននូវគុណភាពខ្ពស់នៃជីវិត សម្រាប់ប្រជាពលរដ្ឋអាស៊ាន។

៧. បញ្ជាក់អះអាងគណៈកម្មការអន្តររដ្ឋាភិបាលអាស៊ានស្តីពីសិទ្ធិមនុស្ស (AICHR) លើការគាំទ្រពេញលេញ និង ការផ្តល់ធនធានគ្រប់គ្រាន់ ដោយ រដ្ឋសមាជិកអាស៊ាន។

៨. ទទួលស្គាល់នូវវិភាគទាន នៃអ្នកពាក់ព័ន្ធដទៃទៀត នៅក្នុងការលើកកម្ពស់ និង ការការពារសិទ្ធិមនុស្ស នៅអាស៊ាន, និង លើកទឹកចិត្តពួកគេឲ្យបន្តការចូលរួម និង ការសន្ទនា ជាមួយគណៈកម្មការអន្តររដ្ឋាភិបាលអាស៊ានស្តីពីសិទ្ធិមនុស្ស (AICHR)។

៩. ទទួលស្គាល់ថា លក្ខន្តិកៈបញ្ញាត់ (Terms of Reference) របស់គណៈកម្មការអន្តររដ្ឋាភិបាលអាស៊ានស្តីពីសិទ្ធិមនុស្ស (AICHR) ត្រូវបានត្រួតពិនិត្យរៀងរាល់ ៥ឆ្នាំម្តង បន្ទាប់ពីការចូលជាធរមានរបស់ពួកគេ ដើម្បីពង្រឹងអាណត្តិ និង ភារកិច្ច នៃគណៈកម្មការអន្តររដ្ឋាភិបាលអាស៊ានស្តីពីសិទ្ធិមនុស្ស (AICHR) ក្នុងបំណងអភិវឌ្ឍន៍បន្ថែម នូវយន្តការនានា លើការការពារ និង ការលើកកម្ពស់សិទ្ធិមនុស្ស។ ការត្រួតពិនិត្យនេះ និង ការត្រួតពិនិត្យបន្តបន្ទាប់ នឹងត្រូវបានអនុវត្តន៍ដោយកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន។

១០. បញ្ចេញជំនឿទុកចិត្តថា សហប្រតិបត្តិការអាស៊ាន លើសិទ្ធិមនុស្សនឹងបន្តវិវត្តន៍និងអភិវឌ្ឍន៍ ដើម្បីឲ្យគណៈកម្មការអន្តររដ្ឋាភិបាលអាស៊ានស្តីពីសិទ្ធិមនុស្ស (AICHR) ជាស្ថាប័នគ្របដណ្តប់ទទួលខុសត្រូវចំពោះ ការលើកកម្ពស់ និង ការការពារសិទ្ធិមនុស្សនៅអាស៊ាន។

១១. បានអនុម័ត នៅ ឆាអាម ហោហ៊ីន (Cha-am Hua Hin) ប្រទេសថៃ ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៩។

## រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
(Cambodian Constitution)

### មាត្រា ៣១

- ព្រះរាជាណាចក្រកម្ពុជា ទទួលស្គាល់ និង គោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញ នៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និង កតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹង សិទ្ធិមនុស្ស សិទ្ធិនារី និង សិទ្ធិកុមារ។
- ប្រជាពលរដ្ឋខ្មែរ មានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និង ករណីកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ ពូជសាសន៍, ពណ៌សម្បុរ, ភេទ, ភាសា, ជំនឿសាសនា, និន្នាការនយោបាយ ដើមកំណើតជាតិ, ឋានៈសង្គម, ធនធាន ឬ ស្ថានភាពឯទៀតឡើយ។
- ការប្រើសិទ្ធិសេរីភាពផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ មិនត្រូវឲ្យប៉ះពាល់ដល់សិទ្ធិសេរីភាពអ្នកដទៃឡើយ។ ការប្រើសិទ្ធិសេរីភាពនេះ ត្រូវប្រព្រឹត្តតាមល័ក្ខខ័ណ្ឌកំណត់ក្នុងច្បាប់។

### មាត្រា ៥១ ថ្មី

- ព្រះរាជាណាចក្រកម្ពុជា អនុវត្តរបបនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស។
- ប្រជាពលរដ្ឋខ្មែរ ជាម្ចាស់វាសនានៃប្រទេសជាតិរបស់ខ្លួន។
- អំណាចទាំងអស់ ជារបស់ប្រជាពលរដ្ឋ។ ប្រជាពលរដ្ឋប្រើអំណាចរបស់ខ្លួន តាមរយៈរដ្ឋសភា, ព្រឹទ្ធសភា, រាជរដ្ឋាភិបាល និង សាលាជម្រះក្តី។
- អំណាចបែងចែកដាច់ពីគ្នា រវាងអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និង អំណាចតុលាការ។

### មាត្រា ៦៥

- រដ្ឋត្រូវការពារ និង លើកស្ទួយសិទ្ធិរបស់ប្រជាពលរដ្ឋ ក្នុងការទទួលការអប់រំ ប្រកបដោយគុណភាពនូវគ្រប់កម្រិត និង ត្រូវចាត់វិធានការគ្រប់បែបយ៉ាងជាជំហានៗ ដើម្បីឲ្យការអប់រំនេះ បានទៅដល់ប្រជាពលរដ្ឋគ្រប់រូបៗគ
- រដ្ឋយកចិត្តទុកដាក់ លើវិស័យអប់រំកាយ និង កីឡា ដែលជាសុខុមាលភាពរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប។

## មាត្រា ១២៩ ថ្មី (មាត្រា ១០៩ ចាស់)

- អំណាចតុលាការ ជាអំណាចឯករាជ្យ។
- អំណាចតុលាការ ជានារក្សាអនាគតិ និង ការពារសិទ្ធិសេរីភាព របស់ប្រជាពលរដ្ឋ។
- អំណាចតុលាការ គ្របដណ្តប់ទៅលើរឿងក្តីទាំងអស់ រួមទាំង រឿងក្តីរដ្ឋបាលផង។
- អំណាចនេះ ត្រូវប្រគល់ឲ្យតុលាការកំពូល និង សាលាជម្រះក្តី គ្រប់ផ្នែក និង គ្រប់ជាន់ថ្នាក់។

‘‘ខ្ញុំចង់បញ្ជូនសារដល់
ប្រជាពលរដ្ឋ ដែលចង់តស៊ូមតិ
ដើម្បីសេរីភាព ថា ពួកផ្ដាច់ការ
ពុំអាចឈ្នះ ដោយគ្រាន់តែដាក់
យើងក្នុងពន្ធនាគារនោះទេ។
ខ្ញុំចង់បង្ហាញថា អ្នកពុំអាច
បំបិទមាត់នរណាម្នាក់
ដែលមិនស្របតាមអស់លោក
ដោយប្រើកម្លាំងបាយទេ"។
—ឌ័ន វៀត ហ៊ាត

DOAN VIET HOAT

# សទ្ទានុក្រមពាក្យ / វាក្យស័ព្ទ GLOSSARY OF TERMS

## ការតស៊ូមតិ (Advocacy)

ដំណើរការនយោបាយ ដែលមានសកម្មភាព បានគ្រោងឡើង ដើម្បីប្រែក្លាយពលរដ្ឋ ឬ ផលប្រយោជន៍របស់ពលរដ្ឋ ទៅជាសិទ្ធិ។ ដំណើរការមួយ ដែលមានគោលដៅជះឥទ្ធិពល លើសេចក្តីសម្រេច ដែលទាក់ទងនឹង គោលនយោបាយ និង ច្បាប់ នៅថ្នាក់ជាតិនិងថ្នាក់អន្តរជាតិ។ សកម្មភាពនានា ដែលបានគ្រោងឡើង ដើម្បីទាក់ទាញនូវការយកចិត្តទុកដាក់ របស់សហគមន៍ ចំពោះបញ្ហា និង ចំពោះអ្នកធ្វើគោលនយោបាយ ដោយផ្ទាល់លើដំណោះស្រាយនេះ។

## ការរើសអើងពូជសាសន៍ អាផាថាយ (Apartheid)

ប្រព័ន្ធមួយ នៃ វិយោគកម្ម និង ការរើសអើងពូជសាសន៍ បានដាក់ដោយរដ្ឋាភិបាលជនជាតិភាគតិចស្បែកស របស់ប្រទេសអាហ្វ្រិកខាងត្បូង ពីឆ្នាំ១៩៤៨ រហូតដល់បានលុបចោល បន្ទាប់ពីការបោះឆ្នោតជាតិ ឆ្នាំ១៩៩៤។

## សិទ្ធិជ្រកកោន (Asylum)

ទីកន្លែងមួយដែលបានផ្តល់ការការពារ ឬ សុវត្ថិភាព។

## ការសម្លុតកំហែង (Bullying)

ការសម្លុតកំហែង គឺជា សកម្មភាពមួយ នៃឥរិយាបថឈ្លានពានដដែលៗ ក្នុងបំណងធ្វើឲ្យឈឺចាប់ដល់បុគ្គលដទៃ ដោយចេតនា ទាំងផ្លូវកាយក្តី ទាំងផ្លូវចិត្តក្តី។ វាបញ្ជាក់ជាចាំបាច់អំពីបំណងមួយ ក្នុងការបៀតបៀន ឬ ធ្វើសកម្មភាពឫកពា ចំពោះសហការី, ជាពិសេស នៅក្នុងសាលារៀន, ដោយផ្ទាល់ក្តី (ដោយរំខានផ្លូវកាយ ឬ ផ្លូវចិត្ត) ដោយប្រយោលក្តី (មិនរាប់បញ្ចូល និង ដាក់ឲ្យនៅដាច់ពីគេ)។ បច្ចុប្បន្ននេះ មានការយកចិត្តទុកដាក់ច្រើន អំពីបញ្ហានេះ, ជាពិសេស ដោយសារតែផលវិបាកដ៏សែនគ្រោះថ្នាក់ ក្នុងការអភិវឌ្ឍចារិកលក្ខណៈ និង សុខុមាលភាពរបស់មនុស្សក្មេងៗ។ ការកើតឡើងថ្មីៗនៃការសម្លុតគម្រាមតាមប្រព័ន្ធកុំព្យូទ័រ, ការប្រើប្រាស់ប្រព័ន្ធអ៊ិនធឺណិត, ទូរស័ព្ទដៃ ឬ ឧបករណ៍ផ្សេងៗ ក្នុងការបញ្ជូន ឬ ការផ្ញើអត្ថបទ ឬ រូបភាព ក្នុងបំណងធ្វើឲ្យឈឺចាប់ ឬ បៀតបៀនបុគ្គលណាម្នាក់, បានបណ្តាលឲ្យស្លាប់ និង ញុំាងឲ្យអាជ្ញាធរកត់ចំណាំ និង ព្យាយាមដោះស្រាយ នូវនិន្នាការដ៏គ្រោះថ្នាក់។

## ការរាំងរាំង (Censorship)

ការពិនិត្យតាមដាន និង ការដាក់កំណត់សុន្ទរកថា និង ការផ្សព្វផ្សាយជាសាធារណៈ ព្រមទាំងទូរគមនាគមន៍។ ការរារាំងនេះ ជាធម្មតា ត្រូវបានធ្វើឡើង តាមរយៈយន្តការនៃ ការអង្កេត និង ការអនុម័តយល់ព្រម ក្នុងការធានានូវការគោរពតាមគោលនយោបាយរបស់រដ្ឋាភិបាលដោយយកលេសថាក្នុងនាមការគោរពតម្លៃប្រពៃណី, សន្តិសុខជាតិ ឬ សីលធម៌សហគមន៍។ ការរារាំងដោយស្វ័យប្រវត្តិត្រូវបានធ្វើឡើង ដោយឧស្សាហកម្ម សារព័ត៌មាន និង ទូរគមនាគមន៍ក្នុងបំណងអនុលោមតាមមនោគមវិជ្ជានានា របស់រដ្ឋាភិបាល។

## សិទ្ធិស៊ីវិល និងសិទ្ធិនយោបាយ (Civil &political rights)

សិទ្ធិស៊ីវិល និង សិទ្ធិនយោបាយ គឺជាថ្នាក់មួយនៃ សិទ្ធិ និង សេរីភាព ដែលបានការពារបុគ្គលម្នាក់ៗ ពីសកម្មភាពមិនត្រឹមត្រូវ ដោយរដ្ឋាភិបាល, អង្គការឯកជន និង បុគ្គលម្នាក់ៗ, និង ធានានូវសមត្ថភាពរបស់គេ ក្នុងការចូលរួមផ្នែកជីវិតស៊ីវិល និង ផ្នែកជីវិតនយោបាយរបស់ប្រទេស ដោយមិនមាន ការរើសអើង ឬ ការបង្ក្រាប។ សិទ្ធិទាំងអស់នេះ ត្រូវបានដាក់បញ្ចូលទៅក្នុង សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (Universal Declaration of Human Rights) ក្នុងឆ្នាំ ១៩៤៨ និង បានគូសបញ្ជាក់នៅក្នុង កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិសេដ្ឋកិច្ច, សង្គមកិច្ច និង វប្បធម៌ (International Covenant on Economic, Social and Cultural Rights)។ សិទ្ធិស៊ីវិល រួមបញ្ចូលទាំងការធានានូវ សេចក្តីថ្លៃថ្នូរ និង សុវត្ថិភាពខាងរាងកាយ របស់ប្រជាពលរដ្ឋ។ ការការពារពីការរើសអើង ដូចជា អសមត្ថភាពខាងរាងកាយ ឬ សតិបញ្ញា, យេនឌ័រ (gender), សាសនា, ពូជសាសន៍, ខាងផ្លូវភេទ, ដើមកំណើតជាតិ, អាយុ, ស្ថានភាពអន្តោប្រវេសន៍, ជាដើម។ ហើយ សិទ្ធិបុគ្គលម្នាក់ៗ ដូចជា សេរីភាព ផ្នែកគំនិត និង មនសិការ, សុន្ទរកថា និង ការបញ្ចេញមតិ, សាសនា, សារព័ត៌មាន និង ការធ្វើដំណើរ។

## ឧក្រិដ្ឋកម្មនៃការរើសអើងពូជសាសន៍ អាផាថាយស៍ (Crimes of Apartheid)

អនុសញ្ញាអន្តរជាតិ ស្តីពី ការសង្កត់សង្កិន និង ការដាក់ទណ្ឌកម្ម អំពីឧក្រិដ្ឋកម្មនៃការរើសរើងពូជសាសន៍ អាផាថាយស៍ (International Covention on the Suppression and Punishment of the Crime of Apartheid) ប្រកាសថា ការរើសអើងពូជសាសន៍ អាផាថាយស៍ (Apartheid) ជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលបណ្តាលមកពីគោលនយោបាយ និង ការអនុវត្ត វិយោគកម្ម និង ការរើសរើងពូជសាសន៍, ហើយការរំលោភគោលការណ៍នៃច្បាប់អន្តរជាតិ, ជាពិសេសស គោលបំណង និង គោលការណ៍ នៃ ធម្មនុញ្ញអង្គការសហប្រជាជាតិ (UN Charter), និង ការបង្កើតឲ្យមាន ការគម្រាមកំហែងយ៉ាងធ្ងន់ធ្ងរ ចំពោះ សន្តិភាព និង សន្តិសុខ អន្តរជាតិ។

## ការដាក់ទណ្ឌកម្មដ៏ឃោរឃៅ ឬ អមនុស្សធម៌ (Cruel or Inhuman Punishment)

មាត្រា៥ នៃ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (Universal Declaration of Human Rights) ចែងថា៖ "គ្មាននរណាម្នាក់ នឹងអាចតម្រូវឲ្យមានការធ្វើទារុណកម្ម ឬ ការប្រព្រឹត្ត ឬ ការដាក់ទណ្ឌកម្មដ៏ឃោរឃៅ, អមនុស្សធម៌ ឬ បាក់មុខមាត់ណាមួយទេ។ ការដាក់ទណ្ឌកម្មដ៏ឃោរឃៅនេះ គឺជាបញ្ហាកង្វល់ដ៏សំខាន់មួយ នៅជុំវិញ

ពិភពលោក, ហើយនិងផងដែរ បានទាក់ទងទៅនឹងបញ្ហាទោសប្រហារជីវិត, ព្រោះថា ការទាមទារនេះ សុំឲ្យមានការពន្យារពេលយូរ មុនពេលប្រហារជីវិត បានបង្កើតឲ្យមានការប្រព្រឹត្តិអមនុស្សធម៌។

## សិទ្ធិមានវប្បធម៌ (Cultural Rights)

វប្បធម៌ គឺជា សមាសធាតុរួម នៃលក្ខណៈ ស្មារតី, សម្ភារៈ, បញ្ញា និង អារម្មណ៍ ដែលបានប្រាប់អំពីលក្ខណៈ សង្គម ឬ ក្រុមសង្គម, ដោយរួមបញ្ចូល ទាំងមិនត្រឹមតែសិល្បៈ និង អក្សរ ប៉ុណ្ណោះទេ, ប៉ុន្តែថែមទាំង គំរូជីវិត, ប្រព័ន្ធតម្លៃ, ប្រពៃណី និង ជំនឿផងដែរ។ សិទ្ធិមានវប្បធម៌ត្រូវបានគេនិយាយជាញឹកញាប់នៅក្នុង ឧបករណ៍សិទ្ធិមនុស្សអន្តរជាតិ និង ផងដែរ ទាក់ទងនឹង សិទ្ធិមានសេដ្ឋកិច្ច និង សង្គមកិច្ច។

## ច្បាប់ប្រពៃណីអន្តរជាតិ (Customary International Laws)

នៅពេលណា មានមតិទូទៅទូលំទូលាយ នៅក្នុងចំណោមរដ្ឋនានាស្តីពីបទដ្ឋានមួយ, វាបានក្លាយជាកាតព្វកិច្ចជាអន្តរជាតិ, និងផងដែរជាប្រភពមួយ នៃច្បាប់អន្តរជាតិ។

## នីតិវិធីផ្លូវច្បាប់ (Due Process)

ទម្រង់ការច្បាប់ បានអនុលោម ឬ មិនបានអនុលោម តាមវិធានការ និង គោលការណ៍នានា សម្រាប់ការការពារសិទ្ធិរបស់ភាគីនីមួយៗ។ ជាទូទៅ ឧបករណ៍ទាំងអស់នេះ ការពារសិទ្ធិរបស់ជនដែលត្រូវបានគេនាំទៅកាន់តុលាការ។

## សិទ្ធិមានសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ (Economic Social & Cultural rights)

សិទ្ធិ សេដ្ឋកិច្ច, សង្គមកិច្ច និង វប្បធម៌ គឺជា សិទ្ធិមនុស្សសង្គមសេដ្ឋកិច្ច (socio-economic) ដែលមានលក្ខណៈខុសគ្នាពីសិទ្ធិស៊ីវិល និង សិទ្ធិនយោបាយ។ សិទ្ធិ សេដ្ឋកិច្ច, សង្គមកិច្ច និង វប្បធម៌ ត្រូវបានដាក់បញ្ចូលទៅក្នុង សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (Universal Declaration of Human Rights) ក្នុងឆ្នាំ១៩៤៨, និង បានគូសបញ្ជាក់នៅក្នុង កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិ សេដ្ឋកិច្ច, សង្គមកិច្ច និង វប្បធម៌ (International Covenant on Economic, Social and cultural Rights)។ ឧទាហរណ៍ នៃសិទ្ធិទាំងអស់នេះ រួមបញ្ចូលទាំង សិទ្ធិមានចំណីអាហារ, សិទ្ធិមានលំនៅដ្ឋាន, សិទ្ធិមានការអប់រំ, សិទ្ធិមានសុខភាព និង សិទ្ធិមានជីវភាពរស់នៅគ្រប់គ្រាន់។

## អំពើហិង្សាផ្អែកយេនឌ័រ (Gender-based Violence)

អំពើហិង្សាបានប្រព្រឹត្តឡើងប្រឆាំងនឹងជនរងគ្រោះ ដោយសារតែយេនឌ័រ (gender) របស់គេ, ជាឧទាហរណ៍ អំពើហិង្សាលើស្ត្រី ដូចជាការចាប់រំលោភ, ការរំលោភផ្លូវភេទ, ការកាត់ស្បែកអង្គជាតិស្ត្រី, ការដុតទ្រព្យសម្បត្តិចោល ជាដើម។ អំពើហិង្សាលើស្ត្រី ដែលមិនអាចអនុលោមតាមបទដ្ឋានសង្គម និង វប្បធម៌ដែលមានកំណត់។ សេចក្តីប្រកាស ហ្វៀនណា (Vienna Declaration) បានទទួលស្គាល់ពិសេសនូវអំពើហិង្សាយេនឌ័រ ជាបញ្ហាសិទ្ធិមនុស្សមួយ។

## អំពើប្រល័យពូជសាសន៍, ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និង ឧក្រិដ្ឋកម្មឈ្លានពាន (Genocide, Crimes Against Humanity, War Crimes and Crimes of Aggression)

មានឧក្រិដ្ឋកម្មជាច្រើន ដែលបានទទួលស្គាល់ថា ជាឧក្រិដ្ឋកម្មធ្ងន់ធ្ងរបំផុត ដែលគម្រាមកំហែងនូវ សន្តិភាព និង សន្តិសុខ។ តុលាការឧក្រិដ្ឋកម្មអន្តរជាតិ (International Criminal Court) ត្រូវបានបង្កើតឡើង នៅក្នុងការកាត់ទោសឧក្រិដ្ឋកម្មទាំងអស់នេះ។ ម៉្យាងវិញទៀត តុលាការឧក្រិដ្ឋកម្មអន្តរជាតិ មិនបានអនុវត្ត យុត្តាធិការលើ ឧក្រិដ្ឋកម្មឈ្លានពាន (crime of aggression) នេះទេ។ អំពើប្រល័យពូជសាសន៍ត្រូវបានកំណត់ថា ជាសកម្មភាព ដែលបានប្រព្រឹត្តឡើងដោយចេតនាក្នុងបំណង បំផ្លិចបំផ្លាញ, ទាំងមូល ឬ ជាផ្នែក, លើក្រុមជាតិជនជាតិភាគតិច, ពូជសាសន៍ ឬ សាសនា។ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (crimes against humanity) គឺជា ការវាយប្រហារ ឬ សកម្មភាពហិង្សាដែលបានប្រព្រឹត្តឡើង ជាផ្នែកនៃការវាយប្រហារ រាលដាល និង ជាប្រព័ន្ធ (widespread and systematic attacks) ប្រឆាំងនឹងប្រជាពលរដ្ឋ, ដោយមានការយល់ដឹង អំពីការវាយប្រហារនោះ។ ឧក្រិដ្ឋកម្មសង្គ្រាម (war crimes) គឺជាឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើង ជាទ្រង់ទ្រាយធំ ជាផ្នែកនៃ ផែនការ ឬ គោលនយោបាយ, ដោយពាក់ព័ន្ធជាមួយការរំលោភយ៉ាងធ្ងន់ធ្ងរ នូវអនុសញ្ញាហ្សឺណែវ (Geneva Conventions)។ ឧក្រិដ្ឋកម្មឈ្លានពាន (crime of aggression) ត្រូវបានកំណត់ថា ជាផែនការ, ការរៀបចំ, ការផ្តួចផ្តើមគំនិត ឬ ការប្រហារជីវិត ដោយបុគ្គលម្នាក់ ដែលអាចអនុវត្តនូវការត្រួតពិនិត្យមានប្រសិទ្ធភាព ឬ ដឹកនាំវិធានការនយោបាយ និង រដ្ឋយោធា (military State), ជាសកម្មភាពឈ្លានពាន ដែលតាមធម្មជាតិ, ភាពធ្ងន់ធ្ងរ និង កម្រិត ទាំងអស់នេះ, បង្កើតការរំលោភយ៉ាងច្បាស់នូវធម្មនុញ្ញអង្គការសហប្រជាជាតិ (UN Charter)។

## ការអប់រំអំពីសិទ្ធិមនុស្ស (Human Right Education )

ការផ្សព្វផ្សាយព័ត៌មាន មានបំណងកសាងវប្បធម៌សិទ្ធិមនុស្សសកលតាមរយៈ ចំណេះដឹង និង ជំនាញ, និង ការបណ្តុះអាកប្បកិរិយាដើម្បី៖ ការពង្រឹងការគោរពសិទ្ធិមនុស្ស និង សេរីភាពជាសារវ័ន្ត។ ការអភិវឌ្ឍពេញលេញនូវបុគ្គលិកលក្ខណៈមនុស្ស និង សមត្ថភាពនៃសេចក្តីថ្លៃថ្នូរ។ ការលើកកម្ពស់ ការយល់ដឹង, ការគោរព, សមភាព, យេនឌ័រ និង មិត្តភាព នៅក្នុងចំណោមប្រជាជាតិទាំងអស់, ជនជាតិដើមភាគតិច, និង ក្រុម, ពូជសាសន៍, ជាតិ, សាសនា និង ភាសាវិទ្យា។ ការជួយធ្វើឲ្យបុគ្គលទាំងអស់ បានចូលរួមយ៉ាងមានប្រសិទ្ធភាព នៅក្នុងសង្គមមានសេរីភាព។ ការលើកតម្កើងសកម្មភាព របស់អង្គការសហប្រជាជាតិ ដើម្បីថែរក្សាសន្តិភាព។

## ជនជាតិដើមភាគតិច (Indigenous People )
មនុស្សគឺជាអ្នករស់នៅដើមដំបូង ឬតាមធម្មជាតិរបស់ប្រទេសមួយ។

## មិនអាចបែងចែកបាន (Indivisible)
ដោយសំដៅទៅរក ខ្លឹមសារស្មើគ្នា នៃច្បាប់សិទ្ធិមនុស្ស នីមួយៗ។ បុគ្គលម្នាក់ គេមិនអាចបដិសេធនូវសិទ្ធិបានទេ ដោយសារតែអ្នកខ្លះសម្រេចចិត្តថា វាមានសារៈសំខាន់តិចតួច ឬ វាមិនចាំបាច់ទាល់តែសោះ។

## I.N.S.
អក្សរកាត់ សម្រាប់ពាក្យ U.S. Immigration and Naturalization Service។ ឥឡូវនេះហៅថាភាពជាពលរដ្ឋអាមេរិកកាំងនិងសេវាកម្មអន្តោប្រវេសន៍ (U.S. Citizenship and Immigration Services)។

## ដែលពឹងពាក់អាស្រ័យគ្នា (Interdependent )
ដោយសំដៅទៅរកក្របខ័ណ្ឌបន្ថែម នៃច្បាប់សិទ្ធិមនុស្ស។ ឧទាហរណ៍ សមត្ថភាពចូលរួមនៅក្នុងរដ្ឋាភិបាលរបស់អ្នក គឺប៉ះពាល់ផ្ទាល់ ដោយសិទ្ធិក្នុងការបញ្ចេញមតិ, សិទ្ធិក្នុងការទទួលការអប់រំ និង សិទ្ធិក្នុងការទទួលបានសេចក្តីត្រូវការរបស់ជីវិត។

## អង្គការក្រៅរដ្ឋាភិបាល
## (Non-governmental Organizations )
អង្គការនានា បានបង្កើតឡើង ដោយមនុស្សស្ថិតនៅក្រៅរដ្ឋាភិបាល។ អង្គការក្រៅរដ្ឋាភិបាល (NGO) ពិនិត្យតាមដាន ទម្រង់ការ នៃស្ថាប័នសិទ្ធិមនុស្ស ដូចជា គណៈកម្មការសិទ្ធិមនុស្ស (Human Rights Commission) នៅឯ អង្គការសហប្រជាជាតិ, ហើយ "ជាស្ថាប័នឃ្លាំមើល" (watchdogs) សិទ្ធិមនុស្ស ដែលមាននៅក្នុងអាណត្តិរបស់ពួកគេ។ ស្ថាប័នខ្លះគឺជាស្ថាប័នធំ និង ជាអន្តរជាតិ។ ស្ថាប័នដទៃទៀត គឺតូច និង ក្នុងស្រុក។ អង្គការក្រៅរដ្ឋាភិបាល ដើរតួនាទីយ៉ាងសំខាន់នៅក្នុងការជះឥទ្ធិពល ទៅលើ គោលនយោបាយ របស់ អង្គការសហប្រជាជាតិ។

## សិទ្ធិនយោបាយ (Political Rights)
សិទ្ធិដែលធ្វើឲ្យប្រជាពលរដ្ឋមានសមត្ថភាព ទៅចូលរួមនៅក្នុងដំណើរការនយោបាយ នៃប្រទេសមួយ ដែលរួមបញ្ចូលទាំង សិទ្ធិបោះឆ្នោត, និង សេរីភាព នៃការបញ្ចេញមតិខាងនយោបាយ, ការប្រជុំ និង ការបង្កើតសមាគម។ សិទ្ធិនយោបាយ ត្រូវបានការពារដោយច្បាប់អន្តរជាតិ ដូចដែលមានចែងនៅក្នុង កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ (International Covenant on Civil and Political Rights) របស់ អង្គការសហប្រជាជាតិ។

## មាតុភូមិនិវត្តន៍ដោយបង្ខំ (Refoulement)
ពេលដែលបុគ្គលម្នាក់ ត្រូវបានគេបង្ខំឲ្យត្រលប់ ទៅកាន់ប្រទេសកំណើតវិញ, នៅក្នុងប្រទេសនោះ ជីវិត និង សេរីភាព របស់គេ នឹងមានការគម្រាមកំហែង។ ផងដែរ គេអាចហៅថា មាតុភូមិនិវត្តន៍ដោយបង្ខំ (forced repatriation)។

## ជនភៀសខ្លួន (Refugee)
បុគ្គលម្នាក់ដែលភៀសខ្លួនទៅបរទេស ឬអំណាច ដែលនឹងត្រូវបង្ខំឲ្យគេចចេញពី គ្រោះថ្នាក់ និង ការធ្វើទុកបុកម្នេញ។

## នីតិរដ្ឋ (Rule of Law)
ដោយបានចងភ្ជាប់យ៉ាងតឹងរឹងនូវរដ្ឋ ដែលមានសេរីភាព, នីតិរដ្ឋ តម្រូវឲ្យមានកម្រិតអប្បបរមានៃការបែងចែកអំណាចរដ្ឋាភិបាល សម្រាប់ការការពារសិទ្ធិបុគ្គលម្នាក់ៗ។ រដ្ឋប្រជាធិបតេយ្យ និង ពហុនិយម តម្រូវឲ្យមាន តុលាការឯករាជ្យ។ ខុសពី "រដ្ឋដោយនីតិ" ("rule by law" vs "rule of law"), ជាឧបករណ៍មួយដែលប្រើដោយអ្នកគ្រប់គ្រងប្រើអំណាចផ្តាច់ការ ដើម្បីថែរក្សានូវបទបញ្ជា ដោយមិនមានការគោរពសិទ្ធិមនុស្ស។

## ការប្តេជ្ញាខ្លួនឯង (Self-Determination)
ការប្តេជ្ញាខ្លួនឯង ដោយប្រជាពលរដ្ឋ របស់អង្គភាពដែនដីនៃអនាគតនយោបាយផ្ទាល់ខ្លួនរបស់ពួកគេ រួចផុតពីការបង្ខិតបង្ខំពីអំណាចនៅខាងក្រៅតំបន់នោះ។

## ការជ្រើសរើសផ្លូវភេទ (Sexual Orientation)
បង្ហាញប្រាប់ទិស ពីការទាក់ទាញអារម្មណ៍ ឬ ការប្រព្រឹត្តិ, សំដៅទៅរកមនុស្សមានភេទផ្ទុយគ្នា (ការជ្រើសរើសផ្លូវភេទផ្ទុយគ្នា, heterosexual), សំដៅទៅរក មនុស្សភេទស្រី ឬ ប្រុស (ការជ្រើសរើសផ្លូវភេទទាំងពីរ, bisexual) ឬ សំដៅទៅរក មនុស្សមានភេទដូចគ្នា (ការជ្រើសរើសផ្លូវភេទដូចគ្នា, homosexual)។

## ការឈ្លបចាប់ (Stalking)
លំនាំនៃ ការយកចិត្តទុកដាក់, ការបៀតបៀន, ការទំនាក់ទំនងដដែលៗ និង ដែលមិនត្រឹមត្រូវ, ឬ ដំណើរការនៃ ការប្រព្រឹត្តណាមួយទៅលើបុគ្គលពិសេសណាម្នាក់ ដែលបង្កឲ្យ បុគ្គលធម្មតាដែលមានវិចារណញ្ញាណនោះ មានអារម្មណ៍ភ័យខ្លាច។ ការឈ្លបចាប់ ប្រឆាំងនឹងច្បាប់។

## ការធ្វើទារុណកម្ម (Torture)
ការប្រព្រឹត្តិដែលមានការឈឺចាប់ក្រៃលែង, តាមផ្លូវកាយក្តី តាមផ្លូវចិត្តក្តី, ជាទូទៅ ដោយដាក់ទណ្ឌកម្ម ឬ ដោយទទួលបានការសារភាព ឬ ដោយទទួលបានព័ត៌មាន, ឬដើម្បី ការសប្បាយរីករាយដ៏អាក្រក់របស់អ្នកប្រព្រឹត្តិទារុណកម្មនោះ។ ការធ្វើទារុណកម្ម ត្រូវបាន ហាមឃាត់ដោយ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (UDHR) និង កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ (ICCPR), និង មិនមានការអនុញ្ញាត សម្បីតែ សម្រាប់ឆ្លើយតបទៅនឹងភេរវកម្ម ឬ ដើម្បីឆ្លើយតបទៅនឹងមធ្យោបាយណាមួយ នៅក្នុងការស៊ើបអង្កេតភេរវជន។ ការហាមឃាត់នៃការធ្វើទារុណកម្មនេះ គឺជា ច្បាប់ប្រពៃណីអន្តរជាតិ (customary international law) និង មានភាពធម្មជាតិចាំបាច់,

ហើយផងដែរ ត្រូវបានចាត់ទុកថា ជាឧក្រិដ្ឋកម្មអន្តរជាតិ ដែលអាចដាក់ទណ្ឌកម្ម ដោយតុលាការក្នុងស្រុក ឬ អន្តរជាតិ។

### ការផ្ទេរយេនឌ័រ (Transgender)

សំដៅទៅលើមនុស្ស ដែលមានអត្តសញ្ញាណកម្មផ្លូវចិត្ត ជាមួយមនុស្សដែលមានភេទជីវសាស្ត្រផ្ទុយពីខ្លួនឯង ដ៏ខ្លាំង និង ទាក់ទាញ, និង បង្ខំអ្នកខ្លះ ឲ្យទៅប្តូរភេទរបស់ខ្លួន ("gender reassignment") តាមរយៈ នីតិវិធីវេជ្ជសាស្ត្រ។ ចំណុចនេះ ជាទូទៅត្រូវបានចាត់ទុកថា ជាបញ្ហាមួយ ដែលទាក់ទងនឹងអត្តសញ្ញាណយេនឌ័ររបស់បុគ្គលម្នាក់។

### សន្ធិសញ្ញា (Treaty)

កិច្ចព្រមព្រៀងជាផ្លូវការ រវាងរដ្ឋ ដែលបានកំណត់ និង បញ្ជាក់អំពីភារកិច្ច និង កាតព្វកិច្ច ទៅវិញទៅមករបស់ពួកគេ។ ដោយប្រើប្រាស់អត្ថន័យដូចគ្នាជាមួយ អនុសញ្ញា និង កតិកាសញ្ញា។

### ការពិត និង ការបង្រួបបង្រួម / សច្ចភាព និង ការផ្សះផ្សា (Truth and Reconciliation)

ពាក្យពេចន៍នេះ ជាញឹកញាប់ទាក់ទងជាមួយ គណៈកម្មការការពិត និង ការបង្រួបបង្រួម (Truth and Reconciliation Commissions) ដែលត្រូវបានបង្កើតឡើងនៅទូទាំងពិភពលោក ដើម្បីផ្តល់វេទិកាសាធារណៈជូនដល់ ជនរងគ្រោះ និង អ្នកប្រព្រឹត្តឧក្រិដ្ឋកម្ម ក្នុងបំណងបង្ហាញអំពីអំពើហិង្សា និង ការរំលោភ ដែលបានប្រព្រឹត្ត នៅក្នុងរបបប្រើអំណាចផ្តាច់ការ និង ការមានជម្លោះ។ នីតិវិធីនេះ លើកកម្ពស់តម្លាភាព នៅក្នុងដំណើរការ នៃការកំណត់ត្រា នូវព្រឹត្តិការណ៍ប្រវត្តិសាស្ត្រពិតប្រាកដ ដែលមានលក្ខណៈសំខាន់ដល់ការព្យាបាល និង ការបង្រួបបង្រួមសង្គម។

### សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (Universal Declaration of Human Rights, UDHR)

"ស្តង់ដាររួមនៃសមិទ្ធផល សម្រាប់ មនុស្សគ្រប់រូប និង ប្រជាជាតិទាំងអស់" បានធ្វើពង្រាងដោយ គណៈកម្មការស្តីពីសិទ្ធិមនុស្ស របស់អង្គការសហប្រជាជាតិ (UN Commission on Human Rights) និង បានអនុម័តដោយ មហាសន្និបាត (UN General Assembly) ក្នុងឆ្នាំ ១៩៤៨។ ទោះបីមិនមានកាតព្វកិច្ចផ្នែកច្បាប់ក៏ដោយ, វាក៏បានជម្រុញឲ្យបង្កើត កម្រងច្បាប់សិទ្ធិអាស្រ័យរដ្ឋធម្មនុញ្ញ, សន្ធិសញ្ញាស្តីពីសិទ្ធិមនុស្ស, និង យន្តការផ្សេងៗ សម្រាប់ការការពារសិទ្ធិមនុស្សជាអន្តរជាតិ។

### ការស្អប់ជនបរទេស (Xenophobia)

ភាពភ័យខ្លាច ឬ ការប្រមាថមកលើជនណាម្នាក់ ដែលជាជនបរទេស ឬជនដែលមិនស្គាល់ ជាពិសេសមនុស្សថ្មី ឬ ជនបរទេស។

# ការទទួលស្គាល់




អ្នកនាង សេង ធារី, ប្រធានស្ថាបនិក នៃ ស៊ីវីកហ្គ័សៈមជ្ឈមណ្ឌលអប់រំដើម្បីពលរដ្ឋខ្មែរ សូមសម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅ ចំពោះ លោកអ្នកគ្រប់គ្នា ដែលបានផ្តល់ឲ្យ យើងនូវ ទេពកោសល្យ របស់ពួកគាត់ និង ការយល់ច្បាស់លាស់ ពិតប្រាកដ ក្នុងការ បង្កើតកម្មវិធីសិក្សា ជាភាសាខ្មែរ, ដោយការ អរគុណ ជាពិសេស ចំពោះ លោក រ៉ុង ឈុន ប្រធានសមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យ និង ជំនួយការផ្ទាល់របស់ អ្នកនាង សេង ធារី, គឺជា អ្នកនាង អៀម ស៊ីវនីន។

អ្នកគ្រូ លោកគ្រូ ចូលរួមសិក្ខាសាលា នៅ ភ្នំពេញ៖ អ្នកស្រី លឹម ស្រីពៅ (Lim Sreypov), អ្នកស្រី អ៊ុក ឆាយ៉ារី (Ouk Chhayary), អ្នកស្រី រស់ ទិត្យម៉ាល័យ (Rous Tithmalay), អ្នកស្រី លី ស៊ីណេត (Ly Sineth), លោក អ៊ឹម វ៉ៃ (Im Vai), អ្នកស្រី ភឿន សោភា (Pheun Sophea), លោក កង សុខសាន (Kang Soksan), លោក ម៉ៃ សុភ័ក្ត្រា (Mai Sopheaktra), លោក ងៀប ពិសិដ្ឋ (Ngeab Piseth), លោក ស៊ុម មិច (Sum Mich), អ្នកស្រី អ៊ុក សុធាវី (Ouk Sotheavy), លោក មឿង សំណាង (Meung Samnang), លោក ចន ហ្វ្រែន-ភើអ៊ីរ៉ា (John Friend-Pereira), លោក វ៉ន សុខ (Van Sok), លោក គួន ងួន (Kourn Ngourn), អ្នកគ្រូ ណុប មុនីលក្ខិណា (Nop Monyleakhna), អ្នកគ្រូ ស៊ុំ សុផាវី (Sum Sophavy), អ្នកគ្រូ ថន ថូ (Than Tho), លោក គឹម ដារា (Kim Dara) ។

ព្រះសង្ឃ, អ្នកគ្រូ លោកគ្រូ ចូលរួមសិក្ខាសាលា នៅសៀមរាប៖ ព្រះតេជគុណ អ៊ី ណុល (Ey Nol), ព្រះតេជគុណ ឡម លឿម (Lam Loeurm), ព្រះតេជគុណ ឯក សុថេរា, (Ek Sothera), អ្នកស្រី ឈិត សុខសាន្ត (Chhit Soksan), លោក ជួប សំអុល (Chuop Sam Ol), លោក ហ៊ី សម្បត្តិ (Hy Sambath), លោក ដែន ពេញ (Den Penh), លោក ច័ន្ទ សុភា (Chan Sophea), លោក គី ពៅ (Ky Pov), លោក សៀង គង់ (Seang Kong), លោក តាន់ សុថន (Tan Sothorn), លោក ស៊ីម ពៅ (Sim Pov), លោក ញ៉ឹក អារុណ (Nheuk Arun), លោក ឃុត សុខខឿន (Khuth Sok Kheun), អ្នកគ្រូ ឡាច ឡាលីន (Lach Lalin), លោក ធួន ពុទ្ធ (Puth Thuon)។

អ្នកបកប្រែ៖ លោក សុខ លាំង (Sok Leang), លោក ជិន ចន្នា (Chin Channa), លោកបណ្ឌិត តាន់ ផល្គុណ (Dr. Phalkun Tan) លោក សំរិទ្ធី ដួងហាក់ (Sam Rithy Duong Hak)។

រចនា ដោយ អ្នកនាង សុង រ៉ានី (Song Rany), និង លោក ហុក គឹមអៀង (Hok Kim Eang) រោងពុម្ព អន្តរជាតិ (International Printing House)។

ហើយជូនជាពិសេស ដល់បុគ្គលិក ស៊ីវីកហ្គ័សកម្ពុជា, អ្នកនាង ឡុង សុជាតា (Long Socheata), អ្នកនាង ហុក ស៊ីវហ័ង (Hok Sivhoing), អ្នកនាង ប៊ន ស៊ីថា (Born Sitha) និង លោក ប៊ុន ច័ន្ទធារ៉ា (BUN Chantheara)។

លោកស្រី យែរី ខិណ្ឌិឌី, ប្រធាន មជ្ឈមណ្ឌល រ៉ូបឺត អ៊ែហ្វ ខិណ្ឌិឌី ដើម្បីយុត្តិធម៌ និង សិទ្ធិមនុស្ស, ដោយមានកតញ្ញូតាដឹងគុណទទួលស្គាល់ជាឯកត្តជន ដែលបានផ្តល់វិភាគទានដ៏សំខាន់ ក្នុងការនាំមកនូវ ផលប្រយោជន៍ “សេចក្ដីក្លាហានគ្មានព្រំដែន”។

ជាពិសេស បុគ្គលិក មជ្ឈមណ្ឌល រ៉ូបឺត អ៊ែហ្វ ខិណ្ឌិឌី ដើម្បីយុត្តិធម៌ និង សិទ្ធិមនុស្ស៖ ការ៉េន រ៉ូប៊ីនសិន ខ្លូត (Karen Robinson Cloete), វ៉ាលិនធីណា ពែកលីអ៊ែ (Valentina Pagliai) (នៅទ្វីបអឺរ៉ុប), ចន ហេហ្វើនិន (John Heffernan), លីន ដេឡានី (Lynn Delaney) និង អ៊ែនឌ្រូ ហ្គ្រាបឺ (Andrew Graber)។

អ្នករចនាភាសាអង់គ្លេស៖ ជេនីហ្វឺ កាកាឡេតទ្រីស (Jennifer Kakaletris)។

យើងខ្ញុំ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ជូនដល់ ស្ថាប័នផ្តល់ជំនួយ គឺជាមូលនិធិសប្បុរសធម៌ (The Charitable Foundation) តាមរយៈក្រុមអភិវឌ្ឍសកល (Global Development Group)។

THE CHARITABLE FOUNDATION

Global Development Group



នៅវត្តអារញ្ញ ក្នុងខេត្តកំពង់ឆ្នាំង, ថ្ងៃទី៩ ខែតុលា ឆ្នាំ២០១១

Copyright ©2011 by Robert F. Kennedy Center for Justice and Human Rights and CIVICUS Cambodia.
All rights reserved.
Essay copyright ©2010 Kerry Kennedy. All rights reserved.
Essays and play copyright © 2008 by Ariel Dorfman. All rights reserved.
Photographs of the defenders copyright © 2000 by Eddie Adams, All rights reserved.
All photographs courtesy of and copyright to the individual photographers
unless otherwise noted.

Speak Truth To Power
Director, John Heffernan
Robert F. Kennedy Center for Justice and Human Rights,
1367 Connecticut Ave, N.W., Suite 200
Washington, D.C. 20036
Tel: 202.463.7575
Fax: 202.463.6606
www.RFKCenter.org

គម្រោង *សេចក្តីក្លាហានគ្មានព្រំដែន*
សេង ធារី, ប្រធានស្ថាបនិក ស៊ីវីកហ្គ័សកម្ពុជា
ស៊ីវីកហ្គ័ស៖ មជ្ឈមណ្ឌលអប់រំដើម្បីពលរដ្ឋខ្មែរ
វីឡា២២បេ, ផ្លូវ៣០២, សង្កាត់បឹងកេងកង១, ភ្នំពេញ
ទូរស័ព្ទ៖ (៨៥៥)-២៣.២១៦.២០៤
www.civicus-cam.org



Eddie Adams (1933 – 2004), Winner of a Pulitzer Prize and recipient of more than five hundred international, national, and local awards. Adams encompassed the fields of journalism, corporate, editorial, fashion, entertainment, and advertising photography. His most notable assignment was in Vietnam, where he accompanied both American and Vietnamese troops in over 150 operations. It was there, in 1968, that Adams captured the indelible image of Vietnamese General Nguyen Ngoc Loan executing a Viet Cong lieutenant at point-blank range. Adams was awarded the Pulitzer Prize for this photograph in 1969. Adams was associated with the Associated Press and Time magazine and served as a Special Correspondent for Parade Magazine for twenty years.

“អ្នកខ្លះ សម្លឹងមើលទៅ
ពិភពលោក នៃបច្ចុប្បន្ននេះ
ហើយសួរថា, ចុះមូលហេតុអ្វី?
ខ្ញុំវិញ សម្លឹងមើលទៅ
ពិភពលោក ដែលអាច
ហើយសួរថា,
ចុះមូលហេតុអ្វីមិនអាច?”

— រ៉ូបឺត អ៊ែហ្វ ខេណ្ណឌី

ROBERT F. KENNEDY

# ប្រតិកិរិយា / ទម្រង់ព័ត៌មានត្រលប់ (Feedback)

## សូមបំពេញ ហើយបញ្ជូនទៅតាម៖

ស៊ីវីកហ្គ័ស៖ មជ្ឈមណ្ឌលអប់រំដើម្បីពលរដ្ឋខ្មែរ (CIVICUS: Center for Cambodian Civic Education)
វីឡា ២២បេ, ផ្លូវ៣០២ បឹងកេងកង១, ភ្នំពេញ ឬ
សមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យ ( សាខាតាម ខេត្ត ឬ ទីស្នាក់ការនៅភ្នំពេញ )

## កម្រិតអាយុនៃអ្នកសិក្សា៖

១. តើអ្នកប្រើប្រាស់សម្ភារៈនេះ ស្ថិតនៅក្នុងស្ថានភាពអប់រំប្រភេទណា ?
សូមគូសយកតែមួយ៖

□ វិទ្យាល័យ □ សាកលវិទ្យាល័យ/មហាវិទ្យាល័យ □ ក្រុមសហគមន៍ □ សាលាឯកជន
□ មធ្យមសិក្សា □ បឋមសិក្សា □ ក្រុមសាសនា

២. តើអ្នកបានដឹងឮអំពី គម្រោង *សេចក្តីក្លាហានគ្មានព្រំដែន* (Speak Truth To Power) តាមរយៈនរណា ឬ ដោយរបៀបណា ?
សូមគូសយកតែមួយ៖

□ គេហទំព័រ www.civicus-cam.org □ មិត្តភក្តិ □ សហការី □ សន្និសីទ ឬ សិក្ខាសាលា
□ សមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យ □ បណ្តាញសារព័ត៌មាន

៣. មុនកម្មវិធីសិក្សា *សេចក្តីក្លាហានគ្មានព្រំដែន* នេះ, តើអ្នកធ្លាប់បង្រៀនអំពីសិទ្ធិមនុស្សដែរឬទេ ?
សូមគូសយកតែមួយ៖ □ បាទ/ចាស □ ទេ

៤. តើអ្នកបានរកឃើញអ្វីខ្លះ ជាអត្ថប្រយោជន៍ / ផលប្រយោជន៍ ច្រើនបំផុត អំពីកម្មវិធីសិក្សា *សេចក្តីក្លាហានគ្មានព្រំដែន* នេះ ?

______________________________

______________________________

៥. តើអ្នកបានរកឃើញអ្វីខ្លះ ជាអត្ថប្រយោជន៍ / ផលប្រយោជន៍ តិចបំផុត អំពី កម្មវិធីសិក្សា *សេចក្តីក្លាហានគ្មានព្រំដែន* នេះ ?

______________________________

______________________________

៦. តើផ្នែកណាមួយ ក្នុង កម្មវិធីសិក្សា *សេចក្តីក្លាហានគ្មានព្រំដែន* នេះ ដែលមានការចាប់អារម្មណ៍ច្រើន ពីសិស្សនិស្សិត ?

______________________________

______________________________

៧. តើអ្នក បានបង្រៀន កម្មវិធីសិក្សា *សេចក្តីក្លាហានគ្មានព្រំដែន* នេះ ទាំងស្រុង ? □
ឬ អ្នកបានបង្រៀន ដោយស្រង់ផ្នែកខ្លះៗ ពីកម្មវិធីសិក្សា *សេចក្តីក្លាហានគ្មានព្រំដែន* នេះ ? □

៨. តើអ្នកចាប់អារម្មណ៍អំពី កម្មវិធីផ្សេងៗ នៃ *សេចក្តីក្លាហានគ្មានព្រំដែន* ដូចជា ការបណ្តុះបណ្តាលអំពីគម្រោងសិក្សានេះ, ការរៀបចំការដាក់តាំងពិព័រណ៍រូបថត, ផលិតកម្មសម្តែងបែបនាដកម្ម សម្លេងចេញពីទឹងងឹត ?
សូមគូសយកតែមួយ៖ □ បាទ/ចាស □ ទេ

៩. សូមផ្តល់យោបល់ / ព័ត៌មានបន្ថែមអំពី កម្មវិធីសិក្សា *សេចក្តីក្លាហានគ្មានព្រំដែន* នេះ។

______________________________

______________________________

“អ្នកមិនត្រូវបាត់បង់ជំនឿលើមនុស្សជាតិទេ។មនុស្សជាតិគឺជាសមុទ្រមួយ។ប្រសិនបើទឹកពីរបីដំណក់ក្នុងសមុទ្រមានភាពកខ្វក់, វាមិនមានន័យថា សមុទ្រនោះ មានភាពកខ្វក់ផងដែរទេ”។ លោក មហាម៉ាត់ គន្ធី MOHANDAS GANDHI. “ចូរសួរខ្លួនអ្នកថា តើអ្នកអាចធ្វើអ្វីខ្លះ ដើម្បីឲ្យមានការផ្លាស់ប្តូរ។ បន្ទាប់មកចូរចាត់វិធានការ, ទោះជាមានទំហំ តូច ឬ ធំក៏ដោយ”។ លោកស្រី ក្រាសា ម៉ាគែល-មែនដឺឡា GRACA MACHEL-MANDELA. “យើងត្រូវតែ... ទទូចសុំឲ្យមានការស្របមតិជាសកល, មិនត្រឹមតែ លើតម្រូវការក្នុងការគោរពសិទ្ធិមនុស្សពាសពេញពិភពលោក ប៉ុណ្ណោះទេ, ប៉ុន្តែ ថែមទាំងនិយមន័យ នៃសិទ្ធិទាំងអស់នេះទៀតផង... ពីព្រោះ សិទ្ធិមនុស្ស គឺជាលក្ខណៈធម្មជាតិ របស់មនុស្សគ្រប់រូប ក្នុងបំណងប្រាថ្នាចង់បានសេរីភាព, សមភាព និង សេចក្តីថ្លៃថ្នូរ, ហើយពួកគេផងដែរ មានសិទ្ធិស្មើភាពគ្នា ក្នុងការសម្រេចបាននូវបំណងនោះ”។ ព្រះតេជគុណ ដាឡៃ ឡាម៉ា THE DALAI LAMA. “បុគ្គលម្នាក់ អាចធ្វើឲ្យមានការផ្លាស់ប្តូរ, ហើយផងដែរ យើងម្នាក់ៗ គួរតែព្យាយាម”។ លោក រ៉ូបឺត អ៊ែហ្វ ខិណ្ណិឌី ROBERT F. KENNEDY. “នេះគឺជាភារកិច្ចរបស់ជំនាន់យើង ខណៈដែល យើងឆ្ពោះទៅក្នុងសតវត្សរ៍ទី២១, គឺជា សាមគ្គីភាពជាមួយ មនុស្សទន់ខ្សោយ, មនុស្សគេគាបសង្កត់, មនុស្សកំសត់ឯកោ, មនុស្សមានជម្ងឺ, និង មនុស្សដែលអស់សង្ឃឹម។ យើងបង្ហាញភារកិច្ចបែបនេះ ដោយសេចក្តីប្រាថ្នា ក្នុងការផ្តល់និយមន័យ ថ្លៃថ្នូរ និង មនុស្សធម៌ ដល់សហគមន៍មួយ ដែលសមាជិកទាំងអស់នឹងកំណត់តាមខ្លួនពួកគេផ្ទាល់ ដោយអត្តសញ្ញាណរបស់អ្នកដទៃ មិនមែនដោយអត្តសញ្ញាណផ្ទាល់ខ្លួនរបស់ពួកគេទេ”។ លោក អ៊ីលី វីសែល ELIE WIESEL. “ខ្ញុំបានដើរផ្លូវវែងឆ្ងាយទៅសេរីភាព។ ខ្ញុំបានព្យាយាមមិនឲ្យជំពប់។ ខ្ញុំបានភ្លាត់ជើងនៅតាមផ្លូវ។ ប៉ុន្តែ ខ្ញុំបានយល់អំពីភាពអាថ៌កំបាំងមួយថា៖ បន្ទាប់ពីបានឡើងលើភ្នំធំមួយ, អ្នកឃើញថា មានភ្នំផ្សេងៗទៀត ដែលអ្នកត្រូវដើរឡើង។ ខ្ញុំបានយកពេលខ្លីនៅទីនេះ ដើម្បីឈប់សម្រាក, ដើម្បីលួចមើលទស្សនីយភាព ដ៏ល្អត្រកាលនៅជុំវិញខ្ញុំ, ដើម្បីងាកមើលចម្ងាយ ដែលខ្ញុំបានឆ្លងកាត់នោះ។ ប៉ុន្តែ ខ្ញុំអាចឈប់សម្រាកត្រឹមតែរយៈពេលខ្លីប៉ុណ្ណោះ, ពីព្រោះ ភ្ជាប់ជាមួយសេរីភាព គឺជា ការទទួលខុសត្រូវ, ហើយ ខ្ញុំមិនហ៊ានបង្អែបង្អង់ ពីព្រោះ ការធ្វើដំណើរដ៏វែងឆ្ងាយរបស់ខ្ញុំ គឺមិនទាន់បញ្ចប់នៅឡើយទេ”។ លោក ណែលសិន ម៉ែនដេលា NELSON MANDELA.

CIVICUS

THE CHARITABLE FOUNDATION

ROBERT F. KENNEDY
CENTER FOR JUSTICE & HUMAN RIGHTS